កម្ពុជសុរិយា

ត្រូវបានដាក់ចូលមន្ទីរបណ្ណាល័យ
COMMISSION DES MŒURS & COUTUMES

រស្មីនៃវប្បធម៌ ផ្សាយដោយគណៈកម្មាធិការ ដែលត្រូវបានបង្កើតឡើង
ដើម្បីសិក្សាស្រាវជ្រាវអំពីពុទ្ធសាសនៃបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក កាំយ-ប៊ុក ក្រមការ
នៅពុទ្ធសាសនៃបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះអនុសង្គា . ស្ងួ - ហ្គាយ
ក្រុមដំណុំព្រះត្រៃបិដក នៅពុទ្ធសាសនៃបណ្ឌិត្យ

មាតិកា

ផ្នែកអក្សរសាស្ត្រ		ទំព័រ
ពុទ្ធសាសនៃបណ្ឌិត្យ	ដួងពរសំគាល់សាធុការឆ្នាំថ្មី	១
	សេចក្តីដួងដំណឹងអំពីពុទ្ធសាសនៃបណ្ឌិត្យ រៀងទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំ ១៩៥០	២
១.ព.ក កាំយ-ប៊ុក ក្រមការ	ប្បាប់ទូន្មានពុទ្ធបរិស័ទ កុមារី	៥
ន្ត្រី ញ៉ាក - ថែន	ការងារដោយចង្វាយញ៉ាំងលោកឲ្យចំរើន	១១
រីភ័ស្ដ៍ ឈឹម - ណាត	រឿងក្មេងតំក្រែ (រឿងព្រៃង)	២៨
ង - សាភិត		
ព្រសួងហិរញ្ញវត្ថុ	រឿងព្រៃងភូមា	៣៩
មនា		
លោក ម៉ុញ-តាំត្រី តំណាងអាស្រ្ត	ពុទ្ធសាសនានឹងការហិរសាសនា.....	៤៣
ហ្វូងខែតខ្ទមន្ត្រី ញ៉ាក-ថែន	ដំណឹងពុទ្ធសាសនាក្នុងទាងប្រទេស	៧២

ឆ្នាំទី ២២ — លេខ ១ ខែមករា ឆ្នាំ ១៩៥០ — ដំឡៃដាក់ ១ ឆ្នាំ ១៤៥ រៀល ។

ជូនសព្វសាធុការពរកុងឱកាសចូលឆ្នាំថ្មី

១៩៥០

ឆ្នាំមួយតាន់ប្រាំបួនរយហាសិបគត់
សូមរលត់ទុក្ខរលាយនូវសោកភ័យ
សូមព្រះប្រិយមហាក្សត្រិយ៍ក្សាន្តទ្រង់ទ័យ
គ្រងរាជ្យប្តៃបានយូរកាលអនាគត ។
សូមរាជរដ្ឋាភិបាលជាតិខេមរា
បានសុខាប្រសើរក្រៃចម្រើនធំធាត
សូមរាស្ត្រខ្មែរកបស្ងួស្តីយរាល់ធាវ៉ាធ្លុត
ស្រួលប្រកបតាមវិសនាកាំកង់លោក ។

ពុទ្ធសាសនបណ្ឌិត្យ

រឿងទស្សនាវដ្តីកម្ពុជសុរិយា

សូមជំរាបជូនដំណឹងដល់បងប្អូនរួមជាតិទាំងឡាយ

កាលពីឆ្នាំ ១៩៤៩ ដែលកន្លងមកនេះ ទស្សនាវដ្តីកម្ពុជសុរិយា មិនអាចចេញផ្សាយតាមកំណត់រៀងរាល់ខែនោះ ដោយហេតុពោធិ៍ពុម្ព មានអក្សរតិចមិនគ្រប់គ្រាន់នឹងប្រើការចុះពុម្ពរឿងផ្សេង ។ ល ។ ប៉ុន្តែចូលមកក្នុងឆ្នាំ ១៩៥០ នេះ ពោធិ៍ពុម្ពព្រះរាជទ្រព្យបានទទួលអក្សរថ្មីៗ មកទៀតជាចំនួនច្រើន ល្មមប្រើការចុះពុម្ពទួទៅបានសព្វគ្រប់ ទើបយើងមានសេចក្តីសង្ឃឹមថា កម្ពុជសុរិយា សម្រាប់ឆ្នាំ ១៩៤៩ ពោធិ៍ពុម្ពបានខំប្រឹងប្រែងចុះពុម្ពទស្សនាវដ្តីនេះ ឲ្យបានគ្រប់ចំនួនដល់លេខ ១២ នៅចុងខែ មករា ឬខែ កុម្ភៈឆ្នាំ ១៩៥០ នេះមិនខាន ហើយនឹងព្យាយាមចុះកម្ពុជសុរិយា ឆ្នាំ ១៩៥០ តទៅទៀត លែលកឲ្យបានទាន់ពេលវេលា គង់មិនយឺតយូរដូចឆ្នាំមុនៗ នេះទេ អាចចេញផ្សាយតាមកំណត់រៀងរាល់ខែ (១ខែ ១ សៀវភៅ) ។

ឯរឿងរ៉ាវដែលមានសារប្រយោជន៍ដល់បងប្អូនរួមជាតិ ទាំងខាងផ្នែកអក្សរសាស្ត្រ ទាំងខាងផ្នែកសាសនា ដូចមានកម្មវិធីដោយសង្ខេបតទៅនេះ ។

ផ្នែកអក្សរសាស្ត្រ

១ — អក្សរសាស្ត្រខ្មែរ (គោលបាំងផ្នែកអក្សរសាស្ត្រខ្មែរ ត្រមាំងពាក្យកាព្យឃ្លោងចាស់ៗ ប៉ុន្តែនើបថ្មីរបស់អ្នកនិពន្ធដែលមានក្តីឈ្មោះក្នុងសតវត្សរ៍ផ្សេងៗ)

២ — ព្រះពុទ្ធសាសនាប្រវត្តិសាស្ត្រកម្ពុជា ទៅមានចោះពុម្ពផ្សាយតទៅទៀត ។

៣ — ប្រវត្តិសាស្ត្រសាកល (បើចប់ប្រវត្តិសាស្ត្រឥណ្ឌាហើយនឹងចោះពុម្ពផ្សាយប្រវត្តិសាស្ត្របស់ជាតិដទៃៗ តទៅទៀត) ។

៤ — រឿងសាមកុក ទៅតែចោះពុម្ពតៗ ទៅទៀត ត្រាតែចប់ ។

៥ — គោគកុលកុមារ ពាក្យកាព្យរបស់អ្នកឧកញ៉ាព្រះឃ្លាំងនន ទៅតែចោះពុម្ពផ្សាយតទៅទៀតត្រាតែចប់ ។

៦ — សុភាសិតផ្សេងៗ របស់នានាជាតិ ។

៧ — រឿងព្រេងខ្មែរ ឬរឿងព្រេងរបស់ជាតិដទៃ ។

៨ — រឿងទំនៀមទម្លាប់ខ្មែរ របស់ក្រុមជំនុំទំនៀមទម្លាប់ ។ល។

ផ្នែកសាសនា

១ — ដំណឹងផ្សេងៗ ក្នុងព្រះពុទ្ធសាសនា ។

២ — ធម្មទេសនា ដែលមានសារប្រយោជន៍ដល់ពុទ្ធសាសនិជនតាំងឡាយ ។

៣- ប្រតិបត្តិបអាស៊ីនៅតែបោះពុម្ពផ្សាយតទៅទៀតគ្រាតែចប់ ។

៤ - សីលធម៌របស់ពុទ្ធសាសនា

៥ - និងជ្រើសប្រើរឿង ព្រះសូត្រខ្លះ ក្នុងសុត្តន្តបិដក ដែលមានសារប្រយោជន៍ខាងផ្លូវប្រតិបត្តិរបស់ពុទ្ធសាសនិកជន ។ល។

ពុទ្ធសាសនបណ្ឌិត្យ សូមជំរាបបញ្ជាក់ថែមទៀតថា ភាសានិងអក្សរជាតិគឺជាឧបករណ៍សំខាន់បំផុតរបស់ជាតិក្នុងសម័យបច្ចុប្បន្ននេះ ។ ប្រទេសជាតិដែលចំរើនរុងរឿងឡើង ក៏ដោយសារប្រទេសក្នុងលោកសឹងមានមូលមកពីភាសានិងអក្សរជាតិ ដែលទុកជូចជាកូនសោសម្រាប់ទៅយកសេចក្តីចំរើនគ្រប់ផ្លូវតាមត្រូវការ ។

ហេតុនេះ ពុទ្ធសាសនបណ្ឌិត្យ សូមប្រកាសជូនដំណឹងដល់អស់លោក អ្នកទាំងឡាយ ដែលមានបំណងល្អ ចង់ពង្រីកនិងជួយទំនុកបំរុងអក្សរសាស្ត្រខ្មែរឲ្យបានចំរើនលូតលាស់ឡើងទាន់សម័យ សូមធ្វើចុះឈ្មោះជាវទស្សនាវដ្តីកម្ពុជសុរិយា នៃពុទ្ធសាសនបណ្ឌិត្យក្នុងពេលឆាប់ៗនេះ ។ ពុទ្ធសាសនបណ្ឌិត្យ សូមអរគុណអស់លោកទុកជាមុន ។

របៀបជាវ : ត្រូវធ្វើឈ្មោះ - ទីលំនៅ និងប្រាប់ទៅអគ្គលេខាធិការក្រុមពុទ្ធសាសនបណ្ឌិត្យ - ភ្នំពេញ ឯតម្លៃជាវប្រចាំឆ្នាំ ១៩៥០ នេះ ១ ឆ្នាំ ១៤៥ រៀល (នេះគិតតែតឹមថ្លៃបោះពុម្ពប៉ុណ្ណោះ) ។

ពុទ្ធសាសនបណ្ឌិត្យ - ភ្នំពេញ ថ្ងៃ ២៣ ដេសេមប្រ៊ែ ១៩៦៩ ។

Adresse:
M. le Secrétaire Général de l'Institut Bouddhique
à Phnom-Penh

សេចក្តីរំឭកជាសំគ្រើនកុមារ - កុមារី

លោកតាយ - ប៊ុតគ្រមការ រៀបរៀងជាពាក្យកាព្យ

ជាតិចំរើនដោយអក្សរសាស្ត្រ មានបទបែបល្បះតាមមាត្រា
សារសោតាមជនជាតិទុសអក្ខរ ប្រើខាងភជការមេយចុះអ័ក្ខ ។
បែបលោកភូមីគត្រស្រុកខេត្តខ័ណ្ឌ បែបខ្លួនគួបគ្រាន់ក្បួនប្រាវឮ
បែបច្បាប់វិទ្យាទាំងថែយប់ ទើបប្រទេសជម្មហាសុរិល័យ ។
បណ្ឌិតបូរាណគ្រូអាចារ្យ មាសពេជរចនាគ្មិបពៃ
គួរគិតអប់រំជាតិនិស្ស័យ ឲ្យបានថ្លាថ្លែអនាគត ។
ព្យាយាមប្រមូលបណ្ឌិតប្រាជ្ញ, ខំយកសុភាចអវិជ្ជាពត់
សតវត្សៈដប់ប្រាំបួនកត់ ធីរៈបែវត្តិក្បួនសៀវភៅ ។
អក្សរសាស្ត្រអតីតលំបាកស្រាវ បូរាណខំជ្រាវមិនយល់ផ្លូវ
សម័យវ័ន្ធអង្គរនៅ សិលាចារឹកជ្រៅជ្រៃតមិនជ្រាប ។
ថែមមានសង្គ្រាមចលាចល កម្ពុជាសុភលក្ខ័ណ្ឌល់ជាប
ជាតិខ្មែរបានដល់ទុព្វលភាព អក្សរសាស្ត្រពុភាគមិនយល់ ។
គួរគិតបកបែបសៀវភៅរៀន ចំណេះរបៀនគ្រែមណ្ឌល
វិទ្យាគ្រប់បែបលោកដំកល់ ជំរើងជាតិដល់ផលចំរើន ។
ទេមកប្រុសស្រីចំរៀនសូត្រ សោយអាហារលូតលាស់គ្រើន
ដំរេះចេះចាំប្រាជ្ញជាស់តឿន នាំគ្នាត្រាច់លឿនលាងមន្ទិល ។

ពូជទុស្សាហ៍ស្វាន់សែនអាត្មាបាន ធ្វើជាតិកល្យាណជាងពូជខ្ចិល
ទាបថោកវង្សត្រកូលពាលខូចវិល ម្តេចកម្មជារំកិលទាន់សម័យ ។
មនុស្សម្នាក់ពុំអាចសម្រេចការ ត្រូវធ្វើសាមគ្គាពលប្រស័យ
ប្រុសស្រីក្មេងចាស់ជួយរឹនិច្ចយ ទើបឆ្នៃបានឈ្នះពីហឺនជាតិ ។
ធម្មតាសិលាអស្រ័យដែក ញែកក្តើងចំបែកធ្វើចេញជាតុ
មនុស្សត្រូវពឹងមនុស្សប្រាជ្ញទាន់ទេ សប្បុរសជាខ្លាតទើបពកខ្នែង ។
គួរអប់រំកាព្យឃ្លោងបាទកវី បទបែបពេញទីភ្លឺស្វាន់សែង
ពាក្យពេចន៍ឃ្លោងឃ្លានិពន្ធតែង ឲ្យចេញក្តើងផ្សែងផ្សព្វលោកា ។
រុក្ខជាតិព្រឹក្សាត្រៃតាប់មកភ្លាម កុំក្តេចឈួសនាមចាំងបន្ទារ
គួសបន្ទាត់ជាប់តែតាមប្រាថ្នា ធ្វើត្រឿងពូសម្ភារគ្រឹះហាបាន ។
ព្យាយាមដំដែកសព្វទិវា កើតជាងរចនាប៉ូវថៅថ្កាន
ប្រទេសថ្កើងប្រុសស្រីព្យាយាមប្រាណ ប្រឹងប្រែងយកឋានសោភ័ណ
គព ។

គួរឰនវិទ្យាសាស្ត្រសម័យ កាយវិភាគប្រស័យចិត្តប្រាព្ធ
មនុស្សព្រឹក្សចិត្តសាស្ត្រចាកយប់ យោងជាតិប្រសប់ចម្រើនយស ។
យក់សត្វគមរាជាទុបម័យ ធ្វើជាតិឲ្យថ្លៃសោភ័ណខ្ពស់
ជញ្ជាំបយកគេសរគន្ធរស រុករកស្វែងសូរធ្វើសំបុក ។
កុំត្រាប់កង្កែបតុម្ពុឈូកនៅ ត្រាប់កន្ធំដៅផុតពីកលីយុគ
នៅឆ្ងាយហើរឈមដង្រែដ៏មុខ មកត្រែបរសសុខបានសួស្តី ។

កុំគ្រាប់មេអំបៅគ្រាច់សប្បាយ　　មិនយល់ខ្វឹមស្រាយធម៌វិន័យ
ត្រូវយកទៅចាចង់និស្ស័យ　　លលកបច្ច័យផ្ទៃលុំទ្រូងឆ ។
វិញ្ញាសាស្តែអប់រំយូរកាល　　កបចេះគ្មីចាលយល់ត្រៃកង
រកយ្នាបប្រាជ្ញាផុតលិចលង់　　ខ្ទើងចាកកក់ផុងកើតប្រាជ្ញប្រាយ ។
ធម្មតាគ្រាប់ឈើកង់ប្រថព្វី　　ចំរើរកវីញ្ញកកកាយ
យល់សែងសុរិយាក្នាពីនាយ　　ទើបផ្សាយដើមដងដុះជាលខ្ទើង ។
ដើមដូងស្រូបយកទឹកល្អកក្រៃ　　គ្រាច់ជាក់ឈមត្រង់មិនត្រងើយ
កងរលាសាច់ផ្ទៃមិនខ្ចាចខ្លើយ　　ប្រែទឹកផ្អែមហើយហូរត្រជាក់ ។
គួរវៀនប្រវត្តិសាស្តែទេមក　　ឲ្យជាតិចៃថ្ងាប្រាថ្នាស្ម័គ្រ
គោកធ្លកព្រះថោងចិនឡាថ្នាក់　　មហារាជព្រាហ្មណ៍ជាក់វង្សវ្រែន ។
សម័យហូណង់ស្តេចអង្គរ　　ប្រាសាទបវរល្អក្តើងថ្កាន
តោរតោសតេញដែនដីទំព្វូស្ថាន　　នានាប្រទេសបានបបូខ្ចាច ។
ពូជតាត្រសក់ផ្អែមគួរផ្លែកនឹក　　កម្ពុជាគោកទឹកមហាអំណាច
មហារាជដុង្កែកំតេញអាច　　ចូលក្តើងមមាចនិន្ទ្រាលក់ ។
ប្រវត្តិសាស្តែនាំស្នេហាជាតិ　　ព្យាយាមសង្វាតកុំងោកងក់
ក្មេងចាស់សព្វរលឿនទៅមុខ　　ញ៉ាំងក្លាហានខ្ពុកមរដកក្តុំ ។
បើបានជាបាបលោកគុត្តរ　　បើស្តែងបុណ្យល្អនិព្វានេ
បើខ្ទើងតំរកុំរិះរេ　　ព្យាយាមគ្នាន់គ្នេរកំពូលលើ ។

បើបានឆ្លើយស្រែចតតាត់ស្រែច　　បើប្រែកលកិច្ចកុំស្អាក់ស្ទើរ
បើចង់សួយជាតិឲ្យទំដើរ　　ដំណើរខ្មៀយហត់ខ្លួកកុំគិត ។
បើចង់បានតេជៈទំកកាយ　　បើចង់ក្លីសាយចូលឆ័ត
បើចង់បានសុខឲ្យហាត់ចិត្ត　　សាមគ្គីមូលមិត្តជាតិផុតមារ ។
បើធ្វើកិច្ចការបរាជ័យ　　ប្រឹងទាំងដើងដៃរង៉ាំក្លា
ចាត់ធ្វើម្តងខ្មៀតមនោក្រៀវក្លា　　គង់សម្រេចប្រាថ្នាប្រយោជន៍ធំ ។
តូជនារក្លាហានអប់រំក្មេង　　រុក្ខាព័ទ្ធពែងពីខ្លុំសំ
ចង់បានប្រាជ្ញាឲ្យទំដំ　　ញយ។ ប្រដុំផលញឹកញាប់ ។
គួរវៀនចេះចាំលេខគនិត　　នព្វន្តគួរគិតយល់សព្វគ្រប់
ចេះក្រែលបានគ្រាន់ប្រាជ្ញប្រសប់　　ប្រសើរក្លៀកពពាក់ផុតភ័យ ។
ឃ្លាណាពោលចាក់ចាងឯក　　ខាងលេខជាគោតាមញាណញ្ញេយ្យ
ក្មេងចូរស្វាធ្យាយស្ទាង់និស្ស័យ　　ចាស់ហើយយប់ថ្ងៃកុំក្តេចប្រាណ ។
បើចំណេះជាប់ចេះបច្ចុប្បន្ន　　ផ្តិតចេះគយគន់កបច្រើនស្ថាន
ចេះអនាគតតាមលំអាន　　ប្រាសមនុស្សឲ្យបានហានសប្បុរស ។
ប្រទេសមានបុព្វបុរសនាំ　　ចែងទាំងាល់ឃើញដល់ត្រីយកោះ
កោរកែប្រែជាតិកោសគិតស្មោះ　　ទើបឆ្ពោះផ្លាស់សម័យលោកា ។
ធ្វើការត្រូវគ្រាប់អ្នកសូចត្រី　　ត្រូតនុយប្រស័យអប្បមាទា
សូង់មើលស្ថាបគិតកលប្រាជ្ញា　　ស្រែចម្ការញមប្ញាយកអាស្រ័យ ។

កុំឲ្យខុកចិត្តសត្វមនុស្សា លស្លុកលាតលាវិនិច្ឆ័យ
ចរិតមារយោទពាក្យបច្ច័យ ឲ្យយល់ថោកថ្លៃពាលបណ្ឌិត ។
គួរវៀនកូមិសាស្ត្រកម្ពុជា ភាពជាតិអាស្រ័យជការគិត
ចំនួនមនុស្សឈ្មោះក្រែងពិនិត្យ សេដ្ឋកិច្ចប្រព្រឹត្តទំនៀមស្រុក ។
ជាតិខ្មែរមិនស្គាល់កម្ពុជា ស្វាធ្យាយសាសនាតាមទំនុក
មិនដឹងពុទ្ធប្រវត្តិពូជកុក មិនស្គាល់ចឹងថ្កុកខែនំខ្ទួន ។
ស្គាល់ខ្លួន។ ឯងលំបាកផុត ស្គាល់ដៃតុខ្មែរបិនយួន
ស្គាល់តពលោកមេឃភាពច្បាប់ក្បួន ស្គាល់លោកធម៌សួនលំបាកប្លែក។
គួរវៀនចងចាំប្រាជ្ញមេធី ឲ្យស្គាល់ពេញទំមនុស្សសត្វញែក
តក្កវិទ្យាស្វាធ្យាយសែក សេពសំខែតមែកដើមចុសគល់ ។
ឆ្លៀសសង្ស័យនាំមានប្រាជ្ញ បើបានជាថាឲ្យមានផល
បើបានជាដើរខំឲ្យដល់ បើបានជាដល់កុំខ្ជាចស្ងាប់ ។
ទស្សាហ៍ព្យាយាមទើបបានចេះ ចង់ចេះឆលាងាំប្រាជ្ញ
ហេតុមនុស្សសត្វឆ្ងិតយប់ បចមកល្ប្រគែប់ស្គាប់មិនពុះ ។
កលោកទឹកដីព្រៃព្រឹក្សា កជាតិសាសនាយល់ស្គាក់ស្ទើរ
បើមានប្រាជ្ញព្រាវឲ្យចេះប្រើ ប្រាជ្ញាដំណើរនាមរូបធាតុ ។
បញ្ជាក្ខន្ធបំបែកញែកតាមការ ឲ្យស្គាល់រូបនាមាតាមក្បួនខ្នាត
ចក្រក់ឲ្យតូចធំខំសង្វាត លោកជាតុទុក់ឲ្យយល់ស្តែង ។

គួរវៀនវិទ្យាហោរាសាស្ត្រ តារាធ្វៀតធ្លុះទំប្រឹងប្រែង
ស្គាល់លេចរិតចរិយាផលកើតឆ្នែង មេឃផ្កាយសំដែងរាសីចន្ទ្រ ។
ចូរប្រុងស្រែដែនកម្ពុជា ស្រឡាញ់គ្រប់គ្នាវិទ្យាគាន់
លោកធម៌និស្ស័យឲ្យបានខាន់ សម័យលោកកាន់តបចេស្តា ។
ទើបហៅស្រឡាញ់មាតុភូមិ សាមគ្គីព្រៀងព្រមស្អាងវិទ្យា
ស្រឡាញ់ជាតិទឹកដីព្រៃព្រឹក្សា ស្រឡាញ់ពុទ្ធសាសនាបានថ្លាថ្លៃ ។
វិទ្យាជាប្រទីបផ្ទុះភ្លាជ្វា ឆ្លើជនខេមរាថ្កើងឃើញថ្ងៃ
វិទ្យាគប្បគុណល្អប្រពៃ ច្បាជ្ញបណ្ឌិតចរណៃដំកើងជាតិ ។
នារីរតនំបុរសអាជានេយ្យ ដឹកនាំប្រស័យខ្មែរឆ្ពៀវឆ្ពាត
ទើបធ្លុះសិរីត្រកូលញាតិ សូស្តីលោកជាតុល្យីអស្ចារ្យ ។
វិទ្យាជាបិតារចនាគ្រប់ រដ្ឋាភិបាលសព្វគាមហានា
សង្គមដុះដាលរៀបរាបជាការ នយោបាយខេមរាចំរើនសុខ ។
កែប្រែខ្មែរឲ្យបានគាល មានរស្មីភ្លឺច្បាលធុតពីទុក្ខ
កែទឹកដីសាសនាតាមទំនុក ជាតិចេញចាកកក់ពស់វិល័យ ។
កែមតិទិដ្ឋិជនជាតិបាន កែចរិយាឈានគ្រាច់យប់ថ្ងៃ
ចំរើនសោភ័ណធ្វើជលាល័យ នាវាសុវណ្ណដ័យដល់ត្រើយគ្រាន ។
កង់លោកវិលសព្វគ្រប់ទិវា ជនជាតិខេមរាវិលគ្រប់ច្បាណ
ប្រឹងប្រែងព្យាយាមកុំអាក់ខាន ដល់ស្ថានឯកភាវប្រជាធិបតេយ្យអើយ ។

ការងារជាមធ្យោបាយនាំឲ្យចំរើន

ហ្គ័ន ឌិត ន្ធូ មន្ត្រី ញ៉ុក - ថែម រៀបរៀង

មនុស្សយើងដែលកើតមកក្នុងលោកគ្រប់រូប ត្រូវតែធ្វើការងារ ដើម្បីចិញ្ចឹមជីវិតរៀងខ្លួន, យើងអាស្រ័យនៅក្នុងលោក មិនធ្វើកិច្ចការអ្វីមិនបានជាជាប់ខាត ព្រោះកិច្ចការរបស់មនុស្ស បើដូចជាតួចក្រុកធំយ៉ាងធំសម្បើមអស្ចារ្យ ដែលអាចធ្វើឲ្យមនុស្សលោកវិលទៅកាន់សេចក្តីចំរើនឥតអាក់ខាប់ចាប់តាំងពីសម័យបុរាណ ជាកបមកដល់សម័យបច្ចុប្បន្ន ។ មនុស្សសម័យបុរាណបានចាប់ផ្តើមធ្វើការតៗ គ្នាមកហើយ ពីរយៗពាន់ឆ្នាំ ទើបលោកយើងបានជុះជាលចំរើនដូចសម័យសព្វថ្ងៃនេះ ។

តាមដោយពិតកិច្ចការស្នាដៃរបស់មនុស្សទេតើ ដែលជាតួចក្រយ៉ាងសំខាន់ សម្រាប់ឯកជន ឬមហាជន ឬសង្គម ឬសម្រាប់ប្រទេសជាតិរហូតដល់ពិភពលោកទាំងមូល ដែលយើងអាស្រ័យនៅសព្វថ្ងៃនេះ ។ ហេតុនេះ ទើបយើងមើលឃើញជាក់ច្បាស់ថា ក្នុងលោកនេះ គ្មានមនុស្សនៅទំនេរទេ សុទ្ធតែមានការងារទៅតាមសភាពរៀងៗខ្លួន កាលយើងនៅតូចយើងក៏ធ្វើការផ្សេង ។ មានស៊ីផឹក, ដេក, ដើរ, ឈរ, អង្គុយ, យំ, សើច ។ល។ ដល់ចំរើនវ័យធំបន្តិចឡើង យើងក៏ធ្វើការសិក្សារៀនសូត្រ ហាត់លោត, ហាត់តៅ, ហាត់ហែលទឹក ។ល។ ដល់

មានអាយុគ្រប់នីតិភាព យើងត្រូវធ្វើការងារចិញ្ចឹមជីវិតអាត្មានឹងគ្រួសារ
ទៀត ។ ការធ្វើរបរចិញ្ចឹមជីវិតនឹងការគ្រប់គ្រងរក្សាគ្រួសារ ជាការ:
ប្រចាំរបស់មនុស្សគ្រប់រូបដោយពិត ។

ខ្លួរក្បាលនឹងសេចក្តីឈ្លាសវៃ ព្រមទាំងសេចក្តីព្យាយាមរបស់មនុស្ស
ទេតើ ដែលធ្វើឲ្យពិភពលោកដ៏ធំធូលាយមហិមានេះ សមជាទីស្នាក់នៅ
នៃមនុស្សលោក ។ សេចក្តីចំរើនដែលហៅថា អារ្យធម៌របស់លោកជា
ផលដែលបានមកពីខ្លួរក្បាលនឹងសេចក្តីប្រឹងប្រែងធ្វើការរបស់មនុស្សទាំង
អស់ ។ គ្រប់យ៉ាងក្នុងលោក តែងតែមានការប្រែប្រួលជានិច្ចគ្រប់ ។
នាទី ។ មនុស្សសម័យបុរាណ មានគំនិតចង់ហោះហើរដើរឆ្ងាន់លើ
អាកាស៍ដូចជាបក្សី ។ មានគំនិតគិតចង់បង្កើតយានដំនិះវិសេសផ្សេង ។
មកហើយ ដូចមានសេចក្តីដំណាលពីមនោភាពរបស់មនុស្ស ក្នុងសាស្ត្រ
ល្បែងនានា មានរឿងហាស្រយន្ត ឬកូនម៉ាល័យជាដើម ។

គំនិតគិតស្មានរបស់មនុស្សសម័យជាន់ដើម ក្រាយទៅជាការពិតឡើង
ក្នុងសម័យជាន់ក្រោយនេះ ដូចជាយានដំនិះយ៉ាងវិសេស ។ ទាំងខាង
ដើរដីទឹក ទាំងខាងដើរគោក ទាំងខាងអាកាស ដូចរថយន្ត, រថក្តឹង,
កប៉ាល់, យន្តហោះ សម្រាប់តែធ្វើញផ្លូវគមនាគមន៍ឲ្យខ្លីចុះ អាចទៅបាន
គ្រប់ទិសទីក្នុងលោក ។ ខាងការជួនដំណឹងគ្នាទៅវិញទៅមក ហាក់
ដូចជាយើងបានសម្រេចវិជ្ជាក្លែកពិភព ត្រឹមកពិភពខាន់ចិត្ត ដូចជូរស័ព្ទជូរ-

លេខនឹងវិទ្យុជាដើម ។ ផ្នែកខាងការរីកចម្រើនសាន្តចិត្តក្នុងវេលាត្រឹមតែ
វិញក៏មានភាពយន្ត (កុនស្រមោល) នឹងវិទ្យុភាពយន្ត ហើយមកក្នុង
សម័យបរមាណូនេះ វិជ្ជាការរបស់មនុស្សរឹងតែតែចំឡែកអស្ចារ្យណាស់
ទៅទៀត ដូចជាគ្រាប់បែកបរមាណូនឹងវត្ថុសព្វសារពើ ដែលធ្វើពីថ្នី
បរមាណូ សុទ្ធសឹងតែអស្ចារ្យណាស់ ។ ហើយអំណើរតទៅខាងមុខទៀត
អាចកើតរបស់អស្ចារ្យចំឡែកឡែកៗថ្មីៗទៀត ច្រើនលើសលន់គណនា
ដែលសម្រេចដោយបញ្ញានឹងស្មាដៃរបស់មនុស្សមិនខាន ។

ក្នុងចំណោមពួកអ្នកដញ្ជឹងរំពឹងគិតចង់រៀបចំ ពិភពលោកឲ្យបានចំរើនរុងរឿង ប្រកបដោយសេចក្តីសុខក្សេមក្សាន្ត បើពោលដោយភាគច្រើន គឺពួកអ្នកប្រាជ្ញវិទ្យាសាស្ត្រ ដែលបានចំប្រឹងកសាងសេចក្តីចំរើននឹងការស្រួលសប្បាយ ដល់មនុស្សជាតិផងគ្នា ។ មានបួនកាល លោកអ្នកនឹកស្មានថា គំនិតពួកអ្នកប្រាជ្ញវិទ្យាសាស្ត្រ ជាគំនិតឥតហេតុផលហួសវិស័យមនុស្សលោក តមកសម័យខាងក្រោយ ក្លាយទៅជាការពិតជាក់ស្តែងឡើង ពិភពលោកទើបប្រជាប់ប្រជាដោយរបស់ចំឡែកៗច្រើនជាអនេកប្រការ គួរឲ្យអស្ចារ្យណាស់ ដែលជាផលកើតឡើងដោយសតិបញ្ញានឹងស្មាដៃរបស់អ្នកប្រាជ្ញវិទ្យាសាស្ត្រដោយភាគច្រើនបំផុត ។

កាលបើយើងសំឡឹងមើលជុំវិញខ្លួនយើង ហើយសួរខ្លួនឯងថា នរ-ណាជាអ្នកកសាងវត្តផ្សេង ។ អស់ទាំងនុះឡើង អ្នកណាកសាងរថយន្ត, រថភ្លើង, ភ្លើងអគ្គិសនី, យន្តហោះជាដើម អ្នកណាជាអ្នកគិតផ្សំថ្នាំបំបាត់រោគនានា ; អ្នកណាជាអ្នកគិតប្រឌិតផលិតកម្ម អំពីវត្ថុតតជំរៃនានា ឲ្យទៅជារបស់មានប្រយោជន៍ គ្រាតែយើងមានគ្រឿងប្រើប្រាស់ប្លែកៗ ច្រើនជាអនេកអនន្ត ; យើងអាចតបដោយខ្លួនឯងថា ពួកអ្នកប្រាជ្ញវិទ្យា-សាស្ត្រអស់នោះហើយដែលបានប្រសិទ្ធិ នឹមិត្តវត្ថុអស់នោះឲ្យកើតឡើង ។ អ្នកប្រាជ្ញវិទ្យាសាស្ត្រទាំងឡាយ មិនបានប្រាថ្នាផលប្រយោជន៍ផ្ទាល់ខ្លួនប៉ុន្មានទេ ដោយយល់ឃើញហើយប្រគាន់ថា កាលបើកើតមកជាមនុស្ស ត្រូវតែបំពេញមុខក្រសួងរបស់មនុស្សគឺជួយគ្នាពួតដៃគ្នាគ្រប់គ្រងពិភពលោកឲ្យបានចំរើន ប្រកបដោយបកតិសុខយ៉ាងធំទូលាយ ។ ដោយហេតុពួកអ្នកប្រាជ្ញវិទ្យាសាស្ត្រ មានបំណងចំពោះផលចំរើនដោយរួបរួមគ្នានេះ ទើបយើងគួរចារឹកវិលឹកគុណ របស់បុគ្គលដែលធ្វើសារប្រយោជន៍ដល់លោកគ្រប់ខណៈ ។

ផលសម្រេច ដែលជួយសួយមនុស្ស ឲ្យមានកេរ្តិ៍ឈ្មោះនឹងកិត្តិយសល្បីល្បាញ ព្រមទាំងធ្វើឲ្យប្រទេសជាតិចំរើនរុងរឿងឡើង នេះនាំឲ្យយើងយល់ថា ផលសម្រេចជារបស់សំខាន់ក្រៃលែង ប៉ុន្តែការដែលនឹងញុំាងផលសម្រេចរបស់ខ្លួន ឲ្យបានដល់គោលបំណងនោះ លុះតែ

អាស្រ័យសមត្ថភាពក្នុងការងារជាគោលសំខាន់ ។ ដូច្នេះបុរសពាល់រូប អ្នកប្រាជ្ញវិទ្យាសាស្ត្រពាល់គ្នានឹងពួកអ្នកសិល្បករ ប៉ានខំព្យាយាមយ៉ាងម៉ឺងម៉ាត់ ដើម្បីញុំាងការដែលខ្លួនធ្វើនោះ ឲ្យប៉ានសម្រេចជារូបភាងឡើង ។

តាមធម្មតា មនុស្សយើងមានអំណាចមួយ ដែលធម្មជាតិប៉ានប្រគល់ឲ្យមក គាំងពីកំណើត គឺខួរក្បាល ។ មនុស្សដែលមានខួរក្បាលរមែងមានសតិបញ្ញាសម្រាប់ត្រិះរិះរកហេតុផល ចំពោះរបស់ដែលមានខៅជុំវិញខ្លួនយើង ព្រមទាំងគោលការសម្រាប់ពិចារណាព្រឹត្តិការណ៍ប៉ានជាក់ច្បាស់ ; ដំណើរនេះធ្វើឲ្យមនុស្សជាតិ មានការៈខ្ពង់ខ្ពស់ជាងសព្វសត្វទាំងឡាយយ៉ាងត្រដែតត្រដឹម ។ ផលសម្រេចគ្រប់ចំណែកដែលមានខៅក្នុងលោកនេះ កើតមកអំពីស្នាដៃរបស់មនុស្សទាំងអស់ចំណែកខាងសព្វសត្វទាំងឡាយ គ្រាន់តែជាគួដៃ ឬជាគ្រឿងឧបករណ៍មួយយ៉ាង ដែលមនុស្សប្រើប្រាជ្ញាឈ្លាសវៃរបស់ខ្លួន យកមកបង្ហាត់ប្រើការជាប្រយោជន៍ដល់មនុស្សផងគ្នា ។ មនុស្សជាតិនេះជាអ្នកគ្រប់គ្រងពិភពលោកមកហើយរាប់សែនរាប់លានឆ្នាំ ហើយនឹងតាំងខៅក្នុងលោកជារាបដល់លោកបែកធ្លាយទំលាយខៅវិញ ។ កាលបើយើងដឹងថា មនុស្សជាតិត្រូវប៉ានគ្រប់គ្រងលោកដូច្នេះ ទើបត្រូវតែយើងដែលជាមនុស្សគ្រប់ៗរូប ប្រើសមត្ថភាពក្នុងការគ្រប់គ្រងលោក ដោយការធ្វើឲ្យកើតសន្តិសុខព្រមទាំងអារ្យធម៌ថ្កុំថ្កលដល់លោក ប៉ានដល់ការធ្វើខ្លួនឲ្យមានប្រយោជន៍ដល់លោករួបរួមគ្នា ។

សេចក្តីសម្រេចគ្រប់យ៉ាង កើតមកពីគំនិតមានបំណងមុតមាំ ជាមូលដ្ឋានដ៏សំខាន់ ។ កាលពីមួយរយឆ្នាំមុននេះ ឬមុននោះទៀតទៅទៀត គ្មាននរណាគិតនឹកថា មនុស្សយើងអាចហោះហើរបាន ឬមានយន្តហោះអណ្តែតលឿនទៅក្នុងអាកាសបាន ជាយានយ៉ាងវិសេស មានសន្ទុះលឿនស្ទើគួរឲ្យអស្ចារ្យ ជាការពន្លឿនពេលវេលាមនុស្សជាតិយ៉ាងធ្ងាយណាស់ ដែលពីដើមត្រូវធ្វើដំណើរពាក់ខែឬឆ្នាំទើបទៅដល់ ឥឡូវទៅត្រឹមតែពាក់មោងឬពាក់ថ្ងៃប៉ុណ្ណោះ ។ ក្នុងទឹកមានកប៉ាល់ការណូតជាដើមប្រើជាយានយ៉ាងលឿនស្ទើមិនចាញ់ប្រើចែវចែក ថ្មោលឬក្តោង ។ លើគោកមានរថយន្តរថភ្លើង ប្រើបានរហ័សស្រួលសប្បាយជាអនេក ជាដំនួសរថសេះ ឬរទេះគោ ឬដំរី ។ ក្រៅអំពីនេះទៅមានគ្រឿងឧស្សាហកម្មផ្សេងៗទៀត ដូចជាឧស្សាហកម្មតម្បាញការដេរប៉ាក់ដោយយន្ត ពួកអ្នកគិតប្រឌិតវត្ថុអស់នេះដំបូងបំផុតនោះ ត្រូវនាំគ្នាសើចចំអកឲ្យកឲ្យឡើយ ហើយយល់ថា ជាគំនិតឆ្កួតរវើរវាយឥតខ្លឹមសារ ។ ដរាបដល់ពួកអ្នកដែលធ្វើគ្រឿងភាជនដ៏ដុត ដែលយើងប្រើប្រាស់សព្វថ្ងៃនេះ ក៏ត្រូវគេចាត់ចំអកហៅថាឆ្កួតផ្តេសផ្តាស ឬថាល្ងង់ល្ងីតណាស់ ។ ប៉ុន្តែអ្នកដែលមានគំនិតដែលគិតប្រឌិត ឬានខំព្យាយាមរកវិធីធ្វើគ្រឿងភាជនដី (ពែង, ចាន, កន្ធោរ,) ត្រាតែបានសម្រេចដូចបំណងនោះ គោងចាយវាយទ្រព្យសម្បត្តិស្ទើរតែអស់រលីងពីខ្លួន ហើយអស់ពេល

វេលាស្រាវជ្រាវរកដល់ ๑๐ ឆ្នាំ ទើបឃុនសម្រែច ដូច្នេះទើបឃើញថា អ្នកដើមគំនិតដែលឃានគិតប្រឌិតរបស់ប្លែក ។ ឡើង ជាមនុស្សមានគំនិតមុតមាំ មានព្យាយាមម៉ឺងម៉ាត់ណាស់ ។

ចិត្តិទ្ធិឃានជារបស់សំខាន់បំផុត ដែលអាចញ៉ាំងសេចក្តីសម្រែចឲ្យបង្កើតឡើងឃានដល់មនុស្សគ្រប់រូប ។ អ្នកធំ ។ ប្តូរជ្ជបុរស ត្រូវតែមានបំណងមុតមាំជាប្រធាន ទើបបិតទៅក្នុងតំណែងសំខាន់ ។ ឃាន ដោយបង្ហាញឲ្យឃើញសមត្ថភាពក្នុងការងារ ហើយអាស្រ័យសេចក្តីព្យាយាមមិនរួញរា តែតែឃានទៅដល់ផលដែលខ្លួនប៉ុនប៉ងសំដៅទុក ទើបឃើញថា សេចក្តីសម្រែចត្រូវអាស្រ័យហេតុ ๒ ប្រការ គឺបំណងនឹងសេចក្តីព្យាយាម បើខ្វះគុណធម៌ ๒ ប្រការនេះ រមែងនឹងសម្រែចទៅឃានដោយកម្រណាស់ ។ យើងគង់ឃានឃើញស្រាប់ហើយថា ហាងពនលក់ដូរប្តូរក្រមហ៊ុន ដែលលើកលែងធ្វើការដំនួញ ព្រោះខាតទុន ឬលក់ដូរមិនដាច់ ។ ការដែលម្ចាស់ហាងពន ឬអ្នកចាត់ការមិនមានបំណងនឹងសេចក្តីព្យាយាមមុតមាំ ក្នុងការលក់ដូរឲ្យឃានចំរើនរុងរឿងតទៅ មិនយកចិត្តទុកដាក់នឹងការទទួលបំរើប្រជាជន ដោយសុចរិតស្មោះត្រង់ទេ កិច្ចការខាងផ្លូវដំនួញ . ក៏នឹងចំរើនលូតលាស់ទៅពុំឃានដែរ ។

ការមានមានះមុតមាំនឹងសេចក្តីព្យាយាមមិនរួញរា ជាបច្ច័យយ៉ាងសំខាន់ក្នុងកិច្ចប្រតិបត្តិការងារដែលខ្លួនចាប់ផ្តើមធ្វើឡើង ឲ្យឃានសម្រែចដូចបំណង ។

មានមនុស្សជាច្រើន ដែលនឹកចង់ផ្តើមធ្វើអ្វីក៏ចាប់ធ្វើការនោះទៅ តែគ្រាន់តែធ្វើទៅបានបន្តិច ក៏ឡើយណាយរសាយសេចក្តីព្យាយាមបន្តិចម្តងៗ គ្រាតែលែងធ្វើការដែលចាប់ផ្តើមធ្វើពីដំបូងនោះ ។ នេះបញ្ជាក់ឲ្យឃើញថា គេខ្វះសេចក្តីមានៈ ដែលជាដើមហេតុនៃសេចក្តីសម្រេចនុ៎ះឯង ។ គោលសំខាន់ដែលនឹងធ្វើការឲ្យសម្រេចទៅបាននោះទៅគ្រង់សេចក្តីមានៈព្យាយាមមិនរួញរា យកជ័យជំនះចំពោះឧបសគ្គនានាប្រការ ចុះដៃធ្វើរឿងៗទៅមិនអាក់ខាន មុខជានឹងបានទទួលផលសម្រេចជាប្រាកដ ។ មានជនតាំងចិត្តធ្វើការមុតមាំក្នុងជាន់ដំបូង ដល់ចាប់ធ្វើការនោះបានបន្តិចទៅ បែរជាមានគំនិតរវែកកន្ទែកចិត្តលះបង់ការចាស់ចាប់ធ្វើការថ្មីតទៅទៀត បុពណាលោកពោលទុកថា "ចាប់នេះចាប់នោះមិនឆ្ពោះត្រង់ណា" រមែងមិនបានសម្រេចការអ្វីឲ្យបានជាប្រយោជន៍ចំពោះខ្លួន ឬចំពោះលោកឡើយ ។ ជនបែបនេះ ក៏បានឈ្មោះថាខ្វះមនសិការៈចំពោះការងារ នឹងសេចក្តីព្យាយាមមិនរួញរាហ្នឹងឯង ។

គំនិតដែលគិតផ្សឹងតាមជោគជតា ធ្វើឲ្យមនុស្សមានសេចក្តីរួញរាដោយយល់ថាខ្លួនគ្មានជោគវាសនា ឬបួនកាលរឹងចាំមានជោគល្អសិនសឹមធ្វើការងារ ។ ការពិតនោះ ជោគវាសនាហ្នឹងឯងមិនសូវជាសំខាន់ប៉ុន្មានទេ បើអ្នកណាគិតតែរង់ចាំជោគវាសនាមានមក មុខជាអត់ឃ្មុំស្ងាប់មិនខាន់ ដូចមានរឿងនិទានបុរស ៣ នាក់ : ម្នាក់នោះគេបញ្ជោតថា

មានបុណ្យក់ស្នាន៏ដ៏ឆ្ងាន់គ្រង៏ពជ្យជាក្សត្រ កំគិតតែពីតអង្គុយចាំដេកចាំ
ភជរថមកទទួលឲ្យទៅគ្រង៏ពជសម្បត្តិ មិនគិតខ្វល់ខ្វាយធ្វើការងារ
គ្រាតែអត់ចុយស្ងាប់ទៅ ។ ឯសម្ងាញ់ពីរនាក់ទៀត ខំខ្វល់ខ្វាយធ្វើការ
ងារ ព្រោះគ្រួគាយថា ឥតជោគវាសនា គ្រាន់តែមានសម្បត្តិចាយវាយ
គ្រប់គ្រាន់ មិនរហេមរហាម ។ អ្នកខ្លះផ្សងជោគវាសនាទិញឆ្នោត
ដែលមានផលយ៉ាន៏ស្តួចស្តើងណាស់ តឹម ១% ប៉ុណ្ណោះ ។ រឿង
ជោគជតាវាសនារបស់មនុស្សយើងនេះ ជារបស់មិនគួរជឿទេ អ្នកដែល
ជឿគ្រួគាយ កំគិតតែដេកចាំជោគឥតធ្វើការអ្វី ជាពួកមិនគិតចេញចុនអ្វី
គិតតែឲ្យខាន៏ចំណេញតែម្យ៉ាន៏ តើគំនិតនេះសមហេតុផលទេ?

មានជនានុជនជោយច្រើន មិនសូវនឹកគិតរលឹកដល់ពេលវេលាដ៏
មានតំលៃរបស់ខ្លួន ដែលកន្លងរំលងទៅពាល់ ។ ថ្ងៃ ដោយមិនបានធ្វើ
ប្រយោជន៍អ្វី ។ ប្រសិនបើនឹកឃើញមុខជានឹកស្តាយគ្រោយច្រើន
អ្នកខ្លះបណ្តោយខ្លួនឲ្យធ្លាក់ទៅក្នុង៏អបាយមុខ គិតតែខាន៏ស៊ីផឹកដើរលេង
សប្បាយទៅតាមពេន៏មហោស្រពផ្សេង ។ រាល់ថ្ងៃ ។ ប្រសិនបើគេគិតថា
គេកើតមកគិតតែពីខាន៏សប្បាយមួយមុខ ឥតគិតដល់ក្តីឈ្លោះកិត្តិយស
ឬសេចក្តីចំរើន ឬវិនាស ក៏លើកទុកទៅចុះ ព្រោះមនុស្សចំពូកនេះ បើ
មានភាគច្រើនក្នុង៏លោក មុខជាធ្វើលោកភ៉ាន៏មួលឲ្យទៅជាសត្វលោក
មិនមែនជាមនុស្សលោកដូចសព្វថ្ងៃនេះទេ ប៉ុន្តែមនុស្សយើងគ្រប់

រូប រមែងមានខ្លះក្បាលសម្រាប់ហាត់រៀនច្រើការណាប្រយោជន៍ឲ្យានតែប់
ខណៈ ហើយអត្ថប្រយោជន៍នេះ កាលបើគាន់តែសូតសាស់ចំរើនខ្លឹង។
នឹងជួយបំពេញសេចក្តីខ្វះខាតរបស់ប្រទេសជាតិ ឲ្យានជាអនេកប្រការ
អ្នកដែលឲ្យានតសាងសេចក្តីចំរើនដល់ប្រទេសជាតិ ឲ្យានច្រើនតែមណា
កិត្តិយសនឹងកើតឈ្មោះតំចារឹកជាប់នៅក្នុងប្រវត្តិសាស្ត្ររបស់ជាតិ អស់
កាលជាយូរអង្វែងជរាបនោះ ។ ហេតុដូច្នេះ ទើបយើងត្រូវតែចេះប្រើ
ពេលទំនេររបស់យើង ឲ្យឲ្យានសម្រេចជាអត្ថប្រយោជន៍ដល់ខ្លួនយើង
ជរាបដល់វង្សត្រកូលប្រទេសជាតិរបស់យើង សូម្បីក្នុង ១ ថ្ងៃតែម ១ ម៉ោង
មួយខែ ៣០ ម៉ោង មួយឆ្នាំ ៣៦៥ ម៉ោង ចុះដល់ ១០ ឆ្នាំទៅ តើ
ប៉ុន្មានម៉ោង? — ការសិក្សារបស់កេងក្នុងមួយឆ្នាំជាង ១.០០០ ម៉ោង
ប៉ុណ្ណោះ ក៏អាចញ៉ាំងផលសម្រេចជាអនេកប្រការពល់ៗឆ្នាំ ។ បើ
លោកចេះប្រើពេលទំនេររបស់លោក តែម ១ ថ្ងៃ ១ ម៉ោង ឬ ២ ម៉ោង
សម្រាប់ការសិក្សា លោកក៏នឹងមានចំណេះ កើនចំរើនខ្លឹងមិនមែនតិច
ឡើយ មានឧទាហរណ៍ដូចវិញ្ញាជន ដែលចេះប្រើពេលទំនេរតែម
១ ថ្ងៃ ១-២ ម៉ោងប៉ុណ្ណោះ គេអាចសរសេរវចនានុក្រមឲ្យានជាច្រើនភាគ
ហើយមានវិញ្ញាជនខ្លះ អាចហាត់និយាយភាសាឲ្យាង ឲ្យានដល់ ១២
ភាសា ព្រោះចេះប្រើពេលទំនេរតែម ១ ថ្ងៃ ១ ម៉ោង ២ ម៉ោងប៉ុណ្ណោះ ។

តអំពីនេះទៅ ឈ្មោកនឹងឃើញថា ការប្រើពេលទំនេរឲ្យមានប្រយោជន៍នោះ តើជាការសំខាន់ដូចម្តេចខ្លះ? —

អស់លោកអ្នកដែលធ្លាប់ធ្វើការមកយូរៗ ហើយ ឃានឧស្ហឹលផលកំរៃខ្លាជដែល មិនកើនចំរើនឡើងសោះ នោះបើគេចេះប្រើពេលទំនេរស្វែងរកប្រយោជន៍តទៅទៀត នឹងមានកំរៃកើនចំរើនឡើង ឃានផ្តល់ឱយសប្បាយចិត្តច្រើនមិនខាន ។

កិលហ្វាដ៏ដេយ៍ ជាអ្នកប៉ាឌិត្យវិទ្យាសាស្ត្រជាតិអង់គ្លេសយ៉ាងល្បីល្បាញ កាលពីក្មេងទំនាល់ត្រណាស់ ធ្វើការហាត់ដេរក្រមសៀវភៅខ្លះៗពុម្ព១ដោយតតឃានឧស្ហឹលប្រាក់ឆ្ងាន់ឈ្លួលទេតែកុមារនេះឃានចំប្រើពេលទំនេរៗ ដែលខ្លះសល់ពីការហាត់ដេរក្រមសៀវភៅនោះ ចំពិនិត្យមើលសៀវភៅទាំងឡាយ ដែលគេយកមកជួលដេរក្រមនោះ ស្ទើរតែគ្រប់ៗសៀវភៅ ទើបបណ្តាលឲ្យសេចក្តីចេះដឹងរបស់ហ្វាដ៏ដេយ៍ កាន់តែរីកចំរើនឡើង ហើយជួបជួនជាមានគេយកសៀវភៅ "តនស៊ីក្លូប៉េឌីប្រីតានិក" មកឲ្យដេរក្រម កុមារក៏បើកមើល ឃានប្រទះត្រូវនឹកខ្លែងដែលនិយាយពីវិជ្ជាអគ្គិសនី ក៏នឹកក្អកចង់ចេះដឹងក៏សាកល្បងលមើល ឃើញផលជាក់ស្តែងហុចដល់គំនិត ។ តាំងពីកាលនោះមក ហ្វាដ៏ដេយ៍ក៏ខំប្រឹងសិក្សាវិទ្យាសាស្ត្រឡើង តមកឃានអានសៀវភៅវិជ្ជាគ្រឹមដែលមានក្នុងសៀវភៅនោះ គ្រាតែស្ទាត់ជំនាញ ។ ថ្ងៃមួយមានឱកាសឃានចូល

ទៅស្តាប់ចុះបកថាខាងវិទ្យាសាស្ត្រ នៅរាជបណ្ឌិត្យស្ថាន មានចិត្តស្ម័គ្រ
ចូលទៅធ្វើការកន្តំណែងក្នុងការវិទ្យាសាស្ត្រ នៅរាជបណ្ឌិត្យស្ថាននោះ
ហ្មង៉ាដែរ ដោយចាន់សាកល្បងវិជ្ជាអគ្គិសនីនឹងគីមី គ្រាតែចាន់ជួបប្រទះរឿង
ផ្សេងៗ យ៉ាងច្រើនបំផុត ។ តមកចាន់ទទួលនាទីជាចាងហ្វាង ហើយ
ចាន់ទទួលកិត្តិយសជានាយកខាងវិជ្ជាហ្ស៊ីសុិកនឹងគីមី ។

គ្មានអ្នកណានឹកនាថា កេងកំសត់កូនជាងដំដែក នឹងមានកិត្តិយស
កេរ្តិ៍ឈ្មោះល្បី ហើយទៅជាអ្នកចេះជ្រៅវិទ្យាសាស្ត្រយ៉ាងល្បីល្បាញដល់
ម្ល៉ោះឡើយ ។

យ៉ាដាស្ទីហ្វេនស័ន ជាតួយ៉ាងដ៏គាប់ប្រសើរមួយរបស់មនុស្ស ។ កាល
ចាប់ផ្តើមធ្វើរថចំហុយដំបូង គេជាអ្នកដឹកអណ្តូងរ៉ែយ៉ាងអ្នកកំសត់ តែមាន
គំនិតគិតឆ្លងដល់ថាន:រថស៊ីនគួរឲ្យចានាប់ប្រសើរជាងនេះណាស់ ក៏
ស្រាប់តែជុះគំនិតសំខាន់ឡើងក្នុងខួរក្បាលរបស់គេ គឺការគិតសាងតួបក្រ
រថភ្លើងឡើង ដ្បិតនៅកន្លងសម័យនោះ គេនៅនិយមប្រើរទេះសេះនឹង
រទេះលា សម្រាប់ដឹកនាំសម្ភារ:នឹងអ្នកដំរោយសារ ដែលនាំមិន
ស្រួលដល់ការគមនាគមន៍ណាស់ ។ តែខ្លួនគេជាអ្នកទីពាល់ក្រណាស់
គំនិតនេះនឹងកើតផលឬតតផលទៅជាប្រសើរ គេខំធ្វើការដឹកធ្យូងថ្ម
ចានកំរៃប្រចាំថ្ងៃបន្តិចបន្តួច ទាំងមិនមានផលកំរៃពីផ្លូវដទៃទៀតផង ។
ទើបគេកើតគំនិតគិតស្វែងរកផលកំរៃពីខាងក្រៅ ក្រៅពីមុខរបរសេពូ

ថ្ងៃ គេគិតធ្វើការស៊ើឈ្លបដួលដេរប៉ះទាក់ការ ដួសដុលស្បែកដើម
របស់ពួកកម្មករផងគ្នា ឃ្លានកំរៃកើនចំរើនឡើងខ្លះ ហើយទំសន្សំឡុក
ការសម្រាប់ជាដំណែសាលារៀនទៅពេលយប់ គេមានសេចក្តីកង្វល់
មួយដែលត្រូវខ្វល់ការ: គឺបិតាខ្វាក់ភ្នែក ដែលត្រូវគេចិញ្ចឹមបីឃ្លាន់ក្បា
បើខ្វុកជាមានឧបសគ្គដូច្នេះក៏ដោយគេក៏ឥតរួញរា គោលបំណងរបស់គេ
គឺការសាងរថក្តឹងឲ្យបានសម្រេច ។

កាលគេដំណាលរឿងនេះឲ្យអ្នកជិតខែស្តាប់ ពួកអ្នកស្តាប់ត្រឡប់ជា
បន្ទុះថា មានគំនិតឆ្កួតរលើរលាយ អ្នកខ្លះក៏ថា រថក្រអ្នកឯងនឹងធ្វើឲ្យកើត
ក្តឹងឆេះមិនខាន អ្នកខ្លះថាធ្វើដូចម្តេចកើត បើប្រើដុតក្តឹងដូច្នោះ មុខជា
អ្នកជិះរថក្រឈ្លក់ផ្សែងក្តឹងស្លាប់មិនខាន អ្នកខ្លះបន្ទុះថា ប្រហែលជា
ដល់គ្រាហឺនហោចនៃពួកជាងធ្វើរថនេះទូកក្តារហើយ ។ ប៉ុន្តែ ១៥ ឆ្នាំ
តមក ពួកអ្នកតិះដៀលដល់គំនិតយ៉ាងចំឡែកនោះ ត្រឡប់ធ្វើឆ្ងល់ខឹក
ស្ងើចពាល់គ្នា កាលដែលរថក្តឹងមួយជំបូងរបស់គេ ឃ្លានចាប់បើកលឿន
ទៅឃ្លានលើផ្លូវដែកត្រមាំងអ្នកជិះជាច្រើនខ្លួនច្រើន នេះហើយជាគំនិត
យល់ឃើញប្តី ត្រឡប់ជាមានមែនពិតឡើងយ៉ាងអស្ចារ្យ ។

លិនគល្ប៍ជាធានាធិបតីនៃទ្វីបអាមេរិកក្នុងសម័យមួយ ដំបូងឡើយ
ជាក្មេងកំសត់ អាស្រ័យនៅក្នុងខ្ទមតូចមួយ មិនដែលចូលសាលារៀន
គ្មានសៀវភៅរៀន គ្មានគ្រូបង្រៀន តែដែលអាចធ្វើជាមនុស្សមានក្តី

ឈ្មោះល្បីល្បាញក៏ព្រោះការហាត់រៀនខ្លួនឯង និងការអាប់អានខ្លួនឯង ។ រីឯដែលគេប្រតិបត្តិ គឺទំរៀនអក្សរដោយខ្លួនឯង ដោយអាស្រ័យពន្ធឹក្លឹងទុសដែលដុតនៅខាងមុខខ្លួម គេជឿថា គេគោងរៀនឲ្យបានសម្រេច ។

យើងបានដឹងជាក់ច្បាស់ហើយថា សេចក្តីសម្រេចរបស់មនុស្ស នៅត្រង់ខ្លួនឯងតាំងចិត្តពិតជាប្រធាន សេចក្តីនិយមរាប់អានខ្លួនឯងក៏ជាការសំខាន់ណាស់ដែរ ។ មានចំនងដែលគួរឲ្យស្តាយពេក ចំពោះយុវជនក្នុងសម័យសព្វថ្ងៃនេះ ច្រើនមានគំនិតមិនរហ័សរួសរាន់ខាន់កាលសម័យរបស់លោក ដែលចំរើនឡើងយ៉ាងឆាប់រហ័ស ហើយគេគិតយល់ដល់ហាន: និងការរបររបស់ខ្លួន ថាល្មមគ្រប់គ្រាន់សម្រាប់ខ្លួនហើយ ប្តូរដោយចំនេះខ្លិលប៉ុណ្ណោះ ទើបគេមិនចំបឹងខ្វល់ខ្វាយស្វែងរកអត្ថប្រយោជន៍អ្វីតទៅទៀត ។ មានខ្លះយល់ខុសថា ការស្តួល ។ ងាយ ។ ជារបស់គាប់ប្រសើរសម្រាប់ជីវិតរបស់ខ្លួន ទោះបីបានប្រាក់ឆ្ងាន់ប្រៀវត្សបន្តិចបន្តួចក៏ដោយ ជនពួកនេះមិនបានក្តុកនឹកដល់ធម្មជាតិ ដែលបានប្រគល់សតិបញ្ញានឹងសមត្ថភាពមកដល់ខ្លួនគ្រប់ ។ រូប តាំងពីមកចាប់កំណើតក្នុងនាលោកិយនេះ ហើយគ្មានប្រើសមត្ថភាពនោះសោះ ។

តាមដោយពិតនោះ នៅប្រទេសយើងសព្វថ្ងៃនេះ មានជនដែលបានទទួលការសិក្សាមកហ្មត់ចត់តិចណាស់ ។ អ្នកដែលចង់ចេះចង់ដឹងច្រើនដែរ ត្រូវតែខំសិក្សាដោយខ្លួនឯង គោងយកចិត្តទុកដាក់អានប្រវត្តិ

របស់មនុស្សសំខាន់ៗ ក្នុងលោក ដើម្បីជាផ្លូវគំនិតសម្រាប់ប្រកបកិច្ចការ
ផ្លូវខ្លួន នឹងជាប្រយោជន៍ដល់ប្រទេសជាតិតទៅ ។ ប៉ុន្តែគួរឲ្យស្តាយ
ពេក ហើយគួរឲ្យអាណោចអាធ័មណាស់ ចំពោះប្រទេសខ្មែរយើង
សព្វថ្ងៃនេះ មិនសូវមានសៀវភៅចោះពុម្ពផ្សាយសម្រាប់ប្រជាជនអាន
ប៉ុន្មាន មានតែសៀវភៅធម៌អាចនឹងប៉ាលីប៉ាគូបន្តិចបន្តួច សម្រាប់សិក្សា
ខាងផ្លូវសាសនា ។ រួមសេចក្តីខ្វះទៅ ទៅស្រុកខ្មែរខាងមូលមិនសូវមាន
ពេញពុម្ពនឹងសៀវភៅចោះពុម្ព ឲ្យសមនឹងឋានៈរបស់ប្រទេសទៅឡើយ
ទេ ត្រង់ណេះត្រូវបងប្អូនរួមជាតិព្រមព្រៀងគ្នាកសាងឲ្យបានចំរើនឡើង
ទើបប្រជាជាតិយើង ធ្វើដំណើរទៅមុខបានរហ័ស បើមិនដូច្នោះទេ មុខ
ជារលំរលាយជាតិ ឬជាខ្មែរក្រៃខ្មែរក្រាយទៅជាជាតិដទៃមិនខាន ។

ទៅនានាប្រទេស គេនិយមពាប់អានការអានសៀវភៅ សំខាន់
ជាងការមើលកុនមើលល្ខោនច្រើនណាស់ ។ ប្រជាជនរបស់គេគ្រប់ថ្នាក់
ច្រើននិយមមើលការសែតពាល់ថ្ងៃ យ៉ាងហោចណាស់ក្នុងមួយថ្ងៃ ២ ច្បាប់
ក្រៅពីនេះទៅនិយមអានសៀវភៅ របស់អ្នកនិពន្ធដែលមានកេរ្តិ៍ឈ្មោះ
ខ្លាតពាល់ថ្ងៃ ដើម្បីជាបច្ច័យជុំសខាត់ខួរក្បាលរបស់គេឲ្យក្លឹងថ្លា ។ ហេតុ
ដូច្នេះ ទើបគេអាចចោះពុម្ពសៀវភៅចំណាយចេញទៅពាប់ហ្នឹងពាប់សែន
ក្បាល ចួនកាលពាប់លានក៏មាន ។

មានតែការអានសៀវភៅប៉ុណ្ណោះទេ ដែលធ្វើឲ្យអ្នកមានខួរក្បាលឈ្លាសវៃតាន់សម័យនិយម ។ សៀវភៅល្អៗ ដែលមានសារប្រយោជន៍អាចនឹងធ្វើជីវិតនឹងហាន:របស់អ្នកឲ្យបានថ្កើងរុងរឿងជាអនេកប្រការ ដូចពួកមហាបុរសក្នុងលោកធ្លាប់ធ្លាន ប្រព្រឹត្តមកហើយ មានអាទិដូចជា ហ្វ្រាំងដេយ៍ពិត្តនាយករដ្ឋមន្ត្រីអង់គ្លេសក្នុងសម័យមួយ នឹង លិនគល់ប្រធានាធិបតីអាមេរិក ដែលមានកេរ្តិ៍ឈ្មោះខ្ចង់ខ្ចរ ព្រោះការអានសៀវភៅនេះឯង ។ ណាប៉ូលេអុង ចក្រពត្តិជាកំងវែសក៏ទ្រង់យកព្រះពាជហប្ដ័យទុកជាតាន់នឹងការអានសៀវភៅយ៉ាងដែរលែង ។ ហ្វ្រានស៊ុសបេទនពោលថា "ការអានសៀវភៅ ធ្វើមនុស្សឲ្យជាមនុស្សបរិបុណ្ណ:" ។ តែការអានសៀវភៅនេះ ក៏មិនមែនជាការងាយស្រួលដែរ ព្រោះសៀវភៅនិមួយៗវមែនមានទាំងរឿងល្អ – អាក្រក់ច្រលំគ្នា ទើបមុននឹងអានសៀវភៅអ្វីនោះ គួរតែសេរកមើលសៀវភៅណាដែលល្អៗសិមអាន ព្រោះសៀវភៅល្អៗ ជាឧបាយជាស់តឿនក្រើនរំលឹកចិត្តគំនិតឲ្យទៅជាអ្នកនិពន្ធមានកេរ្តិ៍ឈ្មោះល្បី ឲ្យកើតមនុស្សធម៌ ឲ្យកើតវិន្យាសាស្ត្រ ឲ្យកើតមនុស្សសំខាន់ៗក្នុងលោក រហូតដល់កើតចោរចិត្តយោរយៅសម្រាប់គេតតញាញីតដៃ ដូច្នេះការជ្រើសរើសមើលសៀវភៅសិនសិមអាន ទើបមានប្រយោជន៍យ៉ាងសំខាន់សម្រាប់ជីវិត ។

សៀវភៅជាមិត្តល្អរបស់មនុស្ស យើងបានសប្បាយរីករាយចិត្តនឹងសារប្រយោជន៍អំពីសៀវភៅ សៀវភៅឥតមានពេលប្រែប្រួលទេ បើទុកជាបានទុក្ខសោកយ៉ាងណាក៏ដោយ សៀវភៅលួងលោមចិត្តកុងគ្រាមានទុក្ខ នាំឲ្យសប្បាយរីករាយនៅពេលទំនេរ សៀវភៅមិនបោះបង់ឲ្យយើងនៅតែម្នាក់ឯង យ៉ាងកណ្តែងកណ្តាច គ្រៅពីនេះ សៀវភៅជាគ្រឿងជាស់គឿនចិត្តឲ្យយើងឈ្វីឃ្លាត ហើយនៅជាយុវជនគង់សម័យជានិច្ច ។

ចប់

រឿងក្មេងកំព្រា (រឿងព្រៃឥន)

ឃុន បុរីរក្សាបរិភ័ណ្ឌ ឈឹម - ណាក ក្រុមពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ជនប្រុសស្រីដែលមានចិត្តជ្រាលជ្រៅ ធ្លៀវឆ្លាសឆ្លាប់ប្រើគំនិតក្នុងការគិតរកប្រយោជន៍, ត្រូវប្រកបដោយសេចក្តីព្យាយាម ដែលខាត់ខន់ដោយខ្មាយនៃចិត្តជ្រាជាក្រឹងត្រិះរិះសព្វៗការ; បើមានតែព្យាយាមមិនមានចិត្តជ្រាជាក្រឹងត្រិះរិះទេ ក៏មិនបានសេចក្តីចំរើន, លុះតែព្យាយាមប្រកបដោយបញ្ញា ទើបបានសេចក្តីចំរើនគ្រប់យ៉ាង ដូចមាននិទានរឿងព្រៃឥនជាឧទាហរណ៍តទៅនេះ:

មានបុរសអ្នកស្រែមួយនាក់ ប្រកបការរបរចិញ្ចឹមជីវិតតែនឹងជាក់ដុចយកត្រីមកលក់ដូរប៉ុណ្ណោះ ។ បុរសនោះមានកូនប្រុសពីរនាក់, កូនបងអាយុ ១៣ ឆ្នាំ, កូនប្អូនអាយុ ១១ ឆ្នាំ ។ ប្រពន្ធស្លាប់ទៅគាត់ទៅពោះម៉ាយជាមួយនឹងកូនទាំងពីរ ហើយរកស៊ីចិញ្ចឹមកូនតែនឹងជាក់ដុចជាដែល ។ រៀលាដែលបុរសនោះទៅព្រៃរកប្លោចរស្ងែ - ផ្តៅធ្វើដុច តែងយកកូនបងទៅជាមួយ, ឯកូនប្អូនទុកឲ្យនៅចាំផ្ទះ ។

ថ្ងៃមួយ កូនប្អូនមានសេចក្តីសង្ស័យពេកណាស់នឹងឪពុកទៅព្រៃប្លោចរស្ងែ - ផ្តៅធ្វើដុច ព្រោះចង់ដឹងឪពុកធ្វើដុចយ៉ាងណា ខ្លួនមិនដែល

ឃើញសោះ ក៏និយាយប្រាប់ទុកថា ខ្ញុំ! ខ្ញុំមិនហ៊ានទៅផ្ទះតែម្នាក់ឯងទេ, ខ្ញុំខ្លាចណាស់, សូមយកខ្ញុំទៅនៃ្រជាមួយផង ។ ទុកក៏ព្រមយកកូនប្អូនទៅជាមួយ, លុះទៅដល់នៃ្រ ទុកក៏ចំបឹងរកប្រាប់រល្ងិ-ផ្តៅ ឪាន ហើយយកមកពុះច្រែកជាចម្រែកតូចៗ ល្មមនឹងធ្វើជាសរសៃដុត, គាត់ក៏រែងធ្វើជាដុតទៅ ។ កូនបងដែលធ្លាប់តែតាមទុកទៅនៃ្រធ្វើដុតសព្វៗថ្ងៃ មិនដឹងជាទុកធ្វើដុតយ៉ាងណាៈឡើយ ព្រោះមិនយកចិត្តទុកដាក់នឹងការងារនោះ គ្រាន់តែឪានឃើញជាដុតជាប់ត្រីប៉ុណ្ណោះ ។ ឯ-កូនប្អូនដែលទើបតែនឹងឪានតាមទៅកន្លងមុខនោះ ក៏ចំពិនិត្យមើលទុកធ្វើដុត ចាប់តាំងពីគាន់គាំបិតយកទៅគាប់រល្ងិ-ផ្តៅ រហូតដល់កើតជារាងដុតយកទៅជាក់ត្រី ជាប់ឪានត្រីហើយ យកត្រីមកដុតអាងចំអិនជាចំណីអាហារ ។

ជួនជាថ្ងៃនោះ ទុកក្មេងមិនឪានយកឈើគូសទៅ, គ្មានអ្វីនឹងបង្អាត់ភ្លើងអាងត្រីឲ្យកូនបរិភោគ, ក៏ទៅគាប់ឫស្សីស្ងួតហែងមួយកំណាត់ យកមកកូតនឹងគ្នាឲ្យគាល់តែក្តៅកើតជាភ្លើងឆេះឪាន ហើយគាត់បង្អាត់អាងត្រីឲ្យកូនតាំងពីរនាក់បរិភោគចំអែតផ្ទៃមួយពេល ។

ចំណែរចិរកាលមកខាងក្រោយ ទុកមានជម្ងឺជាទម្ងន់ដល់ទូវមរ-ណភាព ។ កូនតាំងពីរនៅកំព្រាវេញដ៏ ឥតមេ - ឪានឹងចិញ្ចឹមបីប្រាប់ថែរក្សា នៅអាស្រ័យចិញ្ចឹមជីវិតដោយទ្រព្យបន្តិចបន្តួចដែលសល់ពីទុក ។

មិនយូរថ្ងៃ-ខែប៉ុន្មាន ក៏អស់ទ្រព្យនោះទៅ ។ ទើបប្អូនទិយាយទឹងបងថា ឧបងអើយ ! យើងកាលពីដើមបានឧពុកចំនុកបំរុងរកស៊ីចិញ្ចឹមយើងទាំងពីរនាក់, យើងតតមានសេចក្តីត្រួយលំបាកអ្វីឡើយ ចាំតែទទួលទានស្រាប់ៗ; ឥឡូវនេះឧពុកយើងស្លាប់ចោលទៅហើយ, ឯយើងទាំងពីរនាក់សោតទៀតក៏មិនទាន់ពេញកំឡាំងល្មមនឹងរកស៊ីចិញ្ចឹមជីវិតបានដោយខ្លួនឯង, ទាំងបងក៏នៅតូច ទាំងខ្ញុំក៏នៅតូច ទឹងទៅរកស៊ីឈ្មួលដួលតទ្ល់អ្នកជិតខាងក្រែងគេមិនព្រមទទួល ពីព្រោះយើងជាមនុស្សកំព្រាអនាថារកទីពឹងគ្មាន គេមិនហ៊ានឲ្យនៅជាមួយ គេមិនទុកចិត្តយើង ហេតុតែយើងគ្មានមេឬបៃតកា; បើដូច្នេះ តើបងគិតយ៉ាងណាទើបទឹងបានរស់នៅជាមួយនឹងគេឯង, បង ! អង្គរថ្ងៃនេះនៅតែ ១ ទូកដៃល្មមតែល្ងាចនេះ ថ្ងៃស្អែកគ្មានអង្គរដាំបាយបរិភោគទេ, បង ! ដើរសូមទានគេឬដូចម្តេចហ៎ ! ខ្ញុំមិនទៅសូមទេ ខ្មាសគេណាស់ ស៊ូតែពីស្លាប់ ។ ម្តេចក៏ប្អូនថាយ៉ាងនេះ? បងសួរប្អូន ។ ប្អូនឆ្លើយតបទៅនឹងបងថា ខ្ញុំមានដៃពីរដើងពីរ គំនិតមារយាទដូចអ្នកទាំងពួងដែរ ។ ឧ ! ប្អូនឯងគិតយ៉ាងហ្នឹង ! ពិតមែនតែមានដៃពីរ ដើងពីរ គំនិតមារយាទដូចអ្នកទាំងពួងមែនហើយ តែខ្លួនយើងនៅតូចណាស់ មិនអាចនឹងទៅពុនរែក កាប់គាស់ លើ-សែងអ្វីបានឡើយ ។ ឧ ! បងអើយ ! សត្វចាបក៏ដែលទៅពុនរែក លើ-សែងឯណាដែរឬ? ម្តេចក៏រាប់ចិញ្ចឹមកូនរាស់

ហើយកូនក់ខ្លៃតធំឡើងរកស៊ីដូចមេក់ខ្លៃតបាន ចុះបងម្តេចក៏មិនគិតដល់ការងារបស់ឪពុកយើងផង? ។ ប្អូន! លាក់ប៉ាងអ្វី កាលពីខ្មោចឪនៅរស់ឡើយ គាត់រកស៊ីចិញ្ចឹមយើងតែនឹងដាក់ដុច, ប៉ុន្តែបងមិនដឹងជាគាត់ធ្វើដុចយកទៅដាក់ត្រីយ៉ាងណាទេ បងចាំតែឆ្អិនតែម្តង ។ ម្យ៉ាងទៀត កាលគាត់យកបរស់អ្វីមកធ្វើដុចក៏បងមិនចាំ ហើយគាត់ធ្វើដុចនោះមានសណ្តានបែបណាក៏បងមិនដឹងគាំងអស់,បើដូច្នេះ ឲ្យបងធ្វើដូចម្តេចកើត! ឃើញតែការសូមទាន ឬស៊ីឈ្នួលគេហ្នឹងហើយដូចជាស្រួលគាន់បើ; ប្អូនណ្ហើយចុះគាត់ក្តៅខ្លាសសិនទៅចុះ ទម្រាំយើងធំល្មមរកស៊ីខ្លួនឯងបាន ។ ទេ! បង, ខ្ញុំមិនទៅសូមទានឬស៊ីឈ្នួលគេទេ ខ្លាសគេណាស់ ពីព្រោះពូជយើងមិនដែលសូមទានឬស៊ីឈ្នួលគេ, បើទុកជាតិដាតួត - លួតលាមក ឲ្យាប់សូមទានឬស៊ីឈ្នួលឲ្យកំឡាងគេប្រើដូចជាសត្វតិរច្ឆានក៏ដោយ ក៏ខ្ញុំមិនព្រមប្រព្រឹត្តតាមបវេណីវង្សត្រកូលនោះដែរ នៃបង, ប្អូនគិតយើញថា: កាលបើមានអ្នកសប្បុរសចិត្តល្អជាក់ខានឲ្យយើងឬក៏ឪទៅជ្រកកោននឹងជាទៅហ្វាយនាយ យើងក៏ឪទៅស្រួលបន្តិចទៅ; តែបើប្រទះពារទៅលើអ្នកចិត្តតក់ម៉ក់អាក្រក់ពេកក្លែងសំឡក់ក្តែកស្លែ ដូចតែកមៀម តំហកគម្រាមយើងដូចសត្វតិរច្ឆាន តើយើងយកមុខទៅឪកឯណា? ម្យ៉ាងទៀត អ្នកចិត្តល្អក៏អ្នកចិត្តអាក្រក់ក៏ កាលគេហុចរបស់ឲ្យមកយើងដោយដៃគេ យើង

យកដៃទៅខ្ជួលគាន់គេ ចុះដៃជាដៃ ដើងជាដើង មាត់ជាមាត់ ដូចគ្នាទាំងអស់ ម្តេចក៏ដៃគេគ្មានសំពះសុំអ្នកណា មាត់គេមិនហានិយាយសូមអ្នកណា អនិអ្វីតែដៃដើងមាត់យើងជាងគេម្ល៉ះ, បងគិតមើលចុះ ប្អូនចាប៉ុណ្ណោះខុសឬត្រូវ? ។ បើដូច្នោះ ប្អូនចេះចាំការងារបស់ឪពុកយើងដែរឬ? បងសួរតបទៅប្អូនវិញ ។ អើ មិនអីទេបង! ប្អូនចាំទាំងអស់បងកុំព្រួយ កុំគិតទៅសូមគាន់ឬស៊ីឈ្នួលឲ្យកំឡាំងគេប្រើ ក៏ថាកខ្ជិនណាស់ យើងនេះមិនមែនជាសត្វតិរច្ឆាន គេក៏យឯកើតទៅឯលិចដូចសុនខពេកទេ ឪពុកគាត់ទុកកាំបិតព្រាឲ្យមួយដែរតើ! យើងទៅព្រួយអីសព្វបើគ្រាន់តែចិញ្ចឹមជីវិតមួយប៉ុណ្ណឹង ។ អើ! ប៉ែយ៉ាងហ្នឹង ប្អូនគិតធ្វើការងារឪពុកទៅចុះ ។

ឯប្អូនជាក្មេងមានប្រាជ្ញា ក៏ប្រាប្តូធ្វើដូចកើតយកទៅជាក់ត្រីបានដូចបំណង ។ លុះកន្ងងមកថ្ងៃក្រោយទៀត ប្អូនអង្គុយគិតតែម្នាក់ឯង មិនចេញក៏ថាប្រាប់បងសោះថា: ឪពុកអញគាត់ចេះតែធ្វើដុបជាក់ត្រីប៉ុណ្ណោះត្រង់សត្វឯទៀតៗ គាត់ជាក់ដុបមិនបាន ឃើញថាប្រាជ្ញាគាត់ខ្លោយណាស់ បើដូច្នេះអញរកឧបាយនឹងធ្វើដុបជាក់សត្វមឹតមានសត្វដូចកែព្រៃ ឈ្លូស រមាំងជាដើម លុះគិតដូច្នោះហើយ ក៏និយាយប្រាប់បងថា បង! យើងគិតទៅរកជាក់ដុបឯកែព្រៃវិញ ក្រែងបានជាប់ដូចកែព្រៃឈ្លូស រមាំង ជាសត្វធំៗ បានសាច់ច្រើន ។ បងក៏សុខចិត្តតាមប្អូនទាំងអស់

ព្រៃយល់ឃើញថា ប្អូននេះចាំកិច្ចការរបស់ឪពុកពិតប្រាកដមែន, ហើយក៏បណ្តើរគ្នាពីនោក់បងប្អូន ចូលទៅកន្លែងព្រៃស្រោងជាទីរហោស្ថានទៅដល់ពាក់កណ្តាលព្រៃ បង់ស្រែកទឹកយ៉ាងខ្លាំងនិយាយប្រាប់ប្អូនថា ប្អូន ! បង់ស្រែកទឹកណាស់ រកទឹកឯណាដឹកបាន ។ ប្អូនឆ្លើយថា តាលឪពុករស់នៅ បើដើរទៅទីណាដែលគ្មានទឹកគាត់ដឹកដីត្រង់កន្លែងណាសើមៗយូរៗ ទៅចេញទឹកបាន បើដូច្នេះបង់ជីតាលមើល ? ជីតឯណាកើត បើអស់កំឡាំងយ៉ាងនេះ ។ អើបើដូច្នោះចាំដើរទៅខាងមុខបន្តិចសិនទៅក្រែងជួនប្រទះទឹក, ដើរបានបន្តិចទៅក៏ជួបប្រទះនឹងត្រពាំងមួយមានទឹកថ្លាពាសពេញដោយផ្កាឈូកផ្កែឈូក ; បងប្អូនទាំងពីរនោក់ក៏នាំគ្នាផ្ងូតទឹក-ផឹកទឹកបេះផ្កែឈូកស៊ីតាមសប្បាយ ហើយក៏សម្រាកនៅក្បែរមាត់ត្រពាំងនោះមួយស្របក់ ។ វេលាមានកំឡាំងល្មមនឹងដើរទៅទៀតបានក៏នាំបងប្អូនដើរទៅ ; លុះបានទៅដល់ព្រៃធំមួយឈ្មោះព្រៃហ៊ិមពាន្ត មិនដែលមានមនុស្សណាទៅដល់សោះ, ឃើញតែសត្វម្រឹគជាច្រើនទៅអាស្រ័យក្នុងព្រៃនោះ ប្អូននិយាយទូន្មានបងថា បង ! យើងឈប់ទៅក្នុងព្រៃនេះហើយ មើលទៅព្រៃនេះសម្បូណ៌សត្វម្រឹគម្រឹគាណាស់; យើងគិតធ្វើជាផ្ទះមួយនៅលើចុងឈើ ហើយខ្វែកចោចផ្តៅមកធ្វើជុបដាក់សត្វទាំងនោះយកមកធ្វើជាចំណីអាហារ ។ ប្អូនធ្វើផ្ទះលើចុងឈើរួចហើយ ឲ្យបងទៅអាស្រ័យលើផ្ទះនោះទៅ ខ្លួនទៅរក

ហ្មាចឆ្កៀយកមកឆ្វេងជុចជាក់សត្វកែ រៀបឆ្វើជាចំណារចារឆ្កុំរញៃកែ
ហើយទុកតែឆ្កូវ ១ ល្មមសត្វខោះដើរចូលបាន ជុចជាឆ្វើកខ្លែងជាក់ត្រី
ដែរ ។ ពេលខោះមានសត្វឆ្កែកកែមួយដើរសំដៅពីនាយ ហាក់
ជុចជាគ្មានកោតកែងដល់អ្នកសោះ ដើរមកតាមចន្លោះឆ្កូវដែលកុមារខោះ
ចារ ទៅដល់ត្រង់កខ្លែងជាក់ជុច ក៏ស្រាប់តែជាប់កន្ទឹជុចកុមារ ឆ្កែកខោះ
ខំបំរះខ្លួនខ្លៀលរើយ៉ាងណាក៏មិនរួច ជុចវិតវួតឆ្កែកកែខោះយ៉ាងតឹងស្ទើរ
តែជកជង្កើមមិនរួច, មិនយូរប៉ុន្មានឆ្កែកខោះក៏ជាប់ខ្យល់ស្លាប់ទៅ ។
កុមារទាំងពីរឃើញឆ្កែកកែជាប់ជុចស្លាប់ដូច្នោះហើយ ក៏ត្រេកអរពេក
ណាស់ នាំគ្នាដោះអូសចេញពីជុច យកមកអាំងឆ្អែរឆ្វើជាអាហារបរិ-
ភោគ ។ ឯនជាវេលាខោះ, ឈើគួសដែលជាក់កន្ទឹហោប៉ៅអាវបង
ក៏អស់គ្រាប់ គ្មានអ្វីជាភ្លើងនឹងបង្កាត់អាំងឆ្អែរឆ្កែក; បងភាល់គំនិត
ស្រេញ មិនដឹងគិតឆ្វើយ៉ាងណា; ឯប្អូនជាក្មេងមានគំនិត ចាំនដឹងជាក់
ច្បាស់ជាតិកាលឥតុកខោះនាំទៅកែ បើគ្មានភ្លើងបង្កាត់ចំអិនអ្វី។ គាត់
តែងទៅកាប់ឫស្សីស្តួតមកកួតកើតជាភ្លើងដុតអាំងចាំនតាមច្បាច្បា ហើយ
ចាំនកំណត់ទុកកងចិត្តរួចស្រេច ។ វេលាខោះប្អូននិយាយច្បាប់បងថា
កាលពីឥតុយើងគាត់ខោះ បើគាត់ទៅកែគ្មានភ្លើងដុតអាំងអ្វី។ គាត់
កាប់ឫស្សីយកមកកួតគ្នាកើតជាភ្លើងចាំន, បើដូច្នោះ បងខោចាំសត្វ
កងទីនេះចុះ ខ្ញុំទៅរកកាប់ឫស្សីស្តួតយកមកកួតឆ្កើភ្លើងអាំង ចាតែប៉ុណ្ណោះ

ហើយ កំពៅរកកាប់ឫស្សីបានយកមកធ្វើតាមតម្រាប់ទុកកើតមែន អាឯ
ឆ្នើរជ្រុកនោះទៅតាមបំណង ឆ្អិនបានបរិភោគក្នុងវេលានោះទៅ ។
កុមារទាំងពីរ នៅអាស្រ័យក្នុងព្រៃនោះអស់កាលជាយូរបានសេចក្តីសុខ
សប្បាយ រកស៊ីតែនឹងជាក់ដុចសត្វព្រៃប៉ុណ្ណោះ ។ ពួកសត្វដែល
ដើរមកជាប់ដុចកុមារទាំងពីរនោះ តាំងតែពីសត្វជ្រុកព្រៃ - រមាំង - ឈ្លូស
រហូតដល់ជាប់ដំរី ។ ក្រោយមួយ កុមារប្អូនបានឃើញដំរីស្តមួយយ៉ាងធំដើរកែ្សវឆ្នេះនោះ ក៏មានចំណង់ចង់ស៊ីសាច់ដំរី, និយាយប្រាប់បង
ថា: ខ្ញុំចង់ស៊ីសាច់ដំរីណាស់, ដ្បិតមានដំរីស្តមួយយ៉ាងធំជាត់ដើរមក
កែ្សវឆ្នេះយើងពាល់ពាក្រី, ខ្ញុំគិតជាក់ដុចយកដំរីនេះឲ្យបាន ។ បងនិយាយ
ឃាត់ថាណ្តើយប្អូនកុំ. ដំរីនេះធំណាស់ ប្អូនជាក់ពាមិនជាប់ទេ ឬថាប្រសិន
ជាក់ដើរមកជាប់ដុចប្អូនហើយក៏បំរះត្រដរួចទៅនោះក៏ខឹង, កាលបើក៏ខឹង
ហើយ ថ្ងៃក្រោយក៏មកព្រៃចង្នេះយើងស្លិតស្លោចខ្ទេចខ្ទី ហើយក៏
ជាន់សម្លាប់យើងស៊ីជាចំណីអាហារតុំលែងឡើយ ។ ទេ! មិនអីទេ;
បងកុំព្រួយនៅតែឲ្យស្រីមទៅចុះ ចាំមើលខ្ញុំធ្វើដុចជាក់ដំរីនេះឲ្យគាល់តែ
បាន; ប្អូនថាដូច្នោះហើយ ក៏រកកាប់ផ្តៅក្រែកយ៉ាងធំៗ យកមកវែងធ្វើ
ជាដុច ជាក់ត្រង់កន្ទែងដែលដំរីគោចរ ។

ឯដំរីដែលដើរទៅមកសព្វពាក្រី ឥតមានគិតក្រែងអ្វីសោះឡើយ
ដោយគិតថា: ព្រៃនេះស្រែចរលើអញហើយ គ្មានអ្នកណាជាចំបងលើ

អញទៀតទេ, ក៏ដើរតម្រង់ត្រង់មកកន្លែងដែលកុមារដាក់ដុប ស្រាប់តែ
ចូលទៅក្នុងដុបជាប់ខ្លួនបង្អែតណែនក្តួន, ខំបម្រះនៀលស្រែកពេញកំពង
ត្រៃធំយ៉ាងណាក៏មិនរួច មិនយូរប៉ុន្មានជាប់ខ្យល់ស្លាប់ទៅ ។

កុមារទាំងពីរនាក់ឃើញដំរីជាប់ដុបស្លាប់ហើយ បបួលបងប្អូន
បំពាក់ក្តៀងក្តក់យ៉ាងធំ ជុតឆ្ពោះដំរី ។ វេលានោះ ក្ងិនឈ្ងុយសាច់ដំរីក៏ធ្យាយ
រហូតដល់តាជាទីនៅអាស្រ័យនៃយក្ស ដែលមានអំណាចគាបគ្រប
សង្កត់ពួកយក្សឯទៀតៗ ។ យក្សនោះលាន់មាត់ថា: ថ្ងៃនេះធុំក្ងិនសាច់អ្វី
ក៏ឈ្ងុយឈ្ងប់ម្ល៉េះ, មានអ្នកណាឆ្ពោះសាច់ឯណាអេះ? បើដូច្នេះអញនឹងទៅ
រកមើលថ្កែងឲ្យបានមួយចំអែត ព័ត្រោះសាច់នេះក្ងិនឆ្ងាញ់ណាស់, ហើយ
ដោយស្មានទៅប្រហែលជាច្រើនឆ្ងាំ ឲ្យបានធុំក្ងិនធ្យាយមកដល់ទីអញ
យ៉ាងនេះ, អញទៅត្រូវយកស៊ីទាំងអស់ កុំឲ្យអ្នកឆ្ពោះនោះវាបានស៊ុ" ។
គិតដូច្នោះហើយក៏ចាប់យកដំបងពេជ្រគីរីហោះឡើងលើអាកាសវេហាស៍
ឆាកមើលចុះឡើងឃើញឆ្កែងហុយៗ ត្រង់ត្រៃធំ ក៏ហោះចុះសំដៅទៅ
ត្រង់កន្លែងឆ្កែងនោះ, ក្រឡេកមើលទៅឃើញក្មេងតូចពីរនាក់កំពុងតែ
ឆ្ពោះដំរី គិតថា: ថ្ងៃនេះពេញជាមហាលាភហើយ ឃ្លានទាំងចំណីទាំង
ម្ហូបស់ បើដូច្នេះ តើអញនឹងស៊ុំដំរីមុនឬ ស៊ុក្មេងមុនអេះ? បើស៊ុំដំរីមុន
ក្រែងក្មេងនេះវាភ័យនឹងអញរត់ពួនឃ្លាត់ទៅ, តទ្បាំនឹងស៊ុក្មេងមុន វាគ្មាន
អ្វីគាន់ធ្វើជាបង្អែម សម្រាប់លាងមាត់ខាងក្រោយនឹងស៊ុំដំរីវិញ ។

ខៅខ្ចីបំផុតនោះ យ៉ក្សសម្រែចសេចក្តីថា : ណ្តើយ អញស៊ុំដំរីមុនចុះ ខុកក្នេងស៊ីត្រាយជាបង្អែមវិញ ទើបឆ្អែមាត់ស្រួល ក្នេងនេះកាមិនមែនរត់ ពួនខៅឯណាខ្លៃយ, ខុកជាក់ពួនកន្លែងណា ក៏មិនកំចាំងនឹងក្តែកអញ ដែរ ពាមកពីស្រែកកូមិរបស់មនុស្សលោកចូលជល់ព្រៃនេះម្ល៉េះហើយ ក៏ រត់ខៅណានឹងរួច; ទើបយ៉ក្សចូលគម្រាមកុមារដែលកំពុងឆ្អើរដំរីនោះថា រ៉ាយអាក្នេងច្រមក់ អាឯងមកពីណា ? ដើរចេញឲ្យឆាប់។ ។ កុមារទាំង ពីរដើរចេញពីទីនោះទៅ; ប៉ុន្តែកុមារទាំងពីរនាក់នោះ កុមារបងមាន សេចក្តីគិតភ័យតក្កមា ព្រោះខ្លួនស្គាល់ច្បាស់ជាយ៉ក្ស ហើយចាំនដឹង ប្រាកដអំពីសំណាក់ចាស់។ គេនិយាយប្រាប់ថា យ៉ក្សខ្លួនធំមានចង្កឹមពីរ សម្រាប់ស៊ីមនុស្សលោក, តែមិនចេញក់ចាប្រាប់ប្អូនខ្លៃយ ។ ចំណែក ខាងកុមារប្អូនគិតថា មនុស្សនេះមកពីណា រូបរាងធំគម្រាង ឆ្នេញធំ។ សស្វាចប៉ុនៗ ចបគាប់, ក្អែកខ្លែងត្រដេរ។ ត្រែហមត្រលែត ដូចក្អែក រអូត, ស្បែកមុខខ្លែងគគ្រឹតគគ្រាត ដូចស្បែកគីឆ្កក់, ជង្គង់ដូចត្រប់ ដេកកក់, សំខ្លែងតូចត្រក់។ ដូចជាទឹកដក់ក្នុងរន្ធឈើ, ជុះពុកមាត់តូក ចង្កាស្រមេមស្រមាមដូចបិសាចពាជកូត អានេះប្រហែលជាមិនខ្វាចគោត ញាញើតចិត្តអញទេ, ប៉ានជាហ៊ានមកនិយាយកំហែងអញដូច្នេះ, មិនអី ទេអាឯង ព្រហើនហ៊ានស៊ុំដំរីអញ ។ កុមារប្អូនថយចេញពីកន្លែងនោះ មិនឆ្ងាយប៉ុន្មាននៅឈរមើលយ៉ក្សស៊ុំដំរី តែក្នុងចិត្តនឹកខ្លាញ់ពេកណាស់ មិនទាន់ចេញស្តីថាដូចម្តេចៗ ខ្លៃយ គ្រាន់តែនឹកក្នេងពោះប៉ុណ្ណោះ ។

ពេលនោះយ័ក្សសួរថា នែអាក្មេង អាឯងធ្វើដូចម្តេច ឃានជាឃានដំរីនេះ យកមកឆ្អើរ? កុមារតូចឃានឧកាសពេលនោះ ឆ្លើយតបទៅយ័ក្សវិញ ថា ពូឯងសួរចង់ដឹងអ្វី គិតតែពីបរិភោគទៅចុះ កុំចាំបាច់ដឹងហេតុការណ៍ អ្វីឡើយ ។ យើ! អាច្រមក់ឃ្លាប់ឲ្យធាប់ៗ អញស៊ីអាឯងទៀតឥឡូវនេះ ហើយ, យ័ក្សសួរគម្រាមកុមារតូច ។ អើ! ដំរីនេះវាដើរមកជាប់ដុចខ្ញុំ កុមារឆ្លើយតបទៅនឹងយ័ក្ស ។ យីអ្ហើ! អាឯងធ្វើដុចដូចម្តេចក៏ជាក់ដំរីឃាន អាឯងនិយាយកុហកទេដ្ឋ តែគង់ដំរីវាស្លាប់ខ្លួនវាទេដឹង ហើយអាឯង និយាយបញ្ឆោតអញយ៉ាងនេះទៅ មើលអាឯងនិយាយឲ្យត្រង់កុំកុហក, តែកុហកអញស៊ីអាឯងទៀតឥឡូវនេះមិនខាន ។ ខ្ញុំមិនចេះនិយាយកុហក ទេ ពូឯងមើលចុះដុចខ្ញុំទៅឯណោះហ្ន៎ ។ ឃ្លាតជាអាឯងជាក់ដុចដំរី នេះឃានមែន យ័ក្សសួរសង្កត់សង្កិនកុមារ ។ មែន, កុមារឆ្លើយតបយ៉ាងរួសរាន់ ។ អើ! បើដុចអាឯងពូតែមែន ជាក់អញលង់មើល ។ កុមារ ក៏រត់ទៅយកដុចមក ហើយឃ្លាប់យ័ក្សថា ពូឯងចង់ដឹងចូលទៅក្នុងដុចខ្ញុំ លង់មើល ។ ដោយហេតុតែការមើលងាយថា សត្វបើដុចសរសៃរុំង ប៉ុណ្ណោះ អញគ្រាន់តែកម្រើកក៏ងាប់ខ្លួចខ្លីដែរ ថាហើយក៏ត្បូលក្បាល ចូលទៅក្នុងដុច ឆុតដៃឆុតដើងទាំងអស់, ស្រាប់តែដុចរឹតរួតតឹងខ្លួនមើល តែគេចាក់ស្រែះ បម្រែះនៀលឃុកឈើព្រៃល្អិតល្អោច ស្រែកឲ្យហោ រំពងព្រៃ ឃុទ្ធយ័ក្សដែលធ្លាប់តែយ៉ាងណា ក៏ប្រមូលយកមកអស់,

រឿងព្រៃឆក្ងាមា

លោក សាង - សាវ៉ាត លេខាធិការក្រសួងហិរញ្ញវត្ថុ

ច្រៀបចេញពី សៀវភៅកុងប៊ីរ៉ែន (Contes birmans) របស់លោកលូវុីសូស្យង (Louis Vossion)
ជាភាសាបារាំងមកជាថ្មី ។

ព្រាហ្មណ៍ ធឹងឆ្កែ

ជនណាខុសចិត្តមនុស្សខើបស្គាល់
ចាស់លោកហ៊ានក្លាល់គង់ត្រូវប៉ោក

រឿងនេះ មានយូរអង្វែងណាស់មកហើយ ។ គឺកងសក្រាជព្រះពុទ្ធធូម៉ាណា (Thoumana) ទី ១៣ ។ មានព្រាហ្មណ៍ម្នាក់ ឈ្មោះ អាហ៍មន់ដា (Ahmanda) ដែលរស់នៅកងស្រុក ស៊ីកាមា (Jikama) ។ ថ្ងៃមួយនៅពេលដែលព្រះសុរិយាហៀបអស្តង្គត់រលត់ទៅ ព្រាហ្មណ៍នោះ ចាន ចូលទៅកងវៃព្រៃដើម្បីលុបលាងខ្នងកងទឹកជ្រោះឯតខាង ហើយចាន ឃើញឆ្កែសំគមមួយដែលចូលទៅកងវៃព្រៃនោះដែរ ឆ្កែនេះ គឺជាឆ្កែវៃព្រៃ កំសត់ចាស់ជរាពេមរុះគ្មានសល់ កមរមាស់ពេញខ្លួន ដែលលួចចូលទៅកងទីក្រុងកងវេលាថ្ងៃ ដើម្បីរកអាហារក្រៀមក្រោះ ដែលអ្នកស្រុកបោះចោលកងសំរាមតាមផ្លូវ ។ ដល់ពេលព្រលប់ដោយខ្លាចគេវាយ វាក៏រត់ទៅកាន់ព្រៃដែលធ្លាប់នៅ ។

អាហ៊ីមន់ដា (Ahmanda) ក្មេងគិតដល់ពាក្យទូន្មានព្រះពុទ្ធកាន់ ប្លោងមួយយ៉ាងធំនៅដៃ រត់ដេញតាមឆ្កែនោះទៅ ដោយឥតពិចារណា បន្តិចសោះ ។ ឯឆ្កែនោះកំយតក់ស្ងួតនឹងការប្រហារនេះ ក៏ឈប់រត់ហើយ និយាយថា "ឧ(ព្រាហ្មណ៍! បើលោកសំឡាប់ខ្ញុំ តើលោកឃ្លានផលប្រយោជន៍អ្វី? ខ្ញុំសុំចិត្តលោក សុំលោកកុំសំឡាប់ខ្ញុំឡើយ ហើយខ្ញុំសុំសន្យាថា ខ្ញុំនឹងជូនមាស ២ ពាន់(តែណោតដល់លោក" ។ ឯព្រាហ្មណ៍ក្មេងគិតដល់សាសនាព្រះពុទ្ធបែរចិត្តទៅរកគ្រឿងតំរេក ក្មេងដល់សេចក្តីអំនួតដ៏អាក្រក់ នៅនាលោកនេះ ក៏ឆ្លើយទៅឆ្កែវិញថា: "ស្អាណាស់ អញសុខចិត្ត អញមិនសំឡាប់ឯងទេ ប៉ុន្តែឯងត្រូវឲ្យរបស់ដែលឯងសន្យានោះមកអញឲ្យឆាប់" ។ "ឧ(ព្រាហ្មណ៍! តើឲ្យខ្ញុំជូនមាសនោះមកលោកនៅទីនេះម្តេចបាន? ខ្ញុំឥតជាប់មកជាមួយផងទេ; បើដូច្នោះ អ្នកចូរបីខ្ញុំទៅឯកន្លែងដែលខ្ញុំធ្លាប់នៅក្នុងព្រៃឯណោះទើបបាន តើនៅព្រៃឯណោះទេដែលខ្ញុំលាក់កំណប់របស់ខ្ញុំ, លុះគាលណាទៅដល់ហើយ ខ្ញុំនឹងទៅយកមកជូនលោកភ្លាមឲ្យគ្រប់ចំនួន ។ ព្រាហ្មណ៍ថា "នែបងឆ្កែ បើអញបីសត្វតិរច្ឆានដូចឯងនេះ តើអ្នកដំណើរផងទាំងភ្លូងគេនិន្ទាអញយ៉ាងណាទៅ?" ។ ឆ្កែថា "-បើដូច្នោះ រុំខ្ញុំក្នុងអាវរបស់លោក រួចលើកលីខ្ញុំលើស្មាទៅ បើអ្នកណាមើលឃើញ ខ្ញុំនឹងតែព័ទ្ធគិតស្មានថា លោកលីកូនប្លែលចៅរបស់លោកមិនខាន" ។ ឯព្រាហ្មណ៍ដោយមានចិត្តលោភចង់

ឃ្លានមាស ២ ពាន់គ្រណោត ដែលគាត់ឃើញទៅកន្លែងកណ្តាប់ដៃគាត់ទៅ
ហើយ ក៏ព្រមព្រៀងធ្វើតាមពាក្យឆ្កែបង្គាប់ គាត់រុំឆ្កែនោះក្នុងអាវរបស់
គាត់ហើយ ក៏លើកដាក់លើស្មារួចដើរត្រង់ទៅមុខ ដោយមានជំហាន
នោះវែង ។ ចូលទៅក្នុងព្រៃ ។

លុះទៅដល់កន្លែងឆ្កែដែលសំណាក់នោះ។ ឆ្កែក៏ឃ្លានប្រាប់ហើយ
ក៏និយាយទៅកាន់ព្រាហ្មណ៍ថា: "នែទៅហ្ន៎ម្ចាស់ ខ្លោចាំខ្ញុំត្រង់កន្លែង
នេះមួយស្របក់សិន ខ្ញុំទៅយកមាស ២ ពាន់គ្រណោត រួចខ្ញុំយកមក
ជូនលោកភ្លាម ដើម្បីជាអង្វាន់ដល់លោក ដោយលោកមានចិត្តល្អនឹងខ្ញុំ"
ថាហើយឆ្កែនោះ ក៏ប្រញាលចូលទៅក្នុងព្រៃដ្បែរយ៉ាងហ៊ាសដោយឥតងាក
ក្រោយបន្តិចឡើយ ។

ឯព្រាហ្មណ៍ក៏រង់ចាំទៅកន្លែងនោះគ្រាលតែយប់ ឥតមានឃើញឆ្កែ
នោះត្រឡប់មកវិញសោះ ។ រួចគាត់ក៏ប្រុះដេកទៅលើពស់ធា ទៅ
ត្រង់កន្លែងនោះអស់ ១ យប់ លុះព្រឹកឡើង ក៏មិនឃើញឆ្កែនោះមក;
គាត់ក៏រង់ចាំទៅទៀត លុះត្រាតែដល់ព្រឹកស្អែក ដោយឥតឃ្លានផលអ្វី
សោះ ។

ក្រោយមក មានអ្នកដំណើរម្នាក់ដើរតាមផ្លូវនោះ លុះឃ្លានឃើញ
ព្រាហ្មណ៍ឈរស្ងៀមក្តែតចោលដាប់ទៅត្រង់កន្លែងដែលឆ្កែដើរចេញទៅ
នោះ ក៏សាកសួរទៅព្រាហ្មណ៍ថា តើអ្នករង់ចាំអ្វី ។ ព្រាហ្មណ៍ក៏និយាយ

ប្រាប់រឿងហេតុទាំងអស់ អំពីហេតុដែលគាត់ខានសំឡាប់ឆ្កែនោះ និង
អំពីមាស ២ ពាន់តែណោតដែលឆ្កែបានសន្យាថាឲ្យ ។ ឯអ្នកដំណើរនោះ
និយាយដោយទន្ទេរគោះថា: "អ្នកឯងឆ្កួតជាងឆ្កែនោះទៅទៀត, ហេតុ
ម្តេចបានជាអ្នកឯងធាប់ជឿពាក្យរបស់ឆ្កែតិរច្ឆានដែលមិនចេះរកកំរេចអា-
ហារខ្លួនឯងបានផងនោះ? ឯកិច្ចដ៏ប្រសើរដែលអ្នកត្រូវធ្វើ គឺអ្នកត្រឡប់
ទៅផ្ទះវិញ ហើយប្រយ័ត្នកុំអួតអាងថាគ្រាន់បើ!" ។

ព្រាហ្មណ៍ក៏សុខចិត្ត ប្រតិបត្តិតាមដំបូន្មានដ៏ប្រសើរនេះដោយអៀន
ខ្មាសផង ប៉ុន្តែដោយបានដាស្បើយអំពីកំហុសរបស់ខ្លួនហើយបានធ្វើតាម
ដំបូន្មានអ្នកប្រាជ្ញ ធូដាម្មាសារី (Thou damma Sari) ដែលគេតែង
និយាយមិនដែលឈប់ថា:

"មនុស្សណា ដែលចង់បានឈ្មោះពេញជាមនុស្សឆ្លាត គោង
ប្រុងប្រយ័ត្ន កុំខុសចិត្តមនុស្សដែលមិនសម, មុននឹងខុសចិត្តអ្នកណា
មួយគោងចូរឲ្យល្អិត រួចគោងគិតមើលដំណែលពិតនៃការសម្ងាត់ ដែល
អ្នកត្រូវជ្រើស, បើមិនដូច្នោះទេ អ្នកនឹងត្រូវខ្លួនដូចព្រាហ្មណ៍នេះ
ដែលសត្វឆ្កែកំសត់ បានលួចលេងហើយបានទាំងបំបែរឲ្យទៅជាល្បែង
សើចផង,

(មានត)

ពុទ្ធសាសនា និង ពាហិរសាសនា

លោកម៉ិញ - នាគ្រី តំណាងភស្តុ រៀបរៀង

អារម្ភកថា

ដំណើរដើមដែលនាំឲ្យកើតជាសៀវភៅនេះឡើង ដោយហេតុដែលខ្ញុំបានទៅធ្វើមេប្រយោគបឋមសិស្សចេញពីសាលាចាស់រៀងរាល់ឆ្នាំ ហើយច្រើនត្រូវមុខសួរអំពីរឿងសាសនាចំពោះសិស្សទាំងឡាយ ។ ពេលដែលសួរម្តងៗ អ្នកបឋមច្រើនតែខើសខាល់ ធ្វើយមិនសូវបានហ្មត់ចត់ ខ្ញុំលាយសេចក្តីងាយស្តាប់សោះ ។ រឿងនេះជាហេតុនាំឲ្យខ្ញុំនឹកគួចទុកក្នុងចិត្តថាបៃណាមួយទើងធ្វើសៀវភៅនេះឲ្យកើតឡើង ដើម្បីជាផ្តល់ងាយស្រួលសិក្សានៃពួកសិក្ខាកាម បំបាត់ការខេទាក់ខេទាមក្នុងរឿងនេះចេញ ។

ក្នុងការធ្វើសៀវភៅនេះ បៃកខាងពុទ្ធសាសនាខ្ញុំស្រង់មកអំពីគម្ពីរបឋមសាមន្តបាសាទិកា ព្រមទាំងន័យដទៃទៀតខ្លះ, ចំណែកខាងពាហិរសាសនា, ខ្ញុំបានដកស្រង់មកអំពីចម្បាប់ធ្លាប់ ។ ជាភាសាចាស់ខ្លះ, ចាក់ងខ្លះ, សៀមខ្លះ រួបរួមគ្នាកើតជាសៀវភៅនេះឡើង ។

លុះរៀបរៀងចប់ហើយ ខ្ញុំបានយកទៅជូនពុទ្ធសាសនបណ្ឌិត្យឲ្យជួយចុះពុម្ពផ្សាយ ដើម្បីជាវិជ្ជាសម្បត្តិសំរាប់សិស្សសាលាចាស់ផង

សំរាប់សាធារណជនទូទៅផង លោកអគ្គលេខាធិការនៃពុទ្ធសាសន-
បណ្ឌិត្យក៏បានទទួលដោយសេចក្តីសោមនស្ស ។

ខ្ញុំសូមអភ័យទោសអំពីពួកបណ្ឌិតជនសូមកុំឲ្យយល់ថា ខ្លួនខ្ញុំអួតរៀប
រៀងលំអៀងទៅតាមអគតិណាមួយឡើយ គឺខ្ញុំតែងតាមលំអានដែលមាន
មកហើយស្រាប់តាមច្បាប់នោះ។ បើមានសេចក្តីឃ្លៀងឃ្លាតត្រង់ណា
សូមមេត្តាបំពេញឲ្យគានផង ។

ទីបំផុតនេះ, សូមទទួសកុសលដែលកើតអំពីសៀវភៅនេះ ដួនទៅ
បុព្វការីជនទាំងឡាយ នឹងចែករំលែកដល់សត្វសត្តនិករទូទៅ សូមឲ្យ
ជានសេចក្តីសុខសំពន្ធសត្វ ។ កាល ។

សព្វេ សត្តា អវេរា ហោន្តុ

សូមឲ្យសត្វពាល់គ្នា កុំបីមានពៀរនឹងគ្នាឡើយ

វត្តខណ្ឌាលោម ក្រុងភ្នំពេញ

ថ្ងៃព្រហស្បត៍ ១៦ កើតខែមិគសិរ ឆ្នាំមមែបញ្ចស័ក ព. ស. ២៤៨៦

(ថ្ងៃ ៨ ខែធ្នូ ឆ្នាំ ១៩៤៣)

ម ជ្ឈិ

ពាក្យថា សាសនា

ពាក្យនេះ ពាក្យពួនានៃប្រៀនប្រដៅរបស់សាស្ដាចារ្យណាមួយក្នុងលោក ហៅថា សាសនា ។

សាសនាបើសំដែងដោយប្រភេទជាប្រធាននៃគោលធំៗ មាន ២ គឺ ពុទ្ធសាសនា ១ ពាហិរសាសនា ១ ។

ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាអគ្គបុគ្គល ជាសាស្ដាឯកក្នុងលោក ហៅថា ពុទ្ធសាសនា ។ ពាក្យប្រៀនប្រដៅរបស់គណាចារ្យណាមួយដទៃក្រៅចាកព្រះបរមសាស្ដា ហៅថា ពាហិរសាសនា ។

ពុទ្ធសាសនាប្រដៅឲ្យឆ្ងៀហេតុនឹងផល គឺឲ្យអាងឲ្យប្រកាន់ថាហេតុល្អនឹងឲ្យផលល្អ ហេតុអាក្រក់នឹងឲ្យផលអាក្រក់ អ្វីទាំងអស់ក្នុងលោកសុទ្ធសឹងប្រកបដោយហេតុនឹងផល សមដូចជាគាថាដែលព្រះអស្សជិត្ទ្រេសំដែងអាងឡើងថា :

យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ
តេសញ្ច យោ និរោធោ ច វាទី មហាសមណោ

ព្រះតថាគត ទ្រង់ត្រាស់សំដែងនូវធម៌ទាំងឡាយ ដែលជាធម៌មានហេតុជាដែនកើតមុន ទ្រង់ត្រាស់សំដែងនូវសេចក្ដីរលត់នឹងទុក្ខ

នៃសេចក្តីរំលត់ទុក្ខដ៏ខ្ពង់ខ្ពស់នោះ ព្រះមហាសមណៈខ្ញុំមាន
ប្រក្រតីពោលយ៉ាងនេះ ។

មួយទៀត ពុទ្ធសាសនាប្រដៅឲ្យដឹងកម្មនឹងផលរបស់កម្ម គឺថា
កម្មល្អនឹងឲ្យផលល្អ កម្មអាក្រក់នឹងឲ្យផលអាក្រក់; សេចក្តីល្អ អាក្រក់
សុខទុក្ខ ចំរើនវិនាស មានក្រជាដើម ស្រែចម្ការតែអំពើរបស់ខ្លួន
ដែលបានធ្វើទុកក្នុងអតីតជាតិ ឬក្នុងជាតិជាបច្ចុប្បន្ន ឥតមានអ្នកជួយឲ្យ
កន្ទុំងផុតចាកកម្មនឹងផលនៃកម្មទៅបានឡើយ ។

សមដូចព្រះពុទ្ធដីកាសំដែងទុកក្នុងទសធម្មសូត្រថា **កម្មស្សកោម្ហិ**
អាត្មាអញមានកម្មជារបស់ខ្លួន **កម្មទាយាទោ** មានកម្មជា
ទ្រព្យសំបាប់មត៌ក **កម្មយោនិ** មានកម្មជាកំណើត **កម្មពន្ធុ** មាន
កម្មជាញាតិសាច់សន្តាន **កម្មបដិសរណោ** មានកម្មជាទីពឹង
អាស្រ័យ យំ **កម្មំ** **ករិស្សាមិ** **កល្យាណំ** វា **បាបកំ** វា
អាត្មាអញនឹងធ្វើនូវអំពើឯណា ទោះជាអំពើល្អក្តី អាក្រក់ក្តី **តស្ស**
ទាយាទោ **ភវិស្សាមិ** នឹងបានជាអ្នកទទួលយកផលកម្មនោះប្រាកដ
ពុំខាន ។

ន័យមួយទៀតថា:

អត្តនា វ កតំ បាបំ អត្តនា សំកិលិស្សតិ
អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ

អំពើអាក្រក់ដែលខ្លួនឯងធ្វើហើយ នឹងសៅហ្មងដោយខ្លួនឯង អំពើអាក្រក់ដែលខ្លួនមិនបានធ្វើហើយ នឹងបរិសុទ្ធចំពោះខ្លួន សេចក្តីបរិសុទ្ធ មិនបរិសុទ្ធ ស្រែចលើខ្លួន បុគ្គលដទៃនឹងឲ្យបុគ្គលដទៃបរិសុទ្ធ ដូចម្តេចបាន ។

គោលប្រជៀ ៣ យ៉ាង

ពុទ្ធសាសនា បើសំដែងអំពីគោលនៃការប្រជៀធំៗ មាន ៣ គឺ :

១ – សព្វទាយស្ស អការណំ ការិយាមិនធ្វើអំពើអាក្រក់សព្វយ៉ាង ។

២ - កុសលស្សូបសម្បទា ការញុំាងកុសលឲ្យសំរេចគឺឲ្យខំធ្វើអំពើល្អ ។

៣ - សចិត្តបរិយោទបនំ ការិយាញុំាងចិត្តរបស់ខ្លួនឲ្យផូរផង់ គឺត្រូវជុំសាត់ចិត្តរបស់ខ្លួនឲ្យបរិសុទ្ធ ។

ឯតំ ពុទ្ធានសាសនំ ពាក្យទាំង ៣ យ៉ាងនេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ ។

ពុទ្ធភ្លៅកទាំង ៣ ប្រការនេះ បើនឹងរាប់បញ្ចូលទៅក្នុងបិដកទាំង ៣ គ្រង់ពាក្យថា : "មិនឲ្យធ្វើបាបសព្វយ៉ាង" ចាត់ចូលក្នុងវិនយបិដក, ពាក្យថា "ឲ្យខំធ្វើអំពើល្អ" ចាត់ចូលក្នុងសុត្តន្តបិដក, ពាក្យថា "ទំសំអាតចិត្តរបស់ខ្លួនឲ្យផូរផង់" ចាត់ចូលក្នុងអភិធម្មបិដក ។

ប្រយោជន៍ក្នុងពុទ្ធសាសនា

ពុទ្ធសាសនា បើសំដែងអំពីផលប្រយោជន៍អំពីគុណបំណាច់ប្អូនដៃម្រះផ្ទាន់ដែលពុទ្ធសាសនិកជនត្រូវបាន ព្រះពុទ្ធទ្រង់ប្រដៅបំបែរផ្លូវជា ៣ គឺ:

១ – ទិដ្ឋធម្មិកត្ថ = ប្រយោជន៍ក្នុងបច្ចុប្បន្ន

២ – សម្បរាយិកត្ថ = ប្រយោជន៍ក្នុងលោកខាងមុខ

៣ – បរមត្ថ = ប្រយោជន៍ដ៏ខ្ពង់ខ្ពស់គឺព្រះនិព្វាន

ប្រយោជន៍បច្ចុប្បន្ន ចែកចេញជា ៤ ប្រការគឺ:

១ – **ឧដ្ឋានសម្បទា** សេចក្តីពេញលេញដោយការខ្នះខ្នែងគឺការខំប្រឹងរកទ្រព្យសម្បត្តិ ឲ្យបានមកតាមធម៌ មានវៀរចាកចំនួញ ៥ ប្រការជាដើម ។

២ – **អារក្ខសម្បទា** សេចក្តីពេញលេញដោយការរក្សាគឺការចេះរក្សាទ្រព្យសម្បត្តិដែលបានមកហើយ ឲ្យគង់នៅមិនឲ្យវិនាសទៅដោយល្បែងពាលផ្សេងៗ មានល្បែងស្រី - ស្រា - ស៊ីសង៍ជាដើម ។

៣ – **កល្យាណមិត្តតា** ភាពនៃបុគ្គលមានមិត្តល្អ គឺវៀរចាកចាបមិត្ត ហើយសេពគប់រាប់រកតែកល្យាណមិត្ត ។

៤ – **សមជីវិតា** ភាពនៃបុគ្គលអ្នកចិញ្ចឹមជីវិតស្មើៗ គឺចិញ្ចឹមតាមសមគួរដល់កំឡាំងធនធានរបស់ខ្លួន មិនចាយវាយខ្ជះខ្ជាយឥតបានឥតសណ្តាប់ ។

នេះជាប្រយោជន៍សំរាប់ចែកសេចក្តីសុខក្នុងបច្ចុប្បន្ន ។

ប្រយោជន៍ក្នុងលោកខាងមុខ ចែកចេញជា ៤ ប្រការ គឺ :

๑ – **សទ្ធាសម្បទា** សេចក្តីពេញលេញដោយជំនឿ

๒ – **សីលសម្បទា** សេចក្តីពេញលេញដោយសីល គឺត្រូវរក្សានិច្ចសីល ឧបោសថសីល អតិរេកសីល ចតុប្បារិសុទ្ធិសីល តាមនាទីរបស់ខ្លួន ។

๓ – **ចាគសម្បទា** សេចក្តីពេញលេញដោយការចែកទាន គឺចេះចែករំលែកធនធានដែលខ្លួនរកបានមកដោយធម៌ ដល់សមណៈព្រាហ្មណ៍ យាចកអ្នកកំសត់ទុគ៌ត កំព្រីកំព្រា អនាថា តាមសមគួរ ឈ្មោះថាជាគ្រឿងចែកសេចក្តីសុខដល់អ្នកដទៃ ។

๔ – **បញ្ញាសម្បទា** សេចក្តីពេញលេញដោយបញ្ញា គឺប្រកបដោយសេចក្តីយល់ឃើញជាសម្មាទិដ្ឋិ មានការយល់ឃើញថាធ្វើបុណ្យបានបុណ្យធ្វើបាបបានបាបជាដើម ។

ប្រភេទរបស់ព្រះពុទ្ធសាសនា

ពុទ្ធវចនៈទាំងអស់នោះ គឺ :

រសវសេន ឯកវិធំ មានតែមួយដោយអំណាចនៃរសត្តិរស

ធម្មវិនយវសេន ទុវិធំ មាន ๒ យ៉ាងដោយអំណាចនៃធម៌ និងវិន័យ

បឋមមជ្ឈិមបច្ឆិមវសេន តិវិធំ មាន ៣ យ៉ាង ដោយបឋម-
ពុទ្ធវចនៈ មជ្ឈិមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈ ។

តថា បិដកវសេន មាន ៣ យ៉ាង ដោយអំណាចបិដកទាំង ៣
និកាយវសេន បញ្ចវិធំ មាន ៥ យ៉ាង ដោយអំណាចនៃ
និកាយទាំង ៥

អង្គវសេន នវវិធំ មាន ៩ យ៉ាង ដោយអំណាចនៃអង្គទាំង ៩

ធម្មក្ខន្ធវសេន ចតុរាសីតិសហស្សវិធំ មាន ៨៤.០០០
ដោយអំណាចព្រះធម្មក្ខន្ធ ។

ពុទ្ធវចនៈ ១ យ៉ាង

ពាក្យដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រៀនប្រដៅសត្វលោក
មានទេពតាមនុស្សនាគយក្ខធាដើម ឬធម៌ដែលទ្រង់រំពឹងពិចារណាក្នុង
រវាង ៤០ វស្សា ចាប់ដើមអំពីថ្ងៃដែលទ្រង់ឃានត្រាស់ដឹងនូវអនុត្តរសម្មា-
សម្ពោធិញ្ញាណ ដរាបដល់ពេលដែលទ្រង់រំលត់ខន្ធបួលកាន់បរិនិព្វាន
ដោយអនុឡាទិសេសនិព្វានធាតុ ព្រះពុទ្ធវចនៈទាំងអស់នុ៎ះប្រមូលរួបរួម
មកមានតែមួយ គឺដើម្បីឲ្យសត្វឃានគ្រៃបង្កឹកនូវវិមុត្តិរសប៉ុណ្ណោះឯង;
យ៉ាងនេះឈ្មោះថា ពុទ្ធវចនៈមានតែមួយដោយអំណាចនៃវិមុត្តិរស ។

ពុទ្ធវចនៈ ២ យ៉ាង

សត្ថុសាសនំ នាម្មោ ច វិនយោ ច តំឯពុទ្ធវចនៈទាំងអស់
ហ្នឹងឯង រួបរួមមកមានពីរយ៉ាង គឺធម៌ ១ វិន័យ ១ ។

តត្ថ វិនយបិដកំ វិនយោ បណ្ដាពុទ្ធវចនៈតាំង ២ នោះ វិនយុបិដក ហៅថា វិន័យ, អវសេសំ ពុទ្ធវចនំ ឆឡោ ពុទ្ធ-វចនៈដ៏សេស ក្រៅចាកវិន័យ ហៅថា ធម៌ ។

សមដូចពាក្យដែលព្រះមហាកស្សបត្ថេរពោលទុកថា យន្នូន មយំ អាវុសោ ឆឡេញ្ច វិនយញ្ច សង្គាយេយ្យ ម្នាលអាវុសោ ចើ ដូច្នោះ មានតែយើងនឹងសង្គាយនាទូវធម៌ផង វិន័យផង ឬទុំតែវិន័យ ចំពោះខុបាលី, តែវិសូវធម៌ ចំពោះអានន្ទ; យ៉ាងនេះ ដែលឈ្មោះថា ពុទ្ធវចនៈមាន ២ យ៉ាងដោយអំណាចធម៌នឹងវិន័យ ។

ពុទ្ធវចនៈ ៣ យ៉ាង

សត្ថុសោ បរិយត្តិ បឋមពុទ្ធវចនំ មជ្ឈិមពុទ្ធវចនំ បច្ច-ប្បន្នពុទ្ធវចនន្តិ តិវិធេកេនំ ពុទ្ធវចនៈតាំងអស់នោះ មានប្រភេទ ៣ គឺ : បឋមពុទ្ធវចនៈ ១ មជ្ឈិមពុទ្ធវចនៈ ១ បច្ចុប្បន្នពុទ្ធវចនៈ ១ ។

បណ្ដាពុទ្ធវចនៈតាំង ៣ នេះ ត្រង់ខ្ញុំនានាគាថាដែលព្រះសាស្តា ទ្រង់ទឹកក្នុងអស្ចារ្យក្នុងព្រះទ័យលាន់ចេញមកជាព្រះវាចា ក្នុងកាល ដែលទើបបានត្រាស់ជ័យជំនះថ្មីៗ ថា :

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ

សព្វា ទេ ជាសុកា កន្តា តហាគ្គដំ វិសន្ថុតំ
វិសន្ថរកតំ ចិត្តំ តណ្ហាខំ ១យមជ្ឈគា ។

តថាគតកាលអន្ទោលទៅមក យោនយកកំណើតក្នុងសង្សារវដ្ត
អស់ជាតិជាអនេកស្មើរភជាងផ្ទះគឺតណ្ហា មិនទាន់ដួបប្រទះនៅឡើយ
ម្ល៉េះហើយជាតិតែងនាំមកនូវសេចក្តីទុក្ខលំបាកវើយ។, នែជាងធ្វើ តថា-
គតរកអ្នកឃើញហើយ អ្នកលែងសង់ផ្ទះគឺអត្តភាពឲ្យតថាគតទៀតហើយ
(ព្រោះថា) គ្រឿងប្រក់របស់អ្នកតថាគតបាក់ខ្ទេចខ្ទីបំបាក់ចោលអស់រលីង
ហើយ ទាំងកំពូលផ្ទះតថាគតក៏បាក់ចោលហើយដែរ ចិត្ត (របស់តថាគត)
ផុតស្រឡះចាកការតាក់តែងហើយ ព្រោះតថាគតបានដល់នូវការអស់
ទៅនៃតណ្ហា, នេះហៅថា បឋមពុទ្ធវចនៈ ។

ពុទ្ធវចនៈដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ធ្លាប់ធុតក្នុងកាលទៀប
បរិនិព្វានជាអរិយានត្តវចៈ: **ហាទុធាឯ តំ ភិក្ខវេ អាមន្តយាមិ ភេ**
វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ នែភិក្ខុទាំងឡាយ
តទ្បូវនេះតថាគតឆ្លាំអ្នកពាល់គ្នាថា: "សង្ខារទាំងឡាយរមែងមានសភាព
សោះសូន្យទៅជាធម្មតា (ហេតុនេះ) អ្នកពាល់គ្នា ចូរញ៉ាំងកិច្ចទាំងពួងឲ្យ
សំរេច ដោយសេចក្តីមិនប្រហែសឆេ្ងស", នេះហៅថា បច្ឆិមពុទ្ធវចនៈ ។

ពុទ្ធវចនៈទាំងអស់ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងក្នុង
កាលជាច្រើនោះ ជាកណ្តាលនៃពុទ្ធវចនៈទាំងពីរ គឺបឋមពុទ្ធវចនៈនឹង
បច្ឆិមពុទ្ធវចនៈ ហៅថា មជ្ឈិមពុទ្ធវចនៈ ។

យ៉ាងនេះដែលហៅថាពុទ្ធវចនៈមាន ៣ យ៉ាង ដោយអំណាចពុទ្ធវចនៈជាន់ដំបូង ជាន់កណ្តាល ជាន់ចុងបំផុត ។

ពុទ្ធវចនៈ ៣ យ៉ាង បិដក ៣

ពុទ្ធវចនៈទាំងអស់នោះ មានប្រភេទ ៣ គឺវិនយបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១ ។

បណ្តាពុទ្ធវចនៈទាំង ៣ នោះ ឱ្យដំមោក្ខទាំង ២ (ភិក្ខុបាដិមោក្ខ ភិក្ខុនីបាដិមោក្ខ) វិភង្គទាំង ២ (ភិក្ខុវិភង្គ ភិក្ខុនីវិភង្គ) ខន្ធក ២២ បរិវារ ១ ដែលលោកប្រមូលយកសង្ខិត្តនិទ្ទេសទាំងអស់ កាលបឋមសង្គាយនា បើគិតរួមមកជាគម្ពីរមាន ៥ គឺ: អាទិកម្ម, ឱ្យបាដិយ, មហាវគ្គ, ចុល្លវគ្គ, បរិវារ, រួមមកហៅថា វិនយបិដក ។

ធម៌ដែលលោករួបរួមយកសូត្រ ៣៤ មានព្រហ្មជាលសូត្រជាដើមមកឱ្យឈ្មោះថា "ទីឃនិកាយ" ។ ធម៌ដែលលោករួបរួមយកសូត្រ ១៥២ មានមូលបរិយាយសូត្រជាដើមមកឱ្យឈ្មោះថា "មជ្ឈិមនិកាយ" ។ ធម៌ដែលលោករួបរួមយកសូត្រ ៧៧៦២ មានទសុត្តរសូត្រជាដើមមកឱ្យឈ្មោះថា "សំយុត្តនិកាយ" ។ ធម៌ដែលលោករួបរួមយកសូត្រ ៩៥៥៧ មកឱ្យឈ្មោះថា "អង្គុត្តរនិកាយ" ។ ធម៌ដែលមានប្រភេទ ១៥ គឺខុទ្ទកបាឋ, ធម្មបទ, ឧទាន, តតិវុត្តក, សុត្តនិបាត, វិមានវត្ថុ, បេតវត្ថុ, ថេរគាថា, ថេរីគាថា, ជាតក, និទ្ទេស, បដិសម្ភិទា, អបទាន, ពុទ្ធវង្ស, ចរិយាបិដក, មកឱ្យឈ្មោះថា "ខុទ្ទកនិកាយ" ។

ធម្មសង្គណី, វិភង្គ, ធាតុកថា, បុគ្គលប្បញ្ញត្តិ, កថាវត្ថុ, យមក, បដ្ឋាន ហៅថា "អភិធម្មបិដក" ។

បិដកទាំង ៣ នេះ បើចែកតាមដំណើរទេសនាមាន ៣ គឺ អាណាទេសនា ១ ភេហារទេសនា ១ បរមត្ថទេសនា ១ ។

វិនយបិដក ដែលព្រះដ៏មានព្រះភាគជាបុគ្គលគួរដល់អាជ្ញាត្រាស់សំដែងសម្បូណ៌ដោយអាជ្ញា ហៅថា "អាណាទេសនា" ។ សុត្តន្តបិដក ដែលព្រះដ៏មានព្រះភាគជាភេហារកោសល គឺជាបុគ្គលឈ្លាសវៃដោយភេហារច្បាំព្រះទ្ធត្រាស់សំដែងសម្បូណ៌ដោយភេហារ ហៅថា "ភេហារទេសនា" ។ អភិធម្មបិដក ដែលព្រះដ៏មានព្រះភាគឈ្លាសវៃដោយបរមត្ថត្រាស់សំដែងច្រើនដោយបរមត្ថធម៌ ជាធម៌មានសេចក្តីឆ្លាសដ្ឋៅ ហៅថា "បរមត្ថទេសនា" ។

ចែកតាមដំណើរពាក្យសាសនា (ការប្រៀនប្រដៅ) មាន ៣ យ៉ាងគឺ យថាបរាធសាសនា ១ យថានុលោមសាសនា ១ យថាធម្មសាសនា ១ ។

វិនយបិដក ហៅថា យថាបរាធសាសនា (ការប្រៀនប្រដៅតាមកំហុស) ព្រោះថាពួកសត្វដែលមានកំហុស ព្រះអង្គទ្រង់ប្រៀនប្រដៅតាមកំហុសក្នុងវិនយបិដកនេះ ។ សុត្តន្តបិដក ហៅថា យថានុលោមសាសនា (ការប្រៀនប្រដៅតាមសមគួរ) ព្រោះថាពួកសត្វដែលលង់នៅក្នុងអធ្យាស្រ័យ អនុស័យនឹងចរិយាជាអនេក ព្រះអង្គត្រាស់ប្រៀនប្រដៅ

អម្ពុសោមតាមអធ្យាស្រ័យ អនុស័យនឹងចរិយានោះៗ ក្នុងសុត្តន្តបិដក
នេះ ។ អភិធម្មបិដក ហៅថា យថាធម្មសាសនា (ការប្រែនប្រែជៅ
តាមធម៌ឬតាមសភាពពិតមែន) ព្រោះថា ពួកសត្វដែលមានសេចក្តី
យល់ក្នុងពួកនៃធម៌ថា "ខ្លួនអញ របស់អញ" ព្រះអង្គទ្រង់សំដែង
ប្រែនប្រែជៅតាមសភាពពិត ក្នុងអភិធម្មបិដកនេះ ។

បើចែកតាម កថា មាន ៣ យ៉ាង គឺ: សំវាសំវាកថា ១ ទិដ្ឋិវិនិវេ-
ឋនកថា ១ នាមរូបបរិច្ឆេទកថា ១ ។

វិនយបិដក ហៅថា សំវាសំវាកថា ព្រោះការសង្ឃមនឹងមិន
សង្ឃមជាសត្រូវដល់អធ្យាចារ (សេចក្តីបត្តិត្តិល្អតឹមត្រូវ) ព្រះអង្គទ្រង់
សំដែងទុកក្នុងវិនយបិដកនេះ ។ សុត្តន្តបិដក ហៅថា ទិដ្ឋិវិនិវេឋនកថា
ព្រោះថាការដោះចាកទិដ្ឋិ ជាបំភ្លូពួកនៃទិដ្ឋិ ៦២ ព្រះអង្គទ្រង់គ្រាស់សំ-
ដែងទុកក្នុងសុត្តន្តបិដកនេះ ។ អភិធម្មបិដក ហៅថា នាមរូបបរិច្ឆេទកថា
ព្រោះការកំណត់នូវនាមនឹងរូប ជាសត្រូវដល់កិលេសមានរាគៈជាដើម
ព្រះអង្គទ្រង់សំដែងទុកក្នុងអភិធម្មបិដកនេះ ។

បិដកទាំង ៣ នេះ បើចែកតាមសិក្ខា មាន ៣ គឺ អធិសីលសិក្ខា ១
អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ វិនយបិដករាប់បញ្ចូលក្នុងអធិសីល-
សិក្ខា ពីព្រោះការសិក្សាការរៀនយកអធិសីល ព្រះអង្គទ្រង់សំដែងទុក

ដោយសេចក្តីពិសេសពិស្តារកន្លងនូវបិដក ។ សុត្តន្តបិដក ពាក់ព័ន្ធ
កន្លងអធិចិត្តសិក្ខា ព្រោះចាការសិក្សារៀនយកអធិចិត្ត ព្រះអង្គត្រាស់
សំដែងទុកក្នុងសុត្តន្តបិដក ។ អភិធម្មបិដក ពាក់ព័ន្ធកន្លងអធិប្បញ្ញាសិក្ខា
ព្រោះថាការសិក្សារៀនយកអធិបញ្ញា ព្រះអង្គត្រាស់សំដែងដោយ
សេចក្តីវិសេសកន្លងអភិធម្មបិដក ។

បើចែកតាមប្រភេទនៃការលះ មាន ៣ គឺ វិតិក្កមប្បហាន ១
បរិយុដ្ឋានប្បហាន ១ អនុសយប្បហាន ១ ។

វិតិក្កមប្បហាន (ការលះបង់នូវសេចក្តីល្មើស) ពាក់ព័ន្ធកន្លងវិនយ-
បិដក ព្រោះសីលមានការប្រព្រឹត្តកន្លងប្រព្រឹត្តល្មើសជាសត្រូវ ។
បរិយុដ្ឋានប្បហាន (ការលះបង់នូវទីតាំងរបស់កិលេស) ពាក់ព័ន្ធកន្លង
សុត្តន្តបិដក ព្រោះសមាធិមានបរិយុដ្ឋានក្តៅកិលេសជាសត្រូវ ។ អនុសយ-
ប្បហាន (ការលះបង់នូវអនុសយក្តៅកិលេស) ពាក់ព័ន្ធកន្លងអភិធម្មបិដក
ព្រោះបញ្ញាមានអនុសយ គឺធម៌ជាគ្រឿងដេកគាំក្នុងសន្តានជាសត្រូវ ។
មួយទៀត តទង្គប្បហាន (ការលះបង់នូវអង្គដោយអង្គ) ពាក់ព័ន្ធកន្លង
វិនយបិដក ។ វិក្ខម្ភនប្បហាន (ការលះបង់នូវកិលេសដោយការសង្កត់
សង្កិន) និង សមុច្ឆេទប្បហាន (ការលះបង់ឱ្យផុតផ្តាច់) ពាក់ព័ន្ធ
កន្លង សុត្តន្តបិដកនិងអភិធម្មបិដក ។

មួយទៀត ការលះបង់ខ្លួនចុះតែសង្គិលេស ពាក់ព័ន្ធក្នុងវិនយ-បិដក, តណ្ហាសង្គិលេសនឹងទិដ្ឋិសង្គិលេស ពាក់ព័ន្ធក្នុងសុត្តន្តបិដក នឹងអភិធម្មបិដក ។

ក្នុងបិដកមួយៗ មានគម្ពីរភោពហួនៗ គឺភាពជ្រាលជ្រៅដោយធម៌ ដោយអត្ថ ដោយទេសនា នឹងដោយបដិវេធ ។ ប៉ុន្តែ ហៅថា ធម៌, សេចក្តីអធិប្បាយរបស់ប៉ុន្តែនោះ ហៅថា អត្ថ, ការសំដែងពន្យល់ខ្លួនប៉ុន្តែនោះ ហៅថា ទេសនា (ព្រោះប៉ុន្តែជាសព្ទធាតុដែលបុគ្គលកំណត់ទុកដោយចិត្ត), ការយល់ច្បាស់តាមសេចក្តីពិតក្នុងប៉ុន្តែនឹងសេចក្តីរបស់ប៉ុន្តែ ហៅថា បដិវេធ ។

បរិយត្តិមាន ៣ យ៉ាង គឺ អលគទូបរិយត្តិ ១ និត្ថរណបរិយត្តិ ១ កណ្ឌាគារិកបរិយត្តិ ១ ។

បណ្តាបរិយត្តិទាំង៣នេះ បរិយត្តិដែលបុគ្គលកាន់យកមិនល្អ គឺរៀនដើម្បីហេតុមានការប្រណាំងប្រជែងជាដើម ហៅថា អលគទូបរិយត្តិ (បរិយត្តិប្រៀបដោយពស់មានពិស) មានសេចក្តីប្រៀបដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា: ម្នាលភិក្ខុទាំងឡាយ បុរសអ្នកត្រូវការដោយពស់មានពិស ។ល។ បុរសនោះឃើញខ្លួពស់មានពិសយ៉ាងធំហើយ ចាប់ខ្លួពស់នុ៎ះ ត្រង់ព្រេនក្តី ត្រង់កន្ទុយក្តី ពស់នោះនឹងងាកត្រឡប់ចឹក បុរសនោះត្រង់ដៃឬ ត្រង់ដើមដៃឬ ត្រង់អវយវៈតូចធំណាមួយ បុរសនោះ

និងដល់នូវសេចក្តីស្ងាប់ ឬ នូវសេចក្តីទុក្ខទៀបស្ងាប់, ដំណើរនោះព្រោះ
ហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះតែពស់ដែលខ្ជិនចាប់ហើយ
មិនល្អ មានឧបមាយ៉ាងណាមិញ; ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរស
ខ្លះក្នុងលោកនេះរៀនយកនូវធម៌ ។ល។ មោឃបុរសនោះរៀននូវធម៌
នោះមិនបានពិនិត្យនូវសេចក្តីរបស់ធម៌នោះដោយបញ្ញា ទាំងធម៌ទាំង
ឡាយនោះ ក៏មិនគួរដល់ការពិចារណាឃើញដល់ភិក្ខុទាំងឡាយនោះ
ដែលខ្ជិនមិនពិចារណានូវសេចក្តីដោយបញ្ញា ភិក្ខុទាំងឡាយនោះមានតែ
អានិសង្សតិចតែការប្រណាំងប្រជែងគ្នា មានអានិសង្សគ្រាន់តែរួចចាក
ពាក្យពោលថាជូច្នេះជូច្នោះឯង រៀនយកនូវធម៌ ។ មួយទៀត ភិក្ខុទាំង-
ឡាយរៀនយកនូវធម៌ដើម្បីប្រយោជន៍ឯណា ក៏មិនបានសំរេចប្រយោជន៍
នោះ ដល់ភិក្ខុទាំងឡាយនោះទេ; ធម៌ដែលភិក្ខុទាំងឡាយនោះរៀនហើយ
មិនល្អ រមែងប្រព្រឹត្តទៅតែមដើម្បីមិនជាប្រយោជន៍ . ទឹងសេចក្តីទុក្ខ
អស់កាលអង្វែង; ដំណើរនោះព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះ
ភាពនៃធម៌ដែលភិក្ខុរៀនមិនល្អហើយ ។

ឯបរិយត្តិឯណា ដែលភិក្ខុកាន់យកល្អហើយ គឺដែលភិក្ខុរៀន
ដោយចំណាំនឹងបំពេញនូវធម្មក្ខន្ធមានសីលក្ខន្ធជាដើម មិនមែនដើម្បី
ហេតុមានការប្រណាំងប្រជែងជាដើមឡើយ បរិយត្តិនេះ លោកហៅថា
និត្ថរណបរិយត្តិ ។

ពាក្យដែលព្រះដ៏មានព្រះភាគត្រាស់ទុកថា ធម៌ទាំងឡាយនោះ ដែលកិត្តុទាំងឡាយនោះកាន់យកល្អហើយ រៀនល្អហើយ តែងប្រតិបត្តិទៅតាមដើម្បីប្រយោជន៍ធំសេចក្តីសុខ អស់កាលជាអង្វែង; ដំណើរនោះព្រោះហេតុអ្វី? ព្រោះថាធម៌ទាំងឡាយនោះ កិត្តុរៀនយកល្អហើយ ។

ចំណែកឯព្រះវិណាស្រុត ដែលមានវន្តំណត់ឃ្លានហើយ មានកិលេសស្រាលបង់ហើយ មានមគ្គចំរើនហើយ មានអកុប្បធម៌ចាក់ធ្លុះហើយ មាននិរោធធ្វើឲ្យជាក់ច្បាស់ហើយ លោករៀនយកនូវបរិយត្តិឯណា ដើម្បីប្រយោជន៍វក្ខប្រវេណី ដើម្បីប្រយោជន៍វក្ខវង្ស ប៉ុណ្ណោះ; បរិយត្តិនោះ ហៅថា កណ្ឌាគារិកបរិយត្តិ ។

ពុទ្ធវចនៈ ៥ យ៉ាង

ពុទ្ធវចនៈទាំងអស់នោះ ចែកដោយនិកាយ មានប្រភេទ ៥ គឺ ទីឃនិកាយ ១ មជ្ឈិមនិកាយ ១ សំយុត្តនិកាយ ១ អង្គុត្តរនិកាយ ១ ខុទ្ទកនិកាយ ១ ។

ព្រះសូត្រ ៣៤សូត្រ មានព្រហ្មជាលសូត្រជាដើម ដែលលៅតបរួមទុកកងវគ្គ ៣ ហៅថា ទីឃនិកាយ ព្រោះជាទីប្រជុំ ជាទីលំនៅនៃក្រុមសូត្រមានប្រមាណវែង ។

ព្រះសូត្រ ១៥២ សូត្រ មានមូលបរិយាយសូត្រជាដើម ដែលលោកប្រមូលទុកក្នុងវគ្គ ១៥ មានប្រមាណ យ៉ាងកណ្តាល (មិនវែងពេក មិនខ្លីពេក) ហៅថា មជ្ឈិមនិកាយ ។

ព្រះសូត្រ ៧៧៦២ សូត្រ មានឧឃតរណសូត្រជាដើម ដែលតាំងទៅដោយអំណាចនៃធម៌មានទេវតាសំយុត្តជាដើម ហៅថា សំយុត្តនិកាយ ។

ព្រះសូត្រ ៨៥៥៧ សូត្រ មានចិត្តបរិយាយទានសូត្រជាដើម ដែលបិតនៅដោយអំណាចនៃអង្គមួយៗ ដ៏ក្រៃលែង ហៅថា អង្គុត្តរនិកាយ ។

ព្រះពុទ្ធវចនៈដ៏សេស គឺវិនយបិដក អភិធម្មបិដក ទាំងអស់ព្រមទាំងខុទ្ទកបាឋ ដែលមានប្រភេទ ១៥ ដូចបានសំដែងទុកហើយក្នុងខាងដើម លើកលែងតែនិកាយទាំង ៤ មានទីឃនិកាយជាដើមចេញ ហៅថា ខុទ្ទកនិកាយ ។

ព្រះពុទ្ធវចនៈមាន ៥ យ៉ាងដោយអំណាចនិកាយ ៥ ដោយប្រការយ៉ាងនេះឯង ។

ពុទ្ធវចនៈ ៩ យ៉ាង

សព្វមេវ ហិ៍ធំ សុត្តំ គេយ្យំ វេយ្យាករណំ គាថា ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លន្តិ នវប្បភេទំ

ព្រះពុទ្ធវចនៈទាំងនោះមានប្រភេទ ៩ យ៉ាង គឺ សុត្ត ១ គេយ្យ ១ វេយ្យាករណ ១ គាថា ១ ឧទាន ១ ឥតិវុត្តក ១ ជាតក ១ អព្ភូតធម្ម ១ វេទល្ល ១ ។

បណ្ណាសត្ថុសាសនៈទាំង ៩ ប្រការនោះ ចំណែកខាងទុកគោរពឆ្គ (គឺភិក្ខុវិកឆ្គ ភិក្ខុនីវិកឆ្គ) និងខ្មែស (ចូឡនិងខ្មែស មហានិងខ្មែស) ខន្ធក ៦២ បរិវារៈ ១៦ ពួកសូត្រមានមង្គលសូត្រ រតនសូត្រ នាលកសូត្រ ទីឃនខសូត្រជាដើមក្តី ពាក្យព្រះតថាគត ដែលបានមកថាសូត្រ ដទៃក្តី ហៅថា សុត្ត ។

ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ គឺសូត្រដែលមានបាលីរាយលាយច្រឡំដោយគាថា ហៅថា គេយ្យ ។

អភិធម្មបិដកទាំងមូលនឹងសូត្រដែលឥតមានគាថា ឬក៏ពុទ្ធវចនៈដទៃដែលលោកមិនសង្គ្រោះចូលដោយអង្គទាំង ៨ ហៅថា វេយ្យាករណៈ (ពាក្យបាលីរាយ) ។

ធម្មបទ ថេរគាថា ថេរីគាថា ទីឃនិកាយ ដែលមិនឲ្យឈ្មោះថាសុត្ត ក្នុងសុត្តនិបាត ហៅថា គាថា ។

ពួកព្រះសូត្រ ៤២ ប្រកបដោយគាថាអាស្រ័យសោមនស្សញ្ញាណ ហៅថា ឧទាន ។

ក្រុមព្រះសូត្រ ๑๑๐ ដែលប្រព្រឹត្តទៅដោយន័យថា "ឯវំ មេ សុតំ ពាក្យនេះពិតជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកហើយ" ហៅថា ឥតិវុត្តក ។

ជាតក ៥៥๐ មានអបណ្ណកជាតកជាដើម ហៅថា ជាតក ។

ព្រះសូត្រប្រកបដោយអច្ចរិយព្ភូតធម៌ទាំងអស់ ដែលប្រព្រឹត្តទៅដោយន័យមានដើមថា "ចត្តារោមេ ភិក្ខវេ អច្ឆរិយា អព្ភុតធម្មា អានន្ទេ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ๔ យ៉ាងនេះ អស្ចារ្យមិនធ្លាប់កើតមាន មានទៅកនឹងអានន្ទ" ហៅថា អព្ភុតធម្ម ។

ពួកសូត្រទាំងអស់ មានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហាសូត្រ សង្ខារភាជនីយសូត្រ ទីឃមហាបុណ្ណកសូត្រ ជាដើម ដែលបុគ្គលឮបានសួរនឹងសេចក្តីត្រេកអរត្រេកអរយ៉ាង សួរសាកដេញដោលខ្លឹងនឹង ហៅថា វេទល្ល ។

ព្រះពុទ្ធវចនៈមាន ๙ ដោយអំណាចនៃអង្គ ๙ ដោយប្រការយ៉ាងនេះ ។

ពុទ្ធវចនៈ ๘๔.๐๐๐

ព្រះពុទ្ធវចនៈទាំងអស់នោះ មានប្រភេទ ๘๔.๐๐๐ ដោយអំណាចនៃធម្មក្ខន្ធដែលលោកបំភ្លឺទុកយ៉ាងនេះថា:

ទ្វាសីតិ ពុទ្ធតោ កណ្ហា ទ្វេ សហស្សានិ ភិក្ខុតោ
ចតុរាសីតិសហស្សានិ យេ មេ ធម្មា បវត្តិនោ

ព្រះធម៌ឯណាដែលប្រព្រឹត្តទៅក្នុងហ្មួយនៃខ្ញុំ (ព្រះធម៌នោះ) មាន ៨៤.០០០ គឺព្រះធម៌ ៨២.០០០ ខ្ញុំរៀនយកអំពីព្រះពុទ្ធ, ២.០០០ រៀនអំពីភិក្ខុ ។

បណ្តាធម្មក្ខន្ធទាំង ឡាយនោះ ដែលនឹងកំណត់ដឹងថាជាធម្មក្ខន្ធមួយៗ គឺ ព្រះសូត្រ ដែលអនុសន្ធិតែមួយចាត់ជាធម្មក្ខន្ធ ១, ព្រះសូត្រណាមានអនុសន្ធិច្រើន ការរាប់ធម្មក្ខន្ធក្នុងព្រះសូត្រនោះ ក៏តាមអនុសន្ធិ (ច្រើនដែរ) ។

ក្នុងពួកគាថាពន្ធ លោកកំណត់ការសរសេរទុកប្រស្នាមួយ ចាត់ជាធម្មក្ខន្ធមួយ, ការវិស្សជ្ជនាមួយ ចាត់ជាធម្មក្ខន្ធមួយ ។

ក្នុងអភិធម្មវិញ លោកកំណត់ការចែកទុកតិក: ទុក:មួយៗ ឬការចែកទុកវារ:ចិត្តមួយៗ ចាត់ជាធម្មក្ខន្ធមួយ ។

ក្នុងវិន័យដែលមានវត្ថុ, មាតិកា, បទភាជនីយ, អន្តរាបត្តិ, អាបត្តិ, អនាបត្តិ នឹងការកំណត់ទុកតិក:, ធម៌ទាំងនោះ ចំណែកមួយៗ ចាត់ជាធម្មក្ខន្ធមួយៗ ។

ក្នុងបិដកទាំង ៣ នេះ ព្រះសូត្រមាន ២១.០០០ ព្រះធម្មក្ខន្ធ, ព្រះវិន័យមាន ២១.០០០ ព្រះធម្មក្ខន្ធ, ព្រះអភិធម្មមាន ៤២.០០០ ព្រះធម្មក្ខន្ធ រួបរួមជា ៨៤.០០០ ព្រះធម្មក្ខន្ធ ។

ព្រះពុទ្ធវចន:មាន ៨៤.០០០ ដោយអំណាចនៃធម្មក្ខន្ធ ដោយប្រការយ៉ាងនេះ ។

បឋមសង្គាយនា

កាលព្រះបរមគ្រូអរហន្តសម្មាសម្ពុទ្ធ ទើបនឹងទ្រង់រំលត់ខ័ន្ធចូលកាន់បរិនិព្វានទៅបានរៀង ៧ ថ្ងៃ កើតមានពាក្យចំរូងចំរែកក្នុងពុទ្ធសាសនាមណ្ឌលជាហេតុនាំឲ្យពួកអរហន្តវាល់ក្នុងកិច្ចសាសនា ទើបព្រះមហាកស្សបត្ថេរឆ្លៀតផ្តើមនាំព្រះអរហន្តទាំង ៥០០ អង្គ ធ្វើសង្គាយនាលើកសង្គាយនា ផ្ទៀងផ្ទាត់ធម្មវិន័យលែលកដាក់ទុកដោយពួក-ក្រុមថានេះព្រះវិន័យ, នេះព្រះសូត្រ, នេះព្រះអភិធម្ម, សំរេចសេចក្តីថា ធម្មិតធម្មិមែន ។

កាលធ្វើសង្គាយនាលើកនេះ ព្រះមហាកស្សបជាអ្នកបុច្ឆាព្រះវិន័យ-បិដក ចំពោះព្រះឧបាលី, បុច្ឆាព្រះសុត្តន្តបិដកនឹងព្រះអភិធម្មបិដកចំពោះព្រះអានន្ទ ព្រមដោយការកសង្ឃ សុទ្ធតែជាព្រះអរហន្តបដិសម្ភិទា ៥០០ អង្គ ធ្វើក្នុងសត្តបណ្ណគុហា ទៀបភ្នំវេភារបព៌តក្នុងនគរជគ្គិះ មានព្រះបាទអជាតសត្តុ ជាពុទ្ធសាសនូបត្ថម្ភក៍ អស់កាល ៧ ខែទើបសំរេច ។

ទុតិយសង្គាយនា

កាលព្រះអរហន្តទាំង ៥០០ អង្គ មានព្រះមហាកស្សបត្ថេរជាប្រធានបានធ្វើបឋមសង្គាយនារួចស្រេចហើយ ក៏គ្រប់គ្រងរក្សាព្រះពុទ្ធសាសនាតរៀងមកដរាបដល់អស់ព្រះជន្មបរិនិព្វានទៅរៀងព្រះអង្គ ។ ដល់ព្រះពុទ្ធសាសនាកាលកន្លងទៅបាន ១០០ ឆ្នាំ គ្រានោះ ពួកភិក្ខុជាកូនរបស់

អ្នកស្រុកវជ្ជីនាំគ្នាសំដែងវត្ថុដែលខុសចាកធម្មវិន័យ ១០ ប្រការថា ជាធម៌ ជាវិន័យ ។

ឯវត្ថុ ១០ ប្រការនោះ គឺ :

១ – កប្បតិ សិង្គីលោណកប្បេ អម្បិលដែលជាក់ខុកក្នុងក្អាក់ស្នែង ខុកឲ្យកន្ធឹងរាត្រីហើយយកមកឆាន់ជាមួយអាហារបិណ្ឌបាតបាន មិនត្រូវអាបត្តិ ។

២ – កប្បតិ ទ្វង្គុលកប្បេ ព្រះអាទិត្យជ្រៀតហើយប្រមាណពីរឆ្នាប់ ក៏គួរនឹងឆាន់របស់ជាយាវកាលិកបាន មិនត្រូវអាបត្តិ ។

៣ – កប្បតិ គាមន្តរកប្បេ កិកុមានសេចក្តីគិតថាអញនឹងចូលទៅកាន់ស្រុក ក៏ត្រូវធាន់អនតិរិត្តភោជនបាន មិនត្រូវអាបត្តិ ។

៤ – កប្បតិ អាវាសកប្បេ ទីអាវាសដែលនៅក្នុងសីមាជាមួយគ្នា កិកុសង្ឃនឹងធ្វើសង្ឃកម្មទាំងពួងផ្សេងគ្នាបាន មិនត្រូវអាបត្តិ ។

៥ – កប្បតិ អនុមតិកប្បេ កាលដែលនឹងធ្វើសង្ឃកម្មទាំងពួងមិនចាប់ចាំឲ្យជុំគ្នាទេ បើមកជល់មុន នឹងធ្វើសង្ឃកម្មមុនបណ្តើរទៅក៏បាន ឥតការសង្ស័យ ។

៦- **កប្បតិ អាចិណ្ណកប្បោ** សេចក្តីប្រតិបត្តិជាចរិតទំនៀមទំលាប់របស់បជ្ឈាយ៍ អាចារ្យ ទោះខុសក្តីត្រូវក្តី សិស្ស-នុសិស្សទាំងពួងត្រូវប្រតិបត្តិតាមបាន គឥតមានទាស់ ។

៧- **កប្បតិ អមជ្ជិតកប្បោ** ទឹកដោះស្រស់ដែលប្រែចាកភាពដើមហើយ តែមិនទាន់ក្លាយទៅជាទឹងឡើយ កិក្ខុគ្រាកចាកទីអង្គុយហើយ ឆាន់ទឹកដោះជាអនតិរិត្តបាន ។

៨- **កប្បតិ ជលោកី ថាតុំ តរុណាសុភ** សុរាដែលគេជាក់គ្រឿងស្រវឹងធ្យូគ្រាំជាមួយគ្នាហើយ តែនៅខ្សោយមិនទាន់ពេញជាទឹកស្រវឹងនៅឡើយ កិក្ខុឆាន់បាន ។

៩- **កប្បតិ អនុសនំ ឯសិឆនំ** សំពត់និស៊ីទនៈមិនបាច់ធ្វើឲ្យមានជាយ ក៏ត្រូវប្រើបាន មិនមានអាបត្តិឡើយ ។

១០- **កប្បតិ ជាតរូបរជតំ** កិក្ខុគួរទទួលត្រែកអរបំពោះមាសនឹងប្រាក់បាន មិនត្រូវអាបត្តិឡើយ ។

ព្រះយសត្ថេរ បុត្រតាកណ្ឌកព្រាហ្មណ៍ បានជាបការប្រព្រឹត្តិដូច្នោះ ក៏សង្គាយនាព្រះធម៌ គឺតបដិសេធ ជកវត្ថុ ១០ ប្រការនោះចោលចេញ ទើបនិមន្តទៅក្រុងវេសាលី ដើម្បីរម្ងាប់អធិករណ៍នោះ ។ សម័យនោះឯង ព្រះសង្ឃទាំងឡាយ បានសន្មតព្រះថេរ ៤ អង្គឲ្យទទួលការងារ ជាអ្នកពិភាក្សាសំរេចរឿងនោះ ហើយនិមន្តទៅកាន់វត្ត

ក៏លុកាកមក្រែងវៃសាលី ប្រជុំគ្នាជាសង្ឃសន្និបាតដំរះវត្ត ១០ ប្រការនោះ ហើយវិនិច្ឆ័យសំរេចសេចក្តីថាជាវត្ថុនុសាកពុទ្ធប្បញ្ញត្តិ នាំឲ្យកើតអាបត្តិ (ទោស) ដល់កិក្ខុអ្នកប្រព្រឹត្តកន្ទ ។ ក្នុងសង្គីតិកាវៈនេះ ព្រះវេតត្ថេរជាអ្នកបុច្ឆា ព្រះសព្វកាមីជាអ្នកវិសជ្ជនា ព្រមដោយព្រះសង្ឃជាអរហន្ត ចតុប្បដិសម្ភិទាញាណចំនួន ៧០០ អង្គ តាមរបៀបដែលព្រះអរហន្ត ៥០០ អង្គបានធ្វើមកហើយ មានព្រះបាទកាលាសោកពាជជាពុទ្ធសាសនូបត្ថម្ភក៍ ធ្វើ ៨ ខែទើបសំរេច ។

តតិយសង្គាយនា

ព្រះមហាថេរៈទាំង ឡាយ បានលើកទុតិយសង្គាយនារួចហើយរំពឹងមើលទៅកាលអនាគតឃើញថា ដំណាលទៅខាងមុខ រវាងព្រះពុទ្ធសាសនាកាលបាន ២១៨ ឆ្នាំ ព្រះបាទធម្មាសោកពាជនឹងទ្រង់ទុប្បត្តិឡើងក្នុងក្រុងបាតលីបុត្ត ហើយបានសោយរាជសម្បត្តិក្នុងសកលជម្ពូទ្វីប ទ្រង់មានព្រះទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ហើយនឹងញុំាងលាភសក្ការៈឲ្យប្រព្រឹត្តទៅ ម្ល៉ោះហើយពួកនិគ្រន្ថតិរ្ថិយ ដែលមានសេចក្តីក្រឹក្រលំបាកក្រៃថ្នាលាភសក្ការៈ នឹងលបចូលបួសប្រមប្នុំក្នុងពុទ្ធសាសនមណ្ឌល ហើយយកលទ្ធិរបស់ខ្លួនមកសំដែងអាងថាជាពុទ្ធសាសនា, កាលបើយ៉ាងនេះព្រះពុទ្ធសាសនា ឈ្មោះថាមានមន្ទិលធំតើតទៅទៀត ។

គ្រានោះ ព្រះបរមគ្រូបានឃើញថាតិស្សមហាព្រហ្ម អាចជំរុះមន្ទិលនោះបាន ទើបលោកហោះឆ្ពោះទៅកាន់ទេវលោកអាភស្សរាតិស្សមហាព្រហ្មឲ្យទទួលការៈ រួចហើយលុះត្រឡប់មកជាតំណាងព្រះសិក្ខាវៈនឹងព្រះពុទ្ធវង្ស ដែលមិនបានចូលកាន់សង្ឃសន្និបាតក្នុងទុតិយសង្គាយនាឲ្យទទួលការៈសំរេចឧបសម្បទាកិច្ច នឹង បង្រៀនព្រះបរិយត្តិធម៌ដល់តិស្សមហាព្រហ្ម ដែលនឹងបានមកកើតក្នុងត្រកូលនាឯមោគ្គលីព្រាហ្មណ៍ក្នុងកាលអនាគត ។

លុះដល់សម័យដែលតិស្សមហាព្រហ្មបានមកកើតក្នុងត្រកូលនាឯមោគ្គលីព្រាហ្មណ៍ហើយ ព្រះសិក្ខាវៈត្រូវជាអ្នកទទួលបំបួស ព្រះពុទ្ធវង្សជាអ្នកទទួលបង្រៀន ដរាបដល់ព្រះមោគ្គលីបុត្តតិស្សត្រូវបានជាសង្ឃប្ញាមោក្ខជាប្រធានរបស់សង្ឃក្នុងជំនុំនោះ ។ ដល់មកវេលាសម័យនៃព្រះបាទសិរីធម្មាសោកពាជ ក៏មានមន្ទិលកើតឡើងក្នុងពុទ្ធសាសនមណ្ឌលដូចសេចក្តីយល់របស់ព្រះសង្ឃតិតាចារ្យ ដែលបានពិចារណាឃើញគ្រប់ប្រការ, ព្រះសង្ឃបែកគ្នាខានឆ្នើៗបានសង្គាយនាអស់ ៧ វស្សា ព្រះបរមគ្រូតាំងពាជ្ឈានឹងជំរុះមន្ទិលព្រះពុទ្ធសាសនា ទើបឲ្យយោជាមាត្យអង្គើតចាប់ពួកនិគ្រន្ថ ផ្សឹកអស់រលីង ទុកតែព្រះសង្ឃដែលបរិសុទ្ធ ។ ទើបព្រះមោគ្គលីបុត្តតិស្សត្រេះជ្រើសរើសភេព្រះអរហន្ត ដែលមានបដិសម្ភិទាញាណវិបរកង្វាយក្នុងទីផ្ទៃព្រះត្រៃយបិដក ចានចំនួន ១.០០០ អង្គ

នាំគ្នាធ្វើសង្គាយនាលើក ព្រះពុទ្ធសាសនា ជាគ្រាទី ៣ ក្នុងអសោការាម ក្រុងប៉ាតលិបុត្រមហានគរ តាមដំណើរដែល ព្រះសង្គីតិកាចារ្យបុពាណ ប៉ានធ្វើមកហើយ មាន ព្រះប៉ាទសិរីធម្មាសោកជាសាសនូបត្ថម្ភក៍ អស់ កាល ៩ ខែទើបសំរេច ។

បត្តុទ្ទិសង្គាយនា

ព្រះមោគ្គលីបុត្តតិស្សត្ថេរប៉ានធ្វើតតិយសង្គាយនារួចហើយ រំពឹង មើលទៅកន្លងអនាគតឃើញថា ព្រះពុទ្ធសាសនា នឹងទៅប្រតិស្ឋានក្នុង បច្ចន្តប្រទេសទើបចាត់ ព្រះអរហន្តខ្លះណា ស្រុតឲ្យនាំ ព្រះពុទ្ធសាសនា ទៅ ប្រតិស្ឋានខ្លួនទៅប្រទេសផ្សេងៗ ។ ចំណែក ព្រះមហិន្ទត្ថេរប៉ានទទួល ថេរបញ្ជាឲ្យទៅប្រកាស ព្រះពុទ្ធសាសនាទៅនាលង្កាទ្វីប ឝ្ញាំង ព្រះប៉ាន ទៅនាមរាជតិស្សនឹងអ្នកលង្កាឲ្យមានសេចក្តីជ្រះថ្លា ។

គាថោះ ព្រះនាងអនុឡាដែលជាជាយារបស់ ព្រះមហាទាគទបរាជ ជា ព្រះរាជអនុជាមានប្រាថ្នាចង់បព្វជ្ជាជាភិក្ខុនី ។ ព្រះប៉ានក្រុងលង្កាទ្វីប បញ្ជូនរាជទូតទៅក្រុងប៉ាតលិបុត្ត ដើម្បីគ្រាបទូល ព្រះប៉ានធម្មា-សោកពាជ សូមអាពាធនា ព្រះសង្ឃមិត្តាថេរី ព្រះរាជធីតាមកសំរេចកិច្ច ឧបសម្បទា ដល់ស្ត្រីជាតិសីហឡៈ នឹង សូមអញ្ជើញមែក ព្រះមហា-ពោធិព្រឹក្សមកផង ព្រះអង្គក៏ទ្រង់ ព្រះរាជានុញ្ញាតតាម ។

កាលព្រះពុទ្ធសាសនារុងរឿងឡើងហើយ ព្រះចាវខេត់នម្បាយតិស្សត្រាស់សួរព្រះមហិន្ទត្ថេរថា ព្រះពុទ្ធសាសនាបានឈ្មោះថាប្រតិស្ឋានសិប់ក្តីនោះហើយឬនៅ? ព្រះថេរថ្វាយព្រះពរថា ព្រះពុទ្ធសាសនាដែលនឹងបានយាងចុះសិប់សូន្យ លុះតែបានលើកដម្កើងម្តើងព្រះធម្មវិន័យ។ ស្តេចក៏ប្រារព្ធដើម្បីនឹងធ្វើសង្គាយនា ទើបទ្រង់អារាធនាព្រះមហិន្ទត្ថេរជាអ្នកបុច្ឆា ព្រះអរិដ្ឋមហាថេរជាអ្នកវិសជ្ជនា។ ព្រះសង្ឃស្រុកលង្កាបានសូត្រវៀនចេះចាំព្រះពុទ្ធវចនៈ បែកធ្លុះធ្លាយតតមានសល់ចំពាក់ខាក់ខែសអាចជាគណាបាមោក្ខ ប្រៀនប្រដៅកុលបុត្រកុងក្តីនោះបាន ល្មមសន្និដ្ឋានថា ព្រះពុទ្ធសាសនាមានឫសចុះសិប់កុងក្តីនោះមែន។

សង្គាយនាគ្រានោះ បានធ្វើនៅកុងថូបារាមកុងអនុរាធបុរី ដោយគណសង្ឃ ៦៨ ០០០អង្គ មានព្រះចាវខេត់នម្បាយតិស្សជាសាសនូបត្ថម្ភក៍ អស់កាល ១០ ខែទើបសំរេច កុងវាង ព្រះពុទ្ធសករាជ ២៣៦ វស្សា។

បញ្ចមសង្គាយនា

ព្រះចាវខេត់នម្បាយតិស្សក្សត្រកុងលង្កាទ្វីប ទ្រង់មានបុញ្ញានុភាពប្រកបដោយបញ្ញាច្រើនបានបំពេញព្រះរាជកុសលផ្សេងៗ ជាអនេកហើយស្តេចទិវង្គតទៅ។ បន្ទាប់អំពីនោះមក ព្រះចាវទត្តិយៈ, ព្រះចាវមហាសិវៈ នឹង ព្រះចាវសុរតិស្ស បានសោយរាជ្យជាលំដាប់គ្នាហើយទំនុកបម្រុងព្រះពុទ្ធសាសនាតរៀងមក។

ចំណេរចិរកាលមកខាងក្រោយ វង្សក្សត្រិយ៍តែលង្កាខ្វះចេះតែខ្វះ
គ្រោះថ្នាក់អំពីបច្ចាមិត្តរឿយៗ រហូតដល់ផ្ទាស់ពាជវង្ស ម្ល៉ោះហើយព្រះ
ពុទ្ធសាសនាចេះតែលិចអណ្តែត ។ ទៅតាមវង្សក្សត្រិយ៍ដែលជះថ្នាំនឹងមិន
ជះថ្នាំ ។

ដល់មកសម័យព្រះបាទវត្តគាមិនីអភ័យ ឃានកំចាត់បច្ចាមិត្តអស់
ហើយទ្រង់ឃានសោយរាជ្យសប់សូន្យជាក្សត្រិយ៍ឯករាជ្យ ទ្រង់ឃានសាងវត្ត
អភយគិរីវិហារគេនព្រះតិស្សត្ថេរ ព្រមទាំងទំនុកបម្រុងដោយចតុប្បច្ច័យ
បរិបូណ៌ ជាហេតុនាំឲ្យព្រះសង្ឃមហាវិហារកើតសេចក្តីច្រណែនលើក
ទោសព្រះតិស្សត្ថេរថា ចូលចិត្តដោយគហស្ថ ។ ខណៈនោះ
ព្រះសង្ឃបែកគ្នាជា ២ ពួក គឺពួកខាងមហាវិហារ នឹងពួកអភយគិរីវិហារ ។

កាលសម័យនោះ ពួកព្រះសង្ឃដែលមានប្រាជ្ញា ឃើញហេតុ
ដែលនាំឲ្យសាបសូន្យព្រះពុទ្ធសាសនា ទើបនាំគ្នាលើកសង្គាយនា
ជាគ្រាទី ៥ គឺ ចារឹកព្រះត្រៃបិដកជាភាសាអក្សរជាក់ក្នុងស្លឹករឹតជាលើកដំបូង
ដែលប្រើអក្សរជាគ្រឹងកត់ត្រាព្រះពុទ្ធវចនៈ ។

សង្គាយនាលើកនេះ ធ្វើក្នុងមហាវិហារ នាលង្កាទ្វីប មានការកេ-
សង្ឃពាន់អង្គ មានព្រះពុទ្ធទត្តត្ថេរជាប្រធានជាអ្នកបុច្ឆា ព្រះតិស្ស-
ត្ថេរជាអ្នកវិសជ្ជនា មានព្រះបាទវត្តគាមិនីអភ័យជាពុទ្ធសាសនូបត្ថម្ភក៍
អស់កាល ១ ឆ្នាំទើបសំរេច ។

ដំណឹងពុទ្ធសាសនាក្នុងជាតិប្រទេស

ហ្ជិនិពន្ធមន្ត្រី ញ៉ុក-ថែម រៀបរៀង

រឿងរ៉ាវ ឬ ដំណឹង ព្រះពុទ្ធសាសនាដែលមានសេចក្តីផ្សាយក្នុងឯកសារបស់ប្រទេសនានានោះ នៅក្នុងស្រុកខ្មែរយើងនេះ ពួកពុទ្ធសាសនិកជនមិនសូវបានដឹងពីរឿងរ៉ាវដែលយើងនាំយកមកផ្សាយនេះ ពិតមែនតែមានសេចក្តីផ្សាយក្នុងឯកសារស្រាវជ្រាវរួចហើយ ប៉ុន្តែពួកសាសនិកជននៅស្រុកអាយ នៅមិនទាន់បានជ្រាបពាល់គ្នា ក៏គួរតែនាំយកមកចុះផ្សាយខ្លះដែរ ដូចមានរៀបរាប់ក្តីសារសំខាន់តទៅនេះ :

សមាគមមហាពោធិ ជាពុទ្ធិកសមាគមយ៉ាងធំ ១ ដែលតាំងមន្ទីរចាត់ការរបស់សមាគមនៅស្រុកកល្កុត្តា ប្រទេសឥណ្ឌា, កាលមុនកើតយុទ្ធភ័យខ្មៅងងឹតក្នុងលោក សមាគមនេះបានចាត់វិធីអង្គុំសង្ឃនាយកាសអំពីពួកពុទ្ធសាសនិកជនខ្មែរនៅក្នុងលោក ដើម្បីយកទៅជួសជុលចេតិយស្ថានយ៉ាងសំខាន់បំផុត ដែលហៅថាមហាវិហារពុទ្ធគយា តាំងនៅក្នុងស្រុកគយា ខែត្តពិហារ ប្រទេសឥណ្ឌា ។

ទីតំបន់នេះហើយ ក្នុងសម័យពុទ្ធកាល ហៅថា "ឧរុវេលាសេនានិគម" តាំងនៅក្នុងដែនមគធៈ ជាកន្លែងត្រាស់ដឹងព្រះបរមាគិសេក-

សម្ងាសម្តែងធិញ្ញាណរបស់ព្រះបរមសាស្តា ទើបគួរជាទីគោរពនមស្សការនឹងធ្វើសក្ការបូជានៃពួកពុទ្ធបរិសទ្យ ចាត់ជាសំវេជនីយស្ថានដ៏សំខាន់ ១ ក្នុងសំវេជនីយស្ថានទាំង ៤ អង្គ្វើ ។

ព្រះវិហារពុទ្ធគយានេះ អំពីដើមនោះគេសាងជាអង្គព្រះស្តូបសណ្ឋាន ៤ ជ្រុង រៀវស្រែចង្វើងទៅលើមាន ៨ ជាន់ ។ គ្រាមមានរបៀងព័ទ្ធជុំវិញ ទៅជ្រុងទិសទាំង ៤ មានវិហារមួយ ៗ ទៅគ្រប់ទិសទាំង ៤ តែមានទំហំតូច ។ ទៅរមែរបៀងមានចេតិយតូចរៀងរាយទៅ ។

តាមរឿងភ័ព មានសេចក្តីតំណាលថា ព្រះបាទធម្មាសោកពាជ ទ្រង់កសាងឡុកមកជាពុទ្ធបូជា កាលពីពុទ្ធសករាជ ២៧៤ ដើម្បីជាទីកត់សំគាល់កន្លែងត្រាស់ដឹងនៃព្រះពុទ្ធជាម្ចាស់ ។

លុះអំណើះកាលតមកជាវេលាជាង ១០០ ឆ្នាំ ប្រាកដតាមសេចក្តីកត់ហេតុរបស់សមណទូតចិនដែលបានត្រចៀនមស្សការបូជនីយស្ថានដល់កន្លែងនោះ ថាព្រះវិហារពុទ្ធគយា គេបោះបង់ចោលមានតែព្រៃជុះឡបឡុល ជាទីលំនៅនៃសត្វព្រៃ លុះអំណើះកាលជាយូរអង្វែងមកទៀត ដល់ពុទ្ធសករាជ ១១៧២ ទើបមានសមណទូតចិនចូលទៅប្រទេសឥណ្ឌាទៀត ដើម្បីនមស្សការបូជនីយស្ថាន នឹងសិក្សាវិជ្ជាចំពោះកន្លែងព្រះពុទ្ធសាសនា ប៉ានពោលថា ព្រះវិហារពុទ្ធគយានេះ គេប៉ានជួសជុល ប៉ានល្អឡើងវិញហើយ ។

លុះមកដល់ ព. ស. ២៤០៦ ព្រះវិហារពុទ្ធគយា គេឃើញថាមានចួចខាតបាក់បែកទៅជាច្រើន ទើបពួកពុទ្ធបរិសទ្យ ជាតិភូមាបានចាត់ការជួសជុលក្នុង ព. ស. ២៤២០ ។ តមកគ្រោយទៀត ព្រះវិហារពុទ្ធគយា ក៏ប្រែប្រួលត្រឡប់ទៅជាទេវគ្រោមត្រួតត្រារបស់ពួកហិណ្ឌូវិញ ដែលហៅថា ពួកមហន្ត ជាចៅអធិការបែកខាងសាសនាហិណ្ឌូ (ព្រាហ្មណ៍) ក្នុង ព. ស. ២៤៣៤ ។ តមកពួកក្រុមជំនុំគណៈជាតិឥណ្ឌូបានប្រជុំព្រមព្រៀងគ្នាថា ត្រូវឲ្យពួកពុទ្ធបរិសទ្យមានសិទ្ធិអំណាចបូលទៅនមស្សការស្ថានទីនោះបាន ហើយពួកក្រុមអភិបាលជាអ្នកចាត់ការរក្សាទីនោះ ត្រូវមានហិណ្ឌូ ៥ នាក់ ពុទ្ធបរិសទ្យ ៥ នាក់ជាដរាប គឺថា ព្រះវិហារពុទ្ធគយា ត្រឡប់បានមកជាសម្បត្តិរបស់ពួកពុទ្ធសាសនិកជនឡើងវិញទៀត ។

ឯពួកមហន្តជាចៅអធិការខាងហិណ្ឌូ ក៏នាំគ្នាខឹងតាស់ហើយតវ៉ាថា ព្រះវិហារពុទ្ធគយា គោងជារបស់ហិណ្ឌូ ព្រោះព្រះពុទ្ធជាអម្ចាស់ទុកជាព្រះនារាយន៍ ពួកអ្នកបូជាហិណ្ឌូ តែងថ្វាយបង្គំបិណ្ឌ (ដុំបាយ) ដល់ព្រះពុទ្ធជាម្ចាស់ ដ៏ជាបុព្វបុរសរបស់ខ្លួនរហូតមក ហើយបានស្នើតាលសំខាន់ៗ ឲ្យក្រុមជំនុំពិនិត្យដូច្នេះ :

១ — វត្ថុនេះតសាងឡើងដោយស្នាដៃពួកហិណ្ឌូ ឬ ពួកពុទ្ធបរិសទ្យ?

២ — ព្រះពុទ្ធជាម្ចាស់ស្ថិតនៅក្នុងអាណាព្យាបាលរបស់ហិណ្ឌូកន្លងតំណែងណា?

៣— ឥឡូវនេះ ពួកហិណ្ឌូ ឬពួកពុទ្ធបរិស័ទ្ធ ដែលជាអ្នកគោរពបូជាព្រះពុទ្ធជាម្ចាស់ដោយសេចក្តីជ្រះថ្លាពិតៗ ?

៤— អំណាចតាមច្បាប់របស់ពួកមហន្ត នឹងពួកពុទ្ធបរិស័ទ្ធនោះដូចម្តេច ?

ទុកជាយ៉ាងណាក៏ដោយ ក្រុមជំនុំគណៈជាតិឥណ្ឌូ ប្រាថ្នាជំនុំព្រមឲ្យសេចក្តីយុត្តិធម៌ដល់ពួកពុទ្ធបរិស័ទ្ធយ៉ាងល្មមសមគួរ ព្រោះតាមធម្មតានោះ ស្រុកម៉ក្កៈជាស្ថានសំខាន់របស់ពួកមូស្លីមយ៉ាងណា ? ស្រុកអយោធ្យាជាស្ថានសំខាន់របស់ពួកហិណ្ឌូយ៉ាងណា ? ស្រុកសេរូសាឡែមជាស្ថានសំខាន់របស់ពួកគ្រិស្តាំងយ៉ាងណា ? ព្រះវិហារពុទ្ធគយា ក៏ត្រូវជាស្ថានដ៏សំខាន់របស់ពួកពុទ្ធបរិស័ទ្ធយ៉ាងនោះដែរ ។

កន្លងការស៊ុំសិទ្ធិអំណាចអំពីរដ្ឋបាលគណៈនោះ ពុទ្ធិកសមាគមមហាពោធិ ប្រាថ្នាខ្លួលសេចក្តីយល់ព្រមនឹងសេចក្តីត្រែកអរអនុមោទនាអំពីមនុស្សសំខាន់ៗ ទាំងជាតិគណៈនឹងជនជាតិទូរុប ដូចមានបញ្ជាក់ស្រាយសង្ខេបៗ តទៅនេះ :

១— មហាត្មគន្ធី ពោលថា :

“ មិនបាច់ឆ្ងីឆ្ងល់យ៉ាងណាទៀតឡើយ វត្តពុទ្ធគយាគួរឲ្យមកជាកម្មសិទ្ធិរបស់ពួកពុទ្ធសាសនិកជន . . . ខ្ញុំខ្ញុំឯងក៏ស្ម័គ្រចិត្តជួយចង់ឲ្យពួកពុទ្ធសាសនិកជនបានវត្តនេះ ត្រឡប់មកវិញដែរ . . . ”

២ — ដូកចំនួនពីនេះ ថ្នាក់តាគោរ ពោលថា : "ខ្ញុំឯងឆ្ងឿខុកចិត្ត ថា ពួកអ្នកកាន់សាសនាហិណ្ឌូទាំងអស់ ដែលជាអ្នកថ្លាប់ខ្ពង់កងសីល-ធម៌របស់ខ្លួន គោងយល់ព្រម (បែងចែកសុំទ្វីកងវត្តពុទ្ធគយា) ឲ្យ ពួកពុទ្ធបរិស័ទ្ធខ្លះ ព្រោះមិនគួរបណ្តោយឲ្យវត្តដែលគេបានកសាងឡើង នៅកន្លែងត្រាស់ដឹងរបស់ព្រះពុទ្ធ ធ្លាក់ទៅនៅក្រោមអំណាចអ្នកកាន់ សាសនាដទៃឡើយ ហើយជាពួកមិនបានសិក្សាវិន្ធាពុទ្ធសាសនាយ៉ាងមុតមាំ ទាំងមិនមានសេចក្តីគោរពយ៉ាងមុតមាំចំពោះពុទ្ធសាសនាផង ទាំងមិនបានធ្វើពុទ្ធបូជាតាមប្រពៃណីព្រះពុទ្ធសាសនាផង . . . "

៣ — លោកទាសពន្ធ បានឆ្លើយសេចក្តីក្នុងសារលិខិតមួយ ដែលសុំសួរពីសេចក្តីយល់ឃើញរឿងវត្តពុទ្ធគយាថា : "ខ្ញុំមានសេចក្តី យល់ឃើញតែមួយផ្លូវថា វត្តពុទ្ធគយាជាសម្បត្តិរបស់ពុទ្ធសាសនិកជន ខ្ញុំមានបំណងចង់សុំឲ្យពួកហិណ្ឌូ លើកប្រគល់វត្តនេះឲ្យទៅពួកពុទ្ធសា-សនិកជនគ្រប់គ្រង ឬដោយហោចទៅ កុំទទឹងនាស់ការធ្វើសក្ការបូជា តាមបែបប្រពៃណីរបស់គេឡើយ "

៤ — សៀរអិតវិន អាវរនោលត៍(១) ពោលថា : "ខ្ញុំធ្លាប់ឃើញប្តឹង ដល់រដ្ឋបាលតំណាងទឹងប្រមុខជនជាតិហិណ្ឌូ អំពីការប្រុងប្រយ័ទ្ធ ទីដ៏មានកិត្តិយស ក្នុងប្រវត្តិនៃបរមត្ថវិន្ធារបស់ជនជាតិតំណាងឡាយ

(១) លោកនេះជាជនជាតិអង់គ្លេសមានសេចក្តីទ្រឹះថ្លាម៉ាំក្នុងព្រះពុទ្ធសាសនា ។

តាំងអំពីខោះមកខ្ញុំក៏តាំងចិត្តចាំមើលថា កាលណាទើបវត្តនឹងឧបការៈបស់វត្ត ឬនមកខោះក្នុងការគ្រប់គ្រងរបស់ពួកពុទ្ធបរិស័ទ្យវិញ . . ."

៥ — ម៉ាជាមគារលេក្សរ៍ជ្រាជាវិតនីល[1] ពោលថា : " ចុះខោះមានបុគ្គលណាមួយសោត អាចប្រើមនោគតិះរៀបចំគោលនៃវិរិយៈនឹងការជឿខ្ជួនឯងឲ្យខ្ពស់ជាង ឬឲ្យជាប់ចិត្តជាង្រហៀបបែបបទរបស់ព្រះសិទ្ធាច៍គោតម:បរមសាស្តា ដែលខ្ញុំងឹឬនគិតសម្រេចខោះក្រាមដើមពោធិព្រឹក្សខោះតំបន់ពុទ្ធគយានេះ ?

អ្នកគោរពព្រះអង្គនឹងពួកសាវកព្រះអង្គ តែងមានសេចក្តីជឿនឆ្ងល់មិនឬត់ ដែលឃើញអ្នកកាន់សាសនាឯទៀតមកមានអំណាចគ្រប់គ្រងទីកន្លែងដែលខ្ជួនប្រកាន់ជឿជាក់ថា ជាតំបន់ដែលព្រះសាស្តារបស់ខ្ជួនឬនត្រាស់ដឹងសម្រេចផលដ៏ខត្តម តំបាត់បង់ការជឿប្រកាន់ជោគជតានឹងជឿខ្ជោចបិសាចឬនជាប់ស្រឡះបាកសន្តានរបស់ព្រះអង្គ ។ ល ។

៦ — បណ្ឌិត រិធសេខរ: កដ្ឋាចារ្យ ជាចាងហ្វាងវិស្វកាវតិមហាវិទ្យាល័យស្រុកពលបុរ:[2] ពោលថា:" សុំឲ្យពួកយើងជាតិហិណ្ឌូតាំងពួង ចូរនាំគ្នាត្រិះរិនពិនិត្យពាក្យសួរអំពីរឿងវត្តពុទ្ធគយា ដោយគំនិតដ៏

---

១ ជាស្ត្រីជាតិយាវ៉ាងសែស ជាអ្នកត្រែចស្ទែងរកចំណេះចេះដឹងនៅអាស៊ីខាងកើតឆ្ងាយដើរទៅប្រែទេសចិន ឥណ្ឌូ ទិបេត ។

២ មហាវិទ្យាល័យ នៅក្រោយនបត្តកម្មរបស់ពៅខ្ញុំតាថ ពាពោរ ជាទីទទួលអ្នកសិក្សាអ៊ីនវើសជាតិវើសសាសនាឡើយ ។

ស្អាតផូរផង់ធុះខ្ពង់ត្រង់តំណាលបេះដូងរបស់យើង កុំបីមានចិត្តច្រែកថា ដោយអាឃាតព្យាបាទឡើយ គង់តែនឹងមើលឃើញសេចក្តីពិតថាមានតែពួកពុទ្ធសាសនិកជនប៉ុណ្ណោះទេ ដែលសមគួរជាងពួកយើង ក្នុងការថែរក្សាត្រង់ត្រង់បូជនីយស្ថានទៅតំបន់នេះ" ។

៧— លោក ដ. ន. សេន (D N Sen) បានហ្វាន់វិទ្យាល័យ-ពិហារណាស្បូណាល់ នៅស្រុកឋតន: (១)

លោកនេះថ្លង់យោបល់យល់ឃើញវែងឆ្ងាយ តែបើរួមសេចក្តីខ្លី ។ ទៅថា "រឿងអ្នកកសាងពុទ្ធគយាក្តី អ្នករក្សាត្រង់ត្រង់ក្តី មិនមែនជារឿងធម្មតាដែលតាមតែនិយាយឲ្យផុតពីមាត់ទៅបានទេ តោងមណ្ឌល-ស្ថាន (កន្លែងព្រះមហាបុរសបានត្រាស់សម្មាសម្ពោធិញ្ញាណ) ជាតំបន់សំខាន់បំផុតក្នុងប្រវត្តិសាស្ត្រ ជាកំណើតនៃអារ្យធម៌របស់តណ្ហៀ ល្មមបើកឡើងអួតបាន ទាំងអ្នកកាន់ពុទ្ធសាសនា ទាំងមិនមែនអ្នកកាន់ពុទ្ធសាសនា ដូចេះពួកហិណ្ឌូសាសនិក:ទើងពួកពុទ្ធសាសនិក:នៅវ៉ាទគ្នាធ្វើអ្វី ព្រោះខ្លួនខ្ញុំឯងក៏ធ្លាប់បានឃើញទេវរូបជាចំនួនច្រើនខាងសាសនាហិណ្ឌូ ទើងបូជនីយវត្ថុឯទៀត ។ មាននៅក្នុងពេងទុបោសថវិហារ ក្នុងវត្តកូឡូម្ប៊ូ កោះលង្កា សឲ្យឃើញថា ពួកពុទ្ធសាសនិក: ក៏មានសេចក្តីជ្រះថ្លាក្នុង

---

១ អំពីដើមហៅថាក្រុងបាតលីបុត្រ ក្នុងសម័យព្រះបាទធម្មាសោក

សាសនាព្រាហ្មណ៍ដែរ ដូច្នេះសូមឲ្យពួកហិណ្ឌូអនុញ្ញាតឲ្យពួកអ្នកកាន់ព្រះពុទ្ធសាសនា បីបាច់រក្សាបូជនីយស្ថានដ៏បរិសុទ្ធរបស់គេផងចុះ ។

ក្រៅអំពីបុគ្គលសំខាន់ៗ ដែលបានចេញឈ្មោះមកខាងលើនេះ នៅមានមនុស្សសំខាន់ៗ ឯទៀតជាច្រើន ដែលបានយល់ឃើញដល់ចិត្តគំនិតដ៏ល្អបរិសុទ្ធរបស់ពួកពុទ្ធសាសនិកជន តែយើងមិនចាំបាច់នាំមកថ្លែងក្នុងទីនេះដោយសព្វគ្រប់ទេ ។

ហេតុដែលយើងនាំយករឿងព្រះមហាវិហារពុទ្ធគយាមកសំដែងនេះ ដើម្បីបង្ហាញឲ្យឃើញដម្រែរបស់ព្រះពុទ្ធសាសនាប៉ុណ្ណោះ ព្រោះព្រះពុទ្ធសាសនារបស់យើង ជាសាសនាពិតបរិសុទ្ធមិនមានក្នុងក្រៅ ជាសាសនាត្រង់ ត្រូវតាមគន្ធវិទ្យាសាស្ត្រ ទើបជាហេតុឲ្យជនជាតិដទៃកាន់សាសនាដទៃ ក៏គោរពទួលព្រះពុទ្ធសាសនារបស់យើងនេះដែរ ។

មួយវិញទៀត ជនជាតិឥណ្ឌាក្នុងសម័យសព្វថ្ងៃនេះ គេច្រើនតែកាន់លទ្ធិសាសនាព្រាហ្មណ៍ ឬធ៌សាសនាមោហាម៉ែត តែមានពួកអ្នកកាន់លទ្ធិសាសនាទាំងពីរនេះ ខ្លះបែរទៅមានចិត្តឈឺឆ្អាលនឹងចង់ជួយឲ្យបូជនីយស្ថានសំខាន់ របស់ព្រះពុទ្ធសាសនាធ្លាក់មកនៅក្នុងការគ្រប់គ្រងរក្សារបស់ពួកពុទ្ធសាសនិកជនវិញ នេះក៏សឲ្យឃើញថា ព្រះពុទ្ធសាសនាជាសាសនាផ្លូវផងដ៏បរិសុទ្ធ ជាពន្លឺនៃដួងវិញ្ញាណរបស់មនុស្សលោកបានពិតប្រាកដមែន ។

តាមដោយពិតនោះ ពុទ្ធសាសនិកជនខ្មែរ ដែលបានប្រគល់កាយថ្លាយខ្លួនដល់ព្រះរតនៈត្រៃហើយ តាំងបានសិក្សាចំណេះវិជ្ជាក្នុងព្រះពុទ្ធសាសនា ឲ្យានចេះដឹងច្រើនហើយ ៖ មែនមានចិត្តរីករាយក្សេមក្សាន្តក្នុងចិត្ត មិនដែលកើតចិត្តក្តៅក្រហាយស្តាយក្រោយ ពីព្រោះតែប្រតិបត្តិតាមគន្ថធម្មាប់របស់ព្រះពុទ្ធសាសនានេះឡើយ ហេតុនេះហើយបានជាពុទ្ធសាសនិក: ដែលចេះដឹងពិតៗ មិនដែលងាកចិត្តលះបង់ចោលព្រះពុទ្ធសាសនា ហើយទៅកាន់លទ្ធិសាសនាដទៃ ដោយសេចក្តីជ្រះថ្លាពិតៗ នោះស្មើតែមិនមានសោះឡើយ ។

ស្រុកខ្មែរ - កម្ពុជា ជាដែនមានកត្តាសំណាងធំ ដែលបានគោរពលទ្ធិពុទ្ធសាសនាដ៏បរិសុទ្ធ តាំងអំពីបុព្វបុរសហូតមកដល់សម័យនេះ ហេតុនេះ សូមពុទ្ធសាសនិកជនខ្មែរជាតិតាំងឡាយ នាំគ្នាសិក្សានឹងប្រតិបត្តិតាមព្រះពុទ្ធោវាទ នឹងនាំគ្នាជួយទំនុកបម្រុងព្រះពុទ្ធសាសនា ឲ្យកាន់តែចំរើនរុងរឿងឡើងជាកិយ្យាកាពតទៅអនាគតកាលហោង ។

ចប់តែប៉ុណ្ណេះ

កែពាក្យខុសក្នុងកម្ពុជសុរិយា

ឆ្នាំ ១៩៤៩ លេខ ១២

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
និយាយប្រាជ្ញព្រែងអ្នកឆ្លាត	និយាយប្រាជ្ញព្រែងអ្នកឆ្លាត	៧៧២	៣
ទម្រាំបងាត្រូវបច្ចុប្បន្ន	ទម្រាំបងាត្រូវបច្ចុប្បន្ន	៧៧៣	៥
ចោកឮកខ្ញុំលំខ្ញើយមើលឲ្យច្រិះ	ចោសឮកខ្ញុំលំខ្ញើយមើលឲ្យច្រិះ	៧៧៨	២
ត្រាប់មាន់ប្រាជ្ញស្តីកាន់សច្ច	ត្រាប់មាន់ប្រាជ្ញស្តីកាន់ទៀងភាប់	៧៧១	១១

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀ អក្សរសាស្ត្រ ចោះក្នុងផ្សាយ
នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក ភ័យ-ប៊ុក ក្រែមការ
នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសង្គា: ស្ង-ហាយ
ក្រុមដំទុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

អ្នកអក្សរសាស្ត្រ	បញ្ហៅក្បៀង	ទំព័រ
លោក ភ័យ-ប៊ុក ក្រែមការ:	សុភាសិតអង់ខ្មែរ	៨១
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម	ស័ព្ទថ្មកាំនប្រៃដាខ្មែរ (តទៅ)	៨៤
អ្នកឧកញ៉ាទេពពីទូ		
ឈឹម-ក្រៃសេម	ព្រះរាជពង្សាវតារ ប្រទេសកម្ពុជា (តទៅ) ..	៩៥
លោក សាង-សាវ័ត	ប្រឹងត្រឹងភូមា (តទៅ)	១១៦
រំបលាជសេនា ខ្ង-ភេ	សាមកុក (តទៅ)	១១៧
ព្រ.ឃ្លាំងខេង	ភោគកុលកុមារ (តទៅ)	១២៤
។ម-សុ។ ហៅ		
។	ការច្នៃតស្លែវ	១៣៥
ប៉ . សាត់	រយៈនេសាទត្រី	១៣៧
	សនា	
លោក ភ័យ-ប៊ុក ក្រែមការ	ពន្ធូអាស៊ីទ្វីប (តទៅ).....	១៤១
ឃុនបណ្ណាគុរក្ស ប៊ូ-ប៊ី	កុំបាចនឹងភ្លក់ត្រាសឲ្យល់	១៤៨
ក្រសួងធម្មការ:	បញ្ជីឈ្មោះនាមចៅគណាធិការដែលតាំងថ្មី (តទៅ)..	១៥៤

សុភាសិត អង់គ្លេស

PROVERBES ANGLAIS

លោកព័ឃ - ប៊ុក ក្រមការ កត់ស្រង់ រៀបរៀង

១— សេចក្តីសុចរិតជាមធ្យោបាយមួយយ៉ាងវិសេស ដើម្បីទទឹងទៅ
តាន់សួស្តីជោគជ័យនឹងពលភាព ។

ខាងមីស្សក្ខាភ័ក្ខងង់

" សុចរិតប្រសើរ ប្រកបដំណើរ ឲ្យបានជោគជ័យ សុចរិតគុណ
គាប់ ពលចិត្តប្រស័យ បណ្ដិតនិស្ស័យ យកជាច្បាប់ប្រាណ " ។

២ — មិនត្រូវកត់ចំណាំបុណ្យគុណដែលលោកបានធ្វើហើយ តែ
មិនត្រូវភ្លេចបុណ្យគុណដែលអ្នកដទៃធ្វើចំពោះលោក ។

" ដាំឈើយកផ្លែ ធ្វើបុណ្យចិត្តបែរ ប៉ងសួគ៌និព្វាន កុសលត្រូវលះ
កំណាញ់សម្ពាន ព្យាយាមខ្ជួនប្រាណ ធ្វើបុណ្យជាតិសាសន៍ " ។

៣ — ព្រោះកម្ដិកភាព អ្នកនឹងប្រតិទ្ធម្យាប់, ព្រោះទម្យាប់ អ្នក
នឹងប្រតិចរិយា, ព្រោះចរិយា អ្នកនឹងប្រតិនិស្ស័យ ។

សិរស្ងួនលុប្បក

" កិច្ចការធ្វើកុំឲ្យធ្វេសត្រូវពិនិត្យ
ភ្លៅធឹតឬសោកាកុំឲ្យកាន់
ធ្វាប់ញាយល្អអាក្រក់ចរិយាគ្រាន់
ចិត្តកបកាន់កលកិច្ចកែបានទិស្ស័យ " ។

៤ — អ្នកណាដែលធ្វើស្ពៃចខ្លួនឯង អ្នកនោះនឹងមានហាសន-
ចិត្តត្រង់ត្រួតត្រាខ្លួនឯង ប៉ុន្តែមិនហានច្រាច្រាចង់សោយរាជ្យជាស្ពៃ
ផែនដីទេ ។

សិរវ្ហូម៉ាសប្រ៊ុន

" ត្រួតខ្លួនៗ ឯង អាកាស្វាងសែង ចេះត្រួតកាយចិត្ត មិនចាំធ្វើ
ស្ពៃ ប្រព្រឹត្តធម៌ពិត ផលល្អតាមគ្រិត្យ ត្រួតខ្លួនសោភា " ។

៥ — សេចក្តីបំណងនៃជីវភាព គឺការហាត់សិទ្ធិកងកាយចិត្តរបស់ខ្លួន ។

ស. អ៊ី. ក្នូប៊ែរ

" កាយចិត្តមានអរិយទ្រព្យគួរស្វែងរក
អប់រំយកហាត់ព្យាយាមធ្វើប្រព្រឹត្ត
សម្បត្តិកងប្រសើរពេកតាមពិតិត្យ
សម្បត្តិគិតខាងក្រៅភាពខំឲ្យល្មម " ។

៦ — គួរតែមនុស្សទាំងអស់រាល់គុណជល់អ្នកសង់ស្ពានដែលខ្លួនឆ្លង ។

" អ្នកសង់សាលាតាមផ្លូវឆ្ងាយ សង់ស្ពានប្រឡាយតាមអូរស្ទឹង
ធ្វើអ្នកតំណើរស្រួលពំនឹង ចិត្តគិតជញ្ជឹងនឹកគុណគាប " ។

៧ — មិនជាការធ្ងន់ស្មាលប៉ុន្មានទេ អ្នកមិនត្រូវគេចវេះ ត្រូវតែ
ជួយបុគ្គលដែលជួនអាហារលោកពិសា ។

" អ្នកជួនអាហារជួយជីវិត បើមានគ្រោះពិតត្រូវជួយច្បាណា
កុំឲ្យគេចវេះបើតបបាន គុណគាប់កល្យាណតបៈធម៌ " ។

៨ - មេច្បាប់ដែលធ្វាតជាងគេ ខ្លួនឯងក៏ត្រូវខ្វើនសាលាដែរ (អាលម្ហាយស្ងាប់ព្រោះពស់) ។

ត្រូវនឹងសុភាសិតខ្មែរថា: "ខ្ចើមអាចម៍ជាន់អាចម៍មិនខាន" ។

៩ - ការដែលរស់នៅដោយធ្វើស្មាក្តី ត្រូវមានជីវិតរស់នៅដូចឥសី ហើយធ្វើការដូចពាដី ។

លោងំអែលជង

"ពួកអ្នកស្មាក្តី រស់ដូចឥសី ក្រលំបាកប្រាណ ធ្វើការពាដី យប់ថ្ងៃលំអាន មិនមានអាក់ខាន តាមច្បាប់ដែរដៅ" ។

១០ - គ្រប់ៗគ្នា អ្នកណាដែលធ្វើការបានយ៉ាងល្អជាងគេជាងគេបំផុត អ្នកនោះឈ្មោះថា វីរបុរស ។

សុស្តចិលិង្ស

"ការសោភ័ណពិត ត្រូវប្រើគំនិត ចិត្តមុតបច្ចុប្បន្ន អ្នកណាធ្វើល្អគ្រប់យប់ថ្ងៃ ក្បើនាមថ្លាថ្ងៃ ហៅវីរបុរស" ។

១១- អ្នកដែលកើតក្តី ដូចគ្នានឹងអ្នកចាប់ឆ្កែព្រៃត្រង់ស្លឹកត្រចៀក ។

លោកបុរុតុង

ត្រូវគ្នានឹងសុភាសិតខ្មែរថា: "កាន់កពស់កាន់ឲ្យខ្ជាប់ ត្រែងក្បាច់មកខាំប្រាណ" ។

១២ - ការអ្វីក៏ដោយដែលគួរធ្វើគ្រប់ៗ ប្រកេទ គួរធ្វើឲ្យល្អផង ។

លោងំសេសតៃហ៊ីអែលង់

" កិច្ចការធ្វើកុំប្រមាទខាតប្រយោជន៍
ព្យាយាមខ្មាចកុំខ្លាចក្តៅហត់ខ្សឹយច្បាណ
បើចង់សុខធ្វេីស្រួលស្អាតគ្រប់ស្ថាន
ស្អាងជាតិបានជីវិតបង់ទុកនាមគោត្រ " ។

១៣- មិនមានទុជាវសឯណា ដែលបានដោយគតញើសជាប ។

" មិនធ្វើមិនបានសម្រេចការ កិច្ចអាត្មាត្រូវខំខ្នះខ្នែង
របស់ក្តីនៅផ្សារចាំងចែង ព្យាយាមប្រឹងប្រែងចេញញើសជាប " ។

១៤- មិនមានឃុំ មិនបានទឹកដែ្ឋម, មិនធ្វើការ មិនបានច្បាក់ ។

" មិនរៀនមិនចេះ មិនធ្វើចង់បេះ ផលប្រយោជន៍គាប់ មិនដើរចង់
ដល់ ចង់ដុះតតគ្រាប់ ធ្វើការមិនធ្លាប់ ចង់ស្តាប់សោតឯង " ។

១៥- លោកជាបំណុលគ្រប់ៗ គ្នាកុងរឿងអាស្រ័យនៅកុងលោក,
ហើយគ្រប់ៗ គ្នាកំពាក់បំណុលលោកកុងរឿងទុស្សាហ៍សាងលោក ។

" លោកបំណុលគុណបំណាច់ធ្ងន់ទុត្តម
សាងលោកសមគ្រប់ៗ គ្នាមិនឲ្យឃ្លង
ជ័ឌឹកមេឃប្រសើរមនុស្សគោងខ្នង
មនោធ្លងំបំពេញឃ្លាំងលោកយប់ថ្ងៃ " ។

(មានត)

សព្ទានុក្រមភាសាខ្មែរ

របស់

គណៈកម្មការវប្បធម៌

ហ្លួងធិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួម

(ត្រួត)

Entrepositaire = អ្នកទទួលទុក

Dépositaire = អ្នកទទួលដំបូង

Entrepôt = ឃ្លាំងទុក

Dépôt = ឃ្លាំងលក់

(Mardi 14-9-48)

Personnalité = បុគ្គលិកលក្ខណៈ

Individualité = — —

Parfait = សុក្រិត, គ្រប់លក្ខណ៍, ឥតខ្ចោះ

Intelligent = ឆ្លាត

Sage = ប្រាជ្ញ

Sagesse = ប្រាជ្ញា

Philosophie = ទស្សនវិជ្ជា

Métaphysique = បរមត្ថវិជ្ជា

Métaphysicien = បរមត្ថវិទូ

(Le Vendredi 17-9-49)

Gouverneur d'Etat = ចៅហ្វាយរដ្ឋ

Monopole = ការផ្តាច់មុខ

Angoisse = សេចក្តីតានតឹង, តប់ប្រមល់ (ខុ យាស)

Ligue arabe = សម្ព័ន្ធអារ៉ាប់

Police criminelle = ប៉ូលិសខ្មែរក្រហម

Bulletin de note = ប៊ុលឡែតាំងកំណត់

Régnicole = រដ្ឋភាសី (ស. រដ្ឋភាសិនី)

Crime = បទខ្មែរក្រហម

Criminel = មនុស្សបទខ្មែរក្រហម, មនុស្សហានេយ្យ

Autochtone = រដ្ឋភាសី (ស រដ្ឋភាសិនី)

(Mardi 21-9 48)

Service de la Flotte = ក្រុមពិភក្តិនាវ

ervice de la navigation fluviale ou maritime = ក្រុមនាវចរ
តាមទន្លេ ឬសមុទ្រ

Hiérarchie តាមលំដាប់សក្តិ, លំដាប់តំណែង

Agent contractuel = ភ្នាក់ងារជាប់កិច្ចសន្យា

Agent temporaire = ភ្នាក់ងារកាលិក

Docteur, Doctoresse en médecine = ដុកទ័រ ឬ វេជ្ជបណ្ឌិត

(ឥ. វេជ្ជបណ្ឌិត)

Diplôme de doctorat = សញ្ញាប័ត្រថ្នាក់បណ្ឌិត

Doctorat = ថ្នាក់បណ្ឌិត, បណ្ឌិត្យ

(Le 28 9-48)

Chef de clinique = នាយមន្ទីរពេទ្យ

Interne des hôpitaux = និស្សិតពេទ្យក្នុងមន្ទីរ

Externe des hôpitaux = និស្សិតពេទ្យក្រៅមន្ទីរ

Examen = ការប្រឡង, ការពិនិត្យ

Concours = ការប្រឡងប្រជែង

Attaché parlementaire = សភានុព័ន្ធ

Attaché de Cabinet = អនុព័ន្ធកាប៊ីណេត

Concurrence = ការប្រជែង

Concurrent = អ្នកប្រជែង

Bureau de Législation et de Jurisprudence = ប៊ុយរ៉ូនីតិការ

នីតិនីតិសាស្ត្រ

Fonctionnaire détaché = អ្នករាជការផ្លាស់តំណែង

Elite = វរជន

(Mardi 5-10-48)

La morale = ចរិយាសាស្ត្រ

Le moral — ទឹកចិត្ត, ចិត្ត

Pression morale — ការសង្កត់សង្កិនតាមផ្លូវចិត្ត

La moralité = សីលធម៌

Moral = ខាងផ្លូវចិត្ត

Tendance = និន្នាការ (អាការនុនលំអោនទៅតាម)

Instinct = សភាវគតិ

Conducteur des Travaux publics = នាយការសាធារណការ

Chef de chantier = នាយការដ្ឋាន

Chantier = ការដ្ឋាន

Mesure de police = វិធានការប៉ូលិស

Particularités = អាការពិសេស

Exercice du pouvoir = ការប្រើអំណាច

(Vendredi 8-10-48)

Entrepreneur = អ្នកទទួលការ

Chef-lieu de province = ទីតាំងខែត្រ

Chef-lieu de Srok = ទីតាំងស្រុក

Avion «Taxis» = យន្តហោះតក្សី

Localité de Poipêt = តំបន់ប៉ោយប៉ែត

Camion = កាម៉ង

Camionnette = កាម៉ងតូច

Autocar = អូតូការ

Centre urbain = ទីក្រុង

— rural = ទីជនបទ

Nous . . . . . .

Voulant-donner à M . . . . . en guise de notre reconnaissance particulière pour les services rendus, lui avons décerné la Médaille de la Couronne que nos mandarins seuls ont le droit de porter = ឃ្វាន់ក្រាសប្រទានមេដាយ័មកុជពាជ្យ, ដែលមានតែមន្ត្រីរបស់យើង ទើបពាក់ឃ្វាន់ជល់ . . . . . ដើម្បីតបស្នងគុណបំណាច់ជាពិសេស ។

Cette décoration se porte avec un ruban moiré 36m/m à 6 bandes bleues verticales rayées de jaune séparées par 5 bandes violettes d'égale largeur.

គ្រឿងឥស្សរិយយសនេះ គ្រូវពាក់ជាមួយនឹងរូបឯកប្រតិស្សរ
ទទឹង ៣៦ មីលីម៉ែត្រ (៣៦ម.ម) មានផ្ទាំងខៀវបញ្ឈរឆ្លងសឿង ៦
ខ័ណ្ឌដាច់ពីគ្នាដោយផ្ទាំងស្វាយ ៥ ទទឹងប៉ុនគ្នា ។

DIPLOME DE SAGE FEMME

Le Directeur du service de Santé du Royaume déclare que la nommée . . ., de la province de . . . née à . . . le . . . . a servi les cours de l'Ecole des sages-femmes et a été reçue aux examens de sortie le . . . . .

សញ្ញាប័ត្រឆ្មប

. . . . . ប្រកាសថានាង . . . . . នៅខែត្រ . . . . . កើតនា . . . . . នៅថ្ងៃ . . . . . ឃានរៀននៅសាលាឆ្មប ហើយឃានប្រឡងចេញជាប់នៅថ្ងៃ . . . . . ។

Turban = ឈូត

ruban = វត្តបំណ្ណ

Bande = បំរៀត

(12-10-48)

Taxe additionnelle = អាករបន្ថែម

Conseil consultatif de l'Economie rurale = ក្រុមប្រឹក្សាសេដ្ឋកិច្ច ជនបទ

Quotité de la taxe = អត្រាអាករ

Constater un droit = តាំពន្ធទុក

Recouvrer un droit = ការពន្ធ

Recette comptable = ផ្នែកបញ្ជី

Inspection et service actif = អធិការដ្ឋាននិងក្រុមសកម្ម

Bureau d'Ordre et du Personnel = ប៊ុយរ៉ូរបៀបនិងបុគ្គលិក

M...est prié de se présenter à ... pour affaire le concernant= សូម . . . . អញ្ជើញទៅកាន់ . . . . ដោយមានការផ្តាល់ខ្លួន

Découverte = ការរកឃើញ

Direction des Ateliers de la Flotte du Royaume = នាយកការកង់ជាង នឹងក្រុមចាត់ការពិភ័ក្តិនាវ៉ា នៃព្រះរាជអាណាចក្រ

Service de l'Hydraulique Agricole et de la Navigation du Sud-Indochine = ក្រុមធារាសាស្ត្រកសិកម្ម នឹងនាវ៉ាចរណ៍ប្រចិនភាគខាងត្បូង

Services des Travaux Publics = ក្រុមសាធារណការ

Adresse = ទីលំនៅ

Quinzaine = អឌ្ឍមាស

Bimensuel = អន្តឌ្ឍមាស

Tempérance = មត្តញ្ញុតា

Intempérance = អមត្តញ្ញុតា

Tempérant = មត្តញ្ញុ

Intempérant = អមត្តញ្ញុ

Passion = តណ្ហា

Aide-opérateur = អន្តេវាសី

Inspection et vérification de viande = ការត្រួតពិនិត្យសាច់

Cadre latéral = ក្របខ័ណ្ឌរណប

Vaccinateur = បសុព្យាធិលេខ

Aide- Vaccinateur = បសុព្យាធិលេខរង

Identification = អត្តសញ្ញាណកម្ម

Inspecter = ត្រួតពិនិត្យ

Vérifier = ពិនិត្យ

Injecter = ចាក់ថ្នាំ

Vétérinaire = ពេទ្យសត្វ, បសុពេទ្យ

(Le 15-10-48)

Chef de l'Inspection des Eaux et Forêts= នាយអធិការមណ្ឌលគង្គានទីរុក្ខា

Chef de Cantonnement des Eaux et Forêts= នាយខ័ណ្ឌគង្គានទីរុក្ខា

Chef de Division des Eaux et Forêts = នាយផ្នែកគង្គា នទីរុក្ខា

Triage forestier = សង្គាត់រុក្ខា

Garderie forestière = លំនៅរុក្ខារក្ស

Contrôleur des Eaux et Forêts = អធិការគង្គានទីរុក្ខា

Conservateur des Eaux et Forêts = អភិរក្សគង្គានទីរុក្ខា

Garde Forestier = រុក្ខារក្ស

Construction sommaire = សំណង់មិនបិតថេរ

Municipalité = ទីរាជការក្រុង

(26-10-48)

Botanique = រុក្ខសាស្ត្រ

Les différentes parties d'une plante = ភាគផ្សេងៗ នៃរុក្ខជាតិ

Ses différentes parties = ភាគផ្សេងៗ នៃស្លឹក

Limbe = ដំបារស្លឹក

Pétiole = ទងស្លឹក

Gaine = ស្រទប

Stipule = ប្រណាល

(វ 11-48)

Dévouement = ចិត្តភក្តី

Banderôle = បដា

Etiquette = ស្លាក

Enseigne = យីហោ

Marque = គ្រា (ម៉ាក)

Ecriteau = ក្តារជូ"យ

Panneau = បណ្តូ (ប័ន-ណូ)

Route = ថ្ល

Rue = វិថី

Boulevard = មហាវិថី

Avenue = វុក្ខវិថី

Quai = តីរវិថី

Allée = ច្រក

Piste = ផ្លូវលំ

Chemin = ផ្លូវ (មាគ)

ព្រះរាជាណាចក្រនៃប្រទេសកម្ពុជា

អ្នកឧកញ៉ាខេមពិន្ទូ ឈឹម - ក្រសេម រៀបរៀង

(ត្រឡប់)

ដើម្បីបង្ហាញពីភាពជាប្រទេសមួយដែលមានព្រះរាជាជាប្រមុខ ដែលមានព្រះរាជាជាអ្នកដឹកនាំប្រទេសជាតិ ដែលមានព្រះរាជាជាអ្នកការពារសន្តិភាពនៅក្នុង

២) ត្រូវសាងគ្រឿងសរតើយុទ្ធ (គ្រឿងចំបាំងគ្រប់យ៉ាង) ទឹងសាងនាវាហាន ឲ្យមានចំនួនគ្រប់គ្រាន់ ទុកសម្រាប់ការពារមាតុភូមិ ។

៣) ត្រូវបណ្តុះអារ្យធម៌ដល់ជាតិ ពោលគឺបណ្តុះទឹកចិត្តប្រជាជនឲ្យមានសេចក្តីស្នេហាជាតិ - សាមគ្គី - ក្លាហានទឹងវិជ្ជាយុទ្ធសាស្ត្រជាដើម ។ ព្រះបាទជយវរ្ម័នទ្រង់អនុវត្តតាមសេចក្តីគ្រោងបង្កើតនោះ ។

កន្លះទី ១ គ្រាស់ឲ្យមហាព្រាហ្មណ៍ជាពន្លឹងរហើយ ក៏ចាត់ការសាងព្រះទេវរូបនោះ ដោយថ្នមដ៏បរិសុទ្ធ ស្រេចហើយរាជបុរោហិតទាំងពីរក៏ធ្វើពិធីសម្ពោធ្យដោយមហាមន្តទាំង ៥ ដែលហៅដោយឈ្មោះថា វិនាសិខ ១ នយោត្តរ ១ សម្មោហៈ ១ សិរស្ចេន ១ ។ ព្រះទេវរូបនោះ ក៏កើតឡើងជា តុម្ពុរ គឺជាតួអង្គ ជាអាត្ម័ន ជាវិញ្ញាណតិត្យឡើងស្ថិតនៅក្នុងព្រះទេវរូបនោះ ។ តុម្ពុរ វិក្លែចតុស្តម ព្រះទេវរូបនោះក៏ប្រាកដមានជាព្រះភក្ត្រ ៤ ឡើង ទៅជាព្រះទេវរូបអន្យាវ៉ៃផ្ទៃក្រោម គេថ្វាយព្រះនាមតាមទំនៃនេះថា "ព្រះគម្រែតេង ជគតរាជ[1]" ប្រែថា ព្រះទេវរាជជាអ្នករក្សាផ្ទៃក្រោម ។

ឯរូបព្រះគម្រែតេងជគតរាជនេះ ព្រះបាទជយវរ្ម័នគ្រាស់ឲ្យប្រតិស្ឋានទុកនៅទេវស្ថានកណ្តាលក្រុងមហេន្ទ្របព៌ត, ទ្រង់បញ្ជាឲ្យព្រាហ្មណ៍ធ្វើសក្ការបូជា ជាអាចិណ្ណ ។ ចំណែកព្រះអង្គក៏ទ្រង់គោរពបូជាព្រះ

(១) តាមយោបល់របស់អ្នកប្រាជ្ញថាភាគច្រើនដែលបានស្រាវជ្រាវរួចហើយថា ជាវរលោកវិលុង្គ ។

ទេវរូបនេះដែរ រហូតដល់ព្រះមហាក្សត្រិយ៍ទាំងឡាយខាងក្រោយៗ មក ក៏ទ្រង់ទទួលគោរពបូជា តមកជាច្រើនរដ្ឋកាល ។ លោកថា ក្រោយដែលសាងរូបព្រះគម្រែតេងជតតរាជនេះហើយ ព្រះបាទជយវរ្ម័នទី ២ ក៏បានហានៈនឹងព្រះកត្តិស័ក្តិ ជាចក្រពត្តិវង្សក្រោម ដោយអំណាចទិព្យនោះ ។

កន្លងទី ២ ព្រះបាទជយវរ្ម័នទី ២ គ្រាស់ឲ្យសាងគ្រឿងសស្ត្រាវុធសម្រាប់ព្រះមហាក្សត្រិយ៍ម្ចាស់ផែនដីខ្មែរជាច្បាំជាមុន គឺ ព្រះខ័នពាជ្យ ១ ព្រះខ័នវង ១ ព្រះទម្រង់អសិខ្ញី ១ ព្រះទម្រង់អសិវែង ១ ព្រះទម្រង់លំពែងជ័យ ១ ព្រះទម្រង់ ៥ អង្គនេះ សម្រាប់អង្គព្រះមហាក្សត្រិយ៍, ទឹងគ្រាស់ឲ្យសាងព្រះខ័នសម្រាប់ស្តេចទេបរាជស្រុក (ស្តេចគ្រាញ់) ៤ ឬច្រើនជាង ៤ ទៀត ។

ព្រះខ័នពាជ្យ ឬហៅថា ព្រះខ័នជ័យនេះ សាងខ្មែរដោយផ្ទឹតផ្ចង់មានលក្ខណៈល្អជាបំផុត ក្នុងលោកនេះ ទឹងរកព្រះខ័នណាប្រៀបស្មើពុំបាន, ព្រះបាទជយវរ្ម័នទ្រង់ឲ្យទុកព្រះខ័ននេះជាគ្រឿងរាជកកុធភ័ណ្ឌ នៅជរាបដល់សព្វថ្ងៃនេះ ។ ព្រះខ័នវង ហៅដោយឈ្មោះថា ព្រះខ័នជ័យស្រីមានលក្ខណៈល្អដូចព្រះខ័នពាជ្យ តែរូបតូចជាង, ព្រះបាទជយវរ្ម័នទ្រង់ទុកជាអាវុធសម្រាប់ប្រើប្រាស់ផ្ទាល់ព្រះអង្គជានិច្ច, ព្រះមហាក្សត្រិយ៍ទាំងឡាយជាតំណតមក រហូតដល់រដ្ឋកាលព្រះបាទស្រីន្ទ្រវរ្ម័នទី ២ (ព. ស. ១៨៣៨-១៨៩០) ក៏នៅប្រើព្រះខ័ននេះជាអាវុធផ្ទាល់ព្រះអង្គនៅឡើយ។

ព្រះខ័ន្ធនេះ សម្តេចចៅហ្វាវែន ចាន់លើកថ្វាយទៅព្រះពុទ្ធយ៉ាតហ្វា ក្សត្រិយ៍ចិនក្នុងគ.ស. ១១៤៦ ព.ស. ៦៣២៧, ព្រះពុទ្ធយ៉ាតហ្វាចាន់ទទួលរក្សាទុក ហើយប្រើជាគ្រឿងពាជកកុងតង្ហាខោងរាបបច្ចុប្បន្ននេះ ។ ព្រះទម្រង់លំពែងធំយ៉ង គង់នោងពាបដល់សព្វថ្ងៃនេះ ។ ព្រះទម្រង់អសិវែង គឺជាវជង្គវែង, ព្រះទម្រង់អសិខ្លី គឺជាវជង្គខ្លី, ទាំងពីរយ៉ាងនេះ ប្រហែលជាចាត់បង់ទៅយូរហើយ, ព្រះទម្រង់វែង-ខ្លី នៅក្នុង ព្រះបរមពាជរាំងសព្វថ្ងៃក៏មានដែរ តែជារបស់ដែលខើបសាងឡើងក្នុងជាន់ក្រោយ ។ ឯព្រះខ័ន្ធស្តេចខុបរាជស្រុក មានលក្ខណៈអន់ថយជាង ព្រះខ័ន្ធរាជ្យ មានចំនួនប៉ុន្មាន មិនមានដំណឹងជាច្បាស់ជ, តាមដែលច្បាស់ជនោះសព្វថ្ងៃមាន ៤, តែបើគិតតាមចំនួនស្រុកដែលធ្លាប់តាំងស្តេចខុបរាជមកហើយ ឃើញមានច្រើនជាង ៤ ។

ការសាងគ្រឿងសស្ត្រាវុធអំបាលនេះ សុទ្ធតែមានពិធីប្រសិទ្ធិយ៉ាងធំដុំ តាមរបៀបតម្រាសែយ៍របស់ព្រាហ្មណ៍ ។

ក្រៅពីគ្រឿងសស្ត្រាវុធសម្រាប់ក្សត្រិយ៍ដូចពោលមកនេះ ព្រះបាទជយវរ្ម័នទី ៦ ទ្រង់ឲ្យសាងគ្រឿងសស្ត្រាវុធ ទ្រង់គ្រឿងយុទ្ធភ័ណ្ឌសម្រាប់សេនាទាហានទៀតជាច្រើន ទុកសម្រាប់ការពារប្រទេស ។

កន្លងមកដែលថា ព្រះមហាក្សត្រិយ៍ខ្មែរក្នុងបុរាណកាល ទ្រង់និយមកន្លងខ្លួនក្នុងភ្លឺយៈនោះ អាចនឹងបញ្ជាក់ឲ្យឃើញថាន ដូចមានច្បាប់ជកក្នុង

ក្សត្រ ព្រះរាជពិធីទ្វាទសមាសបុរាណថា: ខែកត្តិកដែលជារដូវចូលឆ្នាំតាម
ចន្ទគតិ ធ្វើពិធីសម្ពយុទ្ធគាហានដើងទឹក (ដែលឥឡូវនេះ ក្លាយទៅជាការ
អុំទូកង ប្រណាំងគ្នាក្នុងការសពិធីចន្ទាយណ: គឺពិធីបូជាព្រះចន្ទ) ។
ខែចេត្រជារដូវចូលឆ្នាំតាមសុរិយគតិ ធ្វើពិធីសម្ពយុទ្ធគាហានដើងគោក,
ព្រះរាជពិធីនេះជាពិធីធំ ១ ដោយមានការប្រជុំមន្ត្រីខែត្រ ទឹងស្តេចគ្រាញ់
ស្តេចទបរាជស្រុកទាំងអស់ ព្រះរាជពិធីនេះ នៅមានសេសសល់ប្រការ
ខ្លះ ដូចជាលក្ខណ៍វច្ឆការ ព្រះបាទស៊ីសុវត្ថិ (ព្រះបរមរាជាខ្មែរគោដ្ឋ) គឺការ
ចំបាប់ ប្រជាល ក្នុងទាសបុណ្យចូលឆ្នាំ នេះជាភាគ ១ ក្នុងការសម
យុទ្ធគាហានដើងគោក ។ ខែផេស្សធ្វើពិធីប្រសិទ្ធិគ្រឿងសិតើយុទ្ធ[1] ។
ខែស្រាពណ៍ ធ្វើព្រះរាជពិធីអានជំរះព្រះខ័នជ័យ ។ ព្រះរាជពិធីទាំងនេះ
កើតឡើងដោយអំណាចព្រះមហាក្សត្រិយ៍ ទ្រង់និយមក្នុងលទ្ធិព្រហ្មណ: ។
ព្រះរាជពិធីពីរខាងក្រោយនេះ ក្នុងជាន់ដើមប្រហែលជាគេធ្វើរួមក្នុងខែ
ណាមួយ តែវេលាក្រោយគេចំបែកធ្វើក្នុងខែផ្សេង ៗគ្នា ។

អាស្រ័យហេតុដែលព្រះមហាក្សត្រិយ៍ខ្មែរ ក្នុងសម័យព្រៃនាយ
ទ្រង់និយមក្នុងលទ្ធិព្រហ្មណ: ពេញទី ប្រជាពលរដ្ឋក៏និយមក្នុងការគោរពតាម
ដូចពោលមក, ប្រទេសកម្ពុជាយើងក្នុងសម័យនោះ ទើបបានជាមហា-
ប្រទេស ១ ក្នុងទ្វីបអាស៊ី (ដម្ពុទ្វីប) មានទំហំផែនដី ១ ក្នុង ៣ ភាគ ដូច
ប្រាកដក្នុងប្រវត្តិសាស្ត្រសម័យនគរភ្នំ ទឹងសម័យនគរធំនេះស្រាប់ ។

(១) ចូរមើលក្សត្រព្រះរាជពិធីក្នុងខែនេះដែលខ្ញុំបានរៀបរៀងទុកនៅពុទ្ធសាសនបណ្ឌិត្យ ។

ព្រះចាន់ជយវរ្ម័នទី ២ ស្តេចគង់នៅមហេន្ទ្របព៌តអស់កាលដ៏សមគួរហើយ ក៏ស្តេចចេញពីក្រុងនោះ មកគង់នៅក្រុងហរិហរាល័យដូចដើមវិញ ឃានទាំងអញ្ជើញយកព្រះទេវរូប គម្រែតេង៍ជតតរាជ មកប្រតិស្ឋាននៅក្រុងនេះឯង, ស្តេចស្ថិតនៅក្នុងរាជសម្បត្តិបាន ៦៧ ឆ្នាំ ក៏សោយទិវង្គតនៅក្រុងហរិហរាល័យនេះ គេថ្វាយព្រះបរមនាមនៃព្រះបរមសពថា "ព្រះចាន់បរមេស្វរៈ" ។ ក្រោយនោះ ព្រះនាងកម្ពុជាលក្ស្មី អគ្គមហេសី ក៏សោយទិវង្គតទៅតាមព្រះរាជស្វាមី គេថ្វាយព្រះនាមព្រះបរមសពថា "តារាទិន្ទ្រាទេវី" ។

តាមដែលអង្គតមក ខំនឿមថ្វាយព្រះបរមនាមនៃព្រះបរមសពព្រះរាជាម្ចាស់ផែនដី ឃើញមានជាប្រវែណីតាំងពីបុរាណកាល រហូតដល់បច្ចុប្បន្នកាល, តែឯការថ្វាយព្រះនាមព្រះបរមសពព្រះរាជជននី (អគ្គមហេសី) នោះ ក្នុងសម័យណាឬក្នុងរដ្ឋកាលណាក៏ដោយ ហាក់ដូចជាមិនដែលឃើញមាន ទើបមកឃើញចំពោះព្រះនាងកម្ពុជាលក្ស្មី អគ្គមហេសីព្រះចាន់ជយវរ្ម័នទី ២, រំលាសោយទិវង្គត គេថ្វាយព្រះនាមព្រះបរមសព ខំនងដូចជាព្រះរាជាម្ចាស់ផែនដី ។ ១នេះគួរឲ្យសន្និដ្ឋានថា ព្រះនាងកម្ពុជាលក្ស្មីព្រះអង្គមានព្រះកិត្តិយសមានព្រះគុណសម្បត្តិគួរគោរពរាប់អាន ព្រះអង្គជាវីរក្សត្រី ជាប្រិយក្សត្រី

ខ្ញុំបានធ្វើប្រយោជន៍ដល់ប្រទេសជាតិជាច្រើន ។ ខ្ញុំនឹងដូចព្រះពុទ្ធស្វាមី ទើបបានគេថ្វាយព្រះនាមព្រះបរមសព្ទ ជាពិសេសយ៉ាងនេះ ។

ព្រះកិត្តិគុណនៃព្រះបាទជ័យវរ្ម័នទី ២

សរុបសេចក្តី: ព្រះបាទជ័យវរ្ម័នទី ២ ខ្ញុំធ្វើឧបការៈដល់ប្រទេសជាតិច្រើនវិសែលែង ពោលដោយសង្ខេបគឺ:

១ — ខ្ញុំបានស្រោចស្រង់មាតុភូមិ ដែលធ្លាក់ទៅខ្មៅកន្លងអំណាចរបស់ជាតិដទៃ ឲ្យបានជាចក្រភពឡើងវិញ ។

២ — ខ្ញុំចាត់ការ ដើម្បីឲ្យកម្ពុជរដ្ឋគង់នៅជាចក្រភពដរាបទៅ ដោយខ្ញុំឲ្យសាងគ្រឹះសំពើយុទ្ធនាការសម្រាប់ការពារ ព្រមទាំងចាត់ការឲ្យមានការបង្ក្រឹកបង្ក្រាបសេនាគាហានឆ្នែកដើងគោក ដើងទឹកឲ្យមានគុណវុឌ្ឍិគ្រប់គ្រាន់ ។

៣ — ខ្ញុំចាត់ការឆ្នែកគ្រប់គ្រង ឲ្យមានរបៀបរៀបរាយទៅតាមសម័យ ដូចយ៉ាងការតែងតាំងព្រះឧបភដស្រុកឲ្យមានឡើងវិញ នឹងដូចកន្លងរជ្ជកាលព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន ដែលបានពោលហើយ ។

ដោយហេតុទាំងឡាយដូចពោលមក ព្រះបាទជ័យវរ្ម័នទី ២ ទើបប្រាកដព្រះកិត្តិយសជា ពជាធិពជ ឬជា ចក្រពត្តិ ១ អង្គក្នុងប្រវត្តិសាស្ត្រកម្ពុជា ។

ព្រះចាន្ទជយវ្ម័នទី ៣

ព.ស. ១៤១៤ – ១៤២០, គ.ស. ៨៦៩ – ៨៧៧

កាលព្រះចាន្ទជយវ្ម័នទី ២ សោយទិវង្គតហើយ ព្រះរាជវរសបានឡើងសោយរាជ្យតមក មានព្រះបរមនាម "ជយវ្ម័ន" ដូចព្រះរាជបិតា តែពាប់ជាទី ៣ ស្តេចគង់នៅក្នុងហរិហរាល័យ ទ្រង់មានព្រះអគ្គមហេសី ព្រះនាមដូចម្តេចមិនប្រាកដ ទ្រង់មានព្រះរាជវរសខ្លះដែរ តែប៉ុន្មានអង្គ ព្រះនាមដូចម្តេច មិនប្រាកដ ។

ការផែនដី ក្នុងរជ្ជកាលនេះ ការផែនដីមិនប្រាកដថា ទ្រង់ធ្វើអ្វីឲ្យបានចំរើនក្នុងផ្លូវណា ជាងរជ្ជកាលមុនទេ តែទ្រង់អាចរក្សាឲ្យគង់វង្សនៅបានដូចដើម ។

ការព្រះសាសនា ព្រះចាន្ទជយវ្ម័នទី ៣ ទ្រង់ពាប់រាជលទ្ធិវៃស្ណវៈ គឺពាប់រាជព្រះវិស្ណុជាធំ មានមហាព្រាហ្មណ៍ឈ្មោះ "រុទ្រាចារ្យ" សឹងជាអំបូរសិរីវិតវ័ល្យ ជារាជបុរោហិតរបស់ព្រះអង្គ ។ ការសាងវត្តក្នុងសាសនានេះគង់នៅមានខ្លះ តែមិនប្រាកដថា បានសាងអ្វី ។

ស្តេចនៅក្នុងរាជសម្បត្តិបាន ៧ ឆ្នាំ ក៏សោយទិវង្គត គេហៅព្រះបរមនាមនៃព្រះបរមសពថា "វិស្ណុលោក" តាមដែលទ្រង់និយមក្នុងលទ្ធិនេះ ។

ព្រះចាន ឬ ទ្រុវ័ន ទី ១

ព.ស. ១៤២០ - ១៤៣២, ត.ស. ៨៧៧ - ៨៨៩

ក្សត្រិយ៍វង្សព្រះបាទជយវរ្ម័នទី ៦ ផ្ទាល់ ឬ នេសាយពាក្យតែតឹមព្រះបាទជយវរ្ម័នទី ៧ ប៉ុណ្ណោះ តាំពីនោះមកពាក្យសម្បត្តិឬនៅ ព្រះតន្ទ្រុវ័ន ដែលជាប់ជាព្រះញាតិវង្ស គឺ ព្រះតន្ទ្រុវ័នទេវជានុរស ព្រះបិតារបស់ព្រះនាង ត្រូវជាកនិដ្ឋភគិនីនៃព្រះពាជជនន៍ ព្រះបាទជយវរ្ម័នទី ៦ ទ្រង់ឬនៅឯគ្រងពិភពឆែនដ៏ មានព្រះបរមនាមថា "ព្រះបាទតន្ទ្រុវ័នទី ១" ស្ដេចគង់នៅក្រុងហរិហរាល័យ, ទ្រង់មានព្រះអគ្គមហេសីព្រះនាម "តន្ទ្រុទេវី" ជាព្រះធីតានៃព្រះមហិបតិវរ្ម័ន ដ៏ជាពាជនុរសព្រះបាទពាជេន្ទ្រវរ្ម័នទី ១ មានព្រះនុរស ១ អង្គ ព្រះនាម "យសោវរ្ម័ន" ។

ការផែនដី ក្នុងរជ្ជកាលនេះ ការឆែនដ៏ប្រព្រឹត្តទៅដូចរជ្ជកាលមុន ។

ការព្រះសាសនា ទ្រង់ពាប់អានលទ្ធិសៃវៈ គឺពាប់អានព្រះសិវៈជាំង ទ្រង់មានមហាព្រាហ្មណ៍ឬជ្ញឈ្មោះសិវសោម ១ ឈ្មោះពាទសិវៈ (សឹងត្រូវជាចៅរបស់ព្រះសិវកៃវល្យ) ១ ជាបុរោហិតពាជគ្រូ ។

ព្រះបាទតន្ទ្រុវ័នទ្រង់ឬនៅប្រគល់ព្រះយសោវរ្ម័ន ជាពាជនុរសឲ្យនៅសិក្សាសិល្បវិទ្យាតាមទាំងពួង ក្នុងសំណាក់ព្រះពាមសិវៈពាជគ្រូ, ព្រះយសោវរ្ម័នទ្រង់ឬនៅសិក្សាសិល្បវិទ្យាការផ្សេង ៗ គឺទាំងផ្នែកអក្សរសាស្ត្រ

ទាំងផ្នែកព្រះសាសនា ទាំងផ្នែកគតិគតិឆែនដ៏ ទាល់តែមានសេចក្តី
ស្ងាត់ជំនាញបរិបូណ៌ ដូចមានប្រាកដក្នុងពេលខ្ញុំបាននិយាយរាជ្យ
ខ្លីដែរហើយ ។

ការកសាងក្នុងព្រះសាសនា : ព្រះបាទតន្ត្រីវរ្ម័ន ទ្រង់បានសាង
ព្រះប្រាង្គខ្មែរស្ថាន ប្រាគោ ១ ប្រាគដ៏ ១ ក្នុងរវាងឆ្នាំ ៣. ស. ១៤៣២
ប. ស. ៨១១ នៅលើកំណែលបានតុបតែងខ្លាំង ហើយទ្រង់ឲ្យយករូប
ព្រះគម្រែតែងជាគតភាជ ដែលព្រះបាទជយវរ្ម័នទី ២ ទ្រង់សាងទៅប្រតិស្ឋាន
ក្នុងព្រះប្រាង្គ ១ ទ្រង់បានសាងទេវរូបសំខាន់ ។ ទៀតខ្លះទៀត យកទៅ
ប្រតិស្ឋានក្នុងព្រះប្រាង្គខ្មែរស្ថានជាមួយគ្នា ។ ទ្រង់សាងព្រះរូបព្រះបរម-
រាជវង្ស គឺព្រះរូបព្រះពាធអយ្យកោ ព្រះពាធអយ្យិកា, ព្រះរូបព្រះពាធជនក
ព្រះពាធជននី របស់ព្រះអង្គ, ទឹងព្រះបរមរូបព្រះបាទជយវរ្ម័នទី ២ ព្រះរូប
ព្រះនាងកម្ពុជាលក្ស្មី ប្រតិស្ឋានក្នុងព្រះប្រាង្គ ១ ទុកជាអនុស្សាវរីយ៍ ទឹង
ជាព្រះបិតរ ។

កាលដែលព្រះបាទតន្ត្រីវរ្ម័ន ទ្រង់សាងព្រះរូបព្រះពាធអយ្យកោ
ព្រះពាធអយ្យិកា រហូតដល់ព្រះពាធជនក ព្រះពាធជននីរបស់ព្រះអង្គនោះ
មិនមានជាបញ្ហាអ្វីទេ តែការដែលទ្រង់សាងព្រះបរមរូបព្រះបាទជយវរ្ម័ន
ទី ២ ទឹងព្រះរូបព្រះនាងកម្ពុជាលក្ស្មី ទ្រង់មិនបានសាងព្រះបរមរូបព្រះ
បាទជយវរ្ម័នទី ៣ នោះ ត្រូវដឹងថាជាបញ្ហា ១ ដោយឡែក ការដោះស្រាយ

បញ្ហានេះ សូមឲ្យជ្រាបថា ព្រះបាទតន្ទ្រវ័ន ដែលទ្រង់សាងព្រះបរមរូប ព្រះបាទជយវរ្ម័នទី ២ នឹងព្រះនាងកម្ពុជាលក្ស្មី ទុកជាអនុស្សាវរីយ៍នោះ ព្រោះក្សត្រីយ៍ទាំងពីរព្រះអង្គ ជារដ្ឋបុរសជារដ្ឋស្ត្រីដ៏ប្រសើរបស់ប្រទេសជាតិ ទ្រង់គោរពចំពោះរដ្ឋបុរសរដ្ឋស្ត្រីទាំងពីរព្រះអង្គនេះដោយស្មោះ, ដូច្នេះ ពួកយើងជាអនុជនខាងក្រោយ ត្រូវតែស្គាល់ដំណែឡនឹងគោរពព្រះបាទជយវរ្ម័នទី ២ ទាំងព្រះនាងកម្ពុជាលក្ស្មីដូចព្រះបាទតន្ទ្រវ័នទី ១ ។

ព្រះបាទតន្ទ្រវ័នកាលទ្រង់សាងព្រះប្ញាស្ត នឹងសាងព្រះទេវរូបព្រះបរមរូបនៃព្រះបរមរាជវង្សក្រសេចហើយ ក៏ស្តេចសោយទិវង្គតក្នុងឆ្នាំនោះ គេថ្វាយព្រះបរមនាម នៃព្រះបរមសពថា "ព្រះបាទសុរលោក" តាមហេតុដែលទ្រង់និយមក្នុងលទ្ធិសៃវៈ ។

(មានត)

រឿងព្រៃឆកូមា

លោកសាង - សាវ៉ាត លេខានុការក្រសួងអប់រំវិញ្ញាតិ

ប្រែចេញពីសៀវភៅកុងត៍ ប៊ីរ៉ែន (contes Birmans) របស់លោក លូ វ៉ុសស្យុង (Louis Vossion)

ជាភាសាជាតិយកមកខ្មែរ

(តមក)

២ – ឆ្លងសេចក្តីបាត

" លាភចំរោះច្រើនកៃ តែគង់ចាញ់រ័យ នៃសុភាចារ "

ក្នុងសកលជ័យព្រះពុទ្ធ តានេនគារ (Tanengara) ដែលខ្ញុំគ្រាស់មុនគេបង្អស់, មានព្រាហ្មណ៍ម្នាក់ជាមហាសេដ្ឋី ជាអ្នកមានចិត្តសោកស្តាយពន់ពេក ដោយសារមានកូនស្រីតែមួយឈ្មោះនាង សិក្តាកុមារី (Sikta Kommari) សំពាប់តវង្សត្រកូល ។

ឯបុត្រីនេះ លុះអាយុបានប្រមាណ ១៦ ឆ្នាំ មិនខ្វៅជាមានរូបល្អទ្រឹងមានគុណធម៌តាមធម្មតារបស់ក្មេងអាយុប៉ុណ្ណោះទេ តែឲ្យប៉ាជាបង្ហាញចារឹកស្នាញស្នាញទឹងគំនិតច្បាស់ខ្វៅខាងផ្លូវលោកនឹងផ្លូវកំណាញ់វិញ ។ មានថ្ងៃមួយនោះ នាងនិយាយម្នាក់ឯងដូចមានតខ្វៅនេះថា: " ឪពុកម្តាយអញ ប្រាកដជាឥតស្រឡាញ់អញបន្តិចទេ, ភ្នែកសម្លឹងរបស់គាត់មានច្រើនណាស់ ហើយគាត់មិនព្រមឲ្យអ្វីអញសោះ; ទំហូកគ្មាន គ្រឿង

លំអក់គ្មាន អ្នកបន្តិចជាប់នឹងខ្លួនក៏គ្មាន, ចំណែកខាងពួកគូកនរបស់អញវិញ គោះគេក្រយ៉ាងណាក៏ដោយ ក៏គង់មានមាសនឹងពេជ្ររបស់គេដែរ; បើសិនណាគាត់ស្ងាប់ទៅ អញជាស្រីគ្មានប្អាប់ទទួលមតិកទេ ម្ល៉ោះហើយទ្រព្យរបស់គាត់ទាំងប៉ុន្មាន មុខជាចូលឃ្លាំងព្រះរាជទ្រព្យមិនខាន វៀរលែងតែរបស់ណាដែលព្រះរាជាមានព្រះទ័យមេត្តាព្រះរាជទានឲ្យមកអញវិញ, ម្ល៉ោះសមអញនឹងទៅជាក្រហើយគ្មានធនធាន អស់មួយជាតិមិនខាន" ។

គំនិតទាំងនេះឯង ឃានក៏បង្កិលខួរក្បាលនាងឲ្យដើរជាន់ចុះមិនឈប់ឈរឡើយ ។ ថ្ងៃមួយ ពេលដែលនៃពុកម្តាយនាងទៅមុជទឹកព្រៃក ហើយដែលពួកឃ្វាលគោនៅលេងក្នុងសួនច្បារ នាងក៏ឆ្លៀតយកឱកាសនោះ ដើម្បីលួចពេជ្រមួយដុំដ៏ថ្លៃបំផុត ដែលនាងដឹងថា លាក់ក្រោមពួកលើគ្រែរបស់ឪពុកនាង ។ រួចនាងយកពេជ្រនោះទៅលាក់កន្លែងមួយផ្សេងដែលនាងស្គាល់តែម្នាក់ឯង ។

រីឯព្រាហ្មណ៍កាលបើលុបលាងខ្លួនរួចហើយ ក៏ផ្ញាស់ទោអាវយ៉ាងស្រួលបួលទៅមាត់ទឹក ។ ស្រាប់តែមានគំនិតគិតដល់ត្បូងពេជ្ររបស់គាត់មួយរំពេច រួចក៏សួរទៅប្រពន្ធគាត់ថា: តើត្បូងពេជ្រនោះនៅលើគ្រែត្រង់កន្លែងដដែលឬ? ។ នាងកវិយាគិតឃើញ ឆ្លើយថា: នៅកន្លែងដដែលទេ, ប៉ុន្តែដោយពិតនោះ កាលចេញពីផ្ទះមក នាងមិនបានមើល

ពិនិត្យបញ្ជាក់ថែមទៀតឲ្យសព្វគ្រប់ទេ ។ ព្រាហ្មណ៍ចាន់ពួកដូច្នោះក៏មានចិត្តសង្ស័យជាខ្លាំង ទើបទំនេរៀតពាក់យ៉ាងច្របាច់ច្របាល់ហើយរត់តម្រង់ទៅផ្ទះវិញ ។

ចំណែកកូនស្រីរបស់ព្រាហ្មណ៍ កាលណាលាក់ស្បង់ពេជដោយត្រឹមត្រូវរួចហើយ ក៏តាំងរៀបចំទឹកតាមទំនៀម ដើម្បីលាងជើងឥតុកម្តាយដែលត្រឡប់មកវិញ ។ ក្នុងពេលនោះ ឥតុកនាងរត់មកដល់មុនដោយអាការត្រដេបត្រដាបស្ទើរដាច់ខ្យល់ ។ ព្រាហ្មណ៍ចាន់ដើរតម្រង់ត្រង់ទៅកន្ទែងលាក់ពេជនោះដោយឥតនិយាយអ្វីមួយម៉ាត់ ហើយរកមើលពេជមិនឃើញ។តែកន្ទែងនោះទទេស្អាត ។ ព្រាហ្មណ៍ធ្លល់ណាស់ក៏លាន់មាត់ឡើង ហើយសួរទៅកូនស្រីរបស់ខ្លួនថា: "កូនសម្លាញ់! កន្លងពេលដែលឥតុកកំពុងមុជទឹក តើកូនបានយកស្បង់ពេជគ្រែតូចប្តូរទេ?" ។ នាងឆ្លើយដោយអាការយ៉ាងច្របូកច្របល់ថា: "ទេ លោកឥតុក, ខ្ញុំមិនដឹងជាមានស្បង់ពេជនៅទីនោះផង" ។

ការទាស់ទែងក៏កើតឡើង ។ ឯម្តាយក៏មកដល់ ហើយចូលទៅជជែកថែមទៀត រួចបន្តិចទៅក្រមញាតិទាំងអស់ក៏នាំគ្នាដើរតាមមាត់ព្រៃកទៅកាន់គ្រឹះស្ថានរបស់លោកសុភាចារបុរសក្នុងភូមិ ដើម្បីទៅសុំលោកបើកអង្កេតមើល ។ ប៉ុន្តែលោកសុភាចារបុរសមិនព្រមបំពេញបំណងក្រមណាជាដាច់ខាត ដោយបានឲ្យហេតុផលថា: "មិនដែលមានកូនស្រី

តែមួយទៅក្នុងត្រលាំង ហើយមានសុភាពរាបសាយ៉ាងនេះ ណាក៏ហ៊ានទៅលួចយកទ្រព្យរបស់ទុកម្ដាយឯង ដូចជាស្រីម៉ដ្ដីមរ័យធម្មតា, បើត្បូងក៏ប៉ុន្តែទៅហើយតោងតែរកឲ្យមែនទែន," ថាហើយលោកចិត្តការក្លែងដើរចូលទៅក្នុងបន្ទប់របស់លោកទៅ ។

ព្រាហ្មណ៍ទឹកភ្នែកមនស្សត្រូចចិត្តណាស់ ក៏ទៅអំពាវនាវដល់លោកថៅហ្វាយខ្ញែត, ឯលោកថៅហ្វាយខ្ញែតក៏ចែងរយោបល់លោកដូចលោកសុភាចារបុរសខ្ញែត ។ ព្រាហ្មណ៍ក៏តែតែទោមនស្សត្រូចចិត្តខ្លាំងឡើងហើយចង់រកយុត្តិធម៌ឲ្យឃើញ ក៏ទៅក្រាបទូលដល់ព្រះពាជាក្នុងព្រះនគរ, ឯព្រះពាជាទ្រង់ស្រឡាញ់ព្រាហ្មណ៍នេះដោយសារកាលពីមុនព្រាហ្មណ៍នេះជាគ្រូអាចារ្យផ្ទាល់ព្រះអង្គ ទើបត្រាស់ហៅលោកនាយកនៃអភិជនហើយមានព្រះពាជឫដ្ឋារថា "បើសិនណាក្នុងរោង ៧ ថ្ងៃទៀត លោកនាយកអភិជនរកឬងនេះមិនឃើញទេ យើងនឹងហួតជារចោល ។

ថ្ងៃបើការធ្លាប់ប្រែសប់ នឹងការមធ្យត្តរបស់លោកនាយកនៃអភិជនដែលជាអ្នកមិនលេងមិនសើចចំពោះយុត្តិធម៌ ម្ដងនេះលោកឃ្លានធ្លាក់ខ្លួនក្នុងទុក្ខមួយយ៉ាងធំ ។ ព្រោះហេតុដូច្នេះ កូនស្រីរបស់លោក គឺព្រះនាងវត្តិយានី ដ៏ល្អហើយមានឫទ្ធានុភាពលើសអាយុរបស់នាង ឃាននាងសួរលោកយ៉ាងសមសួនអំពីហេតុដែលលោកកើតទុក្ខនេះ ក្នុងពេលដែលព្រះនាងបក់ផ្ទឹតដូនលោក ។

លោកនាយកនៃអគ្គិជនតបថា : "ឯហេតុនោះ គឺមានក្រុមញាតិមួយក្រុម មានឪពុកដែលជាព្រាហ្មណ៍ ហើយជាគ្រូអាចារ្យចាស់របស់ព្រះរាជា មានកូនស្រីមួយ, ជនទាំងអស់នេះ ប៉ាត់ស្លឹងពេជ្រមួយដុំដ៏ថ្លៃថ្លៃបំផុត គេលួចក៏មិនដឹង ឬច្រឡំដៃដាក់ឯណាក៏មិនដឹង - រួចបើសិនណាក្នុង ៧ ថ្ងៃនេះ ឪពុកវាកមិនឃើញទេ ព្រះរាជាទ្រង់មានព្រះបន្ទូលថានឹងកំណាត់ឪពុកពីតំណែងព្រមទាំងកិត្តិយសទាំងអស់ចេញ" ។ ព្រះនាងក៏ឆ្លើយដោយឥតគិតថា "សូមអញ្ជើញប្រញាប់ទៅទូលព្រះរាជាវិញចុះថា កូនអាចរកឃើញ ក្នុងរយៈពេលដែលកំណត់នេះប៉ុណ្ណោះ" ។ លោកនាយកនៃអគ្គិជន ប៉ានាំការពិភាក្សានេះទៅទូលស្តេច ។ ព្រះរាជាក៏ដក់ព្រះកេស ហើយទ្រង់ព្រះសំណើចចំអកបន្តិចផង ដែលជាសញ្ញាថាទ្រង់យល់ព្រមតាមការព្រមព្រៀងនេះ ។

ព្រះនាងខត្តិយានីប៉ានសុំឪពុកឲ្យខ្ចីស្នៀនម្នាក់ ដែលជាអ្នកឆ្លាតហើយចេះលាក់ការសម្ងាត់ឲ្យនៅគ្រាមឪពុកវិញ ។ ឯពាក្យសុំនេះក៏ប៉ានដូចបំណង ។ រួចព្រះនាងឲ្យគេទៅហៅព្រាហ្មណ៍ទឹងកិរិយាមកដោយឥតឲ្យបុត្រីនៃជនទាំងគូនេះដឹងឡើយ ហើយព្រះនាងសួរថា : "តើហេតុដូចម្តេច ប៉ានជាអ្នកខ្ចីឪពុកឲ្យសម្បត្តិយ៉ាងសម្បើមនេះ"? ។ ស្វាមីកិរិយាក៏ឆ្លើយថា : "ឯដើមហេតុនៃធនធានរបស់យើងនេះងាយដំរាបទេ គឺតាំងពីគ្រាយថ្ងៃដែលយើងរៀបមង្គលការគ្នាមក ផលដំណាំរបស់យើង

ចេះតែស្អប់ ហើយៈយើងចេះដល់នេះលក់សន្សំថ្កាក់មិនឈប់មិនឈរ, យើងចិញ្ចឹមជីវិតយ៉ាងវេទនាបំផុត ដោយមានបំណងចង់ឲ្យកូនចៅរបស់យើងមានឋាន កុំឲ្យស្គាល់សេចក្តីក្រលំបាកឲ្យសោះ" ។ ទឹកមុខស្រួតត្រង់នៃជនដ៏ប្រពៃនេះ ជាគ្រឿងបញ្ជាក់ពាក្យសំដីទាំងប៉ុន្មាននេះថែមទៀត។ លុះសាកសួរប្រហែល ។ គ្នាយ៉ាងនេះហើយ ព្រះនាងក៏ឲ្យជនទាំងនោះត្រឡប់ទៅផ្ទះវិញ ដោយឋានហាមឲ្យលាក់ការសម្ងាត់នៃកិច្ចពិភាក្សានេះ, ហើយ ព្រះនាងឲ្យគេទៅហៅបុត្រីរបស់ព្រាហ្មណ៍មកសាកសួរយ៉ាងប្រុងប្រយ័ត្ន ដើម្បីកុំឲ្យមានគិតភ័យ ហើយឥតនិយាយដល់ត្បូងពេជ្រដែលឋាត់នោះសោះឡើយ ។

ឯការសាកសួរនេះ ឋានក្លាយបន្តិចម្តង ។ ទៅដាការពិភាក្សាយ៉ាងស្ងៀមស្ងាត, រួចមួយស្របក់មក កូនរបស់ព្រាហ្មណ៍ដោយមានគំនិតហ្មឺងតែមួយដេញតាមដាប់មក ក៏និយាយឋាប់ព្រះនាងថា : "តើយើងមិនមែនជាស្រីអភ័ព្វទេឬអ្វី? បើទុកម្តាយរបស់អ្នកក្តី របស់ខ្ញុំក្តី ទទួលអនិច្ចកម្មទៅ យើងឋានឲ្យរបស់គាត់តែត្រឹមណាដែលព្រះរាជាមានព្រះបំណងព្រះរាជទានមកយើង", ថាហើយនាងក៏នៅស្ងៀម ជាក់ទឹកមុខជ្រប់ដោយគំនិតដ៏ងងឹតរបស់នាង ។ ឯស្នៀនដែលតួនឯងនៅគ្រាយកាំជ្រួនគ្រាស់ ក៏ឋានកត់ពាក្យរបស់នាងយ៉ាងហ្មត់ចត់ ។ លុះគាលណានៅស្ងៀមមួយស្របក់ទៅ, ព្រះនាងឱត្តិយានី ឋាននាំនាង

ជាកូនព្រាហ្មណ៍ចូលទៅក្នុងបន្ទប់ផ្ទាល់ខ្លួនរបស់ព្រះនាង ហើយបិទទ្វារ
សម្ងាត់មិន ឬចង្រៃបរិភោគអាហារបន្តិចបន្តួច ។ ក្រោយមក ព្រះនាង
ចាន់ហៅព្រាហ្មណ៍ទឹងកំរើយឲ្យចូលមកកន្លែងបន្ទប់មួយ ហើយក៏សាកសួរ
ដាច់ដើម, ប៉ុន្តែគ្មានចាន់ការអ្វីទេ ។ ទៅគ្រប់ពាក្យសំនួរដែល
ព្រះនាងចាន់សួរ, ជនទាំងពីរឆ្លើយដដែលថា: "យើងមិនដឹងជាព្រះនាង
សួរធ្វើអ្វីទេ, ទោះបីឲ្យសម្បត្តិធំសន្ធឹងដល់ណាក៏ដោយ ទាំងចាក់ទាំង
គ្រឿងលំអ តែទាំងអស់នេះតើយើងនឹងមិនទុកឲ្យកូនយើងទៅថ្ងៃក្រោយ
ទេឬ? តើយើងនឹងយកទៅកន្លែងដ៏ជាមួយទុកកន្លែងផ្សេងរបស់យើងដែរឬអ្វី?" ។
ឯស្នៀនដែលពួនពីក្រោយកាំងនន ក៏ចាន់តត់ពាក្យទាំងអស់នេះដែរ ដែល
សុទ្ធតែជាពាក្យពិស្តារយ៉ាងច្បាស់នៃចិត្តរបស់ជនទាំងពីរ ។

តាំងពីពេលនោះមក មតិរបស់ព្រះនាងខត្តិយានី ក៏ចាន់សំរេច
ឡើងថា: ត្បូងពេជ្រពិតជានៅក្នុងកណ្តាប់ដៃនាងសិក្ខាកុមារី ។ ប៉ុន្តែ
ការលំបាកបំផុតមិនទាន់ធ្លាប់នៅឡើយ ព្រោះនៅមិនទាន់ចាប់ពិស្តារពិត
ច្បាស់ជាចាន់ ។ ដើម្បីធ្វើការនេះឲ្យសម្រេច ព្រះនាងចាប់គ្រោងការណ៍
មួយភ្លាម, ដំបូងបង្អស់ ព្រះនាងឲ្យមាតាបិតាដ៏ប្រសើរនោះត្រឡប់ទៅ
ផ្ទះវិញ សុំទុកតែកូនស្រីចំនួន ៣ ឬ ៤ ថ្ងៃប៉ុណ្ណោះ ។ ឯឪពុកម្តាយក៏
សុខចិត្តឥតទទឹងអ្វីបន្តិចសោះឡើយ ។

តាំងពីថ្ងៃនោះមក នារីទាំងពីរនាក់នៅជាមួយគ្នាយ៉ាងជិតស្និទ្ធដោយ
មេត្រីភាពដ៏ប្រពៃបំផុត ។ នាងបានបរិភោគបាយជាមួយគ្នា នាំគ្នាអង្គុយ
ក្រោមម្លប់ឈើធំៗ នៃសួនច្បារកន្លែងលោថ្ងៃក្តៅ ដែលនៅជិតស្រះមាន
ទឹកថ្លា ។ នៅពេលល្ងាច នាងនាំគ្នាមុជទឹកកណ្តាលផ្កាឈូកក្នុងស្រះ
នោះ ។ ព្រះនាងខត្តិយានីបានសង្កេតគន់មើលនាងកូនព្រាហ្មណ៍ មិន
ចេះអំពើអ្វីបន្តិចសោះ, ឃើញដូនកាលនាងនេះព្រួយដោយឥតរឿងឥត
ហេតុ; រួចព្រះនាងនឹកមិនឈប់ថា: "អញគ្មានមន្ទិលសង្ស័យអ្វីទៀតទេ
ត្បូងពេជ្រចាកដជានៅក្នុងកណ្តាប់ដៃនាងនេះ, ប៉ុន្តែអញចាប់ថ្នាក់យ៉ាង
ណាដើម្បីឲ្យវាយកពេជ្រមកឲ្យអញហ្ន៎ ! ។ ព្រះនាងខត្តិយានីនេះ
ឈ្មោះថាបានធ្វើសន្លឹកមួយយ៉ាងពិចារ, ថ្ងៃមួយ ព្រះនាងបានទៅនិ-
យាយសុំឲ្យមុកពុកខ្លួនប្រគល់ត្បូងពេជ្រដ៏ប្រសើរ ដែលលោកទុកក្នុង
ឃ្មាំងមកព្រះនាងចំនួន ៣ - ៤ ថ្ងៃ ព្រះនាងនឹងអាចកេតត្បូងពេជ្ររបស់
ព្រាហ្មណ៍ឃើញវិញមិនខាន ។ លោកបានទទួលពាក្យសុំរបស់ព្រះ
នាងយ៉ាងស្រួលរួច ព្រះនាងបានត្បូងពេជ្រនោះហើយក៏ត្រឡប់ទៅវិញ
នារីកូនព្រាហ្មណ៍វិញ រួចទំនុះទៀងភាក់ទាក់នឹងនាងនេះទ្វេមួយពាន់ដង
ឡើងទៀត ដើម្បីធ្វើឲ្យនាងទុកចិត្ត ។ កាលដែលព្រះនាងសូធ៌មើលថា
មុខជាបានការហើយ នៅពេលព្រឹកមួយនោះ ក្នុងពេលដែលនាងនិ-
យាយលេងជាមួយគ្នាយ៉ាងស្កប់ស្កល់ក្រោមម្លប់ពោធិ៍ដ៏ត្រកៃឈ្រៃឈើដែល

មានដើមទឹងមែកជាច្រើន, ព្រះនាងបង្ហាញត្បូងពេជ្រក្រាម ។ នារីកូន
របស់ព្រាហ្មណ៍លុះបានឃើញឋូដ្ឋបំផុតដែលមានតម្លៃថ្លាន់ថ្លាងដែលមាន
ដូច្នេះ ក៏មានចិត្តស្ទើចជាខ្លាំង ហើយសួរព្រះនាងថា: "ត្បូងនេះរបស់
នាងឬអ្វី?" ។ ព្រះនាងខត្តិយានីឆ្លើយតបដោយបន្ទន់សំឡេងថា:
"ត្បូងពេជ្រនេះ របស់ឪពុកខ្ញុំទេ, ប៉ុន្តែខ្ញុំជឿទុកចិត្តសម្លាញ់ ខ្ញុំនឹង
ប្តាប់សម្លាញ់ដោយស្មោះត្រង់ចំពោះ, លាក់បាំងអី ត្បូងនេះខ្ញុំបានលួចជា
ច្រើនខែមកហើយ ព្រោះខ្ញុំគិតថាបើសិនណាជាឪពុកម្តាយខ្ញុំស្លាប់
ទៅ ត្បូងពេជ្រនេះនឹងទៅជាទ្រព្យព្រៃជាមិនខាន ខ្ញុំមុខជាអស់បាន
ហើយ, បើខ្ញុំលួចយកមកយ៉ាងនេះខ្ញុំសង្ឃឹមថា ពិតជាបានមកខ្ញុំ" ។

នាងកូនព្រាហ្មណ៍ឆ្លើយវិញក្រាមដោយឥតប្រយ័ត្នថា: "ខ្ញុំមាន
ត្បូងមួយ ខ្ញុំលួចពីឪពុកម្តាយខ្ញុំដូចអ្នកបងដែរ" ។

ព្រះនាងខត្តិយានីតបថា: "យើអើហ្ន៎ អ្វីយ៉ាងដូច្នេះ? ហេតុ
ម្តេចយើងក៏មានគំនិតនឹងល្បិចត្រូវគ្នាម្ល៉េះ? ប៉ុន្តែនៅពីនេះគ្មានអ្នកណា
មួយអាចសង្ស័យខ្ញុំបានទេ, ឪពុកខ្ញុំក៏មិនដឹងកិច្ចរបស់ខ្ញុំដែរ; បើដូច្នេះ
យើងត្រូវជាក់ត្បូងពេជ្ររបស់យើងកងទីជាមួយគ្នា បងនឹងថែទាំទៅ
ក្នុងនាយ៉ាងហ្មត់ចត់ មិនឲ្យអ្នកឯណារកឃើញ ដឹងដល់តំបូងត្រឹងរបស់
យើងឡើយ ។

ឯនាងកូនព្រាហ្មណ៍ដែលភ្ញាក់គេដឹង ហើយដែលចាប់តឹងទ្រូងនឹងគ្បូងពេជ្រតាំងពីយូរមកហើយនោះ ក៏សុខចិត្តភ្លាមហើយប្រគល់គ្បូងឲ្យមកព្រះនាងវត្តិយានី ។

ឯព្រះនាងជាស្ត្រីប៉ិនប្រសប់ធ្វើឧបាយកលយ៉ាងប្រសើរ បានបញ្ជូនកូនព្រាហ្មណ៍ឲ្យទៅផ្ទះរបស់ឪពុកម្តាយខ្លួនវិញ រួចគេទៅចំលាក់គ្បូងពេជ្រទៅបង្ខំដើងឪពុករបស់ព្រះនាង ហើយដំណាលអំពីពេលដែលនាងជូនគ្បូងពេជ្រដែលឪពុកព្រះនាងឲ្យខ្ញុំ ។ ឪពុកព្រះនាងភ្ញាក់ខ្លួនបានសួរទៅស្មៀនអំពីដំណើរដែលរកឃើញនេះ ។ ដើម្បីនឹងធ្វើយពាក្យសួរនេះ អ្នកបំរើជាស្មៀនត្រង់នោះ បានអានពាក្យចំណោទនៃមាតាបិតានឹងពាក្យចំណោទនៃបុត្រីយ៉ាងពិស្តារ, រួចដំរាបលោកយ៉ាងខ្លី អំពីរឿងដែលបុត្រីរបស់លោកជួយបំពេញកិច្ចដោយមានតំរិះ. អំពីរឿងបុងបង្អស់ក្នុងសួនច្បារ ។ លោកកុងរ៉ីយ៉ក៏ស្រែកឡើងថា : "កូនអញពេញជាមនុស្សជាតិមួយបរិបូណ៌ដោយសោភណចរិយា" រួចលោកអញ្ជើញយកគ្បូងពេជ្រទៅថ្វាយដល់ព្រះពជាក្សាម ដោយមានទាំងបុត្រីរបស់លោកនឹងស្មៀនដែលមានទាំងគ្រជាសជូនជាប់ទៅឯង ដើម្បីទូលព្រះពជាឲ្យជ្រាបថា មិនមែនខ្លួនលោកទេដែលរកឃើញនោះ គឺដោយសារសោភណចរិយានៃបុត្រីរបស់លោកទេ ដែលរកឃើញគ្បូងពេជ្រនេះ ។

កាលណាគេប្រគល់ត្បូងពេជ្រទៅព្រាហ្មណ៍វិញ ព្រាហ្មណ៍ត្រេកអរជាពន់ពេក ហើយទូលសួរព្រះរាជាថា តើគេរកត្បូងនេះឃើញក្នុងកន្លែងណា ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ហើយត្រាស់ថា "រកឃើញក្នុងក្អែករបស់អ្នក ។ ដល់ថ្ងៃក្រោយមក ព្រះរាជាលើកបុត្រីនៃកុង្ស៊ីយ៍របស់ព្រះអង្គឲ្យអង្គុយដិតព្រះអង្គលើស្មេតច្ឆត្រ តាំងជាមហេសីក្នុងព្រះរាជអាណាចក្រ ដោយសារនាងបានបង្ហាញសោភណចរិយានឹងការចេះដឹងយ៉ាងបរិបូណ៌ នឹងដោយការបានឆ្លើងឆ្លងពីមួយទៅមួយ តាមពាក្យទូន្មាននៃព្រះនាងខត្តិយានី ធូដាម្មាសារី (Tboudamma Sari) ដែលបាននិយាយថា "សុភាបើអ្នកចង់បានជាស័ក្តិសិទ្ធិពិតប្រាកដនោះ មុននឹងសម្រេចការអ្វីផ្សេង ។ ត្រូវធ្វើអង្គតមួយយ៉ាងពេញលេញយ៉ាងហ្មត់ចត់យ៉ាងវែងឆ្ងាយ លើការទាំងពួងដែលចំណុះក្នុងឫទ្ធិរបស់អ្នក រួចសោភណចរិយានឹងចាំនៅឡើង ក្នុងការដំឡុងដំរេរបស់អ្នកមិនខាន" ។

(អាឥ)

រឿងសាមកុក

អ្នកឧកញ៉ាវិបុលកជសេនា ខូ-កន ប្រែរៀបរៀង

(ពន្យល់)

ខណៈកាលសំបុត្របក្សីដល់អួនស៊ុតនោះ មានគាហាន់ម្នាក់ ជំរាបអួនស៊ុតថា ស៊ុនកៀនកាលទៅក្នុងស្រុកតាំងតាំង ឧបមាដូចខ្លាធំខ្លាំងពូកែណាស់ ឯតាំងតុៈឧបមាដូចខ្លាឃ្មុំ តែឃ្លាស៊ុនកៀនលើកគាហានចេញទៅជាច្រើនមុខ បើវាយស្រុកឡុកអៀងចាប់តាំងតុៈសំឡាប់ឃ្លានវែលាណា ស៊ុនកៀនក៏នឹងកំរើបចិត្តតតែគាតខ្លាចនរណា ឧបមាដូចខ្លាធំខ្លាំខ្លាឃ្មុំឃ្លាន ក៏រតែតែក្បាហានគាចសាហាវលើសពីដើម ហេតុនេះខ្ញុំយល់ឃើញថា នឹងស្រួមកុំមញ្ជូនស្បៀងទៅឲ្យស្រួលជាង បើពួកសេនាគាហានគ្មានស្បៀងអាហារបរិភោគហើយ តង់នឹងរសាប់រសាយចយអស់ពលាការ ដូចខ្លាជាប់សង្កែងលែងមានកំឡាំងសោះ ។ អួនស៊ុតឃ្លានភ្លក្ខូច្នោះ ក៏ចូលចិត្តគិតមិនឲ្យបញ្ជូនស្បៀងទៅ ខណៈនោះពួកកងទ័ពស៊ុនកៀនក៏ជាប់អស់ស្បៀងអាហារ នឹងរកឃ្លាយទឹកបរិភោគពុំឃ្លានសោះអស់កំឡាំងគាំងអស់គ្នា ។

ឯពួកគយល្បាតខាងស្រុកក្រុង លុះឃ្លានដឹងដំណឹងដូច្នោះ ក៏នាំយកសេចក្តីនោះទៅនិយាយបរិហារកងទ័ពមន្ទាយ នោះនាយគាហានឈ្មោះលីសុកឃ្លានឮក៏ទៅប្រឹក្សានឹងហួយុងថា តឡូវកងទ័ពស៊ុនកៀន

អត់ឃ្លានឡាយទឹកសន្ធឹកណាស់ បើដូច្នេះយប់នេះខ្ញុំនឹងសុំនាំគាហានចូលទៅខាងក្រោយបន្ទាយស៊ុនកៀន សុំឲ្យលោកលើកទ័ពចូលទៅខាងមុខបន្ទាយវាយឆ្ពប់ប្រសព្វគ្នា ឃើញនឹងបែកបានដោយងាយ ហើយនឹងចាប់យកខ្លួនស៊ុនកៀនឲ្យបាន ។ ហួយុងយល់ត្រូវផងក៏ចេញទៅចាត់ចែងបែងគាហានជា ២ កងតាមដែលគិតទុកនោះ ខណៈកាលលើកពលទៅដល់បន្ទាយស៊ុនកៀនពេលយប់យាម ២ ហួយុងក៏ឲ្យគាហានកាយស្ករហៅកញ្ជ្រៀវចូលប្លន់យកបន្ទាយ ។

ឯស៊ុនកៀន ក៏មានសេចក្តីភ័យខ្លាំងណាស់ សុំរៀបខ្លួនពាក់គ្រោះ ហើយទ្បើងដំរីសេះកាន់ដាវចេញមកតយុទ្ធនឹងហួយុងបាន ៥ ភ្លេង ។ ស៊ុនកៀនក្រឡេកទៅឃើញពន្លឺភ្លើងខាងក្រោយបន្ទាយភ្លឺស្រឡះ ឃើញគាហានផ្លេះបះពេញក្នុងបន្ទាយ ខ្លះក៏រត់ព្រាត់ប្រាយស្ងាប់គរលើគ្នា ចូរមៅម៉ូមាទ្បើងសេះបរទៅតាមស៊ុនកៀន ។

ពេលនោះ គាហានហួយុងក៏តាំងព័ទ្ធជុំវិញ ស៊ុនកៀននឹងចូរមៅក៏សុំរទៅចាក់កាប់ទំលាយចេញទៅបាន ហួយុងបំផ្លាយសេះតាមប្រកិតជិតពីក្រោយទៅ ស៊ុនកៀនក៏ងាកមកវិញគាញ្ចក្ចាញ់ហួយុង។ កំងការពារប្លែញបានតាំងសងខាង ស៊ុនកៀនថែមចាញ់ខ្លាន់ៗទៅទៀត ដងធ្វើចាក់ដាច់ជា ២ ស៊ុនកៀននឹងចូរមៅខប់ពុំឈ្នះ ក៏បំផ្លាយសេះរត់ទៅ ហួយុងក៏បំផ្លាយសេះតាម ចូរមៅនិយាយនឹងស៊ុនកៀនថា មួតដែលលោកពាក់

នោះ ពួកសត្រូវចាំបានច្បាស់ណាស់ លោកចូរផ្ញាស់មកឲ្យខ្ញុំពាក់វិញ ស៊ុនកៀនក៏ដោះមួកហុចឲ្យទៅហើយចំផាយសេះបែកផ្លូវគ្នាទៅដោយខ្លួនឯង។ នោះហួយឃុងនឹងភាហានចាំងពួនក៏ចំផាយសេះតាមទៅ មិនដឹងជាស៊ុនកៀនទៅខាងណាចាំសំគាល់ច្បាស់តែមួក ហួយឃុងគិតថា ស៊ុនកៀនប្រាកដជាមិនបរសេះតាមចូរមើ ឯចូរមើឃើញគេដេញប្រកិតជិតខ្លួនណាស់ ក៏ផ្ញាស់ដោះមួកនោះពាក់លើគល់ឈើ ហើយគេចសេះរះចូលទៅក្នុងព្រៃ កាលហួយឃុងដេញជិតប្រកិតតាមទៅនោះ ក៏ជាវេលាពាក់កណ្តាលអធ្រាត្រស្ងាត់ ហួយឃុងមិនដឹងកលចូរមើ ម្តើលទៅស្គាល់បានតែមួក ទើបឲ្យភាហានចោមព័ទ្ធគល់ឈើជុំវិញ ហើយបុះញ៉ាំនឹងធ្នូតម្រង់មួកនោះនៅជាយូរណាស់ លុះឃើញមិនកំរើកសោះ ហួយឃុងឲ្យនាំភាហានចូលទៅមើល ក៏ឃើញឯមួកពាក់លើគល់ឈើសោះ ។

ឯចូរមើកាលរត់ទៅ ។ ពួនទៅក្នុងព្រៃលបង់មើល ឃើញហួយឃុងនឹងភាហានចោមព័ទ្ធគល់ឈើជូរច្នោះ ក៏សំដុះបរសេះត្រឡប់មកនឹងភាហួយឃុង ខ្លួលហួយឃុងឆាកទៅឃើញក៏ញាក់សេះសំដុះទៅទល់មុខគ្នា ហួយឃុងក៏ស្រែកគំហកសង្ឃឹកឲ្យចូរមើ ហើយយកដាវកាប់ត្រូវចូរមើដាច់ពាក់កណ្តាលខ្លួនធ្លាក់ពីលើសេះស្លាប់ ។

លុះព្រឹកក្តីស្អាង ហួយឃុងក៏លើកពលភាហានត្រឡប់ចូលបន្ទាយគយខាងស្រុកក្រូង ឯចៀផ្ទៅអ៊ុំយកាយនឹងហ៊ានតុងព្រមទាំងភាហានខាងា

ដែលនៅសល់ពីបែកខ្ញែកគ្នាទៅនោះ លុះលើកទៅដួបប្រទះនឹងស៊ុនកៀន។ ក៏នាំគ្នាឡប់ចូលទៅក្នុងបន្ទាយលៀងតុង ហើយធ្វើសំបុត្របកទៅដល់អ្នកសៀវតាមដែលបានច្បាំងគ្នានោះ អ្នកសៀវបានដឹងសេចក្តីដូច្នោះក៏ខឹងមនស្សណាស់ ទើបប្រដុំចៅហ្វាយខ្លួនតាំងអស់មកប្រឹក្សាថា ឥឡូវនេះស៊ុនគៀនជាខាហានខ្លាំងពូកែបរាជ័យចាញ់ហួយៗដូច្នេះ យើងនឹងគិតប្រការម្តេច? មួយទៀត ចុ៎ះសិនលបប្រៃចុ៎តុង ទៅជណ្តើមច្បាំង ក៏តាំងតែអន្តរាយស្លាប់ខ្លួនទៅទៀតហើយ ខ្លួចខាតខាហានក៏ច្រើនៗ វេលានោះ នាយកងនាយទំពាំងពួងមិនទាន់ឆ្លើយថាដូចម្តេច ខ្លួលឡៅតី គួនអ៊ូ តៀវហ៊ុយ ដើរចូលទៅឈរពីក្រោយកងស៊ុនចាន ។ អ្នកសៀវក្រឡេកឃើញរូបរាងអ្នកទាំង ៣ ធំមាំមួន មានខ្លួនខ្ពស់ស្រឡះមានអាការដូចជាញញឹមញញែម ក៏សួរកងស៊ុនចានថា ៣ នាក់ដែលឈរនៅពីក្រោយអ្នកនោះឈ្មោះអ្វី? កងស៊ុនចានងាកទៅឃើញឡៅតី ក៏ទាញដៃឲ្យចូលមកឈរពីមុខ ហើយជំរាបថា អ្នកនេះឈ្មោះឡៅតីជាសំឡាញ់នឹងខ្ញុំកាលនៅជាកូនសិស្សរៀនតាំងពីតូចមក ឥឡូវបានធ្វើជាចៅហ្វាយស្រុកផងដូនគួន ។

ចូតូឆ្លើយថា ឡៅតីនេះ កាលគ្រាពួកចោរដួតក្បាលលឿងបានទៅជួយច្បាំងដែរ កងស៊ុនចានឆ្លើយទៀតថា ឡៅតីនេះជាពូជព្រះរាជវង្សព្រះចៅហ័នតេ មានសេចក្តីគាប់ប្រសើរក្នុងរាជការជាច្រើនគ្រា ថា

ហើយកងស៊ុនថានឲ្យទៀតពីគំនាប់អួនសៀវ ។ ក៏អញ្ជើញឲ្យទៀតពីឲ្យអង្គុយ
ក្នុងទីសមគួរ ឯគួនអ៊ូនឆីតៀវហ៊ុយក៏ចូលទៅឈរពីក្រោយទៀតពី ។

ខណៈនោះ ហួយុងឃុំនាំពួកសេនាទាហានចេញទៅដល់មុខបន្ទាយ
អួនសៀវ ហើយឲ្យទាហានយកឈើវែងត្បៀតមួកស៊ុនកៀនគ្រវែងលើក
ខ្ពើង ហើយប្រកាសថា រ៉ឺយអាពួកចៅហ្វាយស្រុកខែត្រក្រៅ ដែលជា
សត្រូវក្បត់ ឯងបានចាត់ប្រើស៊ុនកៀនឲ្យចេញទៅច្បាំង យើងក៏តាំង
ព័យបែកឃ្លាំចាក់តាប់សម្លាប់ពលទាហានជាច្រើនណាស់ហ៊ាយ តឡូវ
នេះ ដែលជាតួនាយដំនោះ ចូរចំពោះចេញមុខមកទៀតចុះនឹងតយុទ្ធគ្នា ។
សេះបំរើបានឮដូច្នោះ ក៏យកសេចក្តីទៅជំរាបដល់អួនសៀវ។ ប្រឹក្សានឹង
នាយទ័ពនាយកងថា ហួយុងលើកទ័ពចូលមកធ្វើអាការដូច្នេះ នរណា
នឹងអាសាចេញទៅតទល់បាន យូសុតទាហានអួនស៊ុតស្រែកឡើងថា
ខ្ញុំបាទនឹងសូមអាសាចេញទៅតទល់នឹងហួយុង ។ អួនសៀវបានឮដូច្នោះ
ក៏ចាត់ទាហានឲ្យយូសុត ។ លើកទាហានចេញទៅ តយុទ្ធនឹងហួយុងបាន
៣ ភ្លេង ហួយុងយកដាវកាប់យូសុតធ្លាក់ពីលើសេះស្លាប់ ។ សេះបំរើ
យកសេចក្តីចូលទៅជំរាបអួនសៀវ។ នឹងចៅហ្វាយខែត្រតាំងពួនប្រឹក្សាថា
ពេលនេះនរណានឹងអាសាចេញទៅតយុទ្ធនឹងហួយុងទៀត ខណៈនោះ
ហ៊ានហុកចៅហ្វាយស្រុកគីដីរធ្វើយឡើងថា ខ្ញុំមានទាហានឯកម្លាក់
ឈ្មោះប៊ូហាង នឹងសុំអាសាចេញទៅកាត់ក្បាលហួយុងមកជូនលោកឲ្យ

ជាន អ្នកស្រីមានសេចក្តីត្រេកអរណាស់ ក៏ចាត់ទាហានឲ្យបួនហាន ។
រៀបខ្លួនពាក់គ្រែហើយឡើងជិះសេះកាន់ភ្លុយថាធំជាអាវុធ លើកទាហាន
ចេញទៅតយុទ្ធនឹងហួយុង៉ជាន ៣ ក្លេង ហួយុង៉យកជាវកាប់បួនហាន់ធ្លាក់
ពីលើសេះស្លាប់ ។ សេះបំរើក៏នាំសេចក្តីចូលទៅ ជំរាបអ្នកស្រី គ្រានោះ
នាយកង៉នាយទំពស្តាប់ដឹងសេចក្តីក៏ភ័យជាម្ភៃណាស់ អ្នកស្រីនិយាយ
ថា ទាហានឯករបស់យើង៉មាន ២ នាក់ឈ្មោះង៉ាន់លៀង ១ ប៊ុនធី ១ តែ
មិនទាន់ឃើញមក បើមកហើយក៏នឹងខ្លាចអ្វីដៃហួយុង៉នោះ បើដូច្នេះ
គ្រានេះ នឹងមាននរណាយកអាសាជាន ។

ក្នុងពេលនោះ កូនអ៊ូជំរាបអ្នកស្រីថា ខ្ញុំជាននឹងសុំអាសាចេញទៅ
កាត់ក្បាលហួយុង៉មកជូនលោក អ្នកស្រីឮហើយសួរគេបថា ដែលអ្នក
ឯងនឹងសុំអាសានោះតើខ្លួនជាតំណែង៉អ្វី ? កង៉ស៊ុនចានជំរាបថា អ្នកនេះ
ឈ្មោះកូនអ៊ូជាប្អូនឡៅពូ ទីជាសេនាសេះកាន់ឆ្នូ អ្នកស៊ុតជាន់ឮដូច្នោះ
ក៏ខឹង៉ណាស់ទើបស្រែកគំហកថា កូនអ៊ូគ្មានតែជាទាហានឡើងជិះសេះ
ប៉ុណ្ណោះ អាចមកមើលង៉ាយនាយទំពនាយកង៉ហ្មាយខ្ញុំត្រង់ពួន
ហើយអួតអាង៉ថានឹងសុំយកអាសាមិនគួរការសោះ ព្រោះទាហានហ្មា-
ហ្មាយខ្ញុំត្រង់អស់មាននៅច្រើនណាស់ ល្មមនឹងប្រើការគេទៅគ្រប់
គ្រាន់ជាន ហើយឲ្យទាហានបណ្តេញកូនអ៊ូចេញ ។

ចូរឆ្លុកយ៉ាត់អួនស៊ុតថា អ្នកកុំអាលខឹងសំបាស់ខ្ញុំ ត្រកលការកួនអ៊ីនេះទៅមានថ្លៃដៃខ្លាំងពូកែមែន ទើបសុំយកអាសា បើមិនសមជូចមាត់ថា ខឹងយកទៅសងល់ស្ងាប់ក៏បាន អួនសៀវឆ្លើយថា កួនអ៊ូជាគាហានឡៅ បើខឹងឲ្យចេញទៅតយុទ្ធខឹងហួយង ។ ក៏គង់ខឹងសើចចំអកឡកលេងថា ក្នុងកងទ័ពពួកយើងគ្មានគាហានឯកសោះឡើយ ចូរឆ្លុកឆ្លើយតបថា ខ្ញុំបានឃើញរូបកួនអ៊ូនេះជាគាហានធំមាំមួនគួរជាឯកណាស់ហួយង គង់មិនស្គាល់ជាគាហានឡៅទេ កួនអ៊ូដំកបថា ខ្ញុំបានខឹងសុំយកអាសាចេញទៅគ្រានេះ បើមិនបានកាលហួយង នាំមកជូនលោកមេ សុំឲ្យលោកយកកាលខ្ញុំបានជាជំនួសចុះ អួនសៀវបានឮដូច្នោះ ក៏អស់គំនិតគិតបែរជាមានចំណុតត្រកអរហើយទើបបានចាត់ចែងគាហានឲ្យកួនអ៊ូ ចូរឆ្លុកឲ្យយកស្រាទៅកំដៅហើយយកមកចាក់ឲ្យកួនអ៊ូ ១ ពែង កួនអ៊ូទទួលគំនាប់ឆ្លើយជំរាបចូរឆ្លុកថា ខ្ញុំបានត្រឹមតែថ្នាក់គាហានឡៅ ខឹងទទួលយកស្រាពីលោកមកទទួលទានពុំសមគួរ សូមឲ្យលោកវង់បង្អង់សិនចុះ បើកាលណាខ្ញុំបានចេញទៅបានកាលហួយង់មកជូន ខ្ញុំបានខឹងសុំទទួលស្រាពីលោកទទួលទានជាក្រោយ ថាហើយកួនអ៊ូក៏ឡើងសេះកាន់ជាវវែងចេញទៅតយុទ្ធខឹងហួយង ។

អ្នកទកញ្ញាព្រះឃ្លាំង នង រៀបរៀង

(តមក)

លុះល្ងមពារព័ - លាល័ក្ខណ៍នាទី ឫក្សបើកប៉ហាន ដោតឫក្សតន្ទុះ
ស្រឡះបើកឫាន ធាយាមែនមាន សេសសោតទត្តម ។ ទើបព្រះរាជា
ទ្រង់នាំព្រះមហា - មហេសីទត្តម ស្តេចតង់ផ្ទាប់ធ្មឹម ទន្ទឹមលើព្រៃ
មាសមានចៀមចំ លើខែនទិព្វទី ។ ទៀងទើបប្រគំ ប្រគបក្ងេង
ផ្ងំ ត្រែសង្ខ៍ភេរី គោះគង់គង្គែង គ្រប់ក្ងេងតន្ត្រី ព្រាហ្មណ៍ព្រឹទ្ធ
ព្រឹទ្ធី ថ្វាយជ័យមង្គលអរ ។ ព្រះកុំភ៍ឫាកង ប្រគបសន្ធត ចំរើន
ព្រះពរ ប្រពៃតបៈ តេជះបវរ ថ្វាយព្រះនាមករ សន្ធតឡើងជា ។
សម្តេចព្រះឫាទ គោតកុលពាជជាត វរវង្សត្រង្ឃ ខត្តិយោត្តម បរម
ក្សត្រា ឯកអគ្គរាជា បរមបពិត្រ ។ អស់មុខមន្ត្រី ចំរើនព្រះស្រី
បវរវរិធ វរុឡ្ឍិពរ សាទរពេកពិត សុខសួស្តីសម្រិទ្ធ សម្រេចការគួរ ។
ឲ្យលេងមហោស្រព រឫាំរគ្រប់ ពេងរៀបជាជួរ អស់ពស្តាំងឡាយ
សប្បាយបបួល ប្រុសស្រីស្រីបស្រួល មកមើលត្រៀបត្រា ។ ស្រី
ខ្លះពកូន ជែករជែតពពូន ពពាំន្ធពានពារ ចង់ចរចូលជិត ពុំគិតអាត្មា
ស្អុះស្អាបមហិមា ស្ងាបកូនខោដៃ ។ ខ្លះមើលព័ត្រៀ ចង់ជែកចូលទៅ
គេឫានស្ទើរក្បាយ រាងរាចៀសចរ មកឈរហាលថ្ងៃ

មុខមាត់ក្រៀមក្រៃ ដូចគេហាលឆៀត ។ អស់ស្រីក្រមុំ ជណ្តើបង្ហាប់ លាបម្សៅរមៀត ប្រុសប្រែយង់យល់ រកកល់ផ្កែកផ្កែត ធ្មុញផ្ចាប់ ប៉ាន់បៀត ដុំដៃដល់ដោះ ។ ដោះដៀងវាវែះ ឆ្កើជាឯងអែះ ខ្លួនប្រាណស្មាន់ស្មោះ ឆ្កើសោះកន្តើយ ព្រងើយស្រីខោះ ជំងឺជាពាលគោះ ដោះដៃដើរចេញ ។ មហាជនដុំជុំ ស្រែចស្រុះអឺងអរ មើលមីរពោសពេញ កង់រោងចង្រ្កែត ចុះច្រែតដុំវិញ ពុំចង់ចរចេញ ទៅផ្ទះអាត្មា ។ ខ្ញុះមើលពីព្រឹក អត់ប៉ាយអត់ឱក អត់ទាំងឆីស្លា ភ្ញាំងក្លេចប្រាណប្រឹង សម្ងឹងសោះសា ខ្ញុះសរសើរថា ល្អម្តេចអម្បាយ ។ ព្រះអង្គឲ្យលេង សព្វសារពើល្បែង មហោស្រពទាំងឡាយ គ្រប់ប៉ុនពីរថ្ងៃ ក្សត្រិយ៍ពណ្ណពាយ ឲ្យទៅយកយាយ ជាធម្មិមាតា ។ បន្ទូលប្រើទៅ ថាអាមាត្យទៅ ចូរចរកគ្នា យកអង្រឹងនូវ តាំងយូយាគ្រា ទៅយកមាតា ធម្មិអញមកថ្លាត់ ។ អាមាត្យចង់ចាំ ព្រះពជបណ្តាំ ប្រញាប្រាណច្រណៃប័ត្តន៍ ក្រញ្ជ្រៃបង្គំ ប្រណម្យមហាក្សត្រ លុតលាចេញថ្លាត់ ដូចព្រះអាជ្ញា ។ ដើរដល់ស្រុកស្រែ ស៊ើបសួរកគេប្រាប់ហើយនាំគ្នា ចរចូលដល់ទៅ លំនៅគឹហា ដូនចាស់ជាក់ស្លា ឲ្យឆីស្រែចស្រាប់ ។ អាមាត្យវិថ្លង់ថា ដ្បិតព្រះពជា មានព្រះបញ្ជ័ត្តិឲ្យយកដូនទៅ តម្រូវធាប់។ អាមាត្យពុំប្រាប់ ហេតុចង់ចំអន់ ។ ដូនចាស់កិតក័យ ញ័រដើងញ័រដៃ ញ័រខ្លួនកិតពន់ កិតពេកកង់ប្រាណ

ក្រែងមានទោសធ្ងន់ ញ៉ាំរមាត់ស្ទើរគ្រុន សំពះប្រណម្យ ។ អង្វរ
លោមថា អ្នកអើយព្រះមហា - ក្សត្រឲ្យឃុំខ្ញុំ ទៅតើទោសម្តេច ការ
កំចួសុខុម អាស្រូវប្តាប់ខ្ញុំ ឲ្យពិតកុំលាក់ ។ អាមាត្យហ៊ាស យាត់
ទៅជូនចាស ថាកុំឆ្អែលភ្លាត់ ថាខេអ្នកយាយ ចៅប្តាយប្តាប់អ្នក ឲ្យ
បានដឹងជាក់ យាយកុំបារម្ភ ។ ក្សត្រថ្លែចមចៅ ឲ្យឃុំយាយទៅ
ទឹងឲ្យជាធំ ថៃទាំព្រះមែ"ខាង ខុនណាង ព្រះស្ងុំ ចិញ្ចឹមជាដំ - ខាវតែង
គាល់ហ្អា ។ បើបានជាធំ សមអ្នកយាយពុំ - ស្គាល់យើងជាចៅ អាង
ស្តេចអាស្រូវ ឲ្យចូលក្នុងក្រែ យលយើងដើរទៅ ប្តាសប្រែមុខចេញ ។
ជូនចាស់ឆ្លើយថា ហៃអ្នកអាជ្ញា កុំចំអន់អញ អ្នកអាស្រូវប្តាប់ ឲ្យ
ឆាប់មកមិញ កុំអ្នកជន្ធញ ជន្ធទៅមក ។ យើងជាអ្នកស្រែ
កំសត់ឥតគេ ណាទឹងរាប់រក ទៅដោយស្រែស្ងាត់ ចុងកាត់មាត់ញាក
កុំអ្នកចំអក ចំអន់អាយនាយ ។ អាមាត្យឆ្លាស់ឆ្លើយ ថាអ្នកយាយអើយ
ពាក្យខ្ញុំប្តាប់ប្តាយ ពិតៗច្មេងឯង ពុំក្លែងពុំក្លាយ ស្តេចថាអ្នកយាយ
ឯងជាម្តាយធម៌ ។ កាលស្តេចពិចារ ខ្ញុតិតតោកយ៉ាក តតអ្នកណា
ស្គាល់ មានតែអ្នកយាយ ជាម្តាយមានធម៌ ឈឺឆ្អាលរៀងរាល់ ដល់
ស្តេចមានបុណ្យ ។ ឥឡូវស្តេចនឹក ស្តេចតិតរលឹក អ្នកយាយពេកពន
យកអ្នកយាយទៅ ស្តេចនឹងសងគុណ ខ្ញុំពុំចំអន់ ចំអកអ្នកយាយ ។
ជូនចាស់ស្តែងស្តាប់ អាមាត្យប្តាយប្តាប់ ដំណើរសព្វសាយ អរឯង

ពេកក្តាត់ មុខមាត់តែកាយ ចិញ្ចើមពណ្ណរាយ ពន្រ្លឹមចរចា ។ ដើម
អញដើមគាណ ថាស្តេចពប់អាន តែងតួម្ចឹម្ចា ដូនទឹកលាបម្សៅ ពាក់
អាវព្រៃផ្កា ស្បែកខៀនខេសជា ហានខៀវផ្ទៃមេឃ ។ លាបគ្រមួនមាត់
ស្អាងខ្ចនស្អាតបាត អង្គុយផ្ទៀងផ្នែក បែរបើកកញ្ចក់ ឆ្លុះមុខយលប្លែក
ថាអញស្អាតពេក ផ្សាដោយខ្សែយណាស់ ។ ល្អតែជាតា ហោរលោក
ទាយថា មានបុណ្យឯចាស់ លោកទាយនេះធ្លុត ប្រាកដត្រូវណាស់
ត្រូវនឹងអម្ចាស់ ពប់អានមេត្តា ។ ដូនចាស់អួតអង្គ ពិតពុំផ្សុះផ្សែង
ចុះចាកគ្រីហា ទ្បើងដំរកង្រឹង ទៅនឹងអាជ្ញា ផ្តាំអ្នកស្រុកថា មើល
ឆ្លុះអញជង ។ ដូនចាស់ចិត្តឆ្មើង ខ្មៃសំយុងដើង ដល់ត្រៃរបង
កាន់ធ្នូតក្រងាស គ្រពសម្ពង ។ ប្រាកបក់ទៅខ្ចង ថាអញក្តៅណាស់ ។
ពលកាន់តាំងយូ ប៉ាំងពុំឲ្យត្រូវ ថ្ងៃដល់ដូនចាស់ ពលសែងរោយស្មា
ហៅគ្នាទៀតផ្ទាស់ ចិត្តចង់ហ៊ាស ដូចព្រះអាជ្ញា ។ ដល់ទ្វារកាំងនោះ
ជាក់ដូនចាស់ចុះ ទើបពាជអមច្ចា នាំទ្បើងលើហាន ពិមានក្សត្រា ខ្ពង
អង្គវន្ទា អង្គុយពីឆ្ងាយ ។ ស្តេចទតទៅយល់ ដូនចាស់មកដល់
ត្រាស់ថាមកអាយ មកឲ្យទៀបទាល់ កុំគាល់ពីឆ្ងាយ ចូរមកនិយាយ
កុំប៉ីខ្លាចអ្វី ។ ដូនចាស់ត្រេកអរ យល់ស្តេចសាទរ ទៅទៀបខែនទី
ស្តេចបើកព្រះស្ងួរ បន្ទូលទៅខ្ញី ប៉ៃនៅធ្លើអ្វី ចាត់បុរសិនបក ។
យើងខ្ញុំនឹងក្រែ ចង់យល់មុខប៉ៃ ប៉ៃតួនសំពក ដល់ប្រើអាជ្ញា យាត្រា

ទៅវេត ទើបបានបៃមក បៃមិនគិតកូន ។ ដូនចាស់ទូលថា ខ្ញុំម្ចាស់ពិត ជា មិនដឹងសោះសូន្យ នៅតែម្នាក់ឯង កណ្តែងតែកូន តតបងតតប្អូន ណានឹងប្រាយប្រាប់ ។ លុះឃើញអាជ្ញា ទៅទើបប្រាប់ថា អម្ចាស់មានកំពូ ឃានសោយរាជ្យស្រេច ជាស្តេចគួរគាប់ . ម្ចាស់អើយ ខ្ញុំស្រាប់ តែភ្ញាក់ខ្លួនអុរ ។ អរនឹងអម្ចាស់ មានបុណ្យកៃគ្រាំស់ លើសលោកនិករ មេត្តាប្រោសប្រាណ រាប់អានស្មោះសរ ហេតុនោះខ្ញុំអរ អរតតុបមា ។ ខ្ញុំមកដៃទេ មិនមានបន្ទូ ចេតខ្ទរដួងស្មារ មកប្រាប់ព្រះអង្គ ព័រពង្សថ្លៃថ្លា ដ្បិតព្រះអាជ្ញា តែងតឿនពេកពន់ ។ សម្តេចរាជា អាសូរកុរណា ដូនចាស់លើសលន់ ប្រទានមាសប្រាក់ យសស័ក្តិទ្រព្យធន ពស្ថាទិព្វតន់ ខ្ញុំប្រសខ្ញុំស្រី ។ ប្រទានអង្គឹង តាំងយូចង់នឹង រវេះដំរី ស្តេចឲ្យជាធំ លើស្នំនារ លើសលែងអស់ស្រី ខុនណាងនានា ។ ឲ្យនៅក្នុងកំផ ថែទាំអស់ឃ្លាំង មាសប្រាក់ទ្រព្យា ដូនចាស់និត្យនៅ គាល់ហ្លួវរាជា សព្វទិនទិវា កេរ្តិ៍មក្សាខ្ពស់សារ ។

ចប់ព្រហ្មគីត

ព្រះពង្សពោធិសត្វ សោយសម្បត្តិសម្បូណ៌ប - រិបូណ៌ជានត្រង់ នគរ ក្រុងពារាណសីសុខ ។ ដោយបុណ្យដោយបារមី ក្សត្រទាំងពីរ បន្ទោខុក្ខ ពស្ត្រាក្រាទៅសព្វស្រុក តតអំពល់អំពីភ័យ ។ សម័យ មួយនាងនាដ ទូលព្រះបាទព្រះបងថ្លៃ រំលឹកព្រះហ្ឫទ័យ សូមព្រះអង្គ

ទ្រង់គិតគន់ ។ ដ្បិតយើងបានដាក់ត្រែ សោយសម្បត្តិសម្បូណ៌ បុណ្យ អន់គ្នាអនេកលន់ បានគ្រងពស្ត្រគ្រងវង្ស ។ ពុំគាប់ពុំគួរស្មើ គួរព្រះរៀមព្រះរាជា ស្តេចមាំខ្ញុំលីលា ទៅសូរព្រះបិតាក្សត្រ ។ ខ្ញុំវព្រះវរមាតា ស្តេចស្នេហាស្ងួនប្រតិព័ទ្ធ សមស្តេចទន្ទឹងក្តាត់ ដ្បិតពុំជាបសារសេចក្តី ។ ព្រះពោធិវង្សស្តាប់ទំនូលដំណើរពី សម្តេចព្រះមហោស័ ទូលលើកព្រះទ័យស្រួល ។ ព្រះទុស្សព្រះអង្គថា ប្អូនពំផ្ទាគិតតាមគួរ សមតែយើងទៅសូរ ទៅក្រាបថ្វាយបង្គំគាល់ ។ ដ្បិតស្តេចទ្រង់ព្រះគុណ វិសេសឆ្ងន់ស្ងំតដោយធម៌ កុំឲ្យស្តេចពីតាល់ អាក់អៀនព្រះហឫទ័យ ។ ទ្រង់ព្រះចិន្តាស្រេច ទើបសម្តេចព្រះជេស្ឋ ដ័យ ចរចេញរោងរត្នវិថី អស់អាមាត្យគាល់រៀងរាយ ។ បែរបើកបន្ទូលថា ហៃសេនាសេនីយនាយ អង្គអញចង់ទៅថ្វាយ បង្គំគាល់ព្រះជនន៏ ។ ខ្ញុំវព្រះបិតា យើងយាត្រាដោយដំរី លំបាកឆ្ងង់ជលធី សមុទ្រមានទំហំធ្ងាយ ។ អញគន់អញគិតទៅ ខ្ទឹងសំពៅទើបសប្បាយ ដើរដោយតែពតាយ ប្រពៃពន់ពេកគួរគាប់ ។ ចូរឯងចូរសើរក ជាងចេះតេះតែងធាប់ ដឹងប្រឹងដឹងប្រជាប់ តាក់តែងតកុំឲ្យឆ្ងល់ ។ សេនាសេនីយស្តាប់ ស្តេចបង្គាប់បង្គំទូល បពិត្រក្សត្រតសូរ ម្ចាស់កុំព្រួយកុំបារម្ភ ។ ខ្ញុំតខ្ញុំតាក់តែង ឲ្យចិញ្ចាចចិញ្ចែងរំ ឲ្យសំក្តីឲ្យស្ងួនសម ជាត្រៃទ្វីនាំងថ្លើងថ្លាន ។ យើងខ្ញុំសោតសឹងចង់ ហៃព្រះអង្គដោយ

ជលសាន សប្បាយពន់ប្រមាណ លើសលែងដើរដោយមាគ៌ា ។ ទើប
អស់មុខមន្ត្រី នូវសេនីយសេនាណា ចរចុះទៅគ្រីហា ហៅអស់ជាង
មួលមកចូរាត់ ។ ជាងចិនជាងចូរាវិង្ស ស្រាលស្រិតស្រាំងសឹងចេះក្តោត
ប្រសាក់ប្រសប់ស្អាត់ ជាអាច់ដឹងៗកលការ ។ កុងខ្លឹមាត់មានស្រាប់
គ្រប់ប្រដាប់ដងក្តោងក្តារ គាក់តែងឆ្លើដោយងារ ដោយកំណាន់
កំណត់នាយ ។

បទកាកគតិ

មន្ត្រីសេនា សេនីយអស់អាថ៌ - ដឹងគិតខ្វល់ខ្វាយ តការកេត្រា
ចេនាចូរាត់ចូរាយ ក្បត្រៃថ្លៃពណ្ណរាយ ឥស្សរសិរសា ។ ចាត់ចែងដោយងារ
ចាំងពត់លើកតារ ចោះកុងម៉ូម៉ា ឡើងសៀវសិតទ្រែង ឆ្លងឆ្លងរចនា
ក្បាលឆ្លាក់មុខរាហ៌ នាគនៃបសងខាង ។ អាណាបក្រៃបក្រៃ បំពេមាស
សន្ធៅ សន្ធោស្អិតស្អាង ក្តារពាសសន្ធប់ គ្រប់ៗរាងង ក្តារខ្លប់សងខាង
ឆ្លាក់ជារាជាន់យើង ។ កន្ទៃកេត្រា ខែនទីក្រឡា – បន្ទំស្តេចស្តែង
ឆ្លើជាប្រាសាទ ស្អាងស្អាតខ្លាត់ខ្លែង មុខជាច់ត្រែឡែង – តែងគួរសំក្តី-
សម ។ មណ្ឌបក្តោងក្តារ មុខនាគដងក្តារ ជហ្វាមេលឹម ត្រីសូល៍រចនា
ឆ្លាក់ជាមុខព្រហ្ម ដាក់ដាំបន្ទំ រាគវត្ថុសូរ្យកាន ។ ហៅជាងដាំពេជ
និលនៃបដោយក្បាច់ ក៏ញ៉ាំប្រតិយាន តញ្ចក់វត្ថុរាយ ខែនទយកូតាន
តែមតែវប្រពាន ប្រពៃពណ្ណរាយ ។ រហូតក្បាច់ពេជ ដាក់ដាំរំលេច

មរកជតៃតាយ តៃខ្សែមុក្តា ដោយផ្កាមាលា ម្ទិះលីសាកយ រស្មីតាយ
ឆើត ។ ក្រឡាបខ្ញុំ ត្រែគ្រែបដោយមុំ រូបគ្រុឌសួយស្ទើត ស្លាញ
សួបកាងកវ ឈានឈរដំឆើត ដំតាញចំអើត ដំអែខ្ទែខ្ទ ។ ឆ្នុក
ឆ្នាក់កុម្ភ័ណ្ឌ ឈានឈរកវកាន់ ផ្ទប់ផ្ទុលខោមក៍ ប្រមុះសឹងសម បន្ទុំ
ជាជវ ត្រួបកឈូកឈ្ម ក្បែបក្បាយជាក្តី ។ ឃ្លាតសំពៅពាស ផែ
ខន់ផែងជាស សព្វត្រួបអស់ក្តី ខើបអស់សេនា យោធាមន្ត្រី រក
ឫក្សនាទី ឧត្តមពេលា ។ ឃ្លានបើកទំនប់ ទំលាយទឹកទប់ ចេញ
តាមជលសា ជំនោរជោរធំ នានាកេត្រា ឃ្លានឃុះយុថ្កា ប្រយ័ត្ន
ជោរនាច ។ លើកជង់ក្តោងក្បាល ជង់ក្តោងកណ្តាល ជាំកញ្ចក់ស្ងាច
បិទមាសឆ្នំនឆ្នើ សន្ធោចិញ្ចាច ចិញ្ចែងត្រជាច ត្រដួចយល់យង់ ។
អាមាត្យខ្លើងជាក់ ខ្សែហូតខ្សែឆ្នាក់ មានមេលឹមចុង ខ្សែឃាត់ខ្សែខារ
កង្ហារប្រៀបប្រុង បង្គាប់តែកុង ថែទាំចង្កូត ។ យុថ្កាស្រោបស្រាក់
ចង្កឹងែកជាក់ មិនឲ្យរបូត ប្រជាប់ស្ងាបក្តោង ខ្សែយោងបង្កូត បង្វែ
ខ្សែលូត ខ្សែលៀរវៀងកល់ ។ ខើបស្រាលស្រិតស្រាំង រើសរេក
ចាំកាំង ប្រសប់ដឹងស្គាល់ មើលត្រីវិស័យ រំពៃគិតការ ដឹងជាន
ពានពារ គោកគ្រឹងកេត្រា ។ ស្រែចខើបសេនិយ សេនាមន្ត្រី
ប្រជាប់ប្រជា សំពៅអង្គឯង តាក់តែងម្ចីមា ប្រុងប្រៀបបានហា - រយ
រៀបស្រាប់ស្រែច ។ នាំគ្នាចរចូល បង្កឹក្រាបទូល ខ្ញែងសព្វ

សេចក្តែច អញ្ជើញព្រះអង្គ ព័រពង្សស្តែងស្តេច យាងយាត្រាត្រែច
ចរចុះកែត្រា ។ គាលណោះព្រះពង្ស ពូជពោធិវង្ស នៅនាងសុខុមា-
លន្ទាស្តែងស្តាប់ សារសព្ទអមច្ចា ត្រែកសោមន័ស្សសោ ទរើបប
ង្គាប់ ។ ទៅលើគ្នាកងារ រៀបរកព័ស្តុភារ អាហារប្រជាប់ អង្គរ
ស្បៀងទឹក ដោយមុខងារស្រាប់ ហើយឲ្យយកទ្រព្យ តែវកងមណី ។
មាសប្រាក់ពស្ត្រា ព្រៃព្រំកាសា គោសេយ្យត្រួតី - កងឃ្លាំងផ្ទុកទៅ
សំពៅបានបី ទឹងថ្ងាយជនន័ ដនកងនាយ ។ ទើបអស់មន្ត្រី សេនា
រសេនីយ ធំតូចគាំងឡាយ តែងតាមបង្គាប់ ប្រជាប់ខ្លួលខ្លាយ រួសរៀប
ប្រញាយ ប្រញាប់ម្ន័ម្ន ។ ស្រាប់ស្រេចបរិបូណ៌ ហៅហោរគន់គូរ
ឆ្នំមផ្ទៀងពេលា រកឫក្សដំយះជាគ យាមរយោគយាត្រា នាទំនាយ
ខត្តមបើកបាន ។ ក្សត្រាក្សត្រែងរែគ្រឹង ល្អុះល្អុងរឿង ចេញចាក
ពិមាន ទាំងពីរព្រះអង្គ ឡើងគន់ព្រះយាន សេមាវាហាន ហែ ។
ត្រែបត្តា ។ បើកចាំងកូសកុំ សែងសូរ្យគតិម្យ រៀបរៀងភយគ្គា
តូរ្យតន្ត្រីត្រែ ធំហែកដា ចរចុះកែត្រា មាសមានរស្មី ។ ទាំងពីរ
ព្រះអង្គ លីលាឡើងគន់ លើខែនទិព្វទី ស្មុះស្មិទ្ធស្រីង្ការ បរិពារនារី
នៅដោយចាល័ សងខាងស្រេចស្រាប់ ។ មន្ត្រីយោធា ចរចុះកែត្រា
អង្គឯងប្រជាប់ លុះបានពេលា ធាយាគួរគាប់ ស្រេចស្រែកច្រាម
ច្រាប់ ឲ្យស្រាវយុច្ចា ។ ទើបខ្ញុងស្ករធំ គោះគងប្រគំ លាន់ឆ្អមហ៊ឹមា

ពលធង់ភ្លាវខ្យៃ ចុះចរនាវ យោនយកកេត្រា ចេញដល់មាត់
ច្រាំង ។ ហើយហូតក្តាំងគ្រប់ កេត្រាសាយសព្វ ច្រើនច្រុះច្រួង
ច្រាំង បើកកាត់សំឆោ ដម្រៅរះពាំង អស់គោះជ្រោយខាង ប្រយ័ត្ន
ក្រែងពក់ ។ គម្ពីរឈរឆោរ ដួបជួនដំនោរ ឡូលជួនតតក់ រំភាយ
រំភើយ រហើយត្រដាក់ ត្រសាយត្រសាក់ ត្រសៀកពត ។ សំពៅ
ល្បឿនលាន ក្បូត្រៃថ្មានបុណ្យ ស្តេចឆោយជលសា បើកកាត់រំលង
គោះធង់ត្រៃបត្រា ទើបដល់ទគរ សត្តកូដបុរី ។ ចូលបត់កេត្រា
ចាមចុះយេុថ្លា ទើបព្រឹមខ្ញី ឡើងគួលព្រះមហា - ក្បូត្រាធិបតី
ជាព្រៃរមនី ជនកពាសា ។ ឲ្យជ្រាបពត៌មាន ក្រោយនោះក្បូត្រកប្បន្ត
ម្លូវនាដាយោ ស្តេចទ្រង់គ្រប់គ្រឿង រុងរឿងរចនា ចុះចាកកេត្រា មើង
លើកឆយោន ។ មន្ត្រីសេនា សេនិយយោធា ហែៗក្បូត្រកប្បន្ត បើក
ប៉ាំងកូសុំ អភិរម្យច្នៃដ៏ថ្លាន ទៅទៀបតំមាន ពជរាំងក្បូត្រា ។ ស្តេច
ចុះចាកយោន យាងព្រះបាទបាន ឡើងលើប្រាង្គប្រា - សាទសុខគ្ឫ
គង់ តុមរង្គអគិរាវ៌ បង្កើបិតា មាតាក្បូត្រី ។ ពីរព្រះមហាក្បូត្រ
យល់រាជបុត្រភ័ក្ត្រ ពីរពង្សពិសី ពិសេសមកដល់ មណ្ឌលទិព្វទី
សោមនល្យបេតី អរតតុបមា ។ មានព្រះបន្ទូល សំណោះមធ្យ
សាកសួរថៃថា ហៃបុត្រសំឡាញ់ កាលចេញយាត្រា ទៅនគរ
ពាពណសី ។ ហេតុម្តេចបាបាន ជាមហាក្បូត្រកប្បន្ត គ្រប់គ្រងបុរី

ព្រហ្មទត្តពាលា មោហាទិដ្ឋិ វាក្យំយជីវ ឬវត់ទៅណា ។ ព្រះពោធិ-
សត្វ ក្រួញក្រាបប្រណិប័តន៍ ទូលព្រះបិតា ពីព្រះព្រហ្មទត្ត ជាក្សត្រ
ពាលា នឹងមេស្រុកវ មកចោមព្រះអង្គ ។ ពុំបានដូចចិត្ត ក្សត្រិណ
ក្សំយជីវិត វិនាសជាក់ជង់ ទូលកាលស្តេចបាន ពិមានពិម - ង្គ្លល
គាប់គួរគង់ សេពសោយរាជា ។ ទូលស្រែចព្រះអង្គ ច្រាប់ច្រៃ
ចតុរង្គ ពលពាលអាសា ជញ្ជូនតែវគង ទ្រព្យធនានា ពីការតេត្រា
ឡើងទៅថ្វាត់ថ្វាយ ។ ព្រះវរបិតា មាតាថ្លៃថ្លា ពីរពង្សព្រណ្ណាយ
ទ្រង់អំណរណាស់ សោមនស្សាសាយ ព្រួចត្រីព្រះកាយ សូបស្រែង
ចេស្តា ។ ទើបពោធិសត្វ នូវនារីវត្ថុ បង្កើលុតលា មកនៅពិមាន ខាង
ហានក្សត្រា ដែលព្រះរាជា ស្តេចគង់ពីមុន ។ អស់មុខមន្ត្រី ព្រាហ្មណ៍
ព្រឹទ្ធសេដ្ឋី ពស្តេប្រជាជន មូលមកបង្គំ ដូចដុំច្រើនលន់ ស្តេចឲ្យទ្រព្យ
ធន ប្រទានគ្រប់គ្នា ។ ហើយស្តេចតែងទៅ បង្គំគាល់ហ្អើ ព្រះវរបិតា
នូវវរជនន៍ ចាន់ចីមាសា ទៀនទើចទូលថា បពិត្រអម្ចាស់ ។ ទាំងព័រ
ព្រះអង្គ វរិសេសទ្រង់ ព្រះគុណកៃក្រាស់ សូមស្តេចសន្តោស អត់
ទោសឲ្យណាស់ ហាក់ខ្ញុំវហ័ស រហួនដោះដៃ ។ ដ្បិតស្រុកពារ-
ណសីមិនមាន អ្នកណាគ្រងផ្ទៃ ក្រៅមក្រែងកង្វល់ អំពល់ការតំយ
ពុំចេះក្សត្រិយ៍ ទ្រង់ព្រះមេត្តា ។ ខ្ញុំទូលព្រះអង្គ គន់គិតចិត្តចង់ អង្វរ
ក្រាបលា នាំនាងនារី បុត្រីក្សត្រា ទៅគ្រងសិមា ពារាណសី ។

(មានត)

ការច្រូតស្រូវ

របស់

ស្មៀន សោម សុខ ហៅ ពាន់-សុខ

ស្មៀនឃុំកំពង់ត្រាច ស្រុកតាមាសហោក ខេត្តស្វាយរៀង

(រឿងខ្លីលេខ ៣)

នៅខែមិគ្គសិរនឹងខែបុស្ស ចូលមកកន្លងហេមន្តដូរស្រែចុំស្រុះពេញ
ទាំងស្រែ ម្ចាស់ស្រែត្រមានកណ្តៀវ - សង្កែក - ដងវែក នឹងរនេះ
នោ - គ្រប់សំរាប់ដឹកនាំយកធញ្ញាណលមកផ្ទះរៀងខ្លួន ។

ឯការច្រូតស្រែមិនតែបុរសជាតិទេ ស្ត្រីក៏ច្រូតជួចគ្នាដែរ, ដៃស្តាំអ្នក
ច្រូតកាន់កណ្តៀវត្រែកឆ្វេងយកដើមស្រែ ដៃឆ្វេងខ្ចប់ចាប់កាន់យកដើម
ស្រែ ហើយដកកណ្តៀវចេញ ត្រឡប់ឆ្លែកណ្តៀវមកកាត់ដើមស្រែរលើ
ថ្នាំងកន្ត្រាំង ដាក់ជាកណ្តាប់ៗ ។ លុះដល់សាយណ្ហសម័យ អ្នកក
រែកជញ្ជានដោយកំឡាំងអត្តភាពនាំយកទៅទុកឯផ្ទះ, ឯអ្នកមានគេមានគូលី
ឈ្លួលច្រូតច្រើន គេដឹកកណ្តាប់នឹងរនេះទឹមដោយគោ ឬក្របី ។ ដល់
ច្រូតហើយ អ្នកស្រែបោកឬបែបនឹងមនុស្សប្តូបញ្ជាន់ដោយក្របីឬគោ
ដើម្បីយកគ្រាប់ ។ ដល់ជ្រះបានជាគ្រាប់ហើយ ពេលឲ្យជ្រះសំដីនឹង
ធូលីដី ទើបយកទៅដាក់ទុកនៅដង្កែក ឲ្យល្មមគ្រប់គ្រាន់នឹងបរិភោគ
មួយរដូវសម្រាប់មួយគ្រួរបស់ខ្លួនអ្នកស្រែនីមួយៗ ។

រឿងព្រៃ

កាលពីព្រៃឆ្នាយ មានរឿងនិយាយថា: ធញ្ញជាតិដុះឯង។ ដល់ពុំវេលាណាក៏ធញ្ញផលហើរមកចូលជង្រែក មិនមែនលំបាកដឹកនាំដូចសព្វថ្ងៃនេះទេ ។ គ្រានោះ មានស្រីកាឡកណ្ណីម្នាក់មានចិត្តអាក្រក់ រមាស់ទឹងលំអងស្រូវដែលហើរចូលមកកងផ្ទះ, នាងនោះក៏ទាញបានដង្កែកវាយស្រូវ។ ក៏រត់ទៅចូលក្រហែងចង្កុំអស់ទៅ, មនុស្សគ្មានអ្វីជាស្បៀងអាហារចិញ្ចឹមជីវិតក៏នាំគ្នាយំសោកអាឡោះ ។ គ្រានោះ គ្មានមនុស្សណានឹងទៅតាមយក មានតែតិស្សាតមានចិត្តអាណិតដល់មនុស្សលោកបានទៅតាមខំឆ្ងៀតឆ្ងៀតចូលតាមក្រហែងថ្ម រកឃើញព្រះពៃស្រួលក៏នមស្សការអញ្ជើញហើយពាំនាំយកមកឲ្យនៅចិញ្ចឹមមនុស្សលោកវិញ ។ ព្រះពៃស្រួលមានវាចាថា: លែងហើរមកចូលផ្ទះមនុស្សទៀតហើយ បើឃ្លានចង់រស់នៅដោយជាតិព្រៃមែ ត្រូវយកគ្រាប់ទៅដាំសាបព្រោះទើបដុះ ហើយដុះតែនៅវស្សន្តរដូវទៀតផង ។ សព្វថ្ងៃនេះមនុស្សទុប្បញ្ញា (ស្រុកខ្វះ) ធ្វើបូជាសែនព្រៃនជញ្ជាត់ព្រលឹងស្រូវ មានទាំងអាំងត្រីស្វាតមួយតំបុតផង នៅពេលដែលធ្វើពលីនោះ ។

សោម - សុខ ហៅ ចាន់ - សុខ

ការនេសាទត្រី(១)

ការនេសាទត្រីដោយឆ្នោះ នៅខែត្រកំពត

ស្រុកកំពត ឃុំកំពង់នឹង ក្នុងឈ្មួងសម្ដែងសៀម

របស់

លោកជាប់-សាក់

នៅសាលាតេភាតន្ទ្រី ភ្នំពេញ

(រង្វាន់លេខ ៣)

រឿងនេះខ្ញុំបានដឹងពីឈ្មោះសុខ-ហ៊ីន អាយុ ១៩ ឆ្នាំ ស្រុកកំណើតនៅស្រុកកំពត ខែត្រកំពត ឃុំកំពង់នឹង ទីលំនៅសព្វថ្ងៃផ្ទះលេខ ៩២ ផ្លូវប៉ូលបែកភ្នំពេញ ហានិយាយប្រាប់នៅថ្ងៃ ១០-៩-៤៨ ។

តាមរបៀបដែលគេកាបឆ្នោះនោះ, ជនប្រុសៗតែងចូលបង់ប្លន់ប្លុកឈ្មួល នៅរកកាប់ដើមអន្សង ដូចប្រុស្សី ប៉ុន្តែមាំជាងដើមប្រុស្សី, ដើមនោះមានដុះនៅជើងភ្នំវល្លិ ឬជើងភ្នំកូនសត្វនៅឃុំខែត្រនោះ ដើម្បីយកមកធ្វើជាបង្គោលនឹងព្រួលឆ្នោះ ។

លុះកាប់បានស្រេចហើយ គេរើសទុកធ្វើបង្គោលប្រហែលជា ៣០០ ឬ ៤០០ ដើម ប្រវែង ៤ ឬ ៥ ម៉ែត្រ, រួចគេពុះប្រុស្សី ធ្វើជានាមបតូចៗ សំរាប់វែងព្រួល ។ ព្រួលនេះមាន ៣ ផ្ទុន គឺផ្ទុនធំបន្ទោះប៉ុន ៤ ផ្ទាប់, ផ្ទុន

---

(១) ប្លាប់ដើមមានគួរប្លុងឆ្នោះ, ខ្ញុំអ្នកនិពន្ធសូមប្លាប់នេះហាត់ត្រឹមផ្សេងៗជាង ។

កណ្ដាលប៉ុនពីរធ្នាប់, ធុនតូចមួយធ្នាប់ ។ ព្រលង់អស់ប្រវែងប្រហែលជា ៣០០ ម៉ែត្រ, លុះក្រងរួចគ្រប់ចំនួនហើយ គេរៀបចុះទូក, ពេលដែលយកប្រជាប់ប្រជាជាក់ក្នុងទូកអស់ហើយ គេតមមិនឲ្យទុសមាត់ហើយហាមផ្ដាច់មិនឲ្យស្រិចូលទៅដិត ឬដើរកន្ទុងលើព្រលឬបង្គោលឡើយ ។

លុះរៀបចំហើយ, គេចេញទូកទៅរកកន្ទែងដែលមានទឹកជម្រៅ ៣ ម. ៥០ ឬ ៤ ម. ដើម្បីចោះបង្គោលទៅឲ្យលិចធុតពីទឹកកន្ទុងម៉ែត្រ ហើយគេធ្វើដៃពីរ: ស្ពាំមួយធ្នេងមួយ. ដៃស្ពាំមានប្រវែង ១០០ ម៉ែត្រ ដៃធ្នេងប្រវែង ៥០ ម៉ែត្រ ទើបគេចោះបង្គោលធ្វើផ្ទះលែង, លុះធ្វើផ្ទះលែងនោះរួចហើយ ទើបធ្វើផ្ទះមួយទៀតហៅថា ផ្ទះកៀរ នឹងផ្ទះកៀរព្រល, រួចធ្វើផ្ទះមួយទៀត ហៅថាផ្ទះចាប់ ។

លុះចោះបង្គោលរួចហើយ គេយកព្រលទៅភាយតាមចន្លោះបង្គោលព្រលដែលធ្វើដៃទាំងពីរ គឺព្រលធំបំផុត, ត្រង់ផ្ទះលែងគេយកព្រលធុនកណ្ដាល, ឯផ្ទះចាប់នឹងផ្ទះកៀរគេយកព្រលធុនតូចបង្អស់ ។ ឯបង្គោលនោះ មានចន្លោះពីមួយទៅមួយ ៥ ឬ ៦ ម៉ែត្រ ។

លុះធ្វើរួចស្រេចហើយ គេនាំគ្នាត្រឡប់មកផ្ទះវិញទាំងអស់ ។ ដល់ពេលអធ្រាត្រ គេទៅឃ្លាំមើលឆ្នោះនោះពីរបីថ្ងៃតមក លុះឃើញមានត្រីធំៗ ចូលច្រើនហើយ ទើបនាំគ្នាទៅចាប់ត្រី ។ មុននឹងចូលទៅ

ចាប់ត្រី គេសង់ទូមអ្នកតាមួយ ហៅថា អ្នកតាអន្ទាប, លុះសង់រួច ហើយគេនាំគ្នាទៅចាប់ត្រី ។ ដើម្បីចាប់ត្រី គេច្រើទូកក្តោងតូចល្មម, គេយកព្រួល ១ បន្ទះទៀត ទៅរាំងត្រង់ទ្វារផ្ទះលែងនឹងផ្ទះកៀរ ទើបគេកៀរម្ខាងបន្តិចៗ លុះត្រាតែត្រីចូលអស់ទៅក្នុងផ្ទះចាប់ រួចគេរាំងទ្វារត្រង់ទ្វារផ្ទះចាប់នឹងផ្ទះកៀរព្រួល ទើបគេយកកន្ត្រងមកជងត្រី ។ ឯកន្ត្រងនេះគេយកអង្រឹតមកស្រោកស្បាលឲ្យជិត ដាក់ជងមួយវែង ។ ដើម្បីនឹងជងយកត្រីក្នុងផ្ទោះ គេមានស្នូសម្រាប់សចាក់ត្រីបែល ។

កាលណាចាប់ត្រីរួចហើយ គេបបួលគ្នាអ្នកជិតខាងនឹងអ្នកធ្វើផ្ទោះ ចាំងប៉ុន្មានមកសែនអ្នកតា មានរណ្តាប់មាន់ស្ងោរមួយ ស្វាធម៌មួយគូ ម្ទូ ៥ ស្លា ៥ ចាវីរ ចាយធម្មតា ស្រាស ទំពិន ទៀន ធូប សម្រាប់អុជទៅតាមសែលសែនព្រៃន, លុះរៀបគ្រប់រណ្តាប់អស់ហើយ គេស្រែកបន្តគ្នាថា "តាលោកអ្នកតាអន្ទាប លោកជាអ្នករក្សាទូវទឹកដីសមុទ្រនេះ សូមឲ្យលោកជួយរក្សាយើងខ្ញុំទាំងឡាយ ឲ្យបានសេចក្តីសុខសប្បាយ សូមឲ្យមានត្រីធំៗ ចូលឲ្យច្រើន យើងខ្ញុំនឹងរៀបសែនព្រៃនឲ្យទៀត," គេនិយាយយ៉ាងនេះ ជាគំរប់បីដង ទើបគេចាប់យកមួយមុខបន្តិចៗ ដាក់ក្នុងទូមអ្នកតាអន្ទាបនោះ រួចបបួលគ្នាត្រឡប់មកផ្ទះវិញ ដប់លៀងគ្នា, គេសែនតែម្តងទេ, លុះដល់កាលណាមានត្រីធំ មានទម្ងន់ ២ ឬ ៣ ហាបចូលផ្ទោះ ទើបគេរៀបសែនម្តងទៀតដូចមុន ។

គេប្រយ័ត្នមាត់ណាស់ មិនហ៊ាននិយាយការអ្វីដែលមិនគួរគប្បីទេ បើមិនដូច្នោះទេ ទឹងមានអន្តរាយដល់ជីវិតមនុស្ស ឬបណ្តាលឲ្យលិចទូកក្តារស្លាប់មនុស្ស ឬមួយត្រីលែងចូលឆ្នោះនោះសោះតែម្តង ។

ឆ្នោះមួយៗប្រើការបានរាងៗ ៣ ខែ ។

គេធ្វើឆ្នោះនៅរដូវណាក៏បាន ប៉ុន្តែគេចៀនធ្វើនៅរដូវរសា ។

ឯត្រីដែលចូលឆ្នោះ មានត្រីសមុទ្រគ្រប់មុខ ។ ត្រីដែលស្គាល់ឈ្មោះខ្លះដូចតទៅនេះ :

ត្រីដែលលក់បានថ្លៃជាងគេពួកត្រីឯទៀត គឺ ត្រីស្នែង, ត្រីការ៉ា, ត្រីស្តង, ត្រីត្រយង់ ។ ត្រីដែលមានថ្លៃធម្មតា គឺ ត្រីកម្តង (សៀមហៅថា ត្រីឫាធូ), ត្រីប្រមា, ត្រីឆ្លាម, បបែល, ម៉ឹក (ចិនហៅត្រីយ៉ាហឺ), ត្រីកន្ទុយរាង, ត្រីខ្ញង, ត្រីម៉ុតថៃ, ត្រីចង្កឹមបី ។ ត្រីធម្មតានេះ ច្រើនតែចូលឆ្នោះគាំងហូងៗក្នុងមួយលើកៗ ។

គេទៅចាប់ត្រីម្តងៗ បានចំនួនត្រី ២០ ឬ ៣០ ហាប (១២០០ គ. ក. ឬ ១៨០០ គ. ក.) ។

ចប់របៀបខេសាទត្រីដោយឆ្នោះតែប៉ុណ្ណេះ ។

ថាច់ · សាក

លោក ប៉ាយ - ប៊ុក ក្រមការ ប្រែរៀបរៀង

(ភាគ)

វគ្គទី ៩

នៅជុំវិញក្រឡាចត្រង្គនេះ មានកុំប៉ាំងារម្មទីយដ្ឋាន ដែលធាតុតែង សម្រាប់ការពារព្រះរាជធានីនៃស្តេចពាំម្ពីសារ, ព្រះរាជធានីនេះមានព្រៃ ព្រឹក្សាជុះព័ទ្ធជុំវិញ ។ កុំទាំង ៥ នោះគឺ ១ – កុំវេភារៈ មានពណ៌ខៀវ ស្រងាត់មានដើមកក់ខ្ពស់ដើមត្នោតជុះនៅលើនោះ, ២ – កុំវិបុល ជាដើម ចម្ការទឹកស្ងួនសស្ពុតិ, ៣ – កុំតប្បោវន មានបឹង មានអាកាសចុះរំពួងឆ្ងីត ហើយមានទឹកហូរចេញពីកំពូល មានឫស្សាខ្មៅ, ៤ – ទាងទិសនរគ្គេយ្យ មានសិលាគីរី ដែលមានពួកបក្សាត្នាតធ្វើសំបុកនៅ, ៥ – ទាងទិស បូព៌ាមានកុំមួយទៀតហៅថា រតនគីរី ជាកុំមានត្បូង ។ មានផ្លូវដើងមួយ ក្រឡឹកក្រឡាត់មានឫស្សីកដាច់ដាយស្មាមជានដើងមនុស្សដើរជាច្រើន, ផ្លូវ ដើងនោះគាត់ឋម្ភារជាច្រើនមកខ្ទែងដែលមានដាំដើមរមៀត ដើមបុស្ស ដើម ស្វាយមានស្ទឹកស្រគាំនឹងដើមតុគ្គា, ផ្លូវនោះចេញទៅកាន់ទីជិតឋ្ងាមាន ថ្នើមថ្ម ថ្មកែវមានពណ៌ស, ហើយតម្រង់ទៅត្រង់ដើងកុំដែលមានចង្កើះ ខោតសន្ធឹមលំប៉ាកដើរពន់ពេក ទឹងស្ងួនបុប្ផាត្រប់យ៉ាង ហើយគាត់ទៅ ម្ខាងកុំ រួចដាក់ទៅទាងទិសឋស្ថិមដែលមានគុហាមួយធំ មានដើមដែជុះ។

ចូរអ្នកអញ្ជើញមើលចុះ បើអ្នកបានអញ្ជើញមកដល់ទីនេះ, ប៉ុន្តែគួរអ្នក
ដោះស្បែកដើងហើយធ្វើអញ្ជលីកម្មគោរព ព្រោះភូមិភាគនេះ មានកន្លែង
ឧត្តម ហើយគួរជាទីគោរព គឺនៅទីនេះហើយដែល ព្រះសម្មាសម្ពុទ្ធជាបរម
គ្រូរបស់យើងកាលដែលមិនទាន់បានត្រាស់ដឹងនៅឡើយ ព្រះអង្គបានរង
ទុក្ខលំបាកដោយកំដៅព្រះអាទិត្យ និងដោយភ្លៀងឬមេឃ អំពីបុព្វណ្ហ
សម័យ និងសាយណ្ហសម័យ ប្រកបដោយអាការត្រជាក់ ដើម្បីនឹង
ស្រោចស្រង់មនុស្សសត្វ ។ ព្រះអង្គទ្រង់តែយំបាវរពណ៌លឿង សោយ
អាហារដូចជាសម្លយាចក ជាអាហារដែល ព្រះអង្គបានមកដោយសទ្ធានៃ
ជនដទៃ, ពេលយប់ព្រះអង្គធ្លុតែឯកឯងនៅលើស្មៅគ្មានអ្វីបិទបាំង ហើយ
ឮតែសូរសំឡូសត្វចចកដែលភាំមានដេកយំជុំវិញគុហានោះ ទីងសំរែកខ្លា
ដែលកាស្រែកឃ្លានហើយស្រែកលាន់ឮរំពងពេញព្រៃ ។ នៅទីនេះគាំង
ឃប់គាំងខ្លៅ, មនុស្សក្នុងសកលលោកតែងគោរពបូជាចំពោះព្រះពុទ្ធ, ព្រះ
អង្គទ្រង់បានផ្ទេញ់ផ្ទាល់រូបកាយដែលល្អស្អាតដើម្បីជាទីសប្បាយក្នុងលោក
ដោយអត់អាហារ ដោយអត់ងងុយមិនបានផ្ទំ ហើយធ្វើសមាធិកន្លងទី
ដ៏ស្ងប់ស្ងាត់ ។ ក្នុងកាលដែលកំពុងធ្វើសមាធិ, ព្រះអង្គបានតាំង
ស្មារតីចុះកាន់អារម្មណ៍មូលនឹងថ្កល់ដូចថ្មសិលា សូម្បីតែសត្វកំប្រុក
លោតលើព្រះជានុ (ក្បាលជង្គង់) បក្សីក្រួចបានពាំយកតង់មកជាក់
ក្រោមព្រះបាទ ឬលលកមកចឹកស្រូវបរិភោគនៅទីងសុកដែលនៅជិត

ព្រះហស្ត កំព្រះអង្គមិនកំរើក ។ នៅទុកាសនោះហើយដែលព្រះអង្គ
បានពិចារណាអារម្មណ៍ របស់កម្មដ្ឋានតាំងពីថ្ងៃត្រង់ ក្នុងពេលដែលព្រះ
អាទិត្យកំពុងបញ្ចេញកំដៅយ៉ាងខ្លាំង សម្បូរតែជញ្ជាំងព្រះវិហារក៏មានកំ-
ស្បួលក្តៅ អាកាសក៏ក្តៅហុយដូចផ្សែង, ព្រះអង្គពិចារណារហូតដល់ពេល
ព្រះសុរិយាអស្តង្គត ដោយមិនបានទឹកនាដល់ព្រះអរុណដែលអណ្តែតលើ
មេឃា ទឹងព្រះសុរិយាដែលភ្លាក់មកលើផែនដីដោយធាប់រហ័សហើយធ្វើ
ឲ្យវាលស្មៅមានពណ៌ក្រហមឆ្អៅ ឬផ្កាយតាកដែលបញ្ចេញរស្មីលើ
មេឃា ឬសំពូសូរស្តេរសម្ភោដែលគេកាយរណ្តុំគ្នាក្នុងទីក្រុង ឬសំឡេងមៀម
ម៉ូមឬក៏ការសង្ក្រាមវេលាយប់ឡើយ, ពីព្រោះព្រះអង្គមានព្រះពាជកង្វល់
ចំពោះការពិចារណាសភាពរបស់ចិត្តគ្រប់យ៉ាង ព្រមទាំងពិចារណា
សង្ខារលោកដែលមិនងាយនឹងយល់បាន: ព្រះអង្គខំព្យាយាមគង់នៅ
កណ្តាលយប់អធ្រាត្រស្ងាត់ មានតែសូរសំពូសត្វលូនក្នុងទីងងឹតឬសំរែក
សត្វផ្សេងៗក្នុងព្រៃព្រឹក្សា ដូចសេចក្តីខ្លាច - ស្អប់ស្រែក ឬដូចតណ្ហា
មច្ឆរិយៈ ឬទោសៈតាំងនៅតាមព្រៃងងឹតគឺអវិជ្ជារបស់មនុស្សដូច្នោះឯង,
រួចព្រះអង្គធ្លុះនៅពេលដែលព្រះច័ន្ទជិតលិចនៅម្ខាងជើងមេឃ ហើយតើន
ឡើងមុនបច្ចូសសម័យ, ទ្រង់គង់ពិចារណាស្ងប់ស្ងៀមនៅលើថ្កល់ គិតដល់
ប្រថពីដែលមានសត្វកំពុងដេកលក់ ដោយព្រះចក្ខុញាណ ហើយតាំង
ព្រះហឫទ័យករុណាគ្រាលសព្វសត្វក្នុងលោកសន្ធិវាស; តែក្នុងពេលនោះតាម

ទ័ក់លគេតុស័ក្តសូរមនុស្សសត្តក្បាក់ព្រឹក ហើយខាងកើតគេបានឃើញ
ព្រះអាទិត្យបញ្ចេញរស្មី, តំបូងឡើយព្រលឹមងងឹតដូចជាយប់នោះ មិនខាន
បានឮសំឡេងនៃសត្តក្បាក់នោះឡើយ ប៉ុន្តែបន្តិចទៀត មុនមានព្រៃ
រងាវពីរដង គេបានឃើញដើមមេឃមានរស្មីភ្លឺស រស្មីនោះកាន់តែធំ ភ្លឺ
ខ្លាំងជាលំដាប់ដំណាយព្រឹកដែលរៀបនឹងលិច ហើយរស្មីនោះក៏ពាល
ដាលពាសពេញមានពណ៌សដូចប្រាក់ មានពណ៌ក្រហមដូចមាសហើយ
មានពណ៌ពុំដុំវិញ មានពន្លឺរស្មីភ្លឺដូចមាសកំពុងដុត ហើយចាំងទៅដើង
មេឃធ្វើឲ្យមានពណ៌លឿងដូចមេត, ក្រហម, ពណ៌ស, ពណ៌ផ្សេងៗ
ហើយមេឃទៅជាមានពណ៌ខៀវស្រស់អស្ចារ្យ ក្នុងពេលនោះព្រះអាទិត្យ
ក៏បញ្ចេញអានុភាពឡើង ។

ក្នុងពេលនោះ ព្រះសម្មាសម្ពុទ្ធយើងទ្រង់បានលើកព្រះហស្តគោរព
ដល់ព្រះអាទិត្យតាមទំនៀមពួកឥសី ហើយព្រះអង្គទ្រង់ស្រប់ព្រះភ័ក្ត្រចេ
ស្តេចយាងទៅតាមផ្លូវដែលក្រឹចក្រៀនក្នុងច្រកក្រុង ហើយព្រះអង្គ
ស្តេចយាងពីវិថីមួយទៅវិថីមួយតាមទំនៀមឥសី, កាន់ចាត្រហើយទទួល
ចង្ហាន់ដែលល្មមចិញ្ចឹមជីវិតបាន, បន្តិចចុះត្រនោះតេញដោយអាហារ
ពីព្រោះប្រជារាស្ត្រតាំងអស់ប្រកាសថា : " សូមព្រះអង្គស្តេចយាងមក
យកចង្ហាន់បិណ្ឌបាតឯនេះ " ដោយបានពិនិត្យនូវព្រះភ័ក្ត្រដែលប្រកប
ដោយរស្មីអស្ចារ្យនឹងព្រះចក្ខុផ្ទាល់ ក្នុងវេលាដែលបានឃើញព្រះអង្គ

យាងតាមផ្លូវ, ពួកស្ត្រីដែលជាមាតាប្រាប់ពួកកូនឲ្យមកថើបព្រះបាទ ហើយនឹងយកថ្វាសទៅប្រាថ្នាឲ្យប៉ះស្បង់ ឬក៏រត់ទៅយកទឹកដោះគោនឹងនំមកជាក់ជូនព្រះអង្គ, ក្នុងពេលដែលព្រះអង្គត្រៃចតាមផ្លូវ មានព្រះទ័យមេត្តាស្ងប់ស្ងាត់មានព្រះរូបឆោមលោមពណ៌ ផ្សាយឆព្វណ្ណរង្សីភ្លឺថ្លៃឆ្អែតចាំងមានព្រះពជវិតក្ខៈចំពោះពួកប្រជាជន ដែលព្រះអង្គទុកជាព្រះញាតិជិតខាង, ពពួកនារីជាតិតណ្ហា ដែលមានក្តែកក្តៅបានសំឡឹងព្រះអង្គដោយនឹកធ្វើនឆ្ងល់ហើយមានរាគៈធុំធុលក្នុងសន្ដានចិត្តឈ្មោះសេរីសុខ មើលទៅព្រះរូបដែលប្រកបដោយសភាពស្អាតជាអស្ចារ្យ ប្រៀបដូចជានាងឃើញនិម្មិតដែលប្លែក ហើយក៏បានបំពេញកិច្ចសមតាមបំណង ក្នុងទុកាសនោះសេចក្តីស្នេហាក៏តើតមានឡើងក្នុងហទយវត្ថុរបស់នាង, ចំណែកព្រះអង្គទ្រង់ត្រេកអរចំពោះពណ៌លឿង ស្តេចយាងកាន់ប្រាតមានព្រះទន្ទ្រារជាពាក្យទន្ទែមទៅកាន់អ្នកដែលជាក់ប្រាតហើយយាងលិតឡប់ទៅកុំវិញ ដើម្បីនឹងសន្ទនាការណ៍ជាមួយនឹងពួកភិក្ខុសង្ឃ ស្តាប់ពាក្យពោល, សាកសួរដើម្បីនឹងកវិធី ព្រមទាំងមធ្យោបាយដែលជាហេតុឲ្យដល់ស្ថានបរមសុខ គឺព្រះនិព្វាន ។

ត្រង់ពាក់កណ្តាលផ្លូវក្នុងគុម្ពោតវៃព្រៃ ឈ្មោះ "វេនតិរី" ជាទាំងលើទឹកក្នុងរាជគឹរិ តែទាំងក្រោមគុហា មានមនុស្សជាច្រើនដែលយល់ឃើញថារូបកាយជាសត្រូវនឹងចិត្តហើយសាច់ខ្លួនប្រៀបដូចជាសត្វតិរច្ឆាន

ដែលត្រូវតែជាក់ច្បាស់ ហើយត្រូវបង្ក្រាបដោយធ្វើឲ្យរង់ទុក្ខលំបាកខ្លាំង
ទាល់តែបាត់សេចក្តីឈឺចាប់, មនុស្សទាំងនោះនាំគ្នាធ្វើបាបសង្កត់សង្កិន
សរសៃរូបកាយរបស់ខ្លួនដូចជានាយពេជ្ឈឃាត គេហៅថា ពួកយោគី,
ពួកព្រហ្មចរិយៈ, ពួកភិក្ខុ[1] ដែលជាពួកមានរូបស្តម នៅទីកន្លែងមួយ
ផ្សេងឆ្ងាយពីគេ; មានមនុស្សខ្លះ ចាន់ប្រតិត្តធម៌ដោយហាត់លើកដៃ
ទាំងយប់ទាំងថ្ងៃ លុះតែតែដៃនោះស្ពឹកទៅជាឈឺ ហើយត្រង់តន្ទាក់ដៃ
ទៅជាបត់បែនមិនកើត សរសៃដៃដុះចេញពាស្មាដូចជាមែកឈើស្ងាប់នៅ
លើដើមវា, មានមនុស្សខ្លះ ខំក្តាប់ម្រាមដៃយូរទៅដោយថាមភាពដ៏ខ្លាំង
ក្លាកាចសាហ៍សន់ពេក ទាល់តែក្រចកដៃស្រួចដុះចូលទៅក្នុងសាច់ចាត
ដៃដែលតំហៀ, មានមនុស្សខ្លះទៀតពាក់ស្បែកដើងផ្ទាត់ដែលចោះដែក
គោលពីលើដើរចុះទៅរ៉ែង, មានខ្លះយកក្រួសស្រួចមកចាក់ចុចត្រង់ក្បូន
ត្រង់ចង្កាសឬត្រង់ភ្លៅ, ខ្លះយកកន្ទេះដែកភ្លើងទៅអុជលើខ្លួន, ខ្លះទៀតយកម្ជុល
ឬដែកស្រួចចាក់សាច់, ខ្លះទៀតយកកាន់ទឹងដែរលាចសត្វសាឆ្កែកាយ,
ខ្លះដេកលើគំនរសែមាម, ខ្លះយកសំពត់ដែលគេរុំសាកសពមកស្ទៀក

---

១ ពួកយោធ ជាអ្នកបានប្រតិត្តធម៌ ១ ចែប ដែលហៅថាយោគៈ គឺជាវិធានការនឹងការ
តម្រង់ខ្លួន ដើម្បីនឹងទៅកាន់សេចក្តីសុខដោយធ្វើឲ្យរួចទៅក្រៃមអំណាចនៃចិត្តហើយបំបាត់នូវ
បុគ្គលិកលក្ខណៈ គឺយល់ថាមានខ្លួនខ្លោងខ្លួន, ពួកព្រហ្មចារី គឺជាពួកតាំងមានវណ្ណៈ ៣
ព្រាហ្មណ៍, ពួកភិក្ខុ គឺជាពួកដែលមានបំណងរៀ ធម៌វិប្រការ គឺ សេចក្តីសញ្ជាយក្នុងលោក ១
ទ្រព្យសម្បត្តិ ១ កាមបួន ។ ដើម្បីនឹងប្រព្រឹត្តនូវធម៌ខ្ពស់ដោយបំបាត់តណ្ហា, សេចក្តីភ្ញាក,
សភាពអួតអាង ។

ពាក់, មានខ្លះនៅអាស្រ័យត្រង់កន្ទែងស្មោកគ្រោក ជិតទីប៉ាផា, ខ្លះ
រស់នៅជិតសាកសព ដែលមានបក្សាត្មាតចោមរោមស្រែកលើគំនរខ្មោច
ទាំងនោះ, មានខ្លះស្រែកប្រាប់ជនក្នុងមួយថ្ងៃ ចំពោះព្រះនាមព្រះសិវៈ
ហើយមានឥសុរុំព័ទ្ធក មានស្បែកក្រឹនដោយកំដៅព្រះអាទិត្យ នឹងចង្កេះ
ផតត្រមាំងយកដើងកាច់ពត់ឲ្យនៅនឹងថ្ពល់ត្រង់គន្លាក់អាចម៍ នេះគឺក្រុម
ជនដែលគួរឲ្យគេគោតញាញើតពន់ពេក ដែលជាអ្នកមានរលាជ័ក្សាល
ពងជាំជាំ ដោយត្រូវកំដៅថ្ងៃ ក្អែកអៀស៊ី សរសៃធំតូចបត់បែន មុខ
ក្រហមហើយស្វាយដូចជាបុគ្គលស្រាប់ចំនួនប្រាំថ្ងៃ ។ នៅទីនេះ មាន
មនុស្សម្នាក់ដេកនៅលើឥសុធា ដ៏ស្រមកដោយធូលីពាសពេញខ្លួន ប្រាន
រកគ្រាប់ថ្លៅ ១.០០០ គ្រាប់មកទុក ដល់ពេលរសៀលក៏យកមកអកម្តង
មួយគ្រាប់ ។ លុះតែតែស្រាប់ដោយអត់អាហារ, មានមនុស្សម្នាក់ទៀត
យកសណ្តែកពងមាសមកលាយនឹងស្វឹកឈើដែលមានរស់ល្វីង ដោយ
ខ្លាចក្រែងរបស់អស់ទាំងនោះដល់ទំពាប៉ះដីក្លាប្រសាទទៅ បង្កឲ្យមាន
តម្រែក, នៅជិតទីនោះ មានសន្តិបុគ្គលម្នាក់លំបាកវេទនាជាខ្លាំង ដោយ
បានធ្វើបាបកម្មរាងកាយរបស់ខ្លួនតាល់តែគ្មានភ្នែក អណ្តាត គ្មានកេរ
ហើយខ្វិនត្រមាំងថ្ងង់ផង,

(មានត)

កុំចាចដឹងឮចំទ្រាសឲ្យល់

ឃុន បណ្ណានុរក្ស ប៊ុ - ប៉ុ ពុទ្ធសាសនបណ្ឌិត្យ

រឿងរ៉ៃ

ពាក្យនេះជាសុភាសិតបុរាណ ជាពាក្យប្រៀប លោកប្រាថ្នានឹងហាមប្រាមថា កុំឲ្យទុក្ខដល់គេ ព្រោះថាទុក្ខនោះនឹងវិលត្រឡប់មកត្រូវខ្លួនឯងវិញ ។

មនុស្សល្អនឹងមនុស្សអាក្រក់តែងតែផ្ទាញ់ផ្ទាល់គ្នាទៅវិញទៅមកជាច្រើនគ្រា ប៉ុន្តែដល់វេលាបានផលជាទីបំផុត ជំយកជំនះជាផលរបស់មនុស្សល្អ ហើយជាផលរបស់មនុស្សអាក្រក់ រឿងនេះសូមលើកនិទានព្រានឈ្មោះ តោក: កុងតម្ពីរជម្បូទមកសាងដូចតទៅនេះ ។

កាលពីព្រេងនាយ មានព្រានពៃម្នាក់ឈ្មោះតោក: ជាអ្នករកស៊ីបរបាញ់សត្វ ។ ថ្ងៃមួយ ពេលព្រឹកព្រហាម នាយព្រានកាន់ធ្នូបណ្តើរហ្វូងឆ្កែសំដៅទៅព្រៃ, កុងពេលកំពុងតែដើរទៅនោះ បានឃើញព្រះមួយអង្គកំពុងតែនិមន្តបិណ្ឌបាត ។ នាយព្រានគ្រាន់តែក្រឡេកឃើញព្រះភ្លាមក៏នឹកទាំងថា "ថ្ងៃនេះអញមកជួបប្រទះនឹងមនុស្សចង្រៃ អញទៅបរបាញ់សត្វកុងព្រៃមុខជាមិនបានសត្វអ្វីមួយទេ" ទើបយ៉ាងនេះហើយក៏គេចចេញទៅ ។ ចំណែកព្រះមានព្រះភាគនិមន្តទៅបិណ្ឌបាតបានបន្តិចបន្តួចហើយ ក៏ត្រឡប់មកវត្តវិញ ។

ឯនាយព្រានចំណើរស្ទុះស្ទើរកសត្វយ៉ាងណា ក៏មិនជួបប្រទះនឹងសត្វអ្វីមួយសោះ ថ្ងៃរះគាន់តែខ្ពស់ឡើង សេចក្តីស្រេកឃ្លានក៏តែតែកើតខ្លាំងឡើងដែរ ។ នាយព្រានទឹកចិត្តណាស់ លិតត្បាល់មកដូរវិញដៃទេ, ពេលនោះ នាយព្រានដើរមកជួបនឹងព្រះថេរៈម្តងទៀត ទទួលគាត់ចិត្តពីជាន់មុនមិនខាន់ឡាត់ ក៏តែតែចិត្តខ្លាំងលើសមុន ហាក់ដូចក្តៅឆេះសម្រាម គាត់គិតថា "ថ្ងៃនេះ ព្រោះតែអញជួបនឹងមនុស្សចម្លែកនេះហើយ ឃ្លានជាអញទោះព្រមិនបានសត្វអ្វីមួយសោះ, មនុស្សចម្លែកនេះមិនគួរស្រស់ទៅឲ្យចង្រៃត្រសកទេសទេ ឲ្យតែខាំស៊ីទៅចុះ" គិតដូច្នេះហើយក៏ពន្យុះឆ្កែឲ្យចោលទៅ ។ ព្រះថេរៈឃើញអាការដូច្នោះឆ្លាបភ្លាមចា "ភ័យអន្តរាយមុខឆាប់នឹងមានដល់អាត្មាអញមិនខាន" ទើបលោកស្រែកអង្វរនាយព្រានដោយពាក្យពិរោះផ្អែមល្ហែមថា "នែឧបាសក, អ្នកកុំធ្វើយ៉ាងនេះឡើយ" ។ នាយព្រានមិនស្តាប់សោះ ស្រែកប្រាប់ព្រះថេរៈថា "ព្រោះតែអញមកជួបនឹងអាចម៍ងងឹតនេះហើយ ឃ្លានជាថ្ងៃនេះអញមិនបានសត្វអ្វីសោះ អញវិលមកដូរវិញតែដៃទេ ឥឡូវស្រាប់តែមកជួបនឹងអាចម៍ងងឹតទៀត អញឲ្យហ្វូងឆ្កែអញខាំអាងងឹតស៊ីហើយ" ថារួចក៏ពន្យុះឆ្កែឲ្យចោលចូលទៅខាំព្រះថេរៈ ។

ព្រះថេរៈឃើញថាមានភ័យអន្តរាយដល់ខ្លួនលោកមែនពិតហើយ លោកក្រឡេកមើលទៅខាងមុខឃើញមានឈើមួយដើម ល្មមនឹងពឹងពាក់

ឲ្យផុតពីទុក្ខភ័យបាន លោកក៏និមន្តយ៉ាងលឿនទៅប្រាប់ឡើងដើមឈើ
នោះ លុះដល់ទៅប្រគាបឈើកំពស់មួយដងបុរស (តាមវិន័យ) លោក
ក៏ឈប់គង់ទៅស្ងៀម ។ ឯហ្វូងឆ្កែកាលឮម្ចាស់ពន្យុះដូច្នោះក៏ប្រាសំដៅទៅរកព្រះថេរៈមួយរំពេច សូម្បីនាយព្រានក៏រត់តាមឆ្កែទៅដែរ ដល់ហើយស្រែកគម្រាមព្រះថេរៈថា "អាចរៃឯងឡើងដើមឈើកំពស់ប៉ុណ្ណោះ ធ្វើម៉េចនឹងរួចពីកណ្តាប់ដៃអញ" ថាហើយយកចុងព្រួញចាក់ប្រាប្រាតព្រះថេរៈ។ ស្រែកអង្វរថា "នែឧបាសក, អ្នកកុំធ្វើយ៉ាងនេះឡើយ" ។ នាយព្រានមិនព្រមស្តាប់ រឹតតែប្រឹងចាក់ខ្លាំងឡើងទៀត, ព្រះថេរៈលើកព្រះបាទដែលនាយព្រានចាក់ត្រូវឡើងហើយ សំយុងព្រះបាទម្ខាងមកវិញ, នាយព្រានចាក់ត្រូវព្រះបាទនេះទៀត, ព្រះថេរៈលើកឡើងវិញ ហើយសំយុងព្រះបាទម្ខាងមកទៀត, នាយព្រានចាក់ត្រូវព្រះបាទព្រះថេរៈទាំងពីរមុតធ្លុះចេញឈាមហូរស្រក់ច្រាកៗមកដី, ព្រះថេរៈទល់ទុក្ខវេទនាឈឺចាប់ពេកជាពន្លឹកខ្លាំងតែបាត់ស្មារតី សូម្បីតែចីវរបូតពីព្រះអង្គក៏ពុំដឹង, ឯចីវរនោះ ធ្លាក់ទៅគ្របលើខ្នងនាយព្រានដែលកំពុងតែឈរចាក់នៅជីតាំងពីក្បាលរហូតដល់ចុងជើង ។ ចំណែកហ្វូងឆ្កែដែលត្រូសគោះជុំវិញគល់ឈើប្រុងតែនឹងខាំព្រះថេរៈនោះ លុះបានឃើញចីវរធ្លាក់មកគ្របនាយព្រានដូច្នោះ ក៏សំគាល់ថា "ព្រះថេរៈ

ភ្លាត់ដើងធ្លាក់ចុះមកដី ។ ទើបនាំគ្នាបោលចូលទៅក្នុងចីពរប្រដែងទាំស៊ី សាច់នាយព្រានអស់លើង ទៅសល់តែពងធ្នើង ស៊ីរួចចេញមកឈរចាំម្ចាស់ទាងគ្រែវិញ ។

ព្រះថេរៈមានស្មារតើដឹងព្រះអង្គឡើង ក៏ចាប់មែកឈើងាប់គ្រែងើងទៅគ្រែឆ្កែ។ កមើលឃើញព្រះថេរៈទៅលើប្រគាបឈើ ក៏ដឹងថា " ពួកយើងធ្វើអំពីភ្លាត់ទុសហួសទៅហើយដោយសេចក្តីក្រោធទឹងខ្ញាំងពេក មិនបានពិចារណាឲ្យសព្វគ្រប់ជាមុនសិន ឃាតជានាំគ្នាទាំប្រញីស៊ីសាច់ម្ចាស់ឯងដូច្នេះ " ហ្វូងឆ្កែដឹងកំហុសខ្លួនយ៉ាងនេះហើយក៏ចោលចូលព្រៃអស់ទៅ ។

ព្រះថេរៈចុះពីប្រគាបឈើ មកពិនិត្យមើលពងធ្នើងរបស់នាយព្រានដែលសល់ពីឆ្កែស៊ី ក៏ពិចារណាថា " ត្រូវឲ្យអាណាច់អាជ័មណាស់! នាយព្រាននេះប៉ងនឹងសម្លាប់អញដោយហេតុតែបន្តិចបន្តួចសោះ ឥឡូវត្រឡប់ជាស្លាប់ខ្លួនឯងទៅវិញព្រោះតែឆ្កែរបស់ខ្លួន បើដូច្នេះតើ សីលរបស់អាត្មាអញនឹងសៅហ្មងពាលពត្រុះដែរឬទេ ? សមណកេនរបស់អញខូចដែរឬទេ ?" គិតរួចនិមន្តចូលទៅគាល់ព្រះបរមសាស្តា ក្រាបទូលរឿងព័ះនោះឲ្យទ្រង់ជ្រាបត្រប់ប្រការ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ប្រាប់ថា " ម្នាលភិក្ខុ, មិនអីទេ សីលនឹងសមណកេនរបស់អ្នក មិនសៅហ្មងមិនខូចខាតទេ " ។

គតិរបស់រឿង

១ – សញ្ញាតិពាល បើទុកជាមានគេប្រលោមលួងលោមអង្វរ
ករដូចម្តេច ក៏នៅតែមិនលះបង់ចោលអំពើពាលដែរ ចៃរដាវកេរឿន
ប្រទុស្តរាយនឹងអ្នកលួងលោមនោះវិញ ប៉ុន្តែក្នុងទីបំផុត អំពើពាលរបស់
ខ្លួននោះត្រឡប់ជាឲ្យផលដល់ខ្លួនឯងវិញ ទាំងក្នុងបច្ចុប្បន្នកពន្លឹងសម្ប-
រាយកព, ហេតុនោះ បុគ្គលមិនគួរសេពគប់នឹងមនុស្សពាលទេ ។

២ – អ្នកប្រព្រឹត្តធម៌ តែងតែជួបប្រទះនឹងឧបស័គ្គសេចក្តីទុក្ខ
លំបាកខើសខាក់ជាពហ ហាក់ដូចជាឧបស័គ្គនោះមកលង្ឃាងមើលចិត្តអ្នក
ប្រព្រឹត្តធម៌ឲ្យដឹងថាអត់ធ្មត់ឯណាបានប្រសេ, ប្រសិនបើអ្នកប្រព្រឹត្តធម៌នោះ ជា
មនុស្សមិនស្រឡាញ់ធម៌ ចិត្តមិនក្លាហានទេ មុខជាចាញ់អំណាចឧប-
ស័គ្គងាយ ។ ណាស់, បើជាមនុស្សស្រឡាញ់ធម៌មែនពែន មុខជាមាន
ចិត្តក្លាហាន មុខជាអត់ធន់តទល់នឹងឧបស័គ្គនោះបាន រមែងលះបង់សុខ
ត្រៃគ្រាត់គ្រាតជាសុខបន្តិចបន្តួចចោលចេញបាន ប្រាថ្នាយកសុខដ៏ធំ
ទូលាយដែលនៅរង់ចាំខាងមុខឯណោះវិញ ដូចភាសិតនៃពុទ្ធគិបណ្ឌិត
ទាំងឡាយថា “ កាលបើស្រឡាញ់អាយុវៈ ត្រូវតែលះបង់ទ្រព្យសម្បត្តិ,
កាលបើស្រឡាញ់ជីវិត ត្រូវតែលះបង់អាយុវៈ, ប៉ុន្តែកាលបើស្រឡាញ់
ធម៌ ត្រូវតែលះបង់ចោលទាំងទ្រព្យសម្បត្តិទាំងអាយុវៈទាំងជីវិត ” ។

៣ – កាលកម្មអាក្រក់ មិនទាន់ឲ្យផល មនុស្សអាក្រក់ រមែងឃើញតែផលល្អ, កាលណាកម្មអាក្រក់ឲ្យផល មនុស្សអាក្រក់ ទើបឃើញផលអាក្រក់, កាលណាកម្មល្អ មិនទាន់ឲ្យផល មនុស្សល្អ រមែងឃើញផលអាក្រក់, កាលណាកម្មល្អឲ្យផល កាលណោះ មនុស្សល្អ ទើបឃើញផលល្អ ។

ឆត្តំ កម្មសមំ ពលំ

គ្មានកំឡាំងអ្វី ខ្លាំងស្មើនឹងកំឡាំងកម្មទេ ។

ចប់ប៊ុណ្ណោះ

សៀចក្តីផ្តួចដំណាំង

បើលោក-អ្នក ចាន់តែងរឿងព័ត៌ផ្នែកអក្សរសាស្ត្រ ឬផ្នែកសាសនា ហើយបញ្ជូនទៅឲ្យក្រសួងពុទ្ធសាសនបណ្ឌិត្យចុះផ្សាយកងកម្មជសុរិយា, ពុទ្ធសាសនបណ្ឌិត្យនឹងទទួលដោយមេត្តាចិត្ត, កាលពិនិត្យរឿងនោះ ឃើញថាមានសារប្រយោជន៍ដល់ពុទ្ធសាសនិកជន ក៏នឹងចុះផ្សាយជូន ។

អំពីតាំងចៅអធិការថ្មី

(តទៅ)

សញ្ញាប័ត្រលេខ ៥៥២ ចុះថ្ងៃសៅរ៍ ១៤ កើតខែមាឃឆ្នាំជូតស័ក ព.ស.
២៥៦៣ តាំងលោកគ្រូ ពត - ប៉ាល់ បញ្ញាជោតត្ថេរ ឆ្នាំច អាយុ ៥១ វស្សា ៣០
ជាចៅអធិការវត្តសុគន្ធារាម ឃុំបាធាយ ស្រុកដើមចឹក ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៥៥៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ឯក - មុំង មុនីជោតត្ថេរ កើតឆ្នាំច អាយុ ៣៩ វស្សា ១៩ ជាគ្រូសូត្រ
ស្តាំ វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៥៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
គង់ - សួន សុវណ្ណត្ថេរ កើតឆ្នាំខាល អាយុ ៣៥ វស្សា ១៤ ជាគ្រូសូត្រ
ឆ្វេង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៥៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ប៊ុត - យិម ឥន្ទប្បញ្ញោ កើតឆ្នាំរោង អាយុ ៤៥ វស្សា ២៥ ជាគ្រូសូត្រ
ស្តាំ វត្តសំរិទ្ធិជោត ឃុំចុងកោះសំរោង ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

សញ្ញាប័ត្រលេខ ៥៥៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
វល្លី - មុន ធម្មសុវណ្ណត្ថេរ កើតឆ្នាំជូត អាយុ ៣៧ វស្សា ១៧ ជាគ្រូ
សូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៥៧ ចុះថ្ងៃសៅរ៍ ១៤ កើតខែមាឃឆ្នាំជូតសំ-រឹទ្ធិស័ក តាំងលោកគ្រូ ឈុន-ជឹម សុវណ្ណត្នេរ ឆ្នាំជូត អាយុ៤៧វស្សា ២៧ ជាចៅអធិការ វត្តស្វាយអាត់ ឃុំព្រៃ ស្រុកកំចាយមារ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥៥៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ពោធ-ចាន់ តន្ធូត្នេរ ឆ្នាំច អាយុ ២៧ វស្សា ៦ ជាចៅអធិការ វត្តក្លូ ឃុំក្រចៅ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៥៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាន់-មៅ តន្ធុប្បញ្ញោ ឆ្នាំថោះ អាយុ ៣៤ វស្សា ១២ ជាចៅអធិការ វត្តឧលុពុទ្ធា ឃុំព្រៃទា ស្រុកព្រៃវែង ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥៦០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខន់-ខ្វេ ខ្វេត្នេរ ឆ្នាំមមែ អាយុ ៣០ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៦១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខេត្រ-ញឹក ញឹកត្នេរ ឆ្នាំច អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រធ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៦២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ា-យី យីរត្នេរ ឆ្នាំមមែ អាយុ ៣០ វស្សា ១០ ជាចៅអធិការ វត្តព្រៃក្តី ឃុំព្រៃកណ្តៀង ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៦៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឡុន - ឡុច ឡុចត្រែ ឆ្នាំកុរ អាយុ ២៦ វស្សា ៦ ជាចៅអធិការ វត្តព្រៃ គ្បាល់ ឃុំព្រៃឫស្សី ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៦៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ហ៊ុន - ឆោម តន្ធវេសរប្បញ្ញោ ឆ្នាំជូត អាយុ ២៥ វស្សា ៤ ជាគ្រូសូត្រ ស្តាំ វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៦៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅរ - សាយ សោរបញ្ញោ ឆ្នាំមមែ អាយុ ៣០ វស្សា ១០ ជាចៅអធិការ វត្តសំបុក ឃុំសំបុក ស្រុកគ្រចេះ ខេត្តគ្រចេះ ។

សញ្ញាប័ត្រលេខ ៥៦៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប្ញាក់ - ន៉ី តន្ធប្បញ្ញោ ឆ្នាំមមី អាយុ ៤៣ វស្សា ២២ ជាចៅអធិការ វត្តស្លែត ឃុំសំបុក ស្រុកគ្រចេះ ខេត្តគ្រចេះ ។

សញ្ញាប័ត្រលេខ ៥៦៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ - ច្រឹង ចរត្រែ ឆ្នាំ គ. ស. ១៩២០ វស្សា ៨ ជាចៅអធិការ វត្តទួល ពង្រ ឃុំតោល ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៥៦៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាំង - ង៉ាង សុវណ្ណប្បញ្ញោ ឆ្នាំកុរ អាយុ ២៦ វស្សា ៦ ជាចៅអធិការ វត្តសាកយ ឃុំស្វាយតាយាន ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៥៦៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជួ-យិម ព្រហ្មជោត ឆ្នាំច អាយុ ៥១ វស្សា ៣០ ជាគ្រូសូត្រស្តាំ វត្តលួស ឃុំសូទ្រនិគម ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ៥៧៥ ចុះថ្ងៃអង្គារ ៩ រោចខែមាឃ ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ជួង-ឯក ធម្មត្ថេរ ឆ្នាំវក អាយុ ៤១ វស្សា ២១ ជាចៅអធិការ វត្តព្រៃរំដេង ឃុំព្រៃរំដេង ស្រុកបាភ្នំ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥៧៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សូរ-សុទ សុវណ្ណបញ្ញា ឆ្នាំរកា អាយុ ២៨ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៧៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស-ជា ធម្មកេសរ ឆ្នាំកុរ អាយុ ២៦ វស្សា ៦ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៧៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សូរ-ហោង ហិន្ទុត្ថេរ ឆ្នាំកុរ អាយុ ៥០ វស្សា ៣០ ជាគ្រូសូត្រស្តាំ វត្តមេសាង ឃុំព្រៃរំដេង ស្រុកបាភ្នំ ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៥៧៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ង្ហួន-នៅ សុវណ្ណប្បញ្ញា ឆ្នាំឆ្លូ អាយុ ៣៦ វស្សា ១៥ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៨០ ចុះគាលបរិច្ឆេទជជែល តាំងលោកគ្រូ ជួង-ខិម តន្ទុត្ថេរ ឆ្នាំវក អាយុ ៦៥ វស្សា ៤៣ ជាចៅអធិការវត្តចំន្ទន៍ ក្រិស្នា ឃុំច្រែស ស្រុក-ខេត្តជជែល ។

សញ្ញាប័ត្រលេខ ៥៨១ ចុះគាលបរិច្ឆេទជជែល តាំងលោកគ្រូ សួស-ប៉ាន់ ធម្មកេសរត្ថេរ ឆ្នាំច អាយុ ៣៩ វស្សា ១៩ ជាគ្រូសូត្រស្ដាំ វត្ត-ឃុំ-ស្រុក-ខេត្តជជែល ។

សញ្ញាប័ត្រលេខ ៥៨២ ចុះគាលបរិច្ឆេទជជែល តាំងលោកគ្រូ ព៉ា-អ៊ុត តន្ទមុនីវ័ន្ត ឆ្នាំរោង អាយុ ៣៣ វស្សា ១៣ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តជជែល ។

សញ្ញាប័ត្រលេខ ៥៨៣ ចុះគាលបរិច្ឆេទជជែល តាំងលោកគ្រូ ឯល-សុំម ពុទ្ធត្ថេរ ឆ្នាំរោង អាយុ ៣៣ វស្សា ១២ ជាចៅអធិការវត្តព្រៃខ្វា ឃុំ-ស្រុក-ខេត្តជជែល ។

សញ្ញាប័ត្រលេខ ៥៨៤ ចុះគាលបរិច្ឆេទជជែល តាំងលោកគ្រូ ជិន-ម៉ម បញ្ញាកេសរ ឆ្នាំមមែ អាយុ ៥៤ វស្សា ៣៤ ជាចៅអធិការវត្តស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុក-ខេត្តជជែល ។

សញ្ញាប័ត្រលេខ ៥៨៥ ចុះគាលបរិច្ឆេទជជែល តាំងលោកគ្រូ ខៀង-សុច មង្គលត្ថេរ ឆ្នាំម្សាញ់ អាយុ ៥៦ វស្សា ២៤ ជាចៅអធិការវត្តស្វាយខង ឃុំ-ស្រុក-ខេត្តជជែល ។

សញ្ញាប័ត្រលេខ ៥៨៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចិន - ឈិត ឥន្ទប្បញ្ញោ ឆ្នាំមមី អាយុ ៣១ វស្សា ១១ ជាចៅអធិការ វត្តក្ដៀត ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៨៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី - ថោង សុវណ្ណត្ថេរ កើតឆ្នាំវក អាយុ ៤១ វស្សា ២២ ជាចៅអធិការ វត្តព្រៃឃ្មេស ឃុំព្រៃឃ្មេស ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៨៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គោគ - ផាប់ សុវត្ថេរ ឆ្នាំច អាយុ ៣៩ ជាគ្រូសូត្រស្ដាំ វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៨៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឃិន - លាស់ ពុទ្ធរក្ខិតោ ឆ្នាំកុរ អាយុ ២៦ វស្សា ៥ ជាគ្រូសូត្រឆ្វេង វត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៩០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចិន - ន័យ ធម្មរក្ខិត ឆ្នាំរកា អាយុ ២៨ វស្សា ៩ ជាចៅអធិការ វត្តសន្ទុង ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៩១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ន្ឋន - វេន ធម្មប្បញ្ញោ ឆ្នាំមមែ អាយុ ៣០ វស្សា ១១ ជាគ្រូសូត្រឆ្វេង វត្តឫស្សីគ្រាវ ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៨២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ យស-បូក បុត្តត្រេ ឆ្នាំមមែ អាយុ ៦៦ វស្សា ៤៥ ជាចៅអធិការវត្តជីជុច ឃុំជីជុច ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៨៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កែវ-ជា ជោតត្រេ ឆ្នាំរកា អាយុ ៥២ វស្សា ៣២ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៨៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ថោង-ជន មុនីតេសរ ឆ្នាំច អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៨៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឥន្ទ-គង់ ឥន្ទត្រេ ឆ្នាំថោះ អាយុ ៤៦ វស្សា ២៧ ជាចៅអធិការវត្តពោធិសាណ ឃុំជីជុច ស្រុកហាក្នុំ ខេត្តកែវវែង ។

សញ្ញាប័ត្រលេខ ៥៨៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ញឹក-ខ្វាន់ សុវណ្ណកេសរ ឆ្នាំរោង អាយុ ៤៥ វស្សា ២៥ ជាចៅអធិការវត្តស្វាយវុន ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៨៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ យិន-តាយ ចន្ទត្រេ ឆ្នាំច អាយុ ២៧ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

(មានត

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀ អក្សរសាស្ត្រ ចោះពុទ្ធប្បវត្តិ
អំពីពុទ្ធសាសនចក្កវត្តិ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក ភ័យ - ប៊ុក
ក្រុមការ នៅពុទ្ធសាសនចក្កវត្តិ

បណ្ណាធិការ ផ្នែកសាសនា: ព្រះទេពសត្ថា សូរ - ហាង
ក្រុមដំនុំព្រះធ្លៃចំងាក នៅពុទ្ធសាសនចក្កវត្តិ

ផ្នែកអក្សរសាស្ត្រ	បញ្ជីក្បឿង	ទំព័រ
លោក ភ័យ-ប៊ុក ក្រមការ	សុភាសិតអង់គ្លេស	១៦១
— —	ឧទាទមហាឌ្ឋៈគន្ធ	១៦៥
ព្រះឃ្លាំង ខង	រឿងភោគកុលកុមារ (តមក)	១៧២
ប - ប៊ុក ក្រមការ	អង្គរកម្លឹងណែលខ្មែរ	១៨៤
រ៉ៃប៊ុលភាជសេនា ង្ហ - ភក្ត	រឿងសាមក្ក (តមក)	១៨៩
ង - សាភ័ត	រឿងត្រែងភូមា (តមក)	២១៦
ប្រមាក់ណ្ឌ ឈឹម - ណាក	រឿងក្មេងកំព្រា (តមកជប់)	២១១
សាសនា		
លោក ម៉ុញ - ឆាំត្រី តំណាងអក្សរស្ត្រ	ពុទ្ធសាសនានិងភាហ៊ារសាសនា (តមក) ...	២១៦
ឃុនបណ្ណាគុរក្ស ប៊ូ - ប៊ូ	ខុរប្បដាតក	២៣៤

ឆ្នាំទី ២២ — លេខ ៣ ខែមីនា ឆ្នាំ ១៩៥០ — ដំឡៃដាក់ ១ ឆ្នាំ ១៥៥ រៀល ។

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire:

		page
M.Ray-Buc Kramakar (I. B.)	Proverbes anglais (suite).....	161
— id —	Recueil des Paroles de Gandhi.....	165
Neak oknha Brah khleang Nong M. Ray-Buc Kramakar (I. B.)	Bhogakula kumara (suite).....	172
	Angkor, patrimoine national des Khmes	184
Néak oknha Vibularaja-séna Nou Kân	Histoire de Sam-kok (suite).....	189
M Sang-Savat Ministère des Finnances	Contes birmans (suite).....	206
Chhim-Nak (I. B.)	L'enfant orphelin (Conte) (suite et fin	210

Partie religieuse:

M. Ménh-Nakry Député	Le Bouddhisme et les autres religions (suite)..	216
Bou - Po (I. B.)	Khurapajataka.....	234

22e Année: No 3 Mars 1959 — Prix d'abonnement: 145$00 par an.

១៦ – បើលោកថ្នាក់ថ្នមចង់ឲ្យានខ្លួនវត្តមាំងឡាយ លោកត្រូវត្រាប់តាមឲ្យជាប់ពីក្រោយក្រ (ត្រូវស្វែងរក) ។

" ស្វែងរកទើបបាន ព្យាយាមប្រឹងប្រែង ទើបសម្រេចផល
រីយាជាគ្រូ មាសប្រាក់តំកល់ ទ្រព្យធនកុំខ្ជល់ ស្វែងរកញើសជាប " ។

១៧ – បើសិនណាជាលោកមិនអាចលះកម្ចាជាតិ សូម្បីតែមួយក៏លោកត្រូវធ្វើស្នែងខានមិនបាន ។

" បើរកម្ចាជាតិមិនបាន មិនត្រូវខានធ្វើការរបស់ខ្លួន
កើតមកជាមនុស្សប្រឹងមាំមួន ធ្វើស្រែជាំសួនកុំនៅស្ងៀម " ។

១៨ – ចូររៀបរៀបប្រាសខ្លួនឯង ទើបព្រះជាម្ចាស់បញ្ជូនអំបោះមកឲ្យ ។

" កុំរង់ចាំព្រឹងពាក្យបុណ្យ ត្រូវតែរកតុនកុំខ្ជាបខ្ជីយ
ខ្លួនត្រូវធ្វើការងារឯ ខំធ្វើឲ្យហើយកុំទុកស្អែក " ។

១៩ – បើមានថ្នាក់ថ្នមឲ្យដល់កំពូល ត្រូវខ្ជីឆ្ងាយពីកាំជាន់គាបជាមុន ។

" ចង់ឡើងគេហដ្ឋានលើឡើងផណ្តើរ
ភាពចះស្មើរចង់ធ្វើធំមិនសម្រេច
មិនខានរៀនធម៌រៀនយកចង់ពុទ្ធកិច្ច
ចង់រត់គាចខ្លួនភារកម្មទើបចេះការ " ។

២០ — ការងារគ្រប់យ៉ាងក្នុងលោកសន្និវាសនេះ មិនមែនសុទ្ធតែប្រើកំឡាំងកាយទេ ។

វិស្វការលំពុង

" ការងារលោកប្រើកំឡាំងកាយភាគ
ចិត្តច្បាច្បាព្យាយាមកិច្ចទើបកបផល
ចិត្តប្រជានច្បានសម្រេចព្យាយាមជល
ទ្រព្យជំគល់យសជំកើងតាមច្បាច្បា " ។

២១ — នៅក្រៃមព្រះអ័ទិត្យនេះ " មានមនុស្សជាច្រើននាក់ដែលធ្វើជាការប្រយោជន៍ ចំពោះមនុស្សមួយនាក់ " ។

ប៊ីរុងក្នុងរឿង "The Corsaire"

" មនុស្សច្រើនភាគ ជាងមន្ត្រីជាប ញាណជំលំអាន ធ្វើការប្រយោជន៍ មនុស្សម្នាក់តាមស្មាន ព្យាយាមប្រឹងច្បាណា បបរថ្ងៃគ្មានឈប់ " ។

២២ — ចូរក្រែបខ្លួនវាសជាតិនៃហាសនចិត្តដែលជាផលរបស់ការងារ។

ប្លុងហ្សេល្សក្នុងរឿង "Masque of Pandora"

" ការងារសុចរិត ធ្វើហើយប្រព្រឹត្ត ហាសនចិត្តផ្សាយ វេសជាតិ
ទុត្តម ប្រសើរពណ្ណភាយ ព្រឹត្តិចអង្គកាយ សប្បាយចំឡែក " ។

២៣ — អ្នកណាព្យាយាមធ្វើការឲ្យបានយ៉ាងស្អាតបរិសុទ្ធបំផុត
ដែលជនសាមញ្ញមិនងាយនឹងធ្វើបាន អ្នកនោះឈ្មោះថាធ្វើការប្រសើរ ។

" បណ្ឌិតធ្វើការ ឈ្លូសចាំងបន្ទារ ល្អស្អាតតតហ្មង ធ្វើកិច្ច
សារពើ ព្យាយាមជាច្បង គោសតែច្រើនជង ទើបបានសោភ័ណ " ។

២៤ — វេលាជាមាសជាប្រាក់ ។

ប៊ុលវ៉ែរលីតុង

" វេលាជាមាសប្រាក់ឲ្យខ្ចី ចេះប្រើសំចៃយកថ្លៃបាន វេលា
ខូចខាតវិនាសប្រាណ វេលាអាក់ខានជួបទុក្ខទោស " ។

២៥ — វេលានាំមកនូវសេចក្តីឈ្លាសវៃ ។

" ចេះប្រើពេលគាចពុះពារទុបសំគ្គបាន
តូដតល្បាណជាតិបណ្ឌិតកំណាញ់កាល
វេលាឲ្យប្រាជ្ញាឈ្លាសវៃក្លៀវក្លាល
វេលាជាលនាំបណ្តុះពូជទុស្សាហ៍ " ។

២៦ — វេលាជាជីវិតរបស់ជួនវិញ្ញាណ ។

ឡុងហ្វេលូ

" វេលាជីវិតសមភាគ ច្រាដច្រាបវេលាថ្នមគួរគាប់
ជីវិតសត្វលោកពេលច្រាត្រ ចៃយប់ធ្វើតពេលកសាងជាតិ " ។

២៧ — គ្រប់ខណៈមានមនុស្សស្លាប់ ហើយគ្រប់ខណៈមានមនុស្សកើត ។

ពែណនាំសុង ក្នុងរឿង · Vision of sin"

" កើតស្លាប់គួរគា យល់ភាពមរណា ស្គាល់កើតដឹងកល សង្ខារក្នុងលោក យើញមគ្គុយល់ផល ភ្លឺឆ្ងឹតដល់ កុំឆ្ងល់ធម៌ពីរ " ។

២៨ — អ្នកទទួលបំរើគេតាមកំណត់វេលា អាចមានអាយុ ៣០ ឆ្នាំ តែរូបរាងកាយចាស់គ្រាំគ្រា ស្លាប់ទៅក៏សឹងមាន ឬអាចមានអាយុ ៩០ ឆ្នាំ តែរូបរាងកាយពេញកំឡាំងដូចកំឡោះ ស្លាប់ទៅក៏សឹងមាន ។

" ពួកទាសកម្មកំរបំរើគេ គ្មានពេលទំនេរមួយនាទី
ឈ្មោះថាហាត់កាយពលវិធី អាយុវាស៊ីរស់យឺនយូរ " ។

២៩ — នៅក្រោមព្រះអាទិត្យ គ្មានកិច្ចអ្វីដែលគួរឲ្យតូចចិត្តជាង ការបណ្តែតបណ្តោយឲ្យខូចពេលអស់មួយថ្ងៃ ដោយខ្លួនមិនបានធ្វើការអ្វីសោះឡើយនោះទេ ។

" ខូចវេលាខាតឲ្យមាស់ច្រាក ខូចបុណ្យយសស័ក្តិវិនាសខ្លួន
ខូចវេលាខាតវិជ្ជាក្បួន ដូចត្រីគួនដុះកន្ទុំក្នុងខ្ចឹង " ។

(មានត)

ខុំភនមហាត្មគន្ធ

Recueil des paroles de Gandhi

លោក ព័ន្ធ - ប៊ុត ក្រមការ ជាតិសង្គ្រោះ

ក). ស្រង់ពីសារព័ត៌មាន ហ្សឺនអាំង "Jeune Inde"

១ — ខ្ញុំបានបង្ហាញដោយឆាប់ស្ពឹងខ្លួនគ្រោងការណ៍ដែលប្រកបដោយសេចក្តីអង់អាចរបស់ខ្ញុំ, ខ្ញុំស្អប់ខ្ពើមការស្ងាត់កំបុតង ដូចជាខ្ញុំស្អប់បទឧក្រិដ្ឋ, ខ្ញុំសូមថ្លែងសេចក្តីអរគុណចំពោះព្រះជាម្ចាស់ ដែលខ្ញុំបានដឹងជាយូរយារមកហើយថា ការស្ងាត់កំបុតងជាអំពើអកុសលមួយចំពោះបញ្ញានយោបាយ, នៅក្បាលដែលខ្ញុំកក្រើកក្នុងចិត្តមិនត្រូវលាក់លៀមទេ ។

សារព័ត៌មាន ថ្ងៃ ១២ ខែធ្នូ ១៩២០
(អំពើអកុសលនៃការស្ងាត់កំបុតង)

២ — ត្រូវប្រើកាលវេលាវែងឆ្ងាយទូលាយណាស់ មុននឹងធ្វើរឿងព័ត៌មានប្រទេសឲ្យទទួលស្គាល់ខ្លួនថ្លាប់ត្រហ្វិហារផង . . . ដល់ទៅថ្ងៃណាមួយគេកេរឃើញ ហើយប្រើបានខ្លួនថាមភាពថ្មីមួយ ចំណែកអ្នកដែលបានកេរឃើញខ្លួនថាមភាពពីជាន់មុន គេអាចពោលថា អ្នកនោះជាឧត្តរិបុគ្គល (Idéaliste) ឬជាអចិន្ត្រៃបុគ្គល (utopique). លោកវិស្វកអគ្គិសនីត្រូវគេចោទថាជាអ្នកមានចរិតខុសពីជនធម្មតា (maniaque) ឬជាមនុស្ស

ម្ចាស់ក: (fou) ចំពោះមជ្ឈមដ្ឋានយានគមនាគមន៍ដែលប្រើស្ទឹន (locomotion à vapeur) លុះតែតែកិច្ចការនេះបានសម្រេចផលប្រយោជន៍ជាស្ថាពរដោយសារបង្កើតខ្សែក្តឹងអគ្គិសនី ទើបគេឈប់ពោល, ត្រូវរកពេលវែងឆ្ងាយ ដើម្បីនឹងដេញខ្សែព្រហ្មវិហារឲ្យជាប់ខាក់ខងរវាងប្រទេសមូលជាឯកច្ឆន្ទ, តែតាមសេចក្តីយល់ឃើញនូវព្រឹត្តិការណ៍នៃទ្វីបនៃរ៉ុប នឹងអាស៊ីបូព៌ាក្នុងពេលមុនៗនេះ ចំពោះរឿងដែលមានសារៈសំខាន់ យើងបានឃើញថា សកលលោកក្នុងសម័យបច្ចុប្បន្ន បានពិនិត្យយល់ជាក់ច្បាស់ថា ពលកាព (force) តែមួយយ៉ាង មិនអាចនឹងដោះស្រាយនូវបញ្ហាផ្សេងៗនេះបានចំពោះប្រជាជាតិនឹងបុគ្គល ហើយថារបៀបប្រែនយោបាយសេដ្ឋកិច្ច ដោយមិនព្រមចូលសមាគមនឹងជាតិដែលកាន់កាប់ប្រទេសអាណានិគម មានសកាពវិសេសជាងប្រែកងំព ជើងគោក - ទឹក ។

សារពត៌មាន ថ្ងៃ ២៣ខែមិថុនា ១៩១៩

៣ — ប្រតិបត្តិតាមច្បាប់របស់រដ្ឋ នេះជាតំណែនៃពលរដ្ឋដែលត្រូវធ្វើដោយសេរីភាពសព្វៗខ្លួន, ធ្វើតាមបង្គាប់នៃរដ្ឋដែលប្រព្រឹត្តអយុត្តិធម៌ពេញលក្ខណៈ គឺប្រព្រឹត្តជំទាស់នឹងសីលធម៌ ត្រមាំងសេរីភាព ។

បញ្ហាមានសារៈសំខាន់ជាបំផុត

សារពត៌មាន ថ្ងៃ ១០ ខែវិច្ឆិកា ១៩២១

៤ — ខ្ញុំស្មើនឹកឃើញថាប្រែណាត គឺធ្វើឲ្យសម្រែចខ្លួនក្នុងខ្លួនឯង ហើយឲ្យសម្រែចនូវផោតវាសនារបស់ខ្លួន គឺថាបានដល់សុក្រិតភាព (perfection), ខ្ញុំបានដឹងដោយលំបាកថា ខ្លួនខ្ញុំល្ងង់ខ្លៅច្រើន ហើយការដឹងប្រែបែបនេះជាតិលភាពរបស់ខ្ញុំ ដោយហេតុថា កម្រមានមនុស្សដឹងខ្លួនៗឯងថាអាត្មានោះខ្លះទាតចំណេះវិជ្ជាគ្រប់យ៉ាង ។

សារពត៌មាន ថ្ងៃ ១៨ ខែធ្នូ ១៩២១

៥ — អរិហ៏សាវ៉ែតក្ត " ការត្រិះរិះមិនប្រែតរបៀនអ្នកដទៃ " ដោយសភាពជាថាមវន្ត ដែលមានធម៌អាចតស៊ូនឹងធន្ទ: នៃមហាពលាល (tyran), បុគ្គលណាប្រព្រឹត្តតាមច្បាប់រឹសេសនេះ អាចតស៊ូនឹងពលភាពនៃប្រទេសដែលមានគំនិតរុញច្រាន ទាំងបណ្តាលឲ្យប្រទេសនោះធ្លាក់ចុះអន់ថយ ឬអាចធ្វើឲ្យប្រទេសនោះវិលប្រែលបាន ។

សារពត៌មាន ថ្ងៃ ១១ ខែកញ្ញា ១៩២០

៦ — ឱព្រះជាអម្ចាស់អើយ !

សូមព្រះអង្គណែនាំប្រទេសតណ្ហៀឲ្យចូលទៅកាន់មាគ៌ាដ៏ស្មុគ្ន !

សូមព្រះអង្គបង្ហាត់បង្ហាញឲ្យប្រទេសនេះកាន់លទ្ធិ " សូទេស្ស៊ី[1] " !

---

1 សូទេស៊ី មកពី សូទេត ប្រែថា " ប្រទេសរបស់ខ្លួន ស្រុករបស់ខ្លួន " (វចនានុក្រមខ្មែរ ភាគ ២) ។

សូមព្រះអង្គប្រមូលជាតិឥណ្ឌូ, មហាហ្វ៊ូត, ប៉ារសិស[1], គ្រិស្ត, ស៊ូវ ដែលរស់នៅក្នុងប្រទេសឥណ្ឌូឲ្យមានសាមគ្គីជាឯកច្ឆន្ទ !

ឪ ទៀប៊ូក : ៩១៩

៧— បញ្ហានយោបាយ ឃានដល់ការគេស៊ូដើម្បីប្រយោជន៍ក្រុម គឺគេស៊ូនឹងសេចក្តីភ័ន្តច្រឡំដែលកើតមកពីច្បាប់អយុត្តិធម៌ ។

ឪ ទៀប៊ូក ១៧១៩

៨— បើប្រជាក្រុលែងខ្វាចនូវពលកាព . វង្វាតិចាលកំត្រូវជឿខ្លួនដោយខ្លួនឯងថា កំលាំងជាសកាពប្រើការមិនកើត ចំពោះបុគ្គលដែលមិនខ្វាចនូវកំលាំង គឺអ្នកនោះលែងហ៊ានប្រើកំលាំងនេះតទៅទៀតហើយ, បុគ្គលណាដែលមានសិទ្ធិទៅកាន់តំណែងរាជការ ច្រើនពេញចិត្តក្នុងការប្រើការណាកម្មចំពោះប្រជាក្រុ ក្បួននៃការគ្រួតគ្រាគឺត្រូវមាន

---

១ ប៉ារសិស ជាឈ្មោះពួកអ្នកកាន់លទ្ធិសូរូអាស្ត្រ (Zoroastre) នៅប្រទេសប៊ែរ្ស ខែលជាកូលមកនៅក្នុងប្រទេសឥណ្ឌូជាច្រើន. សូរូអាស្ត្រ ជាអ្នកកែទម្លែងសាសនា (Réformateur) នៅប្រទេសអ៊ីរ៉ង់ កើតនៅក្នុងមេឌី ៦៦០ មុនគ្រិស្តសករាជ ហើយមរណភាពក្នុងឆ្នាំ ៥៨៣ មុនគ្រិស្តសករាជ, លទ្ធិនេះមានសារៈសំខាន់ពីរយ៉ាងគឺ ១ ព្រះជាម្ចាស់ល្អ គេហៅថា អាហ៊ុយភ៉ា ម៉ាកដា (Ahura Mazda) ខំនៃព្រះជាម្ចាស់អាក្រក់ គេហៅថា អង្គ្រាមន្យូ (Angra Mainyou) ហើយព្រះទាំងពីរនេះធ្វើសង្គ្រាមនឹងគ្នាតទៅវិញទៅមក ។

(រៀបតុក្រមយ៉ាងណ)

កំលាំងត្រប់គ្រាន់បរិបូណ៌សម្រាប់អាត្មា ល្មមនឹងបង្ខិតបង្ខំប្រជាពលរដ្ឋ ដោយប្រើវិធីបំភ័យតាលំតែប្រជាពលរដ្ឋព្រមបុះចាញ់, ហើយរដ្ឋាភិបាលដែលគេទុកជាវត្ថុសម្រាប់បង្ក្រាបន្ទូវផ្នែវការបាន លុះត្រាតែរដ្ឋាភិបាលនោះតាំងដោយឆន្ទៈនឹងសេចក្តីព្រមព្រៀងរបស់ប្រជាពលរដ្ឋ, រដ្ឋាភិបាលដែលធ្វើឲ្យប្រជាពលរដ្ឋប្រតិបត្តិតាមច្បាប់ ដោយប្រើបុងត្រីជាអាវុធ ។

ថ្ងៃ ២២ ខែតុលា ១៧១៩

៩ — ខ្ញុំដឹងថា ពួកពលរដ្ឋមានសិទ្ធិដកហូតសាមគ្គីភាពពីរាជការ បើសាមគ្គីភាពនោះនាំឲ្យថោកខាបប្តូរចក្តីយសដល់ខ្លួន, នេះជាទុក្ខមួយដែលបង្ហាញឲ្យរាជការដឹងជាក់នូវសេចក្តីគោរមនស្សរបស់ប្រជាពលរដ្ឋ ។

សន្ទរកថាលោកនហ្គូតឌិញ

ថ្ងៃតទៅទី ក្រុងអ៊ុង ពីថ្ងៃ ៣ ខែធ្នូ ១៧១៩

១០ — ពិតមែនតែការចលនាមិនសុទ្ធតែនាំទៅកាន់វឌ្ឍនធម៌, ឯការចលាចលក៏មិនសុទ្ធតែនាំទៅកាន់ជោគជ័យដែរ ។

ថ្ងៃគារណ៌ចំពោះត្រ.មហាក្សត្រ

ពីថ្ងៃ ៣១ ខែធ្នូ ១៧១៩

๑๑ — ការចលាចលគ្មានវិន័យ គឺជាកិច្ចការធ្វើដោយកំហឹងខ្លាំ
កំហាលដោយក្តៅចានឹងដោយកម្តៅភាព នាំឲ្យយឺតយូរខ្លួវរីឡូនជម័រថស
ប្រជាជាតិ ហើយនាំឲ្យបានទោសទុក្ខដែលមិនគួរមានសោះ ដូចជាឃាត-
កម្មនៃលោកសាល្ហ៊ីយ៉ង់វាឡាបាគហ៍ (Jallianwalla Bagh) ជាដើម ។

ថ្លែងការណ៍ចំពោះព្រះមហាក្សត្រ
ពីថ្ងៃ ៣១ ខែធ្នូ ១៩១៩

๑๒ — សេចក្តីទុកចិត្តជាគុណធម៌មួយ, ពុំឲ្យភាពខ្លាំមិនឲ្យ
ទុកចិត្ត ។

ថ្លែងការណ៍ចំពោះព្រះមហាក្សត្រ
ពីថ្ងៃ ៣១ ខែធ្នូ ១៩១៩

๑๓ — សម្ព័ន្ធភាព គឺមានចំណងជាមួយគ្នា មានសេចក្តីសង្ឃឹម
ជាមួយគ្នា ខឹង វង់ទុក្ខលំបាកជាមួយគ្នា ។

សម្ព័ន្ធភាពជាតិឥណ្ឌា - មហាហ្ម្មត
ថ្ងៃ ២៩ ខែកុម្ភៈ ១៩២០

๑๔ — បុញ្ញកម្មធ្វើកន្លងពេលដែលមានជោគជ័យតែងមានដំណែរជានិច្ច ។
... គ្មានប្រជាជាតិណាអាចឡើងទៅកាន់ស្ថានឧត្តមបានទេ បើ
គ្មានពលិកម្ម (Sacrifice) ហើយគេអាចពោលពីពលិកម្មចំពោះតែសេចក្តី
សុចរិត មិនមែនសេចក្តីទុច្ចរិតឡើយ ។

ប្រកាសនៅទីក្រុងអាត្លង់តា
ពីថ្ងៃ ៣ ខែមិនា ១៩១០

๑๕ – សកាពត្រួតត្រាលើខ្លួនឯងបាន ជាប្បាប់សម្រាប់ខ្លួនយើង, សុក្រិតភាពជាវិ សសនធីបិតថេរនៅបាន មកពីសកាពត្រួតត្រាខ្លួនឯង ដោយម៉ឺងម៉ាត់, សេចក្តីទុក្ខត្រូវប្រាប់ជាបដិមា (គោលសម្មតិ) (Symbole) នៃជាតិមនុស្ស ។

អហិសកៈ

៨ ខែមិថុនា ១៩២០

๑๖ – ការបង្ហាញឲ្យឃើញជាក់ស្តែងដោយកិច្ចធ្វើពលិកម្មនេះឯង ជាហេតុធ្វើឲ្យប្រទេសជាតិរុងរឿងទៅអនាគត, ប្រទេសជាតិមិនមែនរុងរឿងដោយផ្តងចិត្តប៉ងធ្វើអាឃាតញាប់ទេ ។

សន្ធិបាតថ្ងៃ ៦ ខែឆ ១៣ ខែមេសា ១៩២១

ថ្ងៃ ១១ ខែមិថុនា ១៩២០

๑๗ – មែនពិត បើតាមមតិរបស់មនុស្ស, មានភាគច្រើនយល់ថា ការប្រើអក្សរជាតិនេះ អាចនឹងញ៉ាំងមនុស្សឲ្យគិតការខុតួមបាន ។

បុព្វហេតុនៃអក្សរជាតិ

២១ ខែមេសា ១៩២០

(មានត)

អ្នកឧកញ៉ាព្រះឃ្លាំង ឆង រៀបរៀង

(ត១ក)

មាតាបិតា ស្តាប់បុត្រទូលលា ទើងរំលែងខ្លី ត្រមព្រះហ្ឫទ័យ ក្សត្រៃលែងពាំង
ពីរ បើកបុត្រកាប្រិយ តាមព្រះចំណា ។ ព្រះបាទសត្តកុជ រាជាវិសុទ្ធ វិ-
សេសត្រាស់ថា ហៃកូនសំឡាញ់ ចង់ចេញឃ្លាតឃ្លា ទៅនគរ ពាក-
ណាសី ។ អាពុកតាមចិត្ត ពិតពុំទាំងឃាត់ កូនស្ងួនប្រិមប្រិយ ចូរបាច្ចត់
ច្ចង់ តម្រង់ស្មារតី ត្រៃត្រង់ជានី ជានាវាស្តុធង ។ តាមដោយទស
ពិត រាជធម៌សុចរិត កុំឲ្យមានហ្មង រង្គាស្តួសឫទ្ធាន តតមានភ័យធង
តាមដោយគន្ធង ធម៌ព្រះពុទ្ធាន ។ មួយគឺធម៌ថា ឲ្យសង់សាលា ដីត
ស្រះសង់ស្ពាន ទស្សាហ៍ខ្នូលខ្នាយ ចែកចាយធនធាន ធ្វើបុណ្យឲ្យទាន
សត្វថ្លៃបែកគី ។ គំរប់ពីរចាំ រក្សាសីលថ្កុំ លុះថ្ងៃអដ្ឋមី ថ្ងៃ១ចោ៎សេ
ស្រគត់តខ្ជិយ សូមសីលថ្កុម្ប៉ី កាន់កុំខាតខាន ។ ជាគំរប់បី ចូរចាំប្រ-
ណី ជាក់ព្រះរាជទាន ចិញ្ចឹមរយោធា សេនាគាហាន បរិពារត្រៃបិដ្ឋ ណា
ថែរក្សា ។ ជាគំរប់ ៤ ចូរចិញ្ចឹមខ្លួន តាមដោយសម្មា សមាណបរិ-
ភោគ អធ្យាគអធ្យា កុំគិតបំពា បំពានត្រៃគេ ។ ជាគំរប់ ៥ ចូរចង
ចិត្តចាំ កុំកាន់រៀចរៃ តិតដោះខុក្ខភស្តូ ទាំងធ្លាសឲ្យថៃ ឲ្យធួនប្រើប្រៃ
ព្រះទ័យឲ្យខន់ ។ ជាគំរប់ ៦ មាន តបៈឲ្យបាន ឈ្នះចិត្តលោកលន់

លះលែងទោសា មោហាទូដ៏ន ចានបរិបូណ៌បុណ្យ បំបាត់បាបបង់ ។
ជាឪសោត កុំឲ្យក្រែវក្រោធ ធុរធាប់ឲ្យវង់ ឲ្យរំពឹង ជញ្ជឹងគិតក្នុង
ហ្មុងឲ្យត្រង់ ឲ្យត្រូវធម្មា ។ គំរប់ ៨ កុំបៀតជីវ ជីវិតហឹង្សា
មនុស្សសត្វតតោស សន្តោសមេត្តា អាសូរករុណា ជួយជន្មជីវ ។
ជា ៩ បទ ឲ្យមានអំណត់ អំណរខន្តី សច្ចំបរមត្ថ កាន់កតវេទី គិត
គុណជនន៏ ជនកប្រធាន ។ គំរប់ ១០ ដោយ ធម៌ថាប្រើឲ្យ មហា-
ក្សត្រក្សេមក្សាន្ត ត្រែតទ្រង់សណ្តាប់ តាមច្បាប់បុពណ កុំឲ្យបំពាន
បំពារក្រែកក្រិត្យ ។ បើក្សត្រឯណា គិតគាន់សីលា តាមដោយទស-
ពិធ រាជធម៌ខ្ជាន់ ខ្ជឹងចានសម្រិទ្ធ សម្រែចដួចចិត្ត ដួចក្តីប្រាថ្នា ។
កងលោកកិយគាប់ កើតក្តៅគំនាប់ គំនិតវៃថ្លា បរលោកនឹងចាន
បិតហានសួគ៌ា ជាស់តុសិតា សោយសម្បត្តិបុណ្យ ។

ទើបព្រះជនន៏ ខ្ជូន្នានបុត្រី ថាកូនសួនតន ចូរចេះចាំចិត្ត គំនិត
ឲ្យជ្រួន ឲ្យគិតឲ្យគន់ ឲ្យគួរដោយធម៌ ។ ចូរនាងចងចាំ រក្សាសីល
ប្រាំ សត្វវៃរៀងកាល់ វៃចេតអដ្ឋមី បូណ៌មីឲ្យស្គាល់ ឲ្យដឹងកិច្ចការ
កាន់សីលប្រាំបី ។ ព្រះពុទ្ធប្រតាន ខេស្នាខ្ជូន្នាន អស់អង្គស្រីសីល
ប្រាំពីរប្រការ សត្វសារតើពី កិត្យក្រមនារី ចូរនាងស្តែងស្តាប់ ។
មួយឈ្មោះតេជ្ជយាជ ករិយាប្រមាទ ស្វាមីក្រៅច្បាប់ ចិត្ត ៤ ប្រការ
តតសារតតសត្វ តតសីលពុំគាប់ ពុំគិតក្តើរកោះ ។ ចិត្ត ១ រងរូស

ប្រទះប្រទូស្ត ប្រកាន់ឈ្លាសឈ្លោះ សំឡក់សំឡឹង មុខរឹងចោកចោះ
ពោលពាក្យទ្រគោះ ឲ្យប្តីអៀនអាក់ ។ ចិត្ត ๑ ស្រើបស្រាល សើច
ស្រួលស្នេហ៍ស្មោះ ស្មុំស្មិទ្ធមុខក្យ ឱនប្រសដៃ អាលំយោះស្មោះស្ម័គ្រ
ប្រើប្រុសឲ្យងាក់ សិល្បសាស្ត្រធ្វើប្តី ។ ចិត្តមួយមិនគោត មិន
មានកំណោត តម្កែងស្វាមី រំលើកតំរៀល ដំនៀលជេរស្តី មើល
ងាយស្រដី ពោលពាក្យពុំត្រែង ។ ចិត្តមួយកំណាច គំនិតគិតខ្ទាច
ចរចេញចាយចែង និយាយស្រដី ដើមប្តីតម្កែង ទោសស្វាមីឯង
ឲ្យអស់គេស្តាប់ ។ រីចោរកិរិយា មានចិត្តថ្មាំថ្មា – ការកត់ត្រង់គ្រាប់
មួយមិនចង់ធ្វើ សារពើការគាប់ តុំចង់ប្រជាប់ ប្រជាឲ្យប្តី ។ មួយ
ចិត្តចង់ចាយ ទ្រព្យប្តីពុំស្តាយ គិតតែទិញដំ លួចលាក់ជ្រាំងបិទ
ឲ្យមិត្តភ្ងាប្រិយ បង្គិនទ្រព្យប្តី ពុំចេះផ្តន់ផ្តង់ ។ មួយប៉ើប្តីបាន
មាសប្រាក់ជនជាន រក្សាពុំគង់ តុំតិតជាក់ខ្ទុក ខំខ្ទុកបម្រុង
អម្រែសឲ្យបង់ ឲ្យបាត់តុំស្តាយ ។ មួយចេះតែស្នាង បញ្ជើរូបរាង
ពន្ធ្រីមពន្ធ្រាយ ពន្ធ្រើតដើរលេង ជាល្បែងសប្បាយ ចង់មានសហាយ
ស្អប់ប្តីអាត្មា ។ មួយប៉ើស្វាមី ស្រឡាញ់មេត្រី ស្ម័គ្រស្មោះចិត្តា
រឹងធ្វើចិត្តធំ ពិតំពុំពានា នាំពាក្យចរចា ឲ្យអាក់ចិត្តប្តី ។ សត្រីកិរិយា
មានថ្មាំមួយថ្មា – ការគោចអប្រិយ មួយចិត្តពុំចង់ បំរុងស្វាមី តុំតាម
ចិត្តប្តី យកតែចិត្តឯង ។ មួយខ្ជិលកានការ ខ្ជិលរៀបអាហារ អណ្តាប់
គាក់តែង បើបានចំណី សោតធីតែឯង តុំតិតពុំត្រែង ពុំខុកឲ្យប្តី ។

មួយចុតួចនៃ ចង់ជាធំនៃក្រៃ លើសលែងស្មារម៍ ពោលពាក្យថ្នាំងថ្នាក់
ឲ្យអាក់ចិត្តប្តី មិនមានមេត្រី ចង់ចិត្តស្នេហា ។ មួយចិត្តកំណាច ប្រ-
ច័ណ្ឌកោងកាច ប្រចាំប្តុស្សា បញ្ឆៀសផ្តងប្តី[1] តតបីមេត្តា ប្តូរទេព
ផ្តាសា ពុំគិតបាបកម្ម ។ មួយប្តីមានទុក្ខ មានទោសពុំសុខ សឹងមើល
បំណាំ បើប្តីឈឺថ្លាត់ ដើរបាត់ពុំចាំ ពុំចង់រកថ្នាំ រកតេឲ្យមើលប្តី ។
មួយប្តីប្រជោ សារតើកក់ជ្រៅ កិត្យក្រមច្បាប់ស្រី ចិត្តចោទទ្វឹង
ទៅទឹងស្វាមី ពុំយកពាក្យប្តី ចង់ជាទោសា ។ កិរិយាទាំង៣ នេះគាឡ-
កណ្ណី ចិត្តចោរប្តុស្សា ជាស្រីទូរលីក្ខណ៍ អបាលក្ខណ៍មោហា អស់
អង្គនេះតា បៀនបាកមុខ ។ លុះលែងជាតំពិ កំណើតលោកិយ ធ្លាក់
ទៅនរក ទុក្ខទ្វន់ តេកតាន់ពុំសុខ រងទោសរងទុក្ខ ទៅនាអវីចិ ។
លង់លុះមួយកល្ប ទៀងទើបរួចរាល់ មកកើតជាស្រី ផ្តាមាស្តអបាយ-
ល័ក្ខណ៍ ជាយក្ខិនី កំព្រាតប្តី ច្បាំរយជាតិជាក់ ។ បើស្រីនោះ
បាន ធ្វើបុណ្យឲ្យគាន សឹងតែថ្លស់ធ្លាក់ ទៅនរក ទល់ទុក្ខតតាក់
តតងមានអ្នក ណានឹងច្រៀសច្បាណ ។ ពោះព្រះបញ្ញា : ធិកសាងសង្វា
រិយោញ្ញយញ្ញាណ ត្រៃបត្រាស់ទ្រង់ ស្រោចស្រង់ពុំបាន រហតុ
ស្រីនោះមាន ចិត្តច្បៀសក្រៃជម ។ ភូនអើយចូរចាំ ចូរចេះច្បៀសកម្ម
ច្បៀសកាយអម្បាល នេះនឹងបានសុខ ទៅមុខរៀងកាល់ រៀងរួចទៅដល់

---

๑. ច្បាប់ខ្វះ៣ ម៉ឺនវេះផ្តាប់ប្តី ។

សួគ៌និព្វានពិត ។ ភៃបុត្រពន្ធក ចូរនាងរៀនយក កែត្បូរកែមសុចរិត
អរិយាទាំង ៤ ស្រីសួនចង់ចិត្ត ចាំចេះគន់គិត តាមដោយធម៌ថា ។
ច្បាប់មួយហៅមាតុ – គឺយាជាអាទិ៍ មានចិត្តជ្រុំជ្រា ការកល់មួយមាន
ចិត្តក្សាន្តរក្សា ខុកជាក់ខ្ញាំ ពុំឲ្យបង់ចាត់ ។ មួយចិត្តឈឺឆ្អាល ស្វាមី
គាប់កាល មានទោសទំណាត់ កាលកើតរោគា ជាឈឺថ្ពាត់ ថែទាំ
ប្រយ័ត្ន ប្រយោជន៍រក្សា ។ មួយចេះបំរើ រណ្តាប់សារពើ ឥស្តុ
រោជនា បើបានអាហារ ត្រកាលតុជា ពុំឃ្លានគោក្តា ខុកឲ្យស្វាមី ។
មួយរកបស់ អម្រែអម្រស់ អម្រែងឲ្យប្តី តាក់តែងជួញប្រៃ ធ្វើស្រែរក
ធ៌ ធ្វើការប្រកបី ចិញ្ចឹមអាត្ម ។ មួយចេះសង្ឃឹត រាប់អានសាច់ញាតិ
រៀមច្បងមេថា បើបានឥស្តការ អាហារពិសា ចែកជូនត្រៃបត្ន មិន
មានកំណាញ់ ។ នានាមកគិន៍ – គឺយាល័ក្ខណ៍ស្រី ៤ប្រការមិញ
មួយចេះចាំចិត្ត គន់គិតស្រឡាញ់ ស្វាមីអស់អញ ដូចបងអាត្ម ។
មួយមានអំណត់ អំណរអាចអត់ ចិត្តចាំស្នេហា មែនមានមេត្រី ឥតប៉ី
ក្រែជា ទាសីទាសា ពុំចង់ទោសទុក្ខ ។ មួយមានសីលវត្ត បំរើ
ប្រណិប័តន៍ ស្វាមីជាសុខ មិនមានខឹងខាន ប្រច័ណ្ឌញុកញ៉ុក អាចឲ្យ
ស្រណុក ចិត្តប្តីសព្វថ្ងៃ ។ មួយមានមារយាទ ការក្តើរអង្គអាត្ម មាន
ភ្នាសប្រពៃ បើឃើលបុរស ជ្រាលប្រុសជាខៃ មិនមានមួលមៃ - ត្រឹ
ត្រែតស្រើបស្រាល ។ នានាមាមិត្ត - គឺយាសុចរិត មាន ៧ ប្រការ

មួយមិនប្រទុស្ត រង៉ែរួសបណ្តាល រកហេតុរង្កាល ឲ្យអាក់ចិត្តប្តី ។ មួយមានគំនិត គំនាប់ស្នេហ៍ស្និទ្ធ ស្នេហ៍ស្មោលមេត្រី ស្រឡាញ់ស្មោះស្ម័គ្រ ពាក់ពាក់ន័ធប្តី ដូចយល់មិត្តពី ចំងាយមកដល់ ។ មួយមានអនុកូល ផ្តេកផ្តិតមិត្រមូល ជាសុខសាន្តសល់ នៃបនិត្យស្វាមី តតបីមានកល មានកើតអំពល់ អំពីអ្វី ។ រីឯសកិយា មានលក្ខណ៍បីប្រការ - ការគួរជាស្រី មួយមានពាក្យស្មោះ ពិពេះស្រដី ផ្ញើខ្លួនលើប្តី ឲ្យប្តីអាណិត ។ មួយបើស្វាមី ស្រឡាញ់អស់ស្រីបពែរក្រមក្រែត្យ ចេះជួយស្រឡាញ់ បំពេញតាមចិត្ត តាមដោយគំនិត ស្វាមីស្ម័គ្រស្មោះ ។ មួយបើស្វាមី ទេវីធ៌ស្រដី រំលើកបោកបោះ ផេះពោលប៉ុន្មាន ពុំហានធ្វើយឈ្លោះ សារសង៌ទ្រគោះ តតបវាចា ។ ច្បាប់ស្រីទាំងបួន ចំពូកចូរសួន រៀនរិះក្បាំ ក្នុងលោកិយ តាប់ គំនាប់ថ្លៃថ្លា តតគេនិន្ទា ដៀលដល់មកម្តាយ ។ អស់អង្គទេព្តក្ស្ត្រ មហេសីស័ក្តិ ទេវតាទាំងឡាយ ជ្រោមជ្រែងឲ្យពរ បវរពណ្ណភយ សួស្តីសុខសប្បាយ យសសក្តាក្តាត់ ។ លុះលែងជាតិបាន សោយសុខពិមាន ពិភពតុសិត សិក្តីសម្ផ្ទី សិរីវិបុល វិវេធមានបិត ច្បាំងច្បាសាទេសួគ៌ ។ សុទ្ធសឹងកែវកើត សម្រាប់តែធើត ត្រៃលើសាំងស្រួល ស្រីទេពកញ្ញា រៀបគ្នាជាជួរ គង់គាល់គាប់គួរ ក្រាស់ក្រៃត្រៃបត្រា ។ លុះអស់កំណាត់ សួគ៌សោតប្បត្ត មកកើតទៅនា

ត្រកូលក្សត្រក្សាន្ត មែនមានច្រើនជា ល្អដូចទេវតា ជាស្រីត្រៃលក្ខណ៍ ។ ទើបបានជាមហា - មហេសីក្សត្រា បរមចមមចក្រ — ពត្រាធិរាជ អំណាចឯកអគ្គ ឯកឯង់ទីអ្នក — ណាទើងផ្ចឹមបាន ។ ទោះបីជាថ្នា ទឹកទើងចង់ជាកនៃព្រះញាណ សឹងបានដូចចិត្ត គន់គិតរិះធ្យាន ហេតុស្រីនោះមានមារយាទគួរគាប់ ។ ស្ងួនសង្ឃារសាច់ កុំភ្លាំងភ្លាត់ភ្លេច ចូរចេះចាំចាប់រួសរាកវៀនរិះ ត្រែកត្រិះត្រង់ត្រាប់ ធម៌នេះជាច្បាប់ ប្រៃសើរឯកស្រី ។

ពីរព្រះរាជបុត្រ ពាសេសលំទត អង្គនុនសិរសី ទទួលបណ្តាំ ចង់ចាំពាក្យពី ព្រះវរជននី ជនកទូន្មាន ។ សេចគ្រែចគ្រាន់គ្រប់ អរនុនអង្គអ—គិរាទក្សត្រក្សាន្ត លុតលាៈចញ្ជៅ ដល់ក្រៅវាំងបាន ឡើងគង់រាជយាន មាសមៃយលំយង់ ។ មន្ត្រីសេនា សេនីយោធា រៀបរៀងរាយរង់ តួរ្យតន្ត្រីត្រៃ ផ្ទំហែព្រះអង្គ យាត្រាត្រេចត្រង់ ដល់ឆ្នេរជលសា ។ ចុះចាកយានយាង ព្រះចុងនាំនាង ឡើងលើកេត្រា អស់មុខមន្ត្រីសេនីសេនា ប្រជាប់ប្រជា ប្រុងប្រៃបរិស្រេចស្រាប់ ។

ចម្រៀងឆ្លៀលា

រាជាចេស្តាគួរគាប់ បន្ទូលច្រាមច្រាប់ អស់អង្គយោធា ។ គោះគង ស្គរផងមហិមា ស្រែចស្រាវយុទ្ធា ហើយហូតស្ទាបក្តោង ។ ព្រះពាយ ធ្យូផ្សាយយោលយោង រលកសំពោង សំពៅលឿនលង់ ។ កេត្រាសេនាមុខម-ន្ត្រីត្រៃបរពកពន់ បើកហែក្សត្រៃថ្ម ។ ដល់ទៅជម្រៅ

ជ្រលស័យ សុខសប្បាយក្រៃ មិនមានភ័យតិត ។ ស្តេចច្តើងរុងរឿងរឹងរ៉ឹង
នានានាជវនៃបនិត្យ តង់តន់មច្ចា ។ ត្រឹស្តង់យង់ក្រៃកាឡា ឆ្លាមឆ្មាំរាជ
រ — ហ៊ឺហក់ហៃហៃហែល ។ ល្មេះល្មិចគល់ត្រែចបហែល កុម្ភកុម្ភេល មង្គរ
ពិន្ធូង ។ ត្រីខ្លាបង្កាបង្កង កន្ត្រៃបក់កន្ត្រែង មិងត្រួលក្រុសក្រាញ់ ។ ឃ្មុក
ក្សកកញ្ជ្រែកកញ្ជ្រាញ់ — ចាស់ច្រលឹងលេញ កញ្ជាក់ស្ងាស្ងាត ។ ច្រកែង
អណ្តែងអណ្តាត - ឆ្កែឆ្មោកក្ងាំងហាត ក្ងាំងហាយគុជា ។ ប្ងាជប្ងាមុប្ងាម"
កែសកែប្ងាក់ប្ងា កន្ទុះកន្ទាយ ។ ផ្សោតច្រកែតតសណ្តាយ ឆ្មោ
សំពោប្ងាយ អណ្តើកត្រៃសៃ ។ ធុះផែលអង្កែលអង្កៃ ហែបហែល
ច្រៀវច្រៃ វេរកោក្តា ។ ក្សត្រៃច្រៃបៃពត្តលា ស្តេចទតមច្ចា
ក្រសាលសុខសាន្ត ។ កេត្រាសេនាទាហាន បើកហែក្សត្រក្សាន្ត
លឿនលន់ផ្ងេកផ្ងោះ ។ ទៅដល់មណ្ឌលទៀបកោះ ស្តេចឲ្យបៀតប្ងោះ
យុថ្ងាន់ត្យទៅ ។ ចុះថ្ងាន់សំប៉ាន់មាសផ្តៅ លីលាខ្ទៀងទៅ ប្រតាតលើ
ខ្ញាច់ ។ ស្រីង្កាបរិពារហែស្តេច យាងយាត្រាត្រេច ដោយផ្នែរជល-
សា ។ ខ្ញាច់សណ្តែរណ្តែរសោភា មានមនច្ឆសិលា អណ្តាតសមុទ្រ ។
មានកាំពាហាសសុទ្ធ ច្រាលភ្នៅប្ងាកជ ដុះខ្ទៀងច្រាងច្រង ។ ភ្នៅគ្រំដ
រុំក្តាមត្រោង ក្តាមសេះខ្យងហោង ខ្យងហៀនខ្យងសំង្ខ ។ ផ្ងាវត្រែង
ចាក់ច្រែងច្រលាំង - កាសកៀវញីតាំង គូគៀងរកធី ។ ព្រះមហា-
ក្សត្រាធិបតី នាំព្រះប្ងូនស្រី មុខមន្ត្រីបរ ។ ជាសដេរដោយឆ្នេរសោត

ស្រើបស្រួលអឺងអរ ក្សេមក្សាន្តចំណ្តា ។ លុះដោរដំនោរដលសា ស្តេច
យាងយាត្រា ប្រពាតលើកោះ ។ ត្រីក្សាសាខារចោះ របបចខ្នោះ
ដុះដោយពណ៌ាវ ។ តែរគោជ្ជដោតត្រីស្ពា ក្ងាំពូក្ងាំពា ក្ងាំពាក់ដីប្ល ។
ម្ហូរបញ្ចូកាណ៌ ទូរទួនពីសី ចំនួនសចំនួនច្រាល ។ ខ្នែងខ្ចាស់ច្រមុះសោម
សារ-គុណអន្ទេរឃ្លាល តប្បាលដែកលូតលាស់ ។ ត្រៀកត្រសំចិត្ត-
បុស្សសហស្ស គុណគុយរាជការ លំពូស្មេចស្មែរ ។ សន្ធារទន្សាទន្សែ
អង្គត់អង្កែ ដែកដំរដងដំង ។ ច្រឹសច្រួយគោមួយឆ្នង់ច្នឹង ព្រួសព្រះខ្ទ-
ហឹង ព្រះកំចាត់ដើមចារ ។ ទូរនេមនមៀនមន្ទារ – បុស្សបឹងកុមារ-
ពេជ្រពៃសន្ធែត ។ ស្ងួលស្នាយទំលាយរាក់រោត រាំងរៃម៉ែកជោក ម៉ែក-
ប្រែងម៉ែកច្បាង ។ ឈើជាសំពាកោងកាង លៀតលៀតលាំងលាំង-
សាគសាចតួចគោន ។ ឆាំឆាស្ងែងស្ងាបត្រែកោន ស្ងាស្ងាបលាំគោន
ល្ងង់ល្ងត់សេដា ។ ត្រែសាំងខ្ទះណាំងច្បាយស្រាំ ស្ងាត់ស្ងាយរំពា ស្ងាយ
ក្បាលដំរ ។ ផ្ទៃផ្ការលាំពុំខ្ចី សេនាមន្ត្រី បេះបានច្បាត់ប្លាយ ។ ត្រីរ-
អង្គពីរពាន្យពណ្ណរាយ សោយធលសប្បាយ ស្រែចស្តេចលីលា ។
រឹងប្លានពិមានក្សត្រា ស្រែចស្រាវយុច្ចា ហើយហួតក្តោងទៅ ។ ត្រែច
ត្រែងដម្រងដម្រៅ រាងជ្រោយសំដៅ កណ្តាលដលសាន ។ ខ្សល់
យោងត្រូវក្តោងបែកប្លាន ដល់ក្រែងពារ-ណាសីនគរ ។ ពលធំអឺងកង
ត្រែកអរ សោមនស្សសាទរ ដាក់ក្តោងម្ខាង ។ ស្រើបស្រុះប្លានចោះយុច្ចា

ស្រែចហើយច្រក់ គោះគង់ទូងស្គរ ។ ព្រះមហាក្សត្រាភូធរ
អាំនាងចេញចរ ចុះចាកកេត្រា ។ គង់យានមាសមានសេនា សេនីយោធា
បើកចាំងភ្លឺសក្ដម ។ ត្រែសង្ខ៍ពីរពាំងច្រគំ ហែក្សត្រចត្តម ឡើងគង់
ប្លាសាទ ។ មន្ត្រីសេដ្ឋីអមាត្យ ខុនណាងបត់បាទ បុស្ស៍ចង្កឹគាល់ ។
ស្រីង្កាបពិតាវច្រាសច្រាល់ ចំរើរៀងពាល់ សព្វទិនទិវា ។

បទភាពគតិ

ស្តេចសោយរាជ្យស្តាល់ គ្រងបរិពារពល ពស្តុភរដង្ហា តតក័យ
តតទុក្ខ សុស្តីសុខសាន្តសា — ប្បាយបរមមហា — ក្សត្រក្សាន្តទ្រង់
ធម៌ ។ សាង៍សង់ច្រដាប់ សាលាធនាប់ ល្អល្អះពីព័ណ៌ ជាក់
ព្រះរាជទាន ធនធានសព្វសារ — ពើពុំខ្វើសទាល់ ព្រួយព្រះចិត្តា ។
ស្តេចរៀបអាហារ ចំណីភ័ស្តុការ ជាយទឹកម្ហូបស្វា ក្រចេះចួងច័ន្ទន៍
សុគន្ធមាលា មាសច្រាក់តនោ ករកង៍ចិញ្ចៀន ។ កន្ទេលចៀមចំ
ឡៃខ្នើយព្រៃព្រំ សំពត់អាវខៀន មុង៍មានពានស្តក ទៀនតោក
ធ្លឹលសៀន ចានចន្ទុះទៀន ជាក់ទានសព្វថ្ងៃ ។ ស្តេចទ្រង់សង្ឃ
ឲ្យទានទ្រព្យា អនេកច្រើនរៃ រណ្តាប់ចាយចេញ គិតកាញ់ដំឡៃ
មាសន៍មួយថ្ងៃ បីសែនតម្លឹង ។ អស់មនុស្សកំសត់ កំសោយទូគ្គត
ត្រេកអរអើង៍អឹង ខ្លួយខ្លែគមគាក់ ខ្ញិនខ្ញាក់ចំប្រឹង ដើរមកច្រហឹង
ទ្វល្លភជាន ។ ក្រជ្រួរក្រឆ័យ ក្រដែង៍កំព្រយ កំព្រាកូរត់មាន

ពីស្រុកស្រែគ្រៅ លំនៅខ្ទមហាន ចូលមកយកទាន សព្វទិនទិវា ។
ក្នុងស្តេចជាជន សឹងសុខដោយបុណ្យ ជាវេជ្ជមហា – ក្សត្រខ្ពង់
ខ្ពស់ពិត សុចរិតធម្ម អ្នកឱ្យតែប្រែជា មានមិនហោចហិន ។
ក្សត្រថ្លៃវរលំអូណ៌ វរលោកចមចក្រ ចមរៈចាំភូមិ - ន្ទរធិរាជ សព្វារីរ-
យ៉ិ – ន្ទិយខ្ពង់បញ្ចិន្ទិយ បញ្ជាពលំ ។ ត្រែកខ្ពង់សីលជ្រាំ
អស្តង្គសីលចាំ ពុំភ្លាត់ភ្លេចភ្លាំង ខ្ជូនានមន្ត្រី ប្រុសស្រីកន្ត្រកាំង
នគរឱ្យតាំង រក្សាសីលធម៌ ។ ស្តេចខ្ជូនានថា ហៃអស់គ្រប់គ្នា គួរ
គិតគួរស្តាប់ គិតកាន់សីលជ្រាំ ចង់ចាំរៀងរាល់ ចៀសចាកកម្មការ
បំផ្លាត់ជ្រាបបង់ ។ ជ្រាណាគិជ្ឈាត អ្នកណានេសាទ ចិត្តចោរហេតុចង់
ពិឃាដម្រឹគា មច្ឆានូវអង្គ មនុស្សសត្វឱ្យបង់ ឱ្យជ្រាត់ជន្មា ។ អ្នក
នោះនឹងទៅ រងជ្រាបក្តាត់ក្តៅ លំជ្រាកនៅនា សញ្ជីពនរក ទល់ខ្ទុក
ឈឺផ្សា ខ្ជូនខ្ជួរ រូបរងយូរក្រៃ ។ យមភ្ជូបាលបោះទៅ កន្ធក្តើង
នោះជ្រៅ ធ្លុះធេះក្បាលក្បាយ ហើយរស់រូបរឹង ពុំដឹងតិតព័យ រាវិល
មកឮ ដល់មាត់រណ្តៅ ។ យមភ្ជូបាលមក៍ ចោមចាក់ទឹងស្ន មូល
ប្បាកដែកក្តៅ ចាក់ទឹងលំពែង សឹកសែងចោលទៅ កន្ធទីរណ្តៅ
ក្តើងភ្លឺពុំក្បាច្ច ។ កំណត់ជន្មា នរកនោះហា – រយឆ្នាំប្រមាណ តន់
តិតនាឆ្នាំ ត្រូវច្រាំបួនលាន មនុស្សនេះទើបបាន មួយថ្ងៃនរក ។
លង់លុះដោះ ពីនរកនោះ មកមិនដែលសុខ កើតជាមច្ឆា

មានតាជ្រកស្រុក គេកាប់សាច់លក់ ចិញ្ចឹមយ៉ាងជាតិជាក់ ។ ទៀងទើប-
កើតជា មនុស្សមានទោសា គេចាញ់គេចាក់ គេដោតគេកាប់
សម្លាប់តគ្គាក់ ចិញ្ចឹមយ៉ាងជាតិជាក់ ពិតពុំសុខអង្គ ។ ទើបយកជាតិ
ជា មនុស្សមានកោន ដំណៅពកឃ្លង់ ជាមនុស្សគមគាក់ ក្អែកខ្វាក់
ខ្វិនខ្វង់ ដៃជើងកែងកង់ ក្រកិតអប្រិយ ។ បើបានសំគុំបុណ្យ ដូចគ
ផលពីមុន ចានសាងមកក្តី ពៀរកម្មអាត្មា ឲ្យអាយុខ្លី ពុំយឺនជីវ
ជីវិតដល់ចាស់ ។ ខោះឆក់ឆ្កួសឆ្កើ កាយកម្មចាបបើ ចោះបង់ក្រឡាស់
ក្រឡាច់លែងលះ ប្រែប្រាសរហ័ស ដឹងដោយធម្មិច្ឆាស់ គន់គិតយល់
យល់ ។ ខ្លាចចាបខ្លាសចាប ចៀសចាកដកាប ជីវិតសត្វសល់ ពិតពុំ
តាជា រក្សាដំកល់ ចិត្តចាំសីលធល ចាណាតិចាត ។ ចានទៅកើតនា
សុគតិចាតុម្មហា – រាជិកាជាតិ ជាអង្គទេវបុត្រ បរិសុទ្ធស្អាងស្អាត បិត
លើប្រាសាទ ចុំពីរយោជន៍គត់ ។ ស្រីទេពកញ្ញា ចុំរយអង្គា
បម្រើបានបទ បុស្សបង្គំគាល់ រៀងរាល់ប្រាកដ ប្រកបកំណាត់
កំណាន់សព្វថ្ងៃ ។ ចុំរយៈឆ្នាំគត់ ចិព្វទើបប្រុត មកកើតនៅព្ញ
ត្រកូលក្សត្រក្សាន្តសន្តានថ្លាថ្លៃ រាងរូបល្អថ្លៃ មានលក្ខិណាក្លាត់ ។
មានកំឡាំងលន់ មានចិត្តខោះខន់ ប្រណីទុក្ខសត្វ មានកូនមាន
ចៅ ញាតិផៅពុំព្រាត់ ពុំប្រាសខ្លាត់ក្លាត់ ជាសុខដល់ចាស់ ។

(មានត)

លោក រ៉ាយ - ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀងដោយ ក្បាកញ្ញ

កាលខ្ញុំឃើញប្រាសាទអង្គរ　　កង់ចិត្តសញ្ជរទៅតាមស្នុគ

ព្រឹព្រួចកោតស្ងែងដល់ជាង់ធ្លាក់　　រិស្សកម្មថាក់ខែរបុរាណ ។

នឹកដល់សម័យព្រះក្សត្រា　　យសោវរ័ន្ធជាស្តេចចំណាន

ស៊ីវិល្ហៃថ្កុំថ្កើងស្អាងវិមាន　　កង់ចិត្តស្នានស្នានទេពូនិករ ។

សម័យរាជ្យព្រះកេតុមាលា　　ខ្មែរកម្ពុជាមហានគរ

ច្រៃទេសធំទូលាយទ្រង់ទ្រាយល្អ　　ល្បីល្បាញបវរកង់ទូទ្បា ។

មហាអំណាចអំណាយផល　　កពភូមិសកលខ្ចាចចេស្តា

អាណាចក្រចាំងចែងអស្ចារ្យ　　នឹកឡើងហាសនាចិត្តរីករាយ ។

មាតុភូមិរុងរឿងពលរដ្ឋថ្កៃ　　មនុស្សល្អប្រពៃចិត្តសប្បាយ

គ្រឹះស្ថានមានរបៀបដ៏ស្រស់ស្រាយ　　មើផ្លូវចៅហ្វាយមានកិត្តិសព្ទ ។

ឃើញនិម្មិតជនត្រេចត្រសង　　សួរធ្វើយពាក្យឆ្លងគ្នាច្បាស់ព្ទ

មនុស្សណែនណាន់តាំងថ្លៃយប់　　យល់គ្រប់តាមភាពបែបកង់កាយ ។

ឃើញមានផ្សារហាងលក់ទំនិញ　　ឃើញទិញអីវ៉ាន់ទៅស្រុកឆ្ងាយ

ឃើញអាន្ទុកាតស្រុកក្រៅផ្សាយ　　ទុត្តមពណ្ណរាយកង់លោកា ។

ឃើញមហាក្សត្រប្តូខ្ញុំជោគជ័យ ឃើញព្រះមហេសីល្បីនាមា
បុត្រាបុត្រីស្តុកស្តឹងការ ... មន្ត្រីពលការចតុស្តម្ភ ។
មានទ័ពដើរដីទឹកគោកពាសពេញ ពួកព្រាហ្មណ៍ចូលចេញសាសនាព្រហ្ម
តស៊ូនាគយណ៍មូលជួបជុំ អង្គរកុះកុំបុណ្យកឋកិច្ច ។
អង្គរធំជាកំដរមហាពល មានសិទ្ធិអំណាចលើជនស្រែច
ព្រះអង្គប្រសើរចមកតជាច់ ប្រទេសចរត្រែចជាឆ្នើមឯក ។
មានច្បារទ្យានបោក្ខរណី ព្រះរាជបុត្រីគ្រែសាលត្រែក
វិមានអាកាសល្អស្អិតប្លែក ចូលសេកសេពសមក្នុងតន្ត្រី ។
ក្នុងមហោរីរចុំច្រៀង រូបដើរមានពងល្អពិសី
មានល្ខោនកំច្រៀងចរចាស្តី ភាពស្អាតប្រមប្រិយស្រួលសប្បាយ ។
សម្បត្តិសំបើមសំបូណ៌បុណ្យ គ្រងរាជ្យព្រះគុណខ្ពស់ឆើតឆាយ
មិនមានទុក្ខភ័យបៀតព្រះកាយ សេនាប្រជុំប្រាយគាល់ហ្វូងគាប់ ។
គួរឲ្យស្រប់ស្រែងខ្នែរបុរាណ សាងប្រាសាទប្រាន់គួរចិត្តចាប់
ក្បាច់ក្បូរជាងគួរចេះចំណាប់ ចំណាំចុចជាប់កងទ័យ ។
គួរឲ្យសង្វេគស្តុតស្តងចិត្ត កោតក្រែងគំនិតនឹងប្រាជ្ញ
ខ្នែរសាងប្រាសាទកងរង្គា ទុកនាមធាយាឲ្យកូនចៅ ។
គួរយកមតិខ្នែរបុរាណ មហាអំណាចប្រាំស្តានគ្រប់ជោ
ថ្ងៃខ្នែរបច្ចុប្បន្នឲ្យឈប់ជ្រោ ចំពោះជាតិនៅជាប់នឹងខ្លួន ។

មតិខ្មែរប្រែតាមសម័យ បណ្ឌិតជ្ញាជ្ញវៃតាមកាលដួន
កំត្តីរកស្រអាប់បុណ្យជ្ញាបខ្លួន បុប្ផាច្បារសួនរីកដោយវៃ ។
ត្រូវយកអង្គរអារម្មណ៍ជាតិ ព្រះពុទ្ធសាសនាខ្មែរ
មហាអំណាចជ្ញាជ្ញត្រូវកែ ប្រឹងជ្ញាណទំបែរកេចម្រើន ។
ប្រុសស្រីកុំក្លេចត្រយ៉ងសរណា ទេសជាតិសាស្នាត្រូវបង្កើន
ការនាញឹកញាយចាំត្រូវរើន ការនាឲ្យច្រើនទើបផុតលិច ។
បើតារាជាតិខ្វាក់ដល់ដី បញ្ចេញផ្កាយច្នៃទំចរត្រែច
បើគេហដ្ឋានរលំស្រែច ត្រូវប្រែកបកិច្ចរើឆ្នើមស្អាត ។
កុំនិទ្រាចាំត្រែងវាស្មា រុក្ខាមិនដាំម្តេចផ្លែខ្ចាត
មិនទំស្លឹងដកចង់ស្មាន់ជាតិ មិនប្រឹងសង្វាតរៀនចង់បេះ ។
សាមគ្គីក្លាហានស្មាន់ជាតិ ស្រោចទឹកឧត្តមឈើច្បានបេះ
ផ្លែផាសភាពជូរចិត្តនេះ យល់មេឃស្រឡះជាតិស្មាន់សម ។
គួរឲ្យស្រណោះអតីតា អង្គរខេមរាស្ងាត់ជ្រងំ
បើឃើញចិត្តតែងខ្សូរគម ព្រោះឈើវល្លិ៍រីតរួតរឹង ។
ឥតត្រាប្រណីក្បាច់រចនា ចារឹកសិលាដោយកំហឹង
គំនុំរុកគួនពាល់ត័ទ្ធតឹង កំព្រាគ្មានពឹងអញ្ជើញ ។
ជាត់ព្រះមហាក្សត្រឫទ្ធិអង់អាច រិស្វកម្ម្រជ្ញាជ្ញបណ្ឌិតា
សូន្យមហេសីទត្តិយា មន្ត្រីស្រង្គារលាយជ្ញាត់ ។

កង់ពលយោធារលាយអស់ ចាកលោកសូន្យស្មោះជាតំរិប៉ត្តិ
រីរបុគ្គលសប្បុរសខ្ចាត់ កម្មបក់ផាយផាត់ចាកសីមា ។
ចាត់ស៊ីវិឡៃខ្មែរបុរាណ នៅតែទិព្វស្ថានច្នូសិលា
ជាកេរ្តិ៍មតិកបច្ចុប្បន្នា ស្ថាដៃអស្ចារ្យជីតាយើង ។
ម្តេចខ្លៃយមកនៅតែតំណែល សុរិយាជដែលខ្មែរចុះឡើង
ស៊ីវិឡៃចាត់កើតច្បើនច្រើង ឆេះរលត់ក្លើងសង្ខារសេតូ ។
បុណ្យទ្រព្យស៊ីវិឡៃនាលោកា ប្រែប្រួលធម្មតាតែងភ្ញាំងភ្ញាត់
ដូចចន្ទ្រវិលឡើតរនោចឆាត់ ភាណាវង្សអស្តង្គតរលិច ។
កង់លោកវិលចុះឡើងទៀត បុណ្យឆាបភាពវង់តាមកិច្ច
និស្ស័យគោកធ្លុកប៉ះដំណាច់ ចុះត្រែចខន់ធាបអាប់ពាសី ។
បើប្រទេសបយគ្មានតេជា គ្មានបុទ្ធិពលាអន់រស្មី
កូនចៅកុំដេកចាំសួស្តី ឧឹកកពដីព្យាយាមកុំក្លេច ។
បើយើងខំប្រឹងទាំងអស់គ្នា ដោយក្តីហានក្លាខំចរត្រែច
ធ្វើហើយធ្វើទៀតគង់សម្រេច សោភ័ណផលកិច្ចតាមគួរការ ។
ខំជួសជុលគឺះស្ថានខ្មែរជាតិ សង្ឃាតនុហាតទាន់វេលា
ឈើគ្រញូងបេងទ្វូសម្ភារ សង់ដែនភាពជាតិឧឹកដី ។
កូនចៅខាងក្រៃយខំរៀនសូត្រ កុំលោតលង់លិចផុតសេរី
ប្បាប់ធម្មជាតិសន្សឹមតិច ។ ក្តី តក់ ។ ចាស់ថ្នឹពេញបំពង់ ។

ធ្វើការតាមកាលឲ្យយល់កល កុំធ្វើហួសផលហេតុភ័យលង់
សម័យស្អាងជាតិតាមច្បាប់កង់ កបកែតម្រង់តម្រូវភាព ។
គួរស្ងៀមឬពោលឈប់ចង្អង់ គួរចង់ឬខានមិនខូចលាភ
គួរហ៊ានឬខ្លាចយល់ច្រៃសាប ដូចឃ្លោងឃ្លាកាព្យសោតតីពេះ ។
បើនឹងរាំច្រៀងត្រូវភ្លេងសព្ទ បើត្រែចតាមច្បាប់មាត្រាស្មោះ
ស្ងៀកពាក់ឲ្យសមសួនសក្តិយស បើនឹងសាចព្រោះឲ្យដើរសព្វដ ។

ចប់តែប៉ុណ្ណេះ

សុភាសិត

ជំបូលផ្ទះឆ្ងាយជាងជំបូលផ្សារ,
គូថភរិយាជិតជាងផ្ទម្ភាយឪពុក ។
សួរស្តាយបាន ប្រសើរជាងស្តាយបង់.
សួរខ្លួចអង្គ ប្រសើរជាងអាប់ក្តៅឈ្មោះ ។

ឃ. អ.

អ្នកឧកញ៉ាវិបុលរាជសេនា នួ - កន ប្រែរៀបរៀង

(ត្រមក)

វគ្គទី ៥

តាំងអំពីគួនអ៊ូចេញទៅតយុទ្ធកាត់យកក្បាលហួយឯបាន រហូតដល់កាត់ស៊ុខបាន គឺត
លើកទ័ពទៅវាយយកស្រុកតីដែរ

ពេលនោះចៅហ្វាយខែត្រទាំងអស់ដែលនៅក្នុងបន្ទាយ លុះបានឮសូរសំឡេងគង់ស្គរដ៏សន្ធឹកអឺងអាប់ ក៏ប្រញាប់ប្រមូលគ្នាចេញទៅមើលគួនអ៊ូតបង្កាំងនឹងហួយង៉ គាលបើបានចេញទៅដល់មាត់ទ្វារបន្ទាយ ស្រាប់តែឃើញគួនអ៊ូយកក្បាលហួយង៉ ត្រឡប់មកបោះទុកនៅមាត់ទ្វារនោះ, នាយទ័ពនាយកង៉ទាំងពួងត្រេកអរសប្បាយរីករាយទាំងអស់គ្នា ហើយមីមានាំគួនអ៊ូចូលទៅគំនាប់អួនសៀវ ។ ចូគួបានលើកពែងស្រាចេញមកគុំនាប់គួនអ៊ូ ។ ទទួលហើយគំនាប់តប ទើបលើកពែងស្រាឡើងទទួលទាន ស្រានោះក៏នៅក្តៅៗ ។

ឯតៀវហ៊ុយក៏ចូលទៅគំនាប់នាយទ័ពនាយកង៉ហើយដំណរបាថា គួនអ៊ូបង្វិចុះបានចេញទៅយកអាសា កាត់ក្បាលហួយង៉មកជូនហើយ, ខ្ញុំបាទសូមយកអាសាវ៉ាយទំលាយកង៉ទ័ពចូលទៅក្នុងស្រុកក្រង កាត់យកក្បាលតាំងតុមកជូនអស់លោកទៀត ។ អួនស៊ីតឮដូច្នោះខឹងណាស់ស្រែកគំរាមហើយថា បំណាងនាយទ័ពនាយកង៉ទាំងពួង គេមិនទាន់យល់

ឃើញប្រការម្តេច ស្រែចអ្វីលើខ្លួនមកគួននិយាយកាត់មុខអ្នកដទៃថាសុំ
អាសាខ្មែត ខ្លួនជាមនុស្សអាក្រក់ណាស់, ថាហើយក៏ឲ្យបណ្តេញ
តៀវហ៊ុយចេញអំពីទីជំនុំ ។

ចូរូច្នើយថា ធម្មតាខំនៀមធ្វើសឹកសង្គ្រាម, បើអ្នកឯណាធ្វើ
សេចក្តីគាប់ប្រសើរក្នុងការសង្គ្រាម លោកតែងឲ្យតុរង្វាន់តាមគុណ
បំណាច់យ៉ាងសមគួរ, បើអ្នកឯណាធ្វើការខុស លោកឲ្យចុះទោស
យ៉ាងសាហ៊ស, ដែលនឹងមកខឹងតិះដៀលដោយកាន់តស្បែរយយស
ចំពោះទីប្រជុំនោះមិនសមគួរទេ ។ អ្នកស៊ីតបថា បើកប់គានថាហាន
ឲ្យដាឯកដូច្នេះ, យើងក៏នឹងមិនចូលចិត្តគិតធ្វើការជាមួយគ្នាតទៅខ្មែត
ឲ្យឃ ទឹងលើតទាហានលែទៅស្រុកវិញ ។ ចូរូតបថា គ្រាន់តែ
និយាយរំលឹកគ្នាជាសេចក្តីបន្តិចបន្តួចប៉ុណ្ណោះ បែរជាចង់លះបង់ការធំ
ចោលនោះមិនគួរសោះ, ថាតែប៉ុណ្ណោះក៏ឲ្យកងស៊ុនថាននាំ ឲ្យវ៉ាពី, គួនអ៊ូ,
តៀវហ៊ុយ ត្រឡប់ទៅកាន់ទីលំនៅវៀងខ្លួន ឯចូរូឯងក៏ឲ្យនាំយកមាន់ទា
ជ្រូកលបទៅឲ្យឲ្យវ៉ាពី, គួនអ៊ូ, តៀវហ៊ុយ ។

បណ្តាទាហានហួយុងដែលសេសសល់ពីស្លាប់នោះ ក៏នាំគ្នាត្រឡប់
ចូលទៅក្នុងបន្ទាយគីស៊ុយកួនវិញ ហើយឲ្យចំរើនាំសំបុត្របកចូលទៅដំ-
រាបសួរលីសុក ។ បកសំបុត្រចូលទៅដល់តាំងតុ: ។ ដឹងសេចក្តីក៏កំរើយថាម្ត
ណាស់ ទើបប្រឹក្សានឹងលីយូ, លីយ៉ោ ថា ឥឡូវនេះហួយុងស្លាប់ហើយ
តើយើងនឹងគិតធ្វើដូចម្តេច? ។ លីយូឆ្លើយថា ហួយុងជាតាំហានឯក

ស្ងាប់អសារដូច្នេះ លើសពីនាហានឡៃស្ងាប់មួយម៉ឺនក៏មិនឆួន, ឯក្នុង
កងទ័ពដែលលើកមកធ្វើការគ្រានេះ ខ្ញុំបានដឹងថា អ្នកស្រែវាមេទ័ពធំ
តូចវានេះអ្នកឆ្មុយជាមាអ្នកស្រែវានាហ្នឹងនៅក្រុងនេះ គង់តែបានគិតដឹងគំនិត
គ្នាទៅវិញទៅមកជាកលសឹកពុំខាន សូមឲ្យលោកគិតអានចាប់អ្នកឆ្មុយ
សម្លាប់ចេញចុះ ។ តាំងតុ:ឮដូច្នោះក៏ត្រេកចិត្ត ទើបបង្គាប់លីឈុយ,
គុយតឺ ឲ្យនាំនាហានជាំម៉ឺន ទៅចាប់អ្នកឆ្មុយនឹងបក្ខពួកស្រែប្រសាំង
អស់សម្លាប់ចេញ ហើយឲ្យកាត់យកក្បាលអ្នកឆ្មុយទៅជោតផ្តាលនៅមុខ
បន្ទាយ តែស៊ុយគួន ដើម្បីឲ្យអ្នកស្រែវាជាកុយក្រឡេកឃើញ ហើយឲ្យ
លីឈុយ នាំពលជាំម៉ឺនតាំងទប់ឲ្យខ្ជាប់ខ្ជួនកុំឲ្យបន្ទាយតែស៊ុយគួនអន្តរាយ
បាន ។ លីឈុយ, គុយតឺក៏នាំនាហានតាំងជាំម៉ឺនទៅធ្វើតាមតាំងតុ:
បង្គាប់គ្រប់ប្រការ ។

ឯតាំងតុ:ឧទ្ធលីយូ, លីហ៊ុ", ហួនតៀវ, តៀវធេ កំឃុំនាំនាហាន ១៥
ម៉ឺនលើកទៅកក្បាតយហៅលោកួន ជាប់ព្រំនឹងស្រុកក្រុងឡុកអៀង ផ្លូវ
ចម្ងាយប្រមាណ ៥០០ សិន (២០០ គីឡូម៉ែត្រ) ហើយតាំងតុ:ឲ្យលីហ៊ុ"
នាំនាហាន ៣ ម៉ឺន ចេញទៅតាំងបន្ទាយធំត្រៃកំពែងគយ ។

សេះបំរើដឹងការណ៍ ក៏យកសេចក្តីទៅដំរាបអ្នកស្រែ។ ប្រឹក្សា
ឧទ្ធលីយហ្វាយខែត្រតាំងពួងថា តាំងតុ:លើកទ័ពចេញមកតាំងបន្ទាយនៅ
តយហៅលោកួន ឥឡូវនេះយើងឧទ្ធគិតប្រការម្តេច ។ ចូចូធ្វើយថា ដែល
តាំងតុ:លើកទ័ពចេញមកតាំងនៅត្រៃកំពែងនោះ ជាថ្នាឧទ្ធស្ងាត់ស្ងាត់

ដើមទ្រូវគុក, បើដូច្នេះ យើងត្រូវបែងនាយទ័ពនាយកងទាំងពួង ម្នាក់ ១ ចំណែក លើកទៅវាយទ័ពតាំងតុ:កុំឲ្យតាំងនៅបាន ។ អ្នកនៅវិស្តាប់ឃើញត្រូវ ទើបចាត់ឲ្យអង្គខង ១ តៀវហ្គៅ ១ ហ្គ៊ាសុន ១ អ្នកអ៊ុយ ១ ខុងឡេង ១ តៀវអៀង ១ តោកៀម ១ កងសុនចាន ១ ឃុំនាំទាហានម្នាក់ ១ ចំណែកលើកចេញទៅ ។ ឯបូជ្ឈាមេទ័ពល្បាតចាំយកដំណឹងល្អអាក្រក់មកពន្យល់ឲ្យនាយទ័ពនាយកងទាំងពួង ។

ខណៈនោះ អង្គខងបានលើកទាហានទៅដល់តួយហៅលោកួនមុនគេ ។ ឯលីហ្គ៊ាដឹងការណ៍ក៏លើកទាហានឯក ៣ ពាន់ចេញតយុទ្ធនឹងអង្គខង។ ក៏រៀបពលតាំងជាបែកឆ្វេង - ស្តាំ ហើយបរសេះចេញទៅឈរមុខទាហានទាំងពួង, លុះក្រឡេកទៅឃើញលីហ្គ៊ា តែងខ្លួនច្បាណ ហ៊ឺហាកងក្បួនសង្ក្រាមកាន់លំពែងដ៏ដេះសេះដូច្នោះ ក៏គិតថា លីហ្គ៊ានេះរូបរាងសមជាទាហានសេះណាស់ ទើបស្រែកច្បាប់ទាហានថា នរណាអាចនឹងយកអាសាចេញទៅតទល់នឹងលីហ្គ៊ាបាន? ។ ហង៊ុយ៉ុកជាទាហានឯករបស់អង្គខងធ្វើយសុំទទួលអាសា ហើយឡើងសេះកាន់លំពែងចេញតយុទ្ធនឹងលីហ្គ៊ាបាន ៥ ក្មេង, លីហ្គ៊ាយកលំពែងចាក់ហង៊ុយ៉ុកធ្លាក់ពីលើសេះស្លាប់, ហើយលីហ្គ៊ានឹងទាហានទាំងពួងក៏រាំលំពែងដេញចាក់តាមសម្លាប់កងទ័ពហង៊ុយ៉ុកជាច្រើនឡើបលស់, ទាហានទាំងនោះក៏នាំសស្លាប់បែកបាក់អស់ទៅ ។ ខ្លួលតៀវមៅនឹងអ្នកចាយលើកទាហានពាក់ព័ន្ធចូល

មកទៀត លុះយើញកងទ័ពអង្វរឯបែកមក ក៏បរាលទៅ ។ លីចោ"យើញ
ទ័ពណូនបញ្ជូនចូលមកទៀត ក៏លើកទាហានត្រឡប់ចូលបន្ទាយ ឯអង
្វរឯនឹងតៀវចោ", អួនអ៊ុយយើញដូច្នោះ ក៏បន្ទាយទាហានមកតាំងបន្ទាយ
ទៅជិតនឹងបន្ទាយលីចោ" ប្រមាណ ៣០ សិន (១២០០ម). អង្វរឯត្រួត
ពិនិត្យមើល ក៏យើញថាត់ខ្ចាត់ខ្ចាយទាហានជាច្រើន ។

ខណៈនោះ នាយទ័ពទាំង៥កង ចានៈលើកពលមកដល់តាំងបន្ទាយ
ទៅជាមួយគ្នា, ដល់ពេលព្រឹកឡើង នាយទ័ពទាំង៨នាក់ប្រឹក្សាគ្នាថា
លីចោ"មានកំឡាំងខ្លាំងពូកែណាស់ នរណានឹងមានប៉ុន្មែដៃចេញទៅច្បាំងនឹង
លីចោ"ចាន ។ កាលប្រឹក្សាមិនទាន់ផុតសំដី ខ្លួលសេះបំរើមកថ្លែងថា
ឥឡូវនេះ លីចោ"លើកពលមកតាំងជាក្បួនទ័ពនៅមុខបន្ទាយហើយ នាយ
ទ័ពទាំង ៨ ឮដូច្នោះ ក៏ឡើងមើលលើខ្នងបន្ទាយ ឃើញពួកទាហាន
លីចោ"រោរាំក្បៀវក្បាហោកញ្ជ្រៀវគឹកកងជាច្រើនណាស់ ។ ខណៈនោះមាន
ទាហានតៀវអៀងឈ្មោះបកស៊ុន ជិះសេះកំលាំពែងចេញទៅប្រយុទ្ធគ្នានឹង
លីចោ" ។ ចាក់ត្រូវបកស៊ុនធ្លាក់ពីលើសេះស្លាប់ ។ នាយទ័ពទាំង ៨ឃើញ
ដូច្នោះក៏ភ័យស្លុតទាំងអស់គ្នា, ឈ្មោះប៊ូអាន់កុកទាហានឯកខ្លុងឡើងក៏
ឡើងសេះកាន់ដំបងដែកធំចេញទៅតយុទ្ធនឹងលីចោ"ទៀត, លីចោ"ក៏ចូល
ទ្រួលតគ្នាបាន ១២ ភ្លេង លីចោ"ពាត់នឹងកំពែងត្រូវដៃប៊ូអាន់កុកដាច់ជា ២
ដំបងដែកក៏ខ្ចាត់ធ្លាក់ទៅ, ប៊ូអាន់កុកញាក់សេះបំផាយតេចយត្រាយមក

វិញ ។ នាយទ័ព ៨ នាក់ក្រឡេកឃើញក៏ចុះពីលើខ្នងបន្ទាយ ហើយបរពេលដួលតចាំនឹងលីវប៉ា ។ ប៊ូអានកុកត្រឡប់ចូលបន្ទាយបានហើយប្រឹក្សាគ្នាថា លីវប៉ានេះចេញធ្វើការចម្បាំងខ្លាំងពូកែណាស់ បើនឹងនោតសង្គ្រាមឃើញមិនងាយនឹងយកជ័យជំនះបាន អ្នកឯណានឹងគិតឃើញប្រការដូចម្តេចខ្លះ? ។ ប៊ូឆ្លើយថា ចាំបាតសំបុត្រប្តឹងទៅដល់អ្នកសៀវឡាជាប, វេលានោះ នាយទ័ពទាំងពួងក៏ប្រឹក្សាគ្នាថា នរណាចេះគិតកល់សឹកដូចម្តេចខ្លះ ដើម្បីនឹងយកខ្លួនលីវប៉ាឲ្យបាន បើបានលីវប៉ាហើយគង់នឹងបានខ្លួនតាំងតុ:ដោយងាយ ។

ខណៈនោះ សេះបំរើចូលមកជ្រាប់នាយទ័ពទាំង៨កងថា លីវប៉ាលើកទាហានមកតាំងនៅមុខបន្ទាយខ្មែតហើយ ។ នាយទ័ពទាំង ៨កងក៏ចាត់ចែងទាហានលើកចេញទៅស្រែកវេរគ្នា, ខ្លួលកងស៊ុនបានដឹះសេះគាន់លំពែងចូលទៅតយុទ្ធនឹងលីវប៉ាបាន១ ០ក្បួង, លីវប៉ានោះជិះសេះដែលមានថ្លើដើងពូកែណាស់ឈ្មោះសេកធាវ, កងស៊ុនបានតស៊ូតំទ្រាំងណាស់ក្រឡះញាក់សេះថយរត់, លីវប៉ាក៏ដេញតាមប្រកិតពីក្រោយលុះដល់ជិតក៏លើកលំពែងទ្រំងចាក់, ខ្លួលតៀវហ៊ុយបរសេះស្ទុះមកស្ទាក់ពីមុខជាប់ ហើយស្រែកសន្ធាប់ដោយសំឡេងខ្លាំង, សេះលីវប៉ាតំយតាំងស្ទុះថយក្រោយភ្លាត់ដើងជាច្រើនដំហាន, តៀវហ៊ុយរឹតតែស្រែកដេរបំពានថា អាកូន ៣ អាពុក អញមកនឹងច្បាំងផង ហេតុម្តេចអាឯងញាក់សេះវេរត

ថយទៅវិញ លីចោ"ឮខឹងណាស់ក៏ញាក់សេះចូលតយុទ្ធនឹងតៀវហ៊ុយបាន ៥០ភ្លេង មិនចាន់ចាញ់ឈ្នះ, គួនអ៊ូឃើញកំឡាំងតៀវហ៊ុយខ្លាំងលីចោ" ក៏បរសេះចូលទៅតយុទ្ធនឹងលីចោ"ទៀតបាន ៣០ភ្លេង, ខ្លៅតីក៏បរសេះកាន់គ្រឿងាំងសង៏ខាងចូលទៅជួយ ។ ខណៈនោះសេះខ្លៅតី, គួនអ៊ូ, តៀវហ៊ុយ ចោមព័ទ្ធសេះលីចោ"ជា ៣ជុំង, លីចោ"ក៏តាំងតែប្រយុទ្ធដោយគុណអាវុធការពារខ្លួនតាំងសង៏ខាង លុះឃើញប្រឡោះក៏ទៅចាក់ខ្លៅតីនឹងលំតែង, ខ្លៅតីយកគ្រឿងាត់ជាប់ ហើយបរសេះសន្ធាប់ចូលទៅនឹងចាក់លីចោ" ។ ឃើញស្នៀតអាវុធព័ទ្ធជុំវិញដូច្នោះ ក៏បរសេះស្ទុះចំលុះចេញបាន ហើយនាំគាហានចូលបន្ទាយហ៊ាលៅគួន ។

ឯខ្លៅតី, គួនអ៊ូ, តៀវហ៊ុយ ទឹងនាយទ័ពតាំងផតង៏នាំពលគាហានលើកតាមទៅដល់ចល់ទឹងកំពែងបន្ទាយ ឲ្យគាហានវាយចំលាយជុំវិញ ។ លីចោ"ឡើងទៅនោលើជើងបន្ទាយ ហើយឲ្យពលគាហានបាញ់ទឹងធ្លាក់ចុះមកព្រោងព្រាតហាក់បីដូចគ្រាប់ភ្លៀង ។ នាយទ័ពតាំងពួនឃើញថានឹងពាយរំលំមិនបែក ក៏លើកគាហានថយចូលបន្ទាយវិញ ហើយតែងសេចក្តីសំបុត្រចបក្តឹង ទោដល់អួនសៀវ។ ជឹងសេចក្តីក៏មានចិត្តសោមនស្សត្រេកអរណាស់ ទើបចាត់សំបុត្រទៅឲ្យស៊ុនកៀនស្រួតលើកទ័ពចូលមកឱប៉ាយបន្ទាយលីស៊ុយកួនឲ្យបាន ។ ឯស៊ុនកៀនបានទទួលសំបុត្រជឹងសេចក្តីហើយ ក៏ដឹងថាមានមនុស្សញុះញង់អ៊ួនស៊ុតមិន

ឲ្យបញ្ជូនស្បៀងអាហារទៅឲ្យ, ទើបចាត់ទាហានឲ្យនៅរក្សាបន្ទាយ ខ្លួន
ក៏នាំសៀវភៅទឹងអ៊ុយតាយទៅរកអ្នងស៊ុតជានាយទំពាំងពួន ។ ស៊ុនកៀន
និយាយទឹងអ្នងស៊ុតថា តាំងតុ:ធ្វើការអាក្រក់ជាសត្រូវក្បត់ផែនដី ហើយ
តាំងខ្លួនជាធំ មិនមែនមកធ្វើដល់ខ្លួនយើងឲ្យរំខានអ្វីក៏ទេ ដែលយើង
ទំនុកាតមកធ្វើការ :ដោយនឿយព្រួយលំបាកជាមួយទឹងអ្នងស្បៀវគ្រា
នេះ ព្រោះតាំងចិត្តជាសុចរិតត្រង់ទឹងផែនដី ហើយដើម្បីទឹងរំលាង
តាំងតុ:ដែលសម្លាប់អ្នងឯងដែលជាមាអ្នក:នារេញឆង យើងក៏ទ្រាំង
គ្រាប់រំសេវព្រួញទឹងគ្រឿងអាវុធមិនគិតសេចក្តីស្លាប់ យើងឲ្យដំណឹង
ប្រាប់អ្នកឲ្យបញ្ជូនស្បៀងអាហារទៅឲ្យសេនាទាហាន ហេតុម្តេចអ្នក
មានចិត្តឫស្យាមិនចាត់ការឲ្យយើងតាមសុំ ខ្លួនអ្នកធ្វើជាធំហើយមកស្តាប់
ពាក្យមនុស្សព្រុះព្រាងដូច្នេះមិនគួរការ ដែលអ្នកបង្អង់ស្បៀងអាហារ
សេនាទាហានវេលានេះ ប្រាន់ដាយើងត្រូវបាក់ឈ្លយដល់បច្ចាមិត្រ គួរឲ្យ
យើងឈឺចិត្តខ្លោមនស្សទឹងអ្នកខ្លាំងណាស់ ។

អ្នងស៊ុតឮបានពាក្យសំដីស៊ុនកៀននិយាយប្រៀបប្រាយដូច្នោះ ក៏មាន
សេចក្តីអៀនខ្មាសណាស់ ទើបឲ្យយកខ្លួនទាហានដែលព្រុះព្រាងមិនឲ្យ
ឆ្លួនស្បៀងអាហារនោះទៅពិឃាតដ៏រឹតចំពោះមុខស៊ុនកៀន ។ ខណៈនោះ
សេះបំរើនោតក្នុងបន្ទាយស៊ុនកៀនមកឲ្យដំណឹងថា ឥឡូវនេះលីឈុយឯ:
ប:ចេញមកពីបន្ទាយអ៊ីស៊ុយកួនថានឹងមកកេលោក ។ ស៊ុនកៀនបាន

ស្តាប់ក៏លាអ្នកស៊ុតត្រឡប់ទៅបន្ទាយ ហើយឲ្យគេខ្ចួនលិឈុយចូលមកជួប ក៏សួរថា អ្នកមកនេះមានការអ្វី? ។ លិឈុយឆ្លើយថា មហាឧបរាជឲ្យខ្ញុំមកនិយាយប្រាប់អស់តាំងពីថៅហ្វាយខែត្រ ដែលគប់គិតគ្នាមកធ្វើការសង្គ្រាមតាំងៈខះ ឯមហាឧបរាជនឹងបានកោតញញើតខ្លាចអ្នកឯណាក៏ទេ គឺតនឹងឲ្យចាប់សម្លាប់ចេញតាំងអស់ តែឥឡូវនេះដឹងមានមេត្តាដល់អ្នកតែមួយនឹងបណ្តាយឲ្យស្លាប់ជាមួយនឹងគេក៏មិនគួរសោះ បើនឹងឲ្យអ្នកឯទៀមកពិរោជាមួយនឹងអ្នកពីការនេះទៅ ត្រែងអ្នកសំគាល់ថាជាកិច្ចបញ្ចុះបញ្ចូលហេតុនេះចុះនាមហាឧបរាជថាតឲ្យខ្ញុំមកហាមឃាត់អ្នក កុំឲ្យចូលដៃគិតជាមួយនឹងថៅហ្វាយខែត្រតាំងពួង ៈព្រោះមហាឧបរាជប្រឹងនឹងលើកកូនក្រមុំផ្ទុំផ្ទួនឹងស៊ុនសេកជាកូនអ្នក នឹងបានជាមេត្រីភាពគ្នាតទៅ ។

ស៊ុនកៀនបានស្តាប់ដូច្នោះក៏ពាប់ចិត្តខ្លាំង តាំងតែស្រែកគំរាមគំហកហើយថា អាតាំងតុៈនោះជាមនុស្សក្បត់ផែនដីតាំងមួល ត្តេវំជួលគប់ដើមស្មៅនូវដើមឈើព្រៃតាំងអស់ យើងរិះគិតគ្នានឹងប្រហារកំចេញ ទើបកេណ្ឌកងសេនាយោធាលើកមកនេះ បើចាប់ប្រាន់ខ្ចួនកវៀលណាត្រូវប្រហារឲ្យអស់ ៧ ជួរគេត្រ ទើបអាណាប្រជានុកស្តាតាំងពួងនឹងបានសេចក្តីសុខក្សេមក្សាន្ត ដែលតាំងតុៈនឹងលើកកូនក្រមុំមកឲ្យជាកិរិយាស៊ុនសេកកូនយើង យកយើងធ្វើជាជនឡឹងនឹងតាំងតុៈសត្រូវពាជសម្បត្តិនោះ យើងមានសេចក្តីអៀនខ្មាសពន់ពេកណាស់, មួយទៀតគោសដែល

អ្នកចេញមកនិយាយបញ្ចុះបញ្ចូលយើងនោះ យើងលើកចោលគ្រានេះម្តងចុះ អ្នកចូរស្រួតរូតត្រឡប់ចូលទៅបចូលពលទាហានទាំងពួងឲ្យចូលមកជាចិត្តមួយនឹងយើង ត្រូវបើកទ្វារបន្ទាយចាំទទួលយើងចុះ យើងនឹងលើកទាហានចូលទៅចាប់តាំងតុះសម្លាប់ចេញ បើអ្នកនឹងទាហានទាំងពួងមិនធ្វើតាមយើងពន្យល់ដូច្នេះទេ កាលណាយើងលើកទៅគាប់យកស្រុកបាន យើងត្រូវប្រហារជីវិតឲ្យអស់មិនឲ្យសល់ ។ លំឈុយបានស្តាប់ក៏ស្មុតចិត្តគិតខ្លាច ហើយលាស៊ុនកៀនស្រួតត្រឡប់ចូលទៅប្រាប់តាំងតុះ។ បានស្តាប់ក៏ទឹងណាស់ ទើបប្រឹក្សានឹងលំឈូថា ដែលយើងនឹងទៅបញ្ចុះបញ្ចូលស៊ុនកៀនមិនព្រមចូលចិត្តនឹងយើងនោះ អ្នកនឹងយល់ឃើញប្រការដូចម្តេច? ។ លំឈូទូន្មាថា ដែលលីចាប់ងាប់ប្រៀបគ្រានេះ ទាហានទាំងពួងក៏មានតែពចិត្តឯយចុះ សុំឲ្យលោកលើកទាហានចូលទៅក្នុងសិន ហើយកុញ្ជើញព្រះចៅហៀនតេទៅប្រាប់ឯស្រុកតៀងហ៊ាន ព្រោះខ្ញុំបានឮកងកងស្រុកប្រៀងទំនុកក្តេងថា "តង់ចៅអ៊ុតគោហ៊ាន សៃចៅអ៊ុតគោហ៊ាន ឡុកចៅយ៉ាបតៀងហ៊ានហង គោប៉ឈូលំន" ប្រែថា "ទិសឯលិចមានស្រុកតៀងហ៊ាន ១ ទិសឯតើតក៏មានស្រុក បើប្រើសចោលចូលក្នុងស្រុកតៀងហ៊ានហើយ ក៏មិនមានភ័យមន្តក្យឡើយ" ខ្ញុំបានគិតឃើញក្នុងពាក្យក្តេងនោះថា ពីដើមព្រះចៅហ៊ានគោចាប់បានកុសាងព្រះពជ្ឈានីនោស្រុកតៀងហ៊ាន ហើយមានព្រះមហាក្សត្រ

សោយរាជសម្បត្តិត ។ គ្នាមកបាន ១២ ព្រះអង្គ, ក្រោយនោះព្រះចៅហ៊ាន
កងប៊ូបានកសាងព្រះរាជធានីនៅស្រុកឡុងអៀងវិញ មានព្រះមហាក្សត្រ
សោយរាជសម្បត្តិជាលំដាប់គ្នាមក លុះដល់ព្រះចៅហៀនតេមាន ១២
ព្រះអង្គដែរ ខ្ញុំឃើញថាពួកព្រះរាជវង្សព្រះចៅហ៊ានកងប៊ូនឹងសាបសូន្យ
គ្រានេះហើយ រាជសម្បត្តិនោះគង់នឹងធ្លាក់បានមកលោកជាក្រោកជ័ បើ
អ្នកបានទៅកសាងព្រះរាជធានីនៅស្រុកតៀងហ៊ានវិលាណា ក៏នឹងមិន
មានកើតភ័យអន្តរាយអ្វីឡើយ ។ តាំងតុះបានស្តាប់ហើយក៏មានសេចក្តី
ត្រេកអរជាអនេក ហើយនិយាយនឹងលីយ៉ូថា ដែលអ្នកអធិប្បាយឲ្យយើង
ស្តាប់វេលានេះ យើងប្រុងចិត្តគិតឃើញត្រូវ, ថាហើយក៏លើកទ័ពត្រឡប់
ទៅស្រុកក្រុង ។ លុះវេលាពីរកន្លីស្ងាត់ឡើង តាំងតុះឲ្យប្រជុំនាម៉ឺនមុខ
មន្ត្រីភូបាលមកព្រមគ្នាក្នុងទីគាល់ ហើយនិយាយថា យើងមើលក្នុងតម្រា
ឃើញថាស្រុកឡុងអៀងដែលនៅខាងទិសឯកើត នឹងរៀវរោយសាប
សូន្យហើយ ស្រុកទិសឯលិចនឹងវឌ្ឍនាចំរើនរុងរឿងទៅខាងមុខ យើង
នឹងអញ្ជើញព្រះចៅហៀនតេ ស្តេចទៅសាងព្រះរាជធានីនៅក្នុងស្រុក
តៀងហ៊ាន បើដូច្នេះត្រូវអស់អ្នកលះគ្នាលើកគ្រប់គ្រងទៅតាម សាងទី
លំនៅ ។ ទីនោះឯង ។

អៀវពៀវធ្វើយថា ឯស្រុកឡុងអៀងនេះព្រះចៅហ៊ានកងប៊ូសាង
ក្រុងសោយរាជសម្បត្តិមកជាយូរហើយ មានព្រះមហាក្សត្រិយ៍ដល់ ១២

ព្រះអង្គ ដែលលោកនឹងឲ្យលះបង់ស្រុកនេះ លើកគ្នាទៅនៅស្រុកតៀង ហ៊ានោះ ខ្ញុំឃើញថាអាណាខែត្រនឹងកើតចលាចល បណ្តាប្រជាជនក៏នឹងបានសេចក្តីក្តៅក្រហាយ ដូចមានពាក្យបុរាណថា "ធម្មតាផ្លុំដែលនឹងរើរុះនោះងាយណាស់ លុះនឹងសង់ឡើងវិញក៏បានដោយកម្រ" ប៉ើមិនស្តាប់ពាក្យខ្ញុំខំតែលើកទៅតាំងនៅស្រុកតៀងហ៊ានហើយ បណ្តាពស្តុនឹងបានសេចក្តីភ្ញាក់ផ្អើលបែកខ្ចាត់ខ្ចាយអស់ លុះនឹងតៀរបម្រុលឲ្យមូលមកវិញបាន ដោយក្រណាស់ ដែលខ្ញុំដរាបតាំងនេះ សូមលោកត្រិះរិះមើលតាមសមគួរ ។

តាំងតុ:ឮបានឮក៏ខឹងខ្លាំងណាស់ទើបនិយាយថា ខ្ញុំនេះជាមហាឧបរាជនឹងបង្គាប់បញ្ជាការអ្វីក៏ជាសិទ្ធិឫកជ យើងមើលតម្រាឃើញថានឹងកើតមានអន្តរាយទើបបានជានិយាយពន្យល់ដូច្នេះ ហេតុអ្វីខ្ញុំនេះមកចេះឃាត់ឃាំងខ្ញុំនឹងពាក្យរបស់យើង ។

អ៊ុយអ៊ួនផូនឆ្លើយឡើងថា ដែលអៀវតៀវខ្លាស់នោះត្រូវណាស់ ព្រោះកាលអង់ម៉ាំងជាសត្រូវក្បត់ដណ្តើមយកពរជសម្បត្តិ ហើយដុតស្រុកវិនាសអស់ទៅ ស្រុកនោះក៏ទៅជាវៃព្រៃផ្សៃ ដែលលោកនឹងលះបង់ស្រុកនេះហើយទៅយកវៃព្រៃធ្វើស្រុកនោះខ្ញុំឃើញមិនសមគួរ ។

តាំងតុ:តបថា យើងឃើញខាងទិសឯកើតៗចលាចលដោយពួកចោរធ្វើឲ្យអន្តរាយផ្សែង ។ មកជាច្រើនគ្រាហើយ ខាងស្រុកតៀងហ៊ានោះ

ពីដើមកំជាទីក្រុងដែរ យើងឃើញគួរសម ដោយមានកុំនឹងថ្មសិលាគួរនឹងចាត់ការរៀបស្រុកបានម៉ងលើសពី ១ ខែ កំនឹងជាសុខសប្បាយជាមួយគ្នា ហេតុនេះកុំបីអ្នកទាំងពួងខឹងគាស់តទៀតឡើយ ។

ស៊ុនសង្ឃឆ្លើយឃាត់តាំងតុ:ជូចពាក្យអ៊ុយអួន តាំងតុ:ឆ្លើយថា យើងនឹងខំខុតបំពុងពាជសម្បត្តិនេះជាការធំម៉ាមួនណាស់ ឧបមាដូចគាស់រំលើងគល់ឈើធ្លើស្រែចម្ការ បើនឹងស្ពាយដើមឈើ កាលណានឹងបានស្រួលស៊ុ, ចាហើយតាំងតុ:ក៏ឲ្យដកហូតងារ អៀវពៀវ, អ៊ុយអួន នឹងស៊ុនសង្ឃចេញចាកតំណែងមន្ត្រីទ្វីពជការ ហើយតាំងតុ:ឯងឡើងជំនះនេះនឹងទៅកាន់ទីលំនៅ លុះចេញទៅដល់ក្រៅទ្វារព្រះពាជពំង ប្រទះអៀវពៀវនឹងផៅខេងចូលមកគំនាប់ពីមុខរនេះ តាំងតុ:សួរថា អ្នកទាំង ២ មានការមករកអ្វី? ។ អៀវពៀវនឹងផៅខេងជំរាបថា យើងខ្ញុំបានឮកិត្តិសព្ទថា លោកនឹងលះបង់ចោលស្រុកនេះទៅសាងក្រុងទៅស្រុកតៀវហ៊ន យើងខ្ញុំយល់ឃើញមិនសមគួរ ទើបចូលមកជំរាបឃាត់លោក ។ តាំងតុ:បានស្តាប់ក៏ក្រៃក្រោធហើយថា ឯងទាំង ២ រូបនេះកាលពីពេលមុន បាននិយាយឲ្យយើងតាំងអួនសៀវជាចៅហ្វាយខ្លួនត្រ យើងបានធ្វើតាមសំដីឯងទាំង ២ នាក់ឥឡូវនេះអួនសៀវត្រឡប់មកប្រទុស្តកយនឹងយើងវិញ ប្រហែលជាគាត់ឯងទាំង ២ នាក់ចូលគំនិតគិតធ្វើកលជាមួយនឹងអួនសៀវពិតមែន, ចាហើយគំបង្គាប់ពេជ្ឈឃាដឲ្យចាប់អៀវពៀវនឹងផៅខេង ទៅសម្លាប់កងពេលនោះ

ហើយតាំងតុ:ក៏ហួសទៅដល់ទីលំនៅ ទើបតំណាត់ពេលដែលនឹងលើក
គ្រប់គ្រួសារទៅតាំងភូមិកំពែងនៅស្រុកតៀវហ៊ន ។ ពេលនោះលីយូដុង-
ពថា ដែលលោកនឹងលើកគ្រប់គ្រួទៅសាងទីក្រុងនោះ ស្បៀងអាហារ
នឹងមាសប្រាក់ក្នុងផ្ទៃព្រះឃ្លាំងមាននៅៈច្រើនណាស់ ឃើញថាត់ការមិន
គ្រប់គ្រាន់, នៅក្នុងស្រុកឡុកអៀងនេះមានសេដ្ឋីគហបតីដែលមានភោគ
សម្បូរក៏ច្រើន សូមឲ្យលោកទៅរៃជាន់រើយកមកជាក់ឃ្លាំងឲ្យហើយ
ទើបនឹងគិតធ្វើការនេះបានដោយងាយ, មួយទៀតបណ្តាប័ក្ខពួកក្នុងស្រុ
ដែលនៅក្នុងស្រុកក្រុងនេះក៏ច្រើន សូមឲ្យលោកចាប់សម្លាប់ចេញឲ្យអស់
ហើយរឹបយកទ្រព្យរបស់មកជាក់ឃ្លាំងកុំឲ្យសល់ ។ តាំងតុ:ស្តាប់ឃើល
ត្រេកអំណាត់សេនាគាហាន ៥.០០០ ឲ្យទៅសង្កត់សង្កិនពួកអាណាប្រជា
ដែលមានទ្រព្យសម្បត្តិមាសប្រាក់នោះយកមកតាំងអស់, ឯម្ចាស់ៗបស់ក៏
ឲ្យចាប់ខ្លួនមកបង់ទុកហើយឲ្យយកទង់ដោតជាក់លើកំពូលសេះអស្ស ២
តួថាពួកក្បត់ ហើយនាំទៅប្រហារជីវិតទាំងអស់ ក្នុងពេលនេះតាំងតុ:
ឃុនទ្រព្យសម្បត្តិច្រើន ។ លុះស្រេចការហើយតាំងតុ:ក៏ឲ្យលីឈុយ,
គុយតឺ បណ្តេញបំបរអាណាប្រជានុករស្លក្នុងស្រុកឡុកអៀង ឡើង
ទៅនៅក្នុងស្រុកតៀវហ៊នមិនមានសល់ដល់ម្នាក់ ។

កាលលីឈុយ, គុយតឺ បណ្តេញបំបរអាណាប្រជានុករស្លទៅនោះ
មនុស្សអ្នកនគរទាំងប្រុសទាំងស្រីក្មេងចាស់ប្រហែល ៦០០ ម៉ឺនឬ ៧០០

ម៉ឺន នឹងគាហានតាំងតុ:កំលើកប្រភាក់ប្រភួនទៅជាកង ។ មនុស្សផង
ច្រៀតបៀតជាន់គ្នាស្ទាប់កំមាន គាហានខ្លះកំមកដណ្តើមយកទ្រព្យរបស់
បណ្តាក្រ ខ្លះកំអូសកន្ត្រាក់យកកំរើយាបុត្រគេទៅធ្វើបរទាសកម្មតាមអំពើ
ចិត្តឥតកោតខ្លាច ក៏ស្តេចសាំងនោះសឹងលុះដោយអំណាចដែលគេ
គំហកកំហែងជាចលាចល មនុស្សទាំងក្មេងទាំងចាស់ខ្លះខ្លួញយំតាមដួរ
ទៅ, មុកគួរឲ្យអាណោចអាធ័មពន់ពេក ។

ឯតាំងតុ:ត្រៃមកាទាំងអស់ជាស្រែចហើយ កំឲ្យគាហានយកភ្លើង
ដួលអុជ ព្រះរាជាំនឹងឆ្លុះសំពែង បណ្តាដែលមានកងស្រុកឯកអៀងនោះ
នេះទាំងអស់ ហើយវិលចូ៉ៗនាំពលគាហានទៅដីកវិលរំលើង ព្រះបរម-
សព្តនៃព្រះមហាក្សត្រព័ប្ទុពណដែលមានឆ្លងចេញទុកតមក ហើយកកាយ
រើយកមាសប្រាក់ដែលទៅជាមួយនឹងសពនោះជាច្រើន, គាហានខ្លះកំ
បន្ទំដំកគាស់កកាយយកទ្រព្យរបស់ក្នុងសព រេចសំណាងប្រជាទុក្ខក្រ
មកជាប្រយោជន៍រៀងខ្លួន, តាំងតុ:កំឲ្យដញ្ជួនទ្រព្យទាំងនោះផុតលើរនេះ
ជាងតាន់បរទ្ធឹកលាន់ទាំងប្រចំពីចេញទៅ ហើយកំអញ្ជើញព្រះចៅ
ហៀនតេស្តេចទៅជាមួយនឹងស្រីស្នំក្រមាននឹងឡើងជាការទាំងពួង ។

ឧណ:នោះតៀរធីមដែលចេញទៅតាំងបន្ទាយនៅតយតីស៊ុយគួនជា
មួយនឹងហ្វូយុងដែលស្ទាប់ ហើយនឹងគាហានដែលនៅរក្សាតយ:ហ៊ា

លោគួននោះ លុះដឹងថាតាំងតុ:ចោលស្រុកឡុកអៀងហើយ, តៀវធីមក៏នាំភាហានទាំងអស់នោះទៅតាមតាំងតុ: ។

ឯស៊ុនកៀន កាលឃើញបន្ទាយគីស៊ុយគួនស្ងាត់ឥតមនុស្សម្នាដូច្នោះ ក៏ពិគ្រោះនឹងនាយទ័ពទាំង ៨ ហើយនឹងឡៅពី, គួនអ៊ូ, តៀវហ៊ុយ ដើម្បីស្តាប់ការ លុះដឹងថាតាំងតុ:លើកពលភាហានទៅអស់ហើយ ក៏បរពលចូលទៅក្នុងស្រុកឡុកអៀង កាលចូលដល់ក៏គ្រប់ឡុកទៅឃើញក្លោងកំពូងតេះផ្ទះសំបែង ពេញក្នុងស្រុកនោះ នឹងរកមនុស្សក៏មិនឃើញមានសោះ នោះនាយទ័ពនាយកងទាំងពួង ក៏ចាត់ឲ្យភាហានចូលលត់ក្លោង រលត់អស់ហើយក៏តាំងទ័ពនៅទីនោះ ។

ចូឆូដំរាបអ្នងសៀវថា តាំងតុឲ្យដុតស្រុកចោលបានលើកភាហានរត់ទៅខាងទិសឯលិចហើយ ឯព្រះចៅហៀនតេសោតយើងមិនទាន់ដឹងជាក់ច្បាស់ជាល្អឬអាក្រក់ វេលានេះអាណាប្រជានុពស្តុកពូងមានសេចក្តីភ្លៀកភ្លៃហាយរវើរវាសណាស់ បើដូច្នះត្រូវតែយើងលើកកងទ័ពទៅតាមដើម្បីនឹងចាប់តាំងតុបានដោយងាយ ហេតុម្តេចលោកៈនៅស្ងៀមដូច្នេះ? ។

អ្នងសៀវនឹងចៅហ្វាយខែត្រទាំងពួងឆ្លើយថា ភាហានយើងកំពុងនឿយហត់ណាស់ ចាំឈប់សម្រាក់កំឡាំងបន្តិចសិនសឹមគិតការលើកតាមទៅ ។ ចូឆូបានស្តាប់ហើយក៏នឹកតែក្នុងចិត្តថា ការដែលមករួមគំនិត

គិតធ្វើជាមួយនឹងចៅហ្វាយវៃត្រចាំងអស់នេះជាការធំមាំមួនណាស់ តែបើដូចជាចៅគិតគ្នាជាមួយនឹងក្មេងគង្វាលគោ, គិតដូច្នោះហើយក៏រៀបចាត់ចែងការហានដែលជាបក្ខពួករបស់ខ្លួនបានប្រហែលមួយម៉ឺនថ្វាយ ហើយក៏នាំហែហួនុន, ហែហួអៀន, ចៅហាន, ចៅយិន, លីឡៀន, ងាក់ជិន នឹងការហានទាំងពួងស្រុតលើកតាមតាំងតុ: ទាំងថ្ងៃទាំងយប់ ។

ឯតាំងតុ: កាលលើកពលចៅដល់ស្រុកអេងយ៉ុង នោះស៊ុអេងជាចៅហ្វាយស្រុកដឹងដំណឹងក៏ចេញមកទទួលតាំងតុ: ។ លុយដំរាបតាំងតុ: ថាយើង: លើកពលចេញពីស្រុកក្រុងមកគ្រានេះ ខ្លាចក្រែងពួកសត្រូវនឹងលើកតាមមកពីក្រោយ បើពួកយើងនឹងតទល់មិនបាន ឃើញនឹងខ្ជូចការធំដូច្នេះសូមឲ្យស៊ុអេងឃុំនាំការហានចៅបង្អប់នៅលើកុំចំដើមផ្លូវចុះ បើកងទ័ពតាំង ៨ ស្រុករលើកមកតាមមែន ក៏ឲ្យស៊ុអេងចេញតទល់ជាមុន ប្រសិនកងទ័ពគេចំណាយចូលមកបានតនឹងកងទ័ពយើង ។ ឲ្យស៊ុអេងចេញរាយខ្ជូបពីក្រោយចែមមកទៀត ទ័ពដែលតាមមកគង់នឹងចាញ់ប្រៀបយើងជាប្រាកដ ។ តាំងតុ:បានស្តាប់យល់ឃើញត្រូវ ទើបបង្គាប់ឲ្យស៊ុអេងឃុំនាំការហានលើកចៅបង្អប់លើកុំដើមផ្លូវនោះ ហើយឲ្យលីប៉ានឹងលីឈុយ, គុយតឺ លើកការហានតាមចៅដើរជាទ័ពក្បួនក្រោយ ។

(មានត)

លោកសាង-សារ៉ាត

លេខានុការកែសួនហិរញ្ញវត្ថុ ប្រែរៀបរៀង

(តមក)

៣ — ការកាត់សេចក្តីកាបសាហាវ

" ការណ៍កាបសាហាវ ទឹកចិត្តខ្លះខ្លៅ
គេមិនចាន់ហៅ សុភាចាន់ពិត " ។

មានសេចក្តីដំណាលថា កាលនោះ មានសត្វឆ្កែ ១ គូ ឈ្មោល-ញី រកស៊ីចិញ្ចឹមជីវិតនៅក្នុងព្រៃស្មសាន ដូចជាឆ្កែព្រៃ ។

លុះថ្ងៃក្រោយបន្តិចមក សត្វឆ្កែទាំងគូនោះមានកូន ៣ តឹៈ ឈ្មោល មួយញីពីរ ក៏មានចិត្តពេញចិញ្ចើមដោយបីតិនឹងសោមនស្សដ៏ក្រៃលែងចំពោះកូនទាំង ៣ នោះ ប៉ុន្តែដល់ឃ្លៀវទៅសត្វទាំង ២ នោះក៏តែងមានការទាស់ទែងគ្នាឡើងក្នុងគ្រួសារ ។ ដើម្បីកុំឲ្យមានការឈ្លោះប្រកែកគ្នាជាអចិន្ត្រៃយ៍ ឆ្កែទាំងគូដែលសុទ្ធតែជាសត្វប្រាជ្ញាសន្តិសុខ ក៏បានសម្រេចសេចក្តីដោយស្រុះស្រួលគ្នាថា នឹងបែកចេញពីគ្នាតែរៀងខ្លួន ។

លុះកាលណាសុខចិត្តតែសត្វខ្លួនដូច្នោះហើយ សត្វទាំងគូក៏តាំងចែកមតកគ្នា (ចែកកូនគ្នា) ម្នាក់យកកូនឆ្កែញីមួយ ឯចំណែកកូនឆ្កែឈ្មោលមេនឹងបាចធំបានតែសត្វខ្លួន ។ លុះចែកគ្នាមិនជាប់ស្រេច មិនព្រមព្រៀងគ្នាឆ្កែឈ្មោល-ញីទើបនាំគ្នាចូលទៅកាន់សំណាក់ខ្លា លុះទៅដល់ហើយអង្វរខ្លាសុំឲ្យធ្វើជាអ្នកតាជ្រកណ្តាលកាត់សេចក្តីឲ្យ ។ ឯសត្វខ្លាជុនស្តាប់សត្វសេចក្តីហើយ និយាយថា "បើដូច្នេះ អ្នកឯងមករកខ្ញុំឲ្យខ្ញុំចែកឲ្យឬយ៉ាងណា? តើប្រាកដជាចង់ឲ្យខ្ញុំចែកឲ្យមែនឬអ្វី?" ។

ថ្វីបើមានចិត្តសង្ស័យនឹងពាក្យគំរោះបន្តិចរបស់ខ្លានោះ សត្វទាំងពីរក៏ទៅតែធ្វើសញ្ញាថា "ចំណង់របស់យើងគឺដូច្នោះឯង" ។ ខ្លានិយាយថា "បើដូច្នោះ ខ្ញុំចែកឲ្យ" ថាហើយខ្លាក៏ឲ្យកូនឆ្កែញីមួយទៅថា មួយទៀតទៅមេ ឯកូនឆ្កែឈ្មោលដែលសល់នោះ ខ្លាក៏កាត់ជាពីរកំណាត់ចំពាក់កណ្តាលខ្លួន ហើយចោះ ១ កំណាត់ឲ្យទៅមេ ១ កំណាត់ឲ្យទៅថាទាំងកំពុងហូរឈាមស្រាក់នោះ ។ ឯឆ្កែឈ្មោល - ញីទាំងពីរឃើញដូច្នោះ ក៏ស្រែកលូតលែចឡើងឮសូរខ្ទរខ្ទីរពងពេញព្រៃថា "នែលោកខ្លាមហាចតិត្រអើយ! លោកបានចែកឲ្យខ្ញុំក៏ពិតមែនហើយ ប៉ុន្តែលោកមិនគួរនឹងធ្វើការុណាកម្មយ៉ាងនេះសោះ", ថាហើយ ឆ្កែញី - ឈ្មោលក៏ចោកចំណែកនៃសាច់កូនកំសត់របស់ខ្លួន ដែលប្រឡាក់សុទ្ធតែឈាមនោះទៅនឹងជើងខ្លា ហើយត្រឡប់ចូលទៅកន្លែងព្រៃទាំងគូ លែងនឹកនាពីការបែក

ប្រាក់គ្នាតទៅ តែឲ្យប់ជាស្រុះស្រួលមួលមិត្តគ្នាទៅវិញ ដោយសារមានទុក្ខជាមួយគ្នានេះ ។

៤ - ប្រាជ្ញារបស់ទន្សាយ

"គ្មានទុនគ្មានអត់ មេត្រីប្រាកដ ធាប់បែកធាប់ប្រាក់" ។

កន្លងកាលដ៏កន្លងយូរអង្វែងណាស់មកហើយ នៅក្នុងនគរស្មុកស្តួកមួយ ដែលមានទឹកហូរស្រោចពីទន្លេ ឡឺកង់ (Le gange) កាលណោះ មានសត្វចចក ១ កេ ១ ប្រាថ្នាចង់មេត្រីនឹងគ្នាយ៉ាងស្មោះស្ម័គ្រ ហើយរកស៊ីចិញ្ចឹមជីវិតនៅជាមួយគ្នាជានិច្ច ។ មានមួយព្រឹកនោះ ជាពេលភ្លឺច្បាស់ល្អ មិត្តទាំងពីរនាំគ្នាដើរតាមមាត់ព្រៃក ដើម្បីស្វែងរកអាហារបរិភោគ, លុះដល់ថ្ងៃត្រង់ គេចាប់ឃ្លានតឹមួយយ៉ាងល្អក្នុងដើមត្រែង រួចមិត្តទាំងពីរក៏តាំងវាយចំណែកគ្នា ។ កេនិយាយថា "អញយកក្បាលនឹងពោះ" ចចកឆ្លើយវិញថា "ទេ! ឯងយកចំលើកន្ទែងដែលអញចង់បានដែរ" ។

រឿងនេះ សត្វទាំងពីរបែកគ្នាមិនដាច់ស្រេច ក៏កើតទាស់ទែងគ្នាខុសពីធម្មតារបស់ខ្លួន នឹងខុសពីវិធានការសម្ព័ន្ធមិត្តល្អ ។ ដល់ថ្ងៃក្រោយបង្អស់ព្រោះតែការមិនព្រមព្រៀងគ្នានោះ ក៏នាំគ្នាទៅប្តឹងទន្សាយមួយដែលមានល្បីឈ្មោះខាងគតិបណ្ឌិត គឺទន្សាយនេះហើយដែលនឹងប្រាប់ត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាល ។ សុភាទន្សាយ ប្រាប់ស្តាប់ពាក្យតន្សល់របស់ចចកនឹងកេ ហើយនិយាយដោយក្រៀមក្រំថា

"នែបង៉ាងពីរ បងជាមិត្តភក្តីនឹងគ្នាមកយូរហើយ តើឈ្លោះប្រកែកគ្នាធ្វើអ្វី? រាមិនសមសោះ បងបានស្រឡាញ់គ្នាយ៉ាងម៉ាមួនតាំងពីនោះមក ដល់នេះ ម្តេចក៏ឲ្យបែកគ្នាវិញបាន សត្វប៉ើរឿងបន្តិចបន្តួច រឿងនេះគេងាយនឹងសំរួលទេតើ, ហេតុដូច្នេះ ជាបណាដែលគេចាប់បានត្រីមួយ ជាបនោះគោងចែកដូចខ្ញុំបង្ហាញនេះ" ។

ទន្យាយក៏ពុះត្រីចំពាក់កណ្តាល ពីក្បាលហូតដល់កន្ទុយ រួចហុចឲ្យទៅគេ១ចំហៀង, បបក១ចំហៀង តាមចំណែកដែលគេញុះញង់ខ្លួន ។

រឿងល្បែកនេះ ស័ដែងឲ្យឃើញច្បាស់ជាដំរិសេសនៃពាក្យប្រៀនប្រដៅរបស់ព្រះនាងខត្តិយានី ធូដាម្ន៉ាសារី (Thoudamna Sari) កាលដែលព្រះនាង មានព្រះតម្រាស់ថា:

"នោះស្តេចក្តី នោះអភិជនក្តី នោះចាងហ្វាងក្តី គោងតែយកទន្យាយដែលនឹងបានជាព្រះពុទ្ធក្នុងអនាគតជាគំរូ មិនត្រូវឲ្យបំណងខុចតែផ្សេងៗធុសធុលជុំវិញខ្លួនទេ, គោងឲ្យទៅម្នាក់ៗ នូវចំណែកដែលគេត្រូវបាន, គោងយកសេចក្តីសុចរិតជាប្រធាន ក្នុងការសម្ងាត់របស់ខ្លួន, ជនណាដែលមិនប្រព្រឹត្តតាមសិក្ខាបទនេះទេ ជននោះមិនអាចទៅដល់លំនៅរបស់ក្រុមណាត់ [1] (Nat) ដ៏ប្រសើរឡើយ" ។ (មាន៨)

---

១ ក្រុមណាត់ (Nat) គឺក្រុមទេវតា ក្នុងរឿងព្រេងបុរាណរបស់ជាតិភ្លីង ។

ឃុន បុរីក្សបរិភ័ណ្ឌ ឈឹម-ណាក ក្រុមពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង (ឆ្នាំ)

ថែមទាំងនឹកសូត្រមន្តរបៀនសិល្បសាស្ត្រ ដែលធ្លាប់ចេះធ្លាប់រៀនមក ប៉ុន្មានក៏នៅតែរ៉ែមនរួចអំពីជុចនោះ រឹតតែតឹងឡើងៗ ស្ទើរតែជាច់ខ្យល់នឹងរកស្តីនិយាយស្ទើរតែមិនរួច ។ យក្សទើបដឹងថា ជុចក្មេងនេះពូកែមែន, បើអញមិននិយាយអង្វរឲ្យវាស្រាយជុចនេះចេញទេ នឹងស្ងាប់អសារតែការមិនខាន, ទើបនិយាយអង្វរកុមារថា "នុលោកអើយ! កាលពីដើមខ្ញុំមើលងាយជុចលោក ដោយគិតឃើញថា មើលទៅមិនលម្មនឹងកំឡាំងខ្ញុំសោះ ហេតុតែសេចក្តីមើលងាយនេះហើយ បានជាខ្ញុំស្ទើរតែស្លាប់ខ្លួនយ៉ាងនេះ ហេតុនេះ សូមលោកអាណិតមេត្តាខ្ញុំម្ចាស់ទៅចុះ ខ្ញុំសម្ចាន់ឆ្កែងមួយថ្ងៃ សូមលោកអធ្យាស្រ័យឲ្យរស់តែដ៏រឹតកុំឲ្យតែខ្ញុំស្លាប់ ។

ឯកុមារបានឃើញយក្សបម្រះនេលមិនរួចពីជុចរបស់ខ្លួនហើយ ថែមទាំងឮនិយាយអង្វរទៀត, ក៏បិតនោដៃនិយាយតៈទៅនឹងយក្សវិញថា "ម៉េចអាឯងដឿអញទេ, ឥឡូវមករត្អូជានិយាយអង្វរ, ឯស្ងាច់ដំរីអញអាឯងស៊ីអស់ ហើយគិតនឹងស៊ីអញទៀត អាឯងថ្លើមធំណាស់ អញមិនយកអង្វរអាឯងទេ, លាបន្តិចអញគ្មានអ្វីស៊ីសោះ ម្តងនេះអញស៊ីថ្លើមអាឯង

ហើយ, ចុះមកបង, ទៅរកគាប់ចុស្សីមកធ្វើត្រណោតដោតថ្មើមអាខូច
នេះអាំងស៊ី" ។ បង់ក៏ចុះពីផ្ទះមកគាំងក័យញើរញ័រ ដល់មកដិតប្អូនឃើញ
យក្សគួរស្បើម ក៏តឹងតែញាប់ញ័រ ។ ប្អូននិយាយថា "ឈប់បង កុំញ័រ
បង់ស៊ីក៏ពេក ឈប់សិន ចាំឆ្អិនសិន, ហ៎:ញ័រចង់អ្វីទៀតហើយ កុំញ័រ
អ្វីពេក យើង់ស៊ីឆៅមិនឆ្ងាញ់ទេហើមពោះពុង់ណាបង" ។ យក្សព្រះសំដី
កុមារនិយាយនឹងបង់ដូច្នោះហើយរឹង់តែតក់ស្លុតព្រលឹង់ ហើយនិយាយ
អង្វរកុមារទៀតថា "នែលោកម្ចាស់ថ្លៃអើយ! សូមលោកអាណិតខ្ញុំយក
បុណ្យម្តង់នេះទៅចុះ, ខ្ញុំនឹងជូនកន្សែងបក់កន្សែងចោយមួយ ឲ្យតែលោក
លែងខ្ញុំឲ្យបានរស់មានជីវិត ដ្បិតខ្ញុំជាស្តេចយក្សគ្រប់គ្រងអាណាប្រជា-
ន្តុកស្តុ, បើលោកឲ្យខ្ញុំស្លាប់ទៅ សមជាស្រុកទេសរបស់ខ្ញុំអន្តរធាន
មិនខាន តាំង់កូនប្រពន្ធខ្ញុំទៀតក៏ពុំមានទីពឹង់" ។ កុមារប្អូនសួរបញ្ជាក់
យក្សថា "ចុះឯង់ឲ្យកន្សែងបក់កន្សែងចោយដល់យើង់, កន្សែងនោះបើ
បក់-ចោយទៅអាចឲ្យសម្រេចប្រយោជន៍ដូចម្តេចខ្លះ?" ។ តាមតែលោក
បង់បានអ្វី បក់មកបានតាមប្រាថ្នា បើចង់ឲ្យភ្លៀងទៅវិញ គ្រាន់តែចោយ
ថាទៅវិញចុះ ក៏ស្រាប់តែភ្លៀងអស់រលីង ។ ប្រាកដជាឯង់ឲ្យយើង់
មែនឬ? ។ មែន ។ កែង់កុហកទេដឹង់? ។ មិនកុហកទេលោក ។ បើកុហក
តើឲ្យយើង់ធ្វើដូចម្តេច? យើង់មិនទុកចិត្តទេព្រោះឯង់ជាស្តេចសោយ
រាជ្យ កែង់រួចពីកណ្តាប់ដៃយើង់ទៅ បបួលហៅពលមកច្បាំង់នឹង់យើង់

វិញ? បង! យកកាំបិតមកឥន្ទ្រះសាច់ក៉ាអាំងស៊ីសម្រន់សេចក្តីយ៉ាន ១ ស្របក់សិន ។ បង៉ះនោះនៅតែមិនទាន់ចាត់ក័យនឹងយក្ស ។ យក្សឮ កុមារគួចឲ្យបង៉យកកាំបិតមកឥន្ទ្រះសាច់ខ្លួនដូច្នោះ ក៏ញាប់ញ័រស្ទើរតែចាត់ស្មារតី ហើយនិយាយអង្វរកុមារនោះទៀតថា "សូមតែលោកទុកជីវិតឲ្យចុះ ខ្ញុំនឹងប្រគល់រាជ្យទាំងអស់ ព្រមទាំងស្រុកសួយទាំងអម្បាលម៉ានជូនលោកទៀត ខ្ញុំសូមឲ្យរួចតែខ្លួនឯងនឹងភរិយា - បុត្រី - បុត្រា ហើយនៅធ្វើជាសេនាក្បាលោកទៀត" ។ កុមារប្លួនក៏សួរបញ្ជាក់យក្សថា "បើឯងនិយាយរឿងត្រង់មែន ណ្ហើយយើងអត់ទោសឲ្យបាន, តែយើងមិនដឹងថាឯងជាស្តេចសោយរាជ្យនៅឯណា ចុះធ្វើម្តេចឲ្យយើងទៅតាមយកឥន្ទ្រះឯងបាន? ។ ឧ! លោកមិនសល់កម្លាំងអញ្ជើញទៅឯឥន្ទ្រះខ្ញុំនោះទេ ឲ្យតែលោកលែងខ្ញុំចុះ ខ្ញុំនឹងធ្វើតម្រុយជាលំអានរហូតដល់ទៅឥន្ទ្រះខ្ញុំឯណោះ ។ ឯងធ្វើតម្រុយបែបណា? ។ ខ្ញុំគាប់មែកឈើស្រស់ៗ ហែ ។ តាមផ្លូវទៅ កាលបើលោកអញ្ជើញទៅ សូមទៅតាមស្នាមមែកឈើដែលខ្ញុំគាប់នេះចុះ ។ កុមារទាំងពីរក៏ព្រមដោះយក្សចេញពីដុច ។ ឯយក្សបានរួចខ្លួនពីដុចហើយ ក៏ក្រាបថ្វាយបង្គំកុមារទាំងពីរដើរទៅឥន្ទ្រះខ្លួនវិញ. ហើយគាប់មែកឈើជាតម្រុយ ដើម្បីជាទីសំគាល់ដល់កុមារទាំងពីរថ្ងៃក្រោយ ឥតមានកុហកក្លែតក្លែងអ្វីឡើយ លុះដល់ទៅឥន្ទ្រះហើយ ចូលទៅនិយាយថ្កាប់ពួកពលសេនា យាធាទាហានដែលទៅតាំ

ក្មេងទ្វារ ទាំង៧ ជាន់ថា "នែវ៉ុយ ថ្ងៃស្អែកនេះមានក្មេងតូច ។ ពីរនាក់ ជាក្មេងមនុស្សលោក មកដណ្តើមរាជ្យអញ, បើពួកឯងឃើញវាហើយ ឃាត់កុំឲ្យចូល តែកុំធ្វើទុក្ខបុកម្នេញវាឡើយ គ្រាន់តែស្រែកឃាត់ ប៉ុណ្ណោះបានហើយ ពីព្រោះក្មេងនោះពូតែណាស់ អម្បាលអញដែល មានវិទ្ធី មានអំណាចអាចចាំងដណ្តើមយកនគរឯទៀត ។ បានមកធ្វើជា ប្រទេសរាជទាំងប៉ុន្មាន ក៏វាជាក់ជុចអញជាប់ស្ទើរតែនឹងស្ងាប់អស់រាត្រ តការ, តែពួកឯងកាលគ្នាឃាត់វាល្ងង់មើលសិនចុះ, បើវាមិនខ្លាចទេ បើក ផ្លូវឲ្យវាចូលមកចុះ" ។ យក្សបានប្រាប់គ្រប់សេនាអ្នកចាំក្មេងទ្វារទាំង៧ ជាន់សព្វគ្រប់ហើយ ក៏ចូលទៅក្នុងប្រាសាទ សំដែកលក់ស្រមុក កក្រើកប្រថពី ។ ឯបងប្អូនទាំងពីរក៏បណ្តើរគ្នាទៅនគរយក្សតាមតម្រុយ មែកឈើ, លុះបានទៅដល់ហើយក៏ជួបប្រទះនឹងពួកកងទ័ពមួយកងដែល ទៅចាំក្មេងទ្វារទី ៧ នោះ, កុមារបងបានឃើញយក្សច្រើនដល់ម្ល៉ោះ ក៏ កិតភ័យញាប់ញ័រស្ទើរនឹងបាត់ស្មារតី, ប្អូននិយាយកម្មាបងឡើងថា "នែ បងកុំញ័រចង់ពេក! ឈប់កុំចង់ចាប់គាប់ធ្វើបាបវាឡើយ ឈប់ៗ កុំៗ យើបង! ស្ទើរតែឃាត់មិនឈ្នះ ណ្តើយកុំញ័រចង់ពេក វាខ្លាចបង់ហើយ" ។ ពួកវាហានយក្ស បានពួកកុមារនិយាយដូច្នោះហើយក៏ខ្លាចរួញខ្លួន តត ហ៊ានមាត់កអ្វីសោះ បើកផ្លូវឲ្យកុមារទៅដោយស្រួល រហូតដល់ទៅទ្វារ គំរប់៧ជាន់ យក្សខ្លាចទាំងអស់ ។ ទើបនាំបងប្អូនឡើងទៅលើប្រាសាទ

យក្ស យើញយក្សកំពុងដេកស្រមុកខ្ជិលច្រាសខ្លួន យើញពួកស្រីស្នំកំពុងតែអង្គុយបក់ខាងស្តាំមួយរយ ខាងឆ្វេងមួយរយ ។ ឯបងយើញយក្សច្រើនសម្លឹមណាស់ពេក ក៏ភ័យស្លុតស្មារតី, ប្អូនស្រែកហៅយក្សថា នែ! អានេះគ្រោកឡើង អញមកដល់ហើយ ដេកដល់ណាទៀត ។ ។ យក្សព្រុសំឡេងកុមារតូចស្រែកហៅខ្លួន ដែលកំពុងដេកលក់ដូច្នោះ ក៏ភ្ញាក់ដឹងខ្លួនឡើងក្រេឡេកមើលទៅ ស្គាល់ជាក់ជាកុមារម្ចាស់ដុច ក៏តិតភ័យមហិមាស្ទុះមកម៉ឺម៉ាគ្រាបថ្វាយបង្គំកុមារតូចទាំងពីរ ហើយចាប់ពួកស្រីស្នំដែលកំពុងអង្គុយគាល់, ប្រើអាមាត្យឲ្យហៅពួកកុង្ស៊ីយ៍សេនាបតីនាម៉ឺនមុខមន្ត្រីព្រាហ្មណ៍ព្រឹទ្ធបុរោហិតបណ្ឌិតភរិ ឲ្យចូលមកខាងក្នុងបុរីយ៉ាងឆាប់រៃ។, លុះពួកពាជសេវកាមាត្យមកជួបជុំគ្នាសព្វគ្រប់ហើយ យក្សស្រែកប្រកាសថា "អ្នកពាល់គ្នាចូរគ្រាបថ្វាយបង្គំស្តេចមនុស្សទាំងពីរនេះ ហើយត្រូវគោរពគោតខ្ចាចយកចិត្តទុកដាក់ឲ្យដូចជាខ្លួនអញ, ដ្បិតអញប្រគល់ពរឲ្យស្តេចមនុស្សលោកនេះសោយហើយ, អញសូមរួចតែខ្លួនប៉ុណ្ណោះទេ, ឯអ្នកទាំងអស់នៅជាក្រោមម្លប់បុណ្យស្តេចមនុស្សលោកនេះចុះ" ។ ពួកពាជសេវកាមាត្យទាំងអស់ក៏គ្រាបថ្វាយបង្គំកុមារទាំងពីរគ្រប់ៗគ្នា តតមានរណាមួយហ៊ាននិយាយថាដូចម្តេចឡើយ ។

យក្សក៏បានរៀបចំដំណើរសេកជាឯកមង្គលប្រជុំពួកពលសេកយ៉ាងជាអនេកប្រការ ហើយប្រគល់ធីតារបស់ខ្លួនឲ្យជាមហេសី ។ ប៉ុន្តែកុមារប្អូនមិនសោយរាជ្យខ្លួនឯងទេ ឲ្យបងសោយរាជ្យវិញ ព្រោះយល់ឃើញថាបងបានចិញ្ចឹមបីបាច់ថែរក្សាខ្លួន ។ កុមារទាំងពីរសឹងទៅជាសុខសប្បាយក្នុងនគរយក្សនោះរហូតអាសន្នកាលទៅហោង ។

ចប់រឿងក្មេងកំព្រាពីរនាក់តែប៉ុណ្ណេះ

សុភាសិត

បើធ្វើអ្វីតែគ្មានក្តីគិតពិនិត្យ
ផលល្អពិតឥតអំណោយឲ្យដល់ប្រាណ,
បើធ្វើការចិត្តគិតក្លាខ្លាំងចំណាន
ផលតែងប្រាថ្នាឲ្យបានដល់សកលសុខ ។
អ្នកធំពិតប៉ុន្តែចិត្តឥតមេត្តា
ប្រមាថអ្នកតូចតាចឲ្យទល់ទុក្ខ
តែងមានថ្ងៃអស់ជោគជ័យបាត់មុខ
ទោសតាមលុកឲ្យលិចលង់អង្គុយចុន ។

លោក ម៉ុញ ដាគ្រី តំណាងរាស្ត្រ រៀបរៀង

(ត)

---

២ – ព្រហ្មញ្ញសាសនា

ព្រហ្មញ្ញសាសនា ជាសាសនាកើតកាលបរមបុរាណយូរអង្វែងលើសលែងសាសនាទាំងអស់ក្នុងលោក ចាប់កំណើតឡើងក្នុងមជ្ឈិមប្រទេស (ឥណ្ឌា) ឯណោះ ទើបផ្សាយរាយមកដល់ប្រទេសយើងជាខាងក្រោយ តែផ្សាយមកដល់មុនពុទ្ធសាសនា គឺសាសនាព្រាហ្មណ៍ ទី ១ ពុទ្ធសាសនាទី ២ ។

សាសនានេះដែលឋាននាមដូច្នេះសំគាល់សេចក្តីថា "សាសនារបស់ព្រះព្រហ្ម" ឬ "សាសនាតមកអំពីព្រះព្រហ្ម", ពួកព្រាហ្មណ៍ដែលប្រកាន់ខ្ជួនថាជាបុត្រព្រះព្រហ្ម កាន់តាប់ប្រតិបត្តិសាសនានេះទើបគេហៅថា សាសនាព្រាហ្មណ៍ ។

ពួកអ្នកកាន់សាសនាព្រាហ្មណ៍ តែងគោរពរាប់អានបូជាពួកទេពតាដែលមានបណ្តាសំគ្តិច្រើនអង្គ គឺ ព្រះព្រហ្ម, ព្រះសិវៈ (ឥសូរ), ព្រះវិស្ណុ (នារាយណ៍), ព្រះឥន្ទ, ព្រះអាទិត្យ, ព្រះចន្ទ, ព្រះអគ្គី,

ព្រះវរុណ, ព្រះវាយុ (ពាយុ), ព្រះកុវេរ, ព្រះយម, ព្រះស្កន្ទ, ព្រះកាម . . . (១) ។

ព្រះជាម្ចាស់ប្រចេតា ដែលពួកព្រាហ្មណ៍តែងគោរពរាប់អានបូជានោះ មានច្រើនជួរច្រេះក៏ពិតមែន តែដែលធំជាងគេនោះមាន ៣ គឺ: ព្រះព្រហ្ម, ព្រះសិវៈ ឧមា ព្រះវិស្ណុ ។

ព្រះព្រហ្ម

ព្រះព្រហ្ម សំដៅយកមហាព្រហ្ម មានជាយានាមនាម សរសួតី មានឫទ្ធានុភាព ៣ អង្គគឺ ព្រះទេវ្យ ១ ព្រះភូគុ ១ នាងសុន្ទរី ១ ។

លក្ខណៈរបស់ព្រះព្រហ្ម គឺមានព្រះកាយសម្បុរក្រហម, ទ្រង់ព្រះពស្ត្រស, មានព្រះភក្ត្រ ៤, ព្រះហស្តកាន់ផ្កាឈូក, គង់លើហង្សជាពាហនៈ, ទ្រង់មានញាណពិសេស អាចជ្រាបហេតុក្នុងកាលតាំងបី,

---

១— ពួកទេពតាទាំងអស់នេះ សឹងទ្រទ្រង់នូវគុណសម្បត្តិនឹងមានមុខក្រសួងផ្សេងៗគ្នា គឺ ព្រះព្រហ្មជាអ្នកបង្កើតលោក, ព្រះសិវៈ ជាអ្នកបង្កើតលោកធាតុចំផ្ទាញ់លោកផង, ព្រះវិស្ណុ ជាអ្នករក្សាលោក,ព្រះឥន្ទ្រជាម្ចាស់នៃខ្យល់ព្យុះ, ព្រះអាទិត្យជាម្ចាស់ពន្លឺភ្លើ, ព្រះចន្ទ្រជាម្ចាស់ពន្លឺត្រជាក, ព្រះអគ្គីជាមេភ្លើង, ព្រះវរុណជាមេភ្លៀង, ព្រះវាយុជាមេខ្យល់, ព្រះកុវេរជាម្ចាស់រស់សម្បត្តិ, ព្រះយមជាស្តេចសេចក្តីស្លាប់, ព្រះស្កន្ទជាស្តេចសឹក, ព្រះកាមជាស្តេចសេចក្តីស្នេហា ។ ពួកទេពតាទាំងនេះលើកលែងតែព្រះវិស្ណុ, ព្រះអគ្គី, ព្រះវាយុ នឹងព្រះកាម ៤ អង្គនេះចេញ ក្រៅពីនេះហៅថា គណទេព (ទេពធំគុំ) ពោះតែងចូលរាប់ទេវតាឥន្ទ្រជាច្រើនផងដើម្បីពិភាក្សាអំពីហេតុភេទផ្សេងៗ ។ ពួកទេពតាដែលពួកព្រាហ្មណ៍តែងនិយមរាប់អានមិនអស់ហើយត្រឹមប៉ុណ្ណេះទេ នៅមានច្រើនតទៅទៀត ។

មានអេនុភាពសំក្តិសិទ្ធិ អាចបំពេញចិត្តនៃអ្នកប្រតិត្តតាមឲ្យសំរេចប្រយោជន៍តាមត្រូវការ ។

ព្រះព្រហ្មជាបិតារបស់លោក (ជាដន្តរបស់លោក) ព្រោះគម្ពីរព្រហ្មបុរាណ័មសំដែងថា "មុនដែលនឹងកើតលោក ព្រះព្រហ្មដប់ឲ្យកើតពងមួយសិន ហៅថា "ពងព្រះព្រហ្ម" រួចហើយទ្រង់បែងភាគឲ្យកើតជាមនុស្ស ២ នាក់គឺ ប្រុស ១ ស្រី ១, ប្រុសហៅថាបុម, ស្រីហៅថាវិរជ្ញ, គូស្វាមីភរិយាពាំងនេះបានរួមរាសប្រវេណីជាមួយគ្នា កើតជាពូជពាសពេញសកលលោក" ។ ហេតុនោះបានជាពួកព្រាហ្មណ៍ប្រកាន់ពួកខ្លួនថាជាវង្សខ្ពស់បំផុត ព្រោះជាវង្សរបស់ព្រះព្រហ្ម ។

ព្រះសិវៈ

ព្រះសិវៈ: ប្រែថា "ករុណា, ក្សេមចាកទុក្ខភ័យ" កើតឡើងអំពីតំណក់លោហិតដែលស្រក់ចុះចាកចិញ្ចើមរបស់ព្រះព្រហ្ម, មានព្រះជាយានាម ។ មាកោតវតី, មានឧរស ២ អង្គគឺ ព្រះវិឃនេស នឹងព្រះកត្តិកេយ (ស្កន្ទកុមារ), មានគោឧសភឈ្មោះ នន្ទិយ ជាពាហនៈ ។ លក្ខណៈរបស់ព្រះអង្គគឺមានព្រះកាយសម្បុរស, ព្រះសុរង្គសម្បុរខៀវ, ទ្រង់ស្បែកខ្លាឃ្មុំជារាជាព្រះពស្ត្រ, មានព្រះមោលីសម្បុរលឿងកួចធ្លុះគ្នាលើព្រះសិរ, មានព្រះនេត្រ ៣ គឺពីរដូចមនុស្សធម្មតា មួយទៀតចំកណ្តាលព្រះនលាដៈ (ថ្ងាស),

មានពុកចង្កាវែងបែបព្រាហ្មណ៍, មានខាតជាសង្វារ (ជាគ្រឿងកប់ធ្មាំ), មានពិណព្រះចន្ទចាំងស្មើព្រាកៗ (ជាគ្រឿងសំគាល់កប់ខ្មៅ), មានឆ្នឹងលលាដ៍ក្បាល.. (ជាគ្រឿងសំគាល់កំល្បុយុគ), ទ្រង់អាវុធឈ្មោះចក្រ-តវី នឹងគទា (ដំបង) ព្រះខាន់ឫសរ តែសូល៍, មានកេរឈ្មោះឧមរូ; ទ្រង់សូត្រដំនាញខាងសិល្បសាស្ត្រ នឹង នាដសាស្ត្រ, ជាមហាយោគី ទ្រទ្រង់នូវអានុភាពនឹងព្រះគុណ, ឋិតនៅក្នុងវិមានលើកំពូលភ្នំកៃលាស។ ព្រះសិវៈជាបិតារបស់លោក ជាអ្នកកសាងលោក, ព្រោះមានសេចក្តីក្នុងគម្ពីរព្រាហ្មណ៍ ឈ្មោះសិវបុរាណ័ម នឹងឈ្មោះកថាសរិតសាគរ សំដែងថា: "ទ្រង់វះសាច់ភ្លៅឲ្យឈាមមួយដំណក់ស្រក់ចុះទៅក្នុងទឹក កើតខ្មៅងជាពងមួយ ហើយបែកទៅជាពីរចំហៀង, មួយចំហៀងកើតជាសូគ្រលោក មួយចំហៀងទៀតកើតជាមនុស្សលោក ទើបកើតជាបុម (បុរស). បុមនោះបង្កើតជាប្រជាបតីៗបង្កើតមនុស្សតៗមក"។

អាស្រ័យដំនឿថា ព្រះសិវៈជាបិតាលោក ទើបព្រាហ្មណ៍និកាយប្រឌិតសាងអនុស្សាវរីយទុកជាទីរលឹក គឺធ្វើរូបសិវលិង្គ (លិង្គព្រះឥសូរ) នឹងរូបទមាយោនី (យោនីនាងទមា) ទុកសម្រាប់ធ្វើពិធីសិវរាត្រី លាងហុប លាងចង្រៃទបទ្រពាំងតួង។

ព្រះវិស្ណុ

ព្រះវិស្ណុ ឬ ព្រះនារាយណ៍ មានលក្ខណៈរូបឆោមសម្បុរខ្មៅ, ព្រះហស្តប្រកែតតែពីរ តែអាចបែងចេញទៅជា ៤ ឬ ៨ ក៏បាន, ព្រះខ្លួនមានលាយលំក្ខណ៍ឆ្គងៗ ហៅថាស្រីវត្ស, ទ្រង់អាភរណៈទិព្វពណ៌លឿង, ទ្រង់សង្ខឈ្មោះបញ្ចជន្យជាអាវុធ, ចក្រឈ្មោះសុទស្សនៈ, គទាឈ្មោះកោមោទកី, ធនូឈ្មោះសារង្គ, ព្រះសែងខាន់ឈ្មោះនន្ទក, កាន់ផ្កាឈូកជាគ្រឿងសំគាល់. មានគ្រុឌជបក្សីជាពាហនៈ, ព្រះជាយានាមលក្ស្មី, មានឧរសឈ្មោះកាមទេព, ទីដែលស្ថិតនៅឈ្មោះវៃកុណ្ឋ ។

ព្រះទាំង ៣ អង្គនេះ មានគុណសម្បត្តិផ្សេងៗគ្នាគឺ ព្រះព្រហ្មជាអ្នកសាងលោក, ព្រះឥសូរជាអ្នកសាងលោកផង បំផ្លាញលោកផង, ព្រះវិស្ណុជាអ្នកជួយស្រោចស្រង់លោក ទើបមាននាមថា ហរិ "ករុណា" នារាយណ៍ "ជាដែនកើតនៃនរជន" ។

គម្ពីរត្រៃវេទ

ព្រហ្មញ្ញសាសនិកជន រមែងគោរពបូជាទេពតាដូចបាននិយាយមកហើយ នឹង ប្រតិបត្តិតាមគម្ពីរត្រៃវេទនឹងវោហារថាជាគម្ពីរធំ ។

ឯគម្ពីរត្រៃវេទនោះមាន ៣ គឺ:

๑ — គម្ពីរសាមវេទ សំដែងអំពីពិធីអារក្ខពលីកម្ម បួងសួងសូមឲ្យ ព្រះឥន្ទ្រទេវ ព្រះពាយុ ជួយអភិបាលមនុស្សលោក ឲ្យមានភ្លៀងធ្លាក់ ត្រូវតាមរដូវកាល ។

๒ — គម្ពីរអថ្ងវេទ ឬ តរុវេទ សំដែងអំពីពិធីតុស្តិ, សូមឲ្យ ព្រះវិស្វកម្ម ព្រះមារុត ព្រះព្រហ្ម ប្រទានពរឲ្យសំរេចកិច្ចខាងការហត្ថកម្ម ពាណិជ្ជកម្ម ទទឹងលាភសក្ការៈធ្វើរ ៗ តាមត្រូវការ ។

๓ — គម្ពីរយជុវេទ សំដែងអំពីពិធីយុទ្ធពលីកម្មដល់ ព្រះឥសូរ, ព្រះនារាយណ៍, ព្រះអាទិត្យ, ព្រះអគ្គី, សូមឲ្យមានវិទ្ធិតេជះ ជោគជ័យ ។

បណ្តាវេទទាំង ๓ នេះ មួយៗចែកជាពីរផ្នែកគឺ វេទឬព្រហ្ម ๑ ផ្នែក, មន្ត ๑ ផ្នែក ។ វេទ និយាយអំពីរបៀបធ្វើពលីកម្ម, មន្ត ចានដល់ពាក្យ ស្មូក (គាថា) សម្រាប់សូត្របួងសួងបន់ស្រន់ ទទឹង សរសើរព្រះ ជាម្ចាស់ ។

ព្រាហ្មណ៍ដែលកំពុងសិក្សាត្រៃវេទនេះ ហៅថា ព្រហ្មចារី "អ្នក ប្រព្រឹត្តព្រហ្ម គឺ វេទ", អ្នករៀនចេះចប់ហើយហៅថា វេទគូ "អ្នក ដល់ខ្ងួវទីបំផុតនៃវេទ" ឬ ចារគូ "អ្នកដល់ខ្ងួវត្រើយនៃវេទ" ។ ហេតុនោះ ព្រាហ្មណ៍ទើបមាន ๒ ពួក គឺ ព្រាហ្មណ៍ដោយជាតិ ๑ ព្រាហ្មណ៍ដោយគុណធម៌ ๑ ។

សេចក្តីបដិបត្តិក្នុងលទ្ធិព្រហ្មញ្ញ

អ្នកកាន់លទ្ធិនេះយល់ថា លោកធាតុនឹងវត្ថុធាតុ ធម្មជាតិទាំងអស់ក្នុងពិភពលោកនេះ សុទ្ធតែព្រះឱរសាងឡើង ហើយសុទ្ធតែមានទេពតាប្រចាំ សុទ្ធតែមានទេពតាជាម្ចាស់; ហេតុនេះ ត្រូវតែប្រតិបត្តិខ្លួនឲ្យត្រូវព្រះទ័យព្រះជាម្ចាស់នឹងពួកទេពតា ទើបមានសេចក្តីសុខចំរើន ។

ឯកិច្ចដែលត្រូវប្រតិបត្តិនោះ មាន៣យ៉ាង គឺ:

១– កិច្ចបំពេញតប:

២– ពិធីបូជាព្រះអគ្គិឬបូជាយញ្ញ

៣– ពិធីសិរីភត្តី (លាងបាប) ។

កិច្ចបំពេញតប: គឺទះមានរាងកាយឲ្យលំបាកដោយកិច្ចវត្តផ្សេងៗ មានប្រតិត្តវត្តឈរជាដើម ឲ្យតាលតែលំបាកខ្លៀបស្ងាប់ឬស្ងាប់ទៅក៏មាន ដើម្បីឲ្យក្តៅរំជួលដល់ព្រះជាម្ចាស់ ហើយទ្រង់ប្រសិទ្ធិប្រទានពរឲ្យតាមប្រាថ្នា ។

ពិធីបូជាព្រះអគ្គិ នោះបែកចេញជា ៤ គឺ បង្ហែនវេទដល់សិស្សគណ ហៅថា បូជាវេទ ១, សែនព្រេនដោយគ្រឿងសំណែនមានទំជាដើម ហៅថា បូជា . . . ១, ជុតរបស់កន្ធក់ក្តៅថ្វាយទេពតា ហៅថា បូជា . . . . ១, ឲ្យអាហារជាទាន ហៅថា បូជាសត្ត ១ ។

ពិធីសីរាត្រី សម្រាប់ប្រទេសតណ្ហៀ. គេធ្វើក្នុងខែទ្វេគង្គា ដោយគេយល់ថា ជាមេទឹកសក្តិសិទ្ធិដែលហូរចុះចាកហានសួគ៌ សម្រាប លាងដំរះបាបរបស់សត្វ ។

ពិធីនេះ ពួកព្រាហ្មណ៍ស្រុកតាកណស៊ី រៀលាយបន់នាំគ្នាទៅវត្ត ព្រាហ្មណ៍ ដែលជាទេវហាន ធ្វើកិច្ចសូត្រមន្ត ចំរើនការនា នមស្សការ ទេវរូបនឹងសិរីលិង្គ តាមប្រពៃណីរហូតអស់ពេញ. ទៀបភ្លឺ ទើបនាំគ្នាយក ភ្នមស្ពានមួយៗម្នាក់ទៅកាន់ស្ទឹងគង្គា អង្គុយជង្ហយកមកសូត្រសេក ខ្ពុ មាត់លុបលាងខ្លួនច្រើណា ហើយចុះងូតមុជទឹកលិចក្បាលអស់វារៈ៣ ដង ហើយមុជខ្ទេះយកដីមកជុះខ្លួនច្រើណា នឹង ធ្វើបរិកម្មថា "គង្គា! គង្គា!" កិច្ចប៉ុណ្ណេះ ឈ្មោះថាបានដំរះលាងបាបអស់អំពីខន្ធសន្តាន រួចហើយទើប ដង្ហឹកយកមកកាន់ទេវហានវិញ ដល់ហើយយកទឹកនោះទៅស្រោចស្រប សិរីលិង្គ ទើបត្រង់ទឹកដែលហូរចុះតាមទ្រនៃបល្ល័ង្ក ទុមាយោនី យកមក ស្រោចក្បាល ស្រលាបខ្លួនច្រើណា ធ្វើតាមសេចក្តីត្រូវការ ឈ្មោះថា បានសីរីសួស្តីដែរអស់ចង្កៃ ទុបទ្រូពាំងពួង ។

ឯកំពង់សម្រាប់ចុះងូតនោះ តាមដែលគេសម្គាល់ទុកមាន ៣ អន្លើគឺ កំពង់ព្រះព្រហ្ម ១ កំពង់ព្រះវិស្ណុ ១ កំពង់ព្រះឥស្សរ ១ ។ កំពង់ទាំង ៣ នេះ មានគុណផ្សេងៗគ្នា ស្រេចហើយតែអ្នកត្រូវការចង់ចុះងូតកំពង់

ណាក៏ចាន ។ តែងជ្រៃយស្រែកអស្ចារ្យចាន មានកំពង់មួយស័ក្តិសិទ្ធិ ជាងគេ ហៅថា "ប្រយាគ" មានប្រជុំជននិយមចុះឆ្នូតរាប់ពាន់សែន ។

សម្រាប់ស្រែកម្ពុជាដែលនៅឆ្ងាយអំពីទន្លេគង្គា, បើអ្នកណាចានទៅ ឆ្ងូតម្តង។ តែងជងយកទឹកនោះមកផ្ញើញាតិមិត្រ ឲ្យលុបលាងមុខមាត់ ស្រលាបខ្លួនច្បាណាហើយបរិកម្មថា "គង្គា! គង្គា!", សូម្បីនៅចម្ងាយ ៣០ យោជន៍ ក៏គង់រួចពាក្យបាបដែលខ្លួនចានធ្វើមក ៣ ជាតិហើយ ។

ហេតុនេះ ទើបចានជាពួកតណ្ហា. ដែលមានសទ្ធាជ្រះថ្លាខ្លាំង រៀងទៀបស្លាប់ឲ្យចានទៅស្លាប់ក្បែរទន្លេគង្គា ស្លាប់ហើយឲ្យគេដុតយកធាតុទៅគ្រែងចាចសាចចោលក្នុងទន្លេនោះ ឈ្មោះថាចានជះចាបតគ សេសសល់ ។

សម្រាប់ប្រទេសឆ្ងាយ។ ក្រៅពីប្រទេសតណ្ហា, ពិធីសិរីតែនេះ គេយកសិរីលិង្គទៅដំកល់ទុកក្នុងទីណាមួយហើយដាំសសរ ៤ ដុំរិញសិរីលិង្គ រួចយកខ្សែចងខ្លែងសសរទាំងនោះ ទើបយកក្អមប្តូរឆ្នាំងចោះទម្លុះ ហើយយកមកព្យួរនឹងខ្សែនោះប្តូចងនឹងមែកឈើក៏ចាន ហើយចាក់ទឹកក្នុងឆ្នាំងនោះ ឲ្យស្រក់ចុះមកចំលើលិង្គនោះ ដើម្បីឲ្យហូរទៅតាមបណ្តូង្គ ១មាយោន៍ ដរាបដល់អស់រាត្រីកាល. ដល់វេលាទៀបភ្លឺគេនាំគ្នាដណ្តើ ចាយ លាយដោយទឹកដោះ ទឹកឃ្មុំ ស្ករនឹងគ្រឿងទេសផ្សេង។ ដែល ចាត់ថាជាបណ្ណាការនាំគ្នាបរិភោគ ហើយទោះទឹកទន្លេឬត្រែកដំនួស

ទន្ទេគង្គា រួចហើយទើបយកទឹកសំរិលឆ្អិ ស្រោចស្រង់ខ្លួនច្រាណាវែម ទៀត កិច្ចប៉ុណ្ណោះឈ្មោះថាស្រោចកិច្ចសំរាកត្រី ។

ពិធីនេះ គេធ្វើក្នុង ១ ឆ្នាំតែម្តង ហើយបានតែកង់លោកត្រីផង ទើបហៅថា ពិធីសំរាកត្រី ។

៥ លនៃការប្រតិបត្តិក្នុងលទ្ធិព្រហ្មញ្ញ

និកាយព្រហ្មញ្ញគោរពរាប់អាន ព្រះព្រហ្ម ព្រះឥស្សរ ព្រះនារាយណ៍ ទើង ប្រព្រឹត្តតាមពាក្យប្រដៅក្នុងគម្ពីរវៃវេ ។ ផលប្រយោជន៍ក្នុងការប្រតិបត្តិមាន ២ យ៉ាងគឺ ១ – ប្រយោជន៍កង់លោកនេះ, ២ – ប្រយោជន៍កង់លោកខាងមុខ ។ ប្រយោជន៍ទី ១ សម្រាប់ពួកគ្រហស្ថ, ប្រយោជន៍ទី ២ សម្រាប់ពួកបព្វជិតដែលនឿយណាយក្នុងយសកិច្ច ហើយចេញទៅបួសជាតាបស - ឫសី ស្ទឹងស្នាធ៌ប្រព្រឹត្តតប:ផ្សេងៗក្នុងព្រៃភ្នំកំប្ច មានផ្លែឈើមើមឈើជាអាហារ ដើម្បីឲ្យបានលុះគុណវិសេសជាន់ខ្ពស់ ។

បព្វជិតដែលប្រព្រឹត្តតឹងរ៉ឹងដល់កំរិតដល់ថ្នាក់ ចាត់ថាជាអ្នកបានលុះគុណវិសេសនោះៗហើយ ចែកជា ៤ ពួកគឺ: ១ – រាជឫសី, ២ – មុនី, ៣ – មហាឫសី, ៤ – ព្រហ្មឫសី ។

សរុបយោបល់: ឫសីទាំង ៤ នេះ សឹងនៅប្រកបដោយរាគាទិក្លិសេសនៅឡើយ ព្រោះមានរឿងដំណាលថា ឫសីខ្លះមានប្រពន្ធកូន, ខ្លះញុះញង់សម្លាប់គេជាដើម កុំថាឡើយតែពួកព្រហ្មបរិសេវ្យដែលទំ

ប្រតិបត្តិដល់ថ្នាក់ត្រឹមឫស៊ីប៉ុណ្ណោះ សូម្បីព្រះព្រហ្ម ព្រះសិវៈ ព្រះវិស្ណុ ដែលគេប្រកាន់ថាជាព្រះមេលទ្ធិសាសនា ក៏សុទ្ធតែនៅមានប្រពន្ធកូន មានកំហឹង មានសេចក្តីព្យាបាទបៀតបៀនអ្នកដទៃនៅឡើយ, បើតាមសេចក្តីសង្កេតនៅឃើញថា ពួកទេពតានឹងឫស៊ីទាំងនោះនៅមានរាគៈ ទោសៈ មោហៈ ដូចបុថុជ្ជនធម្មតា ។

លទ្ធិក្រៅ ៦

កុដ្ឋសម័យពុទ្ធកាល ពាហិរសាសនាក្រៅអំពីសាសនាព្រាហ្មណ៍ នៅមានលទ្ធិដទៃៗទៀត ដែលជាលទ្ធិឧបាសន៍នឹងព្រះពុទ្ធសាសនា គឺលទ្ធិក្រៅ ៦ ។

ឯឈ្មោះគ្រូទាំង ៦ នោះ គឺបូរណកស្សប មក្ខលីគោសាល ១ និគណ្ឋនាដបុត្ត ១ សញ្ជយវេលដ្ឋបុត្ត ១ បកុទ្ធកច្ចាយន ១ អជិតកេសកម្ពល ១ ។

ប្រវត្តិរបស់គ្រូទាំង ៦ (សង្ខេប)

១ - បូរណកស្សប គ្រូនេះមានសេចក្តីដំណាលថា: មានតែកូលអ្នកមានម្នាក់ មានខ្ញីប្រុស - ស្រីចំនួន ៩៩ នាក់, ក្នុងចំណោមខ្ញីទាំងនេះ មានខ្ញីម្នាក់មានកូនប្រុសមួយទើបនឹងកើតមក រួមទាំងខ្ញីមុនផងត្រូវជា ១០០ ទើបគេកំណត់ឲ្យឈ្មោះទារកគ្រោយនេះថា បូរណៈ ប្រែថា "បំពេញ" ព្រោះបង្គ្រប់ជា ១០០ នឹងខ្ញីមុន ចាត់ថាជាខ្ញីមង្គល ។

អាស្រ័យហេតុនេះ ទោះបីខារកនោះ ធ្វើកិច្ចការអ្វីល្អក្តីអាក្រក់ក្តី ឬធ្វើក្តី
មិនធ្វើក្តី ក៏ចៅហ្វាយនាយ មិនដែលស្តីបន្ទោសសោះឡើយ ។

ថ្ងៃមួយ ខ្ញុំប្រុសនោះគិតឃើញថា "ការដែលនៅទទេៗ ដូច្នេះមិន
មានប្រយោជន៍អ្វីឡើយ", ទើបរត់ចេញចាកទីនោះទៅ, លុះរត់ទៅដួប
ប្រទះនឹងខារ ។ ដណ្តើមយកសំពត់សម្លៀកបំពាក់អស់រលីង រកអ្វីស្លៀក
មិនបាន ក៏ចូលទៅកាន់ភូមិមួយទាំងខ្លួនអាក្រាតទទេ ។ ពួកមនុស្សអ្នក
ស្រុកឃើញដូច្នោះ គិយល់ឃើញថាជាសមណៈអរហន្ត អ្នកមានសេចក្តី
ប៉ាថ្នាតិច រកបុគ្គលដទៃស្មើគ្មាន, ហើយនាំគ្នាបូជាដោយទំចំណីផ្សេងៗ។
បុរសអាក្រាតនោះឯង អាស្រ័យរឿងនេះ ទើបកើតគំនិតថ្មីឡើងថា
"លាភសក្ការៈទេយ្យវត្ថុទាំងនេះដែលកើតឡើងដល់អញ ព្រោះអាស្រ័យ
ការអាក្រាតកាយ បើដូច្នោះមិនត្រូវស្លៀកសំពត់ទេ" ម្ល៉ោះហើយចាប់
ដើមតាំងអំពីកាលនោះមក ទោះបីមានសំពត់ក៏មិនស្លៀកដណ្តប់ឡើយ
ហើយប្រកាន់យកការអាក្រាតកាយនោះថាជាកិច្ចបព្វជ្ជា ជាកេរបស់អ្នក
បួស, តមកទើបមានមនុស្សជាច្រើនរយចូលបួសក្នុងសំណាក់គ្រូនោះ ។

លទ្ធិរបស់គ្រូនេះ ជាអកិរិយវាទ (ប្រកាន់ថាមិនមានអំពើ) គឺ
ប្រកាន់ថាបុគ្គលដែលធ្វើអំពើបាបផ្សេងៗ មានការសម្លាប់សត្វ លួច
ទ្រព្យអ្នកដទៃ ធ្វើបរទារកម្ម និយាយមុសាវាទជាដើម មិនឈ្មោះថា

ធ្វើអំពើបាបទេ មិនមានបាបទេ ឥតមានទោសឡើយ ។ ហេតុនោះគ្រូនេះឈ្មោះថា អកិរិយវាទី "អ្នកពោលប្រកាន់ថាមិនមានអំពើ" ។

๒ – **មក្ខលិគោសាល** គ្រូនេះមានរឿងដំណាលថា គាត់កើតក្នុងភេន៍គោជាទាសៈរបស់ជនម្នាក់ ។ លុះធំឡើង ចៅហ្វាយបានប្រើឲ្យកាន់ឆ្នាំងខ្វាញ់ដើរកណ្តាលភ្លៀង ប្រកបដោយដីរអិលប៉ុចប៉ុច ហើយហាមប្រាម (តាមភាសាបាលី) ថា: **មា ទលិ** "ប្រយ័ត្នអិល" ថាមិនទាន់ផុតមាត់អិលដួលព្រុះ, ដោយសារសេចក្តីខ្លាចម្ចាស់ គាត់ក៏រត់ទៅបណ្តោយ, ចៅហ្វាយក៏ដេញតាមចាប់ជាយសំពត់ជាប់ គាត់ប្រឹងបំរះរបូតទៅ សំលៀកតែរាងកាយទេហើយរត់ចុតទៅ ។

ពួកមនុស្សដែលនោតលួងខ្លៅ ឃើញដូច្នោះក៏សំគាល់ថាជាព្រះអរហន្ត មានសេចក្តីជ្រះថ្លាតាម, ហើយនាំគ្នាគោរពបូជា ។ បុរសនោះអស់ស័យលាភសក្ការៈក៏ឡើងជោរ សំគាល់ខ្លួនថាជាព្រះអរហន្តមែន ហើយប្រព្រឹត្តវត្តអាក្រាតកាយនោះតមក ។

ឯលទ្ធិរបស់គ្រូនេះ ជាអហេតុកទិដ្ឋិ (ប្រកាន់ថាមិនមានហេតុបច្ច័យ) គឺប្រកាន់ថា: **នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ សង្កិ-លេសាយ** មិនមានហេតុមិនមានបច្ច័យដើម្បីញាំងសត្វឲ្យសៅហ្មង, **អហេតូ អប្បច្ចយោ សុទ្ធិយា** មិនមានហេតុមិនមានបច្ច័យដើម្បីញាំងសត្វឲ្យបរិសុទ្ធ **សត្តា សង្កិលិស្សន្តិ សុជ្ឈន្តិ** សត្វទាំងឡាយមិនមានហេតុមិនមានបច្ច័យ នាំឲ្យសៅហ្មងទេ, **នត្ថិ ហេតុ នត្ថិ បច្ចយោ**

សត្តានំ វិសុទ្ធិយា មិនមានហេតុ មិនមានបច្ច័យ ញ៉ាំងសត្វទាំង-
ឡាយឲ្យបរិសុទ្ធ, អហោសុ អប្បច្ចយា សត្តា វិសុជ្ឈន្តិ សត្វ
ទាំងឡាយមិនមានហេតុ មិនមានបច្ច័យនាំឲ្យបរិសុទ្ធ (សត្វដែលនឹង
សៅហ្មងក៏សៅហ្មងឯង, នឹងបរិសុទ្ធក៏បរិសុទ្ធឯង) ។ ហេតុនោះគ្រូនេះ
ទើបឈ្មោះថា ជាអហេតុកវាទី "អ្នកពោលប្រកាន់ថាមិនមានហេតុ" ។

๓— **និគ្គណ្ឋនាដបុត្ត** គ្រូនេះមានរឿងដំណាលថា: គាត់ជា
កូនរបស់អ្នករាំ (នាដបុត្ត) មានសេចក្តីប្រកាន់មានដើមថា: អម្ហាកំ
កណ្ឋជក្កិ លសោ ឧត្តិ យើងមិនមានកិលេសជាគ្រឿងចាក់ស្រែះ
តែម្តងទេ, កិលេសកណ្ឋាហិតា យើងប្រាសចាកគ្រឿងចាក់ស្រែះ
តែម្តងគឺកិលេសហើយ ។

ម្យ៉ាងទៀត លទ្ធិរបស់គ្រូនេះ ប្រកាន់យកការសង្រួមទាំង ៤ គឺ:
សព្វវារិវារិតោ ឃាត់ហាមទឹកទាំងពួង ๑ សព្វវារិយុត្តោ ប្រកប
ដោយទឹកទាំងពួង ๑ សព្វវារិធុតោ កំចាត់បាបដោយទឹកទាំងពួង ๑
សព្វវារិផុដោ ត្រាំត្រៃដោយទឹកទាំងពួង๑, បុគ្គលដែលប្រកបដោយ
ការសង្រួមទាំង ๔ យ៉ាងនេះឈ្មោះថា ជាអ្នកដល់នូវទីបំផុត ជាអ្នក
សង្រួម ជាអ្នករក្សាខ្លួនបានល្អ ។

គ្រូនេះជា និគ្គណ្ឋវាទី អ្នកប្រកាន់ថាខ្លួនមិនមានកិលេស មិនមាន
គ្រឿងសៅហ្មង ។

๔– สញ្ជ័យ គ្រូនេះមានសេចក្តីថា: គាត់ជាកូនអ្នកតបាញ ផែង (វេលដ្ឋបុត្ត) ទើបគេហៅថា សញ្ជ័យវេលដ្ឋបុត្ត ។

ឯលទ្ធិរបស់គ្រូនេះ ប្រកាន់អមរាវិក្ខេបទិដ្ឋិ គឺសេចក្តីយល់ប្រែបប ដោយវាចាមិនស្ទាប់, ឬសេចក្តីយល់បម្រែបម្រួលជាអនេក, សេចក្តីយល់ចាក់ បណ្តាយ, និយាយដោះខ្លួនឲ្យតែរួចមិនឲ្យគេចាប់ថ្នាក់បាន ។ បើមានគេសួរថា លោកខាងមុខមានឬមិនមាន? ពួកសត្វជាឧបបាតិកមានឬមិនមាន? ផលវិបាកនៃកម្មល្អនឹងកម្មអាក្រក់មានឬមិនមាន? ។ គាត់ឆ្លើយថា បើសេចក្តីយល់របស់ខ្ញុំថាមាន ខ្ញុំឆ្លើយថាមាន, បើមិនមាន – ថាមិនមាន, បើមានខ្លះ មិនមានខ្លះ – ថាមានខ្លះមិនមានខ្លះ, បើមានក៏មិនមែនមិនមានក៏មិនមែន – ថាមានក៏មិនមែនមិនមានក៏មិនមែន, តែសេចក្តីយល់របស់ខ្ញុំយ៉ាងនេះក៏មិនមែន យ៉ាងនោះក៏មិនមែន យ៉ាងដទៃក៏មិនមែន ថាមិនមែនក៏ទេ ថាមិនមែនទេក៏ទេដែរ ។ បើមានគេសួរថា សត្វស្ទាប់ហើយកើតទៀតឬមិនកើតទៀត? ។ គាត់ឆ្លើយថា បើសេចក្តីយល់របស់ខ្ញុំថាកើតទៀត ខ្ញុំនឹងឆ្លើយថាកើតទៀត, បើមិនកើតទៀត - ថាមិនកើតទៀត, កើតទៀតខ្លះ មិនកើតទៀតខ្លះ - ថាកើតទៀតខ្លះមិនកើតទៀតខ្លះ, កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន - ថាកើតទៀតក៏មិនមែនមិនកើតទៀតក៏មិនមែន, តែសេចក្តីយល់របស់ខ្ញុំយ៉ាងនេះក៏មិនមែន

យ៉ាងនោះក៏មិនមែន យ៉ាងដូចេ្នះក៏មិនមែន - ថាមិនមែនក៏ទេ ថាមិនមែនទេក៏មិនមែនដែរ ។

ទិដ្ឋិរបស់គ្រូនេះ ហៅថា អមរាវិក្ខេបទិដ្ឋិ "សេចក្តីយល់ប្រែកបដោយវាចាមិនស្វាប់" ឬ "សេចក្តីយល់បម្រែដូចជាអន្ទង់" ។

៥ – បកុទ្ធកប្បាយនៈ គ្រូនេះមានរឿងដំណាលថា: គាត់ជាអ្នកប៉ាំដ៏សេធមិនប្រើប្រាស់ទឹកត្រជាក់ ដោយយល់ឃើញថាមានសត្វអាស្រ័យនៅ ។ គ្រូនេះសូម្បីបន្ទោបង់ទូលាមកក្តី បរិភោគភោជនក្តី បង្ហាក់ដោយវត្តមិនស្អាតណាមួយហើយ មិនព្រមប្រើប្រាស់ធ្វើកិច្ចនោះៗ ដោយទឹកទេ កាលបើបានទឹកក្តៅឬទឹកប៉ាយរើបធ្វើកិច្ចទាំងនោះ ។ កាលបើដើរឆ្ងែសឹង ឬឆ្ងែទឹកដែលមាននៅក្នុងផ្លូវ តែងធ្វើផ្កាប់អធិដ្ឋានសិលរួចហើយទើបដើរឆ្ងែហួសទៅ ដោយយល់ឃើញថា បើមិនបានធ្វើយ៉ាងនេះនឹងជាប់សីល ។

ម្យ៉ាងទៀតគ្រូនេះយល់ថា កាយឲយ៉ាងគឺបឋវីកាយ (ពួកធាតុដី)១ អាបោកាយ (ពួកធាតុទឹក)១ តេជោកាយ (ពួកធាតុភ្លើង)១ វាយោកាយ (ពួកធាតុខ្យល់)១ សុខៈ (សេចក្តីសុខ)១ ទុក្ខៈ (សេចក្តីទុក្ខ)១ ជីវិតៈ (ជីវិត)១ គ្មានឧណាធ្វើកើតនិម្មិតបានសាងបានទេ ដាសសាវៈអារតាំងនៅមាំដូចជាកំពូលភ្នំ ឬ ដូចជាសសរគោល មិនចេះញាប់ញ័រប្រែប្រួលមិនចេះបៀតបៀនគ្នា មិនអាចធ្វើគ្នាឲ្យបានសុខ - ទុក្ខទេ (ហេតុនោះ)

បុគ្គលសម្លាប់ខ្លួនឯងក្តី ឲ្យគេសម្លាប់ក្តី ស្លាប់ខ្លួនឯងក្តី ប្រើគេឲ្យស្លាប់ក្តី ដឹងខ្លួនឯងក្តី ញុាំងអ្នកដទៃឲ្យដឹងច្បាស់ក្តី មិនមានទៅកើតកាយតាំងនោះឡើយ ទុកណាជាបុគ្គលនោះកាត់សីសៈដោយគ្រឿងសស្ត្រាដ៏មុតក៏ឈ្មោះថាគ្មានន័យណាសម្លាប់អ្នកណាទេ គ្រឿងសស្ត្រានោះគ្រាន់តែចូលទៅកាន់ចន្លោះកាយតាំង ៧ ប៉ុណ្ណោះឯង ។

គ្រូនេះជា អកិរិយវាទី "អ្នកប្រកាន់ថាមិនមានអំពើ" ។

៦ - អជិតកេសកម្ពល គ្រូនេះប្រឹក្សាតែសំពត់កម្ពលធ្វើពីសក់មនុស្ស ប្រកាន់នូវទិដ្ឋិ "សេចក្តីយល់ឃើញថាសូន្យ" គឺប្រកាន់ថា:

១ - នត្ថិ ទិន្នំ ទានដែលបុគ្គលឲ្យហើយមិនមានផល

២ - នត្ថិ យិដ្ឋំ ការបូជាធំមិនមានផល

៣ - នត្ថិ ហុតំ ការបូជាតូចមិនមានផល

៤ - នត្ថិ សុកតទុក្កដានំ កម្មានំ ផលវិបាកោ ផលវិបាកនៃកម្មដែលបុគ្គលធ្វើល្អនឹងធ្វើអាក្រក់មិនមាន

៥ - នត្ថិ អយំ លោកោ លោកនេះមិនមាន

៦ - នត្ថិ បរោ លោកោ លោកខាងមុខមិនមាន

៧ - នត្ថិ មាតា សេចក្តីប្រតិបត្តិកងមាតាមិនមានផល

៨ - នត្ថិ បិតា សេចក្តីប្រតិបត្តិកងបិតាមិនមានផល

៩ – ន ត្ថិ សត្តា ឯបថាតិកា សត្វជាឧបបាតិកមិនមាន

១០ – ន ត្ថិ លោកេ សមណ ព្រាហ្មណា សមក្ខតា សម្មាបដិបន្នា ពួកសមណនឹងព្រាហ្មណ៍ ដែលមានសេចក្តីព្រមព្រៀងគ្នា ប្រតិបត្តិដោយប្រពៃ ក្នុងលោក មិនមាន ។

មួយទៀត ប្រកាន់ថាបុរសដែលប្រកបដោយមហាភូតរូប ៤ បែកធ្លាយរាងកាយទៅហើយសូន្យគឺ: ធាតុដីទៅជាដី ធាតុទឹកទៅជាទឹក ធាតុភ្លើងទៅជាភ្លើង ធាតុខ្យល់ទៅជាខ្យល់ ឥន្ទ្រិយទាំង ៦ សាត់អណ្តែតទៅក្នុងអាកាស ឥតមានអ្វីខាងមុខអំពីសេចក្តីស្លាប់ទៅឡើយ ។

ហេតុនោះគ្រូនេះ ឈ្មោះថាជា ឧច្ឆេទវាទី "អ្នកប្រកាន់ថាសូន្យ" ។

(មានត)

ក្នុងអង្គុត្តរនិកាយ តិកនិបាត

ឃុន បណ្ណានុរក្ស ប៊ូ-ប៉ូ ពុទ្ធសាសនបណ្ឌិត្យ ប្រែរៀបរៀង

ឯស្សា ខុរប្បេតំ ឥធំ សត្តា ជេតវនេ វិហរន្តោ ឯកំ ទុស្សដ្ឋវិរិយំ កិក្កុំ អារព្ភ កថេសិ ។

សត្តា រសម្តេចព្រះបរមគ្រូកាលគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអកល់ះបង់សេចក្តីព្យាយាមមួយរូប ទើបត្រាស់សំដែងធម្មទេសនានេះ មានបទព្រះគាថាតាំងផ្តើមទុកថា ឯស្សា ខុរប្បេ ជូចេ្នះជាដើម ។

តំ ហេ សត្តា ដំណើរសេចក្តីថា សម្តេចព្រះបរមសាស្តាត្រាស់សួរភិក្ខុនោះ ដែលភិក្ខុទាំងឡាយនាំមកកាន់ពេធម្មសភាថា "ម្នាលភិក្ខុ! បានឮថា អ្នកលះបង់ចោលសេចក្តីព្យាយាមមែនឬទេ?" កាលដែលភិក្ខុនោះក្រាបទូលទទួលថាពិតមែនហើយ ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុ! អ្នកបានចូលមកបួសក្នុងសាសនាតថាគត ជាសាសនានាំឲ្យបានសម្រេចមគ្គផលពិតប្រាកដដូចេ្នះ ហេតុអ្វីក៏បានជាអ្នកលះបង់សេចក្តីព្យាយាមចោលចេញទៅវិញ, អ្នកសូមិនបាននឹងបណ្ឌិតទាំងឡាយអំពីកាលមុន ព្យាយាមធ្វើកិច្ចមិនគួរកើតសេចក្តីទុស្សាហ៍ គេក៏នៅតែមិនលះបង់សេចក្តីព្យាយាមចោលឡើយ ។ ភិក្ខុទាំងឡាយក្រាបទូលអាចនាសម្តេចព្រះមុនីនាថ ឲ្យទ្រង់ប្រកាសសេចក្តីនោះឲ្យច្បាស់លាស់ឡើង ។ ព្រះ

អង្គខើបទ្រង់សំដែងដំណាលហេតុខាងដើម ដែលកំចាំងបាត់ស្ងាត់ទៅជាយូរអង្វែងហើយនោះ ឲ្យប្សាស់ប្រាកដដូចតទៅនេះថា :

អតីតេ ពារាណសិយំ ព្រហ្មទត្តេ រជ្ជំ ការេន្តេ ។ល។

កាលកន្លងទៅជាយូរអង្វែងហើយ, គ្រាដែលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី, សម័យនោះ ព្រះបរមពោធិសត្វកើតក្នុងត្រកូលនៃបុគ្គលអ្នកក្សៃព្រៃ លុះចំរើនវ័យធំឡើងហើយ មានបុរស ៥០០ នាក់ជាបរិវារ ជាធំជាធំត្រកូលដែលក្សៃព្រៃខាំងឡាយ បានសំណាក់អាស្រ័យនៅក្នុងស្រុកក្បែរជង្រៃមួយ ជាអ្នកស៊ីឈ្នួលជួនពួកអ្នកដំណើរឲ្យឆ្លងកាត់ផុតពីជង្រៃនោះទៅ ។

អថេកស្មិំ ទិវសេ វេលាខាងក្រោយមក ក្នុងថ្ងៃមួយ សត្ថវាហបុត្ត (កូនឈ្មួញរទេះ) នៅនគរពារាណសីម្នាក់ បានបររទេះ ៥០០ ទៅដល់ស្រុកនោះហើយ ហៅព្រះពោធិសត្វមកនិយាយថា សម្ព ម្នាលសម្លាញ់ អ្នកចូរទទួលយកប្រាក់មួយរាន់រៀល ហើយសូមជួនចំឡង់ឲ្យឆ្លងកាត់ផុតអំពីជង្រៃនេះទៅផង ។ ព្រះពោធិសត្វក៏ព្រមទទួលយកប្រាក់មួយពាន់រៀលពីដៃសត្ថវាហបុត្ត, កាលដែលលោកទទួលយកថ្លៃឈ្នួលជូនហើយ លោកក៏តាំងចិត្តលែងកិតក័យលះកាត់សេចក្តីអាឡោះអាល័យស្តាយដីតិចខ្លួន ក្នុងដំណើរតាមផ្លូវប្រែកបរដោយភ័យដ៏ពន្ធឹក រួចជូនសត្ថវាហបុត្តឆ្លងកាត់ព្រៃទៅ ។

អដ្ឋវីមេ្ឍ បញ្ចសតា ចោរា ខណៈនោះ មានចោរចំនួន ๕๐๐ នាក់ បានធ្វើដំរែសម្រាប់លាក់ខ្លួនពួនសម្ងំនៅនាកណ្តាលជង្ហែព្រៃ ដើម្បីស្កាត់ប្លន់ពួករទេះ ចោរចំនួននោះបានឃើញរទេះចំនួន ๕๐๐ ចរៅជល់ដំរែខ្លួន ក៏នាំគ្នាស្ទុះចូលទៅប្លន់ ឯអ្នករទេះកាលក្រឡេកឃើញពួកចោរ ចូលមកប្លន់ខ្លួនដូច្នោះ ក៏តក់ស្លុតតក់ស្លុតក័យ នាំគ្នាប្រុះដេកក្រាបលើផ្ទៃប្រៀបពីចាំងអស់ នៅសល់តែព្រះពោធិសត្វជាមេធំម្នាក់ឯង លោកក្លែងក្លៃស្រែតសន្ធាប់ បន្ទំសំឡេងស្ទុះសីហនាទ ធ្វើអាការហាក់ដូចជាមានគ្គីគ្នាច្រើនណាស់ លោកវាយគុម្ពឈើធ្វើកំឡាឲ្យពួកចោរតក់ស្លុតអស់ទៅវិញ ទើបជួនសត្ថវាហបុត្រឲ្យឆ្ងាយផុតពីទីកន្លែងនោះទៅបានដោយសេចក្តីសុខសប្បាយគ្មានអន្តរាយអ្វីឡើយ ។

សត្ថវាហបុត្តោ បន ចំណែកខាងសត្ថវាហបុត្រ លុះបានរួចផុតពីចោរក័យទៅហើយ ក៏ដាក់រទេះឈប់នៅជំបន់មួយ អញ្ជើញព្រះពោធិសត្វឲ្យបរិភោគភោជនាហារមានឧជារសឆ្ងាញ់ពិសាផ្សេង។ ហើយបរិភោគបាយព្រឹកខ្លួនឯង កាលស្រេចភត្តកិច្ចហើយក៏អង្គុយសន្ទនានិយាយជាមួយនឹងព្រះពោធិសត្វថា សម្ម ម្ចាលសំឡាញ់ ក្នុងពេលដែលពួកចោរចំនួន ๕๐๐ នាក់ សុទ្ធតែជាអ្នកកាចយោរយៅកាន់អាវុធគ្រប់ដៃស្ទុះចូលមកកំហែងគ្រាមនឹងប្លន់រទេះនោះ ហេតុដូចម្តេចបានជា

អ្នកគ្មានសេចក្តីតិតភ័យតក់ស្លុតសោះ? ។ រួចសត្តវ៉ាហបុត្រសួរព្រះពោធិសត្វតទៅទៀត ដោយគាថាដាំបឋមថា:

ឯស្វា ខុរប្បេ ឆទុវេកទុស្សោ
ទ្វេក្តេ កបិតេ តំក្ខណោ តេលដោតេ
តស្មឹ ភយស្មឹ មរណេ ភីរុទ្បេ
កស្មាទុ តេជាវុ ឆម្ភិតត្តំ ។

(សេចក្តីថា) កាលអ្នកឃើញចោរទាំងឡាយចាញ់កូនសរដ៏ស្រួចនឹងកាន់ជាវដ៏មុត ដែលដុសខាត់ហើយដោយប្រែង, កាលមរណភ័យនោះចូលមកដល់ចំពោះមុខហើយ ហេតុដូចម្តេចបានជាអ្នកមិនតក់ស្លុតសោះ? ។

ព្រះពោធិសត្វបានស្តាប់ដូច្នោះហើយ ទើបឆ្លើយឆ្លាប់ទៅវិញដោយគាថា ២ បទថា:

ឯស្វា ខុរប្បេ ឆទុវេកទុស្សោ
ទ្វេក្តេ កបិតេ តំក្ខណោ តេលដោតេ
តស្មឹ ភយស្មឹ មរណេ ភីរុទ្បេ
វេធំ អលត្តំ វិរុលំ ខុទ្បាវំ
សោ វេធជាតោ អជ្ឈភវី អមិត្តេ
ឥធេវ មេ ជីវិតមាសិ ចត្តំ

ន ហិ ជីវិតេ អាលយំ ករុម្ហាកោ
សុរោ កយិរាសុរកិច្ចំ កទាចិ ។

(សេចក្តីថា) កាលយើងឃើញចោរគាំងឡាយចាញ់កូនសេដ្ឋីចូលនឹងកាន់ជាវដ្តមុត ដែលដុសខាត់ដោយប្រែង, កាលមរណៈភ័យនោះចូលមកដល់ចំពោះមុខហើយ យើងត្រូវបង់ជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងទៅវិញ កាលបើយើងមានសេចក្តីសោមនស្សរីករាយកើតឡើងហើយ ក៏ឃានឈ្នះសត្រូវគាំងឡាយ ព្រោះថាជីវិតរបស់យើង ។ ឃានតាំងចិត្តលះបង់ទុកពីពេលមុនជាស្រេចហើយ យើងគ្មានអាឡោះអាល័យស្តាយជីវិតសោះឡើយ; បុគ្គលអ្នកក្លាហានតែងធ្វើកិច្ចការរបស់បុគ្គលអ្នកក្លាហានក្នុងកាលខ្លះ ។

ព្រះបរមពោធិសត្វសំដែងសភាវរបស់ខ្លួន ជាអ្នកមានសេចក្តីក្លាហានមិនអាឡោះអាល័យស្តាយជីវិត ប្រាប់សត្វវាហបុត្តដូច្នោះហើយ ក៏បញ្ជូនសត្វវាហបុត្តឲ្យចេញទៅ ។ ព្រះពោធិសត្វកាលវិលមកលំនៅនៃខ្លួនវិញ ឃានធ្វើបុណ្យគាំងឡាយមានទានជាដើម ដរាបតរៀងជីវិតហើយទៅចាប់កំណើតថ្មីទៀតតាមយថាកម្ម ។

សត្ថា ឥមំ ធម្មទេសនំ អាហរិត្វា សម្តេចព្រះសម្មាសម្ពុទ្ធជាបរមគ្រូទ្រង់នាំព្រះធម៌ទេសនានេះមកសំដែងចប់ហើយ អរិយសច្ចានិ បកាសេត្វា ក៏ទ្រង់ប្រកាសអរិយសច្ចធម៌គាំង ๔ ប្រការ លុះចប់

ចតុក្កវិយសច្ចទេសនាហើយ កិកអ្នកលះបង់ចោលសេចក្តីព្យាយាមៈនោះ ក៏បានសំរេចអរហត្តផលជាផលដ៏ខ្ពស់បំផុត សម្តេចព្រះសុគត សំដែងធម្មនោះចប់ហើយ ទើបទ្រង់តម្កល់ទុនិបាតជាតកថា:

តទា អារក្កិកជេដ្ឋកោ បន ឯព្រះពោធិសត្វអ្នករក្សាជន្លៀតជាមេធំគ្រានោះ លុះអន្ទោលជាតិមក អហំ ឯវ បានជាអង្គតថាគតក្នុងគ្រានេះឯង ។

គតិរបស់រឿង

ក្នុងរឿងនេះសេចក្តីឲ្យយើញថា:

๑ — មនុស្សដែលធ្វើជាអាណាព្យាបាលលើគេ ត្រូវតែជាអ្នកមានចិត្តក្លាហាន មានអំណត់អត់ធន់ តស៊ូនឹងទុបសគ្គទាំងពួង ត្រូវតែមានគំនិតល្អិតជ្រាលជ្រៅ ត្រូវតែមានចិត្តធ្ងន់ធ្ង មិនត្រូវមានចិត្តស្រាលតប់ប្រមល់ធាប់ប្រទេាតទឹងទេ មិនត្រូវគិតប្រយោជន៍ផ្ទាល់ខ្លួនហួសប្រមាណតាល់តែខូចសាមគ្គីធម៌ទេ ។

๒ — អ្នកជាអាណាព្យាបាលគេ មិនត្រូវខ្ជិលច្រអូសទេ ត្រូវតែមានសេចក្តីព្យាយាមអង់អាចលើសគេ ។

๓ — អ្នកជាអាណាព្យាបាលគេ មិនត្រូវមើលបំណាំអ្នកតូចជាងទេ ត្រូវតែជួយទំនុកបំរុងនឹងជួយការពារអ្នកតូច ក្នុងពេលដែលមានអន្តរាយមកដល់ ។

๔— អ្នកជាអាណាព្យាបាលគេ មិនត្រូវប្រកបដោយអគតិធម៌ ๔ យ៉ាងទេ គឺ:

ក) ឆន្ទាគតិ លំអៀងព្រោះសេចក្តីស្រឡាញ់ ។

ខ) ទោសាគតិ . . . . . ស្អប់ ។

គ) ភយាគតិ . . . . . ខ្លាច ។

ឃ) មោហាគតិ . . . . . លង់ ។

ពុទ្ធជាតក ៥ច់ ។

ន បណ្ឌិតា ឥតុ ណាមាហុ ភាគ្យំ

បណ្ឌិតមិនដែលពោលពាក្យហួសហេតុទេ ។

សេចក្តីផ្តួចផ្តើមដំណាំងរបស់ពុទ្ធសាសនបណ្ឌិត្យ

សៀវភៅតាំងឡាយដែលផ្សាយចេញអំពីក្រមនេះ ជូចជាសៀវភៅ
គតិលោកប្តូនតិធម៌ជាដើមដែលជាវគ្គសៅ ហើយគាត់មានពុំបាននិពន្ធ
តុម្ពជាយូរខ្នាំមកហើយដោយទេសកាលវិបត្តិ ឥឡូវនេះបានរើបោះពុម្ព
ឡើងវិញរួចច្រើនមុខហើយ, លុះដល់ពាក់កណ្តាលឆ្នាំនេះ សៀវភៅ
គតិលោក គតិធម៌តាំងប្តូនាន ទំនងមានចរិបូណាឡើងវិញ ជូចពីដើម
មិនខាន ។

ហេតុនេះ, បើអស់លោក - អ្នកត្រូវការជាវសៀវភៅតាំងនោះ សូម
អញ្ជើញចូលទៅជាវនៅមន្ទីរពុទ្ធសាសនបណ្ឌិត្យ ១ ខន្ធែង ឬនៅចំណា-
គារអយស័យយាន (មន្ទីរលក់សៀវភៅ នាតំណាក់នេះក្តើង កុំពេញ)
១ ខន្ធែងទៀត ។

ចំណែកអស់លោក - អ្នកនៅស្រុកស្រែ បើត្រូវការជាវ សូមផ្ញើ
សំបុត្រទៅពុទ្ធសាសនបណ្ឌិត្យ ។ ទំនងជាត់ចែងផ្ញើមកជូនក្នុងដល់ទីលំនៅ
របស់លោក-អ្នក ជាពុំខាន ។

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀម ភក្សារសាស្ត្រ ប្រោះពុទ្ធផ្សាយ
អំពីពុទ្ធសាសនខេមរិន្ទ

បណ្ណាធិការ ផ្នែកភក្សារសាស្ត្រ: លោក ភ័ឃ - ប៊ុក
ក្រមការ នៅពុទ្ធសាសនខេមរិន្ទ
បណ្ណាធិការ ផ្នែកសាសនា: ព្រះទេវាសន្ត សួរ - ហាយ
ក្រុមដំនុំព្រះធ្លៃចំងាក នៅពុទ្ធសាសនខេមរិន្ទ

ផ្នែកភក្សារសាស្ត្រ	មាតិកា	ទំព័រ
លោក ភ័ឃ-ប៊ុក ក្រមការ	សុភាសិតអង់គ្លេស (ត-ចប់)	២៤១
ក្រុមដំនុំទំនៀមទម្លាប់ស្រុកខ្មែរ	ដំណែនៃការប្រែប្រួលទំនៀមទម្លាប់	២៥០
អ្នកឧកញ៉ាទេពីទូរ ឈឹម-ក្រសេម	ព្រះរាជពង្សាវតារភោគទី២ សម័យនគរធំ (តមក)	២៥៣
ាវិបុលរាជសេនា ខូ-ពត	រឿងសាមក្កុក (តមក)	២៦៣
ព្រះឃ្លាំង ឧង	រឿងភោគកុលកុមារ (តចប់)	២៧៣
ប - ប៊ុក ក្រមការ	ប្រវត្តិសាស្ត្រនៃស៊ីវិល្ហៃខ្មែរសម័យបុរាណ	២៨៣

សាសនា		
ញ-ឆាំត្រី	ពុទ្ធសាសនានិងតាហ៊ារសាសនា (តមក) ...	២៧៩
សមាគមចំណេះសាលាបាលី	តំណើបុណ្យប្រែនេនង្គាន់ចំពោះសិស្សដែលប្រឡង ជាប់សញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ឆ្នាំ ១៩៥១	២៧៨
ក្រសួងធម្មការ	បៅអធិការដែលទើបតាំងថ្មី (តមក)	៣១៨

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		page
M. Ray-Buc Kramakar (I.B.) Commission des mœures et Coutumes.	Proverbes anglais (suite et fin)	241
	Annonce de concours	250
Neak Oknha Debabidura Chhim-Krasem	Histoire du Royaume du Cambodge (suite)	253
Néak oknha Vibularaja-séna Nou-Kân	Histoire de Samkok (suite)	263
Neak oknha Brah khleang Nong M. Ray-Buc Kramakar (I. B.)	Bhogakulakumara (suite et fin) ...	273
	Histoire de l'anciene civilisation khmère de M. Georges Coedes (traduction)	283

Partie religieuse:

M. Ménh-Nakry	Le Bouddhisme et les autres religions (suite)	288
Association des Amis de l'Ecole de Pali	Gérémonie de distribution des prix (Offrandes) aux lauréats de l'examen de l'Ecole Supérieur de Pali	298
Ministère des Cultes	Nomination des nouveaux Chau-Adhikar (suite)	318

22e Année: No 4mois d' Avril 1950 — Prix d'abonnement: 145$00 par an.

1952 (4)

សុភាសិត អង់គ្លេស

លោកវ៉ាយ - ប៊ុក ក្រមការ ប្រៀបធៀង

ឃុនសុវត្ថិវេទី យូរ - អ៊ុន ពិនិត្យកែ

(ត្រង់)

---

៣០ – វេលាជាគ្រូតែឲ្យ ដែលមានតាំងជាពេជ្ឈឃាត ព្រមតាំងជាអ្នកឧបត្ថម្ភក៏យើង ក៏ថាបាន ។

" គាល់វេលាជាគ្រូតែឲ្យមានតំលៃភាព
ប្រាជ្ញគួរផ្ទាប់ចាំវេលាសម្ងាប់យើង
តាំងរក្សាខ្លួនដ៏រឹតឲ្យប្លុំប្លើង
ដូច្នេះយើងត្រូវត្បាយាមត្រង់វេលា " ។

៣១ – ថ្ងៃនេះល្អជាងថ្ងៃស្អែក, ប្លុងថ្ងៃខានស្អែក ។

"ថ្ងៃនេះត្រូវធ្វើ កុំគិតស្អាក់ស្ទើរ ត្បាយាមតាំមួន កុំទុកដល់ស្អែក
ច្រើនប្រែធតាមក្រួន ថ្ងៃនេះថែងួន គាប់ជួនសម្រេច " ។

៣២ – ត្រៃកាថ្ងៃបន្តិចឲ្យតែធ្វើ ប្រសើរជាងត្រៃកាតំព្រលឹម ដែលលះបង់ចោលការងារ ។

" ត្រៃកាថ្ងៃបន្តិចត្បាយាមការ ហៅជនសោកាប្រសើរឯក
បើត្រៃកាបច្ចុសសម័យបែក តែគ្មានលើកែពុំប្រសើរ " ។

៣៣ — អ្នកក្លាហានតាំងខ្លួនជាម្ចាស់ផែនដីចាំនាន លុះត្រាតែខ្លួនប្រកបដោយសេចក្តីវិនិច្ឆ័យ ព្រមទាំងមានពួកវិសេសឡាយផង ។

អែលែស្តៈម៉ូរិត - អារន្តង់

"ធ្វើម្ចាស់ផែនដី កបអង្គសួស្តី ក្លាហានច្បាស់ ព្រះទ័យវិនិច្ឆ័យ
និស្ស័យរាជា ជួយជាតិសាសនា មេត្តាសព្វសត្វ" ។

៣៤ — អ្នកឆ្លៀវឆ្លៀបដូចនាឡិកាគ្មានខ្ទេចវែងខ្លី ទោះបីនាឡិកានោះដើរឬឈប់ក៏គ្មានប្រើការអ្វីបានឡើយ ។

"អ្នកឆ្លៀវធ្វើការមិនខ្ជាប់ខ្ជួនខ្លួន
លោកទុកជានាឡិកាគ្មានខ្ទេចខ្ទី
ទោះបីដើរឬមិនដើរឈប់បន្តិច
ផលនៃកិច្ចគ្មានសេចក្តីប្រយោជន៍ឡើយ" ។

៣៥ — មានតែមនុស្សដែលស្មាប់ហ៊ីយរេ ទើបត្រូវការសម្រាកកំឡាំង ។

ការលំ

"ណាមនុស្សរេមិនស្មាប់ត្រូវធ្វើការ
មិនគួរពាក់ព័ន្ធសម្រាកផ្ទាក់ការណ៍ឡើយ
កិច្ចដែលខ្លួនគប្បីធ្វើកន្លះលោតិយ
ទើបមេត្រីនៃជនជាន់ក្រោយគោរព" ។

៣៦ — ការលំនៅកន្លះបម្រាមវិញ ត្រូវនិយាយលក់លើត្រែដែលមានផ្ទាំ

កុលាបល្អស្រស់ ល្អរដល់បច្ចឹមរយៈដែលរូបកាយចាស់ជរាពុតូលភាព
ត្រូវសម្រាកកំឡាំងលើគ្រែដែលប្រកបដោយបន្ទា ។

ការល្អ

"បបឹមវ័យនៃប្រុសស្រីកន្លងលោភា
កន្លងលោភយតែងប្រាថ្នាល្បែងសម្រស់
ល្បែងសម្រែបនាំក្តីនចិត្តវង្វែងអស់
វង្វែងនុបតែរបស់បញ្ឆោតភាម ។
ជនបច្ចឹមវ័យវុឌ្ឍភាយទ្រុឌទ្រោម
កាយទ្រុឌទ្រោំទើបទំលោមចិត្តឲ្យតាម
ឲ្យទំតោងទៅធម៌ជាប់ដឹតជាម
ជាប់ដឹតដោយគ្រោយរូបនាមទៅបរលោក" ។

៣៧.- ត្រូវចាប់ធ្វើការលំបាកជាមុនសិន សឹមកេការងាយធ្វើជា
ខាងក្រោយ ។

ហោរបែរក្នុងរឿង
(English Poet)

ត្រូវនឹងសុភាសិតខ្មែរថា: គិតក្តីកុំគិតងាយ ការសម្ងាយជាកំពេល។
"ការរៀនការរក ការគិតលេលក ប្តូកិច្ចជនៃ ត្រូវធ្លើមចាប់ធ្វើ
ការលំបាកកៃក្រែ មុនស្រែចហើយវៃ សឹមធ្វើការងាយ" ។

៣៨— សេចក្តីខ្វិលគឺការរស់នៅដោយឥតផល ប្រៀបដូចរុក្ខជាតិ
ដែលមានដើមខ្ពស់ហើយគ្មានផ្លែ ជារុក្ខជាតិឥតប្រយោជន៍ ។

ហ្គូស្សេរាល្អក្នុងរឿង
(M. S. Sermon)

"ហៃកូនចៅប្រុសស្រី ចូរលះក្តីខ្ជិលអូសខ្ជិល
នៅស្ងៀមចិត្តមន្ទិល ពាលខ្ជិចខិលចេញទៅក៏" ។
អ្នកខ្ជិលដូចរុក្ខជាតិ ធំតែមានគ្មានផ្លែផ្កា
ឬដូចសួនបុប្ផា គ្មានគន្ធាក្លិនពិដោរ" ។

៣៩— មិនមានឧសចណាអាចរក្សាភោគគឹការប្រើពេលខ្ជុស ឲ្យ
សរសៃយ៉ាងបានទេ, មិនមានបុគ្គលណាអាចតែប្រែពេលដែលខ្ជិចខ្ជៅ
ហើយ ដោយសេចក្តីខ្ជិលច្រអូសបានឡើយ. ការបណ្តាយចិត្តឲ្យកង្វល់
កង្វាអារម្មណ៍ជាអនេកប្រការ រមែងឲ្យទោសដល់អាត្មាជាយ៉ាងធ្ងន់ក្រៃ
លែង ជាទោសនៃដាននៃញាណរបស់ខ្លួនដែលកម្រនឹងដឹងបាន ឬកម្រ
នឹងតាញបាន ។

ស៊ែ អាប៊ីយដ៍រ៉ៃ

"ប្រែពេលខ្ជុសតែងខ្ជិចឲ្យបង់យសស័ក្តិ
ធ្វើបណ្តោកចក្រចាក់ពុំរលើមិនបានឡើយ,
ឃុតក្តីខ្ជិលទៅតែប្រែពេលខ្ជុសហើយ
មិនដល់គ្រឹយនៃក្តីសុខសម្បាន្តទេ, ។

ការបំណាយឲ្យចិត្តខ្វល់អារម្មណ៍ផ្សេង
ទោសកន្ទេរកែវលែងជាន់វិញ្ញាណវេ
លឿនលយទៅគេមិនដាយគាញ់បានទេ,
ច្នេះគួរតែលះអកុសល ៣ ខេះចេញ" ។

៤០ – ទោះបីមនុស្សខ្ជិលមានប្រាថ្នាចង់ទៅកាន់ស្ថានសួគ៌ក៏
ទៅតាមិនភ្លាមគ្រាប្រាសាទមិនឲ្យចូលទៅបាន ។

"អ្នកខ្ជិលខ្ពើព្រះព្រហ្មស្អប់ បើចិត្តប្រាថ្នាចង់ទៅកាន់
ស្ថានសួគ៌ក៏ទេពយក្សកុម្ភ័ណ្ឌ បិទខ្ទប់ស៊ីមាប្រាថ្នាប្រាសាទ, ។
ខ្ជិលដូចចោរដនចូលកូនស្រុក ធ្លើមនុស្សព្រួយខ្លុតត់ព្រាងព្រាត
ខ្ជិលនាំឲ្យចិត្តមិនស្អាងស្អាត ស្អាងតែអំពើគ្រាតដែលវង់គ្រោះ" ។

(១) ខ្ជិលល្ងង់ ងងឹត
បេះពិត ភ្លឺ
ល្ងង់ខ្លៅ ឈឺ
ឥតដឹម្ដី ប្រាជ្ញ ។
ខ្លាចត្រីន ល្ងង់
បេះខ្ចង់ ហ៊ាន
មានប្រាជ្ញា ខន់
ខុដិន វង់ ។

---

១ សុភាសិតរបស់ឃុនសុវត្ថិវេទី យួរ-អ៊ុន ។

រហ័សរឹង ចេះ

យឺតផ្អែះ លូង

អ្នកប្រាជ្ញ ធ្លិតធ្លង់

អ្នកលូង់ គំរក់ ។

๔๑ — កិត្តិយសទៅត្រង់ធ្វើការដោយសុចរិត ។

ក្រូវែរ ភ្ញីលង់ដ៍

"ធ្វើការសុចរិត ចេញចាកឯងឹត អាកាស្វាងសែង សុចរិតឲ្យសុខ
សុចរិតចាំងចែង សុចរិតភ្លឺខែង យសស្គែងមកដល់ ។

๔๒ — ព្រះអាទិត្យបញ្ចាំងរស្មីទៅកាន់ពពកដែលឯងឹតអ័ព្ទដូច
ម្តេចមិញ កិត្តិយសបំភ្លឺនូវខុបនិស្ស័យដែលពុំឲ្យលាតចេញកំដូច្នោះ
ឯង (សេចក្តីឯងឹតនៃមេឃ រមែងចាំងសុរ្យសែង, និស្ស័យដ៏លាមក
រមែងបិទចាំងមិនឲ្យមានកិត្តិយស) ។

ក្នុងរឿង «Taming of the Shreuv»

"ព្រះសុរិយា បញ្ចាំងមេឃា ឲ្យភ្លឺស្រឡះ ដូចកិត្តិយស បំភ្លឺ
ឲ្យច្បាស់ និស្ស័យចោកណាស់ នៃមនុស្សក្នុងលោក" ។

๔๓ — ក្នុងការដឹកអណ្តូងរ៉ែគឺកិត្តិយសនេះ សូមឲ្យខ្ញុំខំព្យាយាម
ចុះ ខ្ញុំប្រឹងប្រែងធ្វើដីរឹតខ្ញុំឲ្យបានត្រឹមត្រង់ ហើយខ្ញុំសូមរណារដោយ
ការបានបំពេញកិច្ចនេះ ។

កិត្តិយសជាអណ្តូងអ្នកធ្វើការ
ជាតិបុប្ផារីកវុឌ្ឍរឿងតាមសុរិយៈ
កាន់ទុក្ខវិតជាសំអុយតាលមានៈ
សុចរិតជាក់ជាំលំអបណ្តិតថ្លៃ" ។

៤៤ – អ្នកដែលមិនធ្លាប់ហាត់លើកចិត្តឲ្យខ្ពស់ហួសផុតការប្រទូសពាយ រមែងបរាជ័យចាញ់ខ្លួនឯង ។

តារល្ប

" ការខឹងព្យាបាទប្រទូសពាយ នាំចិត្តក្រហាយក្តៅខ្លោចផ្សា
ច្នេះត្រូវមានខន្តីមេត្តា ជាអលង្ការទើបសាន្តសុខ" ។

៤៥ – ចិត្តចងគំនុំព្យាបាទ គឺការបង្អោនខ្លួនឲ្យស្មើនឹងស្មារបស់បច្ចាមិត្ត, ការដែលរំងាប់ខ្លួនសេចក្តីអាឃាតនេះបាន គឺសួយខ្លួនឯងឲ្យបានដល់ស្ថានខ្ពស់បំផុត ។

លរង៉ាយកុង

" ចិត្តព្យាបាទគឺបន្ទាបឲ្យស្មើស្មា
នៃជនណាជាសត្រូវមកនឹងខ្លួន,
ការសួនចិត្តមិនផ្តេកផ្តិតអាឃាតមួន
គឺលើកខ្លួនឲ្យខ្ពស់ផុតពីសត្រូវ" ។

៤៦ – កុំស្មានថាជុតក្លឹងត្រង់ជើងក្រានក្នុងគុក ឲ្យក្លឹងនេះ

ធាបដល់បច្ចាមិត្ត តែមិនប្រយ័ត្នក្លែងនោះនឹងភាលវិលត្រឡប់មកនេះ
ឯអាត្មាឯងវិញ ។

ស្នាក់ស្សប៉ែន

" ខឹងចំពោះអ្នកឯងខ្លែតែបុកវុក
ធ្លើខោសទុក្ខដល់កូនចៅផៅសន្ដាន
ឈ្មោះថាដុតឲ្យនេះដាលក្លែងដើងក្រាន
បើពុំមានប្រាណប្រុងនេះខ្លោចអង្គ" ។

៤៧ — អ្នកដែលចងព្យាបាទគេ ប្រៀបដូចជាដុតដំបៅឲ្យគំខ្ទុះ ។

លរង់ជាកុង .

" ដុតដំបៅ ចេញខ្ទុះ
ដុតខ្ទុស ចេញក្លិន
ដុតចំបើង នេះត្រៃច
ដុតសាច់ រលាកប្រាណ" ។

៤៨ — សភាពស្អប់ខ្ពើមតែងអាស្រ័យនៅក្នុងវិញ្ញាណដ៏ខន់ពាប ។

" អ្នកកំព្រាត្រូវរស់ស្អប់អ្នកមាន
អ្នកប្រាជ្ញជាទីស្អប់នៃអ្នកល្ងង់
អ្នកទុច្ចរិតតែងស្អប់អ្នកវិសុទ្ធអង្គ
ក្មេងពាលតង្ស្យតែងស្អប់ខ្ពើមចាស់ព្រឹទ្ធា ។

๘๙ – អ្នកតូចច្រែនមានទោមនស្សស្អប់ខ្ពើម, អ្នកធំច្រែនមានចិត្ត
មេត្តាករុណា ។

"អ្នកបុណ្យតូចច្រែនស្អប់ខ្ពើមច្រែនទោមនស្ស
ពាលដូចតាស់មានពិសពុលស្នេហ៍ព្យាបាទ
មន្ទិធំជាតិបណ្ឌិតចេះច្រៀវធ្លាត
ច្រែនចិត្តស្អាតមានមេត្តាដល់ពួកជន" ។

๙๐ – អ្នកណាព្រោះពូជវុក្កា ជិសតើល (thistles)
ត្រូវច្រូតកាត់បង្ខារបស់ពាចេញ ។

" ព្រោះស្មៅបានស្មៅ ព្រោះឱ្លឹលបានឱ្លៅ ព្រោះរៀនបានប្រាជ្ញ
ព្រោះល្អបានល្អ ព្រោះពាលបានកាច ព្រោះសុតបានខ្លាច
ព្រោះកាចបានទុក្ខ" ។

๙๑ – សត្វលាដែលចង់ចាត់កំពែង រមែងវិលមកចាត់ខ្លួនឯងវិញ ។

"កុំធ្វើការហួសគំនិតផុតនិស្ស័យ
ត្រូវសូន្យវិស្សវៃឲ្យសមហេតុជ្រៅពាក់
បើខ្លួនឯងមិនត្រូវគុបមេឃប្តូយក្ស
ម៉ងហួសថាក់ពាជាក់ខ្លួនថោកក្តីរឿយ" ។

ចប់

ផលនៃការប្រឡងធំទៀមទម្លាប់

របស់

ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ

ក្នុងឆមាសដើមឆ្នាំ ១៩៤៩ ក្រុមជំនុំទំនៀមទម្លាប់ស្រុកខ្មែរ បានប្រកាសការប្រឡងទំនៀមទម្លាប់ស្រុកខ្មែរ ២ រឿង គឺ: សាវតារវត្ត និងប្រយោជន៍រុក្ខជាត ដល់មហាជនជាតិខ្មែរទូទៅក្នុងកម្ពុជរដ្ឋទាំងមូល ដើម្បីប្រមូលក្បួនខ្នាតដែលទាក់ទងដោយទំនៀមទម្លាប់ផ្សេងៗរបស់ខ្មែរ ។ ផលនៃការប្រឡងនោះ ក្រុមជំនុំបានទទួលសំណុំរឿងជាច្រើន អំពីបេក្ខជនច្រើនរូប, ផ្នែកខាងបព្វជិត ជាភិក្ខុក៏មាន សាមណេរក៏មាន, ផ្នែកខាងគ្រហស្ថជាបុរសក៏មាន ស្ត្រីក៏មាន ។ បណ្តារឿងប្រឡងទាំងនោះ មានរឿងល្អៗជាច្រើន ដែលមានបញ្ជាក់ដើមកំណើត និងក្បួនខ្នាតផ្សេងៗ ។ ក្រុមជំនុំបានជួបជុំពិនិត្យសម្រេច ឲ្យសំណុំ ១០ រឿងរបស់បេក្ខជន ១០ រូប ជាប់លេខជា ៣ ថ្នាក់ រង្វាន់ជា ៣ ផ្នែក ដូចតទៅនេះ ។

រង្វាន់សាវតារវត្ត

ក) រង្វាន់លេខ ១ (១០០រ,០០) សាវតារវត្តវិហារទីទួម ឃុំស្លួង ស្រុកស្លួងឃ្មុំ ខេត្តកំពង់ចាម របស់ឧកញ៉ា កែវ-ហាន់ ចាងហ្វាងអន់រ៉ាំត្រែត នៅឃុំ-ស្រុក-ខេត្តនោះ ។

ខ) រង្វាន់លេខ ១ (១០០រ,០០) សាវតារវត្តចានយ ឃុំអង្គ្រីញ ស្រុកវៃពែកប្បាស ខែត្រតាកែវ របស់លោក ឆួង-អ៊ួច អាចារ្យវត្តនោះ ។

គ) រង្វាន់លេខ ២ (៨០រ,០០) សាវតារវត្តអង្គរសៃ នៅលើកំ-ពូលភ្នំព្រះពជ្រឥន្ទ្រ ស្រុកឧត្តុង្គ ខែត្រកណ្តាល របស់អ្នកអង្គម្ចាស់ខ្សត្រី ខេមរ៉ាត្តម-សុខាន្តារី ធ្វើការនៅក្រសួងព្រះសាសនបណ្ឌិត្យ ភ្នំពេញ ។

ឃ) រង្វាន់លេខ ៣ (៦០រ,០០) សាវតារវត្តកំពង់ជាចិនាពាម ឃុំ ពោធិ៍ ស្រុកកំពង់លែង ខែត្រកំពង់ឆ្នាំង របស់ព្រះវិនៃយធរគណ ចៅអធិការវត្តនោះ ។

ង) រង្វាន់លេខ ៣ (៦០រ,០០) សាវតារវត្តកែវនព្វរង្សី ហៅវត្តកោ នៅឃុំលួស ស្រុកសូទ្រនិគម ខែត្រសៀមរាប របស់ព្រះមហា គុយ-ហួត សិស្សសាលាចាលីជាន់ខ្ពស់ គង់វត្តលង្កា ភ្នំពេញ ។

រង្វាន់ប្រយោជន៍រុក្ខជាត

ច) រង្វាន់លេខ ១ (១០០រ,០០) រុក្ខជាត ៨ ចំពូកមានត្រស់ជា ដើម របស់ព្រះវិនៃយធរគណ ឯក-ញឹម ចៅអធិការវត្តធម្មិស្សរពាម ស្រុកសូទ្រនិគម ខែត្រសៀមរាប ។

ឆ) រង្វាន់លេខ ២ (៨០រ,០០) ក្រូចសើច របស់ព្រះមហា ព្រាប-ឌឹប សិស្សសាលាចាលីជាន់ខ្ពស់ គង់វត្តលង្កា ភ្នំពេញ ។

ជ) រង្វាន់លេខ ២ (៥០រ,០០) ស្វាយ របស់ សោម-សុខ ហៅ ចន្ធូ-សុខ ឃុំប្រសូត ស្រុកស្វាយទាប ខែត្រស្វាយរៀង ។

ឈ) រង្វាន់លេខ ៣ (៦០រ,០០) ដូងនឹងស្វា របស់ព្រមហាលី-គា សិស្សសាលាបាលីជាន់ខ្ពស់ គង់វត្តឧណ្ណាលោម. ភ្នំពេញ ។

ញ) រង្វាន់លេខ ៣ (៦០រ,០០) ត្នោត របស់លោកគ្រូអាចារ្យ ខាន់ វត្តបុប្ផាសុវណ្ណ ឃុំអន្ទង់ត្នោត ស្រុកកែគរ ខែត្រពោធិ៍សាត់ ។

ក្រុមដំទុំទំនៀមទម្លាប់ស្រុកខ្មែរ

សូមជូនដំណឹងជាមុន

សារវិតារវត្តនឹងប្រយោជន៍រក្ខាជារបស់ លោក-អ្នក ដែលប្រឡងជាប់ទាំងនោះ យើងនឹងបុះផ្សាយឆ្លងក្នុងកម្ពុជសុរិយានេះ តអំពីសៀវភៅក្បាលនេះទៅពុំខាន ។

ភាគទី ២

សម័យនគរធំ

អ្នកនិពន្ធ ញ៉ោះ តាំងខូរ ឈឹម-គ្រសម រៀបរៀង

(តទៅ)

ព្រះចាន្ទយសោវរ្ម័នទី ១

ព.ស. ១៤៣២ - ១៤៥៤ គ.ស. ៨៨៩ - ៩១១

កាលព្រះបាទឥន្ទ្រវរ្ម័នទ្រង់សោយទិវង្គតហើយ ព្រះចាន្ទយសោវរ្ម័នជារដ្ឋទាយាទ ចានឡើងគ្រងរាជសម្បត្តិស្នងរាជបិតាតមក តាំងអំពីនៅកុមារ, ស្តេចគង់នៅគ្រងហរិហរាល័យ, ទ្រង់មានព្រះអគ្គមហេសី ព្រះនាម យសោធរាទេវី (?) មានព្រះរាជនុសវដែលប្រាកដព្រះនាម ២ អង្គ គឺព្រះហសិវរ្ម័ន ១ ព្រះគ្គសាណវរ្ម័ន ១ ។

ព្រះគុណសម្បត្តិនឹងព្រះតេជៈបារមី: កន្លងរជ្ជកាលនេះ មានសិលាចារឹក និយាយទាក់ទាមដោយប្រវត្តិសាស្ត្រច្រើនជាងរជ្ជកាលដទៃទៀតទាំងអស់ ។ សិលាចារឹកនៅបន្ទាយក្តី មានសេចក្តីនិយាយសរសើរព្រះបារមីព្រះបាទឥន្ទ្រវរ្ម័នទី ១ ព្រះបាទយសោវរ្ម័នទី ១ នឹង ព្រះបាទហសិវរ្ម័ន ។ និយាយចំពោះព្រះបាទយសោវរ្ម័ននេះថា: កាលនៅកុមារទ្រង់បានសិក្សាសិល្បវិជ្ជាការទាំងពួង តាំងផ្នែកគ្រប់គ្រងទាំងផ្នែក

សាសនា ក្នុងសំណាក់ពជបុរោហិតឈ្មោះវាមសិវៈ (ទីនឹកក្នុងសំណាក់អាចារ្យជាខ្មែរទៀត) ទ្រង់ប្រកបដោយព្រះគុណសម្បត្តិ ទីនឹងព្រះតេជៈ ប្រមើយ៉ាងអស្ចារ្យ គឺទ្រង់មានព្រះតេជៈនឹងឫទ្ធិក្លាហានហាក់ដូចព្រះអាទិត្យ, ទ្រង់មានព្រះពលានុភាពហាក់ដូចព្រះចន្ទ្រពេញបូណ៌មី មានព្រះរូបល្អហាក់ដូចទេវតា (បេ), ព្រះអង្គជាអ្នកខ្លាំងពូកែក្នុងផ្លូវសឹកសង្គ្រាម តាលតែប្រកបដោយព្រះកិត្តិយសជាក្សត្រិយ៍សឹងដំឯក ដោយទ្រង់ប៉ុនណាស់ក្នុងផ្លូវប្រើអាវុធ គឺទ្រង់អាចយឹតព្រះគៅទ័ណ្ឌ (ធនូ) ដោយព្រះហស្តម្ខាង ជាខាងស្តាំឬខាងឆ្វេងក៏ដោយ ហើយអាចបាញ់ទៅបានដោយងាយ, ទ្រង់មានព្រះកាយពលខ្លាំងមហិមា រោចតស៊ូនឹងដំរីសារដ៏សាហាវ ដោយព្រះខ្នែងដៃលកាន់ខ្លួ ព្រមហស្តបានដោយងាយ, ទ្រង់អាចតស៊ូនឹងអ្នកចំបាប់ដ៏ខ្លាំងពូកែមានចំនួនទាំង ១០ នាក់ ឲ្យដួលខ្លែលទៅបាន, ទ្រង់មានព្រះប្រីជាឆ្លាតពាក់ព័ន្ធជាងគេបង្អស់ គឺទ្រង់ដំនាញក្នុងសិល្បៈគុំយោគ្គតន្ត្រី (ក្បួនភ្លេង) នឹងនាដសាស្ត្រ (ក្បួនរបាំរាំ) ព្រះអង្គជាអ្នកប្រាជ្ញក្នុងផ្លូវបរមត្ថ – ប្រជានឹងអក្សរសាស្ត្រយ៉ាងជ្រាលជ្រៅ, ទ្រង់បានទិញន្ធក្បួនវេយ្យាករណ៍ នឹង តែងសេចក្តីអធិប្បាយក្នុងមហាភាព្យរបស់បតញ្ជលី[1] ជាដើម ។

---

១ ជាឈ្មោះអ្នកប្រាជ្ញពាលីង្គ ១ ឧ.ក ។

ការផែនដី: ព្រះចៅទយសោរ៉ែនជារដ្ឋបុរស ១ ដែលមានព្រះសមត្ថភាពខាងព្រះទុត្តមគតិយ៉ាងខ្លាំង កាលទ្រង់បានឡើងគ្រងព្រះនគរដែលហើយ ក៏មានព្រះរាជបំណងយ៉ាងខ្លាំងដើម្បីផ្គត់ផ្គង់ព្រះរាជអាណាចក្ររបស់ព្រះអង្គ ឲ្យគង់នៅជាមហាប្រទេសដូចដើមរៀងទៅ ប៉ុន្តែឲ្យមានតំណែលផ្សាយធំទូលាយជាងមុននេះទៅទៀត, តែជាធម្មតា កាលបើមានរដ្ឋបុរសបែបនេះកើតឡើង ច្រើនតែមានទុបស័គ្គផ្សេងៗ មកជំទាស់ដោយអំណាចសេចក្តីប្រាថ្នាល់ខ្លួន ។ មែនពិត ព្រះចៅទយសោរ៉ែននេះ សូម្បីព្រះអង្គមានព្រះសមត្ថភាព និងព្រះទុត្តមគតិយ៉ាងនេះក៏ដោយ ក្រោយដែលព្រះអង្គបានឡើងគ្រងពិភពហើយ ក៏មានពួកព្រះរាជវង្សក្នុងព្រះចៅទវិស្ណុលោក (ជយវ៉ែនទី ៣) ក្បត់ផែនដី ដើម្បីដណ្តើមរាជបល្ល័ង្ក មានមេទ័ពឈ្មោះ ចារគារសុសមរ៉ុត្តិ (?) ជាអ្នកជំនួយផង ។ គ្រានោះ ព្រះចៅទយសោរ៉ែនមហាវីរៈជ ទ្រង់ក៏រួបរួមសេនាមហាន បានសមគួរហើយ ស្តេចនាំទ័ពចេញទៅច្បាំងតស៊ូនឹងពួកខ្មាំងយ៉ាងខ្លាំង, តែពួកខ្មាំងមានកម្លាំងខ្លាំងជាង, ពួកមហាទរបស់ព្រះអង្គទ្រាំតស៊ូពុំបាន ក៏នាំគ្នារត់ចោលព្រះអង្គអស់ នៅសល់តែសេនាដៃជើង ២ នាក់ (មិនប្រាកដឈ្មោះ). សឹងមានសេចក្តីស្អប់ខ្ពើមចំពោះព្រះអង្គជាយ៉ាងក្រៃពេក ។ សេនាទាំងពីរប្រាណនេះបានចូលលុកទៅកាន់កណ្តាលពួកបច្ចាមិត្ត ប្រឡូកកាយបច្ចាមិត្តឆ្វេង-ស្តាំ ដណ្តើមយកព្រះអង្គអំពីចំណោម

ខ្ញុំដ៏ជាន់មកវិញ ។ កន្លងពេលនោះ អ្នកចំបាំងការស្មានថាបើកុំបានសេនាដៃជែក ២ នាក់ជួយ ព្រះចៅទ្រយសោរវ័ន្ទគង់លុះតណ្ដាប់ដៃខ្ញុំដ៏ ។ កាលរួចពីទីចំណោមខ្ញុំដ៏មកហើយ ព្រះចៅទ្រយសោរវ័ន្ទ ព្រមដោយសេនាដៃជែកទាំង ២ នាក់ជាន់រួបរួមទាហានល្មមសមគួរហើយ ក៏លើកទៅប្រយុទ្ធនឹងពួកក្បត់ជាថ្មីទៀត ពាល់តែមានជ័យជំនះ ។

លុះស្រេចការកម្ចាយសឹកក្នុងប្រទេសសាន្តគ្រានហើយ ព្រះចៅទ្រយសោរវ័ន្ទស្តេចទៅសាងមហាពុទ្ធានីថ្មី ១ ទៀត នៅជាខាងទិសពាយ័ព្យនៃក្រុងហរិហរាល័យ សឹងមិនឆ្ងាយប៉ុន្មាន ឲ្យឈ្មោះថា "ក្រុងស្រីយសោធរបុរៈ" ដោយយកព្រះនាមរបស់ព្រះអង្គទៅភ្ជាប់ជាឈ្មោះក្រុងនេះផង ដែលពាក្យសាមំញ្ញហៅថា "មហានគរ" ឬ "នគរធំ" ។ ក្រុងនេះមានភាពជា ៤ ជ្រុងចតុរស ទំហំទទឹង-បណ្ដោយប្រមាណ ៣.០០០ ម៉ែត្រស្មើគ្នា ធំជាងក្រុងពេមក្នុងសម័យស៊ីសាវ៉ាថៅទៀត មានកំពែងឥដ្ឋព័ទ្ធជុំវិញ, កន្លងទីលំទាំង ៤ នោះទិសបូព៌ាមានទ្វារ ២, ទិសក្រៅអំពីនេះមានទ្វារមួយ ។, ក្រៅតំពែងមានតូរទឹកព័ទ្ធជុំវិញ, នៅមុខទ្វារនិមួយ ។ មានស្ពានថ្មឆ្លងតូរចូលទៅ[1] ។ ខាងក្នុងព្រះមហានគរ នៅត្រង់កណ្ដាលផ្ទៃក្រុង ទ្រង់សាងព្រះប្រាង្គខេមស្នាន ១ ដោយថ្ម. ព្រះប្រាង្គនេះ

(១) កំពែងនិងតូរនោះសាងពីរលើក តាមដែលក្នុងរជ្ជកាលព្រះជយវរ្ម័នទី ៧ ទ្រង់បានសាងបន្ថែមឡើងទៀត ហើយឮឈ្មោះកំពែងនោះថា ជយគិរី ។

ច្រាកដណ្ឌោះតាមសិលាចារឹកជា ២ ឃ្លាៗ គឺហៅ វ៉ែកណ្តាល (កុំកណ្តាល) កំមាន ហៅ យសោធរគិរី កំមាន ។ ទាំងខ្នង់សាងព្រះពជនិវេសន៍ សម្រាប់ព្រះមហាក្សត្រិយ៍គង់ នៅខាងទិសពាយ័ព្យ នៃព្រះច្រាង្គ យសោធរគិរី ។

កាលសាងរួចស្រែចប៉ុណ្ណោះហើយ ក៏ស្តេចចេញអំពីក្រុងហរិហរាល័យ មកគង់នៅមហានគរសាង់ថ្មីនេះ ។ ឥតិមានត្រង់នេះ មានច្រាកដនៅសិលាចារឹកស្តុកក្នុងថា "មន ព្រះបាទ បរមសិវលោក ឋតនគរ ស្រីយសោធរបុរ នាំកម្រតេង់ជតតពងអំរីហរិហរាល័យ យកទុកនគរនេះ, មន ព្រះបាទបរមសិវលោកស្តាបនាវ៉ែកណ្តាល;កម្រតេង់សិរ៉ាស្រម ស្តាបនាព្រះលិង្គអាយកណ្តាល . . " ។

អធិប្បាយសិលាចារឹកនេះ: "ព្រះបាទបរមសិវលោក (ព្រះបាទ យសោវរ្ម័នទី ១) ស្តេចនៅគង់នៅក្រុងស្រីយសោធរបុរ: បានតាំងនាំរូបព្រះកម្រតេង់ជតតពជ (ដែលព្រះបាទជយវរ្ម័នទី ២ ខ្នង់សាង) អំពីហរិហរាល័យ. នៅប្រតិស្ឋានទុកនៅនគរថ្មីនេះផង, ព្រះបាទបរមសិវលោកខ្នង់ស្តាបនាកុំកណ្តាល, កម្រតេង់សិរ៉ាស្រម ក៏ប្រតិស្ឋានព្រះលិង្គទុកនៅកុំកណ្តាល . . . " ។

ក្រោយដែលមកគង់នៅក្រុងស្រីយសោធរបុរ: នោះ ព្រះបាទយសោវរ្ម័នខ្នង់ចាប់កសាងតទៅទៀត គឺសាងព្រះច្រាង្គទេវស្ថាននៅលើ

កំពូលភ្នំចុងខែង ឲ្យឈ្មោះថា "យសោធរស្សរៈ" ជាទីប្រតិស្ឋានរូបព្រះ
ខេមរភ័ក្ត្រ មានព្រះកាឡជាដើម ។ ទ្រង់សាងវត្តខាងព្រះពុទ្ធសាសនា១
ឲ្យឈ្មោះថា "យសោធរតស្រម", តែវត្តនេះមិនដឹងជាទ្រង់សាងនៅទី
ណា, ដោយស្មានប្រហែលជាវត្តដែលហៅកន្លងកាលឥឡូវនេះថា ឫទ្ធាយ
ក្តី(១) នៅខាងអាគ្នេយ៍នគរធំ, ទឹង ទ្រង់សាងមហាស្រះ ១ នៅខាងលិច
ក្រុង ឲ្យឈ្មោះថា "យសោធរតដាក" គឺស្រះធំដែលពាក្យសាម័ញ្ញ
ហៅថា "ចាពយណ៍ទឹកថ្ងា" ។ ស្រះស្រង់នៅមុខបន្ទាយក្តី កំប្រហែល
ជាព្រះមហាក្សត្រិយ៍អង្គនេះទ្រង់សាងដែរ ។

រួមបុរាណស្ថានសំខាន់ៗដែលព្រះចាទយសោវរ្ម័នទ្រង់សាងនៅ
មានព័ស្តុតាងដកបដល់សព្វថ្ងៃនេះ គឺ:

១ — ក្រុងស្រីយសោធរបុរៈ
២ — ព្រះឫទ្ធាឡ័យសោធរគិរី (ភ្នំបូ)
៣ — ព្រះឫទ្ធាឡ័យសោធរស្សរៈ
៤ — វត្តយសោធរតស្រម
៥ — ស្រះយសោធរតដាក ។

ក្រៅអំពីស្ថានអំបាលនេះ ព្រះចាទយសោវរ្ម័ន គង់ជាទ្រង់សាង

---

(១) ក្នុងសៀវភៅដីយរ៉ែទី ៣ ដែលបោះពុម្ពនៅពុទ្ធសាសនបណ្ឌិត្យ ថាព្រះបាទជយវរ្ម័នទី៧
សង់, ដែលថាដូច្នេះ ដោយស្មានតាមលក្ខណៈពាក្យ ។

វត្តសំខាន់ៗ មានទេវរូបជាដើម ទុកទៀតជាច្រើន សឹងមិនអាចនឹងប្រមូលមកវៀបរាប់ទុកក្នុងទីនេះបាន ។

ទីក្រុងរបស់ព្រះបាទយសោវរ្ម័ន បានត្រូវសាងឡើងក្នុងសម័យដែលស្រុកខ្មែរកំពុងសម្បូណ៌សប្បាយ ទាំងកិច្ចការខាងរដ្ឋប្បវេណីនិងសាសនាយ៉ាងរុងរឿងស្រស់ស្អាត ដូចមានបញ្ជាក់ក្នុងសិលាចារឹកដែលគេបានរកឃើញក្នុងឆ្នាំ ព.ស. ១៨៩១ ថា "ក្រុងនេះ ជាក្រុងរបស់មហាប្រទេសដ៏មានសក្តានុភាព ១ សឹងមានព្រំប្រទល់ដែន គឺខាងលិចទល់ប្រទេសមន ខាងឈើនទល់ប្រទេសចិន ខាងកើតទល់ប្រទេសចម្ប៉ា, នេះជាគោលខ្នាតរបស់ប្រទេសកម្ពុជា ក្នុងរជ្ជសម័យនៃព្រះបាទយសោវរ្ម័ន" ។

វិធីគ្រប់គ្រងផែនដី: ក្នុងរជ្ជកាលនេះ ដូចក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី ២ គឺមានស្តេចទបរាជ (ស្តេចត្រាញ់) គ្រប់គ្រងស្រុកធំៗទៅតាមជាយព្រះពុទ្ធអាណាចក្រ ។ ឬកុដទៅក្នុងសិលាចារឹកថា "ក្នុងរជ្ជកាលនេះ មានស្តេចទបរាជជាច្រើន ក្នុងទសាសចូលឆ្នាំ ដែលជាពេលត្រូវនាំយួយមកថ្វាយព្រះមហាក្សត្រិយ៍ពាជាធិរាជម្ចាស់ទាំងនោះ មកជួបជុំគ្នារបេះត្បូងនឹងមាសជ្រុះទៅទីក្រសាលំនាល់ជាច្រើន" ។

ការព្រះសាសនា: ក្នុងរជ្ជកាលនេះ មានពាជបុរោហិត ឈ្មោះ ភ៉មសិវៈ ក្រោយមកគេហៅថា សិវសោម (សឹងតំណាងឬត្រូវមកពីភាសាខ្មែរសុទ្ធ) ជាទីប្រឹក្សាការផែនដី ទឹង ធ្វើពិធីផ្សេងៗថ្វាយ ។

ព្រះបាទយសោវរ្ម័នខ្ញុំពាប់អានសាស្ត្រាព្រាហ្មណ៍លទ្ធិសៃវៈ នឹង ខ្ញុំ
ពាប់អានព្រះពុទ្ធសាសនាលទ្ធិមហាយាន តែខ្ញុំនិយមក្នុងលទ្ធិសៃវៈធំ
ជាង ដូចមានបុរាណស្ថានដែលពោលមកខាងលើនេះជាសមអាងស្រាប់
ព្រោះក្នុងសម័យនោះព្រះមហាក្សត្រិយ៍ទាំងឡាយ ស្ទើរតែគ្រប់ព្រះអង្គ
ខ្ញុំនិយម នឹង ពុកសាសនាព្រាហ្មណ៍ជាសាសនាសម្រាប់រដ្ឋ ។

ក្រៅអំពីនេះ ខ្ញុំបានរៀបចំលទ្ធិទំនៀមសម្រាប់ជាតិ ឲ្យមាន
របៀបរៀបរយទៅតាមព្រះពាជនិយម នឹង ខ្ញុំបញ្ជាក្តឲ្យមានបង់ពន្ធជារ
ផ្សេងៗទៀតតាមសមគួរ ។

ចំបើព្រះអង្គមានសមត្ថភាពនឹងព្រះរាជស្តាដូចពោលមក កំនៅតែ
មានមនុស្សឫស្សាបន្តិចបន្តួច ព្រះរាជស្តា គឺដល់មកពុទ្ធរដ្ឋកាល មានព្រះ
ពន្ធុវង្សដែលមិនច្បាស់នាម ឃ្លានបង្កការណ៍បះបោរឡើងក្នុងប្រទេសជា
ច្រើនលើកលើតទៀតនឹងដូចក្នុងកាលមុន, ព្រះបាទយសោវរ្ម័នឃ្លានស្តេចនាំ
ទ័ពចេញកម្រាបទាំងឡាយទៅជាច្រើនលើក តែក្នុងគ្រាក្រោយបំផុត
ព្រះអង្គត្រូវបានាឈ្មោះចាញ់ពួកទាំងវិញ ដោយខ្ញុំជឿក្នុងព្រះសមត្ថ-
ភាពរបស់ព្រះអង្គ ឃ្លានស្តេចចេញតស៊ូដោយក្លាហានហួសប្រមាណ
កំត្រូវទទួលសោយទិវង្គតកណ្តាលរណរង្គ ក្នុងឆ្នាំ ព. ស. ១៤៥៤ ។
តែក្នុងខ្ទីខ្លះថាខ្ញុំសោយទិវង្គត ក្នុងឆ្នាំ ព. ស. ១៤៥២ គេថ្វាយព្រះ
នាមព្រះបរមសព្ទថា "បរមសិវលោក" ។

ក្នុងរឿងនេះឃើញមានជាគតិតាំងពីបុព្វកាលមកថា "អ្នកភ្ញាំងពូកែក្នុងសង្គ្រាម ច្រើនតែស្លាប់ក្នុងសង្គ្រាម, អ្នកភ្ញាំងពូកែក្នុងផ្លូវនេយោបាយ ច្រើនតែស្លាប់ដោយស្នាដៃរបស់អ្នកឆ្លើនយោបាយផងគ្នា" ។ ព្រះបាទយសោវរ្ម័ន ទ្រង់មានព្រះសមត្ថភាពគ្រប់ផ្លូវ ទ្រង់ប៉ាន់បំពេញព្រះរាជតណ្ហាយកតិច្ចដោយសេចក្តីស្មោះក្នុងប្រទេសជាតិ ទ្រង់កក្ពុងព្រះរាជឥស្សរៈភាពរហូតមកដល់ថ្ងៃសោយទិវង្គត ហេតុនេះ ព្រះអង្គទ្រង់ប្រាកដព្រះកិត្តិយសជាព្រះមហាក្សត្រាធិរាជ ១ អង្គ ក្នុងប្រវត្តិសាស្ត្រ ។

ព្រះបាទជយវរ្ម័នទី ១

ព.ស. ១៤៨៤—១៤៦៤ គ.ស. ៩៤១ - ៩៦១

កាលព្រះបាទយសោវរ្ម័នទី ១ សោយទិវង្គតហើយ ព្រះហស្តិវរ្ម័នរាជនុរសច្ឆត្ត បានឡើងគ្រងព័ករាជ្យព្រះរាជបិតាតមក មានព្រះបរមនាមថា "ព្រះបាទហស្តិវរ្ម័នទី ១" ស្តេចគង់នៅក្រុងស្រីយសោធរបុរៈ, ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្តេចមិនប្រាកដ, ប្រាកដតែថាទ្រង់មានព្រះរាជនុរស ១ អង្គ ព្រះនាម ធាមោទរៈ[1] ។

ការផែនដី: ការផែនដីក្នុងរជ្ជកាលនេះ មានប្រែប្រួលទៅដូចម្តេចខ្លះឬទេ មិនឃើញមានពោលដល់, ដោយស្មានថា ប្រហែល

(១) ព្រះធាមោទរៈ មានព្រះនាម ២ អង្គ ព្រះនាម យាជ្ញវរាហ ១ វិស្ណុកុមារ ១, ទ្រង់មិនបានសោយរាជ្យស្នងព្រះរាជបិតាទេ ។

ជាតន៍ខ្ញុំដូចក្នុងរជ្ជកាលមុន . ទើបមិនមានចារឹកទុកជាសំគាល់ ។
ព្រះចុន្ទហាសិរ័ន្ទ ខ្ញុំរាប់អានសាសនាព្រាហ្មណ៍ជាសំខាន់ ខ្ញុំមាន
ពាជបុរោហិតចាស់តមកពីក្នុងរជ្ជកាលព្រះពាជបិតា ជាទីប្រឹក្សាការផែនដី
នឹង ធ្វើពិធីផ្សេង ។ ថ្វាយតាមលទ្ធិព្រាហ្មណ៍ ។ ការកសាងប្រាកដតាម
សិលាចារឹកថា ខ្ញុំបានសាងប្រាសាទវិមានអាកាស នៅក្នុងព្រះបរម-
ពាជកំនង់ជាន់ក្នុង សឹងគង់រូបពាងនៅដល់សព្វថ្ងៃនេះ ។

ព្រះចុន្ទហាសិរ័ន្ទទី១ស្តេចស្ថិតនៅក្នុងរាជសម្បត្តិបាន១០ឆ្នាំ ក៏សោយ
ទិវង្គតជាអមរណាកាល, គេថ្វាយព្រះនាមព្រះសពថា "រុទ្រលោក" ។

(មានត)

អានិសង្សអ្នកចេះពង្សាវតារ

សាវតារអ្នកណាចេះដូចកើតខាន់
យើញជាក់ស្បាន់ឮជាក់ស្តែងដោយខ្លួនឯង
ទាំងទុកថាអាយុយ៉ឺនយូរអង្វែង
ទុកជាខែងជាងប្រុសស្រីក្នុងលោកិយ ។
ជាធម្មតាអ្នកសាវតារតែងដុះចិត្ត
ដុះគំនិតគិតជាតិភូមិជាប្រក្រតី
ចង់ឲ្យជាតិមាតុគាមមានឈ្មោះល្បី
ដោតសេរីកុំបីជាអាយ័តគេ ។

ភាគទី ៥

អ្នកឧកញ៉ាបែលរាជសេនា ងួ-កង ប្រែរៀបរៀង

(ត ឌក)

ពេលនោះចូងធ្លក់លើកខ្ចីតធ្លងតាមដើមផ្លូវទៅ. លុះលីប៉ោ"ឮសន្ធឹកវេហ៍ពលលើកតាមអីងអាប់មក ទើបគិតយើញថា លិយូនេះជាមនុស្សមានសតិបញ្ញាក់ដែរជាប្រាកដ គិតអ្វីក៏គ្មានដែលខុស ។ លីប៉ោ"កាលយើញខ្ចីតចូងលើកមកជិតហើយ ក៏ឲ្យត្រឡប់មុខភាហានទៅខ្លួលតទល់ ចូងក៏ជិះសេះស្ទុះចេញទៅខាងមុខខ្ចីតហើយស្រែកថា អាសត្រូវកដសម្បត្តិ! អាឯងនាំព្រះថៅហៀនតេយកទៅណា? ។ លីប៉ោ"ឮច្បាស់ខឹងណាស់តបទៅវិញថា អាឯងនេះចំជាមនុស្សអកតញ្ញូ មហាទុ-កដដប់លៀងឲ្យបានសេចក្តីសុខ អាឯងគ្មានដឹងគុណលោកសោះ បែរជាប្រទុស្តចំពោះលោកវិញ លុះមិនសម្រេចតាមសេចក្តីប្រាថ្នា ក៏កៀសខ្លួនតេប៉ាត់ទៅ ទើបតែឥឡូវនេះមកតប់តិតគំនិតអាក្រក់តាមប្រទុស្តលោកទៀត ។ ក្នុងពេលនោះវៃហាប្តូនញាក់សេះស្ទុះទៅតយុទ្ធនឹងលីប៉ោបាន ៥ ស្នៀត លីឈុយក៏បំផាយសេះចូលទៅតទល់ពីខាងស្តាំ ចូងក៏ប្រើវៃហាប្តូអៀនឲ្យបរសេះចេញទៅតនឹងលីឈុយ ឯគុយគីក៏បរសេះចូលទៅតទល់ពីខាងឆ្វេង ចូងប្រើចូយិនឲ្យបរសេះចេញទៅតទល់នឹង

គុយតី ជាច្រួលច្របល់គ្នា សំឡេងគាហានទាំងសងខាងក៏លាន់ឮគគ្រឹកគគ្រែងហុយផ្សែងអំពូទិសទី ព្រះឆវណីហាក់បីដូចជានឹងក្រឡាប់ ហៃហួនយើញថា កំឡាំងខ្លួនមិនធ្លុនធ្លឹងកំឡាំងលីចោ៉ ក៏ញាក់សេរវេរត្រឡប់មកក្រោយ លីចោ៉ក៏បរសេះស្ទុះដេញបណ្តាយតាម គាប់គាហានចូធ្លូបែកខ្ចាត់ខ្ចាយអន្តរាយស្ងាប់ជាច្រើន ។ ឯចូធ្លូនឹងគាហានដែលនៅសល់នោះក៏ស្ទុះត្រឡប់ថយទៅដល់កំដើមផ្លូវ ត្រូវពេលនោះកំយប់យាម ២ ភ្លឺដោយពន្លឺព្រះចន្ទ ក្រឡេកឃើញពលគាហានឿយហត់ណាស់ ក៏ជ្រុសចេញពីផ្លូវទៅសម្រាកឈប់ឲ្យគាហានដាំជុំយទឹកបរិភោគ មិនទាន់ទាំងឆ្អិនជុំយផង ស្រាប់តែស៊ីអេងដែលលើកពលទៅបង្ក្រាប់ត្រឡប់ចេញមកស្ទាក់ពីមុខ គាហានចូធ្លូក៏ផ្អើលគុកវត់ត្រសុកចូលរៃខ្ចាត់ខ្ចាយអស់ទៅ ទៅតែចូធ្លូប្រាក់ឡើងសេះបុំងាយតាមផ្លូវទៅប្រទន្ទឹងស៊ីអេង ចូធ្លូក៏ភ័យរន្ធឹងស្មារតីញាក់សេរវេរទៅខាងរៃ ស៊ីអេងក៏យឹតធ្នូបាញ់ទៅត្រូវជាប់ស្មាចូធ្លូ ។ ក៏បំងាយសេរវត់កាត់មុខទៅ គាហានស៊ីអេងក៏យកលំពែងចាក់ត្រូវសេះចូធ្លូដួលចុះហើយក៏ស្ទុះទៅចាប់ខ្លួនចូធ្លូបាន ។ ខណៈនោះចោហងទទួលតាមមកគាន់ឃើញគាហានស៊ីអេងចាប់ចូធ្លូទុក ក៏ដេញលុកគាប់គាហាននោះស្ងាប់ដេរដាស់ ខ្លះក៏ក្រឡាស់វត់ចោលចូធ្លូទៅ ចូធ្លូត្រូវត្រញាំងចាប់ញាប់ញ័រអស់ទាំងសាច់កាយ ហើយនិយាយទៅនឹងចោហងថា ខ្ញុំយើងមុខជានឹងស្លាប់ហើយ បើដូច្នេះ អ្នកចូរជួយយក

អាយុយើងផង ។ ចោហាងនិយាយថា លោកអញ្ជើញឡើងដំរីសេះចុះ ខ្ញុំ
នឹងដើរច្បាំងកំងពីខាងមុខ ។ ចូធូឆ្លើយតបថា ដែលអ្នកដើរជើងនោះនឹង
ច្បាំងបានដូចជាដំរីសេះដែរឬ? ។ ចោហាងតបថា ស្រុកកើតចលាចល
គ្រានេះគ្មាននរណានឹងដួយខ្នុកបំរុងសោះ មានតែលោកជាៈជ័មគំនិតគិត
នាំចៅហ្វាយនៃត្រកាំងភួនមកធ្វើការជាមួយ ឯជីវិតរបស់ខ្ញុំបើស្លាប់ក៏ស្លាប់
ចុះ សុំឲ្យសេះបែតែជីវិតលោកនឹងបាននៅគិតការផែនដីតទៅ ។ ចូធូបាន
ឮសំដីចោហាងដូច្នោះក៏ឆ្លើយតបថា ខ្ញុំមានអំណរគុណនឹងអ្នកច្រើន, ថា
ហើយក៏ឡើងដំរីសេះ ។ ឯចោហាងដោះគ្រែចោលអស់គាន់តែជាវដើរ
ទៅ លុះទៅប្រមាណយាម ៣ ថ្ងាយក៏ដល់ទៅស្ទឹង ១ ស្រាប់តែឮសូរ
សំឡេងគាហានស្រែកហោតីខាងត្រៃយ ។ ចូធូនិយាយនឹងចោហាង
ថា យើងនឹងតេទៅខាងណា បើមានស្ទឹងនៅពីមុខដូច្នេះ សត្រូវមកដល់
ឥឡូវហើយ ជីវិតរបស់យើងទៀងតែស្លាប់ក្នុងទីនេះជាប្រាកដ ។ ចោ-
ហាងឆ្លើយថា លោកកុំព្រួយបារម្ភអ្វីឲ្យសោះ ធានាលើរូបខ្ញុំនឹងនាំលោក
ឆ្លងទៅឲ្យរួចឥឡូវនេះ, ថាហើយក៏ដោះគាវចោលអស់ពីខ្លួនហើយឲ្យចូធូ
ឡើងជិះលើស្មានាំហែលឆ្លងស្ទឹងនោះទៅដល់ត្រើយម្ខាង ។ ឯពួកគាហាន
ទំស្រុតតាមមកដល់ក្បែរមាត់ស្ទឹងនោះ ត្រឡប់ទៅយើញចូធូឆ្លងទៅដល់
ត្រើយម្ខាង ក៏បបួលគ្នាបាញ់នឹងធ្នូរណ្តៅពីខាងត្រៃយទៅ ។ ចោហាងនាំ
ចូធូដើរទៅប្រមាណ ៣០ សិន ទទួលថ្ងៃរះឡើង ក៏ចូលទៅឈប់សម្រាក

ក្បែរដើងកំមួយ ។ ឯស៊ីអេងក៏នាំគាហានធ្វេងស្ទឹងតាមទៅទៀត ឃើញ
ចូធ្លូនឹងចោហងឈប់នៅទីនោះ ក៏បង្គាប់ឲ្យគាហានចោមព័ទ្ធជុំវិញ ។

ខណៈនោះវៃហ្វូនទីនវៃហ្វូអឿនឃុំនាំគាហានសេះបានប្រវៃហែល
១៦ ឬ ១៧ នាក់ឆ្លងស្ទឹងស្រួតតាមទៅ ឃើញស៊ីអេងនឹងគាហានកំពុង
ឡោមព័ទ្ធចូធ្លូនឹងចោហង ក៏បរសេះបំពានកាត់មុខស៊ីអេងចូលទៅហើយ
ស្រែកគំរាមថា នែវុយពួកអាក្បត់ អាឯងកុំមកធ្វើអន្តរាយដល់នាយចៅ
ហ្វាយអញ ។ ស៊ីអេងបានឮក៏បរសេះចូលទៅតប្បាំងនឹងវៃហ្វូនបាន
១០ ស្នៀត វៃហ្វូនយកលំពែងចាក់ត្រូវស៊ីអេងធ្លាក់ពីលើសេះស្លាប់
ហើយដេញកាប់គាហានទាំងនោះរបកខ្ចាត់ខ្ចាយអស់ ។ ខណៈនោះ
ចោយិន លីគៀន នឹងង៉ាក់ដិន ទាំង ៣ នាក់នេះឃុំនាំគាហានបាន
ប្រវៃហែល ៣០០ ថ្ងៃ លើកគ្នាតាមគ្រាយទៅ ក៏បានជួបនឹងវៃហ្វូអឿន
ទើបបបួលនាំគ្នាទៅកចូធ្លូ ។ លុះចូធ្លូឃើញគាហានឯកបេះខ្លួនតាំ
ពលមកបានខ្លះ ក៏ធូរសប្បាយចិត្តឡើងវិញ ហើយក៏លើកពលគាហាន
តម្រង់ទៅស្រុកហោឡាយ ។

គ្រានោះ ចៅហ្វាយខែត្តទាំងពួងដែលនៅក្នុងស្រុកឡុកអឿន
មានស៊ុនកៀនជាប្រធាន បាននាំគ្នាចូលទៅជំទុំការក្នុងទីព្រះទីនាំងកៀន
សៀងគៀន ហើយទៅមើលទីព្រះតំណាក់របស់ព្រះមហាក្សត្រ ដែល
មាននៅកងបរិវេណនៃព្រះបរមរាជវាំងនោះ ឃើញស្នាមដែលតាំងតុ:

ឲ្យដឹកលើងទុំងប៉ុន្មាន ក៏បានឲ្យគាហានគាយលុបដីទៅវិញហើយសង់ជាកេងឡើង ទើបនាំគ្នាទៅអុជទៀនធូបធ្វើសក្ការបូជាគ្រប់ទីព្រះតំណាក់ទាំងអស់គ្នារួចត្រឡប់ទៅគាន់ទីប្រជុំ ។ លុះវេលាកណ្តាលយប់ទៀក្តីច្បាស់ ស៊ុនកៀនគាន់គ្រប់ចេញទៅអង្គុយទៅមុខព្រះឃាន ក្រឡេកមើលទៅលើឃើញផ្កាយសម្រាប់ព្រះមហាក្សត្រអ័ព្ទសៅហ្មងស្មុំ ក៏ពឹងថា គ្រានេះព្រះមហាក្សត្រមិនបានសេចក្តីសុខក្នុងព្រះអង្គហើយ បានជាអាណាប្រជាខុកស្តេកើតសេចក្តីក្តៅក្រហាយដូច្នេះ ហេតុទាំងនេះមកតែអំពីអាតាំងតុះចេញជាសត្រូវក្បត់ផែនដី ។ ខាល់តែស្រុកទៅជាវៃព្រហោហាន បានជាផ្កាយនោះកើតវិបរិតដូច្នេះ, ស៊ុនកៀនពឹងសព្វគ្រប់ទប់ពុំបានក៏ក្តុលចិត្តស្រក់ទឹកភ្នែក ។ ពេលនោះមានគាហានម្នាក់ឃើញហេតុប្លែកណាស់ក៏ស្ទុះទៅជំពាបស៊ុនកៀនថា សូមមានមេត្តាជ្រាស នៅក្បែរខាងព្រះទីនាំងទិសខាងត្បូងមានអ្វីភ្លឺត្រចះម្ល៉ះទេ ។ ស៊ុនកៀនក្រឡេកមើលទៅឃើញស្មើប្លែក ទើបក្រោកដើរទៅឲ្យគាហានអុជគប់ភ្លើងបំភ្លឺមើល ក៏ឃើញអណ្តាត ១ ទើបប្រើគាហានឲ្យចុះទៅពិនិត្យមើលក្នុងអណ្តាងនោះ ឃើញខ្មោចស្រីម្នាក់ ក៏ឲ្យលើកឡើងមក, ឯសពនោះក៏នៅស្រស់មិនទាន់រលែហើមសោះ មានកំណាត់សំពត់ចងរុំនៅក ស៊ុនកៀនក៏ឲ្យស្រាយចេញ មើលក្នុងកំណាត់សំពត់នោះឃើញមានកូនហិបតូច ១ ចាក់សោយ៉ាងជាប់ ទើបឲ្យគាស់បើកចេញឃើញគ្រា ១ (ធ្វើអំពី

ថ្នាំពណ៌) មានមុខ ៤ ជ្រុងស្មើ កម្រាស់ ៨ ដង្កាប់ កំពូលឆ្លាក់ជាប់ជារូបមកវ ៤ រុំព័ទ្ធគ្នា តែជ្រុងមួយនោះវេរយកមាសប៉ះបំពេញឲ្យស្មើ មុខគ្រានោះឆ្លាក់ជាអក្សរថា "ខេវតាប្រសិទ្ធិគុកឲ្យ ជើគ្គកងណាបានថែរក្សាគុកហើយ នឹងអាចគ្រងរាជសម្បត្តិបានចំរើនព្រះជន្មវស្សាយឺនយូរអង្វែង" ។ ស៊ុនកៀនឃើញថ្លែកអស្ចារ្យដូច្នោះ ទើបសួរទៅទៀតថា គ្រាឆ្លាក់នេះជារបស់នរណា? ។ ទៀផៅឆំរាបថា គ្រានេះជាគ្រូរាជទ្រព្យសម្រាប់រាជសម្បត្តិ ឯក្បាច់ចំឡាក់ដែលឆ្លាក់គ្រានេះ តាំងពីបេងហូឃើញសត្វហង្សខំលើកំពូលភ្នំ ១ ដល់សត្វហង្សនោះហើរចេញទៅ បេងហូក៏យកដុំថ្មនោះមកជាប់ឆ្លាក់ជាក្បាច់ស្រែចហើយ នាំយកទៅថ្វាយព្រះចៅសូប៊ូអង ។ ក៏ក្រុយព្រះជន្មទៅ, លុះដល់ព្រះចៅដិនស៊ីអង់ឡានសោយរាជសម្បត្តិឡើង ទើបទ្រង់ចាត់ឲ្យរាករជាងមកធ្វើជាគ្រាសម្រាប់ព្រះមហាក្សត្រគ្រងរាជដី, លើស៊ូជាជាងឆ្លាក់គ្រានោះ ឆ្លាក់ជាអក្សរ ៤ ភ្លុ, លុះព្រះចៅដិនស៊ីអង សោយរាជ្យបាន ២៦ ឆ្នាំ ព. ស. ២៣១ ស្តេចទៅប្រពាតដោយផ្លូវជលមាគ៌ា ក៏បណ្តាលព្យុះខ្យល់យ៉ាងធំពន្លឹក ស្តេចទ្រង់ភ័យខ្លាចក្រែងខ្លួនព្រះទីនាំងលង់លិច ទើបយកគ្រាឆ្លាក់នោះចាលទៅក្នុងទឹក ព្យុះខ្យល់ក៏បាត់សូន្យសូត្រឈឹងទៅវិញ, លុះតមក ៨ ឆ្នាំទៀត ព្រះចៅដិនស៊ីអង់ស្តេចទៅប្រពាតដោយសថលមាគ៌ា មានមនុស្សម្នាក់យកគ្រាទៅថ្វាយផ្តាល់ព្រះហស្ត មនុស្សនោះកំអន្ទះឆានបាត់ទៅ, កាលព្រះចៅដិន

ស៊ីអង់ស្តេចត្រឡប់មកដល់ព្រះបរមរាជវាំងវិញ ក៏ទ្រង់សោយព្រះទិវង្គត
កន្លះពេលនោះ ជូរអង់ទើបយកគ្រានោះទៅថ្វាយព្រះចៅហ៊ានកួច ពេល
នោះអង់ម៉ាំងជាសត្រូវក្បត់ ព្រះនាងតាំងវៃបាយកគ្រានេះគ្រែវែងចោល
អង់សឹម សោះស្មើមជាតាហានអង់ម៉ាំង ខ្លាតទៅត្រូវជញ្ជាំងផ្ទះបេះ
ជ្រុងបន្តិចទៅ ហើយឲ្យយកមាសប៉ះតែមដែលរបេះនោះស្មើឡើងវិញ,
លុះព្រះចៅហ៊ានកន្លះប៊ីបានគ្រានេះទើបសោយរាជ្យតៗមក ដល់ក្តៅនេះ
ព្រះបរមរាជវាំង ពួកខ្ញុំក៏នាំហង៉ជូរឿន ហង៉ជូរហៀប រត់ទៅនៅក្នុងវៃ
ដល់ពេលត្រឡប់ចូលមកវិញ ឃើនឲ្យខ្ញុំរាជការត្រួតពិនិត្យមើលព្រះរាជ-
ទ្រព្យក្នុងវៃផ្ទះព្រះឃ្លាំងគង់នៅទាំងអស់ ឃាត់តែគ្រាន្លាក់នេះរកមិនឃើញ
សោះ ក៏ឥឡូវលោកមកបានគ្រានេះ ខ្ញុំយល់ថារាជសម្បត្តិនឹងបានដល់
លោកជាប្រាកដ សុំឲ្យលោកនាំយកទៅស្រុកកាំងតាំងចុះ ទើបនឹងបាន
គិតការធំតទៅ ។

ស៊ុនកៀនបានស្តាប់ពាក្យមានដូច្នោះ ក៏មានសេចក្តីត្រេកអរណាស់
ហើយនិយាយថា ព្រឹកនេះយើងទៅលាអ្នកសៀវថាឈឺសុំវិលទៅស្រុក
វិញ, និយាយហើយហាមតាហានទាំងពួងថា កុំឲ្យប្រាប់សេចក្តីនេះឲ្យ
នរណាដឹងជាប្រាកដ ។ កន្លះពេលយប់នោះមានតាហានស៊ុនកៀនម្នាក់
បានដឹងហេតុក៏លបយកហេតុនោះទៅជំរាបអ្នកសៀវ ក៏ឃាត់តាហាន

នោះទុក ហើយឲ្យបំណាច់ផ្ងាន់ជាច្រើន ។ លុះវេលាព្រឹកឡើងស៊ុនកៀនក៏ឡើងទៅជំពប់លាអ្នងសៀវថា ខ្ញុំបាទឈឺមិនសប្បាយសុំលាលោកទៅនៅរក្សាខ្លួនឯស្រុកតៀងសា ។ អ្នងសៀវសើចហើយថា ខ្ញុំដឹងហើយដែលអ្នកថាឈឺសុំលាទៅរក្សាខ្លួននោះ ព្រោះអ្នកបានគ្រាធ្លាក់សម្រាប់រាជសម្បត្តិទេឬ? ។ ស៊ុនកៀនបានស្តាប់ឆ្លើយជាក្បាក់ខ្លួនហើយសួរថា នរណាមកជំពប់លោកដូច្នេះ? ។ អ្នងសៀវតបថា យើងទាំងអស់គ្នាបានរួមគំនិតគិតនឹងរំលាងសត្រូវរាជសម្បត្តិចេញ ប្រយោជន៍ដើម្បីឲ្យព្រះមហាក្សត្រសោយរាជ្យបានសេចក្តីសុខសាន្តសប្បាយ ព្រមទាំងអាណាប្រជានុរាស្ត្រក្នុងព្រះរាជអាណាខេត្ត ដែលអ្នកវើសបានគ្រាសម្រាប់ព្រះមហាក្សត្រ ហើយលាក់ទុកនោះមិនគួរទេ ត្រូវតែអ្នកនាំយកមកឲ្យយើងដែលជាមេទ័ពធំ បើឆ្គើការសេម្រេចវេលាណា នឹងបាននាំទៅថ្វាយព្រះចៅហ្នឹងតេ ឲ្យទ្រង់សោយរាជសម្បត្តិតទៅ តឡូវបើអ្នកនឹងលាក់ទុកហើយនាំទៅនោះ អ្នកនឹងគិតយករាជសម្បត្តិឬ? ។

ស៊ុនកៀនថា ខ្ញុំបាទមិនបានវើសគ្រាសោះ ហេតុម្តេចលោកមកថាដូច្នោះ ។ អ្នងសៀវតបថា យើងដឹងច្បាស់ជាអ្នកបានគ្រាទោះមកទុកអ្នកចូរយកមកឲ្យយើងឥឡូវនេះ បើអ្នកមិនស្តាប់មុខជាមានរឿងមិនស្រួល ។

ស៊ុនកៀនលើកដៃចង្អុលទៅលើអាកាស ហើយនិយាយប្រកាសសេចក្តីពិតត្រង់ថា បើខ្ញុំបាទបានយកគ្រាធ្លាក់ទៅលាក់ទុកមែន សុំឲ្យ

ខ្ញុំស្ទាបនឹងអាវុធផ្សេង ។ ចុះ ។ ចៅហ្វាយខ្មែត្រចាំងអស់ឃើញហើយក៏ដំរាបយ៉ាត់អួនសៀវថា ឥឡូវនេះស៊ុនកៀនឱយសច្ចៈស្បែហើយ សូមលោកលោះលាទោសទៅចុះ ។ អួនសៀវក៏នាំតាហានស៊ុនកៀនដែលទៅដំរាបរឿងនោះ ឲ្យចេញមកតទល់ចំពោះមុខហើយថា កាលដែលអ្នកប្រែតាហានឲ្យចុះកែងអណ្តូងប្រទះបានត្រានោះ តាហាននេះហើយដែលទៅជាមួយនឹងអ្នក ។ ស៊ុនកៀនឃើញតាហានរបស់ខ្លួន ក៏ដឹងច្បាស់ថាវាំនាំរឿងនោះមកដំរាបអួនសៀវជាក្លែងជ ។ ស៊ុនកៀនខឹងណាស់ហូតគ្រប់នឹងចាក់តាហាននោះសម្លាប់, អួនសៀវក៏ហូតគ្រប់ស្ទុះទៅឈរពាំងពីមុខតាហានហើយថា បើអ្នកសម្លាប់តាហាននេះ ខ្ញុំក៏ត្រូវសម្លាប់អ្នកវិញដូចគ្នា ។

ឯវ៉ាន់លៀងនឹងចុងធីវាជាតាហានអួនសៀវដែលឈរតើគ្រាយឃើញដូច្នោះ ក៏ហូតគ្រប់ប្រឆងទុក, ខាងខ្មែវៅ, អ៊ុយកាយ ហាន់តុង តាហានស៊ុនកៀនក៏ហូតគ្រប់ប្រឆងទុកដូចគ្នា ។ ចំណែកចៅហ្វាយខ្មែត្រចាំងពួនលុះបានឃើញហេតុភាស់ខែងគ្នាដូច្នោះ ក៏ចេញទៅហាមឃាត់ចាំងសងខាង, ស៊ុនកៀនក៏ឡើងសេះត្រឡប់ទៅកាន់ទីបន្ទាយខ្លួនវិញ ហើយរៀបចាត់ចែងពលតាហានស្រេចក៏លើកចេញពីក្រុងឡុកអៀង ។

អួនសៀវដឹងថាស៊ុនកៀនលើកចេញទៅហើយ ក៏ធ្វើសំបុត្រតាមហេតុនោះ ឲ្យសេះបំរើនាំទៅដល់ឡៅពៀវចៅហ្វាយខ្មែត្រកេងជីវ ឲ្យ

ខ្ញុំឮពៀវលើកតាហានចាំស្គាត់ដណ្តើមយកត្រាធ្លាក់ដែលស៊ុនកៀនទាំ
ម្តង់យកទៅនោះឲ្យបាន ។ លុះដល់វេលាព្រឹក មានតាហានសេះដែល
នៅយាមល្បាតត្រឡប់មកប្តឹងអួនសៀវថា ខ្ញុំពុតធ្លាដែលលើកទៅតាម
តាំងតុះនោះ ត្រូវបែកទៅនៅស្រុកហាឡាយហើយ ។ អួនសៀវ
ឮដូច្នោះក៏ចាត់តាហានឲ្យទៅទួលចូតូចូលមក់ក្នុងស្រុកឡុកអៀង ហើយ
រៀបតុលៀងភោជនាហារព្រមទាំងចូតូនឹងចៅហ្វាយខែត្រទាំងពួង, បណ្តា
មន្ត្រីខែត្រទាំងនោះ ក៏សាកសួរចូតូតាមរឿងដែលទៅធ្វើការនោះ ។
ចូតូស្តាប់ហើយក៏ដកដង្ហើមធំហើយថា កាលពីដើមខ្លួនខ្ញុំជាដើមគំនិតគិត
បញ្ចុះបញ្ចូលមនុស្សទាំងពួងមកដាក់កំឡាំង ទើងឲ្យដំណឹងទៅអស់លោក
ជាចៅហ្វាយខែត្រទាំងអស់ថា ទើងទំនុកបំរុងនៃនដី អស់លោកក៏ចូល
ចិត្តតាមគំនិតខ្ញុំ ឃានជានាំគ្នាលើកសេនាតាហានមកជួយធ្វើការ ត្រូវ
តាំងតុះលេះបង់ចោលស្រុកឡុកអៀងជាទីក្រុង នាំព្រះចៅហៀនតេទើង
អាណាប្រជាទុកស្តេចគាងក្រុងខាងទិសឯលិចវិញ ខ្ញុំក៏លើកតា-
ហានតាមទៅឃ្លាំមើងឆ្ងាំងបំផ្លាញតាំងតុះឲ្យនៅសេចក្តី ការនោះមិន
សម្រេចតាមបំណងត្រឡប់ជក្តដ័យចាញ់ប្រៀបគេ រីឯមកពេលនេះខ្ញុំ
មានសេចក្តីខ្មាសមនុស្សតូចចិត្តណាស់ តើអស់លោកនឹងយល់ឃើញដូច
ម្តេច? ចូរជួយគ្រិះរិះមើលផងចុះ ។

(មានត)

រឿងកោកកុលកុមារ

អ្នកឧកញ៉ាព្រះឃ្លាំង ឧង រៀបរៀង

(ភាគ)

បុរាកតគតិ

តុំដែលក្សីណាក្សីយ ដ៏វែតប្រលែយ ដោយគ្រឿងសម័ស ប្រាន់បរិភោគរតក អនេកច្រើនណាស់ ឥតទុក្ខទោសទាស់ ឥតព្យាធិភេតា ។ ឥតមាន សត្រូវ កំណាចព្យុះត្យូហ៍ បៀតបៀនបំផ្លាញ អាយុយឺនយូរ បរិបូណ៌ដន្យ នេះផលប្រាណា - តបុប្រជាន ។ អរិន្ទាមាន មនុស្សល្អចត្រព្យា គេគិតចង់ប្រាន បំប្រាត់បញ្ហាត បំពោតបំពាន បំពារអាធ័មាន ឃស សំក្តិទុត្តម ។ លុះលែងជាតិទៅ នរកនាមហៅ កាឡសូត្រឥស់ យមទូតលាចាប់ចង ជាក់ថងដាល់ដំ ឈឺផ្សាពេកតុំ សុទ្ធសោយទុក្ខា ។ ទើបយកបន្ទាត់ - ដែកដុតមកផ្ចាត់ សុះសព្វកាយា ខ្លះយកណារ មក អារអង្កា ពុះពិសិរសោ ទល់ទុក្ខទោសទំណ្ង ។ ឈាមហូរសស្រាក់ ស្រែកយំឥតអាក់ កិតកំយកាំងកាន់ នៅនានរក រង់ទុក្ខកំណាន់ កំណាត់ មួយពាន់ ឆ្នាំទិព្វទើបរដោះ ។ មួយពាន់ឆ្នាំក្រៃ - ត្រឹង្សទើបមួយថ្ងៃ នៅ នរកនោះ យូរពាន់ប្រមាណ លុះបានរួចស្មោះ ពីនរកនោះ មកជាប្រែត ប្រាណ ។ កំពស់គ្មោតលៃ រូបអាក្រក់ក្រៃ រុកអ្វីធ្ងន់ ធ្ងៃតែលាមក ជាទុក្ខឥតឃ្លាន ច្រើរយជាតិបាន មកកើតជាមនុស្ស ។ កំសត់ពិបាក

អត់ឃ្លាន់តោ។ យ៉ាក ទុគតទុយ៌ស ដើរសុំទានធំ ឥតគេសប្បុរស ក្សណា
ខ្លួនបែរ ប្រាំរយជាតិទៀត ។ មានទ្រព្យតិចតួច ចោរចាំលបលួច
ប្លន់បាត់បង្អែរ កើតជាខ្ញុំគេ ម្ចាស់ប៉ុយដេរទៀត ប្លាបបន្ទាំងបៀត
ទ្រព្យអ្នកដទៃ ។ បើអ្នកឯណា មួយមានប្រាជ្ញា ដរទំនងវៃ រៀនប្លាប
អធិន្នា - ទានជាបច្ច័យ មគ្គផលនាស្រ័យ សម្ចាបរិភោគ ។ រៀងខ្លួញ
ប្រាំ ប្រការបងាំ ចិត្តរេងអង្គាគ អធ្យាស្រ័យយល់ ទៅដល់បរលោក
ខ្លាបតម្ងុក្ខសោក ជិតដល់អាត្មា ។ អ្នកនោះនឹងបាន ទៅកើតនៅស្ថាន
សួគ៌តែត្រឹងឆ្ងាំ មានទេពអប្សរ បវរកញ្ញា មួយពាន់ចោមជា បរិវារគង់
គាល់ ។ បិតប្រាសាទខ្ពស់ ប្រមាណខ្នាទស ឃោងន៍យល់ឆើតឆាយ
តែដែតត្រដួច បង្អួចរៀងពាស់ សឹងមាសត្រកាស តិចិត្រវចនា ។ សោយ
សុខប្រមាណ មួយពាន់ឆ្នាំបាន ទើបបានជាតិជា ត្រកូលក្សត្រក្សាន្ត
មែនមានទ្រព្យ ធនធានសក្តា ច្រើនពន់តេកលៃ ។ ទើបយកជាតិជា
ត្រកូលនៃមហា - សេដ្ឋីប្រពៃ មានទ្រព្យប្រស សំគ្តិយសក្តាថ្លៃ ឥតអ្នក
ដទៃ ណានឹងប្រៀបបាន ។ គេរៈ ចារខ្លួយខ្លាំង សត្រូវទៀតទាំង - ឆ្លាយ
លោកធនធាន ចិត្តថងវិកល ប្រមាទពុំបាន ហេតុអ្នកនោះមាន ផលរៈ
លោកវិសេស ។ តាមេសុមិច្ឆា គោះអ្នកឯណា ចិត្តចោរវង្វែង លួចកប្បិយា
គេ ឥតឯមានក្រែង ស្រើឥតថ្លៃឯង អំពើនោតធុក ។ អ្នកនោះនឹងទៅ
ដល់ទុក្ខនិត្យនៅ សង្ឃាតនរក ទាំងប្រុសទាំងស្រី ឥតបីមានសុខ រួចរង

ភោសទុក្ខ លំបាកមហិមា ។ យម្កុំបាលបាន ជាវដេញឲ្យពាន ឡើង
ដើមរកា - ដែកជាលង្វាក្លើង ខ្ពស់ឡើងគណនា មួយយោជន៍បន្ទា ច្រើន
ច្រៃច្រាងច្រង ។ ស្រីពានឡើងមុខ មុតខ្លួនខ្លះ ស្រែកយំរលួង ប្រុស
ឡើងតាមទៅ មុតត្រវាដើមច្រង ធ្លុះថ្លើមបេះដូង ឈាមហូរសស្រាក់ ។
មានឆ្កែសច្រាល ប៉ុនដំរីសារ ទឹងខាំកន្ត្រាក់ ជញ្ជែងហូរហែក ត្មាត
ក្អែកឆក់ឆាក់ ចឹកចោះឆ្អុងឆ្អាក់ ខ្លួនដល់ដែកផ្សារ ។ ឆ្ការឆេះជាភ្លើង ភ្លឺឆ្ងែក
ច្រាលឡើង ត្រែនត្រាយខ្មោល ឆេះខ្លួនត្រឹមត្រែ ទើបយម្កុំបាល
បង្ហេណ្តើញដាល ឲ្យឡើងទៀតទៅ ។ ស្មាប់ក្តងមួយថ្ងៃ ពីរពាន់ដងវិន
តាមកំណត់ទៅ អសារអសោច៍ លន្ទោចក្តាត់ក្តៅ ពីរពាន់ឆ្នាំទៅ រួច
រង៉ែទោសទុក្ខ ។ អាយុពីរពាន់ ឆ្នាំទិព្វគ្រប់គ្រាន់ យាមាសួគ៌សុខ ទើប
បានមួយថ្ងៃ មួយយប់នរក រង៉ែរួចទោសទុក្ខ យោនយកជាតិជា ។
សត្វតិរច្ឆាន តេរ្ថៃវទៀតបាន ទុក្ខទោសវោ កាយកម្មអង្គឯង វង្វែង
មោហា ច្រាំរយជាតិជា ទុក្ខទៀងអប្រិយ ។ កើតជាខ្ទេរខ្ទើយ ច្រាំរយជាតិ
ហើយ មកកើតជាស្រី ច្រាំរយជាតិជា កំព្រាព្រាត់ប្តី ដោយទូវរៀវ-
ច្រកច្រាបពៀរធ្ងន់ ។ ទើបកើតជាប្រុស អាក្រក់ឧឡិស មកមានបុតន្ធ
ចោរចិត្តជាធម៌ តុំតិតច្រាបធ្ងន់ ហេតុពៀរពីមុន បរាគារគេ ។ បើអ្នក
ណាមាន វិញ្ញូញ្ញាយ្យញាណ ប្រុះច្រាជច្រាសប្រៃ ចិត្តចេះចាំចៀស
វៀសបានបែរ វៀរច្រាបកាមេ - សុមិច្ចាចារ ។ អ្នកនោះនឹងទៅ សោយ

សម្បត្តិនៅ សួគ៌សុខយាមា បិតាលើប្រាសាទ ស្អាងស្អាតសោភា
កំពស់អង្គា - រសេយោជនយល់យង់ ។ ភ្នំផ្ទៃកជិញ្ចាច ចិញ្ចែងត្រដាច
ត្រដួចដោមដុង មានទេពអប្សរ បវរគាល់គង់ ពីរពាន់សឹងទ្រង់ ដោម
ធាយបរិសុទ្ធ ។ អាយុពីរពាន ឆ្នាំទិព្វគ្រប់គ្រាន់ ចាកចុះច្យុត យោន
យកកំណើត កើតជាពជបុត្រ ថ្លាថ្លៃវិសុទ្ធ វិសេសប្រសើរ ។ ប្រកប
ភរិយា- ត្រឹមត្រូវលក្ខណា គាប់គួរមៀងមើល ជាស្រីគ្រប់ល័ក្ខណ៍
ឯកអគ្គប្រសើរ ខោះដេកខោះដើរ សឹងសុខសែនសល់ ។ មុសាវាទ
ខោះអ្នកឯណា កុហកកាចកល មានពាក្យវិនិវូស ប្រទុស្តកំហល់
កំហឹងរកកល់ គិតកាប់គិនគេ ។ បញ្ចកបញ្ចោត បញ្ចាំបំពោត បំពាន
វៀចវេ ខោលពាក្យកុកកេរ ជង្ហិរស្រាលស្រែ ឱ្យជង់ឱ្យគេ ឱ្យគេ
កើតទុក្ខ ។ អ្នកខោះនឹងខៅ ខាល់ទុក្ខនិត្យខោ ខោះពនរក ប្រាន់បួន
តាន់ឆ្នាំ វេរកម្មពុំសុខ ព្រោះខៅក់អាក្រក់ ខោលតាក្យមុសា ។ យម្ភ-
ប្រាលយក ដង្កាប់ដែកមក ងុតដកដីភ្លូ ឈាមហូរសស្រាក់ កន្ត្រាក់
អង្គា ចុះខោខៅនា រណ្តៅដំរែក ។ បួនពាន់ឆ្នាំឯណា សួគ៌តុសិតា ខើប
ប្រាន់មួយថ្ងៃ ខោះពនរក វេរទុក្ខវេរភ័យ យំនយ្យរកម្រៃ កម្រែរដោះ ។
លុះរួចមកប្រាន តើតជាប្រេតប្រាណ អសោចសូន្យសោះ កម្មកើតអគ្គី
ឆេះពីមាត់ខោះ ស៊ីសឹងឈាមខ្ទុះ ជាតិជាអាហារ ។ ខើបកើតជាមនុស្ស
អាក្រក់អំប្យយស មាត់វៀចដែលធា កើតជាមនុស្សល្ងង់ គប្បីឥតការ

តតក្តៅអសារ អសោចិ៍ពីមាត់ ។ បើអ្នកឯណា រៀរភាក្យមុសា - វាទ
រៀចតិតកាត់ កាន់សច្ចវាទ ស្រដីពាក្យសត្យ ឱនបានសម្បត្តិ សួគ៌
សោយសុខា ។ ពិភពតុសិត អាយុយឺនក្តាត់ បួនពាន់វស្សា មានទេព
អប្សរ បរិវេតា ប្អូនពាន់ជាតិជា បរិវារសត្វថ្លៃ ។ បិតស្លើប្រាសាទ
ប្រសើរស្អាងស្អាត សិនតែរៀបរៃ ខ្ពស់ម្ភៃប្រាំយោជន៍ ស្មើឆត្រឈើ
តែឈើ សុទ្ធសប្បាយតែក្រៃ ឥតឯទុបមា ។ បានបួនពាន់ឆ្នាំ ទិព្វទើប
ដំលាំ ចុះមកកើតនា ត្រកូលក្សត្រក្សាន្ត មែនមានប្រាជ្ញា ទើបទៅកើត
ជា អ្នកប្រាជ្ញចេះធម៌ ។ មែនមានពាក្យសត្យ ពាក្យពីពោះក្តាត់ ចេះចាំ
អស់អាថិ៍ ចំណោទប្រស្នា បញ្ហាសព្វសារ - ពើពុំពីការ ដល់ប៉ុន
កេសី ។ សុភមេរយោ រមែនុស្សផែនស្រា ក្មេចក្លាំងស្មារតី ក្រែស្មាលជា
ល្ងែង ពុំត្រែងរៀរើ - ឆាកឆាបស្រដី ពុំជឿធម្មា ។ ឱនធ្លាក់ទៅនៅ
នរកជ្រោះជ្រៃ រួបរងវេទនា ដល់តាបនរក ទល់ទុក្ខមហិមា យឺនយូរ
គណនា ប្រាំបីពាន់ឆ្នាំ ។ ហេតុចិត្តរង្វើង ងឹកទឹកទន់ដែង ក្តៅក្តាត់ជោក
ជាំ រលាករលុះ ពង់ពុះដោយកម្ម ប្រាំបីពាន់ឆ្នាំ និម្មានតី ។ ទើបបាន
១ថ្ងៃ នរកយូរក្រៃ លង់លុះឡើងពី ឆាបឆានកើតជា យក្សាតិរ៍ ជា
មនុស្សអប្រិយ សឹងឆ្គួតលេលា ។ មានពាក្យអសុកេរ ពាក្យរឹងទ្រគោះ
លបើលលា អ្នកផងតិះដៀល ដំនៀលនិន្ទា ជាមនុស្សមោហា ដួងជាតិ
ខ្លួនទៀ ។ បើអ្នកឯណា រៀរសេពសុភ នោះនឹងបានទៅ សោយ

សុខបរិតហាន ពាមានសន្ធៅ សឹងកែវនិត្យនៅ និម្មានរតី ។ កំពស់ប្រាសាទ សាមសឹបយោជន៍ស្អាត ប្រកបសឹងស្រែ ខេពអប្បរសួគ៌ គាល់គួរប្រាំបី - ពាន់ជាប្រកតី លុះអស់ជន្មា ។ អាយុប្រាំបី - ពាន់ឆ្នាំទិព្វពី នោះមកកើតជា ស្តេចស្តែងឆ្លើងឋាន មែនមានចេស្តា ប្រកបប្រាជ្ញា ចេះចាំធម៌គាប់ ។ មានចិត្តខ្ជាបថ្កាប ខ្ជាបតៀរជាប មានស្មារតីខ្ជាប់ ជាន់ប្រាជ្ញប្រុះ ឆ្លាស់ឆ្លុះយល់គាប់ ពាក្យពោលគំនាប់ គំនិតសោតធ្ងន់ ។ អំពើទាំងប្រាំ ប្រការបួរចាំ ចិត្តចេះគិតគន់ ចង់បញ្ជូរវេរ កម្មជាទម្ងន់ មិនមានរមាម - ន្ទិលទាស់ទោសទុក្ខ ។ រក្សាសីលប្រាំ នេះឯងនឹងនាំ រូបរួចបានសុខ រៀងទល់និព្វាន មិនមានធោតធ្មុក ផុតពីនរក សោយសុខសម្បត្តិ ។ ឯអស់សេនា - សេនីប្រជា ពស្តេចជាបរិស័ទ្យ ខ្នួលសីលប្រាំ ចង់ចាំប្រយ័ត្ន ប្រយោជន៍ពុំភ្លាត់ ក្លេចភ្លាំងគ្រប់គ្នា ។ ស្តេចសោយពជ្យរុង - រឿងពស្តេកុំឡុង សកលភាព ហាក់ដូចនគរ បវរសួគ៌ា សឹងសុខសួស្តីសា - ប្បាយបរិបូណ៌ក្រៃ ។ ស្តេចឲ្យសាងសង់ មណ្ឌបមាសម - ង្គលគួរប្រពៃ ដាក់ធាតុសិរសោ បិតាថ្ងាថ្ងៃ បូជាសព្វថ្ងៃ ខៀនធូបក៏ផ្កា ។ មានបុណ្យអស្ចារ្យ ល្បីឮទៅទាល់ ប្រទេសនានា ស្តេចមួយរយមួយ នាំសួយក៏ផ្កា មាសប្រាក់រត្នា មកថ្វាយក្សត្រថ្ងៃ ។ ហេតុព្រះបារមី ស្តេចស្ងាងអំពី មុនមកគ្រាស់ក្រៃ ទឹងបានត្រាស់ត្រៃច សារពេជ្ញាណាញ្ញេយ្យ ទើបស្តេចដឹង នាំសួយមកថ្វាយ ។ ហើយ

ព្រះភូបាល ស្តេចឲ្យនាំសារ - សុន្ទរដង្វាយ ស្មូព្រះបិតា មាតាឯនាយ
សព្វធ្នាំតែងថ្វាយ ទ្រព្យពុំដែលដាច់ ។ ស្តេចទ្រង់សន្ធា លង់លុះដក
ចាស់ដន្ធសម្រែច សោយវិលាល័យ ក្បីណាក្បុយផ្តល់ផ្តាច់ ជីវិតស្តេច
ស្មេច ទាំងបួនអង្គា ។ ទៅកើតនាហាន ស្តេតិសុខពិមាន ដល់តុសិតា
បិតលើបុប្ផាសាន ស្អាងស្អាតចេនា សឹងទេវតញ្ញា តន់តាស់ត្រៃ ។

សម្តេចកតាក់ បន្ទូលទេសនា ដោយពុទ្ធញាណញាយ្យ ថ្លែងពីបុព្វជាតិ ដោយខ្នាតវិស័យ ត្រែតត្រាស់ថាវៃហ អស់អគ្គតិក្ខដង ។ រីព្រះទេវតា ទ្រង់ត្រេកសាចត្តាត់ ប្រទានប៉ុនប៉ង តាយាងតថា - គត មានបំណង ចិត្តចោរចាំចង ពៀរពីមុននាយ ។ ពុំបានដូចចិត្ត អសារគំនិត កំណាចអន្តរាយ អង្គឯងវិនាស ព្រាត់ប្រាសខ្លួនខ្លាយ ទៅចតុរាបាយ ច្រើនជាតិពេកពិត ។ រីចិត្តគោសា មានហេតុបីប្រា - ការគួរគន់គិត មួយនាមាមាន បាសាណលិទិតុ - បមោ[1] គំនិត គំនុំចង់ គោស ។ ដូចគេគួសថ្ម ចិត្តនោះកម្រែ អ្នកណានឹងប្រែស នេះដូចទេវតា ឯងឥតសន្ធោស ចាំចិត្តចង់គោស ពៀរពុំសោយ ។ បហីរីលិទិតុ[2] - បមោដូចចិត្ត អរហន្តចាំងឡាយ ទឹងដូចគួសដី ស្នាមថ្មីស្លាក់ស្លាយ ត្រូវភ្លៀងរលាយ រលុបបាត់បង់ ។ ទុកលិទិតុ - បមោ[3] ដូច

• ๑ បាសាណលិទិតុបមោ ប្រែថា មានឧបមាដូចគេគួសថ្នាក់លើថ្ម ។ ๒ បហីរលិទិតុបមោ ប្រែថា មានឧបមាដូចជាគេគួសដី ។ ๓ ទុកលិទិតុបមោ ប្រែថា មានឧបមាដូចគេគួសទឹក ។

ចិត្ត សារពេជ្ជពុទ្ធឥន្ទ្រ ខឹងនាប់រសាយ រលាយចាត់បង់ ដូចគេគួសគ-
ឆ្កាគួរឥតស្នាម ។ ហៃអស់អរហន្ត កិក្ខុមហាជន ប្រែនប្រែងចាណ
ចាម ប្រដៅចិត្តខឹង កំហឹងកុំតាម ទៅទត្តមានស្នាម ដូចគេគួសថ្ម ។
បើអ្នកឯណា មួយមានចាជ្ញា មានចិត្តទន់ល្អ ពុំខឹងចងពៀរ ពំនៀរ
ទៅមក ដូចគល់គេយក គំនូសគួសទឹក ។ ប្រកបសព្វា ព្យាយាម
ទស្សាហ៍ កតញ្ញូវិលឹក គុណអ្នកមានគុណ ឥតអន់ក្លេចភ្លឹក អ្នកនោះ
នឹងនឹក សត្ថុប្រណិធាន ។ ប៉ុនប៉ងចាថ្នា សម្បត្តិចាជ្ញា សារពេជ្ជ
សឹងបាន បរិបូណ៌ដូចចិត្ត គន់គិតរិះធ្យាន ចាកដពុំខាន ចាន់ដូចចាថ្នា ។

សត្ថាតមំ ធម្មទេសនំ អាហរិត្វា រតាមកោដក មេស្រុកឫស្សា
ចេរវិលវិងជា ទៅទត្តប្រែតចាណ ។ កិក្ខុអើយមហាក្សត្រ នាមព្រះ
ព្រហ្មទត្ត ទ្រង់ស្តេចសោរហាន ប្រមាទព្រះអង្គ ពួរឥន្ទ្រពុទ្ធញ្ញាណ
ចេរវិលវិងបាន ជាស្តេចសុបុព្វពុទ្ធ ។ ឯអង្គ៌ព្រះតន្ត្រី ចម៍ចៅទេវិនូ ទេវ-
វិសុទ្ធ អនោលដោយខ្លាត យកជាតិចំហុត ជាព្រះអនុរុ - ទ្ធាចារ្យចេញ ។
ទេព្ពានិមិត្ត ជារុយគន់គិត នាំណែមគ្នា ចេរវិលវិងមក យោន
យកជាតិជា កិក្ខុនីនាមា នាងខុប្បលព័ណ៌ ។ ព្រះចាទសត្តកុដ ភជា
វិសុទ្ធ វិសេសមានធម៌ ជាព្រះសារីបុត្ត បរិសុទ្ធអស្ចារ្យ ចាជ្ញាទូទំរ
លើសលែងអរហន្ត ។ សុនខសសឹង អនោលវិលវិង ជាព្រះគានទូ
អនុជសាស្តា ព្យាយាមលន់ ទុបដ្ឋាកតតន្ត្រន់ ជាឃ្លាំងធម៌ស្មោះ ។

ឯអង្គខេរតា ដែលព្រៃកាឡា ជាគ្នាតតាលណោះ អន្ទោលដោយឫទ្ធិ យកជាតិចំពោះ ជាសិស្សធ្វើនឈ្មោះ ព្រះមោគ្គល្លាន ។ ខេត្តានិម្មិត ជាក្អែកគន់គិត ចេះវិលវែងបាន ជានាងខេមា សោភាមែនមាន សីលសង្រួមប្រាណ សំណាក់សាសនា ។ ឯអង្គជូនចាស់ មានសប្បុរសណាស់ ជាធម៌មាតា អន្ទោលយោនយក ជាតិមកឋានជា នាមនាងកីសា – គោតមីទេវី ។ តិក្ខុតើយឯមហា – សេដ្ឋីនាមា ហៅគោតមីឡើ ចេះវិលវែងមក យោនយកជាតិ ជាព្រះបាទស្រី – សុទ្ធោទន៌បិតា ។ កលិយោសេដ្ឋី មាតាពោធី – សត្វសោតបានជា ព្រះកន្ទោងថ្ងៃ នៃអញ តថា – គតគីនាងមហា – មាយាទេវី ។ រីនាងសុទ្ធមា – លម្អាងីតា មហេសីពោធី – សត្វសឹងមូលមក យោនយកជាតិ ត្រង់នាមនាងស្រីយសោធរា ។ ទីនាងអស្សត្ថ មង្គលបវរ យោនយកជាតិជា រាហុល-ត្តេរោ បុត្តោតថា – គតគីព្រះរា – ហុលត្តេរថៃ ។ ព្រះបាទកោគកុល កុមារនិមិល អង្គឹងដៃ គឺអញឯងច្បាស់ ត្រៃចត្រាស់ញាណ ញ្ញេយ្យ ជាមកុដត្រៃត្រៃ – កូមិកពពុទ្ធចក្រ ។ ជាតិជាគ្រួគ្រប់ នាំសត្វសាយសព្វ លើកឡើងជលជាក់ ទល់ទីឱ្យលហាន និព្វានជៀងជាក់ ជាតិជាពំនាក់ ពំនឹងសត្វផង ។

ហៃជនតាំងឡាយ ចូរស្តាប់និយាយ ដំណើរទំនង កោតកុលកុមារ គ្រអាលចាំចង់ រួសារៀនរង រំសែងមាំថ្ងូថ្លា ។ ទឹងបានមគ្គផល បរិបូណ៌បានដល់ ដូចក្តីប្រាថ្នា ខ្ញុំថ្វងសរសើរ ដំណើរកតាតតិប្បកា – វេនិដ្ឋិតំ ។

ចប់ រឿងកោតកុលកុមារ តែប៉ុណ្ណោះ

សុភាសិត

ល្អ ៤ យ៉ាង

សូរមើលសៀវភៅ កុំទៅមើលរបាំ,
សូរស្តាប់ធម៌ដែលចាំ កុំត្រាំស្តាប់បំរៀង,
សូរនិយាយធម៌ ល្អជាងនិយាយជៀង,
សូរគិតធម៌ពុំទៀង ល្អជាងគិតព្យាបាទគេ ។

ឃ្លោ - អ៊ុំ

ប្រវត្តិសាស្ត្រនៃស៊ីវិលីហ្សែខ្មែរបុរាណ

លោក ក៏យ-ប៉ុក ក្រមការ ប្រែជាខ្មែរ

ចាកសៀវភៅ ជនស្ពារ ឡង់ស៊ុយែន ស៊ីវិលីសាស្ត្រនៃខ្មែរ

(Histoire : l'Ancienne Civilisation Khmère) របស់:លោ។សិរ - ស៊ុដេស

(Georges Cœdès) នៃលេខុះក្នុងទស្សនាវដ្តីហ្វ្រែង់អាស៊ី (France-Asie)

ខែតុលាឆ្នាំ១៩៤៦

មតិរបស់បុគ្គលដែលមានវប្បធម៌ជាមធ្យមថា : ពាក្យ "ស៊ីវិលីហែលេន្ទិក" (Civilisation helléniques) នេះ មិនមែនគេត្រូវយល់ត្រឹមតែប្រាសាទ ឬរូបធ្លាក់ របស់ជាតិក្រិកពីសម័យបុរាណនោះទេ គឺគេត្រូវយល់ដល់ទៅសៀវភៅកាព្យឃ្លោង ដែលពួកក្រិកក្នុងប្រទេសនោះតែង, ពួកទស្សនវិទូ, - រឿងព័ត៌មានអត្ថដ៏គម្ពីរភាព (Mythologie), - បញ្ហាសង្គមនិងអង្គការប្រសាសន៍បាយនៃនគរប្រវត្តិទាំងប៉ុន្មាន ដែលនៅក្នុងប្រទេសនោះផង ។ ឯពាក្យថា "ស៊ីវិលីអាំងឌីយែន" (Civilisations indiennes) ឬ "ស៊ីវិលីចិន" ក៏ដូចគ្នាដែរ គឺគេត្រូវយល់ដល់បញ្ហាដ៏សុខុមចំពោះវិចិត្រសិល្បៈនិងវិទ្យាកាយសិល្បៈ (Arts plastiques) ដែលជាវត្ថុជាតុសម្រាប់បំភ្លឺនូវស៊ីវិលីនោះ ។ ចំណែកមហាជនខ្មែរពីអតីតសម័យគេនៅមិនដឹងច្បាស់ដោយសារអ្វីខ្លះ ក្រៅពីវិទ្យាសិល្បៈ ឬរូបធ្លាក់ដែលអក្សរសាស្ត្របានប្រតិស្ថានខុកដូចប្រុះស្តេចកំលង់ជាដើម ? មួយទៀត

យកអ្វីជាឡាត់ហាន ទើបគេនឹងអាចដឹងបានពីរបៀបរៀបចំអង្គការផ្សេងៗ នៃប្រទេសនឹងដីវាគាខាងផ្លូវច្បាប់ឬសុីវិលៃខាងសង្គារ:? ។

មានគេបានអានពាក្យអ្នកច្បាប់ដែលចងទុកក្នុងសៀវភៅមួយដែលបានបោះពុម្ពនៅក្រុងហាណូយ កាលពីឆ្នាំ ១៩៣៩ ថា "អច្ចរិយវត្តនៃវិទ្យាសិល្ប: នឹងវិទ្យាឆ្លាក់ក្បាច់ ដែលមានក្នុងទីនេះ តើគេនឹងចង់ប្រៀបធៀបទៅនឹងមតិបែបណា? មានប្រយោជន៍អ្វី? តួច្បាសាទដែលមានសភាពសម្បើមអស្ចារ្យ តើគេនឹងចង់ប្រៀបទៅនឹងមត្តនៃទស្សនវិទ្យាបែបណា? បើតាមយោបល់ខ្ញុំថា គ្មានអ្នកណាអាចដឹងបានក្នុងរឿងនេះទេ, បើទុកជាដឹងក៏មិនអាចនឹងយល់ខ្លួរហេតុផលឲ្យច្បាស់លាស់ព្រោះពួកជនជាតិខ្មែរពីអតីតកាល ជាជាងវិទ្យាសិល្ប: នឹងជាជាងរចនានៃច្បាសាទទាំងអស់ តាំងពី គ. ស. ១. ០០០ នោះ មិនបានតត្រាទុកក្នុងសៀវភៅក្បួនខ្នាត ឬផែនទី ឬគ្រឹងសំគាល់អ្វី ដែលល្មមយើងអាចយល់ខ្លួរគំនិតជនជាតិខ្មែរពីកាលណោះបាន" ។

ខ្ញុំមានពេលនុកាសតបន្ទឹងពាក្យពោលថា "គ្មានអ្នកណាអាចដឹងបាន អំពីគំនិតជាតិខ្មែរបុរាណកាល" ដូចតទៅនេះ ។ អ្នកតែងសៀវភៅនោះមានសិទ្ធិពោលដោយសេរីថា មិនដឹងខ្លួរគ្រោងការនៃអ្នកច្បាស្ត្រ អាម៉ីម្ញូនីយេរ (Aymonier), ហ្វីណូត៍ (Finot), ក្រូស្ញូយេរ (Groslier) ហ្វ៊ី, ស្តេនី (Ph -Stern) ។ តាមពិត គេមិនត្រូវយល់ថា

ប្រជាជនក្នុងលោកសន្ធឹកសន្ធាប់ មិនដឹងមិនស្គាល់រឿងព័ត៌មាននោះសោះដូច្នេះឡើយ, ប៉ុន្តែគេមិនបានស្គាល់ទូរឿងព័ត៌មានទាំងអស់ ដូចដីវគាពខាងក្នុងសម្ភារៈនឹងខាងប្រជាជនៃអ្នកកសាងប្រាសាទអង្គរនេះទេ តែគេគង់ដឹងបានខ្លះល្មមនឹងយកមកតែងរឿងដោយសង្ខេបអំពីស៊ីវិលៃខ្មែរក្នុងកាលនោះ, ស៊ីវិលៃដែលយកគម្រាប់តាមប្រទេសឥណ្ឌា ហើយបានខុសគ្នាគំរាលយ៉ាងពិតប្រាកដ, មិនតែនៅប្រទេសកម្ពុជា ថែមទាំងនៅប្រទេសលាវនឹងសៀមទៀតផង ។

ក្នុងពេលនេះ តើគេអាចស្រាវជ្រាវរឿងព័ត៌មានប៉ុន្មានពីណាមក? បើតាមអ្នកប្រាជ្ញដែលគោលនេះ តើពិតជាខេមរជាតិ ក្នុងកាលនោះមិនបានកត់ត្រាទុកជាលាយលក្ខណ៍អក្សរក្នុងសៀវភៅឬ? មិនមែនដូច្នោះទេ, ពួកខេមរជាតិក្នុងសម័យនោះ បានចារឹកអក្សរសំស្ក្រឹតផងសិលាដែលជាភាសាជាទីគោរពនៃស៊ីវិលៃជាតិឥណ្ឌា, សិលាចារឹកខ្មែរបុពណ៌ខ្លះជាពាក្យឲ្យពរសេពួសាធុការ ខ្លះជាអនុស្សាវរីយ៍, ក្នុងសម័យបច្ចុប្បន្ននេះគេបានរកឃើញសិលាចារឹកជាច្រើនម៉ឺន ។

ក្នុង គ. ស. ១៨៧៨ មានអ្នកប្រាជ្ញខាងបូរាវិទ្យានិយមជាតិហុល្លង់ដេសឈ្មោះ ហង់ឌ្រីក – កែណ (Hendrik - Kern) បានបកប្រែឲ្យយល់ច្បាស់ឡើង នូវអក្សរសំស្ក្រឹតជាបឋមដែលចារឹកទុកក្នុងក្នុងកម្ពុជរដ្ឋ ។ ៦ ឆ្នាំតមក បណ្ឌិតសភាខាងសិលាចារឹកនឹងអក្សរសាស្ត្របុរាំងយើង

ចានចោះតុម្ពផ្សាយសៀវភៅភាគទំមួយ នៃសិលាចារឹកសំស្ក្រឹតនៅប្រ-
ទេសកម្ពុជា ។ ចំណែកខាងលោកអេទែន អាម៉ីម្ងូនីយេ (Etienne Ay
monier) ជាប្រតិភូនៃប្រទេសចាំង កាលមកកាន់ប្រទេសកម្ពុជាក៏ចានធ្វើ
បេសកកម្មជាច្រើនដងក្នុងការស្រាវជ្រាវរឿងនេះ លោកចានរកឃើញ
អក្សរធ្លាក់នឹងស្ពាន់ ព្រមទាំងអក្សរតុម្ពក្រជាស ៣៤០ ផ្ទាំង ដែលចា-
រឹកជាពាក្យសំស្ក្រឹត នឹងពាក្យខ្មែរ, សព្វថ្ងៃចានទុកនៅបណ្ណាល័យប្រជា
ជាតិក្រុងប៉ារីស, លោកចានតែងរឿងនេះចុះក្នុងសៀវភៅលោក ឈ្មោះ
ឡឺកម្ពូដ្ស (Le Cambodge) ដែលចានចោះតុម្ពក្នុងរវាង គ. ស. ១៩០០
នឹង គ. ស. ១៩០៣ ដែលលោកចានតាំសោធន៍ចតប្រៃសិលាចារឹក
ទាំងនោះ ។ តមកទៀត សាលាចាំងនោះបូតាប្រទេសចានស្វែង
រកអក្សរដែលធ្លាក់លើស្ពាន់ ហើយនឹងចតប្រៃសិលាចារឹក ។ សាស្ត្រា-
ចារ្យរបស់ខ្ញុំឈ្មោះ "ល្វីហ្វីណូត" ជាជនកម្ពុស្ស ហើយជាចាងហ្វាង
បឋមនៃសាលាចាំងនៅបូតាប្រទេស លោកចានយកសេចក្តីបតប្រៃ
សិលាចារឹកនោះទៅចុះផ្សាយជាច្រើនលើកក្នុងទស្សនាវដ្តីសាលានេះ ។
ខ្ញុំក៏ចានធ្វើតាមគ្រោងការរបស់លោក ហើយខ្ញុំចានចុះផ្សាយរឿងនេះត ។
មក ។ ព្រោះហតុដូចនេះ ចានជាយើងមានវត្តជាតុគ្រប់គ្រាន់ សម្រាប់
កំណត់ដោយច្បាស់លាស់នូវប្រវត្តិការនៃកម្ពុជរដ្ឋសម័យបុពណ, សន្តតិ
វង្សព្រះមហាក្សត្រិយ៍, កាលបរិច្ឆេទនឹងស្ថានទីនៃប្រាសាទដ៏សំខាន់

ដែលមានពាសពេញប្រទេស ។ តែសិលាចារឹកទាំងនោះនៅខ្វះខាតដំ-
ណឹងផ្សេងៗជាច្រើន ។ បើតាមពិនិត្យដោយជាក់ច្បាស់, សិលាចារឹក
ដែលជាអនុស្សាវរីយ៍ទាំងនោះ មានច្រើនតែរឿងផ្នែកសាសនា អាចឲ្យដឹង
ច្បាស់មិនពេញបរិបូណ៌ ហើយមិនចំទូលំទូលាយនៃប្រជាជនស្ថានភាពខាង
សង្គម, លទ្ធិសាសនា, ទំនៀមទម្លាប់ប្រពៃណី ។ បើស្រាវជ្រាវតាម
រះបវិបក្ខរឿងព្រះ ដែលមានក្នុងសិលាចារឹកនោះហើយនឹងដំណឹង ដែល
បានមកពីអ្នកវក្បាឯកសារ នឹងអ្នកដំណើរទាងប្រទេសចិន គេអាចយល់
បានខ្លះតំនិតនៃអង្គការនេះយ៉ាចាស់ប្រសប់ប្រទេសកម្ពុជាពីសម័យបុរាណ,
សាសនានឹងសេចក្តីដំណើរផ្សេងៗរបស់ប្រជាជាតិ ចំពោះពីធីនឹងទំនៀម
ទម្លាប់ប្រពៃណីនិយម ក្នុងការស្តាប់នាច្បាសាទនឹងតាំងនគរនីមួយៗ,
ថ្ងាក់ស៊ីវិល្យសម្ភារៈនឹងវប្បធម៌ទាងផ្លូវច្បាជាជារបស់ពលវដ្តសម័យអង្គរ;
សរុបមូលហេតុមក គឺវត្ថុជាតុផ្សេងៗ ដែលជាឯកគោលនៃស៊ីវិល្យ
សម័យអង្គរ ។ ការស្រាវជ្រាវនេះ នៅមិនទាន់ចប់សព្វគ្រប់ទេ យើង
ត្រូវស្រាវជ្រាវឲ្យរឿងព្រះណាដែលយើងត្រូវការភ្លាមៗ ហើយត្រូវស្វែង
រកយកមកកត់ត្រាឲ្យបានច្រើនតែប្រសិលាចារឹកទាំងអម្បាលម៉ាន ។ ត្រូវអ្នក
ច្បាជ្រាងអនាគតកាល ព្យាយាមស្រាវជ្រាវតទៅទៀត ដើម្បីនឹងយក
មកបញ្ចូលគ្នានឹងការស្រាវជ្រាវក្នុងអតីតកាល ហើយទំធ្វើរឿងទាំង
នោះឲ្យជាក់ច្បាស់ច្បាកជាឡើង ។

លោក ម៉ិញ ឆាំគ្រី រៀបរៀង

(តទៅ)

គ្រិស្តសាសនា

១ - លទ្ធិកាតូលិក

សាសនានេះ ជាលទ្ធិមួយដែលកើតឡើងនៅប្រទេសស៊ីរី ដោយសារដើមគំនិតរបស់គណាចារ្យ ១ នាក់ឈ្មោះហ្សីហ្សូ - គ្រិស្ត (Jésus-Christ = អ្នកស្រោចស្រង់) ។

ប្រវត្តិហ្សេហ្សូ - គ្រិស្ត (សង្ខេប)

ហ្សីហ្សូ - គ្រិស្ត ជាគណាចារ្យមួយដែលកើតឡើងក្នុងរវាង ៣.ស ៥៤៣ ជាបុត្ររបស់ស៊ូសែហ្វ ខឹងនាងព្រហ្មចារី ម៉ារី ជាតិពស្តេ ចាប់កំណើតនៅក្នុងបេត្តឡេហែម (Bethléhem) ទៀបក្រុងហ្សេរូសាឡែមក្នុងរាជ្យព្រះចៅហេរ៉ូដ ។ ដើម្បីទំនុកដំលៃថ្ងៃដែលព្រះហ្សីហ្សូកើត ពួកគ្រិស្តបរិសទ្ធ (កាតូលិក) កំណត់យកថ្ងៃ ២៥ ដេសេមប្រ[1] ជាថ្ងៃបុណ្យមួយសម្រាប់សាសនា ហៅថា បុណ្យណូអែល (Noël) ។

សម័យនោះ មានពួកចោរណាចារ្យហោកសាស្ត្រ ចូលនាំគ្នាមកកាន់ក្រុងហ្សេរូសាឡែម ដើម្បីនមស្សការហ្សីហ្សូ ដោយសំគាល់

---

១ ថ្ងៃដែលហ្សេហ្សូ - គ្រិស្តកើត ជាកាលចាប់ផ្តើមគ្រិស្តសករាជតទៅ ។

ថាជាស្តេចស្ទីហ្វ៍ ព្រោះបានឃើញផ្កាយកំណើតខាងទិសបូព៌ា ។ ដំណឹងនេះជ្រាបដល់ព្រះបាទហេរ៉ូដ ទ្រង់ព្រះត្រាធឲ្យស្វែងរកសម្លាប់ហ្សេ-ហ្សឺតារក ប៉ុន្តែរកមិនប្រទះ ដោយស៊ូសែហ្ស ទឹងនាងម៉ារី នាំពង្រត់យកទៅខ្ទុកនៅស្រុក អេហ្ស៊ីប្ត (Egypte) តាមបង្គាប់សុបិនទិព្វិតរបស់ទេវតាឈ្មោះគាប្រ៊ីយែល (Gabriel), ម្ល៉ោះហើយព្រះបាទហេរ៉ូដ រំងឹតតែខ្លាល់ជាភ្ញាំង ទ្រង់ឲ្យពួកជបុរសតិយាជក្តុកខារកក្នុងស្រុកបេត្តឡេហេម ដែលមានអាយុត្រឹម ២ ឆ្នាំចុះមក ។

ពេលគ្រោយមក ព្រះបាទហេរ៉ូដ ទ្រង់ទិវង្គតទៅ, មាតាបិតារបស់ហ្សេហ្សឺបានទាំកូនមកកាន់ភូមិណាសារេថ ឃុំគាលីឡេ ជាស្រុកដើមរបស់ខ្លួនវិញ ។ ដល់កុមារហ្សេហ្សឺ មានអាយុ ១២ ឆ្នាំ មាតាបិតា កំប៉ាននាំទៅក្រុងហ្សេរូសាឡឹម ដើម្បីធ្វើបុណ្យប៉ាក់ (Pâque) ។ លុះបុណ្យនោះស្រេចហើយ មាតាបិតាស្រាប់តែបាត់កូនរកមិនឃើញ ដោយការច្របូកច្របល់ធំធេមហាជនច្រើន, ដល់ពេលល្ងាច ស្រាប់តែក្រឡេកឃើញហ្សេហ្សឺ កំពុងអង្គុយអធិប្បាយក្នុងចំណោមនៃអ្នកប្រាជ្ញក្នុងក្រុមមួយ ក៏នាំគ្នាត្រឡប់វិលមកកាន់ភូមិណាសារេថវិញ ។

ដល់អាយុបាន ៣០ ឆ្នាំ ហ្សេហ្សឺបានទទួលនាមបញ្ញត្តិថាជាអ្នកបូលសាសន៍ជាបុត្រព្រះម្ចាស់សួគ៌អំពីហ្សឺដ – បាប្ទីស្ត (Jean-Baptiste) នៅមាត់ទន្លេហ្សរដាំង (Jourdain) នៅវេលានោះគេឃើញមានពន្លឺចាំងមកពីកន្លែង

មេឃចំលើកស្បាលហ្ស៊ីហ្ស៊ីហើយឮសូរសព្ទថា "នេះបុត្រសំឡាញ់ខ្ញុំ ដែលខ្ញុំមានសេចក្តីស្នេហាជាទីបំផុត" ។ គេលនោះគេយល់ថា គ្មរិញ្ញាណរបស់ព្រះជាម្ចាស់សួគ៌ចុះមកស្ថិតក្នុងរូបហ្ស៊ីហ្ស៊ី ពាំងសូរសព្ទនោះគឺជាសូរសៀងរបស់ព្រះជាម្ចាស់សួគ៌ទ្រង់ប្រទានពរ ។ ហេតុអស្ចារ្យត្រឹមប៉ុណ្ណេះ ហ្ស៊ីហ្ស៊ីក៏ឈ្មោះថាបានសំរេចគុណវិសេសហើយ ។

លំដាប់អំពីនោះមក ព្រះហ្ស៊ីហ្ស៊ីបានចូលទៅរកទីសូប់ស្ងាត់ដើម្បីល្បងមើលអស់ពាំងពួកចិសាចពាជតូត ហើយអត់អាហារបានអស់រវាង ៤០ ថ្ងៃ, លុះចេញអំពីទីនោះមកវិញ គ្រឡប់មកកាន់ឃុំគាល្លីឡេតាំងចាប់ផ្តើមប្រកាសសាសនាថ្មី តាមលំដាប់ឆ្ពោះទៅពាំងស្រុកចាំឡេ-ស្ពីន ។

របៀបការផ្សាយសាសនានេះ, បើរួបរួមមក, ព្រះហ្ស៊ីហ្ស៊ីប្រើ ៤ ប្រការ ២ យ៉ាងគឺ គាំងខ្លួនជាសាស្តាចារ្យទេសនាប្រៀនប្រដៅ ទំងគាំងជាគ្រូពេទ្យព្យាបាលពេគផ្សេងៗឥតយកឈ្នួល ។ មនុស្សដែលគាត់ប្រទានឲ្យព្យាបាលពាំងអម្បាលម៉ាន គោះបើពិពាគមគាត់ខ្លាក់ខ្ញីនគ្មថ្លង់ភ្លេងភ្លង់ដើងដៃយ៉ាងណា ក៏គង់ក្លាយទៅជាមនុស្សពូកែរឹងប៉ឹងឡើងបាន សូម្បីមនុស្សដែលខើបនឹងស្លាប់ហើយរវាង ៣-៤ ថ្ងៃ ក៏បែរជាមានជីវិតរស់ឡើងវិញ រហូតដល់បានមនុស្សពាំងនោះមកជាសាវករបស់ខ្លួនផង ។

ឯសាវកបស់ហ្ស៊ីហ្ស៊ីមាន ១២ នាក់គឺព្យារ, អង់ដ្រេ, ហ្សាក់, ហ្សង់, ហ្វីលីប្ប៉ូ, ថាតេលេម៉ី, ដូម៉ាស់, មាត្ថឺ, ហ្សាក់, ថាដ្ដេ, ឌីងហ្ស៊ាស់, ឥស្កាវីយ៉ូត ។ កាលបើព្រះហ្ស៊ីហ្ស៊ីមានសាវកដូច្នេះហើយ ទើបហៅសាវកទាំងនោះមកប្រជុំគ្នា ហើយអនុញ្ញាតឲ្យដួយផ្សាយដំណឹងល្អ តាមបែបបទរបស់ខ្លួនតទៅ ។ ឯកិច្ចដែលប្រដៅនោះ ព្រះហ្ស៊ីហ្ស៊ីបានផ្តាំទុកច្រើនយ៉ាងមានដើមថា "ហានសួគ៌មកជិតហើយ, ត្រូវព្យាបាលពេគ្រប់យ៉ាងកុំបាច់យកវ៉ាន់, មិនត្រូវមានមាស-ប្រាក់ក្នុងវៀរបង្កេះរបស់ខ្លួន, មិនត្រូវមានសម្លៀកបំពាក់ពីបន្ទាស់ឡើងទៅទេ. មិនត្រូវពាក់ស្បែកដើង, មិនត្រូវមានដំបងឈើច្រត់ . . . . . ." ។

ពួកគ្រិស្តសាវកទាំងនោះ បានទទួលគ្រិស្តាភ័នហើយ ក៏ត្រៃចវង្កាត់ទៅកាន់ស្រុកតួច-ធំនិគមជនបទ ទំព័តពន្លឺកផ្សាយគ្រិស្តសាសនាខួរទៅក្នុងប្រទេសស៊ីរីទាំងមូល ។ អាស្រ័យទៅបាយទាំង ២ ប្រការនេះហើយ ទើបពួកអ្នកស្រុកស៊ីរីទាំងមូលនាំគ្នាឈូឆគ្នូកឡឹកចុះចូលជាច្រើនជាហេតុនាំឲ្យពួកហ្វារីស្សៀង មិនសប្បាយចិត្ត នាំឲ្យពួកវង្គបាលកើតសេចក្តីរង្គើស, ទើបក្រុមវង្គបាលរិះគិតទៅបាយនឹងចាប់ខ្លួនហ្ស៊ីហ្ស៊ីយកទៅប្រហារជីវិត ។

ថ្ងៃមួយជាគាលកម្មរបស់ហ្ស៊ីហ្ស៊ី នាំបណ្តាលឲ្យពួកហ្ស៊ីដាត់ជាសាវកបស់ខ្លួនកើតចិត្តអាឃាតព្យាបាទឡើង បានចូលទៅជានាអះ

អាងទន្លេខ្លួនស្វែងរកចាប់គ្រងឯងជូនរដ្ឋបាល ដោយរង្វាន់ប្រហែល ៣០ រៀលប៉ុណ្ណោះ ។ ចួនវេលានោះជាឧកាសបុណ្យចូ៉ាក់ (Pâque) ព្រះហ្សីហ្សឺប្រជុំសាវកទាំង ១២ នាក់ មកលៀងគោជនាហារពេលល្ងាចជាមួយគ្នាហើយប្រាប់ថា "បណ្តាអ្នកទាំងអស់គ្នានេះ មានអ្នកម្នាក់គិតក្បត់ខ្ញុំ" ថាហើយហុចនំបុ័ងចែកទៅឲ្យពាល់គ្នារួចថា "អ្នកពាល់គ្នាចូរបរិភោគទៅ នេះជាសាច់របស់ខ្ញុំ" រួចហុចស្រាទៅឲ្យទៀតប្រាប់ថា "អ្នកពាល់គ្នាផឹកទៅ នេះជាឈាមរបស់ខ្ញុំ..." ។

លុះស្រែចកត្តកិច្ចពេលល្ងាចហើយ ព្រះហ្សីហ្សឺនាំសិស្សគណទាំងនោះទៅកាន់ភ្នំ អូលីវីយេរ (Olivier) ។ លោយប់នោះជាអវសានរាត្រីរបស់ព្រះហ្សីហ្សឺ, ហ្សីដាត់នាំពួកសេនាធិបាន ទៅដល់ទៅចាប់ប្លាន់ចង់ឲ្យបណ្តើរនាំមកជូនប៉ុង់ប៉ីឡាត់ (Ponce Pilate) ជាចៅហ្វាយខេត្តហ្សឺដេ ដែលបួបដុំទៅដោយក្រែមតុលាការទំនឹងក្រុមតំណាងពួកស្តេកក្នុងទីនោះ ។ ខណៈនោះព្រះហ្សីហ្សឺជាបុគ្គលកំព្រា ពួកសាវកគេចចោលអស់រលីង នៅសល់តែព្យរម្នាក់ឯងតាមទៅជាមួយដើម្បីចាំមើលផលបំផុតនៃហេតុការណ៍ ។

មន្ត្រីពាំងនោះពាំលាកកាត់ទោសព្រះហ្សីហ្សឺថាត្រូវប្រហារជីវិតបង់ ទើបចាត់ប្រើពេជ្ឈឃាដឲ្យនាំទៅកាន់ភ្នំគោលគោត្តា (Golgotha) ជាទីសម្រាប់ពិឃាដនៅដិតក្រុងហ្សេរូសាឡឹម ដល់ហើយពួកពេជ្ឈឃាដ

កំចាប់ព្រះហ្សីហ្ស៊ូឆ្កាងទាំងរស់តគ្រាប្រណី ក្នុងពេលជាមួយនឹងចោរ
ឫទ្ធិ ២ នាក់ ដែលមានទោសត្រូវដល់ការឆ្កាង ទៅសង្ឃឹង (ឆ្នេងស្តាំ)
ព្រះហ្សីហ្ស៊ូ ។

មុខគួរឲ្យអនិច្ចាដល់រូបព្រះហ្សីហ្ស៊ូ! កាលបើត្រូវទុក្ខវេទនាគ្រប
សង្កត់ទៀបផុតរលត់ជីវិតនិទ្ទិយយ៉ាងនេះហើយ ចេះតែស្រែកហៅព្រះ
ជាម្ចាស់សួគ៌ឲ្យជួយ ពុះស្រែកលួចឡើងថា "ព្រះម្ចាស់ខ្ញុំ, ព្រះម្ចាស់ខ្ញុំ,
ហេតុអ្វីក៏ទ្រង់បោះបង់ចោលខ្ញុំ" (Eli, Eli, lamma sabachthani) ។
ទៅវិញផុតស្រែកនេះ, ព្រះហ្សីហ្ស៊ូក៏ផុតរលត់អស្សាសបស្សាស: ទៅ
វេលាល្ងៃលមោង ៣ ក្នុងថ្ងៃនោះកងរាជអាយុ ៣៣ ឆ្នាំ ។ ដល់វេលា
ល្ងាច, មានកុដុម្ពីក៍ម្នាក់ឈ្មោះហ្សូសែហ្វ ចាន់ចូលមកសុំរូបសពព្រះ
ហ្សីហ្ស៊ូអំពីប៉ុន្ទីយ៉ាឡាត់យកទៅបញ្ចុះទុកនៅក្បែរទីខ្មោះ ។

មានដំណាលថា កាលព្រះហ្សីហ្ស៊ូរស់នៅឡើយ ចាន់ផ្តាំទុកថា
ខ្លួននឹងមានជីវិតឡើងវិញក្នុងថ្ងៃទី ៣ អំពីថ្ងៃមរណកាល ។ ហេតុនេះ
ហើយចាន់ជាមានគាហានខ្លះ ពួកស្ត្រីជាសិស្សគណៈរបស់គាត់ខ្លះ នៅចាំ
យាមក្នុងទីនោះ ដើម្បីចាំពិនិត្យមើលហេតុកេតតាមបណ្តាំព្រះហ្សីហ្ស៊ូ។

លុះគ្រប់កំណត់កាលវេលា, ព្រះហ្សីហ្ស៊ូផុះឡើងចាកផ្នូរហើយ
ហោះឡើងទៅគាន់ភ្នំ គាល្លីឡេ ជាទីប្រជុំនៃសាវកដែលចាន់សន្មតទុក
ពីថ្ងៃមុន ។ ដើម្បីនឹងត្រូតដល់ការរស់ឡើងវិញនៃព្រះហ្សីហ្ស៊ូនេះ

ទើបពួកគាត្រូលិកនាំគ្នាធ្វើបុណ្យប៉ាក់ (Pâque) ទុកជាទំនៀមរៀងរាបមក ។

ព្រះហ្សីហ្ស៊ីបានរស់ឡើងហើយ បីតនៅក្នុងលោកនេះអស់ ៤០ ថ្ងៃទៀត, ក្នុងថ្ងៃចុងក្រោយ ៤០ ថ្ងៃនេះ ព្រះហ្សីហ្ស៊ីបានប្រជុំសាវកទាំង ១២ នាក់នៅតំបូលភ្នំអូលីវែរ ហើយផ្តាំទុកជាបច្ចិមឧទាន ថា "អ្នកទាំងឡាយទៅចុះ ចូរអ្នកបង្រៀនជនជាតិទាំងពួង ហើយញ៉ាំងជនទាំងនោះឲ្យចូលសាសន៍ដោយនាមរបស់បិតា របស់បុត្រនឹងព្រះវិញ្ញាណ, ញ៉ាំងជនទាំងនោះឲ្យប្រព្រឹត្តតាមបញ្ញត្តដែលខ្ញុំបានបញ្ញត្តហើយ ឥឡូវនេះឯងឈ្មោះថាខ្ញុំបានបិតនៅជានិច្ចជាមួយអ្នកទាំងអស់គ្នា ដរាបដល់កាលទីបំផុតនៃលោក" ។

លុះចប់បច្ចិមឧទាននេះហើយ, ព្រះហ្សីហ្ស៊ីក៏ហោះទៅកាន់ឋានសួគ៌ ហើយចូលទៅអង្គុយខាងស្តាំនៃព្រះម្ចាស់សួគ៌ជាបិតា ។ ដើម្បីនឹងរំឭកដល់ថ្ងៃដែលព្រះហ្សីហ្ស៊ីហោះទៅកាន់ឋានសួគ៌នេះឯង ពួកគ្រិស្តបរិសទ្យនាំគ្នាធ្វើបុណ្យអសង់ស្យុង (Ascension) ជាទំនៀមតមក ។

គ្រាយថ្ងៃដែលព្រះហ្សីហ្ស៊ីឡើងទៅកាន់សួគ៌លោកបាត់ទៅ, មានដំណាលថា: ព្រះវិញ្ញាណមានអាការដូចជាអណ្តាតភ្លើងចុះមកឋានសួគ៌មកសណ្ឋិតក្នុងរូបសាវកទាំងនោះ។ ទើបឈ្មោះថាបានពេញលក្ខណៈជាសាវក ហើយនាំគ្នាប្រកាសគ្រិស្តសាសនាតរៀងមក ។ អស្រ័យ

ហេតុនេះ ទើបពួកគ្រិស្តសាសនិកជននាំគ្នាធ្វើបុណ្យបន្តឹកូត៏ Pentecôte) ដើម្បីទុំដូសដល់ថ្ងៃដែលព្រះវិញ្ញាណចុះមកស្ថានសួគ៌ ។

បញ្ញត្តិរបស់ព្រះម្ចាស់សួគ៌ ១០យ៉ាង

១— ត្រូវគោរពបូជាព្រះម្ចាស់សួគ៌[1]

២— មិនត្រូវប្រមាថព្រះនាមព្រះអង្គឬយកមកសច្ចប្រសែរលេង

៣— ថ្ងៃអាទិត្យត្រូវញ៉ាំងខ្លួនឲ្យបរិសុទ្ធ[2]

៤— ត្រូវគោរពមាតាបិតា[3]

៥— មិនត្រូវធ្វើមនុស្សឃាត[4]

៦— កុំប្រព្រឹត្តទុច្ចរិត

៧— កុំគប្បីកាន់យកទ្រព្យអ្នកដទៃ

---

១ ពួកកាតូលិកជឿថា ព្រះមានតែមួយគឺព្រះអ្ងាស់សួគ៌ (Dieu) មានជីវិតរស់នៅជាដរាបមិនចេះប្បែរ ជាអ្នកបង្កើតពិភពលោក ព្រមទាំងធម្មជាតគ្រប់យ៉ាងត្រឹម ៦ ថ្ងៃប៉ុណ្ណោះ គឺថ្ងៃទី ១ បង្កើតពន្លឺគឺព្រះអាទិត្យ ឆ្ងាយព្រះចន្ទ, ថ្ងៃទី ២ មេឃឆ្ងាយដី, ថ្ងៃទី ៣ សមុទ្រ, ថ្ងៃទី ៤ ផ្កាយ, ថ្ងៃទី ៥ បក្សីចក្រា មច្ឆាមច្ឆា, ថ្ងៃទី ៦ ទ្រង់បង្កើតមនុស្សគូបុរសស្ត្រី គឺអាដាមឆ្ងាងតាងអែវ (Adam, Eve) ។ ២ ថ្ងៃអាទិត្យជាថ្ងៃព្រះ ត្រូវញ៉ាំងខ្លួនឲ្យបរិសុទ្ធិ គឺត្រូវបញ្ឈប់កិច្ចការឯទៃក្រៅអំពីកិច្ចសាសនា ។ ៣ ត្រង់នេះសូម្បីអ្នកធំឯទៃក្រៅអំពីមាតាបិតាក៏ត្រូវគោរព ព្រមទាំងជួយបំពេញកិច្ចការសម្រាប់ជាតិភូមិ ។ ៤ ត្រង់នេះសូម្បីខ្លួនឯងក៏មិនត្រូវសម្លាប់, តែបុគ្គល ៣ ពួក ដ៏ពួកទីពបថ្នាមិត្ត មនុស្សមានទោសគួរប្រហារជីវិតឆ្ងាយោរដើលបម្រុងមកប្រហារជីវិតខ្លួន ត្រូវសម្លាប់បាន ។

៨– កុំពោលពាក្យគុហាក់

៩– ត្រូវកំចាត់សេចក្តីច្រណែនចេញ

១០– មិនត្រូវរំពៃរកទ្រព្យអ្នកដទៃ ។

វិធីបួលសាសន៍

វិធីនេះប្រកបដោយអង្គ ២ គឺ ទឹក និងវាចាវិញ្ញត្តិរបស់សង្ឃរាជ ។ សាមីខ្លួនបរិសទ្យអ្នកបួលសាសន៍ ត្រូវបួលទៅរកសង្ឃរាជឲ្យស្រោចទឹក (សុទ្ធ) លើក្បាលហើយប្រសិទ្ធីឲ្យថា "ខ្ញុំប្រសិទ្ធីអ្នកដោយនាមរបស់បិតា និងបុត្រនិងព្រះវិញ្ញាណ" ។ ដោយកិច្ចប៉ុណ្ណោះ បុគ្គលនេះឈ្មោះថាបានជាបុត្ររបស់ព្រះដ៏ម្ចាស់ ហើយបានរួចចាកបាបសព្វយ៉ាង ដែលខ្លួនបានធ្លាប់មកហើយតាំងអំពីកំណើត និងបានទៅកើតក្នុងឋានសួគ៌។

ពិធីលាងបាប

បាបចែកចេញជា ២ យ៉ាងគឺ បាបធ្ងន់និងបាបស្រាល ។ បាបធ្ងន់បានដល់កំហុសដែលកើតឡើងព្រោះការប្រព្រឹត្តកន្លងបញ្ញត្តិយ៉ាងធ្ងន់ៗ របស់ព្រះដ៏ម្ចាស់សូគ៌ប្រកបដោយចេតនាក្លែង; បាបស្រាលបានដល់កំហុសដែលប្រព្រឹត្តកន្លងបញ្ញត្តិយ៉ាងស្រាលៗ របស់ព្រះដ៏ម្ចាស់ ឬកំកន្លងបញ្ញត្តិយ៉ាងធ្ងន់ ប៉ុន្តែមិនប្រកបដោយចេតនាក្លែង ។ បាបទាំង ២ ប្រការនេះកើតឡើងដោយសមុដ្ឋាន ៤ គឺ ការគិត, ការនិយាយ, ការធ្វើ និងសេចក្តីប្រាថ្នាសេចក្តី ។

បុគ្គលដែលប្រកបដោយទោសស្រាល មិនចាប់ធ្វើពិធីលាងបាបក៏បាន, បើមានទោសធ្ងន់ត្រូវធ្វើពិធីលាងបាប ព្រោះជាទោសអាចឲ្យឆ្លាត់ទៅនរក ។ ឯពិធីលាងបាបនោះ អ្នកប្រព្រឹត្តកន្ទុងត្រូវទៅសំដែងទោសំនោះកង់វិហារចំពោះលោកសង្ឃ (Prête) ដើម្បីឲ្យអត់ទោសឲ្យ ។ ពិធីនេះ គ្រូសួបរិសេឲ្យត្រូវធ្វើយ៉ាងតិចក្នុងមួយឆ្នាំម្តង ។

លោកទាំងបី

លទ្ធិនេះប្រកាន់ថា លោកទាំងបីមាន ៣ គឺ ស្ថានសួគ៌, ស្ថាននរក, និងស្ថានសម្រាប់ប្រព្រឹត្តបៈ ។ ស្ថានសួគ៌និងស្ថាននរកទៀង, បុគ្គលដែលស្លាប់ទៅ ព្រលឹងរបស់បុគ្គលនោះ ត្រូវទៅឲ្យជួបនឹងព្រះម្ចាស់សួគ៌ឲ្យទ្រង់វិនិច្ឆ័យសេចក្តីឲ្យ; បើខ្លួនបរិសុទ្ធ ត្រូវបានទៅកើតស្ថានសួគ៌, បើមានទោសធ្ងន់ ត្រូវទៅកើតកង់ស្ថាននរក; បើមានទោសស្រាល ព្រះម្ចាស់សួគ៌ជាក់ទណ្ឌកម្មឲ្យទៅកាន់ទីមួយសម្រាប់ប្រព្រឹត្តបៈញ៉ាំងខ្លួនឲ្យបរិសុទ្ធិ ហើយនឹងបានទៅកើតស្ថានសួគ៌នៅវេលាក្រោយដែលរួចទោសហើយ ។ បុគ្គលដែលបានទៅកើតកង់ស្ថានសួគ៌ក្តីនរកក្តីលែងច្យុតប្រែប្រួលទៅកាន់ទីណាទៀត ។

ដល់ទីបំផុតនៃលោកនេះ មនុស្សដែលស្លាប់ទៅអម្បាលម៉ាន នឹងរស់ឡើងវិញ ។ នៅវេលានោះ ព្រះហ្ស៊ីហ្ស៊ូនឹងចុះចាកសួគ៌មកកាន់ពិភពលោកនេះម្តងទៀត ដើម្បីនឹងពិនិច្ឆ័យសេចក្តីឲ្យសត្វលោកជាកិច្ចទីបំផុត ។

(មានត)

តំណឹងព័ត៌មានផ្លូវការ

ចំពោះសិស្សដែលប្រឡងជាប់សញ្ញាប័ត្រសាលាជាន់ខ្ពស់

របស់សមាគមមិត្តសាលាចាស់

កាលពីថ្ងៃទី ៥ ខែមិនា (មាឬ) ឆ្នាំ ១៩៩០ មានមហាសន្និបាត ជាអស្ចារ្យនៅសាលាជាន់ខ្ពស់ ដោយសមាគមមិត្តសាលាចាស់ដែលមានលោក ប៉ុយ-ប៊ុក ជាអធិបតីនៃសមាគមនេះ ផ្តើមធ្វើឡើងដើម្បីប្រគេនរង្វាន់ជាឧឡារិកដល់សិស្សសាលាជាន់ខ្ពស់ ដែលប្រឡងជាប់សញ្ញាប័ត្រ ។ រឿងនេះគួរតែផ្សាយដំណរលោក-អ្នកសប្បុរសទាំងឡាយឲ្យជ្រាប ដើម្បីនឹងបានចូលអនុមោទនាឲ្យសម្រេចផលស្មើៗគ្នា ។

ឯទេយ្យវត្ថុដែលប្រគេនដល់សិស្សទាំង ៣៧ រូបនោះ មិនមែនជារបស់សមាគមមិត្តសាលាចាស់តែមួយទេ គឺជាអំណោយពីក្រសួងនានាមានក្រសួងធម្មការជាដើមយកមកឧទ្ទិសថ្វាយ, ទេយ្យវត្ថុទាំងនោះបើគិតជាលុយទឹកប្រាក់វិញ ប្រហែលជាង ១ ម៉ឺនរៀល ។

នៅថ្ងៃទី ៥ មិនា វេលាម៉ោង ៤ ព្រឹកឧបាសកជាអម្ចាស់ដីវិតលើត្បូងស្តេចយាងទៅជាព្រះរាជាធិបតីក្នុងពិធីនេះ, មានឥស្សរជនជាច្រើនបានអញ្ជើញទៅដែរ គឺលោកអ្នកឧកញ៉ា យ៉ែម-សំបូរ នាយករដ្ឋមន្ត្រី, លោកអ្នកឧកញ៉ា ស៊ុម-ហាង៉ ឧបនាយករដ្ឋមន្ត្រី, លោកអ្នក

ទុកញ៉ា អ៊ុម - ឃាង់ស៊ុន ប្រធានក្រុមប្រឹក្សាព្រះពុទ្ធសាសនាចក្រ និង
លោកវេជ្ជមន្ត្រី ក៉ុយ - ល្នត, ឃុត - ឃឿន, នាល - ផ្ទែង, ផ្ទេក - ភឿន
ជាដើម នៅមានឥស្សរជនជាច្រើនទៀតដែលបានអញ្ជើញទៅផង ។

ខាងព្រះសង្ឃ មានសម្តេចព្រះសុធម្មាធិបតីអ៊ុង - ស្រ៊ី សង្ឃនាយក
គណៈធម្មយុត្តិ, សម្តេចព្រះធម្មលិខិត ល្វី - ឯមទត្តមប្រឹក្សា, ព្រះមហាសុ-
មេធាធិបតី ជួន - ណាត សង្ឃនាយក គណៈមហានិកាយ, ព្រះពោធិវង្ស
ហួត - តាត ចាង់ហ្វាង់សាលាចាលីជាន់ខ្ពស់, ព្រះមហាព្រហ្មមុនី ខេត - អ៊ូ
និងព្រះពុទ្ធគណៈ ហានានុក្រម ជាច្រើនអង្គបានឧបត្ថម្ភទៅដួបជុំផង ។
ខាងអស់លោកអ្នកដំនួញក៏បានអញ្ជើញទៅជាច្រើននាក់ មានលោកទុក-
ញ៉ាវិសេសកោគា ខា - ជាវលី និងលោកទុកញ៉ាសិរីសម្បត្តិ អឹង - ឌិន - អួន
ជាដើម, ខាងពួកឧបាសិកាក៏បានអញ្ជើញទៅជាច្រើននាក់ដែរ មាន
លោកស្រី សំ - សារី អធិបតិនីនៃសមាគមទេមរសេហជីវិនីជាដើម ។

លុះដួបជុំគ្រប់ក្រមហើយ លោក ក៉ុយ - ប៊ុក អធិបតីសមាគមមិត្ត-
សាលាចាលីបានសូត្រសុន្ទរកថាមួយ, បន្ទាប់មក ព្រះតេជព្រះគុណព្រះ
ពោធិវង្ស ហួត - តាត ចាង់ហ្វាង់សាលាចាលីជាន់ខ្ពស់បានសូត្រសុន្ទរកថា
មួយទៀតដើម្បីទទួលអំណរ ។ តមកទៀត លោកវរសេនីតិសំ - ញាណ
អធិបតីរងសមាគមមិត្តសាលាចាលី បានសូត្រព្រហ្មទេយ្យហៅនាម
ព្រះសង្ឃដែលត្រូវទទួលសញ្ជាប័ត្រ ។ ព្រះគុណជាអម្ចាស់ជីវិតលើ

ត្បូងខ្ញុំព្រះករជនានសញ្ញាប័ត្រ ដល់ព្រះសង្ឃគ្រប់អង្គ រួចហើយខ្ញុំព្រះករជនាវង្វាន់ ។ បន្ទាប់មក អស់លោកជាគានាធិបតីទាំងឡាយបានប្រគេនទេយ្យវត្ថុផ្សាល់ដៃរៀងខ្លួន ។

លុះស្រេចកិច្ចប្រគេនហើយ, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងមុននឹងស្តេចចាកមហាសន្និបាត ទ្រង់ថ្វាយព្រះពរអំណរចំពោះព្រះសង្ឃអ្នកប្រឡងជាប់ទាំង ៣៧ អង្គផង ចំពោះសមាគមមិត្តសាលាបាលីដែលជាអ្នកបួចផ្តើមធ្វើកិច្ចនេះផង ចំពោះអស់លោក-អ្នកប្រុសស្រីជាគានាធិបតីទាំងឡាយផង, ក្នុងទីបំផុត ព្រះរាជាទ្រង់គ្រាស់សរសើរថា "ការប្រគេនវង្វាន់ដល់ព្រះសង្ឃក្នុងគ្រានេះ ជាកិច្ចមួយមានផលយ៉ាងសំខាន់ណាស់ ឈ្មោះថាបានសួយព្រះពុទ្ធសាសនាឲ្យមានកិត្តិយសរុងរឿងផង ជួយលើកកម្ពស់រដ្ឋឲ្យបានខ្ពង់ខ្ពស់ប្រយោជន៍ដោយមានអ្នកចាស់ច្រើនផង" ។

សុន្ទរកថា

លោកវ៉ាយ - ប៉ុកអធិបតីសមាគមមិត្តសាលាបាលី

ថ្ងៃក្នុងឧកាសបុណ្យប្រគេនឆ្នាំងដែលសិស្សសាលាចាស់ជាន់ខ្ពស់ ដែលបាន
ប្រឡងជាប់សញ្ញាប័ត្រសាលាចាស់ជាន់ខ្ពស់

សូមព្រះតេជៈដ៏កល់លើត្បូង,

សូមព្រះពុទ្ធគុណប្រណិប្បណ្តិទូលថ្វាយគ្រែមណ្ឌលធូលីព្រះបាទព្រះករុណា
ជាអម្ចាស់ជីវិតលើត្បូង,

សូមគ្រាបថ្វាយបង្គំ សម្តេចព្រះសុធម្មាធិបតី សង្ឃនាយក,

" សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា,

" ព្រះតេជព្រះគុណ ព្រះមហាសុមេធាធិបតី សង្ឃនាយក,

" " ព្រះពោធិវង្ស ចាងហ្វាងសាលាចាស់ជាន់ខ្ពស់,

" " ជាព្រះឋានុត្តរៈ,

ទាំង,

ព្រះតេជព្រះគុណ នាយករដ្ឋមន្ត្រី ទាំង រដ្ឋមន្ត្រីគ្រប់ក្រសួង,

អស់លោក-អ្នកចាំនឹងឮយ,

ទូលព្រះបង្គំជាខ្ញុំ, ខ្ញុំព្រះករុណា ខ្ញុំប្រថុច ខ្ញុំបាទ ជាតំណាង
សមាគមមិត្តសាលាចាស់ សូមទទួលព្រះពុទ្ធអំណរដ៏ក្រៃលែង ចំពោះ

ស្តេចយួលព្រះចាត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់មានព្រះ
ភជ្ឈាស័យដ្រះថ្វាក្នុងព្រះពុទ្ធសាសនា ចានស្តេចមកជាព្រះពាជាធិបតី,
សូមទទួលអំណរដ៏ក្រៃពេកចំពោះសម្តេច នឹង ព្រះថេរានុត្ថេរៈ, ចំពោះ
ព្រះតេជព្រះគុណានាយករដ្ឋមន្ត្រី នឹង រដ្ឋមន្ត្រីគ្រប់ក្រសួង, ចំពោះអស់
លោក-អ្នកទាំងឡាយ ដែលមានបសាទសទ្ធាចានឧទ្ទិស-អញ្ជើញមកជា
មង្គលកងពិធីបុណ្យប្រគេនទេយ្យវត្ថុដល់សិស្សសាលាចាលីជាន់ខ្ពស់ ។

ក្នុងឱកាសនេះ ខ្ញុំលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំប្រចាទ ខ្ញុំចាទ
សូមក្រាបបង្គំទូល សូមឥត សូមជំរាបថា ព្រះសង្ឃដែលគង់ក្នុងទី
ចំពោះព្រះភក្ត្រចំពោះមុខនេះហើយ ដែលទើបប្រឡងជាប់សញ្ញាប័ត្រ
សាលាចាលីជាន់ខ្ពស់ ក្នុងឆ្នាំ ១៩៥០ នេះ ។ តិក្ខសាមណេរជាសិស្ស
សាលាចាលីជាន់ខ្ពស់ទាំងអម្បាលនេះ សឹងចានបំពេញព្យាយាមរៀន
ព្រះបរិយត្តិ ដើម្បីសែងយកនូវារសនៃព្រះធម៌នុ៎ះ ក្នុងព្រះពុទ្ធសាសនា
ដោយការស៊ូទ្រាំលំបាកនឿយហត់ អស់កាលចំនួន ៤ ឆ្នាំ ទើបសម្រេច
អវសានតិច្ច ចានប្រឡងជាប់សញ្ញាប័ត្រ ។

ព្រះពុទ្ធសាសនាក្នុងភពិជរដ្ឋ ដែលរុងរឿងរៀងពបជពបមក
រហូតដល់មានតិត្តិសព្ទឆ្ងាយដល់ប្រទេសឥណ្ឌាប្រទេសចាង់ជាដើម
ដឹងឮថាជារដ្ឋមានពុទ្ធសាសនាប្រតិស្ឋានមាំមួន ក៏ដោយអាស្រ័យវិជ្ជា
ស្ថានគឺសាលាចាលីជាន់ខ្ពស់ ដែលមានតិក្ខសាមណេរជាសិស្ស ចាន

បំពេញវិញ្ញត្តិរបស់ពុទ្ធសាសនាដោយម៉ឺងម៉ាត់ ។ សាលាបាលីជាន់ខ្ពស់នេះ ជាមរតកនៃលួងជួលព្រះបាទព្រះករុណាជាម្ចាស់ជីវិតលើត្បូង ទាំងជាកេរ្តិ៍កោះរបស់យើងទាំងឡាយ ដែលគួរស្ងួនភ្ងាថែរក្សាទុកឲ្យខាងតែគង់វង់ជាអង្វែងទៅ, ព្រោះសាលានេះ បុព្វបុរសរបស់យើងបានបង្កើតឡើងដើម្បីរក្សាទុកនូវព្រះពុទ្ធសាសនា, អក្សរសាស្ត្រខ្មែរ, វប្បធម៌ខ្មែរ, ប្រពៃណីខ្មែរ ជាពស្តុតាងបញ្ជាក់តាពខ្មែរ ដែលមិនអាចរលាស់ចោលចេញ ឬលាក់បំពួនទៅបានឡើយ ។ អាស្រ័យហេតុនេះ, ទើបខ្ញុំព្រះបង្គំជាខ្ញុំព្រះករុណា ខ្ញុំប្រថុច ខ្ញុំបាទទាំងឡាយ បង្កើតសមាគមមិត្តសាលាបាលី កាលពីថ្ងៃ ១៧ ខែសីហាឆ្នាំ ១៩៤៩ នោះឡើង ដើម្បីឲ្យបានជាកម្លាំង ១ របស់សាលាបាលីជាន់ខ្ពស់ សម្រាប់ជំនួយ ផ្តល់ប្រយោជន៍លើកកម្លាំង ឲ្យជាកិយ្យាកាពតទៅ ។

ក្នុងវេលានេះ សមាគមបានផ្តើមធ្វើបុណ្យប្រគេនទេយ្យវត្ថុជាកិច្ចលើកដំបូង ដើម្បីលើកទឹកព្រះទ័យនៃនិស្សិតសាលាបាលីជាន់ខ្ពស់ដែលបានខំប្រឹងបំពេញកិច្ចព្យាយាមតាមកំតែបាប់សាលា ។ ពិធីបុណ្យនេះ សមាគមមិត្តសាលាបាលី បានយកតម្រាប់តាមមហាប្រទេសក្នុងសកលលោក ដែលគេធ្លាប់តែធ្វើជាគ្រឿងលើកទឹកចិត្តនៃនិស្សិតរបស់គេ ព្រមទាំងប្រតិបត្តិការតាមគោលបំណងនៃលក្ខន្តិក: សមាគមនេះ ត្រង់ប្រការ ៤ ថា "ទំនងជួយឧបត្ថម្ភអ្នកសិក្សាការសាបាលី ទំនងអក្សរសាស្ត្រ ដោយ

គ្រឿងសម្ភារៈ ទឹង សីលធម៌" ។ សូម្បីកាលពុទ្ធកិសមាគមដែលពុទ្ធបរិសទ្យខ្មែរយើង ចានបង្កើតឡើងពីលើកមុននោះ ក៏មានធ្វើពិធីប្រគេនវត្ថាន់ដល់សិស្សសាលាចាលីជាន់ខ្ពស់ដែរ ។

កឋិនពិធីបុណ្យនេះ សមាគមមិត្តសាលាចាលីមានចិត្តសោមនស្សយ៉ាងខ្លាំង ចំពោះព្រះពុទ្ធជ្ឈាធ័យនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលចានស្តេចមកជាព្រះពុទ្ធជាធិបតីផង ចំពោះទឹកព្រះទ័យនៃសម្តេចនឹងលោក-អ្នកទាំងឡាយ ដែលចានទិមន្ត - អញ្ជើញមកជាមង្គលផង, សូមកំណាត់ទុកមិនក្ងេច នូវបុញ្ញាភិលិខិតគាលជាថ្ងៃទក្ខត្តបុក្ខដ៏ប្រកបដោយអច្ឆរិយ-ភាព ទុកជាអនុស្សាវរីយ៍តទៅអនាគតកាល ។ ហេតុដែលឲ្យមានសេចក្តីត្រមេត្រៃនេះ មិនមកអំពីអ្វីទេ គឺដោយព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់មានយោបល់ឈ្វេងយល់ ត្រមទាំងយល់ឃើញនូវសារប្រយោជន៍ដ៏ធំធូលាយនៃសាលាចាលីជាន់ខ្ពស់ ត្រមទាំងមានសេចក្តីស្មោះសរសាទរចំពោះការព្យាយាមសិក្សារៀនសូត្រចស់សិស្សសាលាចាលីជាន់ខ្ពស់ ។ គេលវៀលជាមង្គលមានអច្ឆរិយភាពចស់សមាគមមិត្តសាលាចាលីនេះ ជាគុណដ៏សំខាន់អាចនាំបណ្តាលឲ្យមានកិត្តិស័ព្ទ បង្ហាញឲ្យឃើញច្បាស់ថា "ពុទ្ធសាសនាកងកម្លាំងជាង ដែលមានសាលាចាលីជាន់ខ្ពស់ដាំឃ្មាំងធំនេះ ពួកឥស្សរជនមិនមែនជាមើលមិនឃើញនូវសារប្រយោជន៍ ដូចអ្នកខ្វះឆ្អាប់ស្មានានោះទេ" ត្រមទាំងជាគុណនាំបណ្តាលឲ្យ

ពួកសិស្សសាលាបាលីជាន់ខ្ពស់ដែលទើបនឹងប្រឡងចេញនេះ តើគប្បីតំរែកយកផ្នែកចិត្ត ក្នុងគិតដល់ការលំបាកនឿយហត់អត់ឃ្លាន កន្លងពេលខំរៀននោះបានខ្លះ ។ មិនតែប៉ុណ្ណោះ បុណ្យនេះជាសុភនិម្មិតដ៏ត្រកាល អាចបណ្តាលឲ្យសិស្សទាំងឡាយដែលកំពុងសិក្សាមិនទាន់ប្រឡងចេញ អធិដ្ឋានផ្គងទុកក្នុងព្រះទ័យថា នឹង ខំប្រឹងបំពេញកិច្ចក្នុងសាលាឲ្យបានគ្រប់គ្រាន់ដោយសេចក្តីខ្មៅឃ្មាំយ៉ាងម៉ឺងម៉ាត់ នឹង ដោយគ្មានសេចក្តីប្រមាទតទៅ ។

សូម ព្រះតេជៈដ៏កល់លើត្បូង,

សម្តេច,

ព្រះតេជព្រះគុណគ្រប់ព្រះអង្គគ្រប់រូប,

លោក - អ្នកជាពុទ្ធបរិសទ្យទាំងឡាយ,

សមាគមមិត្តសាលាបាលីដែលផ្តើមធ្វើពិធីបុណ្យនេះ មុនដំបូងមានសេចក្តីព្រួយបារម្ភ ដោយក្រែងខ្លះទេយ្យទានមិនគ្រប់គ្រាន់តាមចំនួនសិស្សដែលប្រឡងជាប់សញ្ញាប័ត្រ ទាំងក្រែងមិនមានសាមគ្គីធម៌កន្លងកិច្ចសន្និបាត, តែឥឡូវនេះ ការគាននឹងចិត្តទាំងអម្បាលណោះខ្ជាត់ខ្ជាយអស់ទៅហើយ ត្រឡប់ជាមានបីតិបាមោជ្ជៈស្រោចស្រង់ក្នុងដួងចិត្តឡើងវិញ ដោយអំណាចនៃកំឡាំងសាមគ្គីរសនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នឹងសម្តេច ព្រះតេជព្រះគុណ លោក - អ្នក ដែលតើត

មានឃើញជាក់ស្តែងក្នុងពេលនេះ ។ សមាគមមានសេចក្តីសង្ឃឹមមាំទុកជាមុនថា "ពិធីបុណ្យចែករង្វាន់ដ៏ប្រកបដោយសេចក្តីជ្រះថ្លាមានសភាពដូច្នេះ នឹងមានក្នុងឆ្នាំជាលំដាប់តទៅអនាគតពុំខានឡើយ" ។

កន្លះបំផុតនេះ សមាគម សូមថ្វាយ-ប្រគេន-ជូន នូវកុសលបុញ្ញាវាសីនេះ ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ចំពោះសម្តេចព្រះតេជព្រះគុណ លោក-អ្នកឧកញ៉ារូបនាម សូមទ្រង់ទទួល នឹង ទទួលអនុមោទនា, ដោយបុញ្ញាភាពនេះ សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់មានព្រះជន្មាយុយឺយាយុឋាន ១០០ ព្រះវស្សា សូមទ្រង់សណ្តិតក្នុងសិរីរាជសម្បត្តិដោយនូវជោគសួស្តី កុំបីមានសត្រូវបៀតបៀនឋានរហូតដល់អវសានកាល; សូមសម្តេច ព្រះតេជព្រះគុណ លោក-អ្នកជាតុន្ត-បរិសទ្យទាំងឡាយ ឋានសម្រេចធម៌ ៤ ប្រការគឺ អាយុយឺនយូរ ១ ឥណសម្បូរល្អ ១ សេចក្តីសុខកាយសុខចិត្ត ១ កម្លាំងកាយកំលាំងប្រាជ្ញា ១ ក្នុងបច្ចុប្បន្ននេះ, លុះដល់អវសានជាតិ សូមឲ្យសម្រេចព្រះនិព្វានគ្រប់រូបនាមកុំបីឃ្លៀងឃ្លាតឡើយ ។

សុទ្ធរកថា

ព្រះពោធិវង្សហ្វូត - តាតចាងហ្វាងសាលាបាលីជាន់ខ្ពស់

សំដែងក្នុងទាសប្រជេនរង្វាន់សិស្សដែលប្រឡងជាប់សញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់

សូមថ្វាយព្រះពរ ព្រះគុណជាអម្ចាស់ដ៏វិត,

សូមថ្វាយបង្គំ សម្តេចនិងព្រះតេជព្រះគុណ,

សូមចំរើនពរ ព្រះតេជព្រះគុណ

និងអស់លោក - អ្នកគាំងឡាយ.

អម្បាញ់មិញនេះ សមាគមមិត្តសាលាបាលី បានថ្វែងសេចក្តីថ្វាយព្រះពរជាអម្ចាស់ដ៏វិត ជូនព្រះតេជព្រះគុណនិងលោក - អ្នកគាំងឡាយ អំពីកិច្ចការដ៏ប្រសើរដែលសមាគមនេះបានចាត់ចែងធ្វើរួចមកហើយ ។

ឯការចែករង្វាន់កិត្តិយសមហាសន្និបាត ដែលមានព្រះករុណាជាអម្ចាស់ដ៏វិតជាព្រះពាជាធិបតី មានសភាពដូច្នេះនេះជាកល្យាណកិច្ចមួយដ៏ប្រសើរដែលនាំឲ្យមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដល់សាលាបាលីជាន់ខ្ពស់ផង ដល់សិស្សដែលប្រឡងជាប់បានសញ្ញាប័ត្រក្នុងសាលានេះផង ។

សាលាបាលីជាន់ខ្ពស់ សូមសំដែងសេចក្តីគ្រេកអរដ៏លើសលប់ចំពោះព្រះករុណាជាអម្ចាស់ដ៏វិត ដែលទ្រង់ស្តេចមកជាព្រះពាជាធិបតីនៃការបុណ្យចែករង្វាន់នេះ ព្រោះព្រះពាជដំណើរមកប្រថាប់កន្លងបាន:

ជាអត្ថិបតីការពារនេះ ប្រាកដដូចជាព្រះគុណជាអម្ចាស់ដ៏វិត ទ្រង់ប្រតិស្ឋានមគ្គលាភសីទុកក្នុងសាលាចាលីជាន់ខ្ពស់នេះតទៅ ។

ម្យ៉ាងទៀត សាលាចាលីជាន់ខ្ពស់មានអំណាចដ៏ក្រៃពេក ចំពោះកល្យាណកិច្ចដែលសមាគមមិត្តសាលាចាលី បានផ្តើមធ្វើជាដំបូងនេះ ព្រោះកិច្ចនេះនឹងនាំឲ្យមានប្រយោជន៍ច្រើនស្ថានគឺ :

១ — នឹងនាំឲ្យសិស្សទាំងឡាយដែលប្រឡងចេញពីសាលាហើយមានបីតិប្រាមោជ្ជគ្រប់រូប ។

២ — សិស្សក្នុងសាលាគប្បីថ្នាក់កងបច្ចុប្បន្នទាំងកងអនាគត នឹងចំប្រឹងរៀបរៀនសូត្រមិនធ្វេសប្រហែស ដោយសំគាល់ថា ការរៀនសូត្រព្រះបរិយត្តិធម៌នេះ ជាហេតុដឹកនាំពុទ្ធសាសនិកជនទាំងឡាយឲ្យមានចិត្តត្រេកអរសាទរ ។

៣ - នឹងបានជាមូលហេតុដឹកនាំឲ្យពុទ្ធសាសនិកជនទាំងឡាយយកតម្រាប់តាមតទៅ ។

តុកាសនេះ សាលាចាលីជាន់ខ្ពស់ សូមព្រះពុទ្ធានអភ័យទោស សូមព្រះពុទ្ធានុកាស ដើម្បីថ្លែងសេចក្តីរំលឹកប្រសើយចំពោះព្រះសង្ឃជាសិស្សសាលាចាលីជាន់ខ្ពស់ ក្នុងតុកាសដែលប្រកបដោយមហាមង្គលឫក្សនេះ ។

អស់លោកជាសិស្សទាំងឡាយ,

អស់លោកគង់ជ្រាបដឹងហើយថា ការសិក្សារៀនសូត្រចំណេះវិជ្ជា គប្បីប្រកេកក្នុងលោកនេះ រមែងធ្វើមនុស្សជាតិឲ្យមានសិរីរុងរឿងថ្កើងថ្កានដោយល្អជាប់ មិនឲ្យមនុស្សជាតិឆ្គងសាសលោកនៅជាប្រក្រតីដូចដែល ឬឲ្យចេះយកចុះចាកបានតិចតួចឡើយ; បើពោលឲ្យច្បាស់ គឺថា សេចក្តីចំរើនរុងរឿង ជាផលបានមកអំពីចំណេះវិជ្ជាៗ បានមកអំពីការសិក្សារៀនសូត្រ របស់មនុស្សក្នុងលោក ។ ក្នុងបណ្តាចំណេះវិជ្ជាទាំងអស់នោះ, ការសិក្សាព្រះបរិយត្តិធម៌ ឧទ្ទិសវិជ្ជាពាយរណ៍ជាដៃៗ ក្នុងសាលាចាលីជាន់ខ្ពស់នេះ គួរចាត់ថាជាចំណេះវិជ្ជាផ្នែកមួយក្នុងលោកបានដែរ ហើយថែមទាំងជនជាតិខ្មែរយើងក្នុងអតីតកាល ក៏ធ្លាប់និយមកាប់អានថាជាចំណេះវិជ្ជាជាន់ខ្ពស់បំផុតរបស់ជាតិ ព្រោះគោលចារឹកសំខាន់ៗ នៃវឌ្ឍនធម៌ខ្មែរ មានអក្សរសោស្តែជាដើមតាំងពីសម័យបុរាណរហូតមកដល់សម័យបច្ចុប្បន្ន រមែងពឹងផ្អែកទៅលើព្រះពុទ្ធសាសនាស្ទើរតែទាំងអស់ ។

កាលសម័យជាន់ដើម ការសិក្សាព្រះបរិយត្តិធម៌ក្នុងព្រះពុទ្ធសាសនាមានសេចក្តីលំបាកពេកណាស់ ដោយហេតុមានអាចារ្យបង្រៀនមិនបរិបូណ៌, មិនមានសៀវភៅចោះពុម្ព, មិនសម្បូណ៌ក្រដាសសរសេរ, មិនមានពេងពុម្ព, មិនមានបែបរៀនចាលីបរិបូណ៌ដូចសព្វថ្ងៃនេះ

មានតែច្បាប់សាស្ត្រាស្ទឹកតែដែលចារចំឡងតៗ គ្នាមក ថែមទាំងរកច្បាប់រៀនដោយលំបាកទៀតផង; ប៉ុន្តែទុកជាមានការលំបាកដូច្នោះក៏ដោយ អស់លោកជាបុត្តបុរសរបស់យើង លោកនៅតែខំប្រឹងសង្វាតក្នុងការរៀនសូត្រ គ្រាតែមានចំណេះចេះដឹងការសាបាលីយ៉ាងជំនាញ, មានអ្នកប្រាជ្ញរូបខ្លះ មានចំណេះចេះតែងគម្ពីរដីកាជាការសាបាលីជាភ្លើតៗ មក ដរាបដល់សម័យនេះ ។

អំណើះតមក កាលវេលាចេះតែកន្លងទៅ។ សភាពនៃប្រទេសក្នុងលោកក៏ចេះតែប្រែប្រួលទៅតាមកាលសម័យ, កិច្ចការក្នុងប្រទេសនីមួយៗ ក៏ត្រូវតែកែប្រែទៅតាមទំនងនោះដែរ, ទាំងខាងគតិលោកទាំងខាងគតិធម៌, ប៉ុន្តែការកែប្រែនោះ សុទ្ធតែដើម្បីឲ្យកើតសេចក្តីចំរើន ។ ហេតុនេះបានជាការពីគ.ស. ១៩១៤ ពួកការព្រះករុណាជាអម្ចាស់ជីវិត បានបង្កើតឲ្យមានសាលាបាលីជាន់ខ្ពស់នេះរឡើង នៅក្រុងភ្នំពេញ ប្រយោជន៍នឹងចាត់រៀបការរៀនសូត្រព្រះបរិយត្តិធម៌ទៅតាមរបៀបថ្មី ដើម្បីឲ្យកើតសេចក្តីចំរើនតាមកាលសម័យឡើង ។

អស់លោកជាសិស្សទាំងឡាយ !

កាលក្នុងពេលដែលលោកគ្រប់រូបនៅជាសិស្សកំពុងរៀនសូត្រក្នុងសាលាចំនួន ៤ ឆ្នាំ លោកដឹងស្រាប់ហើយ គឺបានខំប្រឹងយកចិត្តទុកដាក់ក្នុងការរៀនសូត្រឥតមានធ្វេសប្រហែស ឬជាដល់ពេលត្រូវប្រឡង

ចេញពីសាលា លោកក៏បានសម្រេចនូវលទ្ធផល ត្រូវបានទទួលសញ្ញាប័ត្រជូនប្រាថ្នា ប៉ុន្តែមិនត្រូវសំគាល់ថាការសិក្សារៀនសូត្រនេះសម្រេចចប់ត្រឹមតែបានទទួលសញ្ញាប័ត្រប៉ុណ្ណោះទេ ហើយបោះបង់ចោលលែងរៀនតទៅទៀតដូច្នោះទេ គឺត្រូវតែចំប្រឹងប្រែងសិក្សាដោយខ្លួនយើងតទៅទៀត ព្រោះចំណេះក្នុងសាលា គ្រាន់តែជាមធ្យោបាយ បង្ហាញផ្លូវឲ្យសិស្សចេះដើរចេះប្រើប៉ុណ្ណោះ ត្រូវតែចំប្រឹងរៀន ចំប្រឹងស្រាវជ្រាវរកចេះ ចំប្រឹងពិនិត្យពិចារណា កត់ត្រាដោយខ្លួនយើងតទៅទៀត ទើបចំណេះវិជ្ជាដែលបានរៀនសូត្រមកនោះអាចចំរើនលូតលាស់ឡើងបាន; លុះការសិក្សាបានចំរើនឡើងហើយ ត្រូវបង្ហាត់កាយ វាចា ចិត្ត ឲ្យសមតាមធម៌តាមច្បាប់ថែមទៀត ទើបសមភាពជាបណ្ឌិតជាតិ ហើយអាចទទួលការងារធ្វើការស្នងគ្រូបាអាចារ្យជាលំដាប់តទៅ ។

ម្យ៉ាងទៀត ពួកពុទ្ធបរិស័ទមានសង្ឃមយ៉ាងមាំលើអស់លោកគ្រប់រូបថាបានរៀនសូត្រចេះដឹងចេញពីសាលាទៅហើយ ខឹងចំប្រឹងប្រតិបត្តិឲ្យត្រឹមត្រូវតាមការចេះដឹងចំពោះខ្លួន - ព្រមទាំងដឹកនាំជនទាំងឡាយឲ្យចេះដឹង ឲ្យប្រតិបត្តិតាមការចេះដឹងពុំខាន ព្រោះសេចក្តីប្រតិបត្តិជាគោលសំខាន់នៃព្រះពុទ្ធសាសនា ខឹង អាចឲ្យផលផ្តល់ឲ្យកើតសេចក្តីសុខសមតាមប្រាថ្នាបាន ។

ការរំលឹកទាំងប៉ុន្មានទាំងនេះ សូមផ្តើមពុកផ្តាំលើខ្លួនលោកជាសិស្ស គ្រប់រូប ពុកជារង្វាន់ដ៏ប្រសើរបស់សាលាចាំលើជាន់ខ្ពស់ រួមជាមួយនឹងសញ្ញាប័ត្រ ព្រមទាំងព្រហ្មទេយ្យគឺរង្វាន់ដែលអស់លោកទាំងឡាយនឹងបានទទួលក្នុងកាលឥឡូវនេះ អំពីព្រះហស្តនៃព្រះតេជាអម្ចាស់ជីវិត ដែលខ្ញុំមានព្រះហឫទ័យស្មោះចំពោះក្នុងព្រះពុទ្ធសាសនា នឹងអំពីសុំណាក់នៃពួកពុទ្ធបរិស័ទក្នុងសមាគមមិត្តសាលាចាំលើ. ដែលបានចាត់ចែងការបុណ្យប្រគេនព្រហ្មទេយ្យនេះ ដែលព្រះតេជាអម្ចាស់ជីវិត ឋានស្តេចមកជាព្រះពាជាធិបតី ។

ក្នុងទីបំផុតនេះ សាលាចាំលើជាន់ខ្ពស់ សូមទទួលផលដែលកើតឡើងអំពីការសិក្សាព្រះបរិយត្តិធម៌របស់កិច្ច-សាមណេរទាំងឡាយ ថ្វាយចំពោះព្រះតេជាអម្ចាស់ជីវិត សូមខ្ញុំបានប្រកបដោយសិរីសុវត្ថិមង្គលគ្រប់ប្រការ សូមខ្ញុំបានប្រកបដោយព្រះជន្មាយុយឺនយូរអស់កាលជានិរន្តរ៍ ។ ខ្ញុំសម្តែងនឹងព្រះតេជព្រះគុណនូវអស់លោកអ្នកជាពុទ្ធបរិស័ទ ក៏សូមឲ្យបានប្រកបដោយសេចក្តីសុខចំរើនអស់កាលជាយូរអង្វែងទៅ កុំបីអាក់ខានឡើយ ។

ព្រះរាជទេយ្យដែលសំរេចក្នុងឆ្នាំ

លោកវរសេនីតឿ សំ-ញ៉ា ឯកអធិបតីរងសមាគមមិត្តសាលាបាលី

ស្ថិតក្នុងឧកាសប្រគេនវស្សាំ

ប្រឡងជាប់លេខ ១ – សាមណេរ ប៊ឹង - ប៉ាម វត្តបទុមវតី ពិន្ទុ ៦២០, រង្វាន់របស់លោកអ្នកឧកញ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ ថ្វាយចំពោះព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង, និងសម្តេចធម្មលិខិត - បន្ទែមរបស់ឧបាសិកាឡឹង របស់ក្រុមរដ្ឋាករព្រះពុទ្ធរូប ១ ព្រះអង្គ នាឡិកាកោះធំ ១ ។

ប្រឡងជាប់លេខ ២–កិក្ខុ ថាច់ - ឃៀង វត្តលង្កា ពិន្ទុ ៦១៨½ រង្វាន់សម្តេចធម្មលិខិតឧត្តមប្រឹក្សា បន្ទែមរង្វាន់លោក សុខ - នុត ។

ប្រឡងជាប់លេខ ៣ – កិក្ខុ សុខ - ឈុន វត្តលង្កា ពិន្ទុ ៦១០, រង្វាន់របស់លោកនាយករដ្ឋមន្ត្រី បន្ទែមរង្វាន់របស់លោក មិន-ធុច ។

ប្រឡងជាប់លេខ ៤ – សាមណេរ តើត-តិន វត្តឧណ្ណាលោម ពិន្ទុ ៦០៣, រង្វាន់លោក ធូ - ជា បន្ទែមរង្វាន់លោក ហាង់ - ចាប ។

ប្រឡងជាប់លេខ ៥ – កិក្ខុ អាំ - សាម៉ុល វត្តមហាមន្ត្រី ពិន្ទុ ៥៨២, រង្វាន់ព្រះសង្ឃនាយកគណៈមហានិកាយ បន្ទែមរង្វាន់លោក លី - តាមសៀរ ។

ប្រឡងជាប់លេខ ៦ — តិក្ខ តុប - ណាុប វត្តទ្រណ្ណាលោម ពិន្ទុ ៥៨៨, រង្វាន់លោក ឃួន - រិណ បន្ថែមរង្វាន់លោក លី - គីមស្រៀវ ។

ប្រឡងជាប់លេខ ៧ — តិក្ខ សៅរ - ណាង វត្តទ្រណ្ណាលោម ពិន្ទុ ៥៨៦, រង្វាន់សារពាតិមានសំឡេងខ្មែរ បន្ថែមរង្វាន់លោកប៊ុន - ថាន់ ។

ប្រឡងជាប់លេខ ៨ — តិក្ខ សោម - ឈិង វត្តទ្រណ្ណាលោម ពិន្ទុ ៥៨៦, រង្វាន់លោក ឡូវ - ហុង បន្ថែមរង្វាន់លោក ប៊ុន - ថាន់ ។

ប្រឡងជាប់លេខ ៩ — តិក្ខ ជួប - ជុំ វត្តទ្រណ្ណាលោម ពិន្ទុ ៥៨៥, រង្វាន់លោក ឯល - ញ៉ាន បន្ថែមរង្វាន់លោក ប៉ុក - មុំ ។

ប្រឡងជាប់លេខ ១០ - តិក្ខ ដៀង - កាយ វត្តលង្កា ពិន្ទុ ៥៨៥, រង្វាន់លោក ភ៉ា - ស៊ីយន បន្ថែមរង្វាន់លោក អ៊ុក - ផង់ ។

ប្រឡងជាប់លេខ ១១ — តិក្ខ កោង - ណាង វត្តទ្រណ្ណាលោម ពិន្ទុ ៥៨៤, រង្វាន់លោក ឌា - ជាវលី ។

ប្រឡងជាប់លេខ ១២ — តិក្ខ រឿង - ស្រៀង វត្តបទុមវតី ពិន្ទុ ៥៨២, រង្វាន់លោក ពុត - ស៊ុំ ។

ប្រឡងជាប់លេខ ១៣ — តិក្ខ ឆ្នុង - ពុត វត្តទ្រណ្ណាលោម ពិន្ទុ ៥៨១, រង្វាន់លោក ហេង - យ៉ាន់ ។

ប្រឡងជាប់លេខ ១៤ តិក្ខ ឆោង - ង៉ែង វត្តលង្កា ពិន្ទុ ៥៧៥ $\frac{1}{2}$ រង្វាន់លោក ធឹង - ចាប ។

ប្រឡងជាប់លេខ ១៥ - កិក្ខុ ដិន - ឆន វត្តលង្កា ពិន្ទុ ៥៧៤, រង្វាន់ លោក . មហាវង្ស ។

ប្រឡងជាប់លេខ ១៦ - កិក្ខុ ជា . ណាំ វត្តលង្កា ពិន្ទុ ៥៧២ ½ រង្វាន់លោក យីហោចំរើនសម្បត្តិ ។

ប្រឡងជាប់លេខ ១៧ - កិក្ខុ ញ៉ឹក - ញ៉ុល វត្តមហាមន្ត្រី ពិន្ទុ ៥៦៧, រង្វាន់លោក កែវ - សុខ ។

ប្រឡងជាប់លេខ ១៨ - កិក្ខុ ស៊ូ - ប៊ុត វត្ត ណ្ណាលោម ពិន្ទុ ៥៦៣, រង្វាន់លោក ឯន - ប៉ាន់ ។

ប្រឡងជាប់លេខ ១៩ - កិក្ខុ សុខ - វន វត្ត ណ្ណាលោម ពិន្ទុ ៥៥៩ ½ រង្វាន់លោក រស់ - រឿន ។

ប្រឡងជាប់លេខ ២០ - កិក្ខុ ហ៊ុន - ប្រុញ វត្ត ណ្ណាលោម ពិន្ទុ ៥៥៦, រង្វាន់លោក ថៃ - ធុល ។

ប្រឡងជាប់លេខ ២១ - កិក្ខុ ឆេត - ញ៉ុល វត្ត ណ្ណាលោម ពិន្ទុ ៥៥៥, រង្វាន់លោក ដំ តាសុំ - ហៀង ។

ប្រឡងជាប់លេខ ២២ - កិក្ខុ ហោន - លាង ហោ វត្តកែវព្រះភ្នំ ពិន្ទុ ៥៥៤, រង្វាន់ក្រុមពុទ្ធសាសនបណ្ឌិត្យ ។

ប្រឡងជាប់លេខ ២៣ - កិក្ខុ កែ - ឌុច វត្តលង្កា ពិន្ទុ ៥៥១, រង្វាន់លោក ឈឹម - ស៊ីមន ។

ប្រឡងជាប់លេខ ២៤ – កិត្តិ ម៉ាស - សាំម វត្តលង្កា ពិន្ទុ ៥៤៩, រង្វាន់លោក អ៊ុំ - ខិន - ឡាំ ។

ប្រឡងជាប់លេខ ២៥ – បណ្ឌិត ហួត - ហៀម វត្តលង្កា ពិន្ទុ ៥៤៧ ½ រង្វាន់ក្រុមសមាគម ។

ប្រឡងជាប់លេខ ២៦ – កិត្តិ សៀង - ម៉ាង វត្តឧណ្ណាលោម ពិន្ទុ ៥៤៦, រង្វាន់លោក ប៊ុង - គីរេន ។

ប្រឡងជាប់លេខ ២៧ – កិត្តិ ជោក - យឹប វត្តលង្កា ពិន្ទុ ៥៤៤, រង្វាន់លោក ថៃ - សាំងលី ។

ប្រឡងជាប់លេខ ២៨ – កិត្តិ ស្ងួស - ស៊ុម វត្តឧណ្ណាលោម ពិន្ទុ ៥៤២, រង្វាន់កូនលោក ថៃ - សាំងលី ។

ប្រឡងជាប់លេខ ២៩ – កិត្តិ ឡូត - សុំនអ៊ាង វត្តឧណ្ណាលោម ពិន្ទុ ៥៤១, រង្វាន់លោក មេ៉ - ម៉ី ។

ប្រឡងជាប់ លេខ ៣០ – កិត្តិ នេ៣ - ជិន វត្តមហាមន្ត្រី ពិន្ទុ ៥២៨, រង្វាន់រដ្ឋមន្ត្រីក្រសួងសាធារណការ ។

ប្រឡងជាប់លេខ ៣១ – កិត្តិ ម៉ក់ - ស្ងួង វត្តលង្កា ពិន្ទុ ៥២៧, រង្វាន់លោក ស - អ្នកណៃ ។

ប្រឡងជាប់លេខ ៣២ – កិត្តិ វេង - ត្រឹង វត្តឧណ្ណាលោម ពិន្ទុ ៥២៦, រង្វាន់លោក អ៊ុំ - ខិន - អួន ។

ប្រឡងជាប់លេខ ៣៣ — កិក្ខុ តែក - ង៉ាន វត្តទុណ្ណាលោម ពិន្ទុ ៥២៦, រង្វាន់លោក អុង ចាំង អៃ ។

ប្រឡងជាប់លេខ ៣៤ — កិក្ខុ ចក់ - ដុន វត្តស្វាយពៃ ពិន្ទុ ៥១៥, រង្វាន់លោក ចាប - កន ។

ប្រឡងជាប់លេខ ៣៥ — កិក្ខុ ស្លួង - សាប់ វត្តទុណ្ណាលោម ពិន្ទុ ៥១៣, រង្វាន់លោក គឹម - សេង ។

ប្រឡងជាប់លេខ ៣៦ — កិក្ខុ កង់ - សាន់ វត្តទុណ្ណាលោម ពិន្ទុ ៤៨៣, រង្វាន់លោក អ៊ិម - ឱម ។

ប្រឡងជាប់លេខ ៣៧ — កិក្ខុ ម៉ែន - សឿន វត្តបទុមវតី ពិន្ទុ ៤៨៦, រង្វាន់លោក យស - ម៉ាន់ ។

រង្វាន់របស់លោក - អ្នកដែលចូលជាគ្រូបាត់ គណៈកម្មការបុណ្យបាន ចំណាយទិញសៀវភៅ ចញ្ចានិងខ្នើស ៣៧ ក្បាល ប្រគេនគ្រប់អង្គ ។

រង្វាន់សៀវភៅ សម្ពន្ធមាលា ៣៧ ក្បាល នឹង ព្រះត្រៃបិដកប្រែជាភាសាចាំង ៣ ក្បាល ពីក្រសួងពុទ្ធសាសនបណ្ឌិត្យ, ឯសម្ពន្ធមាលា ប្រគេនគ្រប់ព្រះអង្គ, ចំណែកសៀវភៅព្រះត្រៃបិដកប្រែជាភាសាចាំង ៣ ក្បាល ប្រគេនរៀងតាមលេខខ្ពស់គឺលេខ ១ លេខ ២ នឹងលេខ ៣ ។

លោក តាន់ - ឈីវ - ហេង, តាន់ - ឈីវ - ហ៊ុន កន្សែងចាយ ២០ ។

ចប់ពិធីបុណ្យតែប៉ុណ្ណោះ

ចៅអធិការដែលធើបតាំងថ្មី

របស់ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៥៨៨ ចុះថ្ងៃអង្គារ ៩កេីតខែមាឃឆ្នាំជូតសំរឹទ្ធិស័ក ព.ស. ២៤៩១ តាំងលោកគ្រូខេត-សោម សុវណ្ណត្ថេរ ឆ្នាំច អាយុ ៦៣ វស្សា ៣៦ ជាចៅអធិការវត្តត្រពាំងវែង ឃុំត្រពាំងស្រែ ស្រុក-ខេត្តដងែល ។

សញ្ញាប័ត្រលេខ ៥៨៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាន់-ឃុត ឃវណ្ណប្បញ្ញា ឆ្នាំរកា អាយុ ៤០ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដងែល ។

សញ្ញាប័ត្រលេខ ៦០០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឃួរ-ញឹម ឥន្ទប្បញ្ញា ឆ្នាំច អាយុ ២៧ វស្សា ៦ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដងែល ។

សញ្ញាប័ត្រលេខ ៦០១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឡុង-ជួ មុនិត្ថេរ ឆ្នាំជូវ អាយុ ២៤ វស្សា ៤ ជាចៅអធិការវត្តអង្គ ឃ្លោក ឃុំត្រពាំងស្រែ-ស្រុក-ខេត្តដងែល ។

សញ្ញាប័ត្រលេខ ៦០២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ភ័ន;-នៅ ព្រហ្មត្ថេរ ឆ្នាំខាល អាយុ ៣៥ វស្សា ១៦ ជាចៅអធិការ វត្តសុរគី ឃុំ-ស្រុក-ខេត្តដងែល ។

សញ្ញាប័ត្រលេខ ៦០៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុម-ឡុច ចន្ទត្នោបញ្ញា ឆ្នាំកុរ អាយុ ៦៦ វស្សា ៦ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦០៤ តាំងលោកគ្រូក្រូច-សំរិទ្ធ៍ ឥន្ទវិន័យ ឆ្នាំជូត អាយុ ២៥ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦០៦ ចុះថ្ងៃចន្ទ ១៥ កើតខែផល្គុណ ឆ្នាំជូតសំរឹទ្ធិស័ក ព.ស. ២៤៩១ តាំងលោកគ្រូ អ៊ុយ-គង់ ឥន្ទត្នោ ឆ្នាំហៅ អាយុ ៥៨ វស្សា ១២ ជាចៅអធិការវត្តត្រាចទង ឃុំត្រាចទង ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ៦០៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចក់-ហឹម ឥន្ទត្នោ ឆ្នាំខាល អាយុ ៣៥ វស្សា ១៥ ជាចៅអធិការវត្ត ចាសិតគ្រោម ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ៦០៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុក-លឿង សុវណ្ណជោត ឆ្នាំឆ្លូវ អាយុ ៣៦ វស្សា ១៦ ជាចៅអធិការ វត្តអង្គរកា, ឃុំពញាពន្ធ ស្រុកពញាឮ ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ៦០៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គង់-ធុង ធម្មសារ កើតក្នុង គ. ស. ១៩០៥ វស្សា ៤៦ ជាចៅអធិការវត្ត បង្គន់ ឃុំជង្គាំបិត ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៦១០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ជាន់-ឈួន ឥន្ទ្រិនយត្តេរ កើតក្នុង គ. ស. ១៨០៩ វស្សា ៤០ ជាចៅអធិការវត្តកំពង់ផ្ការ ឃុំគោល ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៦១១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ក់-សៀវ សុវណ្ណត្តេរ កើតក្នុង គ. ស. ១៨១៤ វស្សា ៣៥ ជាគ្រូ-សូត្រស្តាំវត្តកំពង់ផ្ការ ឃុំគោល ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៦១៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ-ប្រែស-ហ៊ួន ព្រហ្មសត្តា កើតក្នុង គ. ស. ១៨២២ វស្សា ២៧ ជាចៅ-អធិការវត្តអារង្គាយ ឃុំរំចេក ស្រុកសៀមរាប ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ៦១៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ប្រាក់-សារ៉ នាមធាយោ ធម្មបញ្ញា កើតក្នុង គ. ស. ១៨២២ វស្សា ២៧ ជាគ្រូសូត្រស្តាំ វត្តអារង្គាយ. ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦១៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សួង-អប់ នាមធាយោ ធម្មរង្គត កើតឆ្នាំថោះ អាយុ ៥៨ វស្សា ៣៨ ជា ចៅអធិការវត្តអង្គរខាងត្បូង ឃុំអង្គរធំ ស្រុកសៀមរាប ខេត្តសៀមរាប ។

(អាខត)

តែពាក្យខុសក្នុងកម្ពុជសុរិយា

លេខ ៣ ឆ្នាំ ១៨៩០

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
រូបដើរមានពន្លឺពីរ	រូបដើរផ្អែងផ្អៀងពន្លឺពីរ	១៨៩,	៩
ទេសជាតិសាស្ត្រវិបង្កើន	ប្រទេសជាតិសាស្ត្រវិបង្កើន	១៨៦,	៩
ផ្ទៃទាសភាពដូរចិត្តឆេះ	ផ្ទៃទាសភាពដូរចិត្តឈួលឆេះ	១៨៦,	១២
រដ្ឋាភិបាលដែលធ្វើឲ្យប្រជា-ពស្ត្រប្រតិបត្តិតាមច្បាប់	រដ្ឋាភិបាលដែលគេទុកជាតែឲ្យទុក្ខដល់ប្រជាពស្ត្រ គឺរដ្ឋាភិបាលដែលធ្វើឲ្យប្រជាពស្ត្រប្រតិបត្តិតាមច្បាប់	១៦៩,	៤

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងពាក់ព័ន្ធសាសនា ទំនៀម អក្សរសាស្ត្រ ប្រវត្តិផ្សាយ
អំពីពុទ្ធសាសនាចក្ក្បាត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក ភ័យ-ប៊ុក
ក្រុមការ នៅពុទ្ធសាសនាចក្ក្បាត្យ
បណ្ណាធិការ ផ្នែកសាសនា: ព្រះទេពសង្គា ស្ង-ហាយ
ក្រុមដំនុំព្រះត្រៃបិដក នៅពុទ្ធសាសនាចក្ក្បាត្យ

ផ្នែកអក្សរសាស្ត្រ	មាតិកា	ទំព័រ
លោក ភ័យ-ប៊ុក ក្រមការ	ឧបាទមហាក្ខន្ធសូត្រ (តមក)	៣៦១
— —	ប្រវត្តិសាស្ត្រនៃស៊ីវិលីហ្សេសម័យបុរាណ (តមក)	៣៦៦
ក្រុមដំនុំវប្បធម៌	ស័ព្ទបកប្រែជាខ្មែរ ញ៉ុក-ថែម ស្រែង (តមក)	៣៦៩
លោកសាង-សាកិត លេខាធិការ	រឿងព្រៃនភូមា (តមក)	៣៣៣
អ្នកនាគញ៉ាវិបុលរាជសេនា ន្ង-កន	រឿងសាមកុក (តមក)	៣៨១
— ទេព៌ពិទូរ ឈឹម-ក្រសែម	ព្រះរាជដំណើរទៅកាន់ប្រទេសកម្ពុជា (តមក)	៣៨៩
ខៀមទម្លាប់ស្រុកខ្មែរ	សារគារវត្តវិហារទង្គិមអ្នកនាគញ៉ាកែវ-ហង់ តែង	៣៩៣
សាសនា		
ប-ប៊ុក ក្រមការ	ពន្ធអាស៊ីទ្ធិ (តមក)	៣៦១
ញ-ឥត្រី	ពុទ្ធសាសនានិងការហ៊ានសាសនា (តមក)	៣៦៦
ខ្លោស្ង-ហាយ	សច្ចប៊ុរិសធម្មកថា	៣៧៤
ជេទី ឈ្ង-អ៊ុន	វិសេសសូត្រ ប្រែជាភាសាភាសា	៣៨១
កណាតនីនិងប្រវត្តិការណ៍		
ព្រះមហា កែ-អើន	ពិធីបុណ្យដំឡើងរឹក នៅវត្តដំណាក់ (សៀមរាប)	៣៧៤
ក្រសួងធម្មការ	ចៅអធិការនៃលទ្ធើបតាំងថ្មី (តមក)	៣៧៩

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire:

		page
M. Ray-Buc Kramakar (I.B.)	Paroles de GANDHI (suite)	321
— id —	Histoire: Ancienne civilisation khmère par M. George GOEDES (suite) ...	326
Commission Culturelle	Recueil des mots traduits fait par M. NHOK-THEM (suite)	329
M. Sang-Savath Secrétaire au Ministère des Finances	Contes birmans (suite)	333
Neak Oknha Vipularaja-sena Nou-Kan	Histoire de SAMKOK (suite),.....	340
Neak Oknha Debabidura Chhim-Krasem	Histoire du Royaume du Cambodge (suite).....	348
Commission des Mœurs et Coutumes	Notice historique de la pagode de Vat Vihara-Tontim (Suong-Kg. Cham) par Neak Oknha Keo-Hang	353

Partie religieuse:

M. Ray-Buc Kramakar	Lumière de l'Asie (suite)	361
M. Menh-Nakry	Le bouddhisme et les autres religions (suite)	366
Brah Debasattha So-Hay Khun Suvatthi vedi You-Oun	Sappurisaddhammakatha	374
	Vasalasutta (Poème)	381

Notes et Chroniques:

Brah Maha Ker-Oeun	Compte rendu des cérémonies religieuses célébrées à Vat Damnak (Siemreap)	394
Ministère des Cultes	Nomination des nouveaux Chau-Adhikar (suite)	398

22e Année: N° 5 mois d' Mai 1950 — Prix d'abonnement: 145$00 par an.

លោក រ៉ាយ - ប៊ុក ក្រុមការនៅពុទ្ធសាសនឥណ្ឌិត្យ

ដកស្រង់ពីសារពត៌មាន ហ្សឺនអាំង (Jeune Inde)

(ត)



២០ – វឌ្ឍនធម៌មានការទាក់ទងនឹងសេចក្តីទុក្ខដែលបុគ្គលទទួល, បើសេចក្តីទុក្ខនោះមានសភាពបរិសុទ្ធ វឌ្ឍនធម៌ក៏មាំមួនអស្ចារ្យ ។

ច្បាប់នៃទុក្ខសច្ច
(១៦-៦-១៩២០)

២១ – អាហារណាដែលយើងបរិភោគកង់កាលនៅជាទារក, ដល់យើងចំរើនវ័យវឌ្ឍនាការធំឡើង អាហារនោះត្រូវផ្ទាស់ចេញ ត្រូវរក អាហារថ្មីបរិភោគវិញ ។

បដិវត្តន៍ ពួកក្រុមប្រឹក្សា
(១៤-៧-១៩២០)

២២ – ការរំលំរដ្ឋាភិបាល ដែលគ្មានសមត្ថភាពត្រួតត្រាប្រទេស ជាកិច្ចស្រួលងាយ ជាងការមើលជំងឺឆ្កួតរបស់ប្រជាជនឲ្យជាសះស្បើយ ។

ថ្ងៃទីមួយខែអ្ងូត
(២៨-៧-១៩២០)

២៣ – យើងត្រូវសិក្សារៀនសូត្រ ហើយត្រូវធ្វើតយកផលប្រយោជន៍អំពីកិច្ចការណាដែលយើងបានប្រព្រឹត្តខុស ឬ កាន់ច្បាំ ឲ្យបានត្រឹមត្រង់ឡើងវិញ ។

... គ្មានមេធ៌ាណាមួយឈប់ធ្វើចម្បាំង ដោយហេតុគ្រាន់តែបានទទួលបរាជ័យឬការខ្ជិលច្រអូសនោះស្តេច ។

... ពួកពលរដ្ឋត្រូវទទួលការខុសត្រូវចំពោះករណីយកិច្ចនៃរដ្ឋាភិបាល ។

ថ្ងៃទីមួយខែអ្ងូត
(២៩.៣.១៩៤)

២៤ - កងកំណាយកិច្ចរបស់យើង បើមានយោបល់ខ្វែងគ្នា យើងត្រូវយកសំឡេងតូចស្ងាត់ដែលនៅក្នុងសន្ដានយើង ជាអាជ្ញាកណ្ដាល ។ ... នៅក្នុងវិដ្ឋាឋានមួយ។ មានមនុស្សបីពួក គឺ មួយពួកមានសេចក្ដីពេញចិត្តខាងធ្វើតាមនយោបាយដែលគេបានកំណត់ទុកមុន; មួយពួកយល់ឃើញថានយោបាយនេះគួរធ្វើ តែមិនព្រមធ្វើ; មួយពួកទៀតមិនយល់ទូវនយោបាយនេះសោះឡើយ ។

សភាកុងក្រែសទី៨ អាមេរិកាភាព
(៤-៩-១៩៤)

២៥ - ខ្ញុំចូលចិត្តឲ្យប្រទេសតូចៗប្រើអាវុធយុទ្ធភណ្ឌ ដើម្បីការពារទ្វីតិត្តិយសរបស់ជាតិ មិនមែនខ្ញុំចង់ឲ្យប្រទេសនេះមានសកាពអន់ខ្សោយដែលជាសាក្សីចំពោះសេចក្ដីអប្បកិត្តិយសនៃជាតិទេ ។ ... តែខ្ញុំយល់ថា អហឹសាវិតក្ក: (non-violence) ជាសកាពវិសេសជាងកំហឹង (ពាលកម្ម), ការអត់ឧនជាគុណប្រសើរជាងធ្វើទណ្ឌកម្ម, សេចក្ដីអត់ឧន ជាគ្រឿងអលង្ការរបស់ទាហាន, តែការមិនធ្វើទណ្ឌកម្ម

នេះ នឹងពុកថាជាសេចក្តីអត់ឱនទោសបាន លុះតែតែកិច្ចដែលប្រព្រឹត្ត
នោះ ជាហេតុគួរឲ្យធ្វើទណ្ឌកម្ម ។ ការមិនព្រមផ្តន្ទាទោស ពុកជាអសារ
ឥតការ បើកិច្ចនោះធ្វើដោយសេចក្តីពុំឮលភាពរបស់ខ្លួន, គេមិនអាច
ពោលថាកណ្តាអត់ទោសឲ្យឆ្មាកង់វែលដែលឆ្មាកំពុងទាំកគេកណ្តាទេ ។
... ពលភាពមិនមែនកើតមកពីកំឡាំងកាយ គឺកើតមកពីធន្ទះដ៏ខ្លាំងក្លា
របស់ចិត្ត ។

... លទ្ធិអហឹសាវិតក្កៈនេះ មិនមែនមានតែក្នុងពួកឥសី ឬព្រះពីណា-
ស្រេតទេ ក្នុងពួកហីនជាតិក៏មានដែរ, អហឹសាវិតក្កៈជាច្បាប់មនុស្សជាតិ,
ភាវុណកម្មជាច្បាប់តិរច្ឆាន ។ វិញ្ញាណដេកសំងំនៅក្នុងសត្វតិរច្ឆាន
តែសត្វតិរច្ឆានមិនអាចដឹងអ្វីក្រៅពីកាយពលភាព, សភាពថ្លៃថ្នូរបស់
មនុស្សនៅត្រង់ការប្រតិបត្តិតាមច្បាប់ដ៏ខ្ពង់ខ្ពស់ គឺកំឡាំងមនោវិញ្ញាណ
ដ៏បរិសុទ្ធ ។

... ខ្ញុំមានប្រាថ្នាយ៉ាងមុតមាំថា ធ្វើម្តេចហ្ន៎ ឲ្យប្រទេសឥណ្ឌាដឹងខ្លួន
ដោយខ្លួនឯងថាខ្លួនមានជួរដ៏វិញ្ញាណមិនចេះស្លាប់ ហើយអាចនឹងតស៊ូនូវ
សេចក្តីខ្វាត់ខ្វោយខាងសម្ភារៈរបស់ជាតិ ទាំងអាចទប់ទល់ក្នុងការចលា-
ចលខាងសម្ភារៈក្នុងសកលលោក ។

... ចិត្តខ្ញុំជាប់ស្និតនឹងប្រទេសឥណ្ឌា ព្រោះខ្ញុំនៅជាប់ជំពាក់ក្នុង
ប្រទេសនេះច្រើនស្មាន ។

. . . ខ្ញុំស្អប់ការស្លាត់កំចាំដូចជាខ្មោចគ្រែដូច ។

ឧទ្ធិពុះពារនៃគ្រឿង
(១១-៨-១៩២១)

២៦- មិនចាំបាច់ពិចារណាឲ្យយូរទេគង់យល់បានថា រដ្ឋាភិបាលដែលមានសិទ្ធិតាំងនៅមាំមួនបាន មកពីអំណាចសាលាតុលាការ ហើយរដ្ឋាភិបាលនេះដែលតុបតែងមន្ត្រីគ្រប់តំណែងបាន មកពីសាលារៀន, សាលាទាំងពីរនេះជាវិជ្ជាស្ថានមានប្រយោជន៍ បើរដ្ឋាភិបាលទទួលការខុសត្រូវរក្សាវិន័យសុចរិត, ជាវិជ្ជាស្ថានដូចជាអង្គប់រាបស់ប្រជាជន បើរដ្ឋាភិបាលប្រព្រឹត្តទុច្ចរិត ។

កម្មវិធីនៃអសាមត្តិភាព
(១៩-៨- ៦២០)

២៧- ខ្ញុំពេញចិត្តជាអនេកប្បការក្នុងការកាន់អំបែងនៃសមយាចកជាជាងការទទួលនូវតួដ៏ប្រសើរអំពីពួកអ្នកមានដៃប្រឡាក់លោហិតក្នុងការចលាចលនៅសល្លីយ៉ង់វ៉ាឡាបាម្ហ (Jallianwala agh), ខ្ញុំចូលចិត្តកាន់ដីតាឃុំខ្លួនជាជាងការស្តាប់ពាក្យផ្អែមដូចទឹកឃ្មុំ នៃពួកដែលធ្វើឲ្យមនោសញ្ចេតនាហារបស់ពួកបង្ហូនកាន់សាស្នាមហាម័តចាំង ៧០ លាននាក់ឲ្យអាក់អន់ស្រពន់ចិត្ត ។

ពុទ្ធហេតុសាសនានៃអសាមត្តិភាព
(២៥-៨-១៩២០)

២៨– គួរតែចោសសំអាតមន្ទិលចេញពីសាសនា, តែជាការគួរណាស់បង្ហាញនូវសេចក្តីចំណាងកងសីលធម៌ដែលគ្មានខ្វះមាររបស់អ្នកពេញចិត្តខាងការស្វែងរកប្រយោជន៍សម្ភារៈជាងប្រយោជន៍សីលធម៌ ជាហេតុឲ្យសីលធម៌ទន់អន់គ្មានខ្វះមារ, ការដឹកនាំពួកអធិមុតក: (អ្នកចុះចិត្តស៊ប់) (Fanatique) ដែលមានសភាពល្ងង់ខ្លៅឲ្យលះបង់ការប្រព្រឹត្តិខុសស្រួលជាងការដឹកនាំពួកចោរចាស់ដែលមានចិត្តជាប់មាំតែនឹងការលួចប្លន់ឲ្យលះបង់នូវអំពើទុច្ចរិត ។

ចរិយាធិស្ថិទ្ធស្នាលនៃលទ្ធិអសាមញ្ញភាព

(៨-៩-១៩២c)

២៩ – ប្រជាជាតិមិនអាចនឹងឡើងទៅកាន់វឌ្ឍនធម៌បានទេ បើប្រជាជាតិនោះពឹងផ្អែកតែលើខ្ញុំម្នាក់ឯង; សេចក្តីចំរើនដែលនឹងកើតមានឡើង លុះត្រាតែប្រជាពស្តុយល់ច្បាស់នូវទត្តមគតិរបស់ខ្ញុំ ហើយប្រតិបត្តិតាមផ្លូវដែលខ្ញុំបានត្រាយទុកមក ។ ដោយវិចារណញ្ញាណនេះខ្ញុំចង់ឲ្យប្រជាពស្តុរក្សានូវសេចក្តីមិនតក់ស្លុតជាដាច់ខាត ហើយត្រូវយល់ថាថ្ងៃដែលគេចាប់ខ្ញុំ ទុកជាថ្ងៃនក្ខត្តឫក្ស, ខ្ញុំប្រាថ្នាចង់ឲ្យទុព្វលភាពរបស់យើងចាកចេញពីសន្តានចិត្តកងថ្ងៃនោះផង ។

ចៀងគេចាប់ខ្ញុំ

រៀងចុះក្នុងសារពិតមាននៃជីវិត (Naojivan)

(១៤-១១-១៩២០)

(មានត)

ប្រវត្តិសាស្ត្រនៃស៊ីវិលីសាខ្មែរបុរាណ

លោកវ៉ាយ - ប៊ុក ក្រុមការ ប្រែរៀបរៀង

(តទៅ)

តាំងពីបឋមកាលនៃគ្រិស្តសករាជ, ឧបទ្វីប[1] ឥណ្ឌូចិនទឹងកោះឥណ្ឌូណេស៊ី ជាប្រទេសដែលមានប្រជាជាតិឥណ្ឌូបានចេញចាកប្រទេសរបស់ខ្លួន មកតាំងទីលំនៅដើម្បីនឹងស្វែងរកមាស គ្រឿងទេសនឹងកោគ-ទ្បាផ្សេងៗ ។ ពួកនាវីកជនជាតិឥណ្ឌូមានចំនួនច្រើននាក់ បានធ្វើដំណើរមកកាន់ប្រទេសដែលមានប្រជាជាតិស៊ីវិលីប្រហែលនឹងជាតិម៉ូយ ឬជាតិបាតាក (Batak) នៅកោះស៊ូម៉ាត្រា ឬជាតិដាយ៉ាក (Dayak) នៅកោះបរណៃអ្នកឯសម័យឥឡូវនេះ ជាហេតុឲ្យកើតព្រះរាជអាណាចក្រជាតិឥណ្ឌូជាច្រើន ហើយអ្នកដែលត្រួតត្រានៅក្នុងអាណាចក្រនីមួយៗកាន់ទំនៀមទម្លាប់សាសនាតាមប្រទេសឥណ្ឌូ ប្រើភាសាសំស្ក្រឹតជាផ្លូវសាសនា ។ ព្រោះហេតុដូច្នេះ ឬនជាកើតមានព្រះរាជអាណាចក្រកម្ពុជា, ចម្ប៉ា, ភូមា, ឧបទ្វីបជ្វា, ស៊ូម៉ាត្រា, ជ្វា:, កោះបាលី ព្រមទាំងសៀម, លាវ ដែលបានទទួលវប្បធម៌ឥណ្ឌូអំពីជាតិមនទឹងខ្មែរ ។

---

១ កោះដែលមានទឹកមិនព័ទ្ធជាប់ដុំវិញ ជាប់តែមួយចំហៀង ហៅថា ឧបទ្វីប ។

ព្រះពុទ្ធសាសនាចូលមកដល់ខ្មែរ, កុងនៅសម័យដើម គឺកុងរវាងពាក់កណ្តាលសតវត្សទី ៦ នៃគ្រិស្តសករាជ, កុងកាលនោះ រដ្ឋកម្ពុជាដែលនៅពាក់កណ្តាលទន្លេមេកុង កុងភូមិភាគជាសាក់ ជានគរមួយរីឯចេញចាកអនិស្សរភាពនៃប្រទេសហ្វូណន់ ។ ពាក្យថា "ហ្វូណន់" នេះជាឈ្មោះអធិបតេយ្យមួយ (Empire) ដែលអ្នកប្រវត្តិសាស្ត្រចិនបានសន្មតឡើងជាប្រទេសធំទូលាយកាន់ទំនៀមទម្លាប់ឥណ្ឌា ស្ថិតនៅខាងទិសទក្សិណកុងឧបទ្វីបឥណ្ឌូចិន ។

កុងសម័យមុនអង្គរ (គឺតាំងពីពាក់កណ្តាលសតវត្សទី ៦ ទៅដល់ចុងសតវត្សទី ៨), កាលប្រទេសកម្ពុជាស្ថិតនៅខាងទន្លេមេកុងខាងក្រោម, មហាពុទ្ធសតវត្សទី ៩ បានតាំងផ្តើមកសាងព្រះពុទ្ធនិវេសស្ថាននៅខាងជើងបឹងទន្លេសាប, អង្គរជាព្រះពុទ្ធធានី ទ្រង់បានស្ថាបនាឡើងកុងខាងចុងសតវត្សទី ៩ នៅជំបន់មួយមានភ្នំគ្បាវែងនៅចំកណ្តាលហើយវាតទីក្រុងធំទូលាយ គឺត្រង់អង្គរធំសព្វថ្ងៃដែលមានប្រាសាទជាច្រើននោះឯង ។ ឯប្រាសាទតាំងនោះជាទីក្រុងកាលពីសតវត្សទី ១២ ។ សម័យអង្គរ គឺពាក់តាំងពីចុងសតវត្សទី ៩ រហូតដល់ពេលដែលលះបង់ព្រះពុទ្ធធានី គឺសតវត្សទី ១៥ ហៅថា សម័យអង្គរ ។

កង់ទីនេះ យើងនឹងប្រមូលវត្ថុធាតុដ៏សំខាន់ៗ សម្រាប់យកមកពណ៌នាពីរឿងស៊ីវិល្យៃសម័យអង្គរ ជាកិច្ចពិសេសតទៅ ។

ត្រូវតែគោរពមនុស្សនីមួយៗ តាមកិត្តិយសសព្វៗ ខ្លួន (A tout Seigneur, tout honneur) យើងត្រូវអធិប្បាយពីព្រះមហាក្សត្រិយ៍ជាមុនសិន ។ បើតាមលំនាំរបស់ធម្មជាតិ មុនដំបូង គួរពណ៌នាអំពីព្រះមហាក្សត្រិយ៍ដែលជាអម្ចាស់លើផ្ទៃក្រោម ជាមូលហេតុនៃអង្គការនយោបាយរបស់រដ្ឋ, ជាប្រភព (Source) ព្រមទាំងបុព្វហេតុនៃអំណាចគ្រប់យ៉ាង ។ តាមពិត ព្រះមហាក្សត្រិយ៍ជាព្រះមួយអង្គនៅលើផែនដីជាបុរសវិសេសគួរបូជាជាផ្លូវការដោយខ្មៅរិក ។ ប៉ុន្តែយើងមិនត្រូវគិតស្មានថា ព្រះមហាក្សត្រិយ៍ដែលសោយរាជ្យនៅអង្គរជាព្រះមហាក្សត្រិយ៍សម្បូណ៌ជ្រាសិទ្ធិជ ដោយមានព្រះរាជវិធានការព្រះដំរិះតែពីស្វែរក្រៃគ្រឿងត្រែកត្រអាលក្នុងលោក, មិនមែនដូច្នោះទេ ព្រះមហាក្សត្រិយ៍ទាំងអស់អង្គសឹងតែមានបច្ចុយ្យាក់ទង់នឹងវិធានការខាងសន្តតិវង្ស ព្រមទាំងច្បាប់ប្រពៃណីនយោបាយនឹងព្រះពុទ្ធចរិយា, ព្រះអង្គជាអ្នករក្សាទុកនូវច្បាប់នឹងរបៀបផ្សេងៗ ទ្រង់ជាអ្នកសម្រេចសេចក្តីជាទីបំផុត ប្រសិនបើគួរក្តីមិនសុខចិត្ត ។

ហ្គងនិពន្ធមន្ត្រី ញ៉ុក-បែម រួបរួម

(តមក)

Sentier = ផ្លូវដើង

Voie = ផ្លូវ

Dernière mode = សម័យថ្មី

(23-11-48)

(Le) mode = វិធី, បែប

(La) mode = ទំនើប

Style = បែប

Chic = ស្រស់

Goût = រសជាតិ

Elégant = សមសួន

Calendrier = ប្រតិទិន

Almanach = មហាសង្ក្រាន្ត

Ephémeride = ឯកទិន

Agenda = ទិនានុលេខន៍

Mot exceptionnel = អញ្ញតរសព្ទ

(30-11 48)

Collaboration = សហការ

Coopération = =

Bâtiment = អគារ

Objet = កម្មវត្ថុ

Institut national d'études juridiques et économiques = វិជ្ជាឋានបរិញ្ញត្តិធម្មសាស្ត្រនិងសេដ្ឋសាស្ត្របស់ជាតិ

En laine = ខ្ណ្ហាម័យ

Oriflamme = ទង់សុវណ្ណផ្ការ

(Le 3-12-48)

Prose = ពាក្យពេយ

Prose rythmée = ពាក្យកម្រង

Poésie = កវីនិពន្ធន៍

Vers = ឃ្លា, ពាក្យកាព្យ

Poème = កាព្យនិពន្ធ

Stance = គាថា

Strophe = បទ

Fable = រឿងល្បែក

Légende = រឿងព្រេង

Le poète (pour les figures) = អលង្ការកវី

Le poète (pour les idées) = អថិកវី

Epopée = ឥតិហាស:

(Le 7-12-48)

Ecriteau = ផ្ការបកាស

Marque = ត្រាសញ្ញា

Enseigne = យីហោ

Panneau = បណ្ឌូ

Facteur = កត្តា

Avenant = កិច្ចសន្យាបន្ថែម

Dénonciation d'un contrat = ការទំលាយកិច្ចសន្យា

Affiliation à la caisse des pensions de retraite = ការបញ្ចូលឈ្មោះកងហិបរ៉ៃត្រែត

Titre universitaire = ហ៊ានន្តរមហាវិទ្យាល័យ

(Le 10-12-48)

Institution = ការស្ថាបនា, ស្ថាប័ន

Construction = ការស្ថាបនា, សំណង់

Constructif = ស្ថាប័ក (=ប៊ុក)

Destruction = ការនិស្ថាបនា

Destructif = និស្ថាបក (= ប្ដូក)

Construire = ស្ថាបនា

Détruire = និស្ថាបនា

Instituer = ស្ថាបនា

(Le 17-12 48)

Collectif = ថវិកាបែបធ្ងន

Bureau de Législation = ប៊ុយរ៉ូនីតិការ

Bureau de Matériel = ប៊ុយរ៉ូសម្ភារៈ

Bureau de Comptabilité = ប៊ុយរ៉ូបញ្ជី

Réquisition = កំណេណ្ហ, សំបុត្រកំណេណ្ហ

Proverbe = ភាសិត, ពាក្យទំនៀម

Devise = ចារចនា

Précepte = សិក្ខាបទ

Apophtegme = សុភាសិត

Attaquer = ប្រហារ

Armée Royale khmère = កងទ័ពខេមរភូមិន្ទ

Défilé = ការរៀបក្បួន

(Le 24-12-48)

(មានត)

រឿងព្រៃឥណ្ឌូមា

លោក សាង - សារ៉ាត លេខានុការក្រសួងហិរញ្ញវត្ថុ

ប្រែចេញពីសៀវភៅកុង ប៊ីរ៉ែន (contes Birmans) របស់លោក លូ វ៉ុសស្យុង (Louis Vossion)

ជាភាសាចិនមកជាខ្មែរ

(តមក)

៥ – ព្រាហ្មណ៍ទាំងបួន

"មិនត្រូវចង់បានទ្រព្យរបស់គេ"

ពាក្យថា "មិនត្រូវចង់បានទ្រព្យរបស់គេ" នេះ ជាសិក្ខាវង់នៃចរិយាសាស្ត្រដែលមិនអាចរុះរើកែប្រែបាន ជាសិក្ខារបស់ជនដែលមានចំណង់ចង់លើកតំកើងខ្លួនឲ្យបានដល់សេចក្តីចម្រើនដ៏ខ្ពង់ខ្ពស់ ឬយ៉ាងតិចណាស់ត្រឹមសេចក្តីចម្រើនណាដែលមនុស្សយើងក្នុងលោកនេះអាចទទួលបាន ។ ធម្មតាមនុស្ស ទោះជាអ្នកកាន់ព្រះពុទ្ធសាសនាចេះដឹងជ្រៅជ្រះយ៉ាងណាក៏ដោយ ក៏មិនអាចមានសន្តិចរិយាពិតប្រាកដបាន បើអ្នកនោះមិនព្រមលះបង់សេចក្តីបំណងផ្សេង ។ ក្នុងលោកចេញអំពីសន្តានរបស់ខ្លួនទេ ។ ដូចមាននិទានជាឧទាហរណ៍បង្ហាញឲ្យឃើញជាក់ស្តែងតទៅនេះ ៖

ក្នុងសកលជ ព្រះពុទ្ធ ជួម៉ាន៉ា ទី ១៣ ។ នៅក្នុងស្រុកតង្គតនាគោ (rangatanago) មានព្រាហ្មណ៍បួននាក់ មានឈ្មោះលួយ៉ាលួយ៉ាញ្ជូនៅក្នុង

ប្រទេស ថាជាអ្នកចេះខាងសិល្បសាស្ត្រ ។ ព្រាហ្មណ៍ទាំងបួននាក់នេះ ចូលចង់ស្គាននមេត្រីយ៉ាងជិតស្និទ្ធនឹងគ្នា ។ បណ្តាព្រាហ្មណ៍ទាំង ៤ នោះ ព្រាហ្មណ៍ម្នាក់ៗ មានមាសចំនួន ១០០ ដុំឡឹង ទុកសម្រាប់ត្រូវការផ្សេងៗ ដើម្បីកុំឲ្យព្រួយនឹងការខ្វះខាតគ្រឿងប្រដាប់ប្រដារបើប្រសិនជាការអត់អាហារកើតពេលដែលចំប្រឹងធ្វើសមណធម៌ ។ ព្រាហ្មណ៍ទាំងបួននាក់នៅរួមសុខទុក្ខជាមួយគ្នា ចរិកោគអាហារជាមួយគ្នា ។ ឯអាស្រមនៃព្រាហ្មណ៍ទាំង ៤ នោះ ជាទីគួរដល់ការអប់រំចិត្ត ព្រោះមានម្លប់ឈើត្រកៃឈើហើយនៅឆ្ងាយពីផ្លូវថ្នល់ធំ ទាំងឆ្ងាយស្ងាត់សូរសព្ទផ្សេងៗ ។

មានថ្ងៃមួយ ព្រាហ្មណ៍ទាំងបួននាក់បាននាំគ្នាទៅមុជទឹកឯជ្រោះដែលមានទឹកហូរចេញតាមបាតច្រកភ្នំ ឆ្ងាយអំពីអាស្រមរបស់ខ្លួន ហើយបានព្រមព្រៀងទុកមាសជាមួយគ្នា ក្នុងកន្លែងមួយដ៏កំបាំងប្របគល់ឈើ ដើម្បីកុំឲ្យពីបាកក្នុងដំណើរតាមផ្លូវ ហើយសន្យាមថាបើបាកជាមិនបាត់លុះកាលណាត្រឡប់មកពីមុជទឹកនឹងយកវិញ ។ បណ្តាព្រាហ្មណ៍ទាំងបួននោះ, ព្រាហ្មណ៍ម្នាក់នៅក្មេងជាងគេ, ព្រាហ្មណ៍ចាស់ ៣ នាក់ប្រើព្រាហ្មណ៍ក្មេងនោះឲ្យយកមាសទាំង ៤០០ ដុំឡឹងនោះទៅកប់ទុក ។

ឯព្រាហ្មណ៍កម្លោះ លុះបានមាសដល់ដៃ ក៏កើតគំនិតអាក្រក់ឡើងក្នុងខ្លួនភ្លាម បីដូចដើមបុប្ផាដែលត្រូវដីមានដីជាតិ បានយកមាសតែ ៣០០ដុំឡឹងទៅកប់ក្នុងរណ្តៅ ឯមាសរបស់ខ្លួនយកទៅកប់ទុកក្នុងទីដទៃ

ឆ្ងាយពីទីនោះបន្តិច ។ ព្រាហ្មណ៍កម្ងោះសង្ឃឹមថា "តែកាលណាត្រឡប់មកវិញ មិត្រយសអញទាំង៣នាក់មុខជាគ្មានសង្ស័យលើរូបអញទេ មុខជាគេនឹកស្មានថា មានចោរណាមួយចូលមកលួចពុំខាន, រួចអញនឹងសុំឲ្យគេចែកមាសដែលនៅសល់ទាំងប៉ុន្មានជាបួនភាគស្មើគ្នា, កាលបើយ៉ាងនេះ អញនឹងបានមាសកើតឡើងទៀត ហើយនឹងយកទៅលក់ស៊ីចាយលេងសប្បាយផ្សេងៗ ឯទីក្រុងជិតខាងណាមួយ" ។ ព្រាហ្មណ៍កម្ងោះដែលមានគំនិតទុច្ចរិតយ៉ាងនេះ ព្រោះចិត្តគាត់ជេកគ្រាក់ក្នុងផ្លូវអកុសលចំណែកខាងសីលដែលគាត់ខ្វះធ្លោៗ ទាំងទទឹងចិត្ត ។

លុះត្រឡប់មកពីមុជទឹកវិញ ព្រាហ្មណ៍កម្ងោះទៅឯកន្លែងដែលលាក់មាស, ក្រោយបន្តិចមក គេឃើញគាត់រត់តម្រង់ទៅផ្ទះ ហើយលើកដៃក្រវៃស្រែកថាមាសឃើញតែ ៣ ថង់ គឺថង់ដែលផ្ទើអំពីសំពត់ទេសឯកសប៉ុណ្ណោះទេ, ឯថង់របស់គាត់ជាត់ ការណ៍នេះជាអស្ចារ្យចំឡែកណាស់; គាត់និយាយឲ្យគេចែកមាសដែលនៅសល់ឲ្យស្មើគ្នាទាំងអស់ដើម្បីជួយគាត់ដោយសារទ្រព្យរបស់គាត់ជាត់នេះ ។ ឯព្រាហ្មណ៍ទាំងបីនាក់នឹកសង្ស័យនឹងការសុំចែកមាសនេះពន់ពេក ហើយមិនសុខចិត្តយល់ព្រមតាមសោះ ដោយគិតឃើញថា "ព្រាហ្មណ៍កម្ងោះនេះបានទុកជាក់មាសនឹងដៃឯង អាស្រ័យហេតុនេះវាត្រូវតែដឹងកិច្ចការទាំងអស់, មួយទៀតខ្លួនទាំងអស់គ្នាក៏សុទ្ធតែក្រផង" ។ ព្រាហ្មណ៍ទាំងបីនាក់និយាយ

ទៅកាន់ព្រាហ្មណ៍កម្លោះថា "អ្នកឯងនេះ យើងបានជាក់ការៈឲ្យទុកមាស ហេតុអ្វីក៏មិនដឹងជាមាសរបស់អ្នកបាត់ទៅឯណា ហេតុនេះយើងទាំងអស់គ្នាមិនត្រូវការទទួលគ្រោះថ្នាក់ឥតប្រយោជន៍ជាមួយនឹងអ្នកឯងទេ" ។

តាមទំនៀមស្រុក, ព្រាហ្មណ៍ទាំងបួននាក់នាំគ្នាទៅប្តឹងលោកសុភានៃភូមិភាគនោះ ដើម្បីនឹងដំរាបលោកតាមដំណើរទំនង ហើយសុំឲ្យលោកវិនិច្ឆ័យកាត់សេចក្តីឲ្យ ។ ឯលោកសុភាមានចិត្តឆ្មើងឆ្មៃនឹងរឿងចំឡែកនេះណាស់ ប៉ុន្តែលោកមិនរវល់ធ្វើអង្កេតវែងឆ្ងាយ; ដើម្បីឲ្យជ្រះស្រឡះផុតពីលោកធាប់ទៅ លោកបានឲ្យចែកមាសដែលនៅសល់ជា ៤ ភាគស្មើគ្នាឲ្យទៅគូក្តីទាំងបួន ។ ព្រាហ្មណ៍ទាំងបី មានសេចក្តីឈឺចិត្តណាស់ ហើយចង់ដឹងសេចក្តីពិតផង មិនយល់ព្រមធ្វើតាមពាក្យលោកសុភានោះឡើយ ត្រឡប់នាំគ្នាទៅឯចៅហ្វាយវិញ ។ លោកចៅហ្វាយវិញ បានបញ្ជូនខ្លួនព្រាហ្មណ៍ទាំង ៣ នាក់នោះព្រមទាំងព្រាហ្មណ៍កម្លោះទៅសាលាយុត្តិធម៌របស់ព្រះមហាក្សត្រិយ៍ ។ ព្រះមហាក្សត្រិយ៍លុះបានទ្រង់ព្រះសណ្តាប់ដោយហ្មត់ចត់ហើយ ទ្រង់ក៏យល់តាមសេចក្តីវិនិច្ឆ័យរបស់លោកសុភាក្នុងភូមិភាគនោះ ។ កាលណាព្រះមហាក្សត្រិយ៍ទ្រង់ឈប់មានព្រះរាជឱង្ការហើយ ព្រាហ្មណ៍ទាំងបីនាក់នៅស្ងៀមមួយស្របក់ ហើយមើលមុខគ្នាទៅវិញទៅមក ដោយឥតនិយាយអ្វីសោះ រួចសូរមាត់ក៏លាន់ឮរដៀវឡើង; ដល់ក្រោយមក

ព្រាហ្មណ៍ដែលចាស់ជាងគេ បានទូលទាស់នឹងព្រះពាជបំណងនេះឡើង។ ព្រះពាជាទ្រង់មិនទាន់យល់រឿងដ៏ចំឡែកនេះដោយជាក់ច្បាស់ ទ្រង់ក៏មានព្រះពាជបំណងចង់ឲ្យមានការអង្កេតមួយយ៉ាងពិស្តារ ហើយហ្មត់ចត់ផង ទើបទ្រង់គ្រាស់ហៅកុដ្ឋប៊ីយ៍ទីមួយមក រួចទ្រង់បង្គាប់ឲ្យរកឿងនេះឲ្យឃើញច្បាស់ឡើង ដោយទ្រង់កំហែងជាក់កំរិតថា បើកន្លងរវាង ៧ ថ្ងៃទៀត លោកកុដ្ឋប៊ីយ៍រកឿងនេះមិនឃើញទេ ទ្រង់នឹងហូតជារបេញខ្លួកថាជាអ្នកគ្មានសេចក្តីឈ្លាសវៃ កន្លងកិច្ចការដ៏ទត្តមរបស់ខ្លួន ។

លោកកុដ្ឋប៊ីយ៍ដឹងថា ព្រះបន្ទូលរបស់ស្តេចជាពាក្យសច្ចៃ, ហើយលោកបានហៅព្រាហ្មណ៍ចាស់ជួននាក់មកសួរម្នាក់ម្តង។ ដើម្បីធ្វើអង្កេតការណ៍នេះឲ្យបានហ្មត់ចត់ ។ ប៉ុន្តែលុះលោកចំធ្វើអង្កេតណាស់ទៅ រឹតតែបែរឃើញរឿងនេះជំពាក់ស្មុកស្មាញក្នុងខួរក្បាលរបស់លោកទ្បើងទៀត រហូតដល់កត្តិគ្រប់ដណ្តប់ផ្ទៃគ្រឹស្ថានរបស់លោកហើយ លោកក៏នៅតែពិចារណារឿងនេះមិនឃើញដដែល ។ ក្នុងពេលនោះ បុត្រីដ៏ប្រសើរបស់លោកឈ្មោះនាង សង់ដាកុមារី (Tsanda Kommari) ដែលស្រឡាញ់លោកជាទីបំផុត បានសង្កេតឃើញសេចក្តីទុក្ខរបស់លោក ។ នាងអង្គុយរមៀលចំបក់ថ្ងូតជូនលោក ហើយសួរថា "លោកឪពុក! ហេតុដូចម្តេច បានជាកើតទុក្ខព្រួយម្ល៉ះ?" ។ លោកឆ្លើយវិញថា "កូនសំឡាញ់មាសឪពុក! ឯហេតុដែលសង្កត់សង្កិនចិត្តរបស់ឪពុកនេះ គឺស្តេចទ្រង់

បង្គាប់ឲ្យឧពុកបំភ្លឺរឿងដ៏ពិបាកមួយ របស់ព្រាហ្មណ៍ចាំងបួននាក់, រួចបើសិនណាកូនរកវង ៧ ថ្ងៃនេះ ឧពុកធ្វើការនេះមិនបានសម្រេចទេ ឧពុកនឹងលែងកាន់តួយសនឹងពាក់របស់ឧពុកសព្វថ្ងៃនេះហើយ" ថាហើយលោកនិយាយរឿងយ៉ាងច្បាស់លាស់ច្បាប់នាង ។ កូនស្រីឆ្លើយថា "សូមលោកឧពុកកុំខ្វាចឲ្យសោះ កូនជានាអះអាងរករឿងនេះឲ្យឃើញមុនថ្ងៃទី ៧ នេះ ឲ្យដឹងតែព្រាហ្មណ៍ណាបានលួចគេ ប៉ុន្តែសុំឲ្យលោកឧពុកសង់រោងបណ្តោះអាសន្នមួយឲ្យសមរម្យ ធ្វើអំពីឫស្សីណាដែលស្រាល។ សង់នៅគៀនសួតមួយកន្លែងច្បារ រួចរុំហ៊ានសន្យាថាការណ៍នេះនឹងបានសម្រេចជាក្រាកជមិនខាន" ។

លោកកុង្សីយ៍បានបង្គាប់ឲ្យជាងធ្វើរោងតាមបំណងនាងដោយរួសរាន់, រួចបន្តិចក្រោយមក រោងស្រាលមួយក៏ដើបឡើងក្នុងទីសួនច្បារនោះត្រង់កន្លែងដែលនាងបង្ហាញ ។ នាងឲ្យព្រាហ្មណ៍ម្នាក់ៗ ឈរនៅជ្រុងរោងមួយៗគ្រប់ជ្រុងទាំងបួន ហើយនាងអង្គុយចំកណ្តាល ជាមួយស្រីបំរើរបស់នាងម្នាក់ នៅលើកន្ទេលដែលមានគ្រាលយ៉ាងរលើបរលង់ ។

លុះដល់ពេលយប់, ផ្ទៃសួនច្បារទាំងមូលក៏ភ្លឺត្រចះត្រចង់ដោយរស្មីនៃព្រះច័ន្ទ, កាលសូរសព្ទទាំងពួងចាត់ស្ងប់ស្ងាត់សូន្យឈឹង នាងសុំឲ្យព្រាហ្មណ៍ទាំងអស់និទានរឿងប្រជ្រុយផ្សេងៗ ដែលខ្លួនចេះចាំជាងគេ ទោះជារឿងទាំង ១៨ នៃលោកយើងនេះក្តី ឬរឿងសាវតារ

រឿងដំបូន្មានណាក្តី ឬ រឿងបរមត្ថវិជ្ជា ដែលជាវិជ្ជាសម្រាប់អ្នកប្រាជ្ញ
និងអ្នកកាន់សាសនាក្តី ។ ព្រាហ្មណ៍ទាំងបួននាក់លុះបានឮដូច្នោះហើយ
ក៏នាំគ្នាលដោយឥតធ្វើយអ្វីមួយមាត់សោះ ។ ក្រោយមក ព្រាហ្មណ៍
ដែលខាស់ជាងគេ ធ្វើយទៀងដោយអឹមអៀមថា "នាង! យើង
ស្តាយណាស់ ចំពោះកិច្ចដែលយើងនឹងធ្វើតាមបំណងរបស់នាងមិនកើត
ព្រោះយើងខ្ចាប់ក្រែងមានកំហុស, ដ្បិតបណ្តាពួកយើងទាំងអស់នេះ មាន
ម្នាក់មានកិរិយាអាក្រក់ ប៉ុន្តែយើងមិនហ៊ានចាប់ថ្នាក់ទេ, បើព្រាហ្មណ៍
អាក្រក់នេះ នៅតែមានកិរិយាមិនស្អាតមិនល្អដរាបណា ដរាបនោះ យើង
មិនអាចនៅសាងធម៌ព្រះពុទ្ធជាមួយបានទៀយ, ហេតុនេះ មានតែព្រះ
នាងនេះហើយ ដែលចេះដឹងជ្រៅជ្រះ មានក្តីឈ្លោះល្បីល្បាញខាង
បរមត្ថវិជ្ជានឹងខាងចរិយាសាស្ត្រ ទាំងមានវ័យនៅក្មេងត្រឡាំងយ៉ាងនេះ
ទើបអាចចេះនិយាយរឿងផ្សេងៗបាន" ។ នាងធ្វើយថា "ទេលោក,
ខ្ញុំជាស្រីល្ងង់ដូចស្រីផងទាំងពួងដែរតើ ខ្ញុំនេះមិនអាចប្រៀបធ្មឹមនឹងលោក
បានទៀយ ហើយខ្ញុំមិនអាចនិយាយឲ្យបានល្អក្នុងទីចំពោះមុខលោកទាំង
អស់ ដែលខ្ញុំកុកដូចជាគ្រូអាចារ្យរបស់ខ្ញុំទេ, ប៉ុន្តែបើលោកមានបំណង
ចង់ឲ្យខ្ញុំនិយាយ ខ្ញុំក៏សុខចិត្តនិទានរឿងមួយជូនលោកស្តាប់ដែរ" ។
ព្រាហ្មណ៍ទាំងបួនក៏ធ្វើសញ្ញាថា យល់ព្រមឲ្យនាងនិទានរឿង ដូចមាន
តទៅនេះ ៖

ភាគទី ៥

អ្នកឧកញ៉ាវិបុលរាជសេនា ង្ហួ-កន ប្រែរៀបរៀង

(តទៅ)

អ្ងនសៀវនឹងបណ្តាចៅហ្វាយខៀត្រទាំងអស់ក៏មិនបានតបថាប្រការម្តេច ។ ចូរឆ្ងល់ក្តួចចិត្តណាស់គិតរំពឹងថា ពួកទាំងនេះមុខជាប្រែចិត្តគំនិតដកថយពីគ្នាជាប្រាកដហើយ ដែលនឹងសង្ឃឹមយកជាគំនិតចិត្តមួយផងគ្នាយើញជាមិនបាន, ចូរឆ្ងល់ណាស់ចុះដើរចេញទៅចាត់ចែងការហាន ហើយលើកត្រឡប់ទៅស្រុកអេងដីវ, បណ្តាចៅហ្វាយខៀត្រទាំងអស់ក៏ត្រឡប់ទៅកាន់ទីដំនុំវិញ ។

ឯកងស៊ុនចាននិយាយទៅនឹងឡៅពី គួនអ៊ូ តៀវហ៊ុយថា អ្ងនសៀវនេះដែលនឹងគិតការណ៍ធំតទៅនោះមិនបានទេ យូរទៅនឹងមានអន្តរាយបើយើងតាមផងនឹងបានតែសេចក្តីលំបាក ដូច្នេះ យើងត្រូវនាំគ្នាទៅស្រុកវិញល្អជាង ។

ឡៅពី គួនអ៊ូ តៀវហ៊ុយ យើញត្រូវផងក៏បបួលគ្នាលើកពលការហានត្រឡប់ទៅស្រុកផងដួនគួន, ឡៅពីក៏លាចូលទៅនៅថែរក្សាស្រុក, កងស៊ុនចាន ក៏លើកហួសទៅស្រុកប៉ាក់បេង ។

ឯឡៅតាយដាច់ស្បៀងអាហារនឹងចាត់តាវឲ្យសេនាទាហានពុំគ្រប់គ្រាន់ បានឲ្យបំរើទៅនិយាយខ្ចីស្បៀងអាហារពីតៀវមៅៗមិនព្រមឲ្យ, ឡៅតាយខឹងណាស់ ដល់ពេលកណ្តាលយប់ ក៏លើកទាហានទៅលុកបន្ទាយតៀវមៅ សម្ងាប់តៀវមៅស្លាប់, គ្នង់ពេលនោះ ពួកទាហានតៀវមៅ នាំគ្នាមកចូលនៅនឹងឡៅតាយទាំងអស់ ។ អ្នកសៀវយើញថៅហ្វាយខៃត្រទាំងអស់គ្នា បែកខែកចិត្តប្រែគំនិតទៅដោយខ្លួន ខ្លះលើកទាហានទៅវិញដូច្នោះ, អ្នកសៀវក៏ឃុំទាហានលើកទៅស្រុកហូឡាយ, ថៅហ្វាយខៃត្រក្រៅពីនោះ លើកទាហាននាំវិលទៅខៃត្រទ័ណ្ឌវៀងខ្លួន ។ ឯឡៅពៀវថៅហ្វាយស្រុកកេងដីវនោះ ជាពូជព្រះពជវង្សព្រះថៅហាន់កូបូ មានទីប្រឹក្សា ៧ នាក់ ឈ្មោះតាន់សៀង ពួកស្រុកយីឡាំ ១ ខុងលិប ពួកស្រុកឡោកុក ១ ហួនខុង ពួកស្រុកពុតហៃ ១ តៀវលី ពួកស្រុកសាន់យ៉ុង ១ តៀវខៀម ពួកស្រុកសាន់យ៉ុង ១ ងឹមទិត ពួកស្រុកឡាំយ៉ុង ១ ហួនហុង ពួកស្រុកយីឡាំ ១ ទាំង ៧ នាក់នេះជាកៀនស្និទ្ធស្នាលនឹងឡៅពៀវមកពីដើម; នៅមានសេនាទាហានឯក ៣ នាក់ទៀតឈ្មោះកេងលៀង ១ កេងអួត ១ ឈួម ១ ទាំង ៣ នាក់នេះជាពួកស្រុកអៀងប៉ែង ។

ឡៅពៀវគាលបានដឹងហេតុតាមសេចក្តីសំបុត្រ ដែលអ្នកសៀវឲ្យក៏ចាត់ប្រៃកេងអួតនឹងឈួមឲ្យលើកទាហាន ១ ម៉ឺន ទៅស្កាត់ផ្លូវដែលស៊ុនកៀនលើកមកនោះ, លុះដួបប្រទះទ័ពគ្នាហើយ កេងអួតក៏ចេញទៅឈរ

ព័ម្ភខ ពាហានចាំឆ័ត្ត ។ ស៊ុនកៀនសើចស្រែកសួរកេង៉អួតថា អ្នកលើក
ពាហានមកស្លាត់ផ្លូវយើង៉ទុកដូច្នេះ តើអ្នកនឹង៉ប្លាថ្នារបស់អ្វី? ។ កេង៉
អួតតបថា ខ្ញុនអ្នកជាខ្ញុំពជការព្រះចៅហៀនតេ បានចាំង៉ស៊ើបព្រៃត្បូងប
មក ហេតុអ្វីអ្នកនាំយកគ្រាឆ្នាក់សម្រាប់ព្រះមហាក្សត្រមកនៅនឹង៉ខ្ញុន
អ្នកយកទៅធ្វើអ្វី អ្នកចូរយកគ្រានោះមកប្រគល់ឲ្យយើង៉ជាប្រញាប់ យើង៉
នឹង៉បាននាំចូលទៅថ្វាយព្រះចៅហៀនតេ បើអ្នកមិនព្រមឲ្យទេ យើង៉
ក៏មិនបើកផ្លូវឲ្យទៅ ។ ស៊ុនកៀនបានស្តាប់ហើយខឹង៉ណាស់ ទើបប្រើ
អ៊ុយកាយឲ្យចេញទៅតយុទ្ធនឹង៉កេង៉អួត, ពេលនោះឈ្លួម៉ាបរសេះស៊ុះ
ទៅមុខកេង៉អួតប្រយុទ្ធនឹង៉អ៊ុយកាយបាន ៧ ស្នៀត អ៊ុយកាយយកដំបង
វែក ៤ ដ្រុងបុកត្រូវដើមទ្រូង៉ឈ្លួម៉ាៗក៏ញាក់សេះរត់ ស៊ុនកៀនក៏ថែម
ដេញចាក់តាប់ពាហានឈ្លួម៉ាទៅដល់មុខស្រែកកេង៉ជីវ ហើយស្រាប់តែឮ
សំឡេង៉គង៉ឃ្មោះលើកំពូលភ្នំ ស៊ុនកៀនក្រឡេកទៅឃើញឡៅពៀវ
លើកពាហានមកជាច្រើនព័ទ្ធជុំវិញខ្លួន ក៏មានសេចក្តីកិតក័យណាស់ ។
ស៊ុនកៀនឧទានគំនាប់ឡៅពៀវហើយថា លោកដឿស្តាប់តែសំបុត្រអ្នន
សៀវហើយលើកពាហានមកធ្វើការចាំង៉នេះ ហាក់ប៉ដូចជាមិនអាណិត
អាសូរដល់ខ្ញុំសោះ ។ ឡៅពៀវសួរថា ដែលអ្នកនាំយកគ្រាសម្រាប់ពជ្យ
មកនេះនឹង៉គិតដណ្តើមយកពជសម្បត្តិឬ? ។ ស៊ុនកៀនឆ្លើយថា បើខ្ញុំបាន
យកគ្រាស៊ើបព្រៃត្បូងមក ដូចអ្នន សៀវឲ្យដំណឹង៉មែន សូមឲ្យខ្ញុំស្តាប់

ដោយគ្រឿងសស្ត្រាវុធផ្សេងៗចុះ ។ ឡៅពៀវធ្វើយថា បើអ្នកនឹងចង់ឲ្យយើងអស់សង្ឃឹយ ចូរហៅទាហានទាំងអស់របស់អ្នកមកឲ្យយើងត្រួតពិនិត្យមើល ទើបយើងដឿជាក់ច្បាកដ ។ ស៊ុនកៀនឮដឹងណាស់ធ្វើយតបថា យើងបានស្បថសច្ចាន់តម្រង់ខ្លួនហើយ នៅតែមិនដឿខ្មៅត បើអ្នកមានថ្ងៃដៃខ្លាំងពូកែយ៉ាងណា ចូរមកល្បងគ្នាចុះ ។ ឡៅពៀបាន ស្តាប់ដូច្នោះ ក៏ក្លែងធ្វើជាលើកពលថយក្រោយទៅវិញ, ស៊ុនកៀនបំផាយសេះដេញទៅដល់ដើងកុំសងខាងផ្លូវ, ឯទាហានឡៅពៀវដែលបង្កប់នៅទីនោះសុះចេញមកទាំងសងខាង, ទទួលឈ្មួ"នឹងកេងអួត ដែលរត់ដោយចាញ់ដៃទ័ពស៊ុនកៀននោះ បរសេះនាំទាហានមកពីក្រោយថែមទៀតត្រួតរាយផ្ចប់ប្រសព្វគ្នា, ឡៅពៀក៏បរពលរាយប្រសព្វមកពីមុខទៀត ស៊ុនកៀនឃាល់ច្រកក៏រាចច្បាំងទាំងសងខាងមុខក្រោយ, អ៊ុយកាយនឹងទៀផៅ ហាន់តុង ឃើញខូចខាតទាហានច្រើនណាស់ ព្រោះទាហានឡៅពៀវឡ្រាមព័ទ្ធជាប់ស៊ុនកៀននៅកណ្តឹងចំណោមទ័ព ក៏សុះទំលុះទំលាយទៅជួយហើយនាំយកស៊ុនកៀនចេញមកបាន ស្រួតលើកទាហានតម្រង់ទៅស្រុកកាំងតាំង ។ ចាប់តាំងពីនោះមក ឡៅពៀវនឹងស៊ុនកៀន ក៏មានសេចក្តីគំនុំគុំគួនព្យាបាទគ្នាជាប់ក្នុងចិត្ត ។

កណ្ឌទី ៦

ចាប់តាំងពីហង់គីបបួលអ្នកសៀវភៅច្បាំងយកស្រុកគីជីវ រៀងរហូតដល់អង្គអ៊ុន
ឱយាយលួងលោមនាងឡៃលៀនជាកូនចិញ្ចឹម ឲ្យទៅធ្វើប្រពន្ធតាំងតុះផង លិចោមផង
ដើម្បីចំណងឲ្យអ្នកទាំង ២ នេះទាស់ទែងខ្វែងគំនិតគ្នា

ខណៈកាលអ្នកសៀវដែលលើកសេនាយោធាទៅស្រុកហូឡាយនោះ
ក៏ដាច់ស្បៀងអាហារអស់រលីង, លុះដំណឹងនេះជ្រាបដល់ហាន់ហុក
ចៅហ្វាយស្រុកគិជីវ។ ហាន់ហុកក៏ចាត់មនុស្សឲ្យនាំស្បៀងទៅជូនអ្នក
សៀវ ។ ពេលនោះ ហង់គីនិយាយនឹងអ្នកសៀវថា បណ្តាមនុស្សទាំង
អស់ក៏ចានដឹងច្បាស់ច្បាកដថាលោកនេះពូជនាហ្នឹងត។ មកពីដើម ដែល
លោកមកធ្វើការទំនុកបំរុងផែនដីសម័យនេះ មិនគួរនឹងមកអង្វរយាចាំពីសា
ដោយគេបញ្ជូនស្បៀងអាហារមកឲ្យនោះសោះ ប្រសិនជាមិនមានគេ
បញ្ជូនមកជូនលោក។ ក៏មានសេចក្តីលំបាក ការណ៍នេះខ្ញុំឃើញថាស្រុក
គីជីវ មានមនុស្សអ្នកមានទ្រព្យសម្បត្តិ ទាំងស្រូវអង្ករចំណីគ្រាន់ក៏សឹងតែ
បរិបូណ៌មិនខ្វះខាត សុំឲ្យលោកលើកសេនាទាហានទៅវាយយកស្រុក
គីជីវចុះ ដល់វាយបានហើយលោកត្រូវនៅកាន់កាប់ស្រុកនោះតទៅ បើ
លោកនឹងប្រាថ្នាគិតការអ្វីជាធំក៏នឹងបានសម្រេចតាមប្រាថ្នា ។ អ្នកសៀវ
ឆ្លើយតបថា យើងក៏បានរិះគិតដូច្នេះដែរ តែថាមិនទាន់មានឧកាសនឹង
ធ្វើបាន។ ជាបង្គំនៅស្ងៀមសិន ។ ហង់គីថា បើលោកគិតជាប្រាកដ

ត្រូវមានសំបុត្រសម្ងាត់ទៅដល់កងស៊ុនចាន ឲ្យលើកទាហានចូលវាយ
ស្រុកគីជីវ ១ ផ្លូវ ចំណែកលោកលើកទៅវាយច្រកសឲ្យ ១ ផ្លូវទៀត ប៉ែ
ចាន់ស្រុកនោះហើយ សឹមបែងវិលែកចែកទ្រព្យរបស់ទឹងមនុស្សចំណុះ
ស្រុកឲ្យកងស៊ុនចានពាក់កណ្តាលចុះ នោះបើកងស៊ុនចានលើកទាហាន
ទៅជួយវាយលើកនេះ, ឯហាន់ហុកទៅហ្វាយស្រុកនោះជាមនុស្សមិនចេះ
គិតអ្វីសោះ គង់ទឹងមានសំបុត្របកដល់លោកឲ្យលើកទាហានទៅជួយ
លោកក៏ទឹងចានស្រុកគីជីវដោយងាយមិនត្រួយចារម្ក ។ អ្នកសៀវ
ឃើញត្រូវ ទើបតែងសំបុត្រការសម្ងាត់ប្រាប់ទៅកងស៊ុនចានតាមគំនិត
របស់ហង៍គី ។

សម័យនោះ កងស៊ុនចានបានទទួលសំបុត្រអ្នកសៀវមើលដឹង
សេចក្តីហើយក៏មានចិត្តត្រេកអរពន់ពេក ទើបធ្វើសំបុត្រតបទៅអ្នកសៀវ
វិញ ប្រាប់ពេលកំណត់ដែលទឹងលើកទាហានទៅវាយស្រុកគីជីវនោះ ។
អ្នកសៀវបានដឹងសេចក្តីសំបុត្រនោះហើយ ក៏ចាត់បំរើម្នាក់ឲ្យនាំសំបុត្រ ១
ច្បាប់ទៅប្រាប់ហាន់ហុកទៅហ្វាយស្រុកគីជីវថា ឥឡូវនេះកងស៊ុនចាន
មានសំបុត្រមកប្រឹក្សាថា ទឹងលើកទាហានមកវាយយកស្រុកគីជីវហើយ ។
ហាន់ហុកទទួលសំបុត្រហើយក៏ហៅទីប្រឹក្សា ឈ្មោះស៊ុនស៊ុមទឹងស៊ុនប៉ែង
មកពីគ្រោះថា ឥឡូវកងស៊ុនចានមុខជានឹងលើកទាហានមកវាយស្រុក
យើងហើយ តើយើងនឹងគិតដូចម្តេច? ។

ស៊ុនសុមឆ្លើយថា ដែលកងស៊ុនចាននឹងលើកទាហានមកវាយស្រុកយើងនេះ ឃើញថានឹងលើកមកច្រើនណាស់ ហើយឡៅពី កួនអ៊ូ តៀវ ហ៊ុយកំគង់នឹងមកផង ទាហានរបស់យើងឃើញជាតស៊ូនឹងគេមិនបានឯអ្នងសៀវក៏ប្រកបទៅដោយសតិបញ្ញា មានទាហានឯកនឹងទាហានឡៅកំច្រើន បើដូច្នេះ សុំឲ្យលោកមានសំបុត្រទៅអញ្ជើញអ្នងសៀវមកនៅឈរការក្សាស្រុកយើងចុះនឹងបានជួយការពារការក្សាគ្នាតទៅ អ្នងសៀវក៏គង់មានសេចក្តីមេត្តាដល់លោកខ្លះ ឯកងស៊ុនចានក៏គង់មិនហានមកញាំញីស្រុកយើងព្រោះក្រែងខ្លាចអ្នងសៀវ ។

ហាន់ហុកស្តាប់ហើយឃើញត្រូវផង ក៏តែងសំបុត្រ ១ ច្បាប់ឲ្យគួនតីនាំទៅដួនអ្នងសៀវតាមពាក្យស៊ុនសុម ។ ពេលនោះ កេងប៊ូដរាបហាន់ហុកថា អ្នងសៀវនោះជាមនុស្សឆ្លាត់តំនិតហើយ ដែលនៅគង់ទ្រង់តាំងខ្លួនចិញ្ចឹមទាហានសព្វថ្ងៃនេះបាន ដោយអាស្រ័យស្បៀងអាហារដែលលោកបញ្ជូនទៅឲ្យ ឧបមាបីដូចជាទារក បើមាតាមិនឲ្យទឹកដោះជ្រហើយ ក៏មានតែសេចក្តីយំសោកជាទុក្ខដោយការស្រេកឃ្លាន, បើលោកនឹងឲ្យអ្នងសៀវមកជួយរក្សាស្រុកជាប្រធាន ក៏ដូចជាចាប់ខ្លាទៅលែងក្នុងហួងប្រើសត្រាយ គង់នឹងមានភ័យអន្តរាយដល់សត្វទាំងនោះ, ការណ៍នេះសូមលោកត្រិះរិះមើលតាមសមគួរសិន ។ ហាន់ហុកតបថា ខ្លួនយើងពីដើមដែលនឹងបានធ្វើជានាហ្មឺនជាប់មកនោះ ក៏ព្រោះសែអ្នងជួយឧបត្ថម្ភនាំសេចក្តីគុណតាប់ឲ្យតើតឡើង ទើបយើងបានមកធ្វើថា-

ហ្នឹយស្រែកនេះ, យើងក៏ឃើញថាអ្នកសៀវមានសតិបញ្ញាល្អជាងយើង, ម្យ៉ាងទៀតចាស់ហ្នឹកណាមានថាទុតមកថា "បើអ្នកឯណាមានសតិបញ្ញាត្រូវឲ្យអ្នកលង់ទុសាហ៍គោរពកោតខ្លាច ទើបអាចរក្សាសេចក្តីសុខបាន" ដែលអ្នកមកយល់ថាស់ឲ្យខុសនឹងពាក្យចាស់ហ្នឹកណាដូច្នេះ យើងមិនយល់ត្រមងនេ ។

កេងប៊ូបានឮដូច្នោះក៏ដកដង្ហើមធំហើយនិយាយថា ស្រែកគីដីវនេះគង់នឹងសាប់សូន្យជាធាប់ប្រាកដ ។ កេងប៊ូនឹងនាហ្នឹនចំនួន ២៣ នាក់ក៏លាងារចេញពីពជការ ។ កេងប៊ូបាននាំកូនស៊ុនទៅចាំអែបប្រយ័ត្នស្រែកដែលអ្នកសៀវនឹងចូលទៅនោះ ។

រៀលាដែលអ្នកសៀវបានទទួលសំបុត្រហានហុក មើលដឹងសេចក្តីហើយក៏ចាត់ចែងសេនាពាហានលើកទៅស្រែកគីដីវ, អ្នកសៀវកាលចូលទៅដល់ព្រំស្រែក កេងប៊ូនឹងកូនស៊ុន ជកគ្រែប៊ីសុះចេញទៅនឹងចាក់អ្នកសៀវ, ង៉ាងលឿងនឹងប៊ុនទិវឃើញដូច្នោះ ក៏សុះជកគ្រែប៊ីរត់ទៅការពារហើយកាប់កេងប៊ូនឹងកូនស៊ុនស្លាប់ ។ អ្នកសៀវលើកពាហានចូលទៅក្នុងស្រែក, ហានហុកក៏ចេញមកទទួលហើយនាំទៅកាន់ទីសំណាក់ពជការ, អ្នកសៀវទទួលកាន់កាប់ក្បាស្រែកនោះពេញទី ហើយតាំងហានហុកជាប៊ុចុងគុន ប្រែថា: "នាយពាហានឯក"; ឯបណ្តាឡុកជការក្រៅពីនោះអ្នកសៀវឲ្យជកហូតចេញទាំងអស់ ហើយតាំងកៀនហាង១ចោស៊ីវ១ទៅស៊ីវ១ហាងគី១ ដែលជាពាហានអ្នកសៀវនោះធ្វើជានាហ្នឹនកងពជការ ។ (មានត)

ព្រះរាជពង្សាវតារប្រទេសកម្ពុជា

ភាគទី ២

សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម - ក្រសេម រៀបរៀង

(តទៅ)

ព្រះចាន្ទសាណវ័ន្តទី ២

ព.ស. ១៦៦៥ - ១៧៣១ គ.ស. ១២២ - ១២៨

កាលព្រះបាទហសិវ័ន្តទី ១ សោយទិវង្គតហើយ, ព្រះឆ្លៀសាណ-វ័ន្ត ជាអនុជាធិរាជ បានឡើងគ្រងរាជបល្ល័ង្កស្នងព្រះជេដ្ឋាធិរាជ មាន ព្រះបរមនាមថា "ព្រះបាទឆ្លៀសាណវ័ន្តទី ២" គង់នៅក្រុងស្រីយសោ-ធរបុរៈ ។ ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្តេច នឹង មានព្រះ រាជនរសព្រះរាជធីតាឬទេ មិនច្បាស់ក្នុងប្រវត្តិសាស្ត្រ ។

ការផែនដី ក្នុងរជ្ជកាលនេះ មានរាជបុរោហិតឈ្មោះ កុមារ ស្វាមិ សឹងត្រូវជាក្មួយ សិរីស្រម ជាទីប្រឹក្សាការផែនដី នឹង ធ្វើពិធី ផ្សេង ។ ថ្វាយ ។ ការផែនដី ក្នុងរជ្ជកាលនេះ បានចំរើនឬអាប់ទន យ៉ាងណា មិនឃើញពោលដល់ ។ តែតាមសេចក្តីយល់ថា ព្រះ មហាក្សត្រិយ៍អង្គនេះ មិនសូវមានព្រះគតិជានុភាពដូចព្រះរាជបិតាទេ ដូច្នេះការផែនដីគង់ខ្សោយចុះបន្តិច ។

ស្តេចស្ថិតនៅក្នុងរាជសម្បត្តិបានត្រឹម ៦ ឆ្នាំ ក៏សោយទិវង្គត, គេ
ថ្វាយព្រះនាមព្រះបរមសពថា "បរមវ្រះលោក" ។

ព្រះបាទជយវ័ន្មទី ៤

ព.ស. ១៤៦៥ - ១៤៨៥ គ.ស. ៩២២ - ៩៤២

កាលព្រះបាទឥសាណវ័ន្មសោយទិវង្គតហើយ, រាជសម្បត្តិបាន
ទៅព្រះជយវ័ន្ម ។ ព្រះជយវ័ន្មអង្គនេះ តំណព្រះវង្សមកអំពីព្រះជយ-
វ័ន្មទី ៣, មានដំណឹងក្នុងរជ្ជកាលព្រះបាទយសោវ័ន្មថា មានពួកព្រះ
រាជវង្សក្នុងរជ្ជកាលព្រះបាទជយវ័ន្មទី ៣ ធ្វើការបះបោរដើម្បីដណ្តើមរាជ-
បល្ល័ង្ក តែព្រះបាទយសោវ័ន្មទឹងព្រះរាជនុសទ្រង់ការពារបានរហូតមក,
លុះផុតរជ្ជកាលព្រះបាទឥសាណវ័ន្មហើយ ជានុកាសឲ្យព្រះរាជវង្សខាង
ព្រះបាទជយវ័ន្មទី ៣ បានឡើងគ្រងបល្ល័ង្ករាជ្យ ទ្រង់ព្រះនាមថា
"ព្រះបាទជយវ័ន្មទី ៤" ។ ដំបូង ស្តេចគង់នៅក្រុងស្រីយសោធរបុរៈ
ទ្រង់មានព្រះអគ្គមហេសីព្រះនាមជយទេវី ជាព្រះរាជធីតារបស់ព្រះបាទ
ឥន្ទ្រវ័ន្មទី ១ ត្រូវជាកនិដ្ឋភគិនីនៃព្រះបាទយសោវ័ន្មទី ១ មានព្រះរាជ-
នុសទ ១ អង្គព្រះនាម ហសិវ័ន្ម ។

ការផែនដី: ក្នុងរជ្ជកាលនេះ មានរាជបុរោហិតចាស់ដែលធ្លាប់
ធ្វើរាជការក្នុងរជ្ជកាលព្រះបាទឥសាណវ័ន្ម គឺកុមារស្វាមិ ជាទីប្រឹក្សា
ការផែនដី ខ្ពឹង ធ្វើពិធីផ្សេង ។ ថ្វាយ ទ្រង់និយមនៅកងលទ្ធិសៈ ។

ក្រោយដែលទ្រង់បានទទួលព្រះរាជពិធីបរមរាជាភិសេកហើយ មិនយូរ, ប៉ុន្មាន បានស្តេចទៅសាងព្រះរាជដានីថ្មីមួយនៅជោគគរគ្យារ គឺនៅកោះកែកុងវែតព្រហ្មទេព ហើយស្តេចទៅគង់នៅព្រះរាជដានីថ្មីនេះ បានចាំងនាំយករូបព្រះកម្រតេងជគតរាជទៅប្រតិស្ឋាននៅក្រុងថ្មីនោះផង ។ ព្រះហស៊ីវរ័ន្តជារាជនុរសគង់នៅអនិន្ទិតបុរៈ ។

មានបញ្ហាថា ហេតុដូចម្តេច បានជាព្រះបាទជយវរ័ន្តស្តេចចេញចាកព្រះមហានគរស្រីយសោធរបុរៈ ដែលជានគរល្អបំផុត ទៅគង់នៅក្រុងតូចដែលទើបនឹងសាងថ្មីនោះវិញ? ។ រឿងនេះ អ្នកប្រវត្តិសាស្ត្របានចាក់ចិត្តដែរ តែមិនប្រទះហេតុផលល្មមនឹងដោះស្រាយបាន ក៏នៅជារឿងងងឹតដដែល ។ កិច្ចការក្រៅអំពីនេះក៏មិនមានអ្វីជាសំខាន់ដែលគួរនាំមកសំដែងក្នុងទីនេះ ។

ព្រះបាទជយវរ័ន្តទី ៤ ស្តេចស្ថិតនៅក្នុងរាជសម្បត្តិបាន ២០ ឆ្នាំ ក៏សោយទិវង្គត, គេថ្វាយព្រះនាមព្រះបរមសពថា " ព្រះបាទបរមសិវបទ " ។

ព្រះឥន្ទ្រាហស៊ីវរ័ន្តទី ៥

ព. ស. ២៤៩៥ - ២៤៩៧ ឆ. ស. ៩៤២ - ៩៤៤

កាលព្រះបាទជយវរ័ន្តទី ៤ សោយទិវង្គតហើយ. ព្រះហស៊ីវរ័ន្តជារាជនុរសបានឡើងសោយរាជ្យស្នងព្រះរាជបិតាតមក មានព្រះបរមនាមថា

"ព្រះបាទហសិវ៉ន្ទ៍ទី ២" ។ ស្តេចគង់នៅជោគគរគ្យារ, ទ្រង់មានព្រះអគ្គមហេសី ព្រះនាមដូចម្តេច នឹងមានព្រះរាជឱរសព្រះរាជធីតាឬទេ គ្មានពោលដល់ ។

ការផែនដី: ក្នុងរជ្ជកាលនេះ មានរាជបុរោហិតឈ្មោះឦសាណមូរ្តិ ជាទីប្រឹក្សាការផែនដី នឹង ធ្វើពិធីផ្សេងៗថ្វាយ ទ្រង់រាប់អានសាសនាព្រាហ្មណ៍ ។ ក្រោយរាជាភិសេកហើយ កើតសង្គ្រាមក្នុងព្រះនគរដោយព្រះរាជទ្រព្យវ៉ន្ត ជាឱរសព្រះនាងមហេន្ទ្រទេវី សឹងរួមព្រះអយ្យកោព្រះអយ្យិកាជាមួយគ្នាខាងព្រះមាតា បានលើកកំឡាំងទៅលុកព្រះអង្គដោយបំណងយកបល្ល័ង្ករាជ្យ ។ ព្រះបាទហសិវ៉ន្ទ៍ទ្រង់លើកកងទ័ពចេញច្បាំងទប់ទល់ពេញទំហឹង ប៉ុន្តែទ្រង់ចាញ់ប្រៀបក្នុងផ្លូវកលយុទ្ធ ព្រះអង្គក៏សោយទិវង្គតកងសម៉រភូមិ ។ ស្តេចស្ថិតនៅកងរាជសម្បត្តិបានតែត្រឹម ២ ឆ្នាំ, គេថ្វាយព្រះនាមព្រះបរមសពថា "ព្រះបាទព្រហ្មលោក" ។

ព្រះចាន្ទរាជេន្ទ្រវ៉ន្ទ៍ទី ២

ព. ស. ១៤៧៣ - ១៥១១ ផ. ស. ៨៤៤ - ៨៦៨

ព្រះបាទរាជេន្ទ្រវ៉ន្ទ៍ កាលទ្រង់ធ្វើសឹកមានជ័យជំនះបានឡើងគង់លើរាជបល្ល័ង្កហើយ មានព្រះបរមនាមថា "ព្រះបាទរាជេន្ទ្រវ៉ន្ទ៍ទី ២"

ស្តេចគង់នៅមហានគរស្រីយសោធរបុរៈ, ទ្រង់មានព្រះអគ្គមហេសីព្រះនាម ភាជេន្ទ្រទេវី ព្រះរាជធីតា ១ អង្គ ព្រះនាម ឥន្ទ្រលក្ស្មី ។

ការផែនដី: ក្នុងរជ្ជកាលនេះ មានរាជបុរោហិតឈ្មោះ អាគ្នសិវៈ ត្រូវជាកូយគ្ឈសាណម្ភរិ ជាទីប្រឹក្សាការផែនដី នឹង ធ្វើពិធីផ្សេង។ ថ្វាយ, ទ្រង់រាប់អានសាសនាព្រាហ្មណ៍ក្នុងលទ្ធិសៃវៈ, ទ្រង់មានសេនាបតីសំខាន់ ២ នាក់ គឺ ១ ឈ្មោះរាជា រាជកុលមហាមន្ត្រី ជាអ្នករាប់អានលទ្ធិសៃយ, ១ ទៀតឈ្មោះភវិន្ទ្រាវិម័ទន៍ (?) ជាអ្នកកាន់ព្រះពុទ្ធសាសនា ។ សេនាបតីក្រោយនេះបានសាងព្រះពុទ្ធរូបទុកនៅប្រាសាទបាទជុំខ្លះ នៅក្រុងស្រីយសោធរៈបុរៈខ្លះ ។

សិលាចារឹកនៅប្រាសាទបក្សីចាំក្រុងថា ព្រះបាទភវេន្ទ្រវរ្ម័នទ្រង់លើកទ័ពទៅវាយនគរចម្ប៉ា" មានជ័យជំនះ បាននគរចម្ប៉ាជាចំណុះកម្ពុជរដ្ឋជាថ្មីម្តងទៀត (១) ។

ព្រះបាទភវេន្ទ្រវរ្ម័នទី ២ ស្តេចស្ថិតនៅក្នុងរាជសម្បត្តិដរាបដល់ ព. ស. ១៥១១ ក៏សោយទិវង្គត, គេថ្វាយព្រះនាមព្រះបរមសពថា "ព្រះបាទសិវលោក" ព្រះអង្គមានព្រះកិត្តិយសជា រាជាធិរាជ ១ អង្គ ក្នុងប្រវត្តិសាស្ត្រ ។ (មានត)

• ក្នុងសិលាចារឹកនោះថា ទ្រង់បានយកព្រះទេវរូបមាស ១អង្គអំពីវិហារពោធិនាគ ។

សាវតារវត្តវិហារទន្ទឹម

នៅឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម

ឯកញ្ញា កែវ - ហាង់

ចាងហ្វាង៖រ៉ែត្រែត នៅឃុំ - ស្រុក - ខេត្តនេះ រៀបរៀង

រង្វាន់លេខ ១

ប្រវត្តិហេតុដើម

មានស្តេចមួយអង្គទ្រង់ព្រះនាម ព្រះបាទទុម្ពរ អគ្គមហេសីមាន នាមមិនប្រាកដ គង់នៅភូមិវិហារហ្លួង ស្រុកត្បូងឃ្មុំ ។ ទ្រង់បានជីក ស្រះ១ ធំ ទទឹងជាង ១០០ ម៉ែត្រ បណ្តោយប្រហែល ៤ ឬ ៥ រយម៉ែត្រ នៅខាងកើតវត្តវិហារទន្ទឹមសព្វថ្ងៃនេះ ។ ស្តេចនេះមានបុត្រីមួយអង្គ តែព្រះនាមមិនប្រាកដ ។ មានសត្វក្រពើទាំបុត្រីស្តេចនេះពាំនាំយក មកចោកនៅវាលខាងជើងវត្តវិហារទន្ទឹម គេហៅជាប់មកដល់សព្វថ្ងៃថា វាលតូងក្រពើ, កាលវាលេបបុត្រីស្តេចនេះហើយក៏គេចវត់ប្តាត់ទៅ, ស្តេច ឲ្យពលរេហ៍តាមរកក្រពើនោះ តែតាមរកមិនឃើញ (តាមស្មានកាលពី ដើមប្រហែលទន្លេនេះជាសមុទ្រពេញទាំងអស់), ស្តេចឲ្យវាស់ថ្នល់ដែល លើកជាប់ពីកំពូតជាំងទៅបន្ទាយព្រៃនគរ គឺបន្ទាយស្តេច កន ក្នុងឃុំជួនតី សព្វថ្ងៃ ។ ពេលបានចំណាយថ្នល់បង្ហូតទឹកឲ្យរីងធ្លើរឆ្ងោះបិទមិនឲ្យក្រពើ

ចេញរួច, ដល់ហួរវ៉ែនទឹកគោកហើយ ក្រពើក្អែងខាក់បុត្រីស្តេចអង្គនោះ ដែលហើមហើយនៅកង់ឃុំដីគំរ; ត្រង់ទីនោះជាប់ហៅមកថា គោកហើម ។ ទឹកក្នុងស្រះធំដែលស្តេចជីកខាងលើក៏គោកវ៉ែង ស្រះនោះគេហៅថា ទន្លេសួត រហូតសព្វថ្ងៃ ។ ឯសត្វក្រពើរត់មកចូលរូងខាងកើតវត្តវិហារខ្ពស់ កង់ឃុំសួង គេហៅជាប់មកថា ក្បាលរូង; សព្វថ្ងៃមានទឹកហូរចេញជាប្រក្រតី ខួបច្រាំងវស្សាមិនដែលជាប់ ។ ស្តេចយកសពបុត្រីទៅធ្វើចេតិយជាក់នៅជិតស្រះធំខាងលើ ហើយទ្រង់ឲ្យជីកស្រះតូច ១ ទៀត នៅមុខចេតិយរៀបពីថ្មបាយក្រៀម, ចេតិយនោះមានដើមដែជុះស្រោបបាក់បែកអស់ គេហៅថា ច្បាសាទដែរយោង រហូតមកដល់សព្វថ្ងៃ, ច្បាសាទនេះ នៅជាខាងកើតវិហារទន្ទឹម ប្រហែល ៣ ឬ ៤ រយម៉ែត្រ ។

និយាយពីទីវត្តវិហារទន្ទឹម

ព្រះបាទឧទុម្ពរ កាលក្រោយសត្វក្រពើទាំបុត្រី ទ្រង់បានយាងមកកសាងវត្តវិហារទន្ទឹមនេះ, ឯអគ្គមហេសីសាងវិហារ ១ ជាខាងដើងទន្ទឹមគ្នានឹងវិហារដែលស្តេចថ្ពស់ធ្វើពីគ្រឿងឈើប្រក់ស្បូវ បានជាហៅថា វិហារទន្ទឹម ដល់មកសព្វថ្ងៃនេះ ។ ស្តេចបានជីកស្រះ ១ ខាងមុខវត្តយកដីមកលើករឿនវិហារទាំងពីរនោះ បានទាំងជីកស្រះពីរតូច។ ចំមុខវិហារខាងដើង ១ ខាងក្បួង ១ រៀបពីថ្មបាយក្រៀមមានជណ្តើរ ៤ ចុះទៅក្នុងស្រះ; តែស្រះ ១ ខាងក្បួងរលុបហើយ នៅតែខាងដើង

សព្វថ្ងៃនេះបាក់បែកស្រុតរួចអស់ជាច្រើន ។ មានថ្មចំណាក់របៀបខ្លោងទ្វារនៅសល់ខ្លះសព្វថ្ងៃនេះ ឮថាមានចារឹកអក្សរផង តែបាត់បង់ទៅយូរហើយ ។ តាមដំណឹងថា វត្តវិហារទន្ទឹមនេះ ព្រះបាទឧទុម្ពរទេន៍សាងមុនអង្គរព្រះជ័យកំពង់ចាម ពីពុទ្ធសករាជប៉ុន្មានមិនច្បាស់ជ ។

កាលពី គ. ស. ១៩១២ ខ្ញុំបានចេញមកធ្វើសុភាវៃត្តឃ្លងឃ្មុំនេះ; កាលណោះមានឈ្មោះ ស អាយុ ៦២ ឆ្នាំ, ឈ្មោះមន្ត្រីអញ្ជិត សំ អាយុ ៥៩ ឆ្នាំ នៅឃុំវិហារហ្លួង, ឈ្មោះយោគ្យ័ត្រ ប៉ុល អាយុ ៦០ ឆ្នាំ, ឈ្មោះអ្នត អាយុមិនចាំ តែចាស់ណាស់ហើយ នៅឃុំសួង; អ្នកទាំងអំបាលនេះបាននិយាយដំណាលរឿងព្រះបាទឧទុម្ពរសាងវត្តវិហារទន្ទឹម ដូចខាងលើនេះ តែអ្នកអំបាលណោះ ឥឡូវនេះអនិច្ចកម្មអស់ទៅហើយ ។ ពីមុនមានឈ្មោះ ឃុំវិហារទន្ទឹម ជាប់មក តែដល់ គ. ស. ១៩២៦ រាជការរួមឃុំវិហារទន្ទឹមបញ្ចូលទៅក្នុងឃុំសួង ។

១ — និយាយពីរបៀបកសាងវត្ត

កាលព្រះបាទឧទុម្ពរកសាងវត្តវិហារទន្ទឹមនេះ ធ្វើដូចក្បួនខាងក្រោមនេះដែរ ឬដូចម្តេចខ្ញុំបានមិនដឹង ។

មានក្បួនមួយនិយាយពីរបៀបកសាងវត្ត កសាងនិវេសន៍ពាំងស្ពេចនឹងភូមិ ក្បួននោះឈ្មោះថា ក្បួនត្រៃភូមិ ។

អ្នកស្រុកភូមិមានគ្នាច្រើនល្មមកសាងវត្តមួយបាន ដើម្បីកុំឲ្យពិបាកដើរទៅធ្វើបុណ្យទានឯវត្តដទៃឡើយ ក៏នាំគ្នាចូលទៅសុំច្បាប់ដល់សម្តេចព្រះមហាសង្ឃរាជ។ នាំយកសេចក្តីក្រាបទូលព្រះមហាក្សត្រិយ៍ ។ លុះបានអនុញ្ញាតហើយ អ្នកស្រុកតែងរកអាចារ្យហោរាដែលចេះក្បួនច្បាប់ទៅមើលទីកន្លែងដី ។ តាមក្បួន ឲ្យរើសរកដីរបៀបខ្នងដើងធ្លងមនុស្សដែលឈរបែរមុខទៅទិសខាងកើត សម្រាប់ធ្វើវត្ត - វាំង - កូមិ ។ អាចារ្យកាន់ទង - បណ្តាយដីជាគំរួយបានហើយផ្អាកទុក ។ អាចារ្យមើលឫក្សវៃថ្ងៃនឹងវាស់បែងគ្រឡានាទីដីនោះ រួចឲ្យធ្វើកន ៣ ថ្នាក់ មានបាយសីស្វាធម៌ ទឹកអប់ សំពត់សគ្រាលកន មានឆ័ត្រចាំងកន មានរៀបព្រះពិស្តុការ ជម ៤ សំពត់ស ១ អាវ ខៀនធួប ៥ ផ្ទៃឈើ ៤ ក្រចាត់ ១ រៀលស្មា ១ ដបផង ។ អាចារ្យឲ្យនិមន្តលោកចៅអធិការវត្តដែលនៅជិតឲ្យទៅឈរនៅក្នុងទីដីនោះ ហើយទាញខ្សែវាស់ដីនោះ ពីព្រំខាងកើតទៅព្រំខាងលិច ពីត្បូងទៅឯជើង ខ្សែនោះយកមកបត់ជាពីរ, រួចទាញខ្សែបត់ពីព្រំខាងកើតទៅឯលិច ពីត្បូងទៅឯជើង ពាក់កណ្តាលដី ចុងខ្សែបត់ជួបគ្នាត្រង់ណា អាចារ្យឲ្យចោះគោលត្រង់ណោះ។ ហៅថា ផ្តិតវត្ត ។ ឯលោកចៅអធិការដែលនិមន្តទៅឈរ វេលាអាចារ្យវាស់ដីនោះ ហៅថាចៅខែ, អាចារ្យឲ្យរៀប បង្អែម ចំអប កន្ទេល ខ្នើយ ប្រអប់ស្វាសំពត់ដំណល់ធ្លង - ស្តាំ ទឹកសំបូរ ១ ផ្តិល, ផ្ងៃពែ ១ មានកន្ទោងបាយស-

ក្រហម យកទៅជាក់រៀបត្រង់គោលផ្ទៃវត្ត ហើយសូត្រអញ្ជើញទេវតា គ្រប់ចក្រឡាវឡនឹងព្រះភូមិ - នាងគង្គីនីព្រះធរណី, សូត្រចប់ហើយ សែនពែសុំទឹកដីពីនាងគង្គីនីព្រះធរណី នឹង សុំពីព្រះភូមិ សុំកសាងវត្តថ្មីនេះ សែនហើយផ្កាប់ពែ ។ អាចារ្យរាស់បែងក្រឡាទីដីនេះ ជា ២៥ ក្រឡាផ្ចាំង មានឈ្មោះគ្រប់ក្រឡាផ្ចាំង (តែចាំមិនអស់) យកតែក្រឡាផ្ចាំងណាខ្លះដែលត្រូវការប្រើ, ត្រង់គោលផ្ទៃវត្ត **សង់សាលាកុដិឬធ្វើអ្វីមិនបានទេ** ។ ក្រឡាផ្ចាំងព្រះមហោសថ សង់ព្រះវិហារ, ក្រឡាផ្ចាំងជោគសេដ្ឋីឬមហាសេដ្ឋី សង់កុដិចៅអធិការ, ក្រឡាផ្ចាំងព្រះពុទ្ធរ **សង់សាលាធ្វើបុណ្យទាន** ព្រោះព្រះពុទ្ធរចេះសំដែងធម៌, ផ្ចាំងសង់សាលាធាន់មិនចាំជាហៅថាផ្ចាំងអ្វី ។ (កាត់ខ្លីចាំមិនអស់) អាចារ្យយកនាមភូមិនឹងនាមវត្តមកផ្សំគ្នា (តែមិនចាំតួអក្សរណាផ្សំនឹងតួណាថាដូចម្តេច) ផ្សំនាមបានហើយអាចារ្យរាប់មូលនៅត្រង់ទិសណា រាប់មូលជាដំបូងនៅទិសនោះថាមូល, ទុស្សាហ៍, មន្ត្រី, កាឡកណ្ណី, បរិវារ, អាយុ, តេជះ, សិរី។ ឯកាឡកណ្ណី សង់បង្គន់, បរិវារ សង់កុដិកិច្ចការបរិស័ទ្យ, មន្ត្រី សង់ផ្ទះអ្នកតា ហៅថាហៅមឿង (ចាំមិនសព្វទេឲ្យមើលក្បួនត្រែភូមិ) ។ ទ្វារវត្តមាន ៤ គឺទ្វារឯកើត - លិច - ត្បូង - ជើង ។ កំផែងស្តេចដូចគ្នានឹងវត្ត ហៅថាទ្វារត្រែឡែងកែង ។ ជីកស្រះខាងកើតឈៀងឦសានវត្ត ។ ខាងខែត្រតាកែវ ច្រើនជីកស្រះជុំវិញវិហារឬជីកក្រៅបងវត្ត ហៅថាអង្គ ដូចវត្តខ្លះ

ឈ្មោះវត្តអង្គរណ, អង្គសឹង, អង្គរំពាត់, អង្គធ្លក, អង្គតាសោម; វត្តណា គ្មានដីតស្រែដុំវិញ គេមិនហៅអង្គទេ ។ (ក្បួននេះឮថាស់ៗ ថា ជារបស់លោកវង្សាសារពេជ្រមុន ហោរ (ដួង) ជាហោរព្រះករុណាសុវណ្ណកោដ្ឋ, ចាស់ៗដែលសរសេរក្បួននេះស្លាប់អស់) ។ មុនដំបូងបាននាំដី អាចារ្យថែងក្រឡាដីហើយ ត្រូវធ្វើកុដិលោកចៅអធិការមុន ហើយធ្វើពោធុបោសថ រួចសង់សាលាជាបណ្តោះអាសន្នតមក ។

២— និយាយអំពីលើកវិហារ

ពេលស្អាច អាចារ្យឲ្យរៀបពលីការត្រង់ផ្ទះវត្ត មានតន្ទេលខ្នើយ សំពត់សក្រាល មានបង្អែមចំអាប សំពត់ថ្កល់ធ្វេង-ស្តាំ មានប្រអប់ស្លាទឹកសំបួរ មានអម្បោះកូក ពែព្រះភូមិ មានស្លាធម៌ ៨ ទិស ជាក់ដុំវិញទីវិហារ មានកន្ទេលទេវតា ១ ខាងកើត មានប្រដាប់ថ្វាយសី ទឹកអប់ ស្លាបារី កន្ទេល ខ្នើយ ។ អាចារ្យធំសូត្រអញ្ជើញទេវតាព្រះភូមិសព្វគ្រប់ហើយ សែនពែនិយាយថា "ឧតេជះព្រះភូមិព្រះធរណីព្រះស្រែក, ថ្ងៃនេះថ្ងៃជាពេលាល្អ យើងបានរៀបពលីការថ្វាយអស់លោកជាម្ចាស់ទឹកដី ជាម្ចាស់ភូមិហើយ, ដ្បិតយើងនឹងរៀបលើកវិហារថ្វាយសង្ឃ ថ្ងៃស្អែកនេះជាថ្ងៃក្តត្តឫក្សជោគជ័យសួស្តី សូមឲ្យអស់លោកជួយទំនុកបំរុងឲ្យបានសេចក្តីសុខ កុំឲ្យមានពេគាកិតភ័យឡើយ បើមានសេចក្តីអន្តរាយមកពីមុខឲ្យរំលង មកពីក្រោយឲ្យរលាយ" ថាដូច្នេះបីដងហើយចាប់ថ្វាយសម្ភ

ជាក់ប្រមូលក្នុងចានមួយ រួចចាក់ត្រង់ផ្ទឹតវត្តនោះ ហើយលើកប្រដាប់តាំងនោះទៅក្រែងពាលីនៅទីសសរណាដែលត្រូវលើកមុន ។ អាចារ្យក្រែងពាលីហើយចាប់ផ្តាយដាក់ក្នុងពែង រួចហើយសែនរបៀបដូចមុន គ្រាន់តែផ្លាស់ឈ្មោះស្តេចក្រែងពាលី រួចហើយផ្តាប់ពែងទៅទីសសរនោះ រួចយកអំបោះក្រូកនឹងអំបោះខ្សែដៃចងសសរនោះប្រស់ទឹកសម្បុរ ហើយរៀបចំរើនព្រះបរិត្តកង់លានទីវិហារ (និយាយខ្លះ) មានភនទៅតាធំ ១ មានចាំងរាជវតី អណ្តាប់មានព្រម, មានអាចារ្យ ៤ នាក់ចូលកាន់គ្រណមតាំងពីពេលយប់សូត្រចំរើនព្រះបរិត្ត, ព្រឹកឡើង អាចារ្យធំចាត់ឲ្យលើកសសរចងអំបោះក្រូកតាមពេលអាចារ្យបង្គាប់, មានចង្វាស់ ១ ចាំងក្បាលសសរនោះ ។ តាមរបៀបពីដើម, លើកវិហារត្រូវចូលគ្រាបទូលសម្តេចព្រះមហាសង្ឃរាជ សុំឲ្យយាងមកជាអធិបតីលើកវិហារនោះ, ត្រូវចៅអធិការឬអាចារ្យវត្តមានពួរអំបោះ ១ តួច ចំសំពត់ជាតី សំពាប់ថ្វាយលើកសសរ (សម្តេចព្រះមហាសង្ឃរាជផ្តាល់ព្រះហស្តទាញធ្វើជាមង្គល) ។ ដំណាតមក មុខងារនេះ ត្រូវចៅហ្វាយស្រុកឬក៏មេឃុំឬលោកអ្នកមានយសសក្តិ មកជាអធិបតី ។

៣ — និយាយអំពីរបតាហោជាងវិហារ

ក្បាច់ហោជាងវិហារ ខ្ញុំមិនដែលឮថាមានក្បួនច្បាប់ឲ្យធ្វើបែបនេះបែបនោះទេ ។ យល់ឃើញថាក្បាច់ហោជាង គ្រាន់តែជាសញ្ញាឲ្យ

ចំឡែកក្បែក ព្រោះធ្វើលាតមិនល្អមើលប៉ុណ្ណោះ ។ អស់លោក-អ្នក
កសាងវិហារមានគំនិតគិតថា កុងលោកមានអ្វីដែលមានឥទ្ធិពល ក៏យករូប
នោះមកវចនាជាក់នៅហោជាង ឲ្យប្លែកហើយល្អមើលផង ។

ខ្លះធ្វើជំរក្សាលបីដែលឈ្មោះឮពាវ័ណ្ណ, ខ្លះធ្វើរូបព្រះនាយណ៍គង់
លើក្សាលជំរីនោះ, ខ្លះធ្វើរូបគ្រុឌដើរចាប់នាគម្ខាង ១ ដៃកាន់កន្ទុយនាគ
ធ្វើរូបព្រះនាយណ៍ឈរជាន់លើស្មាគ្រុឌ, ខ្លះធ្វើរូបហ៊ូចាប់ព្រះច័ន្ទ ឬព្រះ
អាទិត្យ ធ្វើរូបព្រះនាយណ៍ឈរលើស្មារហូ ។ ក្រៅពីនេះ ជាង់គូរ
ធ្វាក់ក្ងីក្ងើង ក្ងីទេស ក្ងីវល្ល៍នៅហោជាង់អមរូបចាំង់នោះ ដូចជាហោជាង
ប្រាសាទព្រះមហាក្សត្រ ធ្វើព្រះសង្ឃជាសញ្ញា ។ រីឯណាចៅអធិការ
មានសមណសក្តិជារាជគណៈបានសាង់វិហារវត្តនោះ ជាង់ធ្វាក់ក្បាច់
ហោជាង់ធ្វើជាផ្ទិតស្រួច ។ រីឯណាលោកចៅអធិការបានហាត់សិក្សា
គម្ពីរបាលី ជាង់ធ្វើក្បាច់ហោជាង់ជាគម្ពីរពានទ្រជាសញ្ញា ។ (មាន)

ឥលក្ខាង់ធំនៀមឧម្ខាច់
ទំនៀមល្អកាន់កើតសួស្តី
ឧម្ខាច់ពិសីកាន់កើតសុខា
ទំនៀមខុសកាន់ថោកអាត្មា
ឧម្ខាច់លាមកកាន់កើតទុក្ខភ័យ ។

យូរ-អ៊ុន

លោក រ៉ាយ-ប៊ុក ក្រមការនៅពុទ្ធសាសនបណ្ឌិត្យ

ចៃរៀចរៀង

(តមក)

ព្រលឹងរបស់បុគ្គលនោះចាកចេញពីរូបកាយ ដើម្បីជាកិត្តិយសដល់ការ
ទទួលទុក្ខលំបាក នឹង ដើម្បីបាច្ចាទៅកាន់ស្ថានសុខ ចំពោះបុគ្គលណា
ដែលបានវង់ទុក្ខតាលតែទៅតាអៀនភ្នំស តាមសេចក្តីដែលមានសំដែង
កងគម្ពីរជាហេតុធ្វើមនុស្សឲ្យមានសមភាពនឹងទៅតា ធ្វើឲ្យមានពលភាព
ឈ្នះនូវសេចក្តីទុក្ខកង់ស្ថាននរកបាន ។

ព្រះសិទ្ធត្ថទ្រង់តមើលឃើញបុគ្គលម្នាក់ដែលជាគ្រូអាចារ្យ នៃ
ពួកដែលវង់ទុក្ខលំបាកនោះ ហើយមានព្រះឧង្ការថា "ឧអ្នក! ខ្លួន
អ្នកបានវង់ទុក្ខលំបាកជាខ្លាំង តាំងពីយូរខែណាស់មកហើយ, ខ្ញុំនៅនឹង
កុំនេះ ខ្ញុំទំស្លះស្លែងរកធម៌ពិតធម៌មែន ហើយខ្ញុំមកឃើញអ្នកនឹងបុគ្គល
ឯទៀតធ្វើបាបខ្លួនឯង គួរឲ្យសង្វេគពន់ពេក, ក្រែងអ្នកយល់ឃើញថា
ទុក្ខកងជីវលោកមានស្រាប់ហើយ ហេតុម្តេចក៏អ្នកធ្វើទុក្ខនោះឲ្យកាន
តែខ្លាំងឡើងទៀត?" ។

គ្រូអាចារ្យនោះ ក្រាបទូលព្រះសិទ្ធត្ថថា "មានចារឹកទុក្ខកង់គម្ពីរ
ថា: បើបុគ្គលណាបានធ្វើបាបខ្លួនឯង បុគ្គលនោះរមែងទទួលនូវសេចក្តី

ឈឺចាប់ជាច្រើនយ៉ាង តាល់តែនៅត្រឹមខ្យល់អស្សាសៈបស្សាសៈប៉ុណ្ណោះ ហើយមានចិត្តសង្ឃឹមថា : នឹងទទួលមរណភាពដោយសោមនស្សបែបនេះ; ដោយអំណាចទទួលនូវទុក្ខលំបាកជាខ្លាំង បុគ្គលនោះ ក៏អាចលាងបាបអកុសលចេញពីកងសន្តាន ហើយព្រលឹងដែលបរិសុទ្ធស្អាតចាកចេញពីសេចក្តីទុក្ខកងលោកនេះទៅកាន់ស្ថានដ៏ឧត្តម ដែលប្រកបដោយសេចក្តីសុខជាអស្ចារ្យ” ។

ព្រះសិទ្ធត្ថទ្រង់តបវិញថា : “ពពកដែលអណ្តែតត្រសែតលើនកាល័យ ដែលត្រជាងដូចជាសំពត់កោសេយ្យពស្ត្រ មានពណ៌ដូចមាសគេរុំជុំវិញរតនបល្ល័ង្កនៃសម្តេចព្រះឥន្ទ្រាធិរាជ, ពពកទាំងនោះចាកចេញហុយពីសមុទ្រទៅលើអាកាស ហើយត្រូវខ្យល់ផ្លាក់មកជាភ្លៀង, ទឹកភ្លៀងនោះហូរធ្លាក់ទៅតាមផ្លូវ ថ្នល់ ស្ទឹង រួចហូរចុះទៅដល់ទន្លេហើយហូរធ្លាក់ចាក់ទៅកាន់សមុទ្រជាទីដែលទឹកនោះធ្លាប់តាំងនៅពីមុនវិញ; អ្នកដឹងឬទេ? សភាពលោកមានការប្រែប្រួលជាធម្មតា; ក្រែងអ្នកមកទទួលទុក្ខលំបាកបែបនេះដើម្បីនឹងស្វែងរកសុខឬ? ដោយហេតុថា : របស់អ្វីដែលទៅកាន់ទីខ្ពស់តែងធ្លាក់មកទីទាបវិញ, រីឯអ្វីដែលគេទិញបានគេត្រូវចែកចាយទៅវិញ; ចុះបើអ្នកយកលោហិតទៅទិញមហាមេឃទៅផ្សារ គឺទុក្ខលំបាកកងស្ថាននរកហើយ តើអ្នកនឹងចៀសពីនរកម្តេចបាន, អ្នកនឹងត្រឡប់សោយទុក្ខវិញមិនខាន” ។

អាចារ្យនោះតបថា "ទុក្ខនោះតែងតែអន្ទោលទៅមក តែងកើតឡើងជាថ្មី មិនចេះផុតមិនចេះហើយ យើងមិនអាចទុកចិត្តនូវតែកងលោកបានទេ ដោយហេតុថាកងវេលាថ្ងៃនឹងយប់ មានសេចក្តីសូម្បី រួចសេចក្តីកង្វល់មកដល់ យើងមានចិត្តស្អប់ខ្ពើមសាច់អាក្រក់ដែលពាំងកាមិនឲ្យអាត្មាន ចាកចេញពីរូបទៅបាន; ព្រោះហេតុដូច្នេះ ដើម្បីនឹងស្វែងរកសេចក្តីសុខ ចំពោះអាត្មានេះ យើងត្រូវធ្វើបាបខ្លួនយើង ចំពោះមុខពួកទេវតាទាំងឡាយ ដើម្បីនឹងប្រយកសេចក្តីសុខទីបំផុតឯនោះ" ។

ព្រះសិទ្ធត្ថតបទៅវិញថា "តាមស្មានថា: សេចក្តីសប្បាយមានកំណត់មួយលានឆ្នាំ, សេចក្តីសប្បាយនោះដល់យូរទៅគង់ស្រពោនរុះរោយមិនខាន, បើមិនដូច្នោះទេ តើមានសត្វណានៅខាងក្រោម ខាងលើឬជិតទីនេះ ឬក៏ផ្សែងពីទីនេះមិនចេះបែបែលដែរ? សូមអ្នកប្រាប់ខ្ញុំ; តើទេវតារបស់អ្នកមានជីវិតរស់នៅស្ថិតស្ថេរជានិច្ចឬ? ។

អាចារ្យនោះក៏តបទៅព្រះអង្គវិញថា "បើតាមសេចក្តីយល់របស់ពួកយោគី មានតែព្រះព្រហ្មមួយដែលលោកនៅជានិច្ច ចំណែកខាងទេវតាគ្រាន់តែរស់នៅមួយពេល" ។

ព្រះសិទ្ធត្ថមហាបុរសមានព្រះបន្ទូលថា "ចុះអ្នកចង់តាំងខ្លួនជាពួកសន្តឬ? ខ្ញុំស្មានថា ចិត្តអ្នកប្រាថ្នាសន្តិភាពនឹងសេចក្តីក្សាន្ត, បើដូច្នេះត្រូវអ្នកបោះបង់ចោលការកំណាចសាហាវ ដែលនាំឲ្យអ្នកប្រកបដោយ

សោកបរិទេវទុក្ខ ដែលនាំអ្នកទៅកាន់បំណងមិនប្រាកដហើយមិនស្ថិតស្ថេរនេះចេញ; គួរបើដែរ ដោយហេតុតែសេចក្តីស្នេហាចំពោះអាត្មនរបស់អ្នកៗ ទៅជាស្អប់សាច់ អ្នកធ្វើទុក្ខលំបាកដល់វា ទាល់តែរូបកាយនោះស្គមច្រដក់មិនអាចរក្សាទូវចិត្តៗ នោះទំរាំតែជ្រកពឹងពួនវង្វេងផ្លូវមុនពេលយប់ ដូចជាអស្សតរស្ងួតតែគេប្រើហួសកំឡាំង; ឥសី! ចុះអ្នកគ្រែងចង់ធ្វើឲ្យវិនាសអតីតជាតិដែលប្រកបដោយទុក្ខ តើអ្នកបានសំឡឹងរកផ្លូវវិសេសតាមចន្លោះបង្អួចដែលមានរស្មីក្តីចាំងចូលមក អាចឲ្យមើលទៅខាងក្រៅបាន ដើម្បីនឹងឲ្យដឹងថាជាពេលព្រឹកព្រហាមហើយឬ? តើផ្លូវវិសេសថ្ងៃថ្ងូរនោះនៅឯណា?" ។

ក្នុងពេលនោះ ពួកយោគីទាំងអស់ស្រែកថា "យើងបានជ្រើសរើសយកផ្លូវនេះហើយ, យើងនឹងធ្វើដំណើរទៅតាមផ្លូវនេះឲ្យផុតដើមចុង; ឧព្រះរាជបុត្រ! បើទុកណាជាតាមផ្លូវនេះមានថ្នូរចេញសុទ្ធតែភ្លើងក៏ដោយ យើងគង់មិនចាកចេញពីផ្លូវនេះទេ; យើងសង្ឃឹមតែនឹងទៅកាន់សេចក្តីស្ងប់ប៉ុណ្ណោះ, យើងសូមសួរព្រះអង្គ: តើព្រះអង្គជ្រាបនូវផ្លូវដែលវិសេសជាងនេះទៀតឬ? បើមិនជ្រាបទេ, សូមស្តេចយាងចេញពីទីនេះចុះ" ។

ព្រះសិទ្ធត្ថបានធ្វើដំណើរតាមផ្លូវតទៅទៀត មានព្រះទ័យព្រួយជាខ្លាំង ដោយព្រះអង្គឈ្វេងយល់ថា "មនុស្សទាំងអស់ខ្លាចសេចក្តីស្លាប់, ហើយមានសេចក្តីតក់ស្លុត ភ័យ ខ្លាច មានបំណងចង់ឲ្យជីវិតរស់នៅ

មានចិត្តស្អប់ដំរីតិន្ទុយនោះ ធ្វើទុក្ខលំបាកដំរីតជាខ្លាំង ប្រហែលជាចង់ឲ្យទេវតាសោមនស្សសប្បាយ, ប៉ុន្តែទេវតាមិនព្រមឲ្យសេចក្តីសុខមកមនុស្សទាំងនោះទេ, ឬប្រហែលចង់ធ្វើខ្លួនឲ្យធ្លាក់ទៅកាន់ស្ថាននរកវិចក៏បង្ក្ត ចំពោះខ្លួនឲ្យទៅសោយទុក្ខក្នុងស្ថាននរកឯទៀត, ឬក៏ប្រហែលដោយមានពេលវេលាធ្វើឆ្គត មានសេចក្តីសង្ឃឹមថា: អាត្មន ចេញពីរូបកាយដែលមានរបួសទុក្ខលំបាកងាយជាជាងរូបកាយដែលស្អុតល្អយ៉ាងនេះទៅដឹង" ។ ព្រះសិទ្ធត្ថក៏ពោលថា "នុ បុដ្ឋក្នុងច្បារទុព្យានអើយ! អ្នកបែរមុខទៅកាន់ព្រះអាទិត្យមានសេចក្តីរីករាយសប្បាយនឹងពន្លឺរស្មី បានបញ្ចេញគន្ធពិជោរក្លិនក្រអូបឈ្ងុយឈ្ងប់ ហើយមានរូបឆោមលោមពណ៌ ដូចសុវណ្ណពណ៌សដូចប្រាក់ក្រហមឆ្អៅ ដែលអ្នកបានមកពីអានុភាពនៃពន្លឺរស្មីនោះ; មិនមានបុប្ផាណាមួយអាចលះបង់ដំរីត រស់នៅបរិសុទ្ធស្អាត, មិនមានបុប្ផាណាមួយអាចលះបង់នូវសេចក្តីស្អាតស្រស់បំព្រងរបស់ខ្លួនចេញឡើយ, នុដើមគ្នាតអើយ! អ្នកមានដើមជង្គុះនៅទីនេះ មានបំណងចង់ទំលុះមេឃហើយនឹងក្រែបធ្មឹកនូវព្រះពាយ ដែលបក់មកពីកំពូហិមាល័យនឹងមហាសាគរ មានពណ៌ខៀវផ្ទៃមេឃ តើអ្នកបានដឹងនូវការស្វាត់កំបាំងអ្វីដែលធ្វើឲ្យអ្នកជុះរស់នៅជាសុខសប្បាយ តាំងពីពន្លកចេញពីគ្រាប់ដំបូងរហូតដល់មកពេលដែលមានផ្ទៃហើយ កាលណាឈ្លប់បក់ត្រូវស្មឹក ក៏មានសត្វសូរដូចតូរ្យតន្ត្រីអ្វីពីពេះម្ល៉ះ? (មាឧត)

លោក ម៉ុញ - តាំគ្រី រៀបរៀង

(តមក)

គ្រិស្តសាសនា

២ – លទ្ធិប្រែចេស្តជ័ត

សព្វនេះបានសេចក្តីថា "លទ្ធិទទឹងទាស់" ឬថា "លទ្ធិកែទម្រង់" (Réforme) *ជាឈ្មោះនិកាយដែលបែកចេញមកអំពីនិកាយកាតូលិក ក្នុងរវាង ព. ស. ២០៦០, គ. ស. ១៥១៧ ដោយសារពាហិរបព្វជិតជាតិអល្លឺមង់តម្លៃយរូបឈ្មោះលូថេរ[1]* (Luther) *ជាអាចារ្យសាលាវិទ្យាល័យវិត្តិរតេម្បឺរ ប្រទេសអល្លឺម៉ាញ ។*

ហេតុដែលនាំឲ្យបែកចេញជានិកាយថ្មីនេះឡើង មកអំពីទោសនៃការប្រព្រឹត្តិជ្រៀតជ្រែកខុសចាកគម្ពីរបច្ចុ (Bible) *នៃគណៈសង្ឃអុលដ្ឋីមានសម្តេចព្រះសង្ឃរាជក្រែងរោមជាដើម ។ តាមសេចក្តីដំណាលថា: សង្ឃរាជនោះមានការចិញ្ចឹមជីវិតដូចគ្រហស្ថ ហើយខ្វនគាប់ចិត្តយ៉ាងណា កំប្រជុំគណៈសង្ឃមកបញ្ញត្តសិក្ខាបទយ៉ាងនោះ ទាំងបញ្ញត្តិថ្មីដែលសង្ឃរាជឬគណៈសង្ឃបញ្ញត្តទាំងអម្បាលម៉ាន, គ្រិស្តបរិស័ទ្ធគ្មាប់ចុះចិត្ត*

---

១ មាត្តិន លូថេរ (Martin-Luther) : កើតនៅស្រុកអីស្លេបេន គ. ស. ១៤៨៣ បែកចាកពួកភេម៉ុង - កាតូលិក (នៅវេលាប្រកាសចុះទោស) គ. ស. ៥១៧ ក្នុងជំនាន់សង្ឃរាជឡេអុង ទី ១០ ក្នុងរាជ្យព្រះចៅទោសារឡើកាំង ដែលទ្រង់ឲ្យកាត់ទោស បញ្ជាជនំយកម្នុបណ្តោញចាកសាសន៍នៅសាណាវិនិច្ឆ័យ ក្រុងវ័រមែ គ. ស. ១៥២១ ។

ដឿសិច់ថាជាបញ្ញត្តិរបស់ព្រះម្ចាស់សួគ៌ គឺព្រះជាម្ចាស់សួគ៌ឲ្យបញ្ញត្តម្ល៉ោះហើយជាទុកាសឲ្យសង្ឃភជឬគណៈសង្ឃបញ្ញត្តតាមសេចក្តីយល់ឃើញថាស្រួល ។

លទ្ធិកាតូលិក យើងធ្លាប់ដឹងមកហើយថា មានពិធីលាងបាប ។ ឯលទ្ធិនេះ បើបុគ្គលមានទោសល្មម ក៏អាចរួចទោសបានដោយពិធីសូត្រមន្តអង្វរកសូមឲមានទោសនឹងព្រះជាម្ចាស់; បើបុគ្គលមានទោសធ្ងន់ត្រូវតែនៅបរិវាសកម្ម ឬដើរធុតង្គកម្មល ទៅនមស្សការកន្លែងព្រះហ្ស៊ីហ្ស៊ូប្រសូត ជាកិច្ចខណ្ឌកម្ម ទើបរួចទោសបាន ។

ថ្ងៃមួយជាហេតុនាំឲ្យផ្ទុះចេញជាលទ្ធិនេះឡើង, សម្តេចព្រះសង្ឃភជក្រែងភេមចង់សាងវិហារវត្ត (Saint-Pierre) ឲ្យល្អឆើតជាប់វត្តទាំងពួងឲ្យសមស័ក្តិរបស់ខ្លួន តែនឹងរកបច្ច័យសម្រាប់កសាងតាមបំណងរបស់ខ្លួនដូច្នោះពុំបាន ទើបកែប្រែបញ្ញត្តិដើមថា: បុគ្គលដែលមានទោសធ្ងន់ ។ យ៉ាងណា ក៏អាចរួចទោសបានដោយការចំណាយប្រាក់កសាងវិហារនេះ (មិនបាច់នៅបរិវាសកម្ម ឬដើរធុតង្គកម្មលដូចមុនទេ) ។

រឿងនេះឯង ជាសេចក្តីអបាយសម្រាប់សាសនា នាំឲ្យលោកអាចារ្យលូថេរឆ្កេចក្អែកមិនជិតស្មៀមមាត់មិនកើត ទើបប្រជុំពួកអាចារ្យមកពិគ្រោះគ្នាអំពីរឿងនេះជាច្រើនលើក ហើយមូលមតិគ្នាសំរេចសេចក្តីថាមិនត្រូវប្រតិបត្តិតាមបញ្ញត្តិរបស់សម្តេចព្រះសង្ឃភជឡើយ ។ ដំណឹង

នេះមិនស្ងាត់ជាត់ ក៏ព្រួយទ្រង់ដល់សម្តេចព្រះសង្ឃរាជក្រុងរេមៗហៅលោក អាចារ្យលូថេរមកជាស់តឿនឲ្យលះបង់ទំដុំផ្ទុយទាស់នោះចោលចេញ តែ អាចារ្យលូថេរមិនព្រមលះសោះ សម្តេចព្រះសង្ឃរាជទើបធ្វើបញ្ជាជនីយកម្ម បណ្តេញលូថេរចេញ ។ តាំងអំពីកាលនោះមក លូថេរប្រកាសសេចក្តី យល់របស់ខ្លួនដែលផ្ទុយទាស់នឹងសង្ឃរាជ ៩៩ ។ ហើយចាប់ប្រែគម្ពីរបិដក ភាសាឡាតាំងមកជាភាសាអ្នកស្រុកសាម័ញ្ញ ដើម្បីនឹងសំដែងឲ្យឃើញ ថាសេចក្តីពិតសម្រាប់គ្រិស្តសាសនានោះតើមណា រួចហើយចោះពុម្ព ផ្សាយសាធារណ៍ទូទៅ ។ ជនដែលមានសៀវភៅប្រែនេះក្នុងដៃ សឹងយល់ត្រូវស្របតាមលូថេរទាំងអស់ គឺយល់ឃើញថាលទ្ធិសម្តេចព្រះ សង្ឃរាជជាលទ្ធិបុរាណនោះ ភ្ញាក់ភ្ញាត់ពុំសូចាកគម្ពីរបិដកច្រើនណាស់ ម្ល៉ោះ ហើយលទ្ធិថ្មីនេះចេះតែផ្សាយឥទ្ធិពលកាន់តែធំទូលាយទៀត រហូតដល់ ផុតអំណាចសង្ឃរាជក្រុងរេមនឹងស្តេចផែនដីការពារលែងបាន ។

ឯលទ្ធិថ្មីដែលលូថេរប្រកាសទៀតនោះដូចខ្លះ: លូថេរប្រកាន់ពុក ខ្លួរគោលធំៗ សម្រាប់គ្រិស្តសាសនាទាំង៣គឺ ត្រីឯកានុភាព (Trinité) ១, បាប គឺកំហុសចំពោះព្រះ (Chute) ១, ទង្វើការលាងបាប (Rédemption) ១ ហើយនឹងធម្មជាតវត្ថុ ២ យ៉ាងរបស់ព្រះគ្រិស្ត (ស្រាទឹងនំបុ័ង) ។

លូថេរបដិសេធហានសម្រាប់ប្រព្រឹត្តិតបៈញ៉ាំងខ្លួនឲ្យបរិសុទ្ធ, ការ ពឹងពាក់ព្រះអរហន្ត, ការលាងបាបចំពោះបុគ្គលម្នាក់ៗ ឯង; បដិសេធពិធី

បុណ្យផ្សេងៗ ទុកតែពិធីបញ្ចូលសាសន៍ នឹងពិធីមហាស្ថិទ្ធិ; មិនឲ្យមានអាចមសម្រាប់ពួកនាងដី, ពួកបព្វជិតត្រូវមានប្រពន្ធបាន, ប្រកាន់ថា វត្ថុដែលល្អដែលសំខាន់បំផុតរបស់ព្រះហ្ស៊ីហ្ស៊ូគ្រិស្ត នៅក្នុងនំបុ័ងនឹងស្រាទំពាំងជូរ ។ មានសេចក្តីយល់ ២ ប្រការទៀតដែលជាគោលធំ គឺយល់ថាសេចក្តីបរិសុទ្ធិអាស្រ័យដំនឿនឹងព្រហ្មលិខិត ។

លូថេរនឹងពួកប្រូតេស្តង់យល់ថា: ដំនឿសឹងពិសេសលើសកិច្ចការ, បុគ្គលដែលជឿវត្ថុដែលគួរជឿនឹងរួចពាក្យទុក្ខបាន ។ ព្រហ្មលិខិត: ព្រះជាម្ចាស់សួគ៌ទ្រង់ជ្រើសរើសរកបុគ្គលតាមដែលទ្រង់ប្រាថ្នា មិនមែនសំរេចតាមចំណង់របស់មនុស្សយើងទេ ។

សាសនាអ៊ិស្លាម

សាសនាអ៊ិស្លាម ជាលទ្ធិមួយដែលកើតឡើងក្នុងប្រទេសអារ៉ាប់ ដោយស្នាដៃថ្លៃគំនិតរបស់គ្រូម្នាក់ឈ្មោះ "មោហម៉ែទ" ។ លទ្ធិនេះដែលបានឈ្មោះដូច្នេះ ដោយសំគាល់សេចក្តីថា "ដំនឿស្រោចស្រង់សត្វ" ។

ប្រវត្តិមោហម៉ែទ (សង្ខេប)

មោហម៉ែទ ជាសាស្តាចារ្យរបស់ជនជាតិអារ៉ាប់, កើតនៅស្រុកមេក: (Mecque) រវាង ៣. ស. ១១៧, គ. ស. ៥៧០, ជាពូជពង្សវង្សត្រកូលរបស់ហាស្មែម (Haschem) ដែលជាវង្សមានឈ្មោះល្បីល្បាញខ្ពស់ក្នុងពួកកូរេច (Koréichite), កំព្រាតាំងអំពីតូច ដីតាយក

មកចិញ្ចឹម, តមកខាងក្រោយអត់អំពីដីតាទៅ ចានទៅនៅអាស្រែយ៉ែនឆ័ត្តកមាឈ្មោះអាប៊ូតាលេប (Abou-Talep) មានការចិញ្ចឹមជីវិតដោយពាណិជ្ជកម្ម, មានលក្ខណៈជាបុគ្គលមានសេចក្តីក្លាហានអង់អាច, មានចិត្តសាធារណៈ ចិត្តទូលាយ, ចានានាកដដដៈជាស្រីមេម៉ាយមានទ្រព្យសម្បត្តិស្តុកស្តម្ភជាករិយា ។ អាស្រែយហេតុនេះ ទើបបណ្តាលឲ្យមោហ-ម៉ែមានឥទ្ធិពល មានអានុភាពរីកធំទូលាយឡើងក្នុងជាតិរបស់ខ្លួន ។

ដល់មកអាយុ ៤០ ឆ្នាំ មោហម៉ែមិនចាន់សំរេចកិច្ចការពិសេសអ្វីមួយដែលអាចឲ្យគេចាយចានថាជាមហាបុរសនៅឡើយ ។ សម័យមួយនោះ គាត់ដកថយទៅរកកន្លែងស្ងប់ស្ងាត់ ដើម្បីស្វែងស្វាធ៌ចំរើនមេត្តាភាវនា ។ រាត្រីមួយ គាត់នៅសម្ងំក្នុងរូងភ្នំហិរៈ, តាមពន្យារតារអារ៉ាប៊ីនិយាយថា: មានទេពតាចុះមកហើយត្រជាងក្បួនបង្ហាញប្រាប់ថា "ឯងមើលទៅ" ។ មោហម៉ែប្រែកែកថា "ខ្ញុំមិនចេះអានទេ" ។ ទេពតានោះក៏ចាប់សក់លើកក្បាលទង្គិចផ្ទប់ទៅលើផែនដីអស់វារៈបីដង ហើយប្រាប់ម្តងទៀតថា "អានក្បួននេះទៅ សុទ្ធតែជាព្រះនាមព្រះជាម្ចាស់ដែលចានបង្កើតវត្តប្រាប់យ៉ាង" ។ ម្តងនេះ មោហម៉ែអានចាន ហើយឮសូរសំឡេងប្រាប់មកទៀតថា "អ្នកឯងជាសាវកបស់ព្រះជាម្ចាស់ហើយ" ។

តាំងអំពីកាលនោះមក មោហម៉ែចានឡើងនាមថា "នប៊ី" សំគាល់ខ្លួនថា "សព្វញ្ញូ" ចាប់ផ្តើមប្រកាសសាសនាថ្មី ដែលខ្លួនឲ្យឈ្មោះថា

អ៊ិស្លាម "ជំនឿស្រោចស្រង់សត្វ" ។ បុគ្គលដែលមានជំនឿពិត។ ក្នុង សាសនានេះបាននាមថា មុស៊ុលម៉ន (អ៊ិស្លាមសាសនិកជន ឬ អ៊ិស្លាមិក-ជន) ។ ពួកនេះដំបូងមានចំនួនតិចទេ តអំពីពេលនោះរាង ៣ ឆ្នាំ មោ-ហាម័ទទើបតែនឹងញ៉ាំងកិរិយារបស់ខ្លួននឹងអាលីដែលជាបងប្អូនជីដូនមួយ ហើយនឹងខ្ញុំកំដរបស់ខ្លួន ព្រមទាំងអ្នកស្រុកមេក:ខ្លះឲ្យចូលសាស្នាថ្មី បាន ។

ដល់មករាង ៣. ស. ១១៩៧, គ. ស. ៦១៤ មោហាម័ទបាន ប្រជុំគណ:ចាមោក្ខបុគ្គល ដែលជាមេពួកមេក្រុមរបស់ខ្លួនហើយសួរថា "បណ្តាអ្នកទាំងអស់គ្នា អ្នកណាអាចធ្វើជាបងប្អូនរបស់ខ្ញុំ — ជាមេទ័ព របស់ខ្ញុំ — ជាសេនាបតីរបស់ខ្ញុំ? ។

អាលីស្ទុះក្រោកក្មេងឡើងធ្វើយតបថា "ខ្ញុំអាចទទួលក៏បាន ទោះបើមាននរណាមួយទាស់ទទឹងនឹងលោក, ខ្ញុំនឹងចាប់កាច់ធ្មេញ នឹងឆ្អៀល ក្អែក នឹងរ:ពោះ នឹងបំបាក់ជើងចោល" ។

លទ្ធិថ្មីនេះ នាំឲ្យផ្ទុយទាស់ដល់អ្នកទាំងពួងជាខ្លាំង បណ្តាលឲ្យ មានគ្រោះថ្នាក់នឹងសេចក្តីទោមនស្សដល់ពួកកូរេច្ចជាច្រើន ។ ហេតុ នោះ ទើបនាំឲ្យមោហាម័ទមានទុក្ខទោសត្រូវដល់សេចក្តីស្លាប់ ក៏កៀស ខ្លួនរត់ចេញចាកស្រុកមេក: ទៅនៅស្រុកអ៊ីអាត្រែប ដែលខ្លួនឲ្យឈ្មោះ ថា ម៉េដីន (Médine) សំគាល់សេចក្តីថា ក្រុងរបស់មោហាម័ទ ។

ការរត់ទៅនេះ ជាកិច្ចសំខាន់ក្នុងពន្យាវគារអ៊ីស្លាមិកនិកាយ តាំងជាកាលចាប់រាប់មោហម៉ាត់សាករាជតាំងពីនោះមកផង (១៦ ស៊ីយេត៦២២) ។

មោហម៉ាតនៅក្នុងទីនោះ មិនយូរប៉ុន្មានក៏តាំងប្រជុំអស់មេក្រុមរបស់ខ្លួនបង្កើរជាកូនទ័ពលើកចេញមកវាយពួកកូរេដ្ឋ ត្រាតែមានជ័យជំនះ ហើយបានជាសាស្តាចារ្យនៅស្រុកមេក:, តមកយកបានកន្លែងវិហារ "កាអាបា" ដែលជាទីបូជនីយស្ថានសម្រាប់គោរពបូជានៃពួកអារ៉ាប់ពីដើម ហើយតាំងបានបំផ្លាញរូបសម្រាប់គោរពក្នុងទីនោះអស់ ៣០០ រូប ហើយនិយាយថា "សេចក្តីពិតមកដល់ហើយ សេចក្តីកុហកចូរសាបសូន្យទៅ" ។

កន្លងពីរឆ្នាំមុនទីបំផុតអាយុរបស់មោហម៉ាត ។ បានផ្សាយសាសនាបញ្ចុះបញ្ចូលពួកអារ៉ាប់បានអស់ ។ ក្នុង ៣. ស. ១១៧៥, គ.ស. ៦៣២ មានពួកអិស្លាមិកបរិសទ្យរាប់សែននាំគ្នាទៅគោរពបូជានៅក្រុងមេក: ។ ក្នុងឆ្នាំនេះ សាស្តាចារ្យមោហម៉ាតដឹងខ្លួនថាជិតដល់មរណកាលហើយទើបប្រកាសថា "បើខ្ញុំបានវាយបង់ប្អូនខ្ញុំណាមួយ ឲ្យគេវាយខ្ញុំវិញចុះ, បើខ្ញុំនៅជំពាក់បំណុលញាតិណាមួយ នេះនែជ្រាក់សម្រាប់សង" ។ ខណៈនោះមានដំណាលថា: មានបុរសម្នាក់មកទារជ្រាក់ចំនួន ២ — ៣ រៀល ។ មោហម៉ាតសង្ខាម ដោយសេចក្តីត្រេកអរថានឹងបានរួចបំណុលក្នុងលោកនេះនឹងលោកខាងមុខ ។

គម្ពីរកោវ៉ាន (គួអាន)

សាសនាមោហម៉ែត មានទៅក្នុងផ្លូវនៃគម្ពីរកោវ៉ានជាក្បួនសាសនាដែលអ៊ីស្លាមិកនិកាយនិយមរាប់អានថាជាគម្ពីរដើម ដូចជាគម្ពីរបិដកក្នុងគ្រិស្តសាសនា ឬគម្ពីរព្រះត្រៃបិដកបែកខាងពុទ្ធសាសនារបស់យើង ។

គម្ពីរកោវ៉ាននេះមានលទ្ធិសាសនា, បញ្ញត្តិ, ឧវាទ ដែលមោហម៉ែតបានសំដែងទុកដោយកិច្ចការផ្សេង ។ ។ គេបានចារឹកទុកដោយគោរពកន្លងស្មឹកតែ: តមកមានមោហម៉ែតសាវ័កម្នាក់ឈ្មោះកាលីហ្វ អាប៊ូ-បាការបានស្រង់ប្រមូលរួបរួមចារឹកចងទុកជាគម្ពីរកោវ៉ានឡើង ។

លទ្ធិមោហម៉ែត

ក្នុងគម្ពីរនេះ មានសេចក្តីពន្យល់ថា ព្រះមានតែមួយគឺ ព្រះអាហ្វា, មោហម៉ែតគ្រាន់តែជាទេវទូត (របស់ព្រះអាហ្វា), ព្រលឹង (វិញ្ញាណ) មិនចេះស្លាប់, ជាតិមុខនឹងត្រូវទទួលយកផលនៃសេចក្តីល្អនឹងទោសនៃសេចក្តីអាក្រក់ពុំខាន ។

គោលដែលសំខាន់បំផុតក្នុងសាសនានេះមាន៣យ៉ាងគឺ: ការសូត្រមន្ត ១ ការអត់អាហារ ១ នឹងការឲ្យទាន ១ ។ អ៊ិស្លាមិកជនយល់ថា ការសូត្រមន្ត ជាកិច្ចឲ្យមានដំណើរទៅរកព្រះជាម្ចាស់បានពាក់កណ្តាលផ្លូវ, ការអត់អាហារ ឈ្មោះថាធ្វើដំណើរឲ្យបានដល់ទៅមាត់ទ្វារពាក់សួគ៌, ការបែកទាន ឈ្មោះថាបានញាំងខ្លួនឲ្យចូលទៅដល់កន្លងពាក់សួគ៌ ។ (មានត)

សប្បុរិសធម្មកថា

ព្រះទេពសត្ថា សូរ-ហាយ ក្រុមជំនុំព្រះត្រៃបិដកវៀបវៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ពេលនេះនឹងសំដែងអំពីសប្បុរស ត្រមាំងធម៌របស់សប្បុរសដោយសេចក្តីសង្ខេបតាមក្រសែនៃព្រះពុទ្ធដីកានឹងអដ្ឋកថា ដើម្បីជាសណ្តាប់នៃពុទ្ធបរិស័ទទាំងឡាយ ដូចសេចក្តីដែលត្រូវសំដែងតទៅនេះ ។

ពាក្យថា "អ្នកសប្បុរស" គឺបុគ្គលដែលប្រកបដោយធម៌សុចរិតគ្រប់ត្រែទ្វារគឺ កាយ វាចា ចិត្ត, ជាអ្នកឃើញប្រយោជន៍ដ៏ធំទូលាយជាសាធារណៈដល់អ្នកដទៃ, មិនឃើញត្រឹមតែប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះយ៉ាងនេះជាដើម ហៅថា "អ្នកសប្បុរសយ៉ាងក្រិដ្ឋ" ។ មួយទៀត មនុស្សអ្នកមានចិត្តល្អ មានការប្រព្រឹត្តិរៀបរយត្រូវល្អចំពោះលោកអ្នកមានគុណ, ចំពោះសង្ឃគ្រហស្ថបាសខ្ពស់, ជាអ្នកមានសីលធម៌គួរជាទីជ្រះថ្លាដល់ភ្នែកអ្នកផង ក៏ហៅថា "អ្នកសប្បុរស" ។

ពាក្យថា "សប្បុរស" នេះមកអំពីបាលីថា "**សន្តំ**" មានអត្ថ្យប្រែបាន ៦ យ៉ាង គឺ:

១ — សន្តំ ប្រែថា "មាន, មានគ្រប់គ្រាន់" ដូចបាលីថា ទ្វេ មេ ភិក្ខវេ បុគ្គលា **សន្តោ** សំវិជ្ជមានា ឧលូកា

លោកស្មើ "ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ មានកង់លោក គេរកបានដោយក្រ" ។

២ – លង្ឃ: ប្រែថា "មនុស្សល្អ" ដូចបាលីថា **សន្តោ ហវេ** សព្ភិ បវេទយន្តិ "ពួកមនុស្សល្អ រមែងនិយាយ នឹងមនុស្សល្អ" ។

៣ – លង្ឃ: ប្រែថា "ហត់ទ្បើយ" ដូចបាលីថា **ទីឃំ** សន្តស្ស យោគនំ "យោជន៍វែង របស់បុគ្គលអ្នកហត់ទ្បើយ" ។

៤ – លង្ឃ: ប្រែថា "រលត់" ដូចបាលីថា **អយញ្ច** វិតក្កោ អយញ្ច វិចារោ **សន្តា** ហោន្តិ "វិតក្កនេះក្តី វិចារនេះក្តី ជាធម៌ រលត់ហើយ" ។

៥ – លង្ឃ: ប្រែថា "ល្អិតល្អន់" ដូចបាលីថា **អធិកតោ** ខោ ម្យាយំ ធម្មោ **សន្តោ** បណីតោ "ធម៌នេះ ជាធម៌ល្អិតល្អន់ ប្រសើរ ដែលតថាគតត្រាស់ដឹងហើយ" ។

៦ – លង្ឃ: ប្រែថា "សូប៉ាម្ងាប់" ឬ "រៀបរយ" ដូចបាលីថា **ឧបសន្តស្ស** សតោ **សតិមតោ** "បុគ្គលអ្នកសូប៉ាម្ងាប់ (ឬ រៀបរយ) មានស្មារតីគ្រប់កាលទាំងពួង" ។

ពាក្យថា "អ្នកសប្បុរស" ក្នុងទីនេះ សំដៅយកមនុស្សល្អ ឬ មនុស្សចិត្តជា ដែលមានសីលធម៌ មានសណ្តាប់ធ្នាប់ដោយកាយ វាចាចិត្ត

ជាសុចរិត អាចឲ្យអ្នកផងគួរសេពគប់ខ្លួលស្គាល់បាន ។ បុគ្គលរួបរួម
ចាក់ដងនឹងគ្នាដោយការណ៍យកិច្ចផ្សេង ។ តាំងពីពីរនាក់ឡើងទៅ ទោះបី
ជាតិជាមួយគ្នាក្តី ជាតិផ្សេងពីគ្នាក្តី គេហៅថា **សហភាព** ប្រែថា
"ការនៅរួបរួមជាពួកជាមួយគ្នា" ។ ពួកជនកងសហភាពនោះៗ, កាល
បើគ្មានមនុស្សសប្បុរសគឺមនុស្សល្អហើយ, ទោះបីប្រកបកិច្ចការអ្វីនីមួយ
ក៏មិនបានសម្រេចផលដោយល្អទេ ច្រើនតែមានទុបសគ្គស្ទាក់ដំណើរ
សេចក្តីចំរើនទៅវិញ ។ មែនពិត, មនុស្សទាំងអស់ក្នុងលោក ដែលមាន
កិច្ចការត្រូវធ្វើ សុទ្ធតែពាក់ដងដោយពួកគណៈ: បើមិនច្រើនក៏តិច, ព្រោះ
ថាមនុស្សយើងនឹងនៅតាមទំនើងខ្លួនម្នាក់ឯង ដោយមិនចាប់ពឹងអាស្រ័យ
នឹងអ្នកណាមួយនោះពុំបានឡើយ ។ តាមធម្មតា មនុស្សក្នុងលោកនេះ
តែងមានអធ្យាស្រ័យ មានគំនិតផ្សេងៗគ្នា គឺមនុស្សខ្លះមានអធ្យាស្រ័យ
ល្អគួរគប់រាក់គួរពាក់អាន មានចិត្តទូលាយផ្សាយប្រយោជន៍ដល់ជាតិសាស-
នារបស់ខ្លួន មានសុចរិតធម៌ស្មោះត្រង់ល្អ ប្រកបដោយមេត្តាករុណា
ចំពោះបុគ្គលទូទៅពុំរើសមុខ មិនចំពោះតែត្រកូលគ្រួសារខ្លួនឡើយ,
បុគ្គលបែបនេះ លោកហៅថា សប្បុរស ។ មនុស្សសប្បុរសកាលបើ
មាននៅកងគណៈណា ក្នុងសមាគមណាឬក្នុងទីប្រជុំណា រមែងបណ្តាល
ឲ្យសម្រេចផលល្អ ញុំាងប្រយោជន៍ឲ្យសម្រេចដោយសុវត្ថិភាព ដល់
គណៈនោះ ដល់សមាគមនោះ ដល់ទីប្រជុំនោះ ដោយពិតពុំខាន ។

ព្រោះហេតុនោះ ការសេពគប់ត្រូវតែជ្រើសពិនិត្យរកបុគ្គលដែលល្អ ដោយហ្មត់ចត់ទើបជាការល្អ ។ មនុស្សខ្លះមានអធ្យាស្រ័យគ្រោតគ្រាតអាក្រក់ គ្មានសុចរិតធម៌គិតតែប្រយោជន៍ផ្ទាល់ខ្លួន មានចិត្តឫស្យាឈ្នានិសដិះដាន់រំលោភរកប្រយោជន៍ទាំងបំពាន គិតខាងតែបានប្រយោជន៍មកខ្លួនដោយផ្លូវខុសច្បាប់ មានចិត្តប្រាសចាកមេត្តាករុណា ក្សត់ចិត្តទឹងមនុស្សជាតិផងគ្នា; បុគ្គលបែបនេះ លោកហៅថា អសប្បុរសគ្រោតគ្រាតបំផុត ។ ក្នុងប្រទេសណាឬក្នុងសមាគមណា បើមានមនុស្សអសប្បុរសនៅលាយឡំផង ប្រទេសនោះ សមាគមនោះនឹងវិនាសហិនហោចឆ្ងាត់ឆ្ងាយចុះជាលំដាប់ ។

មួយទៀត ពាក្យថា "សប្បុរស" សំគាល់យកមនុស្សមានសុចរិតធម៌ ។ សុចរិតធម៌ ទុកដូចជាសញ្ញាប័ត្រមួយដ៏ប្រសើរបំផុត, កាលបើបុរសស្ត្រីណាមួយ មានសុចរិតធម៌, បុរសស្ត្រីនោះគេហៅថា មនុស្សសប្បុរស ។ សុចរិតធម៌ជាគ្រឿងសំគាល់មួយ សម្រាប់ពាយបានថាជាសប្បុរស ដែលផ្ទុយគ្នាអំពីអសប្បុរសដោយពិត ព្រោះថាធម៌របស់សប្បុរសនឹងអសប្បុរសឃ្លាតពីគ្នាដូចទិសខាងកើតនឹងទិសខាងលិច ។

ព្រះពុទ្ធសាសនា ជាសាសនាដែលសម្បូរដោយសុចរិតធម៌នេះច្រើនជាទីបំផុត, អ្នកដែលបានសន្សំសុចរិតធម៌ រមែងបានទទួលសេចក្តីសុខទាំងបច្ចុប្បន្នទាំងបរលោក ។ សុចរិតធម៌ជាមូលហេតុនៃសេចក្តីសុខ ផ្ទុយគ្នា

នឹងទុច្ចរិត, ចំណែកឯទុច្ចរិត ក៏ជាមូលហេតុនៃសេចក្តីទុក្ខ; ឬថា សុចរិត ជាហេតុនៃសន្តិសុខ, ទុច្ចរិតជាហេតុនៃអសន្តិសុខ យ៉ាងនេះវិញក៏បាន ។ រដ្ឋាភិបាលក្នុងប្រទេសនីមួយ ។ ក៏ត្រូវគិតអំពីសុចរិតនឹងទុច្ចរិតដែលតែងតែមាននៅក្នុងក្រសួងឲ្យណាស់ ទើបរំលាងអយុត្តិធម៌ទៅបាន ។

ពុទ្ធសាសនាឈ្មោះថា សកាសន្តិសុខផ្លូវធម៌ ដែលមានព្រះសម្មាសម្ពុទ្ធជាប្រធានរបស់សកា ។ សកាសន្តិសុខក្នុងលោក គ្រៃអំពីព្រះពុទ្ធសាសនា ឈ្មោះថា សកាសន្តិសុខផ្លូវលោក ជាសកាសម្រាប់រក្សាការពារប្រទេស ដើម្បីកុំឲ្យកើតសង្គ្រាមរវាងប្រជាជនក្នុងលោក ឬកុំឲ្យមានការចលាចលប៉ុណ្ណោះ; ទោះបីមានសុកាសន្តិសុខផ្លូវលោកព្រមទាំងមានគ្រឿងអាវុធជាដំនួយយ៉ាងនេះហើយ ក៏គង់តែកើតសង្គ្រាមឡើងបានក្នុងកាលខ្លះពុំខាន, ដូចយ៉ាងសន្ធិបាតជាតិនៅប្រទេសអ៊ីរ៉ុបក្តី អង្គការសហប្រជាជាតិនៅប្រទេសអាមេរិកក្តី សុទ្ធតែជាសកាសន្តិសុខសម្រាប់រំលត់ភ្លើងទុក្ខកង់លោក បានផលខ្លះពិតមែនហើយ, តែថាសកាសន្តិសុខនេះ សម្រាប់រក្សាតែសេចក្តីសុខខាងក្រៅតែម្យ៉ាង ។ ចំណែកខាងព្រះពុទ្ធសាសនា ជាសកាសន្តិសុខផ្លូវធម៌ដ៏ប្រសើរបំផុត ព្រោះអាចរម្ងាប់សត្រូវបានតាំងខាងក្នុងតាំងខាងក្រៅ ហើយនាំអ្នកសមាជិកឲ្យបានមគ្គផលនិព្វាន មានកម្មវិធីដ៏ជាលក្ខណៈសុខុមភាពច្រើនប្រការណាស់ ហើយគួរពាប់ថាជាសកាថស់ខុំ មានអាយុដ៏វែងឆ្ងាយ

ណាស់មកហើយ គួរយើងជាពុទ្ធបរិស័ទរៀបចំដួសជុលឲ្យមានរបៀបឡើង ។ មួយទៀត សភាសន្តិសុខគឺព្រះពុទ្ធសាសនានេះមិនបាច់ប្រើគ្រឿងអាវុធយុទ្ធភ័ណ្ឌ ដូចសភាសន្តិសុខផ្លូវលោកឡើយ ។ ចំណែកខាងគ្រឿងអាវុធក្នុងផ្លូវព្រះពុទ្ធសាសនាក៏មានប្រើដែរ តែជាអាវុធដោយនាមធម៌ សម្រាប់តស៊ូនឹងបច្ចាមិត្តគឺកិលេសមានលោភៈជាដើម មិនមែនអាវុធមានរូបដែលធ្វើអំពីវត្ថុផ្សេង ។ មានដៃកជាដើមនោះទេ ។

អាវុធក្នុងព្រះពុទ្ធសាសនាមាន ៣ យ៉ាង គឺ:

១ – សុតាវុធ ការស្តាប់, ការរៀន, ការប្រតិបត្តិធម៌ដោយគោរព, នេះឯងទុកជាអាវុធសម្រាប់ព្រះពុទ្ធសាសនា ។

២ – បវិវេកាវុធ ការនៅដោយស្ងប់ស្ងាត់ចាកពួកគណៈ, ស្ងប់ស្ងាត់ចាកកិលេសមានរាគៈជាដើម ឬស្ងប់ស្ងាត់ចាកនីវរណធម៌ទាំង ៥ ប្រាយមានកាមឆន្ទៈជាដើម, នេះឯងទុកជាអាវុធសម្រាប់ព្រះពុទ្ធសាសនា ។

៣ – បញ្ញាវុធ ការពិចារណាការកើតហេតុផលរបស់សេចក្តីសុខទុក្ខនឹងហេតុផលនៃលក្ខណៈ ៣ យ៉ាង មានអនិច្ចលក្ខណៈជាដើមរបស់បញ្ចក្ខន្ធ; នេះឯងទុកជាអាវុធសម្រាប់ព្រះពុទ្ធសាសនា ។ មួយទៀតព្រះពុទ្ធសាសនាមានដំបូន្មានដ៏ល្អ ។ ទៀតជាច្រើនណាស់ សម្រាប់

ប្រែនប្រែជាប្រជាជនដែលមិនមានសុចរិតធម៌ ឲ្យមានសុចរិតធម៌ឡើង, ដែលមានឋានៈជាអសប្បុរសអាចធ្វើឲ្យទៅជាមនុស្សសប្បុរសឡើងបាន, ពាក្យនេះឯងក៏ទុកជាអាវុធដ៏ប្រសើរដែលនាំមនុស្សឲ្យក្លាយជាសប្បុរស ។

មួយទៀត សាកម៏ប្រែជុំនិយាយការឯណាដែលមិនមានមនុស្សជាសមាជិកសប្បុរស, ម៏នោះមិនឈ្មោះថាជាសភាឡើយ; សមដូចពុទ្ធភាសិតក្នុងសំយុត្តនិកាយថា:

ន ឯសា សភា យត្ថ ន សន្តិ សន្តោ
សន្តោ ន តេ យេ ន វទន្តិ ធម្មំ
ភកញ្ច នោ សញ្ច បហាយ មោហំ
ធម្មំ វទន្តា ច ភវន្តិ សន្តោ ។

ប្រែថា "មនុស្សសប្បុរសទាំងឡាយ មិនមានក្នុងពួកណា, ពួកនោះមិនឈ្មោះថាជាសភាទេ; ពួកជនណាមិននិយាយធម៌, ពួកជននោះមិនឈ្មោះថាសប្បុរសទេ; លុះតែពួកជនដែលលះបង់នូវភគៈ: ទោសៈ: មោហៈ: ហើយនិយាយនូវធម៌ ទើបឈ្មោះថា "អ្នកសប្បុរស" ។

ពុទ្ធភាសិតនេះ វិនិច្ឆ័យអំពីសភារបស់សមាជិកសប្បុរសនឹងអសប្បុរស ព្រមទាំងវិនិច្ឆ័យអំពីបុគ្គលដែលគួរហៅថា មនុស្សសប្បុរស ។

(មានត)

វសលសូត្រ

ក្នុងគម្ពីរខុទ្ទកនិកាយ សុត្តនិបាត

ឃុនសុរិត្តវេទិ យ្យរ - អ៊ុន នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែជាភាសាកាឡ

ក្នុងសម័យថ្ងៃមួយព្រះអរហន្ត
ស្តេចប្រថាប់ក្នុងវត្តជេតវ័ន ជិតសោភ័ណដែលក្រងសាវត្ថី ។
ព្រឹកមួយនោះទ្រង់ស្តេចទៅបិណ្ឌបាត ក្នុងក្រុងស្អាតប្រាសសត្វតាម
វេណី
ជួនស្តេចដល់ទៅផ្ទះព្រាហ្មណ៍អបិយ មានសញ្ញីអគ្គិការឆ្លាជ: ។
ឯព្រាហ្មណ៍នេះជាអ្នកប្រកាន់ជាតិ ពោលវាងវៀលគន្លះដោយមានះ
ថាជាតិក្សត្រវៃស្យ:ឬសូទ្រ: ពួជហីន:មិនថ្លៃដូចជាតិព្រាហ្មណ៍ ។
ហេតុនេះហើយបានជាព្រាហ្មណ៍នោះឯង ឃើញជាក់ស្តែងព្រះពុទ្ធ
ស្តេចដល់ក្នុងមើលងាយព្រះជាតិក្សត្រមិនមែនព្រាហ្មណ៍ ពោលចេញនាមដោយ
ពាក្យមិនគប្បី ។
ថាអើសមណ៍កំណោរកោរត្រងោល ជាជនចោលបង់ស្បែតកាឡកណ្ណី
ថោកទាបពួជមិនដូចព្រាហ្មណ៍ពិសី ឈប់នៅដីកុំឡើងមកលើផ្ទះ ។
ព្រះឈ្មោះមារគាលឮពាក្យចាក់ដោត ទើបត្រាស់ចោទសួរទៅព្រាហ្មណ៍
មាន:

ថាព្រាហ្មណ៍អើយស្គាល់ទេបុគ្គលខ្លះ ថោកទាបណាស់ចាន់ដល់បុគ្គលណា ។
មួយទៀតធម៌ដែលនាំឲ្យថោកទាប តើអ្នកជ្រាបយល់ដាក់ដោយច្បាស់ថាចាន់ដល់ធម៌អ្វីស្តីមកវ៉ា សព្វប្រការក្នុងកាលឥឡូវនេះ ។
ពេលនោះឯងព្រាហ្មណ៍ចាស់ពោលតបថា ខ្ញុំភ្នំណាគ្មានដឹងគ្មានតម្រែះមិនអាចដោះធម៌នេះឲ្យពិសេស ហេតុដូច្នេះសូមព្រះអង្គថ្លាថ្លែង ។
ព្រះសម្ពុទ្ធគ្រាស់ថានែព្រាហ្មណ៍ព្រឹទ្ធ ចូរតាំងចិត្តប្រុងស្តាប់ឲ្យខ្មែងវែងតថាគតនឹងទេស្នាឥឡូវឯង ដូចនឹងចែងគាថាប្រែបទកាក (គតិ) ។

១ – កោធនោ ឧបនាហី ច ចាបមក្ខី ច យោ នរោ
វិបន្នទិដ្ឋិ មាយាវី តំ ជញ្ញា វសលោ ឥតិ ។

វ័ជនឯណា ក្រោធឹងសម្បា គំនុំឥតស្រាន្ត ចងពៀរប្រកែតអប្រិយ៍សន្ថាន លុបគុណកល្យាណ ទិដ្ឋិវិបត្តិ ។ មាយាបិទបាំងចាបអាក្រក់ខ្លាំង ប្រព្រឹត្តសម្ងាត់ វ័ជននោះឯង ត្រូវដួរជ្រាបថ្លាត់ថាអ្នកថោកក្តាត់ ទាបទន់សន្ថាន[1] ។

• បុគ្គលដួចនៃពាក្យបទកាកគតិ ដែលប្រែពីគាថាខ្លីមួយៗ ខ្ញុំតែងឲ្យដួចជាប់គ្នាទំនងពាក្យកាព្យក្នុងគាថាជាលំដាប់ៗ មក, ហេតុនេះ បើចង់កាត់រំលងយកលីគាថាចោល មើលចំពោះតែពាក្យកាព្យជាប់តគ្នារហូតទៅ ក៏នឹងពីរោះដោយយ៉ាងណា ។

មួយទៀត ចាប់តាំងពីគាថាទី ២ រៀងទៅ ខ្ញុំតែងពាក្យកាត់ពាក្យ "ជនោះ" ចោល, ទុកចាំថាទៅដល់គាថាទី ២ តែម្តង, ដែលធ្វើយ៉ាងនេះដើម្បីកុំឲ្យដួចពាក្យខ្លាំងៗ ប៉ុណ្ណោះ ។

๒— ฝតកដំ ភ ទ្ធដំ ភបិ យោធ ទាណំ វិមាសតិ
យស្សច ទាណោ ទយោ ឯត្ថ តំ ជញ្ញា វសលោ ឥតិ ។
រីឯនឯណា ហៀតហៀនសត្តា ក្នុងលោកដែលមាន កំណើតតែម្តង
ឬពីរដង ប្រាណ ទាំងឯនដែលគ្មាន ចិត្តអាណិតសត្វ ។
๓— យោ ហន្តិ ឧបវុទ្ធេតិ គាមានិ និគមានិ ច
និក្ខមាគោ សមញ្ញាតោ តំ ជញ្ញា វសលោ ឥតិ ។
ឯនណាល្បីនាម សង្កត់ហុតឈាម រំយកសម្បត្តិ ឬទន់ស្រុកនិគម
បុរីរម្យក្នុ ក្បែរមនុស្សសត្វ យកជាទាសករ ។
๔— តាមេ ភ យតិ ភារញ្ច យំ បរេសំ មមាយិតំ
ថេយ្យា អទិន្នំ អាទេតិ តំ ជញ្ញា វសលោ ឥតិ ។
ឯនណាលបលួច ដោយសារចិត្តលួច ទ្រព្យឯនអាក្រក់ល្អ
ដែលគេកំណាន់ កម្មសិទ្ធិបរ ផ្តាច់ពីមាត់ក គេឥតមេត្តា ។
๕— យោ ហាវេ ឥណមាទាយ កុញ្ញមានោ បលាយតិ
ន ហិ តេ ឥណមត្ថីតិ តំ ជញ្ញា វសលោ ឥតិ ។
ឯនណាខ្ចីបុល ទ្រព្យជាបំណុល មកបរិភោគ្តា ថ្លៃក្រោយគេបតែ
បែរជាដោះសា ថាអង្គអាត្មា គ្មានបំពាក់កូវ ។
๖— យោ វេ កតញ្ញុកតមត្តា បន្តុស្មឹ វជតំ ជនំ
ហន្តា កតញ្ញុមាទេតិ តំ ជញ្ញា វសលោ ឥតិ ។

ជនណាច្រណែន ចង់ចាន់ទ្រព្យ នៃអ្នកដើរផ្លូវ ហើយវាយកាប់ចាក់
ឲ្យម្ចាស់ទ្រព្យត្រូវ គ្រោះថ្នាក់ដោយទូវ គ្មានក្តីអាណិត ។

៧– យោ អត្តហេតុ បរហេតុ ឯឯហេតុ ច យោ ឯកោ
សក្កិរុដ្ឋោ មុសា ព្រូតិ តំ ជញ្ញា វសលោ ឥតិ ។

ជនណាសាកសួរ គេសួរដើម្បី ឲ្យដឹងការពិត និយាយមុសា
ព្រោះហេតុដ៏វិត ឯងគេដោយគិត ច្រណែនទ្រព្យា ។

៨– យោ ញាតីនំ សខីនំ វា ឋានេសុ បដិនិស្សត្តំ
សហសា សម្បាយេន វា តំ ជញ្ញា វសលោ ឥតិ ។

ជនណាកំហែង រំលោភឥតត្រែង ទុស្តក្សត់ភរិយា នៃពួកញាតិមិត្ត
ដោយគិតស្នេហា - គមគប់តាមការ - តម្រែកលោភ ។

៩– យោ មាតរំ បិតរំ វា ជិណ្ណកំ គតយោព្វនំ
អបហុសន្តោ ន ភរតិ តំ ជញ្ញា វសលោ ឥតិ ។

ជនណាមានភោគ មិនចិញ្ចឹមលោក អ្នកមានគុណក្រៃ
ដែលវ័យចាស់ជោរ ទន់ទោរដើងដៃ ច្របកបការអ្វី លំបាកវេទនា ។

១០– យោ មាតរំ បិតរំ វា ភាតរំ ភគិនិំ សសុំ
ហន្តិ ភេសេតិ ភថាយ តំ ជញ្ញា វសលោ ឥតិ ។

ជនណាធ្វើទុក្ខ ក្រែងគ្មានយល់មុខ មាតាបិតា បងប្អូនប្រុសស្រី
សស្សូសសុរា ដោយពោលវាចា ច្រគោះច្បាប់ច្បោះ ។

๑๑–យោ អត្តំ បុច្ឆតោ សន្តោ អនត្ថមនុសាសតិ
បដិច្ឆន្នេន មន្តេតិ តំ ជញ្ញា វសលោ តិ ។

ជនណាគេសួរ អំពីការសួរ មានប្រយោជន៍ស្មោះ បែរជាភ្លែងភ្លាប់ ការងារមានគ្រោះ ឬភ្លាប់បណ្តោះ ដោយលាក់បំពាំង ។

๑๒–យោ កត្វា ចាបកំ កម្មំ មា មំ ជញ្ញាតិ ឥច្ចតិ
យោ បដិច្ឆន្នកម្មន្តោ តំ ជញ្ញា វសលោ តិ ។

ជនណាធ្វើបាប ហើយចង់បន្សាប ឲ្យគេកន្តាំង មិនឲ្យគេដឹង ឬប្រឹងបិទបាំង បាបអាក្រក់ខ្លាំង មិនឲ្យសុះសាយ ។

๑๓– យោ វេ ឃរកូលំ កត្វា កុត្វា ច សុចិកោ ជនំ
អាគតំ ន បដិបូជេតិ តំ ជញ្ញា វសលោ តិ ។

ជនណាទៅកាន់ ផ្ទះគេ ។ វន្តាន់ ដូនគោជន៍សប្បាយ ដល់គេមកផ្ទះ ខ្លួនវិញខ្លួនស្តាយ មិនទទួលបាយ ដូចកាលគេសោះ ។

๑๔–យោ ព្រាហ្មណំ វា សមណំ វា អញ្ញំ វាបិ វនិព្ពកំ
មុសាវាទេន វញ្ចេតិ តំ ជញ្ញា វសលោ តិ ។

ជនណាមុសា បញ្ឆោតព្រាហ្មណ សមណៈសូម្បីស្មោះ ដោយភ្លែងថា គ្មាន ឬមានតែបន្តិច ថោកអន់មិនស្រស់ របស់ថ្លៃលាក់ទុក ។

๑๕–យោ ព្រាហ្មណំ វា សមណំ វា ភត្តកាលេ ឧបដ្ឋិតេ
ភោសេតិ វាចា ន ច ទេតិ តំ ជញ្ញា វសលោ តិ ។

ពេលចាយជនណា គ្រែធដ៏ឯសម្បា ពោលពាក្យចាក់រុក ដៀលគ្នុះ
ស្រមណ៍ព្រាហ្មណ៍ មិនត្រៀមកត្តុក អង្គុយគេចមុខ ឲ្យសូមយាចក ។
๑๖– អសតំ យោធ បត្ថេតិ មោហេន បរិភុណ្ឌតោ
កតញ្ញុកំ និដ្ឋកីសាធោ តំ ជញ្ញា វសលោ ឥតិ ។
ជនណាល្ងង់ខ្លៅ គ្មានដឹងកត់ដៀ ហ៊ានតាយកុហក ប្រាប់គ្រែកាចជា
ពេលល្អអាក្រក់ ដោយចិត្តលាមក ចង់ចាន់ឲ្យគេ ។
๑๗– យោ ចត្តានំ សម្ភុក្កំសេ បរេ ច អវជានតិ
និហីនោ សេន មានេន តំ ជញ្ញា វសលោ ឥតិ ។
ជនណាថោកទាប ពោលលើកអត្តភាព ឲ្យខ្ពស់ល្បីកេរ្តិ៍ បង្អាប់បន្ទុះ
ពួកជននៅក្បែរ ឲ្យគ្នាខ្មាសគេ ដោយសំដីខ្លួន ។
๑๘– ភេសកោ កាតរិយោ ច ថាមិច្ឆោ មច្ឆរី សឋោ
អហិរិកោ អនោត្តប្បី តំ ជញ្ញា វសលោ ឥតិ ។
ជនណាគ្រែធា ស្អប់ទានចាគា កំណាញ់មាំមួន ប្រាថ្នាលាមក
លេងតល់សំខ្លួន គ្មានខ្មាសកុដ៏ខ្លួន មិនមានខ្លាចបាប ។
๑๙– យោ ពុទ្ធំ បរិភាសតិ . អថ វា តស្ស សាវកំ
បរិព្វាជកំ គហដ្ឋំ តំ ជញ្ញា វសលោ ឥតិ ។
ជនណាដៀលគ្នុះ ព្រះពុទ្ធជាម្ចាស់ សាវកសុភាព ថាពុំមែនព្រះ
ថាអ្នកថោកទាប កាន់វត្តដូនជាប ពុំជាសោភ័ណ ។

๒๐– យោ វេ អនរហំ សត្ថោ. **អរហំ បដិជានាតិ**

ចោរោ សត្ថុហុត្វា លោកេ ឯសោ ខោ វុសលោធម្មោ ប្បុថុជ្ជនណា ហានិពោលប្តេជ្ញា ជាព្រះអរហន្ត លើកខ្លួនជាព្រះដើម្បីបំភ័ន្ត ឲ្យពួកមហាជន គោរពកោតក្រែង ។ រីឯនបណ្ឌិត ត្រូវជ្រាបតាមពិត នូវជននោះឯង ថាជាមនុស្សប្បាប ចោរពាលជាក់ស្តែង អាក្រក់ក្រៃលែង ជាឯសត្តពស់ខ្វា ។

ឯតេ ខោ វុសលា វុត្តា មយា យេ តេ បកាសិតា ជនពួកនោះ ។ ដែលពោលចំពោះ កុង ๒๐ គាថា ចាត់ជាមនុស្សថោក គ្មានថ្លៃសោះសា លាមកមហិមា គួរចៀសវាងក្បាម ។

ន ជច្ចា វសលោ ហោតិ ន ជច្ចា ហោតិ ព្រាហ្មណោ កម្មុនា វសលោ ហោតិ កម្មុនា ហោតិ ព្រាហ្មណោ ។ ជនដែលឈ្មោះថា ថោកទាបអន្ធការ ឬឈ្មោះថាព្រាហ្មណ៍ មិនមែនព្រោះជាតិ គឺព្រោះកម្មកាម ដែលកើតជិតជាម ដោយគ្រាតាំងបី ។

ព្រះសម្ពុទ្ធកាលសំដែងព្រះធម៌ ដ៏បវរប្រោសប្រាណព្រាហ្មណ៍ព្រឹទ្ធ ដល់ត្រឹមនេះទុកស្ទេះបែរទ្រង់ជា ពណិនាជាដកមាតង្គ: ។ ថាព្រាហ្មណ៍អើយកុងអតីតកាល សឹងបណ្តាលកើតរឿងរ៉ាវមកជាក់ មានបុរសឈ្មោះមាតង្គ:ម្នាក់ ពូជអប្បលក្ខណ៍ចណ្ឌាលតាចយោរយៅ ។ បានចេញបួសជាតាបសឥសី សឹងមានល្បីកេរ្តិ៍ឈ្មោះសុះសាយទៅ

ថាជាអ្នកលុះធម៌ដ៏ជ្រាលជ្រៅ ជាសំពៅផុតសត្វកាត់សង្ខា ។
ឥសីនេះកាន់វត្តប្រព្រឹត្តត្រូវ ឃានលុះនូវសមាបត្តិអភិញ្ញា
នៅអាស្រ័យក្បែរស្ទឹង ១ នាមា កុម្ភវតីនាពន្ធមតី ។
ពួកក្សត្រព្រាហ្មណ៍ឮនាមតាបសនេះ ថាវិសេសដោយគុណគួរមេត្រី
ឃានចុះចូលថ្វាយខ្លួនសិស្សភក្តី បំរើទ្វីតបីគិតជាតិពង្ស ។
ដោយចំណង់គោរពចំពោះធម៌ សណ្តិតល្អកង់ខ្លួនអ្នកជ្រាជ្រួង
ប្រណិបត្តិលុតក្រាបបន្ទាបអង្គ ដោយផ្តិតផ្តង់ទុកជាក់ហាក់ទេវតា ។
នៃព្រាហ្មណ៍អើយនៅក្បែរអាស្រមស្រស់ មានតាបសម្នាក់ទៀតជាតិព្រាហ្មណា
ធ្វើអាស្រមនៅក្រោមខ្សែជលសា ដោយប្តេជ្ញាថាខ្លួនមានជាតិខ្ពង់ ។
តែតែងគុណវិសេសក្រៅពីនេះ សឹងមិនផេះទេគ្មានកង់អង្គ
ឃើញគ្រាន់មួយតែខាងឋាបគ្មានបង់ ខំផ្តិតផ្តង់ផ្លុំភ្លុកគ្មានខំនេរ ។
ប្រកាន់ជាតិថាជាតិខ្លួនប្រសើរ មិនហ៊ានប្រែពស្តុអ្វីឆ្ពោះក្រាយគេ
ឈរដើរដេកអង្គុយអាសនេ ដ៏ខ្ពង្គង់ខ្ពស់ខើបសាន្តសុខ ។
មានថ្ងៃមួយមាតង្គៈបណ្ឌិត ឃានប្រព្រឹត្តប្រឹក្សាឈើសូន្យមុខ
ចោលបណ្តែតតាមទឹកហូរគគុក ទៅឆ្ពោះមុខតាបសប្រកាន់ជាតិ ។
តាបសនោះឃើញហើយគិតខឹងថា ដើរអួតណាប្រមាថអញសល់ខ្លាត
ហ៊ានមកនៅខាងដើមទឹកជាអាថ៌ ដោយមារយាទមើលងាយពូជពង្សអញ ។

លុះខេចឆ័ត្រសញ្ជឹងដូច្នោះហើយ ពុំកន្តើយត្រែចតាមស្ទឹងអញ្ជើ
ដើរគន់ឈ្វេកឃើញលោកកំពោលផ្ទាញ់ នៃរើយអញចឹងក្នាញ់ទឹង
ឯងណាស់ ។

ឯងឈ្មោះអ្វីជាតិអ្វីបួរស្តីមក កុំនិរភកកូតថាឲ្យច្បាស់
តាមឈ្មោះពិតជាតិពិតកុំក្រែងឡាស់ ស្តីឧកាសគេចកែបែរបិទបួន ។
មាតង្គ:តាបសឆោលដោះថា ខ្ញុំកុណាមាតង្គ: តាមនាមខ្ញុំ
ជាតិចណ្ឌាលកាចរាលពីតាដូន ខ្ញុំមកពួនសាងធម៌កសំពៅ ។
តាបសព្រាហ្មណ៍តបភ្លាមថាឧច្នោះ ពូជថោកសោះម្តេចហ៊ានបំពានទៅ
លើខ្សែទឹកបណ្តែតឈើស្ទុនទៅ ធ្វើច្នេះហៅប្រមាទជាតិព្រាហ្មណ។
ចាប់ដើមតាំងពីត្រឹមថ្ងៃនេះទៅ ឯងកុំទៅចេញទៅកុំសង្កា
ទៅតាំងទីលំនៅត្រែកាមជលសា បើទៅអាអញនឹងជាក់សម្បថ ។
មាតង្គ:គ្មានថ្នាក់អាក់ចិត្តា ចេញយាត្រាទៅនៅតាមកំណត់
មិនយូរថ្ងៃឥស៊ីសីលម៉ត់ចត់ ដុសមាត់មដ្ឋចោលស្ទុនកងគង្គា ។
ដោយតេជ:តប:នៃតាបស ឈើស្ទុនស្រស់អណ្តែតចាសទឹកថ្លា
មកដល់មុខតាបសជាតិព្រាហ្មណ នៅរោទក្បាលខ្ញុំដុំអង្គ ។
ព្រាហ្មណ៍ឥស៊ីឃើញខ្លឹនេះធុរនេវ ហាក់ដូចមេរ្យាត្រែវក្លើងគ្មានពាង់
ទៅបន្ទោសហើយឲ្យតាបសខ្ចី មកនៅត្រង់កន្ទែងដើមដែលវិញ។
មាតង្គ:ឥស៊ីបរិសុទ្ធច្បាប់ ស៊ូធ្វើត្រាប់បង្កាប់គ្មានខោមនេញ

ខោះខៅនៅហ៊ាយត្រូវគេបណ្តេញ កំសូចេញគ្មានចង់អាយាគា ។
តែខោះបរិយ៉ាងនេះគង់តាបស អសប្បុរសរកឿងដេរផ្តាសា
ថាឲ្យក្បាលអាងងបែងបែកគ្នា កងវេលាសុរិយារះថ្ងៃកដ ។
មានឮ:ញុជាក់ពិគ្រោះម៉ែល តាបសព្រឺលងើលជាក់សម្បថ
តើត្រូវខ្លួនឬស្លួនត្រូវអ្នកស្បថ ឃើញថ្ងៃកដត្រូវមាត់អ្នកផ្តាសា ។
ទើបឥសីទប់ខឹព្រះអាទិត្យ រុងរឿងរិទ្ធិងងឹតមិនយាគ្រា
ដោយតេជានុភាពនៃអាត្មា ព្រោះថ្ងៃថ្ងាសង្រ្គោះតាបសខិល ។
នៃព្រាហ្មណ៍អើយកាលនោះមហាជន ជ្រួលជ្រើមស្ងួនស្ងៃស្ងោក្តែកវេ—
វិល ដោយគ្មានថ្ងៃច្រើនថ្ងៃអាប់មន្ទិល ថ្ងាត់សុរិលប្រកបការពុំបាន ។
ទើបនាំគ្នាទៅក្រាបបង្គំសូរ ឥសីតួពាលាពុតសាមាឡ
ថាលោកម្ចាស់សូមមេត្តាច្រោសច្រាណ ច្រាប់ដើមដានដែលថ្ងៃមិនរះ
នេះ ។
ហេតុកេនម្តេចបានជាថ្ងៃកត្រកាល នាំបណ្តាលងងឹតជិតឈឹងម៉្លេះ
ឲ្យយើងខ្ញុំទុក្ខព្រួយទ្រូងស្ទើរប្រែះ បើដូច្នេះម្តេចអេះថ្ងៃរះបាន ។
ព្រាហ្មណ៍ឥសីពោលខ្ញីថាអាត្មា ខឹងសម្បានឹងតាបសមួយច្រាណ
នៅលើខ្សែទឹកក្បែរនេះដែលបាន បណ្តែតច្រានឈើសូន់មកលើក្តី ។
ឯអាចក្តីបានស្តីដេរផ្តាសា ឲ្យសុរិយារះចាំងប៉ាំងសិរសី
ឲ្យវាក្ស័យប្រល័យចំណីដី តែដឹងអ្វីថ្ងៃនេះមិនរះសោះ ។

ជនស្រីប្រុសទើបចុះទៅក្រាបអង្គ សួរមាតង្គបណ្ឌិតគិតពិគ្រោះ
តាមដំណើរស្ទើរដូចគ្នាមុននោះ ចង់ដឹងស្មោះតាមហេតុកេតកើតមាន ។
មាតង្គៈបណ្ឌិតពិតតបថា រឿងនេះអាត្មាបានរៀនច្បាន
យើញគោសស្ដែងលើឥសីគ្មានឈាន ដោះបំពានអាងមានជាតិ
ព្រាហ្មណ ។
ហេតុដែលថ្ងៃមិនរះព្រោះអាចក្ដី មានប្រណីជួយដោះគ្រោះថ្នាក់គេ
ទើបឃាត់ថ្ងៃមិនឲ្យរះឡើងទេ លុះតែគេលន់តួទើបឲ្យរះ ។
មហាជនដឹងដើមដាននូវច្បោះ ទៅពិគ្រោះពិតទូលព្រាហ្មណ៍មាន
ថាសូមលោកនិមន្តទៅសំពះ លន់តួព្រះមាតង្គកុងឥឡូវ ។
ព្រាហ្មណ៍ឥសីស្ដីតបថាអាត្មា ជាតិព្រាហ្មណាពូជខ្ពស់ហួសពេកក្រៃ
ឲ្យគំនាប់ចណ្ឌាលនោះមិនត្រូវ តាមពិតក្រែងគួរគេសំពះវិញ ។
ជនពាំនោះទោះចំអង្វរស្ដី ក៏ឥសីតឹមិនចរចេញ
ទើបពួកជនខឹងយោរទោមនេញ ស្ដីបណ្ដេញចាប់ចេញទាញនាំទៅ ។
ហើយសង្កត់ឲ្យទន្លេក្រាបសិរសា ទាបចុះទាមាតង្គផង់ផ្លូវផៅ
រួចបង្កាប់ឲ្យស្មារណោទោសទៅ តែរឹងនៅចចេសមិនចរចា ។
ឯមាតង្គបណ្ឌិតចិត្តសុភាព ឃាននឹកបពួកជនដោយមេត្តា
ថាអត់ទោសលុះតែអ្នករាល់គ្នា ឃាននឹងធ្វើការតាមបង្គាប់អាចក្ដី ។
គឺត្រូវអ្នកយកដីមកសូនធ្វើ ដាក់នៅលើកេសានៃឥសី

រួចឲ្យគាត់ចុះត្រាំក្នុងវារី បន្ទឹមត្រីត្រមកគាត់ដោយគិត ។
បើធ្វើច្នោះរួចគ្រោះមិនបែកក្បាល បែកតែដីកណ្តាលសិរានោះពិត
ហើយឲ្យគាត់មុជលូនរកច្រាំងជិត ដើរឡើងសិតដោយស្ងួតលាងដីខ្វិ ។
ពួកអ្នកស្រុកលើកគ្នានាំតាបស អសប្បុរសទៅក្នុងគន្លងវារី
ហើយយកកក់ពពោកដោកកេសី ទើបទូលខ្វិទៅអង្គព្រះមាតង្គ ។
ថាលោកម្ចាស់សូមឈប់សំដែងរិទ្ធិ ឲ្យឯងឆឹតបែបនេះកុំបង្អង់
មេត្តាឲ្យអាត្មារះរឿងរុង ដោយស្រោចស្រង់ជីវិតយើងរាល់គ្នា ។
មាតង្គៈទ្រង់បើកព្រះសុរិយ៉ាង រះបញ្ចាំងត្រូវត្រង់អង្គមុខា
បែកដីកក់ផ្ងួងខ្ចាយពេញគង្គា តាបសពាលាលោតមុជលូនទៅ ។
លុះដើរឡើងខ្ចាសគេគេចពួនព្រៃ ដោយឃើញន័យកំហុសទោសកំលៅ
លែងចូលស្រុក ១ ជាតិរហូតទៅ អាស្រ័យនៅក្នុងព្រៃដោយក្តីទុក្ខ ។
រីពួកជនកាលឃើញហេតុអស្ចារ្យ សឹងដែរថាក្នុងការកិច្ចទំនុក
បំរុងផ្ងងគោរពចំពោះមុខ មាតង្គទុកជាទីពាក់អានធំ ។
ឯមាតង្គលុះអង្គអស់ជន្ម ទៅកើតនាស្ថានព្រហ្មធំទុត្តម
ដោយតេជៈគុណសីលដែលខិតខំ ស្មាធិ៍សន្សំធម៌អប្បមាទៈ ។

លុះព្រះពុទ្ធទេស្នាចប់រឿងនេះណា ព្រាហ្មណ៍នាមថាអគ្គិការភ្វាជៈ
ក្តីក្នុងចិត្តឥតឆ្ងល់ខ្វល់ស្ទើរស្ងាត់ ឃានយល់ថ្នាក់ថ្លៃថោកមិនយោគជាតិ ។
ទើបក្រាញក្រាបបន្ទាបបង្គំទូល សូមខ្ជួនចូលសរណាគមជាអាទិ៍

លះប្រកាន់ជាតិពូជពង្សប្រមាទ ខំសង្វាតស្អាងសីលនិន្នរ ។
នៃបងប្អូនខេមរាសូមពិនិត្យ រឿងនេះគឺតធៀបទៅនឹងផ្លូវធម៌
អ្នកគំយល់ថាខ្មែរដែលមានក្រ អាក្រក់ល្អមិនយកជាប្រមាណ ។
យកសំខាន់គោលធំត្រង់អប់គុណ ធម៌ជាទុនទុកនៅក្នុងសិន្ធាន
ចុះគួរខ្មែរយើងទាំងអស់លាន់ ខំផ្គងំប្រាណាប់អានធម៌បវរ ។
ឃុនសុវត្ថីវេទីខ្ញុំយូរ-អ៊ុន សូមអគុណទុកមុនដោយស្មោះសរ
ចំពោះខ្មែរបានប្រែចិត្តសញ្ជរ តាមផ្លូវធម៌, រួចខ្ញុំសុំលាអើយ ។

ចប់វេសសន្តរ ។

កុំដេកចាំព្រៃផ្សំណាង

ជោគលាភផលតែងមានដល់បុគ្គលណា
ព្យាយាមក្នុងធ្វើកិច្ចការស្ម័គ្រណ៍អង្គ
ប្រុសគម្រក់ដេកទម្រក់ចាំព្រៃផ្សង់
ចាំលាប់បង់ប្រាត់ជីវិតក៏ឥតផល ។
ព្រៃវាស្មាបើវៀរការព្យាយាមមាំ
មិនអាចពាំពេជ្រអំពីគីរីផ្តាល់
លុះតែធ្វើទូរអំពើដោយខ្ជាប់ខ្ជួល
ជោគមកដល់ទើបបានព្រៃផៃផងវាស្មី ។

ពិធីបុណ្យដ៏ឧឡារិក

នៅវត្តដំណាក់ ខេត្តសៀមរាប

ព្រះមហាកែ-អឿន វត្តព្រះពេហ្វវ័តន៍ រៀបរៀង

ឃុនសុវត្ថីវេទី យូរ-អ៊ុន ពិនិត្យកែ

កន្លងពេលជិតផ្ទាស់ឆ្នាំចាស់ចូលឆ្នាំថ្មី(ខាលចោស័ក ព.ស.២៤៩៣) នេះ ក្រុមពុទ្ធបរិស័ទវត្តដំណាក់ សៀមរាប មានព្រះតេជព្រះគុណ ព្រះសុមង្គលសិលាចារ្យ មេគណ ជាអ្នកទទួលភ្ជុំ បានធ្វើមធ្វើពិធីបុណ្យដ៏ឧឡារិកជាច្រើនផ្នែក គឺ :

១) ពុទ្ធបរិស័ទជាសិស្សានុសិស្ស មានព្រះសុមង្គលសិលាចារ្យ មេគណជាប្រធាន បាននឹករលឹកដល់គុណូបការនៃព្រះសពទាំង ៣ អង្គ គឺ : ព្រះសពនាមអ៊ុត ១ ព្រះសពនាមកុយ ១ ព្រះសពនាមឈិត ១ ជាអតីតនេវាសិក វត្តដំណាក់ ដែលសុគតទៅជាយូរឆ្នាំហើយ ។

២) បុណ្យឆ្លងសេនាសន: ទាំង ៨ ខ្នងជាដើម ដែលពុទ្ធបរិស័ទ បានសាមគ្គីគ្នាសាងថ្វាយព្រះសង្ឃក្នុងទីវត្តដំណាក់ ។

៣) ព្រះសុមង្គលសិលាចារ្យមេគណបានប្រមូលផ្តុំសាមគ្គីចំពោះលោកគ្រូចៅអធិការ - ឧបាសក - ឧបាសិកា គ្រប់វត្តក្នុងខេត្តសៀមរាប ដើម្បីរួបរួមហិរញ្ញវត្ថុបូលជួយកសាងកុដិសម្រាប់ព្រះសង្ឃនាយកជាសង្ឃបិតាគណៈមហានិកាយ ក្នុងវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

៤) ដើម្បីសំបូរសន្ធឹងរកសេចក្តីសាមគ្គីចំពោះប្រទេសកម្ពុជាឲ្យ បានទទួលហាន:ជាប្រទេសឯកពូជដោយសម្បូណ៌ ។

កាលដែលករណីយកិច្ចនេះដល់ត្រមហើយ, ក្នុងវត្តដំណាក់ចាំង មូល, ពួកពុទ្ធបរិស័ទបានតាក់តែងដោយគ្រឿងសក្ការបូជាប្រជាប់ដោយ ទង់ជាតិ ស្លឹកឈើស្រស់ ប្រទីបផ្កាលាក្តឹព្រោងព្រាត ទៀវ ស ក្រហម ដុំរុងរឿងចាំងកុដិ សាលាវិហារ ចំពែងចិញ្ចេចពាសពេញអាវាម ដោយ ទើបលាបលនថ្មី គួរជាទីសម្រាកការ នៃជនាទុជនដែលគមនាគមន៍ទៅ មកក្នុងពេលបុណ្យនោះ ។

ក្រុមវិធី

ទី ១ — ថ្ងៃ ៧ មេសាឆ្នាំ ១៩៥០ វេលាយប់ម៉ោង ៨ ចំរើនព្រះបរិត្ត, តពីនោះ លោកព្រះវិជិតសេដ្ឋា អាង-គិម-យន ថ្លែងបាឋកថា អំពីការ ធ្វើបុណ្យនឹងទទួលអំណរចំពោះពុទ្ធបរិស័ទ ដែលអញ្ជើញទៅជួយអនុ-មាទនាបុណ្យ; យប់ម៉ោង ៩ កន្ទុះ និមន្តព្រះអាចារ្យកែវ-អ៊ីវ សំដែងធម៌ ទេសនា; ត្រឡប់ម៉ោង ១១ វេរកត្តដល់ព្រះសង្ឃ ចំនួន ១០០ អង្គ ។

ទី ២ — ថ្ងៃ ៨ មេសាឆ្នាំ ១៩៥០ វេលារសៀលម៉ោង ៧ មានកង៉ឯក-ទេសខ្មែរចាំងប្រុសចាំងស្រីមកកាន់ធម្មស្សវនដ្ឋានជាង ១០០ នាក់ ឃាន ច្រៀងចំរៀងជាតិនឹងពិរោះជូនបង៉ប្អូនស្តាប់មើលំ ចំនួនមួយម៉ោង, វេលា យប់ម៉ោង ៩ លោកពលបាលឯក ចក់-ពេជ្រ ក្រុមការហានទេមរ:កូមិន្ទ

ថ្ងៃដ៏ជាឋកថា អំពីសេចក្តីសាមគ្គីនៃលោកគ្រូចៅអធិការគ្រប់វត្តនឹងបងប្អូនរួមជាតិ ដោយក្បោះក្បាយ ចំនួនកន្លះម៉ោង; លោយបម៉ោង៩កន្លះ និមន្តព្រះតេជព្រះគុណ ព្រះមហាសុមេធាធិបតី សង្ឃនាយក ជួន - ណាត សំដែងធម្មទេសនាជាង១ម៉ោង; លុះចប់ហើយ កងឯកទេសចូលថ្វាយបង្គំព្រះតេជព្រះគុណសង្ឃនាយក។ មានថេរវាចាជូនពរសំពះសាធុការៈចំពោះកងឯកទេស។ ចាប់ផ្តើមប្រឹងចំរៀងជាតិនឹងរាំវង់តទៅទៀត ដរាបដល់ម៉ោង ១ យប់ ទើបឈប់ ។

ថ្ងៃ ៣— ថ្ងៃ ៩ មេសា ឆ្នាំ ១៩៥០ ពិធីបុណ្យ ដូចថ្ងៃទី ១ ទី ២ដែរ, ពេលនេះ មានកងឯកទេសខ្មែរទាំងប្រុសទាំងស្រីចំនួន ៥ ឡានទៅច្រើនជាងមុន, លោកវរសេនីយ៍តែនាយកកងឯកទេស នឹងលោកស្រីជាកិរិយាក៏អញ្ជើញទៅជាអធិបតី កងពិធីបុណ្យ ព្រមទាំងអស់អ្នកពាក់ការគ្រប់តំណែងក៏អញ្ជើញទៅជាច្រើនក្នុងពិធីបុណ្យនោះដែរ, យប់នោះព្រះតេជព្រះគុណសង្ឃនាយកសំដែងធម្មទេសនាទៀត; ថ្ងៃ ១០ មេសា ព្រឹកពាក់ព័ន្ធតែធ្វើបង្ហើយបុណ្យ ។

ចំនួនហិរញ្ញវត្ថុ ដែលពុទ្ធបរិស័ទមានសទ្ធាចូលក្នុងការកសាងកុដិសម្រាប់ព្រះសង្ឃនាយក ដូចមានចំនួនតទៅនេះ គឺ:

ស្រុកសៀមរាប ចំនួន ៤៧៤១ រៀល

" សូទ្រនិគម " ៣៩៤០ "

ស្រុកក្រឡាញ់ ចំនួន ៣.៣៥៣ រៀល

" ដីក្រែង " ៥.៥៧៥ "

" ពួក " ២.៦៩១ "

" សំរោង " ២០១ "

ចូករួមទាំងអស់ចំនួន ២០.៥០១ រៀល

កន្លងកាសបុណ្យទាំង ៣ ថ្ងៃនោះ មានពុទ្ធបរិស័ទអញ្ជើញទៅជួយ អនុមោទនាជាច្រើនកុះករ ហើយសេចក្តីដែលថ្លាចំពោះធម្មទេសនា និងកម្មពិធីបុណ្យជាដើម ដោយកិរិយាភាព ។

ក្រុមពុទ្ធបរិស័ទដែលបានផ្តើមធ្វើកុសលនេះ មានព្រះតេជព្រះគុណ ព្រះសុមង្គលសីលាចារ្យមេគណជាប្រធាន សូមទុទ្ទិសកុសលរាសីនេះ ថ្វាយចំពោះព្រះប្រិយមហាក្សត្រ ព្រមទាំងសម្តេចព្រះបរមរាជជនកា សម្តេចព្រះវររាជជននីនាថ និងព្រះរាជវង្សានុវង្ស; ដោយតេជានុភាពនៃព្រះតេនត្រ័យនិងកុសលរាសីនេះ សូមទ្រង់ប្រកបដោយសុខសួស្តីសិរីសុវត្ថិភាព សូមឲ្យមានព្រះជន្មាយុយឺនយូរអង្វែង ទាំងមានព្រះតេជានុភាពច្រើន; មួយទៀត សូមជូនកុសលនេះដល់ពជរដ្ឋាកិបាលរបស់ព្រះអង្គ ហើយសូមឲ្យបានសេចក្តីសុខគ្រប់ប្រការជានិច្ចរា និងសូមឲ្យប្រទេសកម្ពុជរដ្ឋស្ថិតនៅក្នុងសន្តិភាពនិងវឌ្ឍនធម៌ អស់កាលជាយូរអង្វែងតទៅ ។

ព្រះមហា កែ - អឿន

ចៅអធិការដែលទើបតាំងថ្មី

របស់ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៦១៥ ចុះថ្ងៃចន្ទ ១៥ កើត ខែផល្គុន ឆ្នាំជូត សំរឹទ្ធិស័ក ព.ស. ២៤៩១ តាំងលោកគ្រូ សាប់-ចិក នាមឆាយា ឥន្ទសត្ថា កើតឆ្នាំម្សាញ់ អាយុ ៥៦ វស្សា ៣៦ ជាគ្រូសូត្រស្តាំ វត្តនគរខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខែត្រសៀមរាប ។

សញ្ញាប័ត្រលេខ ៦១៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាប-ឡាន់ នាមឆាយា ធម្មជោត កើតឆ្នាំកុរ អាយុ ៦២ វស្សា ៣៣ ជាគ្រូសូត្រឆ្វេង វត្តនគរខាងត្បូង ឃុំនគរធំ ស្រុកសៀមរាប ខែត្រសៀមរាប ។

សញ្ញាប័ត្រលេខ ៦១៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ភាល់-សាំង នាមឆាយា ឯកសុវណ្ណ កើតឆ្នាំពេង អាយុ ៤៥ វស្សា ២៥ ជាចៅអធិការ វត្តព្រៃមេរេង ឃុំព្រៃខ្វា ស្រុកកោះអណ្តែត ខែត្រតាកែវ ។

សញ្ញាប័ត្រលេខ ៦១៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុយ-ជា នាមឆាយា ពុទ្ធសាពេ កើតឆ្នាំមមី អាយុ ៤៣ វស្សា ២៣ ជាចៅអធិការ វត្តព្រៃតបស្សាស ឃុំព្រៃតបស្សាស ស្រុកព្រៃតបស្សាស ខែត្រតាកែវ ។

សញ្ញាប័ត្រលេខ ៦២០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អាត់-សយ នាមធាយា សុធម្មប្បញ្ញោ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

, សញ្ញាប័ត្រលេខ ៦២១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ករ-សួល នាមធាយា បញ្ញាសារោ កើតឆ្នាំរកា អាយុ ២៨ វស្សា ៤ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦២២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-តុង នាមធាយា ញាណរក្ខិត កើតឆ្នាំជូត អាយុ ៤៩ វស្សា ២៩ ជាចៅអធិការ វត្តធម្មក្តីរ ឃុំគោកគង់ ស្រុកកញ្ជ្រៀច ខេត្តវៃព្រវែង ។

សញ្ញាប័ត្រលេខ ៦២៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សូ-ជិន នាមធាយា ជោតត្ថេរ កើតឆ្នាំកុរ អាយុ ៥១ វស្សា ២៨ ជាចៅអធិការវត្តខ្នាយភ្លារ ឃុំត្នោតក្រឡាមាយ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦២៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ូ-ឃៃ នាមធាយា ឥន្ទសរ កើតឆ្នាំរោង អាយុ ៣៣ វស្សា ១៣ ជាចៅ-អធិការ វត្តសុវណ្ណារាម ឃុំច្រកមេស ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៦២៦ ចុះថ្ងៃពុធ ១ កើតខែចេត្រ ឆ្នាំជូតសំរឹទ្ធិស័ក ព.ស. ២៤៩១ តាំងលោកគ្រូ មាស-យាង នាមធាយា ចន្ទប្បជោត កើតឆ្នាំរកា អាយុ ២៨ វស្សា ៧ ជាគ្រូសូត្រស្តាំ វត្តកំណាច់ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តវៃព្រវែង ។

សញ្ញាប័ត្រលេខ ៦២៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខៀង-សៀម នាមឆាយា តន្ធុសរ-កើតឆ្នាំ... អាយុ ៥៦ វស្សា ៧ ជា ចៅអធិការវត្តពោធិវ័ន ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ ។

សញ្ញាប័ត្រលេខ ៦២៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ក់-សុំម នាមឆាយា ធម្មិស្សរោ កើតឆ្នាំ... អាយុ ៤៧ វស្សា ៧ ជា ចៅអធិការ វត្តកំពង់កុក ឃុំកំពង់កុ ស្រុកលើកដែក ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ៦៣០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ត្រែង-អឹម នាមឆាយា តន្ធុប្បញ្ញា កើតឆ្នាំ គ.ស. ១៩៨៦ អាយុ ៤៨ ជាចៅអធិការ វត្តពោធិសន្តារាម ឃុំអាំងនិញ ស្រុកឃ្លាំង កូសំង៍ស៊ីន ។

សញ្ញាប័ត្រលេខ ៦៣១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅ-យ៉ែម នាមឆាយា យឹមមុនីជោតត្ថេរ កើតឆ្នាំខាល អាយុ ៣៥ វស្សា ១៥ វត្តកំពង់ចាម ឃុំកំពង់ចាម ស្រុកកោះសូទិន ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៦៣២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ា-ច្រង់ នាមឆាយា មុនីមង្គលត្ថេរ កើតឆ្នាំវក អាយុ ២៤ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៣៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខឹម-ជា នាមឆាយា ជោតប្បញ្ញា កើតឆ្នាំវក អាយុ ២៩ វស្សា ៧ ជា គ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

ត្រូវមានសំបុត្រសម្ងាត់ទៅដល់កងស៊ុនចាន ឲ្យលើកទាហានចូលវាយ
ស្រុកគីជីវ ១ ផ្លូវ ចំណែកលោកលើកទៅវាយចុងខាង ១ ផ្លូវទៀត ប៉ើ
បានស្រុកនោះហើយ សឹមចែករំលែកចែកទ្រព្យរបស់ធំធេងមនុស្សចំណុះ
ស្រុកឲ្យកងស៊ុនចានពាក់កណ្តាលចុះ នោះបើកងស៊ុនចានលើកទាហាន
ទៅជួយវាយលើកនេះ, ឯហាន់ហុកចៅហ្វាយស្រុកនោះជាមនុស្សមិនចេះ
គិតអ្វីសោះ គង់ធំធេងមានសំបុត្រចុកដល់លោកឲ្យលើកទាហានទៅជួយ
លោកក៏ធំធេងបានស្រុកគីជីវដោយងាយមិនត្រួយបារម្ភ ។ អ្នកសៀវ
ភៅត្រូវ ទើបតែងសំបុត្រការសម្ងាត់ប្រាប់ទៅកងស៊ុនចានតាមគំនិត
របស់ហងគី ។

សម័យនោះ កងស៊ុនចានបានទទួលសំបុត្រអ្នកសៀវភៅលើលដឹង
សេចក្តីហើយក៏មានចិត្តត្រេកអរពន់ពេក ទើបធ្វើសំបុត្រតបទៅអ្នកសៀវ
ភៅវិញ ប្រាប់ពេលកំណត់ដែលនឹងលើកទាហានទៅវាយស្រុកគីជីវនោះ ។
អ្នកសៀវភៅបានដឹងសេចក្តីសំបុត្រនោះហើយ ក៏ចាត់បំរើម្នាក់ឲ្យនាំសំបុត្រ ១
ច្បាប់ទៅប្រាប់ហាន់ហុកចៅហ្វាយស្រុកគីជីវថា ឥឡូវនេះកងស៊ុនចាន
មានសំបុត្រមកប្រឹក្សាថា ធំធេងលើកទាហានមកវាយយកស្រុកគីជីវហើយ ។
ហាន់ហុកទទួលសំបុត្រហើយក៏ហៅទីប្រឹក្សា ឈ្មោះស៊ុនសុមធំធេងស៊ុនប៉ង
មកពីគ្រោះថា ឥឡូវកងស៊ុនចានមុខជានឹងលើកទាហានមកវាយស្រុក
យើងហើយ តើយើងនឹងគិតដូចម្តេច? ។

ស៊ុនសុមឆ្លើយថា ដែលកងស៊ុនចាននឹងលើកទាហានមកវាយស្រុកយើងនេះ ឃើញថានឹងលើកមកច្រើនណាស់ ហើយឡៅពី កួនអ៊ូ គឺវាហ៊ុយកំគង់នឹងមកផង ទាហានរបស់យើងឃើញជាតស៊ូនឹងគេមិនបានឯអ្នងសៀវក៏ប្រកបទៅដោយសតិបញ្ញា មានទាហានឯកនឹងទាហានឡៅកំច្រើន បើដូច្នេះ សុំឲ្យលោកមានសំបុត្រទៅអញ្ជើញអ្នងសៀវមកនៅឈរការក្សាស្រុកយើងចុះនឹងបានជួយការពារការក្សាគ្នាតទៅ អ្នងសៀវក៏គង់មានសេចក្តីមេត្តាដល់លោកខ្ញុះ ឯកងស៊ុនចានក៏គង់មិនហានមកញាំញីស្រុកយើងព្រោះក្រែងខ្លាចអ្នងសៀវ ។

ហាន់ហុកស្តាប់ហើយឃើញត្រូវផង ក៏តែងសំបុត្រ ១ ច្បាប់ឲ្យគួនគីនាំទៅដូនអ្នងសៀវតាមពាក្យស៊ុនសុម ។ ពេលនោះ កេងប៊ូដរាបហាន់ហុកថា អ្នងសៀវនោះជាមនុស្សឆ្លាត់គំនិតហើយ ដែលនៅគង់ខ្ជង់តាំងខ្លួនចិញ្ចឹមទាហានសព្វថ្ងៃនេះបាន ដោយអាស្រ័យស្បៀងអាហារដែលលោកបញ្ជូនទៅឲ្យ ឧបមាបីដូចជាទារក បើមាតាមិនឲ្យទឹកដោះបៅហើយ ក៏មានតែសេចក្តីយំសោកជាទុក្ខដោយការស្រេកឃ្លាន, បើលោកនឹងឲ្យអ្នងសៀវមកជួយរក្សាស្រុកជាប្រធាន ក៏ដូចជាចាប់ខ្លាទៅលែងក្នុងហ្វូងប្រៃសត្រាយ គង់នឹងមានភ័យអន្តរាយដល់សត្វទាំងនោះ, ការណ៍នេះសូមលោកត្រិះរិះមើលតាមសមគួរសិន ។ ហាន់ហុកតបថា ខ្លួនយើងពីដើមដែលនឹងបានធ្វើជានាហ្មឺនជាប់មកនោះ ក៏ព្រោះសែអ្នងជួយឧបត្ថម្ភនាំសេចក្តីគុណតាប់ឲ្យកើតឡើង ទើបយើងបានមកធ្វើចៅ-

អក្ខរសុទ្ធិយោ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៃ អក្សរសាស្ត្រ ចោះពុទ្ធផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក ភ័យ-ប៊ុក
ក្រុមការ នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកសាសនា: ព្រះវេតសត្ថា សូរ-ហាយ
ក្រុមដំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	មាតិកា	ទំព័រ
លោក ភ័យ-ប៊ុក ក្រមការ	ឆិតទមហាន្តគន្ធិ (តមក)	៤១១
— —	ប្រវត្តិសាស្ត្រខែស៊ុំរ៉ែប្បខ្មែរសម័យបុរាណ (តមក)	៤០៦
ក្រុមដំនុំវប្បធម៌	ស័ព្ទបាលីដែលប្រើដោយខ្មែរ ញ៉ុក-ថែម ស្រែង់ (តទក)	៤១២
លោកសាង-សាវ៉ាត លេខាធិការ	រឿងព្រែតភូមា (តទក)	៤១៧
អ្នកនាយកាញ៉ាវិបុលកវិសេនា ខ្ទូ-ពត	រឿងសាមកុក (តមក)	៤២៥
— ទេពពិទូរ ឈឹម-ក្រសេម	ព្រះរាជពង្សាវតារព្រះបាទក្តីដា (តមក) . . .	៤៣៣
ក្រុមដំនុំទំនៀមទម្លាប់ស្រុកខ្មែរ	សារាការវត្តវិហារទន្លឹមលោកកែវ-ហង់តែង (តចប់)	៤៤១
ផ្នែកសាសនា		
លោក ម៉ុញ-តាំត្រី	ពុទ្ធសាសនៈនឹងភាពិរសោសនា (តចប់) ...	៤៤៧
លោក ភ័យ-ប៊ុក ក្រមការ	ពន្ធីមាស៊ីទ្ធិប (តមក)	៤៥១
ព្រះវេតសត្ថា សូរ-ហាយ	សប្បុរិសធម្មកថា (តចប់)	៤៥៦
កំណត់ទំនឹងប្រវត្តិការណ៍		
ព្រះមហា កែ-អ៊ឿន	ពិធីដង្ហែព្រះសារីរិកធាតុ វត្តដំណាក់ សៀមរាប	៤៦២
ព្រះវេតសត្ថា សូរ-ហាយ	ពិធីបុណ្យស្រង់ទឹក សម្តេចព្រះមហាសុមេធាធិបតី ជួង-ណាត សង្ឃនាយកគណៈមហានិកាយ....	៤៦៤
ក្រសួងធម្មការ	បញ្ជីរាយនាមបោះឆ្នោតជាសមាជិកថ្មី (តមក) ..	៤៧៤

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : M. Ray-Buc Kramakar à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déba Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		page
M. Ray-Buc Kramakar (I.B.)	Recueil des paroles de GANDHI (suite).	401
—id —	Histoire: Ancienne civilisation khmère par M. George COEDES (suite) ...	406
Commission Culturelle	Recueil des mots traduits fait par M. NHOK-THEM	412
M. Sang-Savath, Ministère des Finances	Contes birmans (suite).....	417
Neak Oknha Vibularaja-sena Nou-Kân	Histoire de SAMKOK (suite).	425
Neak Oknha Debabidûra Chhim-Krasem	Histoire du Royaume du Cambodge (suite).....	433
Commission des Mœurs et Coutumes	Notice historique de la pagode de Vihara-Tentim de Neak Oknha Keo-Hâng	441

Partie religieuse:

M. Menh-Nakry	Le bouddhisme et les autres religions (suite)	447
M. Ray-Buc Kramakar	Lumière de l'Asie (suite)	450
Brah Debasattha So-Hay	Sappurisaddhammakatha (suite et fin).	456

Notes et chroniques

Préah Moha Ker-Oeun,	Compte rendu des fêtes et de la procession des reliques sacrées à la pagode de Damnak (Siemreap)	462
Préah Débasatha So-Hay	Cérémonie d'aspersion d'eau lustrale de Samdach Préah Moha Sumedhathipadi Chuon-Nath, Chef de Secte Mohanikay	468
Ministère des Cultes	Nomination des nouveaux Chau-Adhikar (suite)	478

22e Année: N° 6 Juin 1950 — Prix d'abonnement: 145$00 par an.

លោក រ៉ាយ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ

ដកស្រង់ពីសារពត៌មាន ហ្សឺនអាំង (Jeune Inde)

(តទក)

---

៣០ – របបប្រជាធិបតេយ្យមិនមែនជាវត្ថុមានសភាពដូចគ្រឿងច័ក្រ ដែលគេអាចលៃលកដោយកែប្រែរូបភាពក្រៅនោះទេ របស់នេះត្រូវកែប្រែនាមធម៌ ។

ប្រៀបរឿង:
(៨ - ១២ - ១៩២០)

៣១ – ខ្ញុំមិនបានគិតដល់របៀបនឹងកំឡាំងប្រៃពណីសកល ដែលគួរមានចំពោះរដ្ឋាភិបាលប្រជាធិបតេយ្យនោះទេ យើងត្រូវស្វែងរកសភាពសាមគ្គីមូលដ្ឋានឯកច្ឆន្ទ កន្លែងដែលមានសភាពខុសគ្នា ។

អំណាចដែលនឹងគាំទ្រហើយរចនាអ្នកទុព្វលភាពឲ្យកាន់តែប្រសើរឡើង លុះត្រាតែអំណាចនោះជាស្នាដៃនៃវិចារណញ្ញាណ ដែលបូចផ្តើមពីសំឡេងតូចស្ងាត់នៅកន្លែងយើង អំណាចនោះត្រឡប់ទៅជាកិច្ចដ៏លាមកយ៉ាងក្រៃលែង ។

ប្រៀបរឿង:
(៨ - ១២ - ១៩២០)

៣២ – សំដីមានសភាពជាផ្សុសភ្នែ នាំឲ្យគេដឹងថាជាបុគ្គលញាប់ញ័រ ហើយនាំឲ្យបក្ខាមិត្តសង្ស័យមិនយល់ច្បាស់លាស់នូវកិច្ចដែលខ្លួន

ប្រព្រឹត្ត, សេចក្តីសន្តោសដោយវាចាជាកូនសោសម្រាប់បើកទ្វារដែលនាំទៅកាន់ជោគជ័យ ។

ឆ្លើយតបសេចក្តីសួរ
(១៨-៩-១៩២១)

៣៣- ពួកបិសាចអាចធ្វើការសំរេចនូវផលប្រយោជន៍បាន លុះត្រាតែមានពួកបិសាចជួចគ្នាជួយឧបត្ថម្ភផង វាតែងបានផលនោះពីសភាពអន់ខ្សោយនៃធម្មជាតិយើង ដើម្បីនឹងសង្កត់សង្កិនយើងឲ្យនៅក្រោមអំណាចវា ។

ជាបនៃអ្នកគ (ស្លូ)
(១៩-១-១៩២១)

៣៤- ព្រលឹងប្រទេសឥណ្ឌាតយុទ្ធនឹងដែកថែប ប្រទេសព្រីតន្ទិក (អង់ក្លីតែរ) ។

១៥-១២-១៩២១

៣៥- មហត្មៈគន្ធីខ្ញុំនាងចំពោះពួកពលរដ្ឋនៅខែត្រក្រៅ-បណ្ឌិត-វាទដែលមហត្មៈគន្ធីបានថ្លែងដោយសង្ខេបទៅនឹងប្រជាជន កន្លងកាលដែលលោកអញ្ជើញទៅទស្សនាការនៅខែត្រអ៊ូដ (Audh) ។

ការដែលនឹងតាំងប្រទេសក្នុងឋានៈជាស្ងួយភាវហើយនឹងកិច្ចការពារនូវអំពើអយុត្តិធម៌ ដែលយើងមិនអាចនឹងធ្វើទៅតាមបំណងបាន ព្រោះយើងមិនបានប្រតិបត្តិតាមវិធានការដូចមានខាងក្រោម :

ក) យើងមិនត្រូវធ្វើបាបកម្មប្រជារាស្ត្រ, យើងមិនត្រូវប្រហារបុគ្គលនឹងដំបង, យើងមិនត្រូវប្រើបេសុញ្ញាវាទ ឬកំហែងគំរាមបុគ្គលណាមួយឡើយ ។

ខ) យើងមិនត្រូវប្លន់ទៅលុកលុយប្លន់កូនពាណិជ្ជការ ។

គ) យើងត្រូវប្រតិបត្តិការទៅនឹងបច្ចាមិត្តរបស់យើងដោយប្រើសេចក្តីល្អ. មិនត្រូវប្រើវិធីកំហែងបង្ខិងដោយឥរិយាបថ ឬធ្វើឲ្យគ្មានទឹកបរិភោគ ឬកាំរាមិនឲ្យពួកជាងកាត់សក់ ឬអ្នកអ៊ុតនោអាសអាភាសធ្វើការរបស់ខ្លួន ។

ឃ) យើងមិនត្រូវគាន់ចិត្តថា មិនព្រមបង់ពន្ធដារជូនរដ្ឋាភិបាល ឬមិនព្រមបង់ថ្លៃឈ្នួលផ្ទះឲ្យម្ចាស់គេហដ្ឋានទេ ។

ង) ប្រសិនបើមានគេបំណងចង់បន្ទោសពួកសាម័ងដារ (Zamindars) យើងត្រូវយកសេចក្តីនេះ ទៅដាក់បណ្តោះបណ្តិតនេហ៎ុ ហើយត្រូវយើងប្រតិបត្តិតាមឧត្តរបស់លោក ។

ច) ត្រូវយល់ថា យើងចង់ឲ្យពួកសាម័ងដារត្រឡប់មកជាមិត្តមេត្រីនឹងយើងវិញ ។

ឆ) ក្នុងពេលនោះ យើងមិនត្រូវប្រទុស្តកាយនឹងរដ្ឋាភិបាល យើងត្រូវស្តាប់បង្គាប់ពាជការគ្រប់ក្រសួង គ្រប់ក្រុម ។

ជ) យើងមិនត្រូវបញ្ឈប់អាយស្ម័យយាន (រទេះក្តៅ) ធ្វើឲ្យខានដើរ ឬឡើងដំរីអាយស្ម័យយានគ្មានសំបុត្រទេ ។

ឈ) ប្រសិនបើចៅហ្វាយនាយយើងណាមួយត្រូវគេចាប់ឃុំឃាំង យើងមិនត្រូវប្រទុស្តរាយឃាត់ហាមមិនឲ្យគេចាប់ទេ ឬបង្កហេតុឲ្យមានចលាចលវឹកវរក្នុងទីនោះ បុព្វហេតុនៃរឿងនេះមិនអាចនឹងសូប់ស្ងាត់ទៅបាន ព្រោះរដ្ឋាភិបាលបានចាប់ចៅហ្វាយនាយយើងហើយ, តែហេតុនោះទៅជាពិតប្រាកដ បើកងពលនោះយើងវង្វេងស្មារតីទៅប្រព្រឹត្តការណកម្មវិញ ។

ញ) ត្រូវចៀសវាងកុំសេពសុរានឹងមេរ័យ កុំសេពសតិសមោសាទសថ (Stupéfiants) កុំប្រព្រឹត្តន្ទូវអបាយមុខគ្រប់យ៉ាង ។

ដ) ត្រូវបំពេញកាតវេទិយកិច្ចចំពោះស្ត្រី ទុកស្ត្រីទាំងនោះដូចជាមាតាយើង ដូចជាបងប្អូនស្រីយើង, ត្រូវគោរពកោតខ្លាចស្ត្រីហើយការពារកុំឲ្យអ្នកណាប្រមាថ ។

ឋ) ត្រូវញ៉ាំងជាតិឥណ្ឌានឹងមហាហ្គាន្ធីឲ្យមានសាមគ្គីព្រមព្រៀងគ្នាកាន់តែមួនមាំឡើង ។

ឌ) យើងមិនត្រូវយល់ថា ជាតិឥណ្ឌាមានហាន: ផ្សែងគ្នាឬសំគាល់ថាមានជាតិឥណ្ឌាខ្លះ ជាហីនជាតិឬជាពួកសូទ្រ: អ្នកងារ (Intouchables) ត្រូវបណ្តុះធម៌សមភាព ឬភាតរភាព ឲ្យមានក្នុងសន្តានចិត្តចំពោះប្រជាជាតិគ្រប់ជាន់ – ថ្នាក់ទាំងអស់; យើងត្រូវគិតថា ប្រជារាស្ត្រឥណ្ឌាទាំងមូលជាបងប្អូនស្រីយើង ជាប្អូនប្រុសប្អូនស្រីយើង ។

ឍ) យើងមិនត្រូវលេងល្បែងស៊ីសងប្តឹងគ្នាឡើយ ។

ណ) យើងមិនត្រូវប្រព្រឹត្តល្មើចបន់ ។

ត) យើងមិនត្រូវពោលពាក្យមុសាវាទ បើទុកជាពាក្យនោះប្រកបដោយវិចារណញ្ញាណយ៉ាងណាក៏ដោយ យើងត្រូវប្រព្រឹត្តធម៌សុចរិតក្នុងការប្រស្រ័យគ្នាខាងវាណិជ្ជកម្ម ។

ថ) យើងត្រូវនិយមប្រើរហាត់រៀនអំពោះនៅគ្រប់គេហដ្ឋានទាំងអស់ហើយត្រូវតែប្រុងស្រីធ្វើតទុកាស ដើម្បីនឹងរៀបចំប្រាសប្តូរបង្ហាត់ក្មេញាំងចិត្តវាឲ្យទុស្សាហ៍រៀនគ្នាញារៀបួនម៉ោងក្នុងមួយថ្ងៃ ។

ទ) យើងមិនត្រូវនិយមប្រើសំពត់បរទេស ត្រូវនាំគ្នាប្រើប្រាស់តែសំពត់ដែលជនជាតិយើងត្បាញដោយអំពោះរៀងខ្លួនឯង ។

ធ) យើងត្រូវរកគ្នាឯងជាអាជ្ញាកណ្តាល សម្រាប់ផ្សះផ្សាការវិវាទឈ្លោះទាស់នៃគ្នា មិនត្រូវធ្វើពាក្យប្តឹងទៅតុលាការទេ ។

ន) កិច្ចសំខាន់បំផុតដែលយើងត្រូវចាំជាប់ក្នុងហទយវត្ថុជានិច្ច គឺត្រូវសង្កត់សង្កិន កុំឲ្យចិត្តខឹងទោមនស្សផ្ទុះក្នុងសន្ដានឡើងបាន, ហើយមិនត្រូវប្រើពាក្យកំណាកម្នក់ឡើងនេះ ព្រមទាំងត្រូវឆ្លងដោយហសនចិត្តនូវអំពើកាចសាហាវដែលគេធ្វើរំលោភមកលើយើង ។

ធម្មនុស្សធម៌នឹងសភាពស្នេហាជាតិ

(៩ - ៣ - ១៩២១)

(មានត)

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(ភាគ៧)

តាមសិលាចារឹកខាងនោះ យើងអាចយល់បានអំពីបញ្ហាខាងសាសនានៃស៊ីវិលាយ្ខែរក្នុងសម័យនោះថា ព្រះមហាក្សត្រិយ៍ជាសាសនូបត្ថម្ភក: ជាអភិរក្សនូវប្រពៃណីសាសនាព្រមទាំងព្រះស្តូបចេតិយ ដែលពួកជនកជនបានបូជាថ្វាយចំពោះព្រះអង្គ, ព្រះមហាក្សត្រិយ៍ត្រូវធ្វើពលិកម្មនិងពិធីបុណ្យផ្សេងៗ តាមទំនៀមទម្លាប់ជូនទៅទេវតា ដើម្បីនឹងរក្សាសេចក្តីសុខដល់ប្រជាជន, ត្រូវការពារកុំឲ្យបច្ចាមិត្តខាងក្រៅចូលមកលុកលុយក្នុងព្រះរាជអាណាចក្រ ត្រូវរក្សាសន្តិសុខខាងក្នុងប្រទេស ដោយគ្រាស់បង្គាប់ឲ្យប្រជាជនប្រតិបត្តិតាមរបៀបសង្គម គឺការបែងចែកទៅតាមពួកក្រុមក្នុងសង្គម ។ គេមិនអាចដឹងបានដោយច្បាស់ប្រាកដថា តើព្រះមហាក្សត្រិយ៍ ជាមេកម្មសិទ្ធិលើដីក្នុងព្រះរាជអាណាចក្រទាំងមូលឬ ។ តែគេបានឃើញព្រះអង្គចែកដីទំនេរ ហើយទ្រង់បានប្រថាប់ព្រះសង្ខ្លាលើលិខិតដែលផ្ទាស់ប្តូរអសង្ហារិម: ។

បើតាមសង្កេតឃើញ: គេស្គាល់មិនច្បាស់លាស់នូវព្រះរាជចរិយាឫទ្ធិបុគ្គលិកលក្ខណៈនៃព្រះមហាក្សត្រិយ៍ ៦៥ អង្គ ដែលសោយរាជ្យសម័យអង្គរ ក្នុងរវាងសតវត្សទី ៩.ទៅសតវត្សទី ១៤ ។ មានតែព្រះ

មហាក្សត្រិយ៍អង្គមួយទេ ដែលគេអាចធ្វើនូវប្រវត្តិត្រមាំងប្រមូលវត្ថុធាតុ
នៃដីកោតព្រះអង្គបានគ្រប់យ៉ាង· គឺព្រះបាទជយវរ្ម័នទី ៧ ដែលទ្រង់
សោយរាជ្យរាវង ២០ ឆ្នាំ ខាងចុងសតវត្សទី ១២ ។ ព្រះមហាក្សត្រអង្គនេះ
ទ្រង់មានថាមកាពខ្លាំងមហិមា ព្រះទ័យលោកលន់ពន់ប្រមាណ, ព្រះរូប
ចំឡាក់នឹងព្រះរូបនៅក្បាច់ជញ្ជាំងដែលគេបានឃើញជាក់ស្តែងថា ព្រះ
អង្គពិតមែនតែមានព្រះជន្មាយុរាវង ៩០ ឆ្នាំ តែមានព្រះកាយពលមាំមួន
នៅឡើយ, កាលនៅតរុណវ័យព្រះអង្គបានរងទុក្ខលំបាកជាច្រើនឆ្នាំ ទ្រង់
ស្តេចទៅនៅកន្លែងប្រទេសជវៃ ឃ្លាតចាកពីព្រះអគ្គជាយា ដែលទ្រង់សព្វ
ព្រះពជហឫទ័យជាខ្លាំង· កាលព្រះអង្គវិលត្រឡប់មកកាន់ព្រះពជនិវេស-
ស្ថានវិញ បានទ្រង់តតាំងប្រាំងជណ្តើមពជ្យពីស្តេច ១ អង្គដែលមានចរិយា
នាំឲ្យប្រទេសជាតិទៅកាន់សេចក្តីវិនាស ។ ព្រះបាទជយវរ្ម័នបានស្រោច
ស្រង់ប្រទេសកម្ពុជាពីសង្រ្គាមចាម ហើយបានចាត់ចែងរៀបចំប្រទេស
ឲ្យបានស្ថានដ៏ឧត្តមផុត ទ្រង់ដួសដុលព្រះពជធានី, បានស្អាងប្រាសាទ
ជាយ័នទឹងព្រះវិហារពុទ្ធសាសនាជាច្រើន, បានស្ថាបនាមន្ទីរពេទ្យបាល
រោគចំនួន ១០២ ខ្នងទៅគ្រប់ខែត្រក្នុងព្រះពជអាណាចក្រ ហើយទឹង
សាលាសំណាក់តាមផ្លូវឆ្ងាយ ដែលជាផ្លូវគមនាគមន៍ភាកទង់គ្នាទៅកាន់
ក្រុងធំៗក្នុងប្រទេស ។

ចំពោះបុគ្គលិកលក្ខណៈនៃព្រះមហាក្សត្រិយ៍អតីតសម័យអង្គនេះ គេបានដឹងនូវរឿងរ៉ាវបន្តិចបន្តួចតាមរដ្ឋកាលនោះអំពីអត្ថន័យតាមនោះ ព្រោះពួកវិនិពន្ធកឯជាន់នោះច្រើនតែឯកើតដំកើងព្រះមហាក្សត្រិយ៍ជាទេពនិម្មិត, សេចក្តីព្យាយាមនៃពួកវិកឯសម័យនោះ គឺខំរចនាមហាកាព្យនោះឲ្យមានសភាពសម្បើមអស្ចារ្យ ដោយសរសើរអំពីកិច្ចការដែលធ្វើ អំពីព្រះរាជចរិយគុណធម៌ អំពីកិច្ចការស្នាព្រះហស្តគួរជាទីស្ងប់ស្ងែង, ទាល់តែព្រះមហាក្សត្រិយ៍ពេលនោះមានតេជានុភាពលើសពួកទេវតាដែលមានពណ៌នាកឯគម្ពីរវេណ្ហៃនោះទៅទៀត ឧទាហរណ៍ដូចព្រះឥន្ទ្រ គឺជាព្រះមេឃនាទ (Tonnerre) នឹងជាព្រះភុំណ (pluie) ព្រះអង្គបានធ្វើពលិកម្មកឯសាស្ត្រឹតមួយរយដង មានឈ្មោះតម្កាយថា "ព្រះមួយរយពលិកម្ម" ។ ដើម្បីនឹងសរសើរថាព្រះមហាក្សត្រិយ៍មានព្រះទ័យដ៏ថ្លាក្នុងសាសនា ពួកវាជកវិពោលថា "ព្រះអង្គទ្រង់បានធ្វើពលិកម្មមួយសែនដង, លើសព្រះឥន្ទ្រដែលបានធ្វើពលិកម្មតែមួយរយដង" ។ ឧទាហរណ៍មួយទៀត: ព្រះសិវៈបានទៅតាំងសីលនៅរមនីយដ្ឋានមួយ កឯទុកាសដែលព្រះអង្គបានពិចារណានូវធម៌ ទម្លួមានទីវារណធម៌គឺកាមឆន្ទមកគ្រប់សង្កត់នាំឲ្យព្រះអង្គត្រេកត្រអាលក្នុងកាមរាគដោយតណ្ហា បានយកព្រួញមួយចាញ់ចំហាយវត្ថុ, ព្រះសិវៈទ្រង់ព្រះក្រោធជាខ្លាំង បានធ្វើឲ្យតណ្ហាទៅជារុះដោយព្រះនេត្រសំឡឹងចំ ។

ដើម្បីនឹងសរសើរអំពីព្រហ្មចរិយធម៌នៃព្រះមហាក្សត្រិយ៍ ពួកវាជនិពន្ធ
ពោលថា " ព្រះសិវៈដែលមានជោគជ័យតែមួយជង ដោយយក
ចក្ខុប្រសាទសំឡឹងតណ្ហា គួរឱ្យស់អស់ព្រះមហាក្សត្រិយ៍ ដែលឈ្នះ
តណ្ហាគ្រប់ពេលគ្រប់ខណៈ ដោយព្រះអង្គបានផ្ទាញ់ផ្ទាល់ចំពោះអា-
រម្មណ៍ទាំងអស់ ។

ព្រះមហាក្សត្រិយ៍ជាព្រះអម្ចាស់ផែនដី, មានឋានន្តរខ្ពស់ជាងទេវតា
ឥន្ទ្រហ្មា, ព្រះអង្គទៅក្នុងព្រះរាជធានីៗ នេះ មិនមែនដូចសេចក្តីយល់នៃ
ពួកទេសចរ ដែលមិនពិនិត្យហ្មត់ចត់នោះទេ គឺជាព្រះរាជធានីមានកំពែង
ស្មាមក្តោះនឹងព្រះវិហារមានរូបភាពជាចេតិយ នៅចំពាក់កណ្តាលក្រុងគឺ
ជាចក្រវាឡតូច (Microcosme) ឬជារស្មីនៃចក្រវាឡធំ ដែលមានកងគម្ពីរ
សាសនាតណ្ហ (Cosmologie Hindoue) បានថ្លែង ។ សារៈសំខាន់នៃ
រាជាធិបតេយ្យ ដែលព្រះមហាក្សត្រិយ៍បានអប់រំជាជាតុមួយប្រកបដោយ
និច្ចតាធម៌ ឬអមតធម៌របស់អាត្មនោះ គេបានប្រមូលយកទៅបង្ហាញជា
រូបលិង្គមួយ ជាបដិមាករដែលធ្លាក់ប្រសិទ្ធិលិង្គព្រះសិវៈ រូបសម្មតិនេះ
គេយកទៅជាក់កងព្រះវិហារដែលសាងចំពាក់កណ្តាលក្រុងដែលគេស្មាន
ថានៅចំពាក់កណ្តាលលោក ។ លិង្គនេះគឺជាព្រះបរមនាមនៃព្រះដែល
រក្សាស្នូតច្បាត្រ (Dieu Roi ou dieu de la royauté) ជាឯកនាមនៃ
ព្រះមហាក្សត្រិយ៍នៅលើផែនដី គឺជារស្មីឬកំសួលនៃព្រះនោះប៉ុណ្ណោះ

ឃានធ្លាក់ចុះពីលើមេឃ ដោយមានព្រាហ្មណ៍ម្នាក់នាំយកមកថ្វាយនៅលើកំពូលចំពោះព្រះមហាកស្សបជាន្តេវាសិកនៃសន្តតិវង្ស ។ ការសម្ពន្ធកិច្ចព្រះមហាក្សត្រីយ៍ នឹងពួកទេវតានៅលើភ្នំពិសិដ្ឋជាទីគោរព (Montagne Sacrée) ដោយមានព្រះសង្ឃជាប្រធាន នោះត្រូវធ្វើពិធីសព្វឆ្នាំនៅព្រះវិហារមានរូបភាពជាចេតិយដែលស្ថិតនៅចំពាក់កណ្តាលក្រុង ដោយហេតុថាដូចជាភ្នំព្រះសុមេរុ ជាភ្នំដែលសង្កត់ពិភពលោកតាមជាតិឥណ្ឌានៅចំពាក់កណ្តាលចក្រវាឡ ហើយកំពូលឡើងចូលទៅកប់មេឃ មានស្នានភពតាំងពីអឌ្ឍយកូមិជាន់ទាបឡើងទៅ ក៏នៅនឹងចន្លុះកំនោះដែរ យ៉ាងណាមិញ, បូជនិយដ្ឋានដែលតាំងនៅកណ្តាលព្រះវិហារ ដែលនៅចំកណ្តាលព្រះរាជធានី ជាទីសម្រាប់ធ្វើសម្ពន្ធកិច្ចនៃមនុស្សលោកទៅនឹងពពួកទេវតាឥន្ទ្រព្រហ្ម ដោយមានព្រះមហាក្សត្រីយ៍ឬព្រះសង្ឃជាអ្នកបំពេញកិច្ចកង៏ពិធីនោះ ក៏យ៉ាងនេះឯង. ។

ព្រះមហាក្សត្រីយ៍នីមួយ ។ អង្គណាដែលមានពេលវេលាសំនោរបានច្រើនធ្យោចុះយកសាងព្រះស្តូបចេតិយចំពាក់កណ្តាលក្រុង ដល់ព្រះអង្គសោយព្រះទិវង្គតទៅ ព្រះអដ្ឋិនៃព្រះមហាក្សត្រីយ៍នោះគេត្រូវយកទៅបញ្ចុះនៅព្រះស្តូបនោះ ហើយមុននឹងសោយព្រះទិវង្គត ទ្រង់ត្រូវសម្មតិនាមមួយហើយប្រកាសថា ព្រះអង្គទ្រង់យាងទៅបដិសន្ធិនៅស្ថានណា ហើយព្រះវិញ្ញាណក្ខន្ធចូលទៅសន្តិតក្នុងព្រះឬទេវតាណា ។

ការសោយរាជ្យតវង្ស ត្រូវចាត់វិធីតាមរបៀបធម្មតា ចំពោះភេទ
ប្រុស តាមថ្នាក់ជាព្រះរាជបុត្រច្បង ; តែជួនកាលមានពិធីខុសពីរបៀប
នេះដែរ ។ បើពិចារណាទៅតាមសន្ធតិវង្ស ឃើញថាក្រសែខាងស្ត្រី
ច្រើនជាប់ខាក់ខ្លឹត ។ គ្នាក្នុងព្រះរាជវង្សានុវង្ស : ធម្មតាព្រះរាជាយាទ
គឺព្រះជេដ្ឋានៃព្រះកនិដ្ឋ ដូចមានពណ៌នាក្នុងករណីនៃទុត្តមត្រកូលខាង
ក្រោមនេះ ឬដូចក្នុងកុលសម្ព័ន្ធជាតិម៉ូយ (Tribus mois) ក្នុងសម័យ
បច្ចុប្បន្ន ។ ពួកជាតិម៉ូយប្រើសិទ្ធិមួយហៅថា មាតេយ្យកា (matriarcat)
គឺសិទ្ធិខាងមាតាជាប្រធានក្នុងការសម្រេចកិច្ចការទាំងពួង ។ បើតាម
សេចក្តីយល់ឃើញ : ព្រះរាជាគ្រាហិន (Usurpateurs) ដែលនឹងធ្វើព្រះរាជ-
សិទ្ធិឲ្យបានពេញលក្ខណៈតាមផ្លូវច្បាប់ ត្រូវធ្វើព្រះរាជសមរសជាមួយ
នឹងព្រះរាជបុត្រី ឬ ព្រះរាជយោសិត (une femme) នៃអតីតមហាក្សត្រ ។

នៅក្រោមបញ្ជាការនៃព្រះមហាក្សត្រ ព្រះរាជវង្សានុវង្ស នឹង
មន្ត្រីធំៗ ដែលមានវង្សត្រកូលខ្ពង់ខ្ពស់ ច្រើនជាអ្នកជាប់វង្សខាង
មហាក្សត្រ ដែលរួបរួមហៅថា អភិជន សិទ្ធិជាអនាធិបតេយ្យ (Oligarchie
Aristocratique) ដែលមានឋានន្តរស័ក្តិជាប់តវង្សត្រកូល ហើយមាន
មុខងារទៅតាមក្រសួងក្នុងប្រទេស ។

(មានត)

សព្ទានុក្រមបារាំងប្រែជាខ្មែរ

របស់គណៈកម្មការវប្បធម៌

ហ្លួងធិពន្ធមន្ត្រី ញ៉ុក-ថៃម រួបរួម

(តមក)

Démagogie = ចលាកិថុតិ (= ថុត) (ការបញ្ជោចក្បស្ត)

Chambre de Commerce = មន្ទីរពាណិជ្ជកម្ម

Chambre mixte de Commerce et d'Agriculture = មន្ទីរចំរុះពាណិជ្ជកម្មនឹងកសិកម្ម ។

Primata = បឋមតា

Duplicata = ទុតិយតា

Triplicata = តតិយតា

Couloir = របៀង

Membre correspondant = សមាជិកឆ្លើយឆ្លង

Correspondance = ការឆ្លើយឆ្លង, លិខិតឆ្លើយឆ្លង

(Le 31-12-48)

Scepticisme = លទ្ធិមជ្ឈធាតុ

Optimisme = លទ្ធិសុទិដ្ឋិ

Pessimisme = លទ្ធិទុទិដ្ឋិ

Nécessaire = ខានពុំបាន

Sceptique = អ្នកមជ្ឈត្តា

Optimiste = អ្នកសុទ្ធិដ្ឋិ

Pessimiste = អ្នកទុទ្ធិដ្ឋិ

(Le 4 1-49)

Patron de chaloupe breveté = នាយកប៉ាល់មានប្រកាសនីយប័ត្រ

Peintre = វិចិត្រករ

Préparateur diplômé = អ្នកផ្សំឱសថមានសញ្ញាប័ត្រ

Agents de vulgarisation agricole = ភ្នាក់ងារផ្សាយចំណេះកសិកម្ម (ដល់មហាជន)

Calculateur = អ្នកគិតលេខ

Copiste = អ្នកចម្លង

Correcteur = អ្នកកែតម្រូវ

Gestion = ការចាត់ចែង

Gardien chef d'aérodrome = មេឆ្មាំកាល់យន្តហោះ

Gardien = ឆ្មាំ

Gardien de paix = (ប៉ូលិស) សន្តិបាល

Identification de bétail = អ្នកកត់ត្រាសត្វ

Gérant = អ្នកចាត់ការ

Geste = កាយវិការ

Mouvement = ចលនា (ច:-ល៉:-ណា)

Position = តំរិយាបថ, ទីតាំង, ស្ថានភាព

Attitude = អាកប្បកិរិយា

Lecteur au son = អ្នកអានតាមសូរ

Ouvrier instructeur des écoles industrielles = កម្មករបង្រៀនសាលាឧស្សាហកម្ម

Identité = អត្តសញ្ញាណ

Titre d'identité = អត្តសញ្ញាណប័ណ្ណ (21-1-49)

Armurier = អាវុធិក

Caporaux-éclusiers = កាប៉ូរ៉ាលទំនប់ទឹក

Economiste = អ្នកសេដ្ឋកិច្ច

Agence de Représentation commerciale = ផ្ទះតំណាងហាងជំនួញនានា

Protection des intérêts des commerçants = ការពារផលប្រយោជន៍

Calqueur = អ្នកផ្ទាប់ចម្លង

Caporaux matelots = កាប៉ូរ៉ាលកម្មករនាវ

Chef d'entretien certifié = មេថែរក្សាមានវិញ្ញាបនប័ត្រ

Chef étalonnier = មេបង្គាត់សេះ

Résultat = លទ្ធផល (លា"ត - ធ: -)

Compositeur et héliographe des T. P. = អ្នកជំនឹងអ្នកសុរិយ
លេខនៃសាធារណការ ។

Planimétreur = អ្នកសមភូមិមាត្រ (-- ស: ម:-)

Restituteur de Cadastre = អ្នកឋតកែតម្រូវសុរិយោដី

Sapeur pompier = អ្នកលត់ភ្លើង

Teneur de carnet et croquisseur = អ្នកកាន់សៀវភៅនឹងអ្នកគូរវាស

Croquis = គំនូរវាស

Garçon de laboratoire et manipulateur = អ្នកបំរើកង់ទីពិសោ-
ធន៍នឹងអ្នកលាយថ្នាំ

Lithographe et relieur = អ្នកសិលាលេខនឹងអ្នកដេរសៀវភៅ

Maitre d'hôtel et chef-cuisinier = មេសណ្ឋាគារនឹងមេចុងភៅ

Vaguemestre - planton = វ៉ាក់ម៉ែស្ត្រនឹងឆ្មាំតុង

Agent de statistique local = ភ្នាក់ងារស្ថិតិស្រុកអាយ

Agent lecteur de marégraphe = ភ្នាក់ងារមើលកំតៃទឹក
ជោរ - នាច

Chaineur = អ្នកតាញវែងម៉ែត្រ

Etalonnier et traqueur = អ្នកបង្កាត់សេះនឹងអ្នកវាតទឹកដោះ

Facteur tram = ហ្វាក់ទ័រដនបទ

Guichet = បញ្ជរ

Guichetier = បញ្ជរបាល

Plombier = ជាងសំណរ

Saigneur et racleur de l'abattoir = អ្នកពិឃាដនឹងអ្នកកោសក្នុងទីសត្តឃាដ

Désinfecteur = អ្នករម្ងាប់មេរោគ

(Le 4 — 2 — 49)

Source = ប្រភព

Dossier = សំណុំរឿង, សំណុំការ

Congé = ការឈប់សំរាក

Autorité = អំណាច

Prendre Congé = សុំលាចាក

Donner Congé = បញ្ឈប់

Centraliser = ធ្វើមជ្ឈការ

(មានត)

រឿងព្រៃឆកុមា

លោក សាង - សារ៉ាត លេខានុការក្រសួងអ៊ីរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

(ត្រង់)

ក្នុងកាលដ៏កន្លងយូរណាស់មកហើយ នៅក្នុងប្រទេសតិក្កាថូ (Tekkatho) មានព្រះរាជបុត្រស្តេចមួយអង្គ ជាយុវអភិជន ទើងមានកូនប្រុសអ្នកកែម្នាក់នៅក្នុងប្រទេសនោះដែរ ដែលបានរៀនសូត្រជាមួយគ្នាក្នុងព្រះវិហារមួយ ជាមួយនឹងនារីកូនរបស់បុរសម្នាក់ទៀត ដែលជាអ្នកមានភោគសម្បត្តិយ៉ាងវិសេស ។

មានថ្ងៃមួយ នាងកំពុងចំឡងមេទន្លេញ ដែលគ្រូនាងបានទុកលើស្មឹកវិត ស្រាប់តែនាងធ្វើឲ្យធ្លាក់ដង្កៀបប្រាក់របស់នាង ហើយនាងទន្ទេញមើលទៅឃើញព្រះអង្គម្ចាស់នៅពីក្រោម នាងបានអង្វរព្រះអង្គម្ចាសនោះសូមឲ្យរើសដង្កៀបប្រាក់នោះឲ្យនាង ។ ឯព្រះអង្គម្ចាស់នេះកាលពីថ្ងៃមុន មានព្រះហឫទ័យស្រឡាញ់នាងជាពន់ពេក ប៉ុន្តែក្នុងឧកាសដ៏ប្រសើរនេះបែរជាទើសធ្វើកន្តើយវិញ, ទ្រង់គ្រាន់តែងើបមើលនាង ហើយមានព្រះរាជឱង្ការដោយញញឹមថា : "ខ្ញុំរើសដង្កៀបនេះជូននាងវិញបាន; ប៉ុន្តែខ្ញុំសុំធ្វើសន្យាថា ខ្ញុំស្រឡាញ់នាង សុំឲ្យ

នាងសន្យាថា ដល់កាលណានាងអញ្ជើញត្រឡប់ទៅផ្ទះរបស់ឪពុកម្តាយនាងវិញ សុំនាងទៅរកខ្ញុំក្នុងទីធ្លាវាំងសម្តេចព្រះមាតាខ្ញុំ រួចនាងត្រូវបណ្តាយទុកឲ្យខ្ញុំបេះបុប្ផាដ៏បរិសុទ្ធ គឺរូបរបស់នាងនេះកុំខាន” ។ នាងីនោះលុះឮដូច្នោះ ក៏គិតមួយស្របក់ នាងឥតមានចិត្តស្រើបស្រាលស្នេហាអ្វីបន្តិចក្នុងព្រះអង្គម្ចាស់នេះសោះ តែនាងក៏បានព្រមព្រៀងសន្យាទៅ ទាំងមានសេចក្តីក្តៅសរឿន ។ ឯព្រះអង្គម្ចាស់ក៏ទ្រង់ហុចដង្កៀបចុកនោះឲ្យទៅនាងវិញ; នាងទទួលយកហើយនិយាយឡើងថា: “សុំព្រះអង្គម្ចាស់ទ្រង់ជឿជាក់ចុះថា ខ្ញុំម្ចាស់នឹងធ្វើតាមកត្តិកាសញ្ញានេះមិនខាន” ។

លុះកាលណានាងរៀនចេះចប់សព្វគ្រប់ហើយ នាងក៏ត្រឡប់ទៅផ្ទះបិតាមាតាវិញ ។ ចំណែកខាងព្រះអង្គម្ចាស់ ស្តេចទ្រង់យាងត្រឡប់ទៅប្រទេសរបស់ព្រះអង្គវិញដែរ ។ កាលទ្រង់យាងទៅដល់ប្រទេស មិនយូរប៉ុន្មាន សម្តេចព្រះបិតារបស់ព្រះអង្គទ្រង់សោយព្រះទិវង្គតទៅ ហើយព្រះអង្គក៏បានឡើងសោយរាជ្យជាស្តេចផែនដីស្នងព្រះបរមរាជបិតា ។

ហេតុតែស្តេចផែនដីមានកិច្ចការនឹងអំណាចច្រើនពេក ព្រះអង្គទ្រង់ភ្លេចនាង ទាំងភ្លេចពាក្យសន្យាមុននោះបាត់ទៅ ។ ប៉ុន្តែចំណែកនាងឥតភ្លេចទេ ។ តាមទំនៀមលាប់ស្រុកនោះ ត្រូវឪពុកម្តាយនៃបុត្រីរើស

រកប្តីឲ្យកូនតាមចិត្ត, នាងក៏បានគោរពតាមវាចៀបនេះ ឥតល្អៀងបន្តិច ឡើយ ។ លុះដល់នាងរៀបមង្គលការរួច នាងស្រឡាញ់ប្តីណាស់ ប៉ុន្តែ ដោយជាប់កិច្ចសន្យានឹងដៀសវាងពុំបាន នាងក៏អង្វរសុំច្បាប់ប្តី ចំនួន ២-៣ ថ្ងៃ ហើយបានទាំងច្រាប់ប្តីថា នាងទៅសងចំពាក់ពាក្យសន្យាមួយ ដែលនាងបានធ្វើកាលពីមុន ។ ឯប្តីក៏បានសាកសួរនាងគ្រប់ប្រការ, នាងបាននិទានរឿងដែលកើតមានឡើង ក្នុងព្រះវិហារមួយនៅប្រទេស តិក្កាថូ ។ នាងនិយាយថា: "ខ្ញុំទៅទូលព្រះរាជាថា ខ្ញុំមានប្តីហើយ រួចមុខជាទ្រង់នឹងបំភ្លេចកិច្ចសន្យានេះពុំខាន" ។

ឯស្វាមីនឹកក្នុងចិត្តថា "ពាក្យសន្យាជាចំណងមួយខ្ជាប់ខ្ជួនណាស់ មិនថាតែអ្នកកាន់ព្រះពុទ្ធសាសនា ឬអ្នកមិនកាន់ទេ សឹងតែផ្តាច់ពាក្យ សន្យានោះមិនបាន" ហើយក៏យល់ព្រមឲ្យភរិយាចេញទៅ ។ ស្វាមី តើតទុក្ខជាខ្លាំង ប៉ុន្តែមានចិត្តសង្ឃឹមជាក់ថា: ភរិយាម៉ុខជាត្រឡប់មក វិញ ដោយឥតខូចខ្លួនជាណា ហើយនាងមុខជានៅស្រឡាញ់ខ្លួន ដដែលមិនខាន ។ នាងនុនក្បាលទាល់តែដល់ចុងដើងរបស់ស្វាមី រួច នាងទៅស្ថិតស្ថានខ្លួន ពាក់សុទ្ធតែមាសពេជ្រ នឹងសំលៀកបំពាក់ណា ដែលនាងស្រឡាញ់ជាងគេបំផុត ។ លុះស្រេចកិច្ចតែងខ្លួនហើយ នាងក៏ចេញដំណើរទៅ មានទាំងស្រីស្នំម្នាក់ទៅជាមួយផង ។

លុះទៅដល់ពាក់កណ្តាលផ្លូវ នាងជួបប្រទះនឹងមេចោរម្នាក់, មេចោរនេះ ចាប់ដៃនាងជាប់ ហើយនិយាយថា "អ្នកទៅណាមកណា? អ្នកមានកិច្ចការអ្វី? ម្តេចក៏ដើរតែម្នាក់ឯងក្នុងផ្លូវស្ងាត់យ៉ាងនេះ? ចូរអ្នកដោះសំលៀកបំពាក់នឹងគ្រឿងមាសពេជ្រទាំងអស់នោះមកឲ្យយើងឲ្យឆាប់ ។ ឡើង ប៉ុន្តែយើងខ្លាំងណាស់ តើអ្នកទៅណាបានជាតែងខ្លួនយ៉ាងដូច្នេះ?" ។ នាងឆ្លើយទៅវិញថា: "ឯសំលៀកបំពាក់នឹងគ្រឿងមាសពេជ្រទាំងអស់នេះ ជារបស់លោកហើយ ខ្ញុំមិនអាចការពារបានទេ ព្រោះខ្ញុំខ្សោយហើយខ្ញុំមកតែឯងឯង ឯហេតុដែលខ្ញុំដើរមកនេះ ខ្ញុំមិនលាក់អ្វីនឹងលោកទេ" ។ រួចនាងដំណាលរឿងប្រាប់មេចោរនោះថា "កាលណោះ ខ្ញុំនៅរៀនសាលាក្នុងប្រទេសតិក្កាថូ ខ្ញុំសន្យានឹងព្រះអង្គម្ចាស់មួយព្រះអង្គថា ដល់ខ្ញុំត្រឡប់ពីរៀនទៅផ្ទះឪពុកម្តាយខ្ញុំវិញ ខ្ញុំទៅជួបនឹងគ្នា បើសិនណាជាខ្ញុំមិនចាំពាក្យរបស់ខ្ញុំនេះទេ សុំកុំឲ្យខ្ញុំបានស្គាល់ស្ថានទេវតាឡើយ, ខ្ញុំបានសុំអនុញ្ញាតប្តីរបស់ខ្ញុំ ដែលឪពុកម្តាយខ្ញុំដាក់ឲ្យ ឯប្តីខ្ញុំក៏សុខចិត្ត រួចខ្ញុំធ្វើដំណើរមក ហើយស្រាប់តែមកជួបប្រទះនឹងលោកនេះ" ។ មេចោរលុះកាលណាបានឮដូច្នោះ ក៏មានចិត្តសរសើរជាខ្លាំងថា "នាងនេះបានគាន់សេចក្តីពិតត្រង់ណាស់ ហេតុដូច្នេះអញមិនត្រូវដាស់ផ្លូវនាង" ហើយបើកឲ្យនាងធ្វើដំណើរតទៅមុខទៀត ដោយឥតយកអ្វីពីនាងបន្តិចសោះ ។ ប៉ុន្តែមេចោរនេះ បានផ្តាំឲ្យនាងមក

រតនៈនិតាលណានាងត្រឡប់មកវិញ ។ ស្ត្រីនោះលុះបានរួចពីកណ្តាប់ដៃ
ចោរដូច្នេះ នាងបានដើរទៅដល់ដើមពោធិធំមួយដើមដែលមានស្លឹកជា
ច្រើន ។ ដើមពោធិនេះ មានទេវតាមួយអង្គក្បាលធំនៅលើមែកមួយធំ ។
ទេវតានេះ លើកដៃបញ្ជាប់នាង ហើយសួរថា "នាងទៅណា?" រួចគិត
ចុះមកដើម្បីចាប់នាង ។ នាងឆ្លើយថា : "ឧ មហាបតិត្រអើយ! ឯហេតុ
ដែលបណ្តាលឲ្យខ្ញុំមកដល់លោកនេះគឺហេតុយ៉ាងនេះទេ" រួចនាងនិទាន
រឿងដែលនាងប្រាប់មេចោររួចមកហើយនោះ ។ ទេវតាមានចិត្តកោត
សរសើរនាងជាច្រើន ហើយបានសុំឲ្យនាងមកជួបនឹងលោក កាលណា
នាងត្រឡប់មកវិញ រួចលោកក៏ឲ្យនាងធ្វើដំណើរតទៅទៀត ។

លុះនាងទៅដល់កំងស្តេច, ទេវតាដែលរក្សាស្វែតច្ឆត្របានបើក
ទ្វារចំហយ៉ាងធំឲ្យនាងចូល ដើម្បីជាកិច្ចគោរពដោយសារនាងកាន់ពាក្យ
សច្ចៈនេះ នាងបានទៅដល់ព្រះរាជាដោយឥតយឺតយូរឡើយ ។ ឯ
ព្រះរាជាទ្រង់ក្តៅចនារីដ៏មានរូបល្អឆើតឆាយ ដែលមានពាក់គ្រឿងយ៉ាង
ប្រពៃនេះ ហើយដែលជាគូកនរបស់ព្រះអង្គពីដើម ។ ស្តេចទ្រង់សួរ
ទៅនាងអំពីបំណងរបស់នាងដែលមកនេះ ។ នាងឆ្លើយដោយអឹមអៀម
ថា : "សូមទ្រង់ព្រះមេត្តាប្រោស! ខ្ញុំម្ចាស់នេះហើយដែលបានសន្យា
នឹងព្រះអង្គកាលដែលព្រះអង្គនៅរៀនជាមួយខ្ញុំម្ចាស់ នៅព្រះវិហារ
មួយក្នុងប្រទេសតក្កាថូ; កាលដែលខ្ញុំម្ចាស់ត្រឡប់មកដល់ផ្ទះវិញ ឪពុក

ម្តាយរបស់ខ្ញុំម្ចាស់ ចានរៀបចំទុកជាក់ឲ្យខ្ញុំម្ចាស់មានប្តី រួចខ្ញុំម្ចាស់ចានសុំច្បាប់ស្វាមីមកវាកព្រះអង្គ ដើម្បីបំពេញកិច្ចដែលចានសន្យានោះ" ។ ព្រះរាជាទ្រង់មានព្រះបន្ទូលទៅកាន់នាម៉ឺនសព្វមុខមន្ត្រីថា "នេះចានចំជាប្រសើរមែន ស្ត្រីនេះបង្ហាញឲ្យឃើញជាក់ស្តែងថានាង មិនក្វេចពាក្យសំដីរបស់នាង គួរឲ្យស្ងើចណាស់" រួចព្រះអង្គទ្រង់ព្រះរាជទានរបស់ល្អៗ ផ្សេងៗ ឲ្យនាង មានតង្កតង្កើអំពីពេជ្រយ៉ាងល្អិតនឹងចិញ្ចៀនដ៏ថ្លៃថ្លាជាដើម ហើយទ្រង់ត្រាស់បញ្ជារលេងថា "ខ្ញុំឲ្យរបស់អស់នេះទៅនាង ដោយសារនាងមានចិត្តត្រង់ល្អ ចូរនាងត្រឡប់ទៅវិញឲ្យចានជួបជុំជាមួយស្វាមីរបស់នាងចុះ, ឯពាក្យដែលយើងចានសន្យានោះ នឹងផុតរលត់ពីថ្ងៃនេះហើយ, សេចក្តីកោតសរសើររបស់ខ្ញុំមានស្មើសេចក្តីគោរពដល់រូបនាងដែរ" ។

លុះនាងទូលគ្រឿងមាសពេជ្ររួចស្រេចហើយ នាងមានចិត្តរីករាយជាពន់ពេក ហើយនាងត្រឡប់មកផ្ទះវិញ មានទាំងទាហានតាំងតែជល់មាត់ទ្វារគូមិរបស់នាង ។ នាងដើរទៅជល់ដើមពោធិ៍ហើយនិយាយបន្ទន់សំឡេងដ៏ពីរោះដូចសំឡេងនៃសត្វការវិក (Karaviek) ថា "លោកសំពន ឬលោកក្បាត់? ខ្ញុំចានបំពេញកិច្ចសន្យារបស់ខ្ញុំជាមួយព្រះករុណារួចស្រេចហើយ · ឥឡូវខ្ញុំត្រឡប់ទៅផ្ទះឪពុកម្តាយរបស់ខ្ញុំវិញ ប៉ុន្តែខ្ញុំចានសន្យានឹងលោកថា កាលណាខ្ញុំត្រឡប់មកវិញ ខ្ញុំចូលមក

រកលោក" ។ កន្លងពេលនោះ ទេវតាបានឮសំឡេងនាងក៏ចុះពីលើមែកពោធិ៍ខ្ពស់មកដល់ហើយក៏កោតសរសើរនាងជាអនេក ប៉ុន្តែលោកនិយាយថា: "ការណ៍នេះជាការណ៍លំបាកនឹងនិយាយណាស់ ព្រោះគេឲ្យនាងផុតទុក្ខអាសន្នរួចទៅហើយ ម្តេចឡើយក៏នាងចូលចិត្តមករងទុក្ខអាសន្ននេះវិញ?" ។ នាងនិយាយថា: "មែនហើយលោក ប៉ុន្តែបើខ្ញុំភ្លាចអាសន្ននេះឬភ្លាចស្លាប់ខ្ញុំមិនមករកវិញនោះ ដល់ថ្ងៃក្រោយទៅ ខ្ញុំនឹងធ្លាក់ខ្លួនកន្លងវណ្ណៈទុក្ខតាំង ៤ មិនខាន ដោយសារខ្ញុំមិនចាំពាក្យរបស់ខ្ញុំនេះ, កាលបើដូច្នេះ ខ្ញុំមិនអាចចូលកន្លងកពទេវលោកបានឡើយ" ។

ឯទេវតាដែលមានតណ្ហាកំពុងតែដុតកេលយ៉ាងខ្លាំងនោះ លុះបានឮនាងនិយាយយ៉ាងនេះហើយ ក៏បាត់ចិត្តលែងចង់ច្រាច្នារូបកាយដ៏ល្អរបស់នាង បែរទៅជាមានសន្តិចរិយាដ៏ប្រសើរវិញ ហើយយកដើងពានមាសមួយដែលមានលំអដោយក្បាច់រចនាផ្សេង ។ ឲ្យទៅនាង ដើម្បីជាអ្នាន់ដល់ចិត្តស្មោះត្រង់របស់នាង ហើយបានឲ្យពរសំពះសាធុការឲ្យនាងរស់នៅបានសុខសប្បាយយឺនយូរឆ្នាំផង រួចឡើងទៅលើមែកពោធិវិញ ហើយលើកដៃជាសញ្ញាឲ្យនាងធ្វើដំណើរតទៅមុខទៀត ។

ស្ត្រីនោះលុះចេញអំពីទីស្នាទេវតានេះទៅ នាងដើរតាត់តំរង់ទៅដល់កន្លែងមេចោរ ។ ពេលនោះ មេចោរកំពុងដេកលក់យ៉ាងស៊ប់ ។

នាងនិយាយថា: "ខ្ញុំមករកលោកដើម្បីលាងពាក្យសន្យារបស់ខ្ញុំ ឯដីវិតខ្ញុំ ត្រូវតាំងមាសពេជ្រតាំងអស់នេះ សឹងនៅក្នុងកណ្តាប់ដៃរបស់លោក ហើយ" ។ មេចោរស្រែកឡើងថា: "នេះបានចំជាចំឡែកមែន ខ្ញុំ ភ្លេចបាត់ហើយ, ណ្ហើយអ្នក! អ្នកបានកាន់ពាក្យសន្យាដ៏លំបាកពិត មែន, អំពើយ៉ាងនេះរកគ្មានទេក្នុងលោកនេះ, ហេតុដូច្នេះ បើសិនណា ខ្ញុំធ្វើបាបអ្នក ខ្ញុំប្រាកដជាមានទុក្ខមិនខាន សូមអ្នកអញ្ជើញចេញពីទី នេះដោយសួស្តីចុះ! សូមទេវតាតាមរក្សាអ្នកកុំបីឃ្លាតឡើយ!" ថាហើយ មេចោរក៏បើកឲ្យនាងទៅ រួចឈរមើលនាងតាល់តែជាប់កន្ទុយភ្នែក ថែម តាំងមានចិត្តកោតសរសើរនាងជាខ្លាំង ។

ក្នុងរវាងប៉ុន្មានថ្ងៃក្រោយមក នាងបានទៅដល់ផ្ទះស្វាមីរបស់នាង ដោយឥតមានរឿងហេតុអ្វីឡើយ ។ ឯស្វាមីនាងដែលទន្ទឹងចាំមើល ផ្លូវតាល់វេលានោះ លុះបានឃើញនាងត្រឡប់មកវិញដោយគ្មានខូចខ្លួន ប្រាណ ទឹងគ្មានគ្រោះថ្នាក់យ៉ាងនេះ ក៏មានចិត្តត្រេកអរសើចញញឹម ញញែមមិនជាប់ ។ លុះកាលណា បានស្តាប់រឿងដ៏ប្លែក ដែលនាង និយាយប្រាប់ដោយគ្មានរំលងត្រង់ណាសោះ បុរសស្វាមីបានសរសើរ នាងជាច្រើន ហើយបាននាំនាងទៅផ្ទះបិតាមាតារបស់នាង ។ ក្រោយ មកស្វាមីករិយារស់នៅដោយសុខសប្បាយជាមួយគ្នាទៅហោង ។

(មានត)

កណ្ឌទី ៦

អ្នកឧកញ៉ាវិបុលរាជសេនា ឆួ-កន ប្រែរៀបរៀង

(ត១ក)

សម័យនោះ ការរាជការក្នុងស្រុកគីជីវ ជាកម្មសិទ្ធិស្រែចជាច់ខាតលើអ្នកសៀវទាំងអស់ ។ ហាន់ហុកឃើញដូច្នោះក៏ភ្ញាក់ខ្លួនថា "អ្នកសៀវមកធ្វើដូច្នេះក៏ព្រោះតែអញគិតខុស ដែលអញទំនៅស្រុកនេះជាមួយនឹងអ្នកសៀវនោះ អំណោះតទៅមុខឃើញទឹងកើតអន្តរាយពុំខាន", លុះគិតដូច្នោះ ក៏កាត់ចិត្តចោលភរិយាបុត្រ រត់តែម្នាក់ឯងទៅនៅស្រុកតាន់លីវ ។

ឯកងស៊ុនចានកាលបានដឹងថា អ្នកសៀវបានស្រុកគីជីវហើយ ក៏ឲ្យកងស៊ុនអួតជាប្អូនទៅសួរអ្នកសៀវថា តើនឹងព្រមបែងចែងព្យរបស់មនុស្សប្រុសស្រីទឹកដីក្នុងស្រុកគីជីវពាក់កណ្តាល តាមសំបុត្រសញ្ញាធ្វើទុកនោះឬទេ? ។ អ្នកសៀវតបថា ឲ្យទៅអញ្ជើញកងស៊ុនចានជាបងអ្នកមកចុះនឹងនិយាយគ្នា ។ កងស៊ុនអួតក៏លាត្រឡប់ទៅវិញ បានពាក់កណ្តាលផ្លូវ ស្រាប់តែជួបនឹងកងទ័ពលើកផ្លូវមកទាំងសន់ទាងហើយស្រែកថា "អញជាទាហានមហាឧបរាជ," ថាហើយក៏លើកដង្ហាញ់ត្រូវកងស៊ុនអួតស្លាប់នៅទីនោះ; បណ្តាទាហានកងស៊ុនអួតដែលមកជាមួយក៏រត់រួចទៅដល់ស្រុកហើយយកសេចក្តីទៅជំរាបកងស៊ុនចានតាមការណ៍ ។

កងស៊ុនចានខឹងខ្លាំងណាស់ក៏ថា វេលានេះអ្នកសៀវមានកត្តូតែឡប់ចាន
ស្រុកគីជីវដោយស្រួលហើយ ហេតុម្តេចគេចប្រើកលឧបាយឲ្យតាហាន
មកចាំបង្កប់សម្លាប់កងស៊ុនអ្នកឯអ្នក ហើយកែងថាជាតាហាន
តាំងតុ: អ្នកសៀវធ្វើដូច្នេះមុខតូរឲ្យស្តាយណាស់ បើអញសងសឹក
អ្នកសៀវមិនបានទេ ខ្លួនអញមិនពេញជាកូនប្រុសជាតិជាតាហាន
ឡើយ ។ តមក កងស៊ុនចានក៏រៀបចាត់ចែងតាហានគេណាមកអស់ពី
ក្នុងស្រុក លើកទៅចាំជំនឹងអ្នកសៀវ ។

ឯអ្នកសៀវដឹងការណ៍ជាកងស៊ុនចានលើកតាហានមកដល់ព្រំខែត
ហើយក៏កេណ្តាតាហានលើកជាក្បួនទ័ពចេញទៅទួលនៅមាត់ស្ទឹងកួនហួ
ត្រើយខាងលិច ស្ទឹងនោះមានស្ពានថ្មសិលាធ្លងវែងតៅ ។ កងស៊ុន
ចានឃើញទ័ពអ្នកសៀវលើកមក ក៏ដឹះសេះឆ្លងស្ពានទៅហើយស្រែក
ហៅអ្នកសៀវថា ខ្លួនឯងនេះចំជាមនុស្សខ្ជិតខ្ជិលមកល្បងបញ្ឆោតអញ
យកប្រយោជន៍ខ្លួន ហើយថែមធ្វើឧបាយកលសម្លាប់ប្អូនអញទៀត ។
អ្នកសៀវក្តៅដូច្នោះក៏ឡើងដឹះសេះបរឆ្លងស្ពានទៅ ប្រទល់មុខនឹងកងស៊ុន
ចានហើយឆ្លើយថា ហានហ៊ុកជាមនុស្សឆោតល្ងង់មិនដឹងគិតអ្វីសោះ
លើកស្រុកគីជីវឲ្យយើងទាំងអស់ជាស្រេចហើយ ត្រូវការអ្វីអ្នកឯងមក
លាដៃតាមយកចំណែកឧទេដូច្នេះមិនគួរឡើយ ។ កងសុនចានតបថា
ចៅហ្វាយខែត្តទាំងអស់ប្រឹក្សាមូលមាត់គ្នា ព្រោះឃើញថាឯងជាមនុស្ស

សុចរិតពិតត្រង់ ទើបតាំងឲ្យធ្វើជាមេទ័ពធំដូច្នេះ ឥឡូវអញឃើញចិត្ត
គំនិតឯងប្រហែលគ្នានឹងសត្វតិរច្ឆាន មិនគួរមកនៅក្នុងស្ថានមនុស្សលោក
ឲ្យចង្អៀតទេ ។ អ្នងសៀវឆឹងណាស់ក៏សួរគាហានថា នរណានឹងយក
អាសាចាប់កងស៊ុនចានមកឲ្យយើងបាន ។ ប៊ុនទិវធ្វើយសុំខ្លួនហើយពាំខ្លួន
ជិះសេះឆ្លងស្ពានទៅ, កងស៊ុនចានក៏ញាក់សេះថយទៅឈរដល់ផែនដី,
ប៊ុនទិវក៏បរសេះតាមទៅចូលប្រយុទ្ធគ្នាបាន ៩ ឬ ១០ ស្នៀត, កងស៊ុនចាន
កំឡាំងខ្សោយក៏ថយសេះទៅបំបាំងនឹងពួកគាហាន, ប៊ុនទិវក៏ដេញបំពាន
ទៅទៀត គាហានចាប់ពុំឈ្នះក៏ប្រាសបែកបាក់ខ្ចាត់ខ្ចាយអស់, នៅមាន
គាហានកងស៊ុនចាន ៤ នាក់ទៀត បំផ្លាយសេះចូលមកតយុទ្ធនឹងប៊ុនទិវ
ចាក់នឹងលំពែងត្រូវគាហានម្នាក់ធ្លាក់ពីលើសេះស្លាប់, គាហាន ៣ នាក់
ញាក់សេះរត់ថយចេញ, ប៊ុនទិវដេញតាមទៅទៀត ជិតចាន់កងស៊ុន
ចាន ក៏លើកលំពែងប្រហែនឹងចាក់, កងស៊ុនចានកន្ត្រាក់សេះបំផ្លាយរត់
ចេញយកាត់ព្រៃទៅច្រើនតំបន់, ប៊ុនទិវក៏តាមប្រកិតពីក្រោយហើយ
ស្រែកថា អាឯងចុះពីលើសេះឲ្យធាប់ អញនឹងចាប់យកុំទាំងរស់ បើរត់
ដោះ អញនឹងចាក់ឲ្យស្លាប់ឥឡូវ ។ កងស៊ុនចានក៏បំផ្លាយសេះទៅទៀត
ឯធនឹងអាវុធក៏របូតធ្លាក់ពីដៃ មួកក៏ធ្លាក់ពីលើក្បាល លុះរត់ទៅដល់
ដើមកំមួយកន្លែង សេះក៏ជំពប់នឹងដុំថ្មដួលចុះ, ប៊ុនទិវលើកលំពែង
នឹងចាក់ ទទួលមានគាហានម្នាក់ឈ្មោះដូង្គ ជិះសេះបរស្ទុះមកស្ទាក់

ព័ម្ភ១ប៊ុនទិវជាប់ តាំងតែប្រកាប់គ្នានឹងប៊ុនទិវ, ឯកងស៊ុនចានក៏ស្ទុះ
រត់រួចទៅពួននៅកៀនភ្នំនោះ, ដូឡុងនឹងប៊ុនទិវតយុទ្ធគ្នាដល់ ៦០ ស្នៀត
មិនចាញ់មិនឈ្នះ ។ លោះនោះមានពួកទាហានកងស៊ុនចានដែលបែក
ទ័ពត្រឡប់លើកគ្នាមកទាន់ ក៏ចូលទៅឡ្អមព័ទ្ធប៊ុនទិវនៅក្នុងចំណោម,
ប៊ុនទិវឃើញថានឹងចាញ់ប្រៀបគេ ក៏ញាក់សេះទំលុះទំលាយរត់ចេញ
ទៅបាន ។ កងស៊ុនចានក៏ចេញមកពីកៀនភ្នំឃើញទាហាននោះមានខ្នង
ខ្ពស់ប្រហែល ៦ ហត្ថ មុខមាត់សំបើមចិញ្ចើមក្រាស់ភ្នែកក្រឡេតក៏សួរថា
អ្នកឈ្មោះអ្វី? បានមកជួយជីវិតយើងពេលនេះ យើងមានសេចក្តីអរគុណ
ជាច្រើន ។ ដូឡុងបន្ទន់ខ្លួនតបគំនាប់ហើយថា ខ្ញុំបាទឈ្មោះដូឡុង
សៃតៀវ នៅស្រុកសៀងសាន់ ពីមុននោះខ្ញុំបាទទៅនៅនឹងអ្នកសៀវម្ខាង
តែខ្ញុំបានឃើញថាអ្នកសៀវជាមនុស្សកំណាចអាក្រក់ណាស់ មិនជា
មនុស្សសុចរិតទៀងត្រង់ទេ ខ្ញុំក៏រត់មកដោយបំណងទីពឹងនៅនឹងលោក
ទទួលខ្ញុំបាទចេញមកជួនជាជួបនឹងលោកនៅទីនេះ ។ កងស៊ុនចានក៏
មានសេចក្តីត្រេកអរណាស់ ទើបឡើងជិះសេះមួយម្នាក់ ហើយនាំដូឡុង
នឹងទាហានទាំងពួងលើកត្រឡប់ទៅបន្ទាយត្រើយស្ទឹង ។

ឯអ្នកសៀវដល់ដឹងដំណឹងថា កងស៊ុនចានលៃទៅចូលបន្ទាយ
ហើយ ឲ្យក៏ចាត់ជាន់លៀង, ប៊ុនទិវឲ្យលើកទាហានជម្រាក់មួយពាន់ បំបែក
ជា ២ ផ្លូវ ទៅបង្កប់នៅដើមស្ពាន បានសន្មតគ្នាថា "បើឮសំឡេងផាវជា

សញ្ញាហើយ ឲ្យបាញ់ចម្រុះទាំងធ្វេងស្តាំតំរង់ទៅបន្ទាយ" ហើយចាត់ឲ្យចុកយីលើកទាហានធ្នូ ៨០០ នឹងទាហានឡវែមួយម៉ឺនជ្រាបាន់ ជាកងមុខចេញច្បាំងបញ្ឆោត, ឯអ្នកសៀវលើកទាហានជ្រាមុឺនជាទ័ពហួង លុះចាត់ស្រេចការហើយក៏ឲ្យទាហានទាំងអស់សម្ងំនៅស្ងៀម ។

ខណៈនោះ កងស៊ុនចានចាត់ឲ្យយ៉ាំកុងលើកទាហានជាកងមុខ ហើយបំបែកជាបែកធ្វេងស្តាំ តែដូច្នេះនោះ កងស៊ុនចានពុំទាន់ស្គាល់ចិត្ត ក៏ចាត់ឲ្យលើកទាហានជាកងក្រោយ ហើយឲ្យយកទង់សរសេរជាភួអក្សរដោតឡើង អក្សរនោះថា "ឈួយគី" ប្រែថា "ទង់សម្រាប់មេទ័ព" ហើយលើកទាហានតាំងជាក្បួនទ័ពនៅលើស្ពានសិលានោះស្រេចហើយឲ្យទាហានទាំងពួងវាយឃ្លោះវាយគងទួងកាំរ ហ៊ោកញ្ជ្រៀវអឺងកងតាំងពីព្រឹកដល់ថ្ងៃរសៀល, ទាហានកុងកងទ័ពអ្នកសៀវក៏នៅសម្ងំស្ងៀម, ឯយ៉ាំកុងជានាយកងទ័ពមុខក៏លើកទាហានទន្ទ្រានចូលទៅ ។

ខាងទ័ពអ្នកសៀវគឺចុកយីជានាយកងទ័ពមុខ បានលើកទាហានថយបញ្ឆោតទៅផុតចុងស្ពាន ឃើញបានការហើយ ក៏អុជផាវជាសញ្ញាឡើង ឯពួកទាហានធ្នូ ៨០០ នាក់បាញ់ចំរុះតម្រង់មក ។ យ៉ាំកុងយល់ថានឹងគ្រាគ្រេតលំពុំបានក៏ដេញទាហានថយក្រោយទៅដល់ដើមស្ពានវិញ ។ ចុកយីឃើញបានការ ក៏បំផាយសេះរាំផាវចូលតយុទ្ធនឹងយ៉ាំកុងបាន ៥ ស្នែត ហើយយកផាវគាប់យ៉ាំកុងធ្លាក់ពីលើសេះស្លាប់, ទ័ពកងស៊ុនបានបែកធ្វេងនឹងស្តាំក៏លើកគ្នាចូលព្រួតទាំងសងខាងមកទៀត ។

ខណៈនោះ ដាន់លៀងនឹងប៊ុនទៀ ក៏លើកទាហានឆ្លងស្ពានដែលបង្កប់នៅដើមស្ពាននោះចាញ់ដួចម្រុះពីក្រោយ ទាហានកងស៊ុនចានចូលជួយពុំបាន ចុកយីក៏ដេញទាហានចូលប្រគាប់សង្កៀរទៅដល់កងស៊ុនចាន ហើយយកក្រប៊ីកាប់ដងខ្នងជ័យចាក់ធ្លាក់ចុះ កងស៊ុនចានទប់ពុំឈ្នះ ក៏ត្រឡប់ថយទ័ពចុះពីស្ពានវត់ទៅ ចុកយីដេញជិតប្រកិតចាក់កាប់សម្លាប់ទាហានកងស៊ុនចានជាច្រើនលើស ទាហានដែលនៅសល់តាំងប៉ុន្មានក៏វត់បែកចាក់ខ្ចាត់ខ្ចាយអស់ទៅ ។

ពេលនោះដូឡុងជានាយទ័ពក្រោយ ឃើញទ័ពមុខនឹងទ័ពហួងបែក ក៏បំផាយសេះដែកចូលទៅតទល់នឹងចុកយីបាន ៥ ស្នែត, ដូឡុងយកខ្លួនចាក់ចុកយីធ្លាក់ពីសេះស្លាប់ ថែមចូលដេញកាប់សេនាទាហានចុកយីវាក់រីកណ្តាលហួងទ័ព ដូឡុងឆាកទៅកាប់ខាងឆ្វេងៗ ក៏បែក ឆាកទៅកាប់ខាងស្តាំៗ ក៏ចាក់ នឹងរកអ្នកឯណាតទល់ពុំបាន, កងស៊ុនចានបានឃើញដូច្នោះក៏លើកទ័ពត្រឡប់មកជួយដូឡុង កងទ័ពចុកយីក៏បែកអស់ទៅ ។

កាលចុកយីកាប់ដងខ្នងសម្លាប់មេទ័ពចាក់ កងស៊ុនចានបែកទ័ពត្រឡប់ទៅក្រោយនោះ, មានទាហានម្នាក់ទៅប្រាប់អ្នកសៀវភៅថា កងទ័ពចុកយីបែកហើយ ។ អ្នកសៀវភៅត្រកអរណាស់ ក៏នាំគ្នាទៅហងនឹងទាហានកាន់ខ្លួនប្រមាណ ៣០០ កាន់ធ្នូ ៥០ ចេញមកសំឡឹងមើលគ្រែបន្ទាយ

ឃើញសមដូចពាក្យទាហាននិយាយ អ្នកសៀវភៅនេះដែរសើចហើយថា កងស៊ុនចាននោះជាមនុស្សមិនចំណានក្នុងការសង្គ្រាមសោះ យើងគ្រាន់តែច្បាំងប៉ុណ្ណោះបែកទ័ពទៅហើយ ។ អ្នកសៀវភៅមានសេចក្តីប្រមាទធ្វេសការ ។

ក្រោយនោះដូឡុងនឹងកងស៊ុនចាន ស្រុតលើកទាហានធ្វើស្ពានតាមទៅទៀត លុះឃើញពួកទាហានអ្នកសៀវ ដូឡុងក៏បរសេះសុះតាមទៅចាក់កាប់សម្លាប់ទាហានទាំងនោះពិការជាច្រើន ឯកងស៊ុនចានក៏ស្រុតលើកទាហានខ្លួនស្លាក់ដុំវិញទ័ពអ្នកសៀវ ហើយបាញ់ធ្នូចម្រុះទៅទៀត ។

តៀនហង៍ឃើញដូច្នោះក៏យល់និយាយនឹងអ្នកសៀវថា គ្រានេះយើងមុខជាខូចការនឹងស្រួរហើយ លោកចូរអែបទៅខាងក្បែរបន្តិចរត់ទៅចុះ ។ អ្នកសៀវតបថា “តើតមកជាជាតិទាហានហើយមិនស្រួរខ្លាចស្លាប់ទេ”, ថាហើយក៏ស្រែកហៅទាហានឲ្យចូលច្បាំងប្រកាប់ជាប់គ្នា ពួកទាហានទាំងសងខាងក៏ប្រញាក់ប្រញូនទៅវិញទៅមក ។ ជាន់លៀង ឃើញកងស៊ុនចាននឹងដូឡុងច្បាំងជាប់ដៃគ្នានឹងទាហានខាងខ្លួន ក៏ដេញបញ្ជូនទាហានវាយខ្លួនពីខាងក្រោយថែមទៅទៀត ។ ទាហានអ្នកសៀវដែលលើកទៅបញ្ឆោតហើយបែកទៅនោះ លុះក្រឡេកឃើញទ័ពកំពុងប្រកាប់ជាប់ដៃគ្នា ក៏វាមកព្រួតខ្លួនពីខាងម្ខាង ។ ដូឡុងច្បាំងលក់ក្នុងកងទ័ពដែលខ្លួនដុំវិញ ឃើញថានឹងការពុំឈ្នះ

ចំណាយចេញឆ្ងង់ស្ពានរួចទៅ ។ អ្នកសៀវនឹងងាន់លៀង កំលើក
ទាហានទន្ទ្រានតាមទាល់តែផុតស្ពាន បានចាក់កាប់សម្លាប់កងទ័ពកងស៊ុន
បានធ្លាក់ពីលើស្ពានស្លាប់ជាច្រើន ហើយដេញកងស៊ុនបាននឹងដួងឡុង
ហួសស្ពានទៅទៀត ប្រហែលចំងាយផ្លូវ ៥០ សិន ។

វេលានោះ ឡៅពីដឹងដំណឹង ទើបនាំកូនអ៊ូ តៀវហ៊ុយ នឹង
ទាហានទាំងពួងលើកមកជួយកងស៊ុនបាន កាលគ្រឡេកឃើញទ័ព
អ្នកសៀវលើកដេញកងស៊ុនបានបានទៅជល់ដើងភ្នំ, ឡៅពី កូនអ៊ូ
តៀវហ៊ុយ នាំគ្នាបំផាយសេះសុះទៅស្លាក់ពីមុខសេះអ្នកសៀវ។ គ្រឡេក
ឃើញឡៅពី កូនអ៊ូ តៀវហ៊ុយ នៅទទឹងពីមុខ កំតក់ស្តុតស្ទើរនឹងបាត់
ស្មារតី ជាវដៃលកាន់នៅដៃក៏របូតធ្លាក់អស់នៅតែខ្លួនទេ ហើយបែរ
ត្រឡប់សេះសុះថយក្រោយទៅចូលបន្ទាយ ។

ឯកងស៊ុនបានឃើញឡៅពី កូនអ៊ូ តៀវហ៊ុយ មកជួយដូច្នោះ
ក៏មានសេចក្តីសោមនស្សពន់ពេក សាកសួរគ្នាហើយក៏ថយចូលទៅក្នុង
បន្ទាយ ។ កងស៊ុនបាននិយាយប្រាប់ឡៅពីថា កាលគ្រាប៉ុនទីវ
ជាទាហានអ្នកសៀវដេញខ្ញុំមក កុំតែបានដួងឡុងចេញមកជួយ ខ្ញុំក៏មិន
បានគង់ជីវិតទេ ពេលនេះអ្នកសៀវដេញខ្ញុំមកម្តងទៀត បើកុំតែបានអ្នក
មកជួយខ្ញុំ។ ក៏អន្តរាយជីវិតប្រាកដណាស់ ។

(ម្ភៃឆ)

ភាគទី ២

សម័យនគរធំ

ឧកញ៉ាទេពពិទូរ ឈឹម - ក្រសែម រៀបរៀង

(ត្រួត)

ព្រះចោទជយវរ្ម័នទី ៥

ព.ស. ១៥១១ - ១៥៤៤, គ.ស. ៩៦៨ - ១០០១

កាលព្រះបាទជេន្ទ្រវរ្ម័នទី ២ សោយទិវង្គតហើយ, ព្រះជយវរ្ម័ន ភជនុរស បានឡើងសោយរាជសម្បត្តិនៅក្រុងយសោធរបុរៈតមក ទ្រង់ព្រះនាម **ព្រះបាទជយវរ្ម័ន** ភាប់ជាទី ៥ ។ ទ្រង់មានព្រះអគ្គមហេសី ព្រះនាម **ឥន្ទ្រលក្ស្មី** មានព្រះរាជនុរស ១ អង្គព្រះនាម **ទិវាករ** ។

ការដែនដី – ក្នុងរជ្ជកាលនេះ ការគ្រប់គ្រងព្រះរាជអាណាចក្រ ទាំងមូលនៅតំបន់ជួបដើម ។ ក្នុងផ្លូវរដ្ឋបសាសនោបាយ ព្រះបាទជយ-វរ្ម័នទ្រង់មានការសម្ព័ន្ធភាក់ទង់ទៅនឹងព្រះមហាក្សត្រិយ៍ផ្សេងៗ ដែលមានព្រះរាជអាណាចក្រនៅតាមជួរទន្លេគង្គាក្នុងដែនឥណ្ឌា ជាច្រើនប្រទេស, ទ្រង់បានយកព្រាហ្មណ៍ជាជម្ងាក់អំពីក្រុង ខេលហ៊ី មកជាទីប្រឹក្សាការ ផ្សេងៗ ហើយទ្រង់ព្រះមេត្តាប្រោសព្រះរាជទាន នូវព្រះកនិដ្ឋភគិនី (មិនប្រាកដព្រះនាម) ឲ្យជាភរិយាព្រាហ្មណ៍នេះផង ។

ការសាសនា - ព្រះចាទជយវរ្ម័ន ទ្រង់និយមរាប់អានទាំងសាសនាព្រាហ្មណ៍ ទាំងព្រះពុទ្ធសាសនា ។ ផ្នែកសាសនាព្រាហ្មណ៍ ព្រះអង្គបានរាជបុរោហិតឈ្មោះ **សិរវៃរ៉ែវល្យ** ដែលជាប់អំបូរវង្សអំពីរាជបុរោហិតក្នុងរជ្ជកាលមុន ។ នឹងរាជបុរោហិតថ្មីដែលមកពីក្រុងខេលហ៏ ជាទីប្រឹក្សាការ នឹង ធ្វើពិធីផ្សេង ។ ថ្វាយ ។ ផ្នែកព្រះពុទ្ធសាសនា ព្រះអង្គបានសេនាបតី ១ នាក់ឈ្មោះ **ប្ញទ្ធិបណ្ឌិត** (ព្រឹទ្ធិបណ្ឌិត) សឹងជាអ្នកច្បាស់ម្នួយជាទីប្រឹក្សានឹងជាអ្នកចាត់ការផ្សេង ។ ក្នុងផ្នែកនេះ ។

ការសាងវត្តស្លាង - តាមដែលបានស្រាវជ្រាវក្នុងវេលានេះ ប្រាកដថា ព្រះចាទជយវរ្ម័នអង្គនេះ ទ្រង់បានសាងប្រាសាទសិលា ដែលហៅថា ប្រាសាទព្រះខ័ន នៅក្នុងស្រុកកំពង់ស្វាយ (គឺនៅក្នុងទីរួមខេត្តកំពង់ធំក្នុងបច្ចុប្បន្ននេះ) ប្រាសាទនេះគង់រូបរាងនៅជាឥស្តូតាងដរាបដល់សព្វថ្ងៃនេះ ។ ក្រៅពីនេះ ព្រះឃ្លាំង (គឺប្រាសាទឃ្លាំង) ខាងជើងនឹងប្រាសាទកែវ (ដែលពាក្យសាមញ្ញហៅថា ប្រាសាទតាកែវ) នៅខាងកើតខ្ទៀបព្រះមហានគរ ក៏ប្រាកដថា សាងឡើងក្នុងរាងរជ្ជសម័យនេះដែរ, ទាំងបានទ្រង់សាងវត្តព្រះឥន្ទ្រកោសី នៅក្នុងតំបន់សៀមរាបសព្វថ្ងៃនេះ ។

ព្រះចាទជយវរ្ម័នទី៥ស្ថេចស្ថិតនៅក្នុងរាជសម្បត្តិបាន ៣៣ឆ្នាំក៏សោយទិវង្គត ។ រាជបណ្ឌិតថ្វាយព្រះនាមព្រះបរមសពថា **បរមវិរលោក** ។

ពួកព្រះពាជវង្សដែលបានសោយពាជ្យតៗមកអំពីព្រះបាទឥន្ទ្រវរ្ម័ន ទី ១ នៅក្រុងហរិហរាល័យ បានផុតវង្សត្រឹមព្រះបាទជយវរ្ម័នទី ៥ នេះ តអំពីនេះទៅ ជាវង្សដទៃ ។

ព្រះចាន ឧទយាទិត្យវរ្ម័នទី ៣

ព.ស. ១៥៤៤ - ១៥៤៥, គ.ស. ១០០១ - ១០០២

កាលព្រះបាទជយវរ្ម័នទី ៥ សោយទិវង្គតហើយ, បើតាមច្បាប់ពាជសន្ដតិវង្ស ពាជសម្បត្តិកន្ដរកាលនោះ ត្រូវបានទៅព្រះ **ទិវាការ** ជាពាជនុសេដ្ឋភាយាទរបស់ព្រះបាទជយវរ្ម័នទី ៥, តែនេះមិនបានប្រព្រឹត្តទៅតាមគន្ធន៍ច្បាប់ទម្លាប់ទេ ដោយវេលានោះមានព្រះពាជវង្ស ១ អង្គ ព្រះនាម **ឧទយាទិត្យវរ្ម័ន** ជានុសេទី ២ របស់ព្រះពាជបតិវរ្ម័ន ជាក្សត្រិយ៍ចុងក្រៃ បានតាំងខ្លួនជាគូបដិបក្ខនឹងព្រះទិវាការដើម្បីពាជសម្បត្តិ ហើយបានលបលើកទ័ពទៅវាយឆក់ព្រះទិវាការចេញ ក្នុងពេលដែលទ្រង់នឹងទ្បើងគ្រងពាជបល្ល័ង្ក ហើយខ្លួនក៏ទ្បើងគ្រងពាជបល្ល័ង្កជំនួស មានព្រះបរមនាមថា **ព្រះបាទឧទយាទិត្យវរ្ម័ន** តទៅជាទី ១ ។

ជាធម្មតា តែកាលណាមានការណ៍ចះបោកក្នុងប្រទេស កាលនោះតែងមាននានាប្រទេសដែលនៅជិតខាងឆ្នៀងក្អែកមើល ។

គ្រានោះ ក្សត្រិយ៍ខ្មែរពាជមន អ្នកគ្រប់គ្រងនគរលំកូន ព្រះនាម **ត្រាពក** ឬ **អត្រាពក** បានលើកទ័ពមកវាយនគរលវបុរៈ (លវេ)

របស់ខ្មែរ ដែលមានព្រះមហាឧបរាជព្រះនាម **ឧប្ប៊ីតបក្រវត្តិ** ឬហៅខ្លីថា **បក្រវត្តិ** ជាអ្នកគ្រប់គ្រង ។ ព្រះបក្រវត្តិបានលើកទ័ពចេញតស៊ូនឹងបច្ចាមិត្តពេញទំហឹង តែតាមដែលអ្នកថ្មីកការពិនិត្យទៅឃើញថា ព្រះបក្រវត្តិមិនអាចនឹងទប់ទល់កំឡាំងបច្ចាមិត្តបាន, វេលានោះ ខាងក្រុងធំក៏មិនឃើញលើកទ័ពទៅជួយ ប្រហែលជាខាងក្រុងធំនោះមិនទាន់សាន្តត្រាណរៀបរយទៅឡើយ ។ ព្រះបាទឧទយាទិត្យវរ្ម័នគោងប្រយ័ត្នការផ្ចាល់ព្រះអង្គជាមមាញឹក ទើបមិនបានលើកទ័ពទៅជួយ ឬមួយមិនបានជ្រាបហេតុការណ៍នេះទេ ក៏សឹងតែថាបាន ។

ទុកជាភ័ព្វធំ ទោះបីខាងក្រុងធំមិនបានអំពល់ផងក៏ដោយ តែជោគជាតារបស់លង្វបុរៈមិនទាន់ដល់កម្រិតរលត់ ដំណឹងនេះក៏ជ្រួតជ្រាបទៅដល់ព្រះសូរ្យវរ្ម័ន មហាឧបរាជអ្នកគ្រប់គ្រងរដ្ឋមាល័យ (មាលយូ) ដែលមានស្រុកស្រែធម្មនគរជាវាជធានី ទ្រង់មិនមើលបំណាំក្នុងរឿងនេះ បានស្តេចមកជួយព្រះបក្រវត្តិដោយរួសរាន់ ។ កងទ័ពខ្មែរទាំងពីរពួក ឃានព្រួតគ្នាវាយកងទ័ពព្រះអត្រាពកចាស់តែបរាជ័យយ៉ាងខ្លោចខ្លឹ ហើយតាមវាយរហូតដល់នគរលង្កូន ចាស់តែបាននគរលង្កូនមកជាសម្បត្តិរបស់ខ្មែរ, តែក្នុងវេលានោះនគរលង្កូនគោងចំហសិន ព្រះសូរ្យវរ្ម័នទ្រង់មិនទាន់បានតាំងអ្នកពាជការខ្មែរឲ្យទៅគ្រប់គ្រងនៅឡើយទេ ព្រោះទ្រង់មានព្រះរាជការៈធំនៅក្នុងព្រះមហានគរ គោងស្តេចប្រញាប់លើកទ័ព

ត្រឡប់ទៅក្រុងលវបុរៈវិញ ដើម្បីទទឹងតតាវរម្ងាប់អសន្តិសុខ នៅព្រះមហានគរតទៅទៀត ។

ការណ៍ដែលព្រះទុទយាទិត្យវរ្ម័ន ក្បត់ដណ្តើមរាជសម្បត្តិ ដល់ទៅរំលោភព្រះទិព្វការចេញនោះ លោកទុកជាអធម្មកម្ម ។ អំពើអធម្មកម្មនេះ ទោះបីដូចម្តេចក៏ដោយគង់មិនជាទីគាប់ព្រះហឫទ័យនៃព្រះរាជវង្សធំ ។ ដែលមានព្រះជន្មនៅក្នុងវេលានោះ, មិនត្រឹមតែព្រះរាជវង្សទេ សូម្បីប្រជារស្ត្រ ៨ កន្លះភាគ ១០ ក៏យល់ថាស់ដែរ, ដូច្នេះ ការគ្រងរាជបល្ល័ង្ករបស់ព្រះបាទទុទយាទិត្យវរ្ម័ន នៅក្នុងរាជដែលត្រូវពិភាក្សាដោយផ្លូវច្បាប់តទៅ ។

ព្រះសូរ្យវរ្ម័ន ដែលស្តេចមកគង់នៅក្រុងលវបុរៈទាំងគ្រឿងចំពាំងនោះ ដើម្បីពិភាក្សាទទឹងស្តាប់សំឡេងមហាជនក្នុងរឿងនេះ ។ កាលទ្រង់ព្រះសណ្តាប់សេចក្តីជំនុំរបស់ក្រុមជំនុំ ទទឹងសំឡេងភាគច្រើនថា "មិនត្រមទទួលស្គាល់ ព្រះបាទទុទយាទិត្យវរ្ម័នហើយ ព្រះអង្គក៏លើកទ័ពសំដៅទៅក្រុងយសោធរបុរៈភ្លាម ដោយទ្រង់ព្រះចិន្តាឃើញថា ដែលទទឹងរកសេចក្តីសុចរិតយុត្តិធម៌ឲ្យឃើញឡើងវិញ លុះតែប្រើកំឡាំងអាវុធ ។

ចំណែកខាង ព្រះបាទទុទយាទិត្យវរ្ម័ន ទ្រង់ជាបក្ខងព្រះអង្គមកហើយថា ការសោយរាជ្យរបស់ព្រះអង្គនោះ មិនបានប្រព្រឹត្តទៅដោយសុភាព ឬដោយច្បាប់ទម្ងាប់ទេ ដូច្នេះត្រូវតែត្រៀមការទុកការពារព្រះ

អង្គជាយ៉ាងម៉ឺងម៉ាត់បំផុតជាដរាប ។ កាលទ្រង់ជ្រាបថា ព្រះសូរ្យវរ្ម័ន លើកទ័ពមកប្រទុស្តព្រះអង្គហើយ ក៏គ្រាស់ឲ្យសេនាបតីរៀបទ័ពចេញតទល់មួយរំពេច ទាំងព្រះអង្គក៏ស្តេចចេញច្បាំងដោយព្រះអង្គឯងផង ។ កងទ័ពទាំងពីរខាងតស៊ូគ្នាយ៉ាងពេញសមត្ថភាព, តែកងរយៈវេលាមិនយូរប៉ុន្មាន ខាងកងទ័ពព្រះសូរ្យវរ្ម័នក៏ចាញ់ជ័យជំនះយ៉ាងជាច់ខាត ដោយបានទាំងរំលាងព្រះជន្មដ៏ព្រះបាទទុទយាទិត្យវរ្ម័នឲ្យសូន្យទៅផង ។

ព្រះបាទទុទយាទិត្យវរ្ម័នទី ១ ទ្រង់គង់នៅក្នុងរាជសម្បត្តិមិនលើសពី ១ ឆ្នាំ ទ្រង់ក៏សោយទីវង្គតក្នុងសមរភូមិ ។

ដោយហេតុដែលទ្រង់សោយរាជ្យដោយអយុត្តិធម៌នោះ បានជាកាលទ្រង់សោយទិវង្គតទៅហើយ គេមិនបានថ្វាយព្រះនាមព្រះបរមសពដូចព្រះបរមសពនៃព្រះមហាក្សត្រិយ៍ទាំងពួងទេ តែគេពាប់ជារដ្ឋកាល ១ ក្នុងព្រះរាជពង្សាវតារដែរ ព្រោះក្សត្រិយ៍អ្នកជារដ្ឋទាយាទគឺព្រះទិវាករនោះផុតរលត់ទៅហើយ ប្រសិនបើអ្នករដ្ឋទាយាទនៅគង់ជីវិត ហើយនៅតវ៉ាក្នុងរឿងរាជសម្បត្តិនោះ, ព្រះទុទយាទិត្យវរ្ម័ន ទោះបីច្បាំងឈ្នះដោយកំឡាំងអាវុធ បានឡើងសោយរាជ្យក៏ដោយ ក៏មិនត្រូវគេពាប់ជាព្រះរាជាម្ចាស់ផែនដីពេញទីទេ ។

រាជសម្បត្តិតពីនោះ ក៏បានទៅព្រះសូរ្យវរ្ម័នអ្នកមានព្រះកិត្តិយសខ្ពស់ ឧឹង មានព្រះសមត្ថភាពដូចពោលហើយ ។

ព្រះចាន ឧស្សវ្រ័ន្ធទី ១

ព. ស. ១៥៤៥ - ១៥៩៣, គ. ស. ១០០២ - ១០៥០

ព្រះសូរ្យវរ័ន្ធអគ្គនេះ ជាព្រះនុរសរបស់ព្រះមហាឧបរាជអ្នកគ្រប់គ្រងរដ្ឋមាលីយ (មាលយូ) ដ៏ជាបច្ចន្តរដ្ឋ ១ របស់កម្ពុជាក្នុងសម័យនោះ សិងតាំងរាជធានីនៅស្រីធម្មនគរ ។ ឯព្រះនាមព្រះរាជបិតានោះដូចម្តេចមិនច្បាស់ដ, ច្បាស់ដតែថា ជាប់ជាព្រះញាតិមកអំពីព្រះនាង **ប្រិទ្ធិវិឥន្ទ្រទេវី** ដ៏ជាព្រះរាជជននីនៃព្រះបាទឥន្ទ្រវរ័ន្ធទី ១ ។ ព្រះរាជមាតាព្រះនាមដូចម្តេច ក៏មិនច្បាស់ដដែរ ។ កាលនៅកុមារទ្រង់បានទទួលសិក្សាចំណេះវិជ្ជាទាំងផ្លូវគតិលោកទាំងផ្លូវគតិធម៌ដោយបរិបូណ៌ គឺទ្រង់ចេះភាសាជ្វា - មាលយូ - ភាសាឥណ្ឌៀ - នឹងភាសាសំស្ក្រឹត ទ្រង់ជំនាញក្នុងក្បួនអក្សរសាស្ត្រ ទាល់តែច្បាស់ដព្រះកិត្តិយសថា **ក្សត្រច្បាស់ក្នុងក្បួនកាព្យ** ។ លោក្រោយមកព្រះអង្គបានទ្រង់និពន្ធកាព្យ ជាភាសាសំស្ក្រឹតជាច្រើន, កាព្យដែលទ្រង់និពន្ធនោះបានផ្សាយរហូតទៅដល់មហាប្រទេសឥណ្ឌៀ ដោយចំពោះតែផ្សាយទៅដល់ប្រទេសអយុធ្យានឹងភាណោជ, ព្រះមហាក្សត្រនឹងអ្នកច្បាស់ក្នុងប្រទេសអំបាលនេះបានទត - អានហើយ ក៏និយមនឹងសរសើរទូទៅ ។ ទ្រង់បានសិក្សាវិជ្ជាគ្រប់គ្រងមានយុទ្ធសាស្ត្រជាដើមតាមរាជប្រពៃណី ទ្រង់ជំនាញក្នុង

ក្សត្រយុទ្ធវិធី ហៅថាយ៉ាងឯក ១ អង្គ ។ កាលព្រះរាជបិតាទិវង្គតហើយ ព្រះអង្គក៏បានទទួលគ្រប់គ្រងរដ្ឋមាល័យស្នងព្រះរាជបិតាតមក ។

លុះមកដល់ឆ្នាំ ព. ស. ១៩៤៤ ក្រោយដែលព្រះបាទជយវរ្ម័នទី ៩ សោយទិវង្គតហើយ ក៏កើតសឹកចំបាំងក្នុងប្រទេសចាំងខាងក្រៅប្រទេសចូលមកញាំញីថែមទៀត, ព្រះសូរ្យវរ្ម័នមហាឧបរាជ តោងស្តេចលើកកំឡាំងចេញរម្ងាប់អសន្តិសុខចាំងពីផ្លូវទ្រាបទាបទៅ ដូចពោលហើយ ។ អំពីនោះមក ព្រះអង្គបានឡើងគ្រងពិភពក្សត្រជាចាំងមូល តែពុំទាន់បានធ្វើព្រះរាជពិធីបរមរាជាភិសេកនៅឡើយ ព្រោះហេតុក្នុងគ្រានោះ មានការណ៍ចះចោរជាថ្មីទៀត ដោយមានព្រះរាជវង្ស ១ អង្គទៀត ព្រះនាម ជយវីរវរ្ម័ន តែមិនដឹងជាតំណាវង្សមកពីខាងណា បានបង្កហេតុដែកជាច្បាំងទៀត ។ ព្រះបាទសូរ្យវរ្ម័នតោងទ្រង់ចាត់ការកម្ចាត់ព្រះជយវីរវរ្ម័ននេះផង តោងចាត់ការផែនដីផ្នែកផ្សេងៗផង ដរាបដល់ឆ្នាំទីពាក្យរឿងចះចោរទើបបានស្ងប់, ព្រះអង្គទើបត្រាស់ឲ្យធ្វើព្រះរាជពិធីបរមរាជាភិសេក។ រាជបណ្ឌិតថ្វាយព្រះបរមនាមតាមព្រះនាមដើមថា ព្រះបាទសូរ្យវរ្ម័ន រាប់ជាទី ១ ។ ព្រះអង្គមានព្រះអគ្គមហេសីព្រះនាម វីរលក្ស្មី[1] ។

---

១ មានព្រះអនុជ ២ អង្គ ព្រះនាម សទាសិវៈ ១ ជយៅត្តវរ្ម័ន ១ ។

សាវតារវត្តវិហារធំ

នៅឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម

ឧកញ៉ាកែវ - ហង់

ចាងហ្វាង៖ ប៊ុត្រែត នៅឃុំ - ស្រុក - ខេត្តនេះ រៀបរៀង

(រង្វាន់លេខ ១)

(៩–១០)

៤– និយាយអំពីនាគដង្កាននិងគ្រុឌ

នាគដែលជាក់នៅចែងចុងដងក្តារ លើដំបូលវិហារនោះ ខ្ញុំមិនដែលឮថាមានក្បួនច្បាប់ទេ ។ ជាន់ដើម វិហារនេះធ្វើដូចកុដិតឹងគ្នា នាគដីក, ខាងស្រុកបាត់ដំបងហៅ បូប ជាពេងទុយោសឋ, តមកធ្វើដំបូលស្រួចដូចផ្ទះខ្មែរ តែគ្មាននាគដែរ; ជាន់ដើម ច្រើនធ្វើជាសកុណាកន្ធុយហង្សដូចគល់កណ្តៀវ ជាក់នៅចុងដងក្តារជ្រុងចែង ច្រើនជារូបក្បាលតោ - ខ្លា ។ តមកចុងក្រោយជាជាងឬអ្នកកសាងយល់ថាក្បាលនាគល្អមើលហើយសមផង ។ តែរូបនាគនេះឮចាស់ៗ ថា នាគសៀមហៅថា នាគសន្ធឹក គ្មានក្អែកគ្មានម៉ាត់ទេ (ដែលបានឃើញហើយឮពាក្យចាស់ថានាគសៀម ជាង ៦០ ឆ្នាំហើយ) ។ តាមខ្ញុំយល់ឃើញចុងក្រោយជាងសៀមបង្កើតធ្វើរូបនាគជាក់វិហារជាមុនមែន ទើបផ្សាយមក

ស្រុកខ្មែរជាក្រោយ ។ តមកជាន់អ្នកធ្វាក់ក្បាលនាគធ្វើមានក្អែកមាន
មាត់មានធ្មេញមានចង្កឹម មាត់ពាំកែវ មានពុកចង្កា រចនាថ្មែកថែមខ្លឹង
ខៀត រហូតដល់សព្វថ្ងៃមើលឥតទាស់ភ្នែក; ប្រហែលយល់ថាកាលព្រះ
ជាម្ចាស់បានត្រាស់ហើយ ឃានគង់លើនាគសំដែងធម៌ នាគដកពពារ
ចុំងពីលើមិនឲ្យព្រះអង្គត្រូវកំដៅព្រះអាទិត្យ ដូច្នេះទេដឹង? ព្រោះមាន
ពាក្យចាស់ថា ធ្វើវិហារហើយ ត្រូវលើកដីវាជង់ក្តារ មិនឮថាមាននាគ
សោះ ។ ជាន់ដើម ពិធីលើកដីវាជង់ក្តារនេះជាកិច្ចធំបំផុត អ្នកសាង
វិហារត្រូវគ្រាបបង្គំទូលព្រះមហាក្សត្រ ទទឹងសម្តេចព្រះមហាសង្ឃរាជ;
ព្រះមហាក្សត្រចាត់តំណាង, ព្រះមហាសង្ឃរាជយាងមកផ្ចាល់ ទើបអ្នក
សាងលើកដីវាជង់ក្តារនោះបាន ។ របៀបលើកដីវាជង់ក្តារ មានរបៀបពួ-
ការដូចលើកវិហារ, សែងដីវាឡើងទៅមានភូសំចុំង តែដីវាមួយត្រូវលើក
មុន មានវាយស្គរ គង ហៅ អុជធូប ជាឧឡារិក ។ ខ្ញុំធ្លាប់បានឃើញ
បានដឹងកាលពីក្មេងមក មិនឮថានាគសោះ ។ ឆៀបបន្តិច ដូចប្រាសាទ
អង្គរវត្ត ខ្ញុំមិនឃើញមានរូបនាគជាក់លើកំពូលប្រាសាទទេ ឃើញរូប
នាគជាក់នៅតែត្រង់បង្អាន់ដៃ ។

៥- និយាយពីគ្រុឌនៅខាងក្រោម នាគនៅខាងលើ

រូបគ្រុឌនឹងនាគនេះ មិនមែនជាប្រស្នានៃបូរាណាចារ្យទេ ប្រហែល

ជាជាងឬអ្នកកសាងចូលចិត្តធ្វើរូបគ្រុឧជាក់នៅជ្រុងចែង ។ ខ្លះជាក់គ្រប់សសរបៀងវិហារតាំងអស់ ។ ពីមុនមក ធ្វើតែក្បាច់អែក ជាក់ជ្រុងចែងនឹងគ្រប់សសរបៀងតាំងអស់ ។

រូបគ្រុឧនាគនៅលើក្រោមនេះ បើប្រស្នាសម័យបច្ចុប្បន្នប្រហែលជាត្រូវដឹង! ។ គ្រុឧជាអ្នកមានវិជ្ជិ នាគខ្លាចគ្រុឧ ឥឡូវនាគនៅពីលើគ្រុឧ ។ ពួនជ្រកនៅចែងរបៀងសំយាបវិហារបែបខ្លាចនាគទៅវិញឬគ្រុឧពួនចាំចាប់នាគវិញទេដឹង! ។ ប្រស្នាត្រង់នេះ ស្រែចនៅលោកជាអ្នកប្រាជ្ញពិចារណាផងចុះ ។

៦- និយាយអំពីប្រយោជន៍កសាងវត្ត

អ្នកកសាងវត្តចង់ប្រយោជន៍ធំបំផុត វត្តជាអន្សាស្រុកជាសិរីសួស្តីភូមិស្រុកនៃអ្នកកសាង, បើវត្តថ្មើរើងរឿង ភូមិស្រុកចំណុះវត្តក៏ថ្មើរើងមានកោតសម្បើម, បើវត្តអាប់ឥន ភូមិស្រុកក៏អាប់ឥនវិចលើខ្លាត ខ្សោយទ្រព្យធនធាន ។ ពាក្យនេះខ្ញុំបានឮចាស់ថា, ប្រហែលជាមែនដឹង ព្រោះតិតមកជាន់សម័យនេះគង់ជួបប្រទះឃើញមានខ្លះ ។ ម្យ៉ាងទៀត អ្នកកសាងវត្ត មានបំណងចង់បានបុណ្យអំពីទីសេនាសនៈសំរាប់សង្ឃ ព្រោះមានទិដ្ឋានរឿងជោគសេដ្ឋី ដែលមានប្រាសាទទៅគាន់ម្ចិតឲ្យសុទ្ធតែកែវ ព្រោះអានិសង្សសាងកុដិថ្វាយព្រះពុទ្ធជាម្ចាស់ ។ អនាថបណ្ឌិក-សេដ្ឋីសាងវត្តព្រះជេតពនថ្វាយព្រះពុទ្ធអង្គ អស់ប្រាក់ពីឃ្លាំង ដោយ

អំណាចកុសលផលបុណ្យនោះដួយឲ្យសម្បត្តិហូរចូលឃ្លាំងពេញដូចដើមវិញ ។ សទ្ធាជ្រះថ្លារបស់សាមញ្ញជន ដែលខំសាងវិហារដោយចង់បានផលដូចនេះឯង ។

ម្យ៉ាងទៀត អ្នកសាងវត្តអារាម ដោយចង់បានឲ្យវត្តនៅជិតភូមិលំនៅខ្លួន ដើម្បីងាយដើរទៅមកធ្វើបុណ្យទានផង ដើម្បីឲ្យកូនៗចៅស្រួលទៅរៀនសូត្រអំពីសំណាក់លោកចៅអធិការដែលបង្ហាត់បង្ហាញវិជ្ជាទាំងឡាយ ឲ្យបានចេះដឹងស្គាល់គុណទោសខុសត្រូវកងលោកនេះនឹងលោកខាងមុខផង ។

៧. និយាយពីរបៀបនិមន្តលោកធ្វើមេវត្ត

អ្នកស្រុកកសាងវត្តថ្មី ពីមុនមកជ្រាបចំណុះវត្តណា ចូលចិត្តស្រឡាញ់កិក្ខុឬគ្រូសូត្របូណា ត្រូវនាំគ្នាទាំងប្រុសស្រីជាច្រើនទៅសុំឲ្យលោកជាចៅអធិការវត្តនោះចាត់កិក្ខុ ឬគ្រូសូត្រនោះមកធ្វើមេវត្តថ្មី ។ បើគ្មានកំណត់រូបលោកណាទេ កំរើសចនៅលោកចៅអធិការ ចាត់លោកអង្គណាដែលគួរធ្វើជាមេវត្តបាន ឲ្យមកធ្វើជាមេវត្តថ្មី ។ បើលោកព្រមចាត់ឲ្យហើយ, វត្តនោះមានកិក្ខុច្រើន សូមនិមន្ត ៤ ឬ ៥ រូបដែលខ្ចីវស្សាជាងមេវត្តថ្មីឲ្យនិមន្តមកជាមួយ មកគង់វត្តថ្មីផង ។ អ្នកស្រុកឲ្យអាចារ្យមើលឫក្សថ្ងៃនឹងទទួលលោកឲ្យចូលមកក្នុងវត្ត ។ អាចារ្យមើលឫក្សថ្ងៃពេលល្អបានហើយ, ត្រូវរៀបរាណាប់កងវត្ត ហើយនាំគ្នាទៅទទួលលោក

ពីវត្តមក ហៃហាមជាអ៊ុកធីក តាំងលោកចៅអធិការជាមេវត្តថ្មី កំនិមន្ត
មកជាមួយ; លុះមកដល់វត្តហើយ អ្នកស្រុកឬអាចារ្យអ៊ុជទៀនធូបច្រាប់
អ្នកតា ទេវតា ព្រះភូមិ នាងគង្គីនព្រះធរណី ថាបានិមន្តលោកឈ្មោះ
នេះមកគង់ធ្វើជាមេវត្តនេះ ព្រមតាំងកិក្ខុជាបរិសេស្យ សូមឲ្យបានសេចក្តី
សុខចម្រើនរុងរឿងចិតថេរចិរកាលតទៅ ។ ដល់ពេលល្ងាច រៀបចំរើន
ព្រះបរិត្ត (សូត្រមន្ត) ព្រឹកឡើងបែគេនកត្តរួចរៀងដីទៃត្រវត្ត ព្រមតាំង
សាលា កុដិ ពោធ ចេតិយ បែគេនលោកមេវត្តថ្មី ជាសូរចេកិច្ច ។

ថ្ងៃក្រោយមក ត្រូវសុំអនុញ្ញាតចំពោះសម្តេចសង្ឃរាជ សុំឲ្យ
តាំងលោកមេវត្តនេះជាទីចៅអធិការ, សម្តេចទ្រង់បានអនុញ្ញាតតាំងជាចៅ
អធិការហើយ, ចៅអធិការនេះ ចូលគាល់សម្តេច។ ប្រទានទឹកស្រោច
ជាចៅអធិការ ឲ្យពរស័ព្ទសាធុការ ព្រមទាំងប្រគល់សញ្ញាប័ត្រ ។

សូមអភ័យទោសអំពីសំណាក់លោកអ្នកច្បាស់

សេចក្តីបរចាខាងលើនេះមានបំពានទីងសេចក្តីហាមខ្លះ ធ្វើយមិន
ត្រូវតាមសូរខ្លះ ធ្វើយហួសសូរក៏មានខ្លះ តាំងមិនបានរៀបរយដោយចាំ
មិនសព្វគ្រប់ ព្រោះពោលតាមដែលបានឮឃើញហោរារៀបរៀបក
សាងវត្តថ្មី, និមន្តចៅអធិការថ្មី ទីងបំផ្លាក់ក្បាលនាគ, សន្ទឹកជានាគ
សៀម, ជាងធ្លាក់ក្បាច់ហោជាង ។ ជួរតែខ្ញុំបានឃើញវិហារចាស់ខ្លះ
ដែលមានដីរាជដងក្តារគ្មានទាគ ដូចនិយាយកុង ១ ទី ៤ នោះ តាំងពីខ្ញុំបាន

អាយុ ៧ - ៨ ឆ្នាំមកម្ល៉ះ ឥឡូវខ្ញុំបានអាយុ ៦៥ ឆ្នាំហើយ ។ រឿង ដែលខ្ញុំបានរៀបរៀងជូនលោកអ្នកប្រាជ្ញពិនិត្យទំនៀមទម្ងាប់ តាមបាន ឃើញបានចាំមកនេះ ឥតមានប្រាថ្នាជាប់លេខ ឬ សន្មតថាត្រឹមត្រូវ នោះទេ ។ ហេតុនេះខ្ញុំបានទទឹងជាក់សេចក្តីថាសុំរង្វាន់ បៃបនេះ បៃបនោះ ក៏ទឹកអៀនខ្លួនឯងសោកអ្នកប្រាជ្ញពន់ពេក ហាក់ដូចជាខ្ញុំបានសង្ឃឹមថា ជាប់លេខ មុនលោកអ្នកប្រាជ្ញពិនិត្យ ។

កែវ - ហង់

ប្រាជ្ញាខ្លះអាចិកំពាំង

រីទំនៀមនឹងទម្លាប់ជាប់មានមក
ប្រាជ្ញគួរយកបញ្ញាអារកាត់សេចក្តី
បើឃើញថាទំនៀមណាពុំពីសី
គួរកុំបីស្តាយធ្វើអ្វីលះចោលបេញ ។
បើឃើញថាទំនៀមណាត្រូវផ្លូវធម៌
គួរខំបរកធ្វើទ្បើងឲ្យពេញលេញ
ធ្វើយ៉ាងនេះរឹះយ៉ាងហ្មង់ទើបបំណេញ
បាននាមពេញជាបណ្ឌិតពិតប្រាកដ ។

ឃួរ - អ៊ុន

លោក ម៉ុញ - ឆាំគ្រី រៀបរៀង

(៣ - ចប់)

សាសនាសិន្ធូ

ពាក្យថា "សិន្ធូ" សំគាល់សេចក្តីថា "វិថីប្រផ្សុរបស់ព្រះជាម្ចាស់"។ សាសនានេះ កើតឡើងក្នុងប្រទេសជប៉ុន ។ គោលសំខាន់របស់សាសនានេះគឺ ការបូជាធម្មជាតិ និងបូជាបុព្វបុរស ។ ឯបុព្វបុរសសំខាន់បំផុតគឺស្តេចម្ចាស់ផែនដី, ព្រោះសាសនានេះប្រដៅគ្នាថា ប្រទេសជប៉ុនជាបំណែករបស់ដួងព្រះអាទិត្យ ដែលផ្ទុះពេយរាយចុះមកជាកោះតូច ។, តមកព្រះអាទិត្យបានប្រទានគូបុរសស្ត្រីជាដំបូងគឺ ព្រះពជានិងព្រះពជនី ទើបកើតជាកូនពូនជាចៅជាតិដប៉ុនរៀងមកដល់សព្វថ្ងៃនេះ ។

សេចក្តីស្អាតជាកិច្ចធំបំផុតសម្រាប់សាសនានេះ ព្រោះមានសេចក្តីបញ្ជាតិសម្រាប់សាសនាចង្អាប់ថា ការចូលទៅជិតទីបូជារបស់សិន្ធូត្រូវដូតទឹកសំអាតកាយឲ្យស្អាតសិន, ការចូលទៅជិតមនុស្សស្លាប់ក៏ដូចគ្នា ចាំងត្រូវសំអាតចិត្តផង ។

មួយទៀតសាសនាសិន្ធូជាសាសនាប្រដៅឲ្យជឿថា វិញ្ញាណជាវត្ថុមិនស្លាប់ ហេតុដូច្នោះការស្លាប់ក៏ទុកដូចជាផ្លាស់សម្លៀកបំពាក់ជាថ្មី និងមានហានៈតែតែវិសេសឡើង ព្រោះជាទីគោរពបូជានៃជនានុជនក្រោយ ។

ហេតុនេះហើយបានជាក្នុងប្រទេសជប៉ុន មានវិធី "ហាកគីរ" គឺវិធីអត្តវិនិបាតកម្ម (សម្លាប់ខ្លួន) ដែលគេពាប់អានទូទៅថាជាកិច្ចប្រសើរសម្រាប់លាងថ្ការ ជាកិច្ចសំដែងសេចក្តីសុចរិតសត្យាធិដ្ឋានជាក់ស្តែង ។

កិច្ចនេះត្រូវធ្វើចំពោះមុខប្រជាជន មិនមែនលបលាក់ធ្វើដោយស្ងាត់ៗនោះទេ ។ ឯពិធីដែលត្រូវធ្វើនោះ ដំបូងសាមីរូបដែលជាប់ចិត្តត្រូវពាក់អាវពិធីសម្រាប់តែកូលពាល់គ្នា ហើយចូលទៅអង្គុយមុខតុ:ពិធីដែលធ្វើពីឈើពណិស ដែលមានដំកល់កាំបិតនៅលើនោះ ។ កាំបិតនោះមានខ្នាតប្រវែង ៩ ង្កាប់ ហើយរុំដោយក្រដាសពណិសច្រើនជាន់ទុកឲ្យនៅសល់តែចុងស្រួច ទើបយកកាំបិតនោះមកវះឆូតពោះឬវះជាដើងក្អែក ឲ្យមានប្រវែង ៦ ឬ ៧ ង្កាប់ រួចហើយទើបអារកសំរេចជាខាងក្រោយ; ចួនកាលសាមីរូបអារកខ្លួនឯងមិនខាន់ស្រែកហៅឲ្យអ្នកជំនួយមកជួយបង្ហើយទេ ។ ឯអ្នកជំនួយនោះត្រូវរើសតែបុគ្គលដែលស្និទ្ធស្នាលជួចយ៉ាងមាតា-បិតា ឬញាតិសាច់មិត្តសំឡាញ់ដែលជិតដិត ។ អ្នកជំនួយដែលបានជួយពិឃាតនេះទៀតសោត សឹងមានសេចក្តីពេញចិត្តនឹងកិច្ចនោះជាទីបំផុត ទុកដូចជាអ្នកដែលបានជួយបំបួសកុលបុត្រសម្រាប់ពុទ្ធសាសនាយើង ។

កិច្ចនេះ សម្រាប់ធ្វើបានតែពួកអ្នកដែលយល់ឃើញថាសុចរិតផង, ចំណែកមនុស្សដែលមានទោសគួរដល់ពិឃាតជិតបង់ គេមិនព្រមឲ្យ

វិធីនេះទេ ត្រូវតែប្រព្រឹត្តតាមច្បាប់ពាជការ ។ សាសនានេះហើយ ដែលនាំឲ្យជាតិជប៉ុន មិនចេះរួញរាពនឹងសេចក្តីស្លាប់ ។

សាសនាស៊ិនតូ ជាសាសនាដើមរបស់ជប៉ុន, តែតមកខាងក្រោយ ព្រះពុទ្ធសាសនាផ្សាយចូលទៅដល់នាំឲ្យមនុស្សជ្រះថ្លាច្រើនជាង រហូតដល់ក្លាយទៅសាសនាសម្រាប់ពាជការផែនដីដំនួសកន្លែងស៊ិនតូបាន ។

ព្រះពុទ្ធសាសនាផ្សាយចូលទៅប្រទេសជប៉ុនរាវ៉ាង ព. ស. ១០៩៥ ដោយព្រះចៅផែនដីកៅហ្គីបានបញ្ជូនព្រះពុទ្ធរូបទៅថ្វាយព្រះបាទ កិមេ្ម៉ រប់ជប៉ុន, បន្ទាប់មកបានបញ្ជូនកិកូឲ្យចូលទៅប្រកាសសាសនាក្នុងប្រទេសជប៉ុនទៀត ដរាបតាល់តែសម្ប្បុរពុទ្ធសាសនិកនិកាយ ដល់ចំនួន ៤៨ លាននាក់ មានវត្តចំនួន ៧ ហ្មឺន, ឯសាសនាស៊ិនតូមានចំនួនមនុស្សតែ ១៦ លានប៉ុណ្ណោះ ។

កាលបើព្រះពុទ្ធសាសនា ជាភ័យធំរបស់សាសនាស៊ិនតូដូច្នេះហើយ អធិករណ៍ក៏កើតឡើងរាវ៉ាងសាសនាទាំងពីរ, តែព្រះពុទ្ធសាសនាមានជ័យជំនះ គឺគេទុកជាសាសនាសម្រាប់ផែនដី ដរាបដល់មកពាជ្យព្រះនាង ឈុយកូ (ព. ស. ១១៣៦ - ១១៧១) ។

លុះដល់មកពាជព្រះបាទមត្សុហិតូ (ព. ស. ២៤១០ - ២៤៥៥) ទើបប្រកាសផ្ទាស់យកសាសនាស៊ិនតូជាសាសនាសម្រាប់ពាជការវិញ ដើម្បីឲ្យជនជាតិជប៉ុនមានលក្ខណៈជាជប៉ុនសុទ្ធទាំងសាសនាសម្រាប់ជាតិផង ។

លោកវ៉ាយ-ប៊ុក ក្រមការទៅពុទ្ធសាសនបណ្ឌិត្យ

ប្រៃរៀបរៀង

(ភាគ)

ឧបក្សាទាំងអស់ដែលរស់នៅសប្បាយស្រួលនឹងវុក្ខជាតិព្រឹក្សព្រៃ, សេក ដែលមានស្លាបហើរលឿន, បក្សាស៊ីនំម៉ាល់, ពពូល, ត្រាប! អ្នក ទាំងអស់តែងមានស្លាប់ខ្ចីមន្ទូវដីវាតាវបស់អ្នកឡើយ ហើយមានថ្ងៃថ្ងា ចង់រចនាដីវាតាវនោះឲ្យបានថ្លៃថ្លាឡើង ដោយធ្វើទុក្ខលំបាកខ្លួនឯងឬ? តែមនុស្សដែលធ្វើឃាតកម្មចំពោះអ្នកជាពួកបណ្ឌិត្យ ហើយថ្លៃជាអ្នក នោះប្រឡាក់មន្ទិលលោហិត, អាចឲ្យចំរើនឡើង ក្នុងពេលដែលទទួល ទុក្ខលំបាកដែលអ្នកនោះធ្វើចំពោះខ្លួន ដោយយល់ឃើញថា ខ្លួនជា នាយកលើពិភពលោកឬ?" ។

ក្នុងខណៈដែលព្រះបរមគោធិសត្វមានព្រះបន្ទូល ព្រះអង្គបាន ឧត្តៅឃើញធូលីដីហុយពីខាងក្នុមក ដោយមានហ្វូងពពែញីស ទឹង ដៀមភ្នៅដើរមួយ។ ឈប់បង្អង់ចាំបរិភោគនៅតាមគុម្ពោតព្រៃដែលឃ្លាត ចេញពីផ្លូវ តម្រង់ទៅខាងស្ទឹងឬទៅទីដែលមានឆ្នៃជ្រៃសំយុងចុះពីមែក, តែដល់កាលណាសត្វទាំងនោះដើរឃ្លាតចេញពីផ្លូវ, អ្នកឃ្វាលក៏ស្រែក ដោយសំឡេងខ្លាំង យកដុំថ្មចោលហើយកៀងសត្វទាំងនោះឲ្យទៅខាងទី

ភ៌ល; នៅកន្លែងហ្នឹងនោះមានដៀមញីមួយនឹងកូនពីរ, កូនមួយនោះនាយ
គង្វាលចោលត្រូវគ្រែចដើរមុខ ហើយដើរតាមហ្នឹងនោះបានដោយ
លំបាក, កូនមួយទៀតដើរទៅខាងមុខ, ឯដៀមញីក៏ដើរទៅក្រោយម្តង
ទៅមុខម្តងការពារកូននោះមិនឲ្យហ្មង ។ ព្រះពោធិសត្វលុះទ្រង់បាន
ឃើញដូច្នោះ ក៏មានព្រះទ័យករុណាអាណិតអាសូរ ព្រះអង្គលើកបឋម
ថ្មកូនដៀមដែលរបួសនោះ ហើយមានព្រះបន្ទូលនឹងមេថា: "នាង
ជាមាតាអើយ, នាងកុំព្រួយឡើយ. បើនាងទៅដល់ទីណា យើងក៏យក
កូនទៅឲ្យដល់ទីនោះដែរ: យើងត្រូវតែការពារកុំឲ្យសត្វឆ្កែទុក្ខលំបាក,
មិនត្រូវអង្គុយពីចារណាសេចក្តីទុក្ខកង្វល់សន្ធិវាស នៅរួងគុហាភ្នំ
ជាមួយនឹងពួកឥសីដែលកំពុងសូត្រធម៌នេះឡើយ" រួចព្រះអង្គមានព្រះ
បន្ទូលសួរទៅអ្នកគង្វាលថា: "ហេតុដូចម្តេចបានជាអ្នកនាំហ្នឹងសត្វនេះទៅ
ភ៌ល កន្លែងអស្ចារ្យគួរសម័យដូចនេះ? តើពីកាលណាមកបានជាកន្លែងសាយណ្ហ-
សម័យគេនាំហ្នឹងសត្វមកទីនេះ?" ។ ឯពួកអ្នកគង្វាលក៏ក្រាបទូលព្រះ
អង្គថា: "គេបានបង្គាប់ឲ្យយើងរំយកពពែញីចំនួន ១០០ ដៀម ១០០
ទៅបូជាយញ្ញ តាមព្រះរាជតម្រាស់ព្រះមហាក្សត្រិយ៍ថា ឲ្យយកទៅ
ពីយាតយប់នេះ ដើម្បីនឹងថ្វាយដល់ពពួកទេវតា" ។ ព្រះពោធិសត្វ
មានព្រះបន្ទូលថា: "យើងទៅជាមួយនឹងអ្នកដែរ" រួចទ្រង់ស្តេចយាងទៅ
តាមក្រោយពួកអ្នកគង្វាលនោះ ជាមួយនឹងកូនដៀមទៅផង ។ ពិតមែនតែ

ធ្លាល់ដីហុយឆ្ងាំតមេយហើយនឹងកំដៅព្រះអាទិត្យក្តៅពន់ពេក ឯមេដៀម
នោះ កំរៀសកយំបណ្តើរក្រឡេកមើលកូនបណ្តើរនៅជិតព្រះអង្គ ។
លុះដល់ព្រះអង្គនឹងពួកអ្នកគង្វាលព្រមទាំងហ្វូងសត្វទៅដល់ជិតស្ទឹងនោះ
មានស្ត្រីម្នាក់មានក្អែកដូចព្រាប មុខស្រោចស្រប់ដោយទឹកភ្នែក ដៃ
ទាំងពីរប្រណម្យថ្វាយបង្គំព្រះពោធិសត្វហើយពោលថា: "ព្រះអង្គ
អើយ? ពីមុនលិញ្ចៃនឹងបានអាណិតអាសូរខ្ញុំព្រះអង្គនៅតុម្ពោតរៃ
ដែលខ្ញុំព្រះអង្គបានរស់នៅម្នាក់ឯង ចិញ្ចឹមគ្រាកទាំងនោះ, ឯកូនខ្ញុំព្រះអង្គ
បានទៅលេងតាមសួនបុប្ផាពីក្បែរៃ បានជួបប្រទះនឹងឥសពីសមួយរូប
ស្ទុះមកវ័ណ្ឌរុំកដៃ, កូនខ្ញុំព្រះអង្គក៏អង្អែលអណ្តាតឥសដែលវាលៀនចេញ
ពីមាត់នោះ, ឥឡូវស្រាប់តែកូនខ្ញុំព្រះអង្គមុខឡើងស្វាយហើយស្ទឹម
ស្លាប់លែងនិយាយអ្វីរួច, ខ្ញុំព្រះករុណាមិនអាចយល់ហេតុថាដូចម្តេច
បានជាកូននោះឈប់លេង ហើយបបូរមាត់ជ្រាក់ពីសុជន់ ខ្ញុំព្រះអង្គដូច
នេះ", មានបុរសម្នាក់ឆ្លើយថា "វាត្រូវពិសឥសចិត កូននាងឯងនោះវា
ជិតស្លាប់ហើយ", តែខ្ញុំព្រះអង្គសុំនូវសច្ចដែលពូកែសច្ចាសិទ្ធិ អាចធ្វើឲ្យ
ក្អែកកូនខ្ញុំព្រះអង្គបើកបាន មើលឃើញរស្មីព្រះសុរិយា ស្នាមរបួសដែល
ឥសចិតនោះតិចណាស់, សត្វនោះបើតាមខ្ញុំព្រះអង្គយល់ មិនគួរនឹងស្លាប់
ហើយធ្វើឲ្យក្មេងដែលប្រឡែងជាមួយនឹងវារបួសសោះឡើយ; មានបុរស
ម្នាក់ទៀតពោលថា: "មានសន្តបុគ្គលម្នាក់នៅក្នុងគុហាកំ, នាងឯង

យើញទេ នោះហ្ន៎! លោកនិមន្តមកនេះ, គឺលោកដែលស្លៀកសំពត់លឿង, នាងឯងចូរសួរឥសីនេះ តើមានមធ្យោបាយយ៉ាងណាដែលជាអាចកំចាំង ដើម្បីនឹងធ្វើឲ្យសះស្បើយរោគដែលកើតចំពោះកូននាងឯង, ខ្ញុំព្រះអង្គក៏បានចូលមកដល់ព្រះអង្គ ដែលមានព្រះនលាដ:ភ្លឺចាំង ខ្ញុំព្រះអង្គយំសោកស្តាយកូននេះពន់ពេក បានបើកសំពត់ដែលបិទមុខកូន ហើយសូមឲ្យព្រះអង្គជ្រាប តើមានទុសថអ្វីដែលអាចធ្វើឲ្យកូនខ្ញុំព្រះអង្គដឹងខ្លួនវិញបាន, ពេលនោះ ព្រះអង្គនឹងមានព្រះបន្ទូលថា ឲ្យខ្ញុំព្រះអង្គចាកចេញពីទីនេះក៏ទៅដែរ តែព្រះអង្គបានទតក្មេងនោះដោយព្រះចក្ខុស្រងូតស្រងាត់ បានយកព្រះហស្តស្ទាបក្មេងនោះ ហើយត្រាស់ថា "អើនាង, មានតែវត្ថុមួយមុខទេដែលអាចធ្វើឲ្យសះស្បើយរោគនាងនឹងកូននាង បើនាងរកបានបន្តិចបន្តួច, ព្រោះថាបើអ្នកណាទៅស្មើគ្រែពេទ្យៗនោះតែងបង្គាប់ឲ្យយកទុសថនេះទៅផឹក ព្រោះហេតុដូចនេះ ខ្ញុំសូមឲ្យនាងរកគ្រាប់មូតារដ៍ខ្មៅ (Moutar Noire) ចំនួន ១ តុលា[1] តែនាងប្រយ័ត្ន ត្រូវកុំយកអំពីផ្ទះណាដែលមានបិតា មាតា បុត្រឬទាសកម្មករណាមួយ ធ្វើមរណភាពនៅទីនោះ" តើព្រះអង្គមានវាចាដូចម្តេចលើនេះមែនឬ? ។

ព្រះអង្គទ្រង់ញញឹមដោយមានព្រះទ័យអាណិតអាសូរនាងនោះពន់

---

១ តុលា ១ម្ជុំនឹងមួយរ៉ាប្រមាណ ៨ ក្រាម ។

ពេក ទើបគ្រាស់ថា: "អើនាង! បើយើងបានពោលពាក្យនោះមែន, តើនាងឯងរកគ្រាប់មូតារ៉ដ៍នោះបានឬ?"

– ទូលព្រះអង្គ! ខ្ញុំព្រះអង្គបានគ្រាប់ទៅតាមគេហដ្ឋាន ហើយបានបបុត្រដែលមានកាយគ្រជាក់នោះទៅជាមួយផង បានសួរកពីគេហដ្ឋានមួយទៅគេហដ្ឋានមួយនៅក្នុងវៃព្រៃធំ (jungle) នឹងក្នុងនគរថា: សូមលោកមេត្តាខ្ញុំ! សូមលោកឲ្យខ្ញុំសុំនូវគ្រាប់មូតារ៉ដ៍ទៅ ចំនួនមួយតុលា" ហើយអ្នកណាដែលមានគ្រាប់នោះក៏គេឲ្យមកខ្ញុំ ពីព្រោះអ្នកក្រែចឹនមានចិត្តល្អចំពោះអ្នកក្រដូចគ្នា, ប៉ុន្តែខ្ញុំសួរទៅគេវិញថា "តើនៅគេហដ្ឋានអ្នកពីដើមមានស្វាមី, ភរិយា, បុត្រឬបាវព្រាវធ្លាប់មរណភាពដែរឬ?", អ្នកទាំងនោះតបមកខ្ញុំព្រះអង្គថា "ទូនាង! ចុះនាងសួរដូចនេះធ្វើអ្វី?, មនុស្សស្លាប់មានច្រើន មនុស្សរស់មានតិច" ខ្ញុំព្រះអង្គក៏ធ្វើអភិនិន្ទនាលាចេញពីទីនោះ ដោយទឹកមុខស្រងូតស្រងាត់ ហើយក៏ប្រគល់គ្រាប់មូតារ៉ដ៍នោះឲ្យទៅគេវិញ ខ្ញុំព្រះអង្គបានទៅសួរអ្នកដទៃទៀត តែអ្នកនេះពោលមកកាន់ខ្ញុំព្រះអង្គវិញថា: "នេះគ្រាប់មូតារ៉ដ៍, តែនៅទីនេះមានស្លាប់ឥតមានសល់" ខ្លះថា "នេះគ្រាប់មូតារ៉ដ៍, តែស្វាមីខ្ញុំអនិច្ចកម្មទៅហើយ" ខ្លះទៀតតបថា: "នេះគ្រាប់មូតារ៉ដ៍ តែអ្នកដែលព្រោះពូជគ្រាប់នេះរំលាងខន្ធទៅកាន់បរលោក កងរាងវិស្សានរដូវ នឹងរដូវប្លែតទៅហើយ" ទូលព្រះអង្គ! ខ្ញុំព្រះអង្គមិនអាចស្វែងរកគ្រាប់មូតារ៉ដ៍

នៅគេហដ្ឋានណាមួយដែលគ្មានបុគ្គលស្លាប់នោះបានឡើយ! ព្រោះ
ហេតុដូចនេះ បានជាខ្ញុំព្រះអង្គទុកកូនដែលឈប់ថ្មៅសុជន់, មានមុខ
ឥតញញឹមសោះនៅប្រឈមាត់ទន្លេ ជិតដើមទំពាំងបាយដូ ហើយវិល
ត្រឡប់មកមើលព្រះភ័ក្ត្រព្រះអង្គ, ថើបព្រះបាទ, អង្អែវព្រះអង្គ តើនៅ
ទីណាខ្ញុំព្រះអង្គនឹងរកគ្រាប់មូតារជ៍នោះបាន ដោយកុំឲ្យឃើញសេចក្តី
ស្លាប់ បើសិនជាកូនខ្ញុំព្រះអង្គមិនទាន់ស្លាប់នៅឡើយទេ ក្នុងពេលដូច
ជាខ្ញុំមានសេចក្តីភ័យតក់ស្លុតជាខ្លាំងហើយ ដូចជាមានគេច្បាប់ខ្ញុំ" ។

ព្រះពោធិសត្វតបថា: "នាង! បើនាងស្វែងរកវត្ថុដែលគ្មានអ្នក
ណានឹងរកបាន, នាងទើបអាចរកឃើញនូវទុសថដែលមានរសជាតិល្វីង
ដែលយើងនឹងប្រគល់ជូននាង, កូនជាទីស្រឡាញ់របស់នាងនោះមរណ
ភាពទៅហើយ; ឥឡូវនេះ នាងជ្រាបឬទេ? ថាក្នុងលោកសន្និវាសនេះ
គេតែងតែយំសោកទទួលនូវសេចក្តីទុក្ខគ្រប់យ៉ាងដូចនាងដែរ, សត្វទាំង
អស់តែងទទួលសេចក្តីលំបាក ខុសគ្នាតែខ្លះលំបាកតិច ខ្លះលំបាកច្រើន;
នាងឃើញទេ? យើងស៊ូបង្ហូរលោហិតយើង បើសិនជាពលិកម្មនេះអាច
ការពារកុំឲ្យនាងយំសោកបាន សូមនាងបង្ហាញប្រស្នាអាថ៌កំបាំងចំពោះ
ទុក្ខនោះ! ប្រស្នាដែលធ្វើសេចក្តីស្នេហាជាហេតុឲ្យកើតទុក្ខនោះ នាំចិត្ត
មនុស្សឲ្យនាំសត្វទាំងនេះត្រមទាំងមនុស្សនឹងអ្នកកង្វល់ទៅតាមវាលដើម្បី
នឹងបូជាយញ្ញ ឥឡូវកំពុងរកប្រស្នាគម្ពីរភាពនេះ, ឯចំណែកនាង ចូរ
យកបុត្រនេះទៅកប់ទៅ" ។ (មាឧត)

សប្បុរិសធម្មកថា

ព្រះទេសនាស្តែរ-ហាយ រៀបរៀង

(៣-ចប់)

ទីណាឬប្រទេសណាដែលសម្បូរដោយមនុស្សសប្បុរស, ទីនោះប្រទេសនោះរមែងប្រព្រឹត្តទៅដើម្បីសេចក្តីសុខ សេចក្តីចំរើន ដោយពិតប្រាកដឥតអាក់; កុំថាឡើយដល់ទៅសង្គ្រាម សូម្បីតែចោរលួចប្លន់ក៏ពុំមានឡើយ ។ មួយវិញទៀត ធម៌របស់សប្បុរស ឬធម៌សម្រាប់សំគាល់ឲ្យដឹងថាអ្នកនេះជាមនុស្សសប្បុរសឬអសប្បុរសនោះ លោកហៅថា សប្បុរិសធម៌ មាន ៧ យ៉ាង :

១- ធម្មញ្ញុតា សេចក្តីដឹងធម៌ សំដៅយកការដឹងហេតុនៃសេចក្តីសុខទុក្ខ ហើយកាន់យកហេតុនៃសុខលះបង់ហេតុនៃទុក្ខចេញ ។

២- អត្ថញ្ញុតា សេចក្តីដឹងអត្ថ គឺដឹងផលនៃសេចក្តីសុខទុក្ខ ហើយតាំងចិត្តសន្តោស គឺត្រេកអរតាមមានតាមបាន ។

៣- អត្តញ្ញុតា សេចក្តីដឹងខ្លួន គឺដឹងថាអាត្មាអញមានជាតិត្រកូលថោកទាប ឬខ្ពង់ខ្ពស់យ៉ាងណា ហើយប្រព្រឹត្តខ្លួនឲ្យសមគួរ មិនឲ្យជាទំនាស់ដល់អ្នកដទៃ ។

៤- **មត្តញ្ញុតា** សេចក្តីដឹងប្រមាណ គឺដឹងច្បាស់ក្នុងការស្វែងរក, ការទទួលយក, ការបរិភោគប្រើប្រាស់ ចំពោះតែផ្សែងៗ ហើយអាចចេះលៃលកឲ្យសមគួរដល់ប្រមាណ, ប្រកបដោយធម៌សន្តោសសមគួរដល់ប្រទេសជាតិរបស់ខ្លួន, មិនស្តុះស្តារមិនលោតឡើង ឲ្យហួសហេតុពេកខុសទំនងដែលនាំឲ្យខូចតម្លៃកិត្តិយសរបស់ជាតិសាសនារបស់ខ្លួន ព្រោះតែនយោបាយរបស់គេនោះឡើយ ។

៥- **កាលញ្ញុតា** សេចក្តីដឹងកាល គឺដឹងថាកាលវេលានេះគួរប្រកបកិច្ចការនោះៗ, កាលវេលានេះជាកាលមិនគួរប្រកបកិច្ចការនោះៗទេ ។

៦- **បរិសញ្ញុតា** សេចក្តីដឹងបរិសទ្យ គឺដឹងថាប្រជុំជននេះមានឋានៈបែបនេះមានកិរិយាបែបនេះ ហើយប្រព្រឹត្តខ្លួនតម្រូវឲ្យសមគួរដល់អធ្យាស្រ័យនៃបរិសទ្យនោះ ។

៧- **បុគ្គលបរោបរញ្ញុតា** សេចក្តីដឹងបុគ្គលជាន់ខ្ពស់-កណ្តាល-ទាប គឺដឹងថាបុគ្គលនេះជាមនុស្សសប្បុរស គឺមនុស្សល្អដែលគួរសេពគប់, បុគ្គលនេះជាមនុស្សអសប្បុរស គឺមនុស្សអាក្រក់ដែលមិនគួរសេពគប់ជាដើម ។

សប្បុរិសធម៌ ៧ ប្រការនេះ ទុកជាគ្រាប់ថាប់ប្តូជាសញ្ញាប័ត្រមួយសម្រាប់ឲ្យទាយបានថា : បើនរណាមានធម៌ ៧ ប្រការនេះ នរៈនោះ

ទើបឈ្មោះថាជាមនុស្សសប្បុរសដោយពិត, បើបុគ្គលណាមិនមានធម៌ ៧ ប្រការនេះទេ, បុគ្គលនោះក៏ឋានឈ្មោះថាជាមនុស្សអសប្បុរស ។

មនុស្សយើងដោយប្រកបតែរមែងមានធម៌ទាំងនេះតាំងនៅក្នុងខ្លួនខ្លះមិនខាន, បើមិនមានច្រើនក៏គង់មានតិច ។ អ្នកដែលមានធម៌នេះតិចមិនគប្បីគ្រាន់តែក្នុងសន្ដាន រមែងទៅជាមនុស្សមានសេចក្ដីអង់អាចតិច, មានសេចក្ដីសុខសេចក្ដីចំរើនក៏តិចតាមលំដាប់ ។ អ្នកដែលមានធម៌ទាំងនេះច្រើនក្នុងសន្ដាន រមែងបានជាមនុស្សមានសម្ផស្សភាព, ថ្លៃថ្នូរ, មោះមុតអង់អាចច្រើន ធ្វើប្រយោជន៍ដល់ខ្លួននឹងជាតិសាសនារបស់ខ្លួនក៏បានច្រើន; ទាំងសេចក្ដីសុខសេចក្ដីសរសើរនឹងក្លើរឈ្មោះយសស័ក្ដិក៏មានច្រើន ។

ព្រះពុទ្ធសាសនា ជាចដិបទាឲ្យកើតសន្ដិសុខដោយសូតសុភាព សម្រាប់ដឹកនាំមនុស្សឲ្យទៅជាសប្បុរស ។ ឯពាក្យថា "សន្ដិសុខ" នេះសំដៅយកសេចក្ដីសុខសាន្ដ ទាំងលោកនេះនឹងលោកខាងមុខ ។ មួយទៀត សេចក្ដីសុខនេះមាន ២ យ៉ាង គឺ សេចក្ដីសុខដែលកើតអំពីការស្ងប់រម្ងាប់ ចាកទុក្ខទោសពៃរភ័យសង្រួវ ជាសេចក្ដីសុខរបស់ប្រទេសជាតិ របស់មនុស្ស របស់ទេវតា ដែលនៅលាយឡំដោយទុក្ខខ្លះ ហៅថា សាមិសសុខ ១; សេចក្ដីសុខអ្នកបរិសុទ្ធដែលកើតអំពីការស្ងប់រម្ងាប់ចាកកិលេស ចាកបញ្ចក្ខន្ធ គឺជាសុខដែលមិនលាយឡំដោយទុក្ខទោសពៃរតទៅទៀត ឋានដល់សេចក្ដីសុខរបស់ព្រះនិព្វាន នេះ

លោកហៅថា និពាមិសសុខ ១ ។ ព្រះពុទ្ធសាសនា តែងឲ្យសម្រេច ផលដ៏ខ្ពស់ឯណាយ គឺសុខ ២ ប្រការនេះឯង ។

ព្រះពុទ្ធសាសនា ប្រៀបដូចជាផ្ទះផ្សារមួយខ្នង ដែលមានទំនិញល្អៗច្រើន ហើយជាទំនិញសុទ្ធតែវត្ថុបរិសុទ្ធ មិនមែនជារបស់ក្លែងក្លាយ ឬមានពិសពុលក្តៅក្រហាយ ដូចពាណផ្សារគឺសាសនាឯទៀតៗនោះទេ ។ ផ្សារគឺពុទ្ធសាសនានេះ បើកលក់ចំពោះតែបុគ្គលណាមួយដែលមិនជាសត្រូវ ។ ទំនិញដែលបរិសុទ្ធនោះ គឺមគ្គប្រកបដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម នឹងកុសលធម៌ទាំងឡាយឯទៀតៗជាច្រើន, គួរតែប្រជាជនក្នុងលោកចូលមកទិញទំនិញល្អៗនោះតាមត្រូវការ ។ ព្រះពុទ្ធសាសនា មានបញ្ញត្តិសិក្ខាបទជាសាធារណៈដល់មនុស្សនឹងមនុស្សផងគ្នា ព្រមទាំងដល់មនុស្សនឹងសត្វតិរច្ឆាន ឥតមានរើសជាតិឡើយ, ទោះបីមនុស្សក៏ត្រូវមានធម៌សុចរិតក្នុងវាងសត្វតិរច្ឆាន ។ ព្រោះសត្វតិរច្ឆានមានជីវិតជាទីស្រឡាញ់ មានមេ មានឪ មានកូន ជាទីស្រឡាញ់របស់ឪយ៉ាងណា; មនុស្សយើងក៏យ៉ាងនោះដែរ ។ សាសនាឯទៀតៗក្រៅពីនេះ ឬច្បាប់បញ្ញត្តិរបស់ប្រទេសទាំងឡាយក្នុងលោក ច្រើនតែបញ្ញត្តតឹងរ៉ឹងតែក្នុងវាងមនុស្សនឹងមនុស្ស ដូចយ៉ាងផ្លូវបុណ្យបាប ឬអទិន្នាទានជាដើម ចំពោះតែមនុស្សផងគ្នា, ត្រង់មនុស្សសម្លាប់តិរច្ឆានឬលួចបន្លំដណ្តើមស៊ីតសត្វតិរច្ឆានកូនចៅសត្វតិរច្ឆាន មិនឃើញមានបញ្ញត្តិផងឡើយ ។

បុគ្គលជាមនុស្សជាតិណាមួយ កាន់ធម៌សុចរិតទៀងទាត់ពិតត្រង់ក្នុងការរបស់ប្រទេស របស់សាសនា គាំងរវាងមនុស្សនឹងមនុស្សជួបគ្នា, ទោះបីជាមនុស្សជាន់ខាងបុរាណជាន់ខ្ពស់ ក៏មិនត្រូវប្រមាថមើលងាយបៀតបៀនរំលងជាន់ដល់គ្នានឹងគ្នាទេ, គាំងមនុស្សក៏ត្រូវកាន់ធម៌សុចរិតចំពោះគ្នាដែរ ។ បុគ្គលអ្នកកាន់ធម៌តាមបញ្ញត្តិនៃព្រះពុទ្ធសាសនាដូច្នេះ ហៅថា សប្បុរស ។ មនុស្សសប្បុរសនេះ ច្រើនមានតែក្នុងព្រះពុទ្ធសាសនា ។ អ្នកដែលកាន់ធម៌សុចរិតរើសមុខដោយអាងថា ខ្លួនអញជាមនុស្សជាន់ខ្ពស់, ជាអ្នកមានយសស័ក្តិអំណាច, ជាមនុស្សមានកំឡាំងទ្រព្យធនច្រើន, ជាមនុស្សមានទុប្ចយកិច្ចកលច្រើន ហើយសង្កត់សង្កិនបៀតបៀនមនុស្សដែលថោកទាប, បៀតបៀនមនុស្សដែលឥតយសស័ក្តិ មើលងាយមនុស្សដែលក្រខាត់ទ្រព្យសម្បត្តិ, ប្លោកប្លាស់បំបាត់មនុស្សដែលល្ងង់ខ្លៅដែលគ្មានទុប្ចយ; អ្នកដែលមានសេចក្តីប្រមាថពាយងាយដូច្នេះ ទោះបីបន្ទំខ្លួននៅក្នុងសាសនាក៏ហៅថា អសប្បុរស ដែរ ។

ពណ៌នាមកថាអំពីសប្បុរិសធម្មកថា ក៏សមគួរដល់វេលា សូមសន្មតបញ្ចប់តែប៉ុណ្ណេះ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្ពេបិ ទាណិនោ ។


សត្វទាំងឡាយ ដែលដល់នូវទុក្ខ សូមឲ្យជាអ្នកបាត់ទុក្ខទៅ!

ដែលដល់នូវភ័យ សូមឲ្យបាត់ភ័យទៅ! ដែលដល់នូវសេចក្តីសោក សូមឲ្យបាត់សោកទៅ!

រតនត្តយតេជេន ភាគ្គោជវជ្ជកាសិនោ
រក្ខំ ពុទ្ធិំ បវេទ្យាន្តុ សន្តិភាវាយ ជាញថា ។

ដោយតេជៈនៃព្រះរតនត្រ័យ សូមឲ្យប្រជាជនទាំងឡាយអ្នកកើតនៅកន្លែងកម្ពុជវដ្ត ដល់នូវការលូតលាស់ចំរើនទទឹងសន្តិភាព កុំបីឃ្លៀងឃ្លាតក្លាយទៅជាប្រការដទៃឡើយ ។

ចប់



ធម៌ស្មាន១ឧបមា៖

ពួជតែកូល, ទទួលនាគ, នហាតទំ;
តែកូលខ្ពស់ដោយសន្សំអប់រំល្អ,
ទទួលនាគដោយមនោស្អាតសុទ្ធ,
នហាតដោយចំចរប្រព្រឹត្តិការ ម
ធម៌ ៣ នេះគុណវិសេសសាងសួស្តី
ដល់ប្រុសស្រីកន្លងកាយឲ្យអស្ចារ្យ
ជាធម៌ពិតជួយប្រសិទ្ធិជោគសង្ឃារ
ឲ្យថាវាស្ថាពរខ្ពស់ឡើង ។

ពិធីបុណ្យដង្ហែព្រះសារីរិកធាតុ

នៅវត្តដំណាក់ ខេត្តសៀមរាប ។

ព្រះមហា កែ - អឿន រៀបរៀង

ដោយទទួលបើរចនាការពីព្រះគុណព្រះសុទ្ធិលសីលាចារ្យមេគណ ស ន ប

កាលថ្ងៃចន្ទ ១៥ កើតខែពិសាខ ជាថ្ងៃបុណ្យវិសាខបូជា ឆ្នាំខាលចោស័ក ព. ស. ២៤៩៣ ត្រូវនឹងថ្ងៃ ១ ខែឧសភា គ. ស. ១៩៥០ នេះ ពួកពុទ្ធបរិស័ទជាចំណុះដើមវត្តទាំង ៤ គឺ: វត្តដំណាក់, វត្តព្រះព្រហ្មវត្តន៍, វត្តពោធិលង្កា, វត្តព្រះឥន្ទកោសា ប្រាសាមគ្គីស្រុះស្រួលបបួលរួបរួមគ្នា ចាត់ចែងធ្វើពិធីបុណ្យមួយដ៏ឧឡារិកនៅទីវត្តដំណាក់ ហៅថា "បុណ្យហែព្រះសារីរិកធាតុ" ។ នៅវេលាម៉ោង ៤ រសៀល ពួកពុទ្ធបរិស័ទវត្តទាំង ៤ ប្រាសមកជួបជុំគ្នានៅមុខវត្តដំណាក់; បណ្តាពួកពុទ្ធបរិស័ទដែលបានអញ្ជើញមកទាំងប៉ុន្មាន មានសន្ធានដ្រះថ្លាកុងព្រះពុទ្ធសាសនា មានហត្ថាកាន់យកគ្រឿងសក្ការៈបូជាដ៏វិចិត្រ រចនាដោយបុប្ផាផ្កាឈើស្រស់, ផ្កាក្រដាស, ទៀនធូប, គ្រឿងក្រអូប, ទង់ជាតិ ។ ឯគ្រឿងដំកើងលើកដម្កល់ព្រះសារីរិកធាតុនោះ ជាង់ធ្វើព្រះស្តូបរចនាដោយប្រាក់ ជាន់ខាងក្រងរចនាជាកោដ្ឋមាស ហើយជាក់ព្រះធាតុដម្កល់ក្នុងក្រងខ្ចីតូចមួយជាន់ទៀត ។ គ្រឿងដម្កល់ហែ ជាង់ធ្វើជាបុស្សបុកកំពស់ប្រមាណ ៩ ម៉ែត្រ ហើយដំកល់លើរថយន្តសណ្តោងមួយដ៏ប្រដាប់

តាក់តែងដោយកូរក្បាច់រំលេចរចនាដោយផ្កាឈើស្រស់ផ្កាក្រដាសទង់ជាតិគួចៗនឹងគ្រឿងសក្ការៈផ្សេងៗទៀត ។ ក្នុងពេលនោះ គេក្រឡេកមើលពីចម្ងាយទៅ ឃើញក្រុមពុទ្ធបរិស័ទច្រើនមើរដេរជាសកាន់គ្រឿងសក្ការៈបូជា ឆ្ងាស់ពណ៌ចំរុះទីខែៗពីគ្នា គួរឲ្យមានសេចក្តីរីករាយនឹងសេចក្តីជ្រះថ្លាពន់ពេក ។ លុះពេលដឹតហៃព្រះសារីរិកធាតុ, ភិក្ខុសាមណេរវត្តទាំងបួនបានទិមន្តទៅដួចដុំជាង ១០០អង្គ លោករាជការក្នុងក្រុងសៀមរាបគ្រប់តំណែង មានលោករាជការសាលាខេត្ត, ក្រសួងសិក្សាធិការ លោកចាងហ្វាងសាលាសិក្សាធិការ នឹងគ្រូបង្រៀនទាំងអស់ ព្រមទាំងកុមារាកុមារីជាសិស្សានុសិស្សសាលារៀនជាដើម ក៏បានអញ្ជើញទៅជាមង្គលក្នុងពិធីបុណ្យនោះដែរ ។

កាលពុទ្ធបរិស័ទទាំងអំបាលនេះដួចដុំហើយ, មុននឹងហៃ អាចារ្យវត្តនាំគ្នាមស្សការព្រះរតនត្រ័យ, សូរសព្ទធម្មតឹកកងំរំពងឡើង ។ លុះចប់នមស្សការហើយ, មានថ្លែងសុន្ទរកថាដួចមានតទៅនេះ ៖

សូមបង្គំទូលព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ !

សូមជំរាបអស់លោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ !

ថ្ងៃ ១៤ កើតខែវិសាខនេះ ជាថ្ងៃនក្ខត្តឫក្សរបស់អ្នកកាន់ព្រះពុទ្ធសាសនា គឺត្រូវជាថ្ងៃរួបព្រះសម្មាសម្ពុទ្ធជាបរមគ្រូយើងទ្រង់ប្រសូតិ, ទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ នឹងទ្រង់រំលត់ខន្ធបូល

ក្នាន់ព្រៃបរមនិព្វាន ; ថ្ងៃ ១៥ កើតខែវិសាខនេះ ក៏សន្មតថា ដូចជាថ្ងៃ ១៥ កើតខែវិសាខកន្លងកាលនោះ សឹងជាទីនិយមរាប់អានរបស់អ្នកច្រើនជ្រុងជាថ្ងៃមហាអស្ចារ្យនឹងជាមហាមង្គលដ៏ប្រសើរ ព្រោះហេតុនោះ បានជាអ្នកកាន់ព្រះពុទ្ធសាសនាទាំងឡាយគ្រប់ប្រទេស កាលបើដល់ថ្ងៃពេញបូណ៌មីខែវិសាខ ដែលជាថ្ងៃអតិលិខិតកាលដូច្នោះហើយក៏នាំគ្នាចាត់ចែងគ្រឿងសក្ការៈដ៏ផ្ចិតផ្ចង់គ្រប់ដៃ មានប្រទីបផ្កាលាទៀនជូបនឹងកម្រងផ្កាជាដើម យកទៅបូជាគោរពវន្ទាចំពោះព្រះស្ពឹបជាទីបញ្ចុះព្រះសារីរិកធាតុ នឹងខ្ទេសិកចេតិយ គឺព្រះពុទ្ធបដិមាករ ដែលប្រតិស្ឋានទុកជាគ្រឿងសំគាល់នៅក្នុងអារាមផ្សេងៗ ទុទ្ទិសចំពោះព្រះសម្មាសម្ពុទ្ធដែលទ្រង់បរិនិព្វានទៅជាយូរអង្វែងឆ្នាំហើយ, រួចប្រជុំគ្នានមស្សការព្រះរតនត្រ័យ ស្តាប់ព្រះសង្ឃសូត្រស្មូធ្យាយនឹងស្តាប់ព្រះសទ្ធម្មទេសនាជាទីរំលឹកដល់ថ្ងៃដែលព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើង ទ្រង់ប្រសូត, ត្រាស់ដឹង, បរិនិព្វាន តាមសេចក្តីដំនឿនឹងសេចក្តីជ្រះថ្លារបស់ខ្លួនៗ ជាប់ជាប្រពៃណីតៗ មកដល់សព្វថ្ងៃនេះ ។

ក៏ក្នុងថ្ងៃ ១៥ កើតខែវិសាខឆ្នាំនេះ អស់យើងទាំងឡាយជាពុទ្ធបរិស័ទមានគ្រឿងសក្ការៈគ្រប់ដៃ បានមកជួបជុំគ្នាហើយក្នុងទីមហាសន្និបាតនេះ ដើម្បីដង្ហែព្រះសារីរិកធាតុ នៃព្រះសក្យមុនីគោតមបរមគ្រូយើង ដែលទ្រង់បរិនិព្វានទៅអស់កាលជាយូរអង្វែងឆ្នាំហើយ នៅសល់តែព្រះ

កិត្តិគុណនឹងព្រះបុរេមជាតុឲ្យយើងទើពឹងពំនាក់អាស្រ័យយកជានិស្ស័យទៅ
បរលោក ។ អស់លោកអ្នកចាំងឡាយ! ព្រះជាតុដែលដំកល់នៅ
ក្នុងទីចំពោះមុខនេះ ពិតជាព្រះសារីរិកជាតុនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់
ប្រាកដហើយ សូមលោក-អ្នកចាំងឡាយតាំងសតិឲ្យខ្ជាប់ ហើយញ៉ាំង
បសាទសទ្ធា គឺសេចក្តីជ្រះថ្លាដឿជាក់ក្នុងព្រះពុទ្ធគុណ ប្រកបដោយ
ឧស្សាហ្មកុសលចេតនា នមស្សការថ្វាយបង្គំនឹករលឹកដល់គុណព្រះពុទ្ធ
ជានិច្ចកាលទៅ នឹងបានផលានិសង្សដ៏ប្រសើរពុំលែងឡើយ ។

ដោយគុណានុភាពនៃសេចក្តីជ្រះថ្លា ក្នុងព្រះរតនាទិគុណនៃយើង
ជាពុទ្ធបរិស័ទចាំងអស់គ្នានេះ សូមឲ្យយើងខ្ញុំបានប្រកបដោយសេចក្តីសុខ
សេចក្តីចំរើនគ្រប់ប្រការ រៀងរាល់ជាតិកុំបីឃ្លាត ដរាបដល់ព្រះនិព្វាន
ជាបរិយោសានទៅហោង ។

លុះថ្វៃងសុន្ទរកថាចប់ហើយ ពុទ្ធបរិស័ទចាំងឡាយក៏ចាត់ចែងដង្ហែ
ព្រះសារីរិកធាតុតទៅ ។ ឯការហែនុះ បានរៀបចំជាក្បួនដូច្នេះ :

ក្បួនហែព្រះសារីរិកធាតុ

សង្កាត់ ទី ១ — ពួកកុមារកុមារី កាន់ទង់ជាតិ

" " ២ — ភ្លេងពិណពាទ្យ

" " ៣ — ភិក្ខុសាមណេរ

" " ៤ — បុស្សកដំកល់ព្រះសារីរិកធាតុ

សង្ហាត់ ទី ៥ - ពួកស្រីៗក្មេង, ចាស់

" " ៦ - ពួកប្រុសៗក្មេង, ចាស់

លុះរៀបចំជាក្បួនស្រេចហើយ ក៏គោះគងទួងកេរីលេងក្មេងពិណពាទ្យ ដង្ហែព្រះសារីរិកធាតុចេញពីមុខវត្តដំណាក់ទៅតាមវិថីមាត់ស្ទឹងត្រើយខាងកើត ដរាបទៅដល់ស្ពានថ្ម ឆ្លងស្ទឹងទៅត្រើយខាងលិចរហូតទៅដល់គេហដ្ឋានក្រមវង្សាកវ បត់ចូលទៅតាមវិថីស្ទឹងថ្មីពង្គដុំវិញក្រុងសៀមរាប ហើយដង្ហែចូលទៅដម្កល់ទុកលើបុស្សកកង់មុខយ៉ព្រះវិហារវត្តដំណាកវិញ រួចនាំគ្នានមស្សការព្រះរតនត្រ័យម្តងទៀត ។ ចាប់ពីត្រឹមម៉ោង ៧ ល្ងាចនោះតទៅ ពួកពុទ្ធបរិស័ទចាំងភ្លាយក្នុងដំណាក់មានកិក្ខុសាមណេរជាដើម ក៏នាំគ្នាធ្វើវិសាខបូជាតាមទំនៀមដរាបដល់ភ្លឺ ។ ចំណែកខាងពុទ្ធបរិស័ទចាំងភ្លាយវត្តដទៃៗ ចាំងគ្រហស្ថចាំងបព្វជិតលុះផុតកិច្ចនមស្សការហើយ ក៏នាំគ្នាកាន់យកគ្រឿងសក្ការៈគ្រប់ដៃអញ្ជើញនិមន្តទៅកាន់វត្តរៀងៗខ្លួន ធ្វើវិសាខបូជាតាំងពីព្រលប់ដរាបដល់ភ្លឺដែរ ។

ដោយតេជានុភាពនៃកុសលវាសីដ៏ប្រសើរក្នុងពេលនេះ យើងខ្ញុំព្រះអង្គសូមថ្វាយព្រះពរជកុសលចំពោះព្រះបិយមហាក្សត្រ ដែលព្រះអង្គជាអគ្គសាសនូបត្ថម្ភ ព្រមទាំងព្រះពរជវង្សានុវង្ស សូមឲ្យបានទ្រង់ស្ថិតនៅក្នុងសិរីរាជសម្បត្តិជាសុខក្សេមក្សាន្ត ។ សូមជូនកុសលនេះដល់

គណៈរដ្ឋមន្ត្រី ទឹង សូមប្រគេនដល់ព្រះសង្ឃគ្រប់អាវាស មន្ត្រីទឹងបណ្តាជនខ្មែរដែលអាស្រ័យនៅក្នុងគ្រប់ទំណាសីមាកម្ពុជរដ្ឋទាំងមូល សូមឲ្យបានប្រកបដោយសេចក្តីសុខសេចក្តីចំរើនគ្រប់ប្រការសព្វទិវាកត្រកាលកុំបីអាក់ខានឡើយ ។ សូមតេជះព្រះរតនត្រ័យដែលជាទីពឹងពុំនាក់របស់ជាតិខ្មែរ សូមតេជានុភាពនៃពួកទេពតា មានមហិទ្ធិឫទ្ធិនឹងទេពតាមហេស័ក្តិ ដែលទទួលថ្វាក់តំណែងចុះមកកាន់ឆ្នាំថ្មីនេះ ព្រមទាំងទេព្តាដែលស្ថិតនៅក្នុងអន្តរបក្រវាឡទាំងប៉ុន្មាន សូមជួយឲ្យប្រទេសកម្ពុជាជៀសវាងឆ្ងាយពីសេចក្តីទុក្ខវេទនាផ្សេងៗ ឲ្យបានថ្កើងរុងរឿងធាប់ដូចអំពីអតីតកាលឡើងវិញ, សូមជួយបណ្តុះបណ្តាលសតិបញ្ញាដល់បណ្តាជនជាតិខ្មែរ ឲ្យបានកើនចំរើនឡើង ហើយវិតំធ្វើការងារល្អៗដែលជាប្រយោជន៍ដល់ប្រទេសជាតិមាតុភូមិ លះបង់នូវសេចក្តីខ្ជិលច្រអូសពីខន្ធសន្តាន ឲ្យជ្រះស្រឡះតាំងចិត្តសុចរិតប្រព្រឹត្តការងារដ៏វិសេស ឲ្យបានថ្កើងថ្កានធាប់ដូចជាពពួកជននៅក្នុងអាវ្យប្រទេសនានា កុំបីឃ្លៀងឃ្លាតឡើយ ។

ចប់

មានតែអ្នកដែលមិនធ្វើទេទើបមិនខុស ។

យូ — អ៊ិន

ពិធីបុណ្យស្រង់ទឹក

សម្តេចព្រះមហាសុមេធាធិបតី ជួន - ណាត

សង្ឃនាយក គណៈមហានិកាយ វត្តឧណ្ណាលោម ក្រុងភ្នំពេញ

និង

ព្រះទេពសត្ថា សួរ - ហាយ

ក្រមជំនុំព្រះវិន័យបិដក នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

កាលពីថ្ងៃ ៩ - ១០ កើតខែពិសាខឆ្នាំខាលចត្វាស័ក ព. ស. ២៤៩៣ (១០ - ១១ ខែឧសភា គ. ស. ១៩៥០) មានពិធីបុណ្យស្រង់ទឹកព្រះមហាសុមេធាធិបតី ជួន - ណាត សង្ឃនាយកគណៈមហានិកាយ ដោយហេតុបានទទួលសមណស័ក្តិជា "សម្តេចព្រះមហាសុមេធាធិបតី" អំពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់ច្រោសព្រះពរជាន' ដូចមានពិធីបុណ្យខាងក្រោមនេះ ៖

សុំនៅខ្លោងទ្វារវត្ត

ខ្លោងទ្វារកំពែងវត្តនឹងខ្លោងទ្វារកំពែងព្រះវិហារ មានការតាក់តែងសុំដែលរចនាដោយរបៀបល្អដ៏វិចិត្រដូចគ្នាចាំងពីរកន្លែង, សសរសុំសុទ្ធតែស្រោបដោយស្វឹកទន្សែរហូតដល់កំពូល, មានផ្ទាំងតួអក្សរធំៗ ដែលកាត់ក្រដាសពណ៌មាសបិទនៅសុំទ្វារ, កំពូលសុំចាំងពីរនោះមានដោតទង់ជ័យព្រោងព្រាត, ផ្លូវដែលចូលទៅអំពីខ្លោងទ្វារខាងក្រៅរហូតដល់ខ្លោង

ថ្វាយទាន់ក្នុង. សឹងមានសសរទង់ជ័យជាពីរជួរ, សសរទាំងនោះសុទ្ធតែ
ស្រោបដោយស្នឹកដៃក្រឹម ។

ពោងតាំងតុនៅជ្ជាមុខព្រះវិហារ

នៅទីជ្ជាមុខព្រះវិហារនឹងទីជ្ជាក្នុងកំពែងព្រះវិហារ ជាទីដ៏ដេរដាស
ដោយពោងតាំងតុ:រៀបចំសក្ការបូជា ថ្វាយព្រះរតនត្រ័យ នឹងបុស្បក
បាំងធំតូច ដែលប្រដាប់ដោយគ្រឿងតាំងដ៏វិចិត្រផ្សេងៗ, មានអំពូលភ្លើង
អគ្គិសនីជាដើម គ្រប់ពោងតាំងតុទាំង ៨ នឹងបុស្បកបាំងធំតូចទាំងអស់ ។

ឯពោងតាំងតុទាំង ៨ នោះ តាំងនៅអមផ្លូវចំមុខព្រះវិហារ គឺខាង
ត្បូងផ្លូវមានពោង ៤, ខាងជើងផ្លូវមានពោង ៤ ប្រឈមមុខរកគ្នា ព្រម
ទាំងបាំ ១ ខ្នង ជារបស់លោកអ្នកឧកញ៉ាសិរិន្ទរបវរសេក្តីចៅហ្វាយក្រុង
កំពេញ (សាន-យុន) ។ ពោងទាំង ៨ នោះជាពោងដែលពុទ្ធបរិស័ទ្យ
ទាំងបព្វជិតទាំងគហស្ថ មានចិត្តជ្រះថ្លាមកសង់តែរៀងៗខ្លួន តាមតំរូ
ផែនទីដែលគណៈកម្មការបុណ្យបានសំដែងទីឲ្យ ។ ចំហំនឹងកំពស់នៃ
ពោងទាំង ៨ នោះប៉ុនៗគ្នា ដូចគ្នាទាំងអស់គឺ ទទឹងនឹងបណ្តោយពោង
នីមួយៗប្រវែង ៣ ម៉ែត្រ ៥០ កំពស់ ៤ ម៉ែត្រ ។ បណ្តាពោងតាំងតុ
ទាំង ៨ នោះ វត្តខ្ញុំណាលោមមានក្រុម ៨ ទទួលរៀបពោងតាំងតុ ៤ ដោយ
ការរួមរួមចូលគ្នា គឺមេក្រុមពីរៗ ទទួលចាត់ចែងរៀបចំពោងតាំងតុ ១ ។
ឯពោងតាំងតុ ៤ ទៀត ជារបស់វត្តទាំង ៩ ក្នុងក្រុងកំពេញ គឺវត្តលង្កា,

វត្តមហាមន្ត្រី, វត្តកែវព្រះភ្លើង, វត្តព្រះពុទ្ធមានបុណ្យ, វត្តពិតទួរធ្យី, វត្តរតនារាម វត្តសារវ័ន, វត្តកោះ នឹង វត្តសំពៅមាស ។

ភេនតាំងតុតាំង ៨ ខ្នងនឹងបាវ ១ ខ្នងនោះ មានការរៀបចំដោយគ្រឿងលំអស្រស់ស្រដៀងៗគ្នា គួរឲ្យអ្នកផងជែះថ្លាជាប់ចិត្តចង់មើលហើយមើលទៀត ។ ភេនតាំងតុនីមួយៗ សុទ្ធតែដេរដាសភៅដោយកម្រងផ្កាឈើ - ស្លឹកដៃក្រឹមនឹងស្លឹកទន្យែ ។ ខាងក្នុងភេនតាំងនោះសុទ្ធតែពាសដោយសំពត់ពណ៌លឿងខ្លះ, សខ្លះ, ខៀវខ្លះព័ទ្ធជុំវិញ ។ នៅលើតុក្នុងភេននោះ សឹងមានវត្ថុយ៉ាងឆើតឆាយជាច្រើនមុខ មានព្រះពុទ្ធរូបចម្លាក់ខ្ទឹមឈើនឹងផើងផ្កាជាដើម ។ ក្នុងភេននោះមានតែងរំលេចពន្លឺរស្មីភ្លើង ៣-៤ ពណ៌ ដែលលោកចៅហ្វាយក្រុងបានអញ្ជើញមកមើលចាត់ការឲ្យដាក់ភ្លើងអគ្គិសនី ព្រមទាំងចេញថ្លៃភ្លើងឲ្យប្រើក្នុងឧកាសបុណ្យនេះដរាបដល់ថ្ងៃបង្ហើយ ។ ក្នុងវេលាពេលទាំង ២ ក៏មានរស្មីភ្លើងពណ៌ស ក្រហម លឿង ខៀវ ភ្ជាប់ពន្លឺចញ្ចាចចោលរស្មីដាលច្រាត់ប្រទាក់រកគ្នា, នៅខ្ញងទ្វារភេនមានផែនក្តារអក្សរតួធំៗ ដែលចំពេលជាសពណ៌មាសបញ្ចាំងស្រមោលភ្លើងភ្លឺអស្ចារ្យណ្ហមើលជាទីបំផុត ។ ឯអក្សរនៅផែនក្តារនោះជាសេចក្តីសូមប្រគេនពរដល់សម្តេចព្រះមហាសុមេធាធិបតី ។

ពិធីរៀបបុស្បកខាងក្នុងកំពែងព្រះវិហារ

ក្នុងកំពែងវិហារខាងក្នុង ត្រង់ទីលានខាងកើតវិហារ មានបុស្បក ១ សម្រាប់សម្តេចស្រង់ទឹក ដែលពួកជាងអ្នកថ្នឹកការបានរចនាកសាងឡើង

ដំណួអស្ចារ្យ, មានដើងក្រោស ៣ ជាន់ទ្រគួបុស្បក, មានកំពស់តាំងពីដើង
កោសរហូតដល់កំពូលបុស្បកទាំងអស់ ៧ម៉ែត្រ, មានជណ្តើរនឹងបង្កាន់ដៃ
គ្រប់ទាំង ៤ ជ្រុង, មានធ្នែរតួគ្រប់ជ្រុងទាំង ៤ ។ គួបុស្បកនោះក៏មាន
សន្ទិយាសំយុងចុះមកគ្រប់ទាំង ៤ ជ្រុង ។ ឯផ្ទាំងសន្ទិយានោះសុទ្ធស្នឹង
តែចិត្រលេចដោយផ្កាចន្ទន៍ពយផ្កាយ ដែលរចនាអំពីត្រជាសពណ៌មាស ។

បារាំ ៣ ខ្នងខាងក្នុងកំពែងព្រះវិហារ

ខាងក្នងកំពែង នៅខាងស្តាំវិហារ មានបារាំធំ ១ ខ្នងសម្រាប់ជាព្រះ
ពន្ធាថ្វាយព្រះករុណាជាម្ចាស់ជីវិតនឹងលោកកុម្មិស្សែរព្រមទាំងអស់លោក
គណៈរដ្ឋមន្ត្រីដែលទ្រង់ស្តេច - អញ្ជើញមកប្រថាប់ - អង្គុយជាអធិបតីក្នុង
ពិធីបុណ្យស្រង់ទឹកនេះ ។ នៅខាងឆ្វេងវិហារ មានបារាំធំ ១ ខ្នងទៀត
សម្រាប់ប្រគេនព្រះសង្ឃជាគណៈមេគណ អនុគណ នឹងលោកចៅ-
អធិការ ។ បារាំធំទាំងពីរខ្នងនេះមានរបៀបរៀបចំដូចៗគ្នាគឺ មានផ្កា
កម្រងវែងៗ ចងខ្វែងកាត់ប្រជាក់គ្នាដល់ទីបំផុតបារាំ ព្រមទាំងផ្កាកម្រងវែង
មួលក៏មាន, ជា ៣ ជ្រុងក៏មាន, ជាផ្ការំយោលក៏មាន ដែលចងព្យួរសំយុង
ចុះជេរជាសក្នងបារាំទាំង ២ ខ្នងនោះ ។ សសរបារាំទាំងអស់សុទ្ធតែស្រោប
ដោយស្លឹកដៃនឹងស្លឹកទន្សែ, មានទង់ជ័យបីៗចោះបំពាក់ភ្ជាប់គ្រប់សសរ
បារាំ ព្រមទាំងផើងផ្កា - ផើងកូនឈើក៏រៀបចំឲ្យត្រូវគ្នាជាគូៗរៀងរាយ
តាមសសរបារាំជួរមុខ ។ ក្នងបារាំនោះក៏សុទ្ធតែគ្រាលព្រំខ្សែវែងៗ ទាំង
អស់ ។ នៅផ្លូវដង្ហែនព្រះវិហារចំពីខាងកើត មានបារាំតូច ១ ខ្នង គេ

រៀបតុបតែងគ្រឿងសក្ការបូជាដ៏វិចិត្រ គួរជាទីជះថ្លាដូចកោងតាំងនៅជាក្រៅកំពែងព្រះវិហារនោះដែរ ។ បាវាំតូចនេះក៏មានតួអក្សរធំៗដែលយកក្រជាសពណ៌មាសកាត់ជាតួអក្សរបិទនៅផ្ទាំងជាក់អំពីខាងមុខ ប្រកាសដំណឹងថា "បុណ្យសម្ពោធសមណសក្តិនឹងបុណ្យចំរើនព្រះជន្មសម្តេច" ។

ហេតុជ័អស្ចារ្យនៅថ្ងៃបួលបុណ្យ

នៅថ្ងៃពុធ ៩ កោចខែពិសាខជាថ្ងៃបួលបុណ្យនោះ ក្នុងវេលាព្រឹមានពន្លឺភ្លើងចាំញ្ជែងចិញ្ចាច តាំងពីពេលព្រលប់ដរាបដល់ពេលអរុណរះ ។ ក្នុងថ្ងៃនោះ មានភ្លៀងបង្អុរចុះមកយ៉ាងច្រើន តាំងពីម៉ោង ៦ ព្រលប់ដល់ម៉ោង ៨ កន្លះទើបរាំង, តែភ្លៀងនោះគួរឲ្យនឹកអស្ចារ្យណាស់ គឺបង្អុរមកដោយស្ងប់ស្ងៀមឥតមានខ្យល់សោះ, ឯកោងតាំងតុនឹងគ្រឿងតាំងទាំងអស់ឥតមានជាប់ជាប្រឡូកនឹងភក់ដីដោយភ្លៀងនោះឡើយ ។ ក្នុងព្រឹនោះសូម្បីមានភ្លៀងបង្អុរធ្លាក់មកជាខុបស័ក្តិប៉ុណ្ណោះហើយក៏ដោយ, ក៏នៅតែមានពុទ្ធបរិស័ទ្ធទាំងបព្វជិតទាំងគហស្ថ ចូលមកមើរដោរជាសចង្អៀតណែនណាន់តាន់តាប់ ទាំងខាងក្នុងកំពែងព្រះវិហារ នឹងខាងក្រៅព្រះវិហារ ។

ថ្ងៃទី ១ គឺថ្ងៃពុធ ៩ កោចខែពិសាខ

ម៉ោង ១៨ គឺម៉ោង ៦ រសៀល – គេរៀបគ្រឿងសក្ការបូជាក្នុងព្រះវិហារ, អុជប្រទីបជ្វាលាខាងក្នុងព្រះវិហារនឹងខាងក្រៅព្រះវិហារ ។

ម៉ោង ២០ គឺម៉ោង ៨ យប់ – ពុទ្ធបរិស័ទ្ធជួបជុំគ្នានមស្សការ

ព្រះរតនត្រ័យ, និមន្តព្រះសង្ឃ ๖๙ អង្គ សុទ្ធតែព្រះរាជាគណៈ មេគណ អនុគណ ទទឹងចៅអធិការ ចំរើនព្រះបរិត្តកង ព្រះវិហារដើម្បីបែគេនពរ សិរីសួស្តីដល់សម្តេចព្រះមហាសុមេធាធិបតី ។ លុះចប់កិច្ចចំរើនព្រះបរិត្ត ហើយ ព្រះមុនីកោសល ចៅអធិការវត្តពោធិ៍រាល មេគណខែត្តបាត់ដំបង តំណាងព្រះសង្ឃ ๖๙ អង្គផ្តើមថ្វែងសេចក្តីបែគេនពរដោយសេចក្តីគ្រែក អរដ៏ក្រៃលែងចំពោះសម្តេចដែលទើបបានឡើងសមណស័ក្តិខ្ពស់បំផុត ។ បន្ទាប់អំពីនេះ, សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា ចៅអធិការវត្តលង្កា ប្រកាសសេចក្តីចំពោះព្រះសង្ឃទាំងអស់ថា "ខ្ញុំព្រះករុណា មានសេចក្តី គ្រែកអរជាទីបំផុត ចំពោះព្រះមហាសុមេធាធិបតី ដែលទើបបានឡើង ឋានៈជាសម្តេចនេះ គួរជាទីពេញចិត្តនៃពុទ្ធបរិស័ទ្យទាំងអស់ ដោយ សម្តេចអង្គនេះជាព្រះថេរៈមានប្រាជ្ញាវាងវៃ ប្រកបដោយសមត្ថភាពនឹង ចរិយាធម៌ដ៏ប្រសើរ ដែលគួរព្រះសង្ឃយកតម្រាប់តាមបានដោយពិត" ។ រួចសម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា ប្រគេនពរស័ព្ទសាធុការចំពោះ សម្តេចដូចព្រះមុនីកោសលដែរ ។

លុះដល់ទីបំផុតថេរវាចានៃព្រះមុនីកោសល ទទឹង សម្តេចព្រះធម្ម-លិខិត ឧត្តមប្រឹក្សាហើយ, សម្តេចព្រះមហាសុមេធាធិបតី ទទួលថ្វែងតប ថេរវាចាវិញថា "ខ្ញុំព្រះករុណា ដែលបានស្តាប់ថេរវាចាអម្បាញ់មិញនេះ មានសេចក្តីគ្រែកអរសាទរដ៏មហិមាចំពោះសម្តេចព្រះធម្មលិខិត ព្រមទាំង ព្រះសង្ឃរាជាគណៈ មេគណ អនុគណ ទទឹងចៅអធិការទាំងអស់ ដែល

បាននិមន្តមកដួបជុំគ្នាពិធីបុណ្យនេះ ដើម្បីសំដែងមិត្តភាពចំពោះពុទ្ធបរិ-
សទ្យ ឲ្យមានសេចក្តីសាមគ្គីរសវែងឆ្ងាយតទៅ" ។

បន្ទាប់អំពីនោះ មានអ្នកឆ្លុះកុនទៅខាងដើមព្រៃវិហារតាំងពីម៉ោង
១០ រហូតដល់ម៉ោង ២ ទើបឈប់ ។

ថ្ងៃទី ២ គឺថ្ងៃព្រហស្បតិ៍ ១០រោចខែពិសាខ

ម៉ោង ៧ នឹង ៣០ នាទីពេលព្រឹក - សម្តេចព្រះមហាសុមេធាធិបតី
នឹងព្រះសង្ឃរាជគណៈហានានុក្រម ព្រមទាំងមន្ត្រីសង្ឃជាមេគណៈ
អនុគណក្នុងព្រះពុទ្ធអាណាចក្រ មួយអន្លើនឹងពួកពុទ្ធបរិសទ្យ រង់ចាំ
ទទួលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នឹងលោកកុម្មុំស៊ីរីសោភារ-
ណរដ្ឋបាល នៅទីបាំទាងមុខព្រះវិហារ ។

ម៉ោង ៨ - ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នឹងលោកកុម្មុំស៊ីរី
ស្តេចមក - អញ្ជើញមកដល់មុខព្រះវិហារ មានទាហានក្រមរក្សាព្រះអង្គ
នឹងក្រមក្មេងវៃតព្រះពុទ្ធទ្យចាំទទួលជាព្រះពុទ្ធកិត្តិយស រួចហើយ
ស្តេចមក - អញ្ជើញមកប្រថាប់នៅទីព្រះពន្លាខាងមុខព្រះវិហារ ដោយ
មានគណៈរដ្ឋមន្ត្រីនឹងក្រមប្រឹក្សាព្រះពុទ្ធអាណាចក្ររង់ចាំក្រាបថ្វាយបង្គំ
គាល់ក្នុងទីនោះផង ។

ម៉ោង ៨ នឹង ១០ នាទី - ព្រះពោធិវង្ស ហួត - តាត ចាងហ្វាង
សាលាចាលីជានន្ទសូត្រសុន្ទរកថាថ្វាយសេចក្តីអំពីប្រវត្តិរបស់សម្តេច

ព្រះមហាសុមេធាធិបតីសង្ឃនាយក ចំពោះព្រះករុណាជាម្ចាស់ជីវិត (សុន្ទរកថានេះមាននៅខាងចុង) ។

ម៉ោង ៨ ទឹង ៣០ នាទី – សម្តេចឡើងគង់លើបុស្សកបែរព្រះភ័ក្ត្រទៅទិសបូព៌ា ព្រះសង្ឃរាជគណៈ ឋានានុក្រមទឹងមន្ត្រីសង្ឃ មេគណអនុគណគ្រប់វត្ត សូត្រជយន្តោ ប្រគេនជយមង្គលចំពោះសម្តេចព្រះមហាសុមេធាធិបតី ។

ព្រះករុណាជាម្ចាស់ជីវិតនឹងលោកកុម្មិស្សៃរ ស្តេច-អញ្ជើញទៅលើបុស្សក ប្រោះសុគន្ធភ៉ាវលើព្រះហស្តខាងស្តាំនៃសម្តេចព្រះមហាសុមេធាធិបតី រួចស្តេចចុះ អញ្ជើញចុះមកវិញ ប្រថាប់នៅព្រះពន្លាដដែល ។

លំដាប់ពីនោះ សម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្តិនឹងសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សាគណៈមហានិកាយ និមន្តឡើងទៅលើបុស្សក ប្រោះសុគន្ធភ៉ាវលើព្រះហស្តស្តាំនៃសម្តេចព្រះមហាសុមេធាធិបតី រួចនិមន្តចុះមកគង់កន្លែងដដែលវិញ ។

សម្តេចព្រះមហាសុមេធាធិបតី ក្រោយដែលបានទទួលសុគន្ធភ៉ាវរួចហើយ និមន្តចុះពីបុស្សកមកទទួលព្រះពរព្រះករុណាជាម្ចាស់ជីវិតនឹងលោកកុម្មិស្សៃរ ។ បន្ទាប់មក សម្តេចព្រះមហាសុមេធាធិបតីថ្វែងសុន្ទរកថាថ្វាយព្រះពរតបព្រះករុណាជាម្ចាស់ជីវិតនឹងលោកកុម្មិស្សៃរ (សុន្ទរកថានេះមាននៅខាងចុង) ។

ម៉ោង ៩ នឹង ៤០ នាទី - ព្រះករុណាជាម្ចាស់ជីវិតនឹងលោកកុម្មុំស្បែរ នៃសាធារណរដ្ឋប្បាំង ស្តេចត្រឡប់ - អញ្ជើញត្រឡប់ទៅវិញ ។

ម៉ោង ៩ នឹង ៤៥ នាទី - ពុទ្ធបរិស័ទ្ធទាំងបព្វជិតទាំងគ្រហស្ថ និមន្តសម្តេចព្រះមហាសុមេធាធិបតី ឲ្យគង់លើបុស្សក ដើម្បីស្រង់ព្រះសុគន្ធវារីម្តងទៀត ។ លុះស្រង់ស្រេចហើយ និមន្តចុះមកវិញ ។ ក្នុងខណៈនោះ ព្រះទេពសត្ថា សូរ - ហាយ ក្រមដំទុំព្រះវិន័យបិដក សូត្រសុន្ទរកថាជាតំណាងព្រះសង្ឃរាជគណៈ មេគណ អនុគណនឹងថៅអធិការទាំងអស់ ប្រគេនពរចំពោះសម្តេចដោយសេចក្តីគ្រែកអរចំពោះកិត្តិយសនៃសម្តេច (សុន្ទរកថានេះមាននៅខាងចុង) ។

បន្ទាប់ពីនោះមក សម្តេចព្រះមហាសុមេធាធិបតី ប្រទានថ្លែងតបថា "ខ្ញុំខ្ញុំព្រះករុណាកាលបើបានស្តាប់សុន្ទរកថាអម្បាញ់មិញនេះហើយ ខ្ញុំមានសេចក្តីសោមនស្សដែរ តែខ្ញុំមិនឡើងបញ្ជោរដោយក្តេចខ្លួនតាមសុន្ទរកថាដែលសរសើរអំពីគុណសម្បត្តិនោះទេ" ។ រួចសម្តេចមានថេរវាចាសំណេះសំណាលចំពោះព្រះសង្ឃនឹងគ្រហស្ថ ទាំងប្រគេនពរជូនពរឲ្យកើតសេចក្តីក្រៃពាយក្នុងការបុណ្យនេះដោយសង្ខេប ។ ។

ម៉ោង ១១ នឹង ២០ នាទី - ប្រគេនចង្ហាន់ដល់ព្រះសង្ឃ ៦៩ អង្គដែលនិមន្តចំរើនព្រះបរិត្តត្រមទាំងមន្ត្រីសង្ឃ រាជគណៈ មេគណ អនុគណនឹងថៅអធិការ ដែលនិមន្តមកអំពីគ្រប់ខេត្តក្នុងព្រះរាជអាណាចក្រ ។

ម៉ោង ១៩ នឹង ៣០ នាទី – ពួកពុទ្ធបរិស័ទនាំគ្នានមស្សការចំពោះព្រះតេនត្រ័យ រួចហើយនិមន្តសម្តេចព្រះមហាសុមេធាធិបតីទេសនា ។ សម្តេចបានព្រមទទួលនិមន្តដោយសេចក្តីអនុគ្រោះចំពោះពុទ្ធបរិស័ទ ។ ធម្មទេសនាក្នុងពេលនោះជាកំរិតទុតិយាសនសូត្រ បំពង់សំឡេងលាន់ឮគ្រាន់ក្រអោរ ។

ធម្មទេសនានៃសម្តេចកើតពេលនោះ កំពុងកេះក្បាះក្បាយអស្ចារ្យចម្លែកណាស់ជាងពីកាលមុនៗមក ។ ពុទ្ធបរិស័ទគាំងបព្វជិតគាំងគ្រហស្ថ សឹងតែលាន់មាត់សរសើរគ្រប់ៗគ្នា ។ អ្នកខ្លះពោលថា “ធម្មទេសនានេះទើបសមជាធម្មទេសនារបស់សម្តេចមែន” ។ អ្នកខ្លះសរសើរថា “ទេសនានេះពីពេះអ្វីម៉្លេះទេ”! លុះចប់ធម្មទេសនាហើយ អ្នកខ្លះពោលដោយទឹកស្តាយថា “ធម្មទេសនានេះ បើកុំអាលបញ្ចប់ សូមឱ្យទេស្មមួយម៉ោងឬពីរម៉ោងទៀតក៏មិនធុញគ្រាន់” ។

ពួកពុទ្ធបរិស័ទគាំងអស់ដែលមកធ្វើបុណ្យពិធីស្រង់ទឹកនេះ ច្រើនតែលាន់មាត់សរសើរថា “ពិធីបុណ្យនេះជាបុណ្យធំថ្កុំថ្កើងរុងរឿងដោយមានរបៀបគ្រប់យ៉ាងឥតខ្ចោះត្រង់ណា ជាទីជ្រះថ្លារីករាយចិត្តដ៏កៃលែង” ។

លុះព្រឹកឡើងថ្ងៃ ១១ កេះ ៦ ពិសាខ ម៉ោង ៧ នឹង ៣០ នាទី, ពុទ្ធបរិស័ទ្យចាត់ចែងប្រគេនយាគូដល់ព្រះសង្ឃ ជាការបង្ហើយបុណ្យក្នុងវេលានោះ ។

(មានត)

បញ្ជីរាយនាមចៅអធិការដែលតាំងថ្មី

របស់

ក្រសួងធម្មការ

(តមក)

សញ្ញាប័ត្រលេខ ៦៣៤ ចុះថ្ងៃពុធ ១ កើតខែចេត្រឆ្នាំជូតសំរឹទ្ធិស័ក ព.ស. ២៤៩១ តាំងលោកគ្រូ តុក-សាន់ នាមធាយា សុធម្មប្បញ្ញា កើតឆ្នាំមមី អាយុ ៣១ វស្សា ១១ ជាចៅអធិការវត្តគ្រាំង ឃុំព្រះធាតុ ស្រុកកំពង់ត្របែក ខែត្រស្វាយរៀង ។

សញ្ញាប័ត្រលេខ ៦៣៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យស-សូរ នាមធាយា សង្ឃរក្ខិត កើតឆ្នាំឆ្លូវ អាយុ ៤៨ វស្សា ២៨ ជាគ្រូសូត្រស្តាំ វត្តធម្មក្ខេត្តិ ឃុំគោកគង់ ស្រុកកញ្ជ្រៀច ខែត្រស្វាយរៀង ។

សញ្ញាប័ត្រ លេខ ៦៣៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន-ប៊ុប នាមធាយា ឥន្ទូជោត កើតឆ្នាំថោះ អាយុ ៤៦ វស្សា ២៥ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខែត្រដដែល ។

សញ្ញាប័ត្រលេខ ៦៣៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គួច-គង់ នាមធាយា ព្រហ្មប្បញ្ញា កើតឆ្នាំថោះ អាយុ ៣៤ វស្សា ១០ ជាចៅអធិការវត្តកំពង់សំរឹទ្ធិ ឃុំមៀន ស្រុកព្រៃឈរ ខែត្រកំពង់ចាម ។

សញ្ញាប័ត្រលេខ ៦៣៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខែក - ឈិន នាមនាយា ឥន្ទ្រេប្បញ្ញា កើតឆ្នាំមមី អាយុ ៣១ វស្សា ១១ ជាគ្រូសូត្រធ្លេង វត្តត្រពាំងព្រះ ឃុំត្រពាំងព្រះ ស្រុកកៃពឈរ ខែត្រកំពង់ចាម ។

សញ្ញាប័ត្រលេខ ៦៣៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម - គី នាមនាយាធម្មជោត កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជាចៅអធិការវត្តព្រះបន្ទរឆ្លី ឃុំក្រាំងស្នា ស្រុកទឹកផុះ ខែត្រកំពង់ឆ្នាំង ។

សញ្ញាប័ត្រលេខ ៦៤២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហង់ - ប៉ែង នាមនាយា វិសុទ្ធិប្បញ្ញា កើតឆ្នាំ គ.ស. ១៩០៩ អាយុ ៦៤ វស្សា ៦២ ជាចៅអធិការវត្តសិរីសុន្ទរវង្សារាម ឃុំក្រចេះ ស្រុកក្រចេះ ខែត្រក្រចេះ ។

សញ្ញាប័ត្រលេខ ៦៤៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ហ៊ុន - ញឹម នាមនាយា ឥន្ទ្រប្បញ្ញា កើតឆ្នាំជូត អាយុ ៣៨ វស្សា ១៧ ជាចៅអធិការនៅវត្តក្តឿងពយ ឃុំក្តឿងពយ ស្រុកកញ្ជ្រៀច ខែត្រវិញវែង។

សញ្ញាប័ត្រ លេខ ៦៤៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ជេត - យឹម នាមនាយា សុវណ្ណត្ថេរ កើតឆ្នាំ ព.ស. ២៤៤៩ អាយុ ៤៣ វស្សា ២២ ជាចៅអធិការវត្តចាកយណ៍ ឃុំចារយណ៍ ស្រុកកៃពឈរ ខែត្រកំពង់ចាម ។

សញ្ញាប័ត្រលេខ ៦៤៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មួយ - ចិល នាមឆាយា ធម្មត្ថេរ កើតឆ្នាំ ព. ស. ២៤៦២ អាយុ ៣០ វស្សា ៧ ជាគ្រូសូត្រស្តាំនៅវត្តស្រែងស្រឡៅ ឃុំបឹងណាយ ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៤៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុង - សាយ នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំច អាយុ ២៨ វស្សា ៧ ជាចៅអធិការ នៅវត្តស្តៅ ឃុំព្រៃកណ្តៀង ស្រុកព្រៃវែង ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៦៥០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ផូរ - កុយ នាមឆាយា ចន្ទត្ថេរ កើតឆ្នាំរោង អាយុ ៥៨ វស្សា ៣៥ ជាចៅអធិការនៅវត្តព្រៃកន្ទោង ឃុំព្រៃកន្ទោង ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៥១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាន់ - ចិន នាមឆាយា បញ្ញាជោត កើតឆ្នាំខាលអាយុ ៤៨ វស្សា ២៧ ជាគ្រូសូត្រស្តាំ នៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៦៥២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន - ឌុល នាមឆាយា បញ្ញាកេសរ កើតឆ្នាំរកា អាយុ ២៩ វស្សា ៩ ជាចៅអធិការនៅវត្តកអណ្តើក ឃុំច្រាសាទ ស្រុកកំពង់ត្រែក ខេត្តព្រៃវែង ។

(មានត)